ទីស្តីការគណៈរដ្ឋមន្ត្រី
គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់

# ក្របខ័ណ្ឌទស្សនាទាន
# ស្តីពី
# ការកសាងបូរណភាពនៃប្រព័ន្ធច្បាប់កម្ពុជា

មេសា ២០២៦

# មាតិកា


**ខ្លឹមសារសង្ខេប** ........ ៨

**១. សាវតា** ........ ១១

**១.១. បរិបទសកល** ........ ១១

១.១.១ ច្បាប់អន្តរជាតិ ........ ១២

១.១.២ សមាហរណកម្មអន្តរជាតិ ........ ១៣

១.១.៣ ឧត្តមានុវត្តន៍អន្តរជាតិ ........ ១៥

១.១.៤ សេចក្តីត្រូវការរបស់វិនិយោគិនបរទេស និងដៃគូពាណិជ្ជកម្មអន្តរជាតិ ........ ១៧

១.១.៥ សេចក្តីត្រូវការរបស់ជនបរទេស ........ ២០

១.១.៦ យន្តការវាយតម្លៃអភិបាលកិច្ចអន្តរជាតិ ........ ២១

១.១.៧ បច្ចេកវិទ្យា ........ ២៤

**១.២. បរិបទរបស់កម្ពុជា** ........ ២៦

១.២.១ វេជ្ជធម្មនុញ្ញ ........ ២៨

១.២.២ ចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០ ........ ២៨

១.២.៣ កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា សម្រាប់ការ កសាង និង ការការពារមាតុភូមិ ឆ្នាំ២០២៣-២០២៨ ........ ២៩

១.២.៤ យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ........ ៣០

១.២.៥ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល នីតិកាលទី២ នៃរដ្ឋសភា ........ ៣១

១.២.៦ ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល ........ ៣៣

១.២.៧ ក្របខ័ណ្ឌបទដ្ឋានគតិយុត្ត និងស្ថាប័នសម្រាប់ការរៀបចំ និងកែទម្រង់ច្បាប់៣៤
១.២.៨ ស្ថានភាពសេដ្ឋកិច្ច សង្គម និងស្ថាប័ន ..................................................៣៥
១.២.៩ ការអប់រំ និងធនធានមនុស្ស ..................................................................៣៦
១.២.១០ ការចាកចេញពីប្រទេសអភិវឌ្ឍតិចតួចនៅឆ្នាំ ២០២៩ ....................................៣៧
១.២.១១ ការរំពឹងទុករបស់ប្រជាពលរដ្ឋក្នុងបរិបទសន្តិភាព ........................................៣៨
២. **សន្និដ្ឋានភាព** ....................................................................................៣៩
២.១. **បញ្ហាប្រឈម**........................................................................................៣៩
២.១.១ សង្គតិភាពនៃច្បាប់ជាធរមាន.......................................................................៣៩
២.១.២ សង្គតិភាពនៃមធ្យោបាយតាក់តែង...................................................................៣៩
២.១.៣ គម្លាតរវាងគោលនយោបាយ ច្បាប់ និងបទប្បញ្ញត្តិអនុវត្ត ..................................៤០
២.១.៤ ភាពមិនច្បាស់លាស់នៃបទដ្ឋាន និងការបកស្រាយច្បាប់ .....................................៤០
២.១.៥ ប្រសិទ្ធភាពនៃការអនុវត្ត និងយន្តការតាមដានវាយតម្លៃ ....................................៤០
២.១.៦ រចនាសម្ព័ន្ធស្ថាប័ន និងការបែងចែកតួនាទីភារកិច្ច ..........................................៤១
២.១.៧ ពិនិត្យានុភាវូបនីយកម្មគតិយុត្ត និងឌីជីថលូបនីយកម្ម........................................៤១
២.១.៨ សមត្ថភាពធនធានមនុស្ស កិច្ចសហការ និងឧបករណ៍អភិបាលកិច្ចគាំទ្រ ... ៤១
២.១.៩ ក្របខ័ណ្ឌសមត្ថភាពវិជ្ជាជីវៈផ្នែកច្បាប់.............................................................៤២
២.១.១០ និម្មាបនកម្មប្រព័ន្ធច្បាប់..............................................................................៤២
២.២. **តម្រូវការនៃក្របខ័ណ្ឌប្រព័ន្ធច្បាប់**...........................................................៤២
២.២.១ ជាមូលដ្ឋានវាយតម្លៃបូរណភាពនិងសង្គតិភាពនៃប្រព័ន្ធច្បាប់...............................៤២
២.២.២ ជាត្រីវិស័យនិងផែនទីបង្ហាញផ្លូវរួមអំពីប្រព័ន្ធច្បាប់ ............................................៤៣

២.២.៣ មូលដ្ឋានសម្រាប់កែទម្រង់ ....................................................... ៤៣
២.២.៤ បញ្ចៀសវិវាទគតិយុត្តរវាងស្ថាប័ន ................................................ ៤៣
២.២.៥ ជម្រុញការអភិវឌ្ឍន៍ជាតិ ............................................................ ៤៣
៣. **ទស្សនាទានគ្រឹះនៃក្របខ័ណ្ឌ** ........................................................ ៤៤
៣.១. **និយមន័យនៃប្រព័ន្ធច្បាប់** ......................................................... ៤៤
៣.២. **ទ្រឹស្តីនៃប្រព័ន្ធទូទៅ** ( General System Theory ) ................................ ៤៥
៤. **ប្រវត្តិនៃប្រព័ន្ធច្បាប់** .............................................................. ៤៧
៤.១. **កំណើតនៃប្រព័ន្ធច្បាប់ក្នុងសង្គមមនុស្ស** ............................................ ៤៧
៤.១.១ ការប្រែប្រួលពីទម្លាប់ទៅជាច្បាប់សរសេរ ........................................... ៤៧
៤.១.២ ការចងក្រងជាក្រម និងការរៀបចំច្បាប់ជាប្រព័ន្ធ ..................................... ៤៧
៤.១.៣ ប្រភពច្បាប់សរសេរ និងប្រភពច្បាប់អត់សរសេរ ....................................... ៤៨
៤.១.៤ សារៈសំខាន់នៃប្រវត្តិនៃប្រព័ន្ធច្បាប់ ................................................ ៤៨
៤.២. **ប្រវត្តិនៃប្រព័ន្ធច្បាប់សកល** ........................................................ ៤៨
៤.២.១ ទិដ្ឋភាពទូទៅនៃប្រពៃណីច្បាប់សកល ................................................ ៤៨
៤.២.២ ប្រព័ន្ធច្បាប់ស៊ីវិល និងឫសគល់ច្បាប់រ៉ូម៉ាំង ........................................... ៤៩
៤.២.៣ ប្រព័ន្ធច្បាប់អង់គ្លូសាក់សុង និងតួនាទីរបស់យុត្តិសាស្ត្រ .................................. ៤៩
៤.២.៤ ប្រព័ន្ធច្បាប់ហិណ្ឌូ និងគោលគំនិត Dharma ........................................ ៥០
៤.២.៥ ទស្សនវិជ្ជាចិនបុរាណ និងការយល់អំពីច្បាប់ ........................................... ៥០
៤.២.៦ ពុទ្ធសាសនា និងមូលដ្ឋាននៃច្បាប់សង្គម ............................................. ៥១
៤.២.៧ សេចក្តីសន្និដ្ឋានអំពីប្រព័ន្ធច្បាប់សកល ............................................... ៥១

៤.៣. ប្រវត្តិនៃប្រព័ន្ធច្បាប់កម្ពុជា ........ ៥១

៤.៣.១ ទិដ្ឋភាពទូទៅនៃការវិវត្តនៃប្រព័ន្ធច្បាប់កម្ពុជា ........ ៥១

៤.៣.២ សម័យបុរេប្រវត្តិ និងច្បាប់ប្រពៃណីខ្មែរ ........ ៥២

៤.៣.៣ សម័យហ្វូណន និងការទទួលឥទ្ធិពលឥណ្ឌា ........ ៥២

៤.៣.៤ សម័យចេនឡា និងការរៀបចំរដ្ឋបាលនីតិ ........ ៥២

៤.៣.៥ សម័យអង្គរ និងការបញ្ចូលគ្នារវាងធម៌ ទម្លាប់ និងព្រះរាជបញ្ញា ........ ៥៣

៤.៣.៦ សម័យក្រោយអង្គរ និងការរៀបរៀងក្រមខ្មែរ ........ ៥៣

៤.៣.៧ សម័យអាណានិគមបារាំង និងការបំលែងទៅប្រព័ន្ធច្បាប់ស៊ីវិល ........ ៥៣

៤.៣.៨ ក្រោយឯករាជ្យ ដល់របបកម្ពុជាប្រជាធិបតេយ្យ ........ ៥៤

៤.៣.៩ ការកសាងឡើងវិញក្រោយឆ្នាំ១៩៧៩ និងក្រោយរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ........ ៥៤

៤.៣.១០ អត្តសញ្ញាណនៃប្រព័ន្ធច្បាប់កម្ពុជាសម័យទំនើប ........ ៥៥

៤.៣.១១ សេចក្តីសន្និដ្ឋានអំពីប្រវត្តិនៃប្រព័ន្ធច្បាប់កម្ពុជា ........ ៥៥

៥. វិធីសាស្ត្រក្នុងការរៀបចំក្របខ័ណ្ឌទស្សនាទាន ........ ៥៥

៥.១. សមត្ថកិច្ចរបស់គ.ក.ច.និងទិសដៅគោលនយោបាយរបស់រាជរដ្ឋាភិបាល ........ ៥៥

៥.២. ការពិគ្រោះយោបល់ និងប្រមូលផ្តុំចំណេះដឹង ........ ៥៦

៥.៣. ក្របខ័ណ្ឌទ្រឹស្តីនិងការវិភាគ ........ ៥៦

៥.៣.១ វិធីសាស្ត្រស្រាវជ្រាវ ........ ៥៧

៥.៣.២ ការស្រាវជ្រាវអំពីប្រព័ន្ធច្បាប់កម្ពុជា ........ ៥៨

៥.៣.៣ វិធីសាស្ត្រក្នុងការរៀបចំរចនាសម្ព័ន្ធគោលគំនិត ........ ៥៨

៦. ក្របខ័ណ្ឌទស្សនាទាននៃការកសាងប្រព័ន្ធច្បាប់កម្ពុជាដែលស្នើឡើង. ៥៩
៦.១. គោលបំណងជាតិ ..................................................... ៥៩
៦.២. ទស្សនាទាន ..................................................... ៦០
៦.៣. គោលបំណង ..................................................... ៦១
៦.៤. វិសាលភាព ..................................................... ៦២
៦.៥. ការធ្វើបច្ចុប្បន្នភាពក្របខ័ណ្ឌជាប្រចាំ ..................................................... ៦២
៦.៦. ចក្ខុវិស័យ ..................................................... ៦៣
៦.៧. ធាតុផ្សំស្នូលនៃប្រព័ន្ធច្បាប់ ..................................................... ៦៣
៦.៧.១ គុណតម្លៃគ្រឹះ ..................................................... ៦៣
៦.៧.២ សារជាតុគតិយុត្ត ..................................................... ៧១
៦.៧.៣ រចនាសម្ព័ន្ធគតិយុត្ត ..................................................... ៧៨
៦.៧.៤ វប្បធម៌គោរពច្បាប់ ..................................................... ៩១
៦.៧.៥ យន្តការវាយតម្លៃ ..................................................... ៩៧
៧. ការរៀបចំក្របខ័ណ្ឌប្រព័ន្ធច្បាប់កម្ពុជា ..................................................... ១០៣
៧.១. ដំណើរការនៃការរៀបចំ ..................................................... ១០៣
៧.២. អភិបាលកិច្ចនៃកិច្ចការរៀបចំ ..................................................... ១០៤
៧.២.១ ក្រុមការងារស្នូល ..................................................... ១០៤
៧.២.២ ក្រុមការងារបច្ចេកទេស ..................................................... ១០៥
៧.៣. ក្របខ័ណ្ឌពេលវេលា ..................................................... ១០៥
៧.៤. លក្ខខណ្ឌគុណវុឌ្ឍិ ..................................................... ១០៦

៧.៥. លទ្ធផលរំពឹងទុក ........ ១០៧

៨. សេចក្តីសន្និដ្ឋាន ........ ១០៧

ឧបសម្ព័ន្ធ ១. បញ្ជីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ........ ១០៩

ឧបសម្ព័ន្ធ ២. បញ្ជីស្ថាប័ននៃប្រព័ន្ធច្បាប់កម្ពុជា ........ ១៦៥

ឧបសម្ព័ន្ធ ៣. បញ្ជីសន្ធិសញ្ញា និងកិច្ចព្រមព្រៀងដែលកម្ពុជាជាភាគី ........ ១៨៦

ឧបសម្ព័ន្ធ ៤. បញ្ជីអង្គការអន្តរជាតិដែលកម្ពុជាជាសមាជិក ........ ២២៨

ឧបសម្ព័ន្ធ ៥. កម្មវិធីនីតិកម្ម និងសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត ........ ២៣២

ឧបសម្ព័ន្ធ ៦. ជំនួយស្មារតីទាក់ទងនឹងការកសាងប្រព័ន្ធច្បាប់កម្ពុជា ........ ២៧៤

ឧបសម្ព័ន្ធ ៧. សេចក្តីព្រាងសេចក្តីសម្រេចបង្កើតក្រុមការងាររៀបចំក្របខ័ណ្ឌប្រព័ន្ធច្បាប់កម្ពុជា ........ ៤៣៦

## ខ្លឹមសារសង្ខេប

កម្ពុជា កំពុងឈានដល់ដំណាក់កាលថ្មីនៃការអភិវឌ្ឍជាតិ ដែលទាមទារឱ្យមានប្រព័ន្ធច្បាប់មួយមានភាពច្បាស់លាស់ សង្គតិភាព បូរណភាព និងសមត្ថភាពគ្រប់គ្រាន់ ដើម្បីគាំទ្រការគ្រប់គ្រងរដ្ឋ ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ការការពារសិទ្ធិ និងសេរីភាព ការទាក់ទាញវិនិយោគ និងការធ្វើសមាហរណកម្មអន្តរជាតិ។ ក្នុងបរិបទសកលភាវូបនីយកម្ម បច្ចេកវិទ្យាឌីជីថល ការកើនឡើងនៃកាតព្វកិច្ចអន្តរជាតិ ការវាយតម្លៃអភិបាលកិច្ចអន្តរជាតិ និងសេចក្តីរំពឹងទុកកាន់តែខ្ពស់របស់ប្រជាពលរដ្ឋ វិនិយោគិន និងដៃគូអន្តរជាតិ ប្រព័ន្ធច្បាប់ជាតិមិនអាចត្រឹមតែជាបណ្តុំច្បាប់ និងស្ថាប័នដាច់ដោយឡែកពីគ្នានោះទេ ប៉ុន្តែអភិវឌ្ឍទៅជាប្រព័ន្ធមួយដែលមានទំនាក់ទំនងប្រទាក់ក្រឡា មានទិសដៅរួម និងមានសមត្ថភាពធ្វើស្វ័យកែតម្រូវ ជាបន្តបន្ទាប់។

ឯកសារក្របខ័ណ្ឌទស្សនាទាននេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងឈានទៅដល់ការរៀបចំក្របខ័ណ្ឌប្រព័ន្ធច្បាប់កម្ពុជាដើម្បីជាមគ្គុទេសន៍បង្ហាញផ្លូវ ឬ blueprint / master plan សម្រាប់ការកសាង "ប្រព័ន្ធច្បាប់កម្ពុជា" ឱ្យមានឯកភាព សមានគតិភាព ឧត្តមានុភាពគតិយុត្ត និងសន្តិសុខគតិយុត្តស្របតាមឧត្តមានុវត្តន៍អន្តរជាតិ និងបរិការណ៍ជាក់ស្តែងរបស់កម្ពុជា។ ឯកសារនេះមានបំណងមិនត្រឹមតែពណ៌នាអំពីស្ថានភាព និងបញ្ហាប្រឈមនៃប្រព័ន្ធច្បាប់បច្ចុប្បន្នប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងកំណត់ទិសដៅ និម្មាបនកម្ម និងជាតុផ្សំស្នូលនៃប្រព័ន្ធច្បាប់ទាំងមូល ដើម្បីក្លាយជាមូលដ្ឋានសម្រាប់ការវាយតម្លៃការសម្របសម្រួល និងការកែទម្រង់នាពេលអនាគត។

ជាសារវតា ការរៀបចំក្របខ័ណ្ឌនេះកើតឡើងក្នុងបរិបទដែលប្រព័ន្ធច្បាប់កម្ពុជានៅតែប្រឈមនឹងបញ្ហាសារវន្តជាច្រើន រួមមាន ភាពមិនមានសង្គតិភាពនៃច្បាប់ជាធរមាន កង្វះស្តង់ដារតាក់តែងច្បាប់ គម្លាតរវាងគោលនយោបាយ ច្បាប់ និងបទប្បញ្ញត្តិអនុវត្ត ភាពមិនច្បាស់លាស់នៃបទដ្ឋាន និងការបកស្រាយច្បាប់ កង្វះយន្តការតាមដាន និងវាយតម្លៃ ការបែងចែកតួនាទីភារកិច្ចរវាងស្ថាប័នមិនទាន់ច្បាស់លាស់ កម្រិតឌីជីថលូបនីយកម្មនៅមានកម្រិត សមត្ថភាពធនធានមនុស្សផ្នែកច្បាប់មិនទាន់ស៊ីសង្វាក់គ្នាជាប្រព័ន្ធ និងកង្វះក្របខ័ណ្ឌសមត្ថភាពវិជ្ជាជីវៈផ្នែកច្បាប់។ បញ្ហាទាំងនេះប៉ះពាល់ដោយផ្ទាល់ដល់សន្តិសុខគតិយុត្ត ភាពអាចព្យាករណ៍បាននៃច្បាប់ ប្រសិទ្ធភាពនៃការគ្រប់គ្រងរដ្ឋ និងទំនុកចិត្តសាធារណៈលើប្រព័ន្ធច្បាប់។

ដើម្បីឆ្លើយតបទៅនឹងតម្រូវការទាំងនេះ ឯកសារនេះបានប្រើប្រាស់ទ្រឹស្តីប្រព័ន្ធទូទៅ ( General System Theory ) និងទ្រឹស្តីប្រព័ន្ធច្បាប់ ជាមូលដ្ឋានក្នុងការស្វែងយល់និងវិភាគអំពីប្រព័ន្ធច្បាប់។ តាមទស្សនៈនេះ ប្រព័ន្ធច្បាប់ត្រូវមិនត្រឹមជាបណ្តុំវិធានគតិយុត្ត ឬស្ថាប័នតែប៉ុណ្ណោះទេ ប៉ុន្តែជាប្រព័ន្ធរស់មួយ ដែលដំណើរការក្នុងបរិបទនយោបាយ សេដ្ឋកិច្ច សង្គម វប្បធម៌ បច្ចេកវិទ្យា និងអន្តរជាតិ មានជាតុ

ចូល ដំណើរការ សមិទ្ធផល ផលសម្រេច ផលប៉ះពាល់ និងយន្តការវាយតម្លៃជាប្រចាំ។ ផ្អែកលើមូលដ្ឋាននេះ ឯកសារនេះបានកំណត់ថា ប្រព័ន្ធច្បាប់កម្ពុជាមានធាតុផ្សំស្នូលចំនួន ៤ គឺ៖ (១) គុណតម្លៃគ្រឹះ (Foundational Ethos) (២) សារធាតុគតិយុត្ត (Legal Substance) (៣) រចនាសម្ព័ន្ធគតិយុត្ត (Legal Structure) និង (៤) វប្បធម៌គោរពច្បាប់ (Legal Culture)។ ក្នុងនោះដើម្បីឱ្យប្រព័ន្ធច្បាប់ជាប្រព័ន្ធរស់ដែលអាចកែលម្អដោយខ្លួនឯងបានក៏ចាំបាច់ត្រូវមាន យន្តការវាយតម្លៃ (Feedback Mechanism / Feedback Loops) ផងដែរ។

ក្នុងចំណោមធាតុផ្សំទាំងនេះ "គុណតម្លៃគ្រឹះ" ត្រូវបានដាក់ជាមូលដ្ឋានកំណត់អត្តសញ្ញាណ និងទិសដៅរួមនៃប្រព័ន្ធច្បាប់កម្ពុជា។ គុណតម្លៃគ្រឹះនេះរួមបញ្ចូលទាំងការរស់រានមានជីវិត និងអធិបតេយ្យភាពជាតិ សន្តិភាព និងសណ្តាប់ធ្នាប់ នីតិរដ្ឋ និងរដ្ឋាភិបាលតាមរដ្ឋធម្មនុញ្ញ ប្រជាធិបតេយ្យ និងគណនេយ្យភាព អត្តសញ្ញាណជាតិ និងអរិយធម៌ រដ្ឋរឹងមាំ និងអភិបាលកិច្ចផ្អែកលើគុណាធិបតេយ្យ ឯករាជ្យភាពយុទ្ធសាស្ត្រ និងម្ចាស់ការជាតិ វិបុលភាព និងការអភិវឌ្ឍប្រកបដោយចីរភាព ព្រមទាំងសុចរិតភាព និងការបម្រើផលប្រយោជន៍រួម។ ធាតុនេះមានតួនាទីជាគ្រឹះទស្សនវិជ្ជា និងគោលការណ៍ដឹកនាំសម្រាប់ការរៀបចំខ្លឹមសារ រចនាសម្ព័ន្ធ និងដំណើរការនៃប្រព័ន្ធច្បាប់ទាំងមូល។

"សារធាតុគតិយុត្ត" សំដៅដល់ខ្លឹមសារផ្ទៃក្នុងនៃច្បាប់ ដែលរួមមានមូលដ្ឋានគតិយុត្ត រចនាសម្ព័ន្ធនៃបទដ្ឋាន ប្រតិបត្តិការនៃច្បាប់ វិធីសាស្ត្រគតិយុត្ត ការចងក្រងជាប្រព័ន្ធ និងទំនាក់ទំនងរវាងច្បាប់ជាតិជាមួយប្រភពនិយាមផ្សេងៗ។ ធាតុនេះបង្ហាញថាប្រព័ន្ធច្បាប់កម្ពុជាចាំបាច់ត្រូវមានភាពច្បាស់លាស់លើប្រភពច្បាប់ គោលការណ៍ទូទៅ សុពលភាពច្បាប់ ឋានានុក្រមច្បាប់ ប្រភេទនៃនិយាមគតិយុត្ត កម្មវត្ថុ និងទំនាក់ទំនងគតិយុត្ត អានុភាពច្បាប់ក្នុងពេលវេលា ទីកន្លែង និងស្ថានភាពពិសេស វិធីសាស្ត្របកស្រាយ និងសំអាងហេតុផល និងយន្តការក្រមនីយកម្ម ការរួមបញ្ចូល និងការកែលម្អច្បាប់ជាប្រព័ន្ធ។

"រចនាសម្ព័ន្ធគតិយុត្ត" សំដៅដល់និម្មាបនកម្មស្ថាប័ននៃប្រព័ន្ធច្បាប់ ដែលរួមមានស្ថាប័នធម្មនុញ្ញ និងការបែងចែកអំណាចរដ្ឋ ស្ថាប័នកសាងច្បាប់ ស្ថាប័នពិនិត្យធម្មនុញ្ញភាព និងនីត្យានុកូលភាព ប្រព័ន្ធតុលាការ និងអភិបាលនៃវិស័យតុលាការ ប្រព័ន្ធអយ្យការ ស្ថាប័នស៊ើបអង្កេត នគរបាល និងអនុវត្តច្បាប់ ស្ថាប័នដោះស្រាយវិវាទរដ្ឋបាល និងការការពារនីត្យានុកូលភាព ស្ថាប័នវិជ្ជាជីវៈច្បាប់ និងសេវាកម្មច្បាប់ យន្តការដោះស្រាយវិវាទក្រៅតុលាការ ស្ថាប័នអប់រំ ស្រាវជ្រាវ និងចំណេះដឹងច្បាប់ ព្រមទាំងស្ថាប័នទទួលបន្ទុកព័ត៌មានច្បាប់ និងផ្សព្វផ្សាយច្បាប់។ ធាតុនេះមានគោលបំណងធានាថា តួនាទី ភារកិច្ច សមត្ថកិច្ច និងទំនាក់ទំនងរវាងស្ថាប័នទាំងអស់ត្រូវបានកំណត់យ៉ាងច្បាស់ និងស៊ីសង្វាក់គ្នា។

"វប្បធម៌គោរពច្បាប់" សំដៅដល់បរិយាកាសសង្គម និងវិជ្ជាជីវៈដែលធ្វើឱ្យច្បាប់អាចរស់នៅក្នុងការអនុវត្តជាក់ស្តែង រួមមានវប្បធម៌នីត្យានុកូលភាព សម្បជញ្ញៈអំពីច្បាប់ និងសិទ្ធិ ជំនឿសាធារណៈលើស្ថាប័នយុត្តិធម៌ សមត្ថភាពច្បាប់របស់ពលរដ្ឋ វប្បធម៌វិជ្ជាជីវៈរបស់ចៅក្រម ព្រះរាជអាជ្ញា មេធាវី និងមន្ត្រី

រដ្ឋបាល ក្រមសីលធម៌ និងសុចរិតភាពរបស់ស្ថាប័ន វប្បធម៌អនុលោមភាពរបស់ធុរកិច្ច និងវប្បធម៌ដោះស្រាយវិវាទដោយសន្តិវិធី។ ជាតុនេះរំលេចថា ប្រព័ន្ធច្បាប់មិនអាចដំណើរការបានល្អ ប្រសិនបើសង្គម និងស្ថាប័នពុំមានការយល់ដឹង ការជឿទុកចិត្ត និងការគោរពច្បាប់ជាប្រចាំ។

"យន្តការវាយតម្លៃ" ឬ feedback mechanism គឺជាយន្តការសំខាន់សម្រាប់ធានាថាប្រព័ន្ធច្បាប់កម្ពុជា ជាប្រព័ន្ធរស់ និងអាចធ្វើស្វ័យកែតម្រូវបាន។ យន្តការនេះរួមមានគោលការណ៍នៃប្រព័ន្ធច្បាប់រស់ ក្របខ័ណ្ឌសូចនាករ និងរបាយការណ៍សាធារណៈ ការតាមដានជាបន្តបន្ទាប់ និងប្រព័ន្ធព្រមានមុន ការធ្វើច្បាប់ផ្អែកលើភស្តុតាង ការពិនិត្យឡើងវិញក្រោយការអនុវត្ត ការត្រួតពិនិត្យរបស់សភា យន្តការបណ្តឹង និងដំណោះស្រាយរដ្ឋបាល ការធ្វើអធិការកិច្ចឯករាជ្យ និងសវនកម្ម ហេដ្ឋារចនាសម្ព័ន្ធទិន្នន័យ និងព័ត៌មានច្បាប់ ព្រមទាំងការបណ្តុះបណ្តាលបន្ត និងការពិនិត្យប្រព័ន្ធច្បាប់ជាតិជាទៀងទាត់។ ទាំងនេះបង្ហាញថា ប្រព័ន្ធច្បាប់មិនបញ្ឈប់ត្រឹមការអនុម័តច្បាប់ទេ ប៉ុន្តែត្រូវមានយន្តការសម្រាប់ពិនិត្យ កែលម្អ និងមាននីតិវិធីបិទបញ្ចប់ការកែទម្រង់ប្រកបដោយប្រសិទ្ធភាព។

ដោយសារសារៈសំខាន់ និងភាពស្មុគស្មាញនៃកិច្ចការនេះ ឯកសារនេះបានស្នើឱ្យការរៀបចំក្របខ័ណ្ឌប្រព័ន្ធច្បាប់កម្ពុជាត្រូវអនុវត្តតាមដំណាក់កាលច្បាស់លាស់ ក្រោមការដឹកនាំរបស់ គ.ក.ច. និងក្រុមការងារស្នូល និងក្រុមការងារបច្ចេកទេសដែលមានសមត្ថភាពសមស្រប។ ដំណើរការនេះរួមមានការស្រាវជ្រាវ ការតាក់តែង ការពិគ្រោះយោបល់ ការពិនិត្យបច្ចេកទេស ការពិគ្រោះអន្តរក្រសួង និងការដាក់ឆ្លងគណៈរដ្ឋមន្ត្រី ដោយមានគោលដៅបង្កើតជាឯកសារមូលដ្ឋានថ្នាក់ជាតិមួយសម្រាប់ដឹកនាំការកែទម្រង់ច្បាប់ និងការកសាងវប្បធម៌នីតិរដ្ឋរយៈពេលវែង។ ឯកសារនេះក៏ជាឯកសារទន់ និងរស់ ដែលត្រូវធ្វើបច្ចុប្បន្នភាពជាប្រចាំ ដើម្បីឆ្លើយតបទៅនឹងការវិវត្តន៍នៃបរិបទជាតិ និងអន្តរជាតិ។

សរុបជារួម ក្របខ័ណ្ឌទស្សនាទានស្តីពីប្រព័ន្ធច្បាប់កម្ពុជា មានបំណងបង្កើតមូលដ្ឋានគំនិត និងនិម្មាបនកម្មរួមសម្រាប់ការយល់ដឹង រៀបចំ វាយតម្លៃ និងអភិវឌ្ឍប្រព័ន្ធច្បាប់កម្ពុជាទាំងមូល។ តាមរយៈការកំណត់ច្បាស់លាស់អំពីគុណតម្លៃគ្រឹះ សារជាតុគតិយុត្ត រចនាសម្ព័ន្ធគតិយុត្ត វប្បធម៌គោរពច្បាប់ និងយន្តការវាយតម្លៃ។ ឯកសារនេះនឹងប្រែក្លាយប្រព័ន្ធច្បាប់កម្ពុជាពីការវិវត្តបែបដាច់ដោយឡែកពីគ្នា ទៅជាប្រព័ន្ធច្បាប់ជាតិមួយដែលមានបូរណភាព ប្រទាក់ក្រឡា អាចទុកចិត្តបាន និងមានសមត្ថភាពគាំទ្រដល់ការកសាងរដ្ឋរឹងមាំ នីតិរដ្ឋ ការអភិវឌ្ឍជាតិ និងចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០។

# ១. សាវតា

## ១.១. បរិបទសកល

នាពេលបច្ចុប្បន្ន ប្រព័ន្ធច្បាប់ជាតិអាចដំណើរការប្រកបដោយប្រសិទ្ធភាពបានចាំបាច់ត្រូវផ្សារភ្ជាប់នឹងនិម្មាបនកម្មអភិបាលកិច្ចសកលលោក។ ការផ្សារភ្ជាប់នេះក៏ចាំបាច់ត្រូវធ្វើឡើងប្រកបដោយយុទ្ធសាស្ត្រ និងការប្រុងប្រយ័ត្នខ្ពស់។ ក្រៅពីកត្តាផ្ទៃក្នុងដូចជា មូលដ្ឋានវដ្ដធម្មនុញ្ញ នយោបាយ សេដ្ឋកិច្ចនិងសង្គម ក្របខ័ណ្ឌប្រព័ន្ធច្បាប់របស់ប្រទេសនីមួយៗត្រូវបានកំណត់ដោយកត្តាខាងក្រៅផងដែរ ដែលជាបរិបទអន្តរជាតិដែលមានការវិវត្តយ៉ាងឆាប់រហ័សនិងលក្ខណៈស្មុគស្មាញផងដែរ។ ច្បាប់អន្តរជាតិ សមាហរណកម្មអន្តរជាតិ ឧត្តមានុវត្តន៍អន្តរជាតិ ប្រព័ន្ធវាយតម្លៃចំណាត់ថ្នាក់ប្រទេស សេចក្ដីត្រូវការរបស់ ដៃគូបរទេស ព្រមទាំងបច្ចេកវិទ្យាថ្មីៗ ជាកត្តាខាងក្រៅដែលរួមចំណែកលើការវិវត្តនៃប្រព័ន្ធច្បាប់ជាតិ។ ហេតុនេះ ទោះបីជាត្រូវ ផ្អែកជាចម្បងលើកត្តាផ្ទៃក្នុង ការកសាងប្រព័ន្ធច្បាប់ជាតិមួយដែលមានបូរណភាព ចាំបាច់ត្រូវផ្សារភ្ជាប់ទៅនឹងកត្តាខាងក្រៅផងដែរ។

ក្របខ័ណ្ឌអន្តរជាតិទាំងនេះមានឥទ្ធិពលដល់រដ្ឋលើក្របខ័ណ្ឌច្បាប់ ក្របខ័ណ្ឌស្ថាប័ន និងក្របខ័ណ្ឌអនុវត្ត។ ក្នុងក្របខ័ណ្ឌច្បាប់ ការចុះសន្ធិសញ្ញា អនុសញ្ញា កិច្ចព្រម ព្រៀងអន្តរជាតិ និងការចូលរួមក្នុងស្ថាប័នអន្តរជាតិបានបង្កើតជាកាតព្វកិច្ចដែលរដ្ឋត្រូវគោរព អនុវត្ត និងផ្ដល់សច្ចាប័នជាច្បាប់ជាតិ។ ក្នុងក្របខ័ណ្ឌស្ថាប័ន ច្បាប់អន្តរជាតិទាំងនោះក៏ជាចំណែកមូលដ្ឋានក្នុងការរៀបចំរចនាសម្ព័ន្ធ តួនាទី នីតិវិធី និងស្តង់ដារប្រតិបត្តិរបស់ស្ថាប័នសាធារណៈ ជាពិសេសស្ថាប័នពាក់ព័ន្ធនឹងកិច្ចការនីតិកម្ម រដ្ឋបាល ការដោះស្រាយវិវាទ ការអនុវត្តច្បាប់ ពាណិជ្ជកម្ម វិនិយោគ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ។ ចំពោះក្របខ័ណ្ឌអនុវត្ត ច្បាប់អន្តរជាតិទាំងនោះបានក្លាយជាស្តង់ដារសម្រាប់វាយតម្លៃលើប្រព័ន្ធច្បាប់ ជាតិពីសំណាក់ភាគីពាក់ព័ន្ធរួមមាន វិនិយោគិនបរទេស ដៃគូអភិវឌ្ឍន៍ ស្ថាប័នអន្តរជាតិ ដៃគូពាណិជ្ជកម្ម និងសង្គមស៊ីវិលអន្តរជាតិ។ ក្នុងន័យនេះ ប្រព័ន្ធច្បាប់ជាតិត្រូវមានអនុលោមភាពជាមួយប្រព័ន្ធច្បាប់ អន្តរជាតិផងដែរ។

ជំនឿទុកចិត្តពីសំណាក់សហគមន៍អន្តរជាតិមានសារៈសំខាន់ក្នុងការទាក់ទាញការវិនិយោគ ទេសចរណ៍ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ។ ដើម្បីកសាងជំនឿទុកចិត្តនេះបាន ក្រៅពីបំពេញតម្រូវការផ្ទៃក្នុងប្រព័ន្ធច្បាប់ជាតិត្រូវមានភាពច្បាស់លាស់ សង្គតិភាព តម្លាភាព អាចព្យាករណ៍បាន និងអាចអនុវត្តបានក្នុងបរិបទអន្តរជាតិ។ ដូចច្នេះ ការវាយតម្លៃលើប្រព័ន្ធច្បាប់ជាតិ គឺមិនត្រឹមតែផ្អែកលើចំនួន ច្បាប់ និងចំនួនស្ថាប័នប៉ុណ្ណោះទេ ប៉ុន្តែក៏ផ្អែកលើសមត្ថភាពនិងប្រសិទ្ធភាពក្នុងការធានាភាពច្បាស់លាស់ ព្រមទាំងគុណភាពច្បាប់ ការទទួលខុសត្រូវរបស់ស្ថាប័ន ប្រសិទ្ធភាពនៃការដោះស្រាយវិវាទ ស្ថិរភាពនៃ គោលនយោបាយ និងការអនុវត្តច្បាប់ជាក់ស្តែង។

ក្នុងបរិបទភូមិសាស្ត្រនយោបាយនិងការប្រកួតប្រជែងទីផ្សារអន្តរជាតិ ក្របខ័ណ្ឌអន្តរជាតិទាំងនោះ និងការផ្សារភ្ជាប់ខ្លួនទៅនឹងនិម្មាបនកម្មសកលលោក ជាអាវុធមុខពីរដែលអាចផ្តល់បច្ច័យវិជ្ជមាន និង អវិជ្ជមាន។ បច្ច័យវិជ្ជមាន រួមមានការពង្រីកទីផ្សារពាណិជ្ជកម្មនិងកិច្ចសហប្រតិបត្តិការអន្តរជាតិ ព្រមទាំង ការការពារផ្លូវច្បាប់តាមរយៈស្ថាប័នអន្តរជាតិ។ រីឯបច្ច័យអវិជ្ជមាន រួមមានការប្រើប្រាស់ច្បាប់ អន្តរជាតិជា គំនាបរារាំងការអភិវឌ្ឍន៍ ជារបាំងពាណិជ្ជកម្ម និងជាមូលដ្ឋានក្នុងការដាក់សម្ពាធដើម្បីទទួល បានសម្បទាន នយោបាយ។ ហេតុនេះ ប្រព័ន្ធច្បាប់ជាតិត្រូវធានាការចូលរួមក្នុងនិម្មាបនកម្មសកលលោក នេះត្រូវធ្វើឡើង ប្រកបដោយយុទ្ធសាស្ត្រនិងការប្រុងប្រយ័ត្នខ្ពស់ដោយតម្កល់ផលប្រយោជន៍ជាតិជាធំ។

សម្រាប់កម្ពុជាក្នុងនាមជាប្រទេសតូច ការចូលរួមក្នុងនិម្មាបនកម្មសកលលោកមានសារៈសំខាន់មិន ត្រឹមតែចំពោះការកសាងប្រព័ន្ធច្បាប់ប៉ុណ្ណោះទេ តែក៏មានសារៈសំខាន់ចំពោះអាយុជីវិតជាតិទាំងមូល ផងដែរ។ ក្នុងន័យនេះកម្ពុជាចាំបាច់ត្រូវទាញយកផលប្រយោជន៍ជាអតិប្បរមា និងកាត់បន្ថយហានិភ័យ ជាអប្បបរមាពីការចូលរួមក្នុងសហគមន៍អន្តរជាតិនេះ។ ខណៈពេលដែលការចូលរួមសហគមន៍អន្តរជាតិ ជាខែលការពារជាតិមួយដ៏សំខាន់ ការចូលរួមនេះក៏បានបង្កើតកាតព្វកិច្ចអន្តរជាតិ និងសេចក្តីត្រូវការពី ដៃគូអន្តរជាតិជាច្រើនផងដែរ មានឥទ្ធិពលដោយផ្ទាល់លើការអភិវឌ្ឍ ការកែទម្រង់ និងប្រសិទ្ធភាពនៃ ប្រព័ន្ធច្បាប់កម្ពុជា។

ក្នុងបរិបទនេះ ការកសាងក្របខ័ណ្ឌប្រព័ន្ធច្បាប់កម្ពុជាដែលមានភាពច្បាស់លាស់ សង្គតិភាព និង ពេញលេញ ពុំត្រឹមជាការរៀបចំនិម្មាបនកម្មច្បាប់ផ្ទៃក្នុងប៉ុណ្ណោះទេ ប៉ុន្តែជាការឆ្លើយតបយុទ្ធសាស្ត្រចំពោះ តម្រូវការនៃបរិយាកាសសកលផងដែរ។ ក្របខ័ណ្ឌនេះ មានសារៈសំខាន់ក្នុងការគាំទ្រការអនុលោមភាព របស់កម្ពុជាចំពោះកាតព្វកិច្ចអន្តរជាតិ ពង្រឹងសុខុដុមនីយកម្មជាមួយការវិវត្តច្បាប់អន្តរជាតិ លើកកម្ពស់ ភាពអាចព្យាករណ៍បាន និងភាពងាយស្រួលក្នុងការចូលប្រើប្រព័ន្ធច្បាប់ ពង្រឹងភាពប្រកួតប្រជែងជាតិ និងបង្កើនការជឿទុកចិត្តពីសំណាក់វិនិយោគិន ដៃគូអន្តរជាតិ និងសហគមន៍អន្តរជាតិទាំងមូល។ ដូច្នេះ ការស្វែងយល់អំពីបរិយាកាសសកលជាចំណុចចាប់ផ្តើមដ៏សំខាន់សម្រាប់ការកំណត់ទិសដៅ រចនាសម្ព័ន្ធ និងតម្រូវការកែទម្រង់នៃប្រព័ន្ធច្បាប់កម្ពុជាក្នុងរយៈពេលវែង។

### ១.១.១ ច្បាប់អន្តរជាតិ

នៅក្នុងនិម្មាបនកម្មសកលនាពេលបច្ចុប្បន្ន ការចូលរួមរបស់រដ្ឋនៅក្នុងសន្ធិសញ្ញា អនុសញ្ញា កិច្ចព្រមព្រៀងអន្តរជាតិ និងស្ថាប័នអន្តរជាតិ មិនត្រឹមជាការចូលរួមកម្រិតការទូត ឬនយោបាយប៉ុណ្ណោះ ទេ តែជាការទទួលយកនូវកាតព្វកិច្ចជាលក្ខណៈផ្លូវច្បាប់ ស្ថាប័ន និងការអនុវត្តផងដែរ ដែលមានទំនាក់ ទំនងដោយផ្ទាល់ និងប្រយោលលើរចនាសម្ព័ន្ធ និងដំណើរការនៃប្រព័ន្ធច្បាប់ជាតិ។ ក្រៅពីបង្ហាញនូវការ ប្តេជ្ញាចិត្ត ការចូលរួមក្នុងក្របខ័ណ្ឌអន្តរជាតិនេះតម្រូវឱ្យរដ្ឋគោរពនូវកាតព្វកិច្ចទាំងនោះ និងចាត់វិធានការ ចំបាច់នានាដើម្បីធានាថាកាតព្វកិច្ចទាំងអស់នោះអាចត្រូវបានអនុវត្តយ៉ាងមានប្រសិទ្ធភាពនៅក្នុងប្រព័ន្ធ

ច្បាប់ជាតិ។ ក្នុងន័យនេះ កាតព្វកិច្ចអន្តរជាតិជាចលករសំខាន់មួយ ដែលជម្រុញការអភិវឌ្ឍ និងកែទម្រង់ប្រព័ន្ធច្បាប់ជាតិ។

ការចូលរួមក្នុងក្របខ័ណ្ឌអន្តរជាតិ រដ្ឋតម្រូវឱ្យមានការវាយតម្លៃអំពីអនុលោមភាព និង សុខុដុមនីយកម្មរវាងកតព្វកិច្ចអន្តរជាតិ និងច្បាប់ជាតិ ថាតើច្បាប់ ស្ថាប័ន នីតិវិធី និងយន្តការអនុវត្តដែល មានស្រាប់មានសមត្ថភាពក្នុងការអនុវត្តកាតព្វកិច្ចអន្តរជាតិដែលនឹងទទួលយកដែរឬទេ។ ក្នុងករណីដែលមិនមានអនុលោមភាព ឬខ្វះចន្លោះ រដ្ឋត្រូវចាត់វិធានការដើម្បីបង្កើតច្បាប់ថ្មី វិសោធនកម្មច្បាប់ដែល មានស្រាប់ បង្កើតស្ថាប័នថ្មី ឬពង្រឹងយន្តការដែលមានស្រាប់ដើម្បីធានាថាកាតព្វកិច្ចអន្តរជាតិត្រូវបាន អនុវត្តប្រកបដោយប្រសិទ្ធភាព។ ក្នុងនោះផងដែរឥទ្ធិពលនៃច្បាប់អន្តរជាតិក៏រួមចំណែកពង្រឹងប្រសិទ្ធភាពនៃប្រព័ន្ធច្បាប់ជាតិ តាមរយៈការមានស្តង់ដារអនុវត្តនិងយន្តការតាមដានការអនុវត្តច្បាស់លាស់ ដែលជួយរដ្ឋដែលពុំមានបទដ្ឋានទាំងនោះក្នុងការបង្កើតបទដ្ឋានដើម្បីអនុវត្ត ហើយស្របទៅនឹងស្តង់ដារអន្តរជាតិ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិទ្ធភាពនៃកាតព្វកិច្ចអន្តរជាតិអាចសម្រេចបានមិនត្រឹមតាមរយៈ ការអនុម័តច្បាប់និងបង្កើតស្ថាប័នថ្មីនោះ ប៉ុន្តែក៏អាស្រ័យលើសមត្ថភាពរបស់រដ្ឋក្នុងការប្រែក្លាយខ្លឹមសារ នៃកាតព្វកិច្ចទាំងអស់នោះទៅជាការអនុវត្តជាក់ស្តែងប្រកបដោយប្រសិទ្ធភាពនៅក្នុងប្រព័ន្ធច្បាប់ជាតិ។

សម្រាប់កម្ពុជាដែលជាប្រទេសតូចនិងមានប្រព័ន្ធច្បាប់ក្មេងខ្ចី ច្បាប់អន្តរជាតិមានសារៈសំខាន់សម្រាប់ការកសាងបូរណភាពនៃប្រព័ន្ធច្បាប់ និងអាយុជីវិតប្រទេសជាតិ។ កម្ពុជាបានអនុម័តសន្ធិសញ្ញា អន្តរជាតិជាច្រើនរួមមានវិស័យសិទ្ធិមនុស្ស ពាណិជ្ជកម្ម កម្មសិទ្ធិបញ្ញា បរិស្ថាន សន្តិសុខ វិនិយោគ កិច្ចសហប្រតិបត្តិការអន្តរជាតិ មនុស្សធម៌អន្តរជាតិ និងអធិបតេយ្យជាតិ ក្នុងទម្រង់ទ្វេភាគីនិងពហុភាគី។ ចំនួនដ៏ច្រើននៃច្បាប់អន្តរជាតិទាំងនេះ ចាំបាច់ត្រូវមានយន្តការគ្រប់គ្រងកិច្ចការនេះច្បាស់លាស់ដើម្បី ធានាការអនុវត្តច្បាប់ទាំងនោះជាច្បាប់ជាតិនឹងផ្តល់អត្ថប្រយោជន៍ជាអតិបរមា និងបញ្ចៀសហានិភ័យ ជាអតិបរមាផងដែរ។ ការណ៍នេះទាមទារឱ្យកម្ពុជាមានមិនត្រឹមតែអនុលោមភាពនោះទេ តែថែមទាំង សមត្ថភាព និងរចនាសម្ព័ន្ធប្រព័ន្ធច្បាប់ដែលធានាដល់ការអនុវត្តកាតព្វកិច្ច និងធានាសង្គតិភាពរវាង ច្បាប់ជាតិនិងច្បាប់អន្តរជាតិ។

### ១.១.២ សមាហរណកម្មអន្តរជាតិ

ក្នុងបរិបទសកលភាវូបនីយកម្មនិងអន្តរជាតិតូបនីយកម្ម ការធ្វើសមាហរណកម្មអន្តរជាតិជាកិច្ចការដែលមិនអាចខ្វះបានសម្រាប់ប្រទេសនីមួយៗ។ ក្រៅពីច្បាប់អន្តរជាតិ ដំណើរការប្រព្រឹត្តិទៅរបស់ស្ថាប័នអន្តរជាតិ និងលិខិតបទដ្ឋានគតិយុត្តរបស់ស្ថាប័នទាំងនោះក៏មានឥទ្ធពលដល់ការវិវត្តន៍នៃប្រព័ន្ធច្បាប់ជាតិផងដែរ ជាពិសេសក្នុងវិស័យសិទ្ធិមនុស្ស ពាណិជ្ជកម្ម គយ វិនិយោគ សេវាកម្ម ពន្ធដារ ដឹកជញ្ជូនពាណិជ្ជកម្មឌីជីថល ការប្រកួតប្រជែង កម្មសិទ្ធិបញ្ញា ការគ្រប់គ្រងហិរញ្ញវត្ថុ ការងារ និងស្តង់ដារបច្ចេកទេស។

ក្នុងកិច្ចដំណើរការប្រព្រឹត្តទៅរបស់ស្ថាប័នអន្តរជាតិ រដ្ឋសមាជិករមែងត្រូវបំពេញនូវរបបប្រជុំ របបរាយការណ៍ និងរបបតាមដាននិងត្រួតពិនិត្យ ព្រមទាំងមានអង្គភាពទទួលបន្ទុកច្បាស់លាស់។ កាតព្វកិច្ចផ្នែកអភិបាលកិច្ចនេះជាយន្តការជានាការអនុវត្តនូវកាតព្វកិច្ចរបស់រដ្ឋសមាជិកស្របតាមកិច្ចព្រមព្រៀងអន្តរជាតិដែលបានអនុម័ត ព្រមទាំងការបំពេញមុខងាររបស់ស្ថាប័នទាំងមូលផងដែរ។ ការចូលរួមក្នុងកិច្ចដំណើរការនេះ តម្រូវឱ្យរដ្ឋនីមួយៗមានក្របខ័ណ្ឌច្បាប់ និងរចនាសម្ព័ន្ធច្បាស់លាស់នៅ ក្នុងប្រព័ន្ធច្បាប់របស់ខ្លួនដើម្បីធានាសមាជិកភាពរបស់ខ្លួននៅក្នុងក្របខ័ណ្ឌអន្តរជាតិនេះ។ លើសពីនេះ ផងដែរ យន្តការនេះក៏រួមចំណែកដល់ការវិវត្តន៍ជាប្រចាំនៃប្រព័ន្ធច្បាប់ជាតិដើម្បីធានាអនុលោមភាព និងសុខដុមនីយមកម្មរវាងប្រព័ន្ធច្បាប់ជាតិនិងប្រព័ន្ធច្បាប់អន្តរជាតិ។

ក្រៅពីនេះសេចក្តីសម្រេចនិងលិខិតបទដ្ឋានគតិយុត្តរបស់ស្ថាប័នអន្តរជាតិ ក៏មានចំណែកដល់ការ វិវត្តន៍ប្រព័ន្ធច្បាប់ជាតិផងដែរ។ សេចក្តីសម្រេចនិងលិខិតបទដ្ឋានគតិយុត្តទាំងនោះតែងចងកាតព្វកិច្ចដល់រដ្ឋ ឬមានទម្ងន់សម្រាប់ការអនុវត្ត រួមមានសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ សេចក្តីសម្រេចរបស់រដ្ឋសមាជិកអាស៊ាន សេចក្តីណែនាំរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស សេចក្តីសម្រេចរបស់តុលាការយុត្តិធម៌អន្តរជាតិ និងសេចក្តីសម្រេចរបស់អង្គការពាណិជ្ជកម្ម ពិភពលោកជាដើម។ ឯកសារទាំងនេះត្បិតពុំមែនជាសន្ធិសញ្ញាអន្តរជាតិនិងពុំបានឆ្លងការអនុម័តដោយ សភា មានតម្លៃគតិយុត្តនិងឧត្តមភាព ដែលរដ្ឋត្រូវអនុវត្តផងដែរ។ ក្នុងន័យនេះប្រព័ន្ធច្បាប់ជាតិត្រូវមាន សមត្ថភាពនិងរចនាសម្ព័ន្ធដើម្បីឆ្លើយតបទៅនឹងសេចក្តីសេចក្តីសម្រេចនិងលិខិតបទដ្ឋានគតិយុត្តរបស់ស្ថាប័នអន្តរជាតិផងដែរ។

សម្រាប់កម្ពុជា ការធ្វើសមាហរណកម្មអន្តរជាតិជាការបង្កើតសម្លេងនយោបាយរបស់ខ្លួន ការរួមចំណែកក្នុងការកសាងច្បាប់អន្តរជាតិដែលពុំត្រឹមតែជាអ្នកប្រតិបត្តិច្បាប់ ព្រមទាំងពង្រឹងការអភិវឌ្ឍន៍និងការពារជាតិ។ ការធ្វើសមាហរណកម្មក្នុងអាស៊ាន អង្គការសហប្រជាជាតិ អង្គការពាណិជ្ជកម្មពិភពលោក និងក្របខ័ណ្ឌសហប្រតិបត្តិការអន្តរជាតិផ្សេងៗបានបង្កើតឱកាសជាច្រើនរួមមានការពង្រីកទីផ្សារពាណិជ្ជកម្ម ការដោះស្រាយវិវាទដោយសន្តិវិធី និងការចូលរួមធ្វើសេចក្តីសម្រេចចិត្តលើបញ្ហាសំខាន់ៗ។ ដោយមូលហេតុនៃសារៈសំខាន់នៃសមាហរណកម្មអន្តរជាតិ និងចំនួនដ៏ច្រើននៃស្ថាប័ននិងក្របខ័ណ្ឌអន្តរជាតិដែលកម្ពុជាសមាជិក ប្រព័ន្ធច្បាប់ជាតិចាំបាច់ត្រូវមានក្របខ័ណ្ឌច្បាប់និងរចនាសម្ព័ន្ធច្បាស់លាស់ និងមានគុណភាព ដែលធានាបាននូវការអនុវត្តកាតព្វកិច្ចអន្តរជាតិជាប្រព័ន្ធនិងជាយុទ្ធសាស្ត្រ ជាជាងការអនុវត្តដោយឡែកៗពីគ្នា ដើម្បីកាត់បន្ថយភាពមិនប្រាកដប្រជាផ្នែកច្បាប់ ពង្រឹងការសម្របសម្រួលរវាងស្ថាប័ន និងលើកកម្ពស់កេរ្តិ៍ឈ្មោះរបស់កម្ពុជាក្នុងឆាកអន្តរជាតិដែលកំពុងវិវត្តជាបន្តបន្ទាប់។

### ១.១.៣ ឧត្តមានុវត្តន៍អន្តរជាតិ

ក្រៅពីកាតព្វកិច្ចអន្តរជាតិដែលមានលក្ខណៈចងកាតព្វកិច្ចតាមរយៈសន្ធិសញ្ញា អនុសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិផ្សេងៗ ការអភិវឌ្ឍប្រព័ន្ធច្បាប់ជាតិបច្ចុប្បន្ន ក៏រងឥទ្ធពលដោយឧត្តមានុវត្តន៍អន្តរជាតិផងដែរ។ ឧត្តមានុវត្តន៍អន្តរជាតិទាំងនេះ ពុំចងកាតព្វកិច្ចផ្លូវច្បាប់ក្នុងន័យតឹងរឹងលើរដ្ឋនោះទេ តែមានតួនាទីសំខាន់រួមចំណែកក្នុងការកែទម្រង់ច្បាប់ជាតិ ការកសាងបទប្បញ្ញត្តិ ការប្រព្រឹត្តទៅរបស់ស្ថាប័ន និងប្រសិទ្ធភាពនៃការគ្រប់គ្រងសាធារណៈ។ ភាគច្រើន ឧត្តមានុវត្តន៍អន្តរជាតិទាំងនេះត្រូវបានប្រើ សម្រាប់ឱ្យរដ្ឋនានាសម្របប្រព័ន្ធច្បាប់របស់ខ្លួនឱ្យស្របនឹងគោលការណ៍ដែលត្រូវបានទទួលស្គាល់ជាសកល ដូចជាប្រសិទ្ធភាព តម្លាភាព ការទទួលខុសត្រូវ សង្គតិភាព និងភាពអាចព្យាករណ៍បាននៃច្បាប់។ ហេតុនេះ ឧត្តមានុវត្តន៍អន្តរជាតិបានក្លាយជាផ្នែកសំខាន់មួយសម្រាប់ការកសាងនិងការប្រព្រឹត្តទៅរបស់ប្រព័ន្ធច្បាប់ជាតិ។

ឧត្តមានុវត្តន៍អន្តរជាតិត្រូវបានបង្កើតឡើងពីប្រភពផ្សេងៗគ្នា រួមមានស្ថាប័នអន្តរជាតិ អង្គការបច្ចេកទេស បណ្តាញនិយតករ សមាគមវិជ្ជាជីវៈ ស្ថាប័នកំណត់ស្តង់ដារ វេទិកាអភិបាលកិច្ចហិរញ្ញវត្ថុ និងបទពិសោធន៍ប្រៀបធៀបផ្នែកច្បាប់រវាងប្រទេសផ្សេងៗ។ ឧត្តមានុវត្តន៍អន្តរជាតិទាំងនេះមានទម្រង់ជាច្បាប់គំរូ (model laws) គោលការណ៍ណែនាំ (guiding principles) បទដ្ឋានបច្ចេកទេស (technical standards) ក្រមសីលធម៌វិជ្ជាជីវៈ (codes of conduct) អនុសាសន៍អនុវត្តជាក់ស្តែង (recommended practices) សូចនាករអភិបាលកិច្ច និងក្របខ័ណ្ឌបកស្រាយនានា។ ទោះបីជាមិនមានលក្ខណៈចងកាតព្វកិច្ចផ្លូវច្បាប់លើរដ្ឋក៏ដោយ ឧត្តមានុវត្តន៍អន្តរជាតិទាំងនេះរមែងមានឥទ្ធិពលខ្លាំង ព្រោះត្រូវបានប្រើប្រាស់ដោយរដ្ឋាភិបាល តុលាការ វិនិយោគិន ដៃគូអភិវឌ្ឍន៍ ស្ថាប័ននិយតករ អង្គការអន្តរជាតិ និងសហគមន៍អាជីវកម្ម ជាមូលដ្ឋានសម្រាប់វាយតម្លៃគុណភាពនៃប្រព័ន្ធច្បាប់ និងភាពជឿជាក់នៃស្ថាប័ន។

ឧត្តមានុវត្តន៍អន្តរជាតិទាំងនេះក៏មានសារៈសំខាន់ផ្នែកគោលនយោបាយ ដើម្បីប្រើប្រាស់ជាមូលដ្ឋានក្នុងការគាំទ្រការធ្វើទំនើបកម្មច្បាប់ និងការធ្វើសុខដុមនីយកម្មប្រព័ន្ធច្បាប់ តាមរយៈការផ្តល់ជាគំរូ និងបទពិសោធន៍ដែលត្រូវបានសាកល្បងរួច សម្រាប់រដ្ឋក្នុងការដោះស្រាយបញ្ហាច្បាប់ និងបទប្បញ្ញត្តិដែលកាន់តែស្មុគស្មាញ និងមានលក្ខណៈអន្តរជាតិ ដូចជាប្រតិបត្តិការពាណិជ្ជកម្ម មជ្ឈត្តការនិងការដោះស្រាយវិវាទ អភិបាលកិច្ចសាជីវកម្ម ការគ្រប់គ្រងហិរញ្ញវត្ថុ ការប្រឆាំងការលាងលុយនិងហិរញ្ញប្បទានភេរវកម្ម ពាណិជ្ជកម្មឌីជីថល រដ្ឋបាលសាធារណៈ បទប្បញ្ញត្តិបច្ចេកទេស និងការគ្រប់គ្រងបរិស្ថាន។ តាមរយៈការយកឧត្តមានុវត្តន៍អន្តរជាតិទាំងនេះមកពិចារណា រដ្ឋអាចកាត់បន្ថយភាពមិនប្រាកដប្រជាផ្នែកច្បាប់កែលម្អសង្គតិភាពនៃបទប្បញ្ញត្តិ ពង្រឹងប្រសិទ្ធភាពស្ថាប័ន និងបង្កើនសុខដុមនីយកម្មប្រព័ន្ធច្បាប់អន្តរជាតិ។ ក្នុងន័យនេះ ឧត្តមានុវត្តន៍អន្តរជាតិទាំងនេះបានបំពេញតួនាទីជាឧបករណ៍ជាក់ស្តែងសម្រាប់ការកែទម្រង់ច្បាប់ ទោះបីជាមិនមានសន្ធិសញ្ញាផ្លូវការណាមួយតម្រូវឱ្យធ្វើការកែទម្រង់ក៏ដោយ។

ឥទ្ធិពលរបស់ឧត្តមានុវត្តន៍អន្តរជាតិទាំងនេះ អាចត្រូវបានមើលឃើញច្បាស់ក្នុងវិស័យដែលទាមទារឱ្យមានការជឿទុកចិត្តខ្ពស់ និងប្រតិបត្តិការឆ្លងដែរ។ ក្នុងវិស័យពាណិជ្ជកម្ម និងច្បាប់ពាណិជ្ជកម្មអន្តរជាតិ ឧត្តមានុវត្តន៍អន្តរជាតិទាំងនេះជួយបង្កើតច្បាប់ដែលមានភាពច្បាស់លាស់សម្រាប់កិច្ចសន្យា ប្រតិបត្តិការទូទាត់ប្រាក់ ឯកសារដឹកជញ្ជូន មជ្ឈត្តការ ការដោះស្រាយវិវាទ និងប្រតិបត្តិការអេឡិចត្រូនិក។ ក្នុងវិស័យហិរញ្ញវត្ថុ ឧត្តមានុវត្តន៍អន្តរជាតិទាំងនេះជួយកំណត់ស្តង់ដារសម្រាប់ការត្រួតពិនិត្យហិរញ្ញវត្ថុ សុចរិតភាពផ្នែកហិរញ្ញវត្ថុ ការប្រឆាំងអំពើពុករលួយ ការប្រឆាំងការលាងលុយ និងការពារភាពសុចរិតនៃទីផ្សារ។ ក្នុងវិស័យអភិបាលកិច្ចសាធារណៈ ឧត្តមានុវត្តន៍អន្តរជាតិទាំងនេះផ្តល់ជាគោលការណ៍ណែនាំសម្រាប់ការកែលម្អគុណភាពបទប្បញ្ញត្តិ ការសម្រួលនីតិវិធីរដ្ឋបាល ការផ្តល់សេវាសាធារណៈ ការទទួលខុសត្រូវ និងការសម្របសម្រួលស្ថាប័ន។ ក្នុងវិស័យវិជ្ជាជីវៈច្បាប់និងការដោះស្រាយវិវាទ ឧត្តមានុវត្តន៍អន្តរជាតិទាំងនេះជួយកំណត់ស្តង់ដារសីលធម៌វិជ្ជាជីវៈ នីតិវិធីដោះស្រាយវិវាទ និងការអនុវត្តន៍ជាមជ្ឈត្តករ។ ក្នុងវិស័យថ្មីៗ ដូចជា អភិបាលកិច្ចឌីជីថល បញ្ញាសិប្បនិម្មិត សន្តិសុខសាយប័រ និងការអភិវឌ្ឍប្រកបដោយចីរភាព ឧត្តមានុវត្តន៍អន្តរជាតិ ក៏កំពុងក្លាយជាមូលដ្ឋានសម្រាប់ការបង្កើតបទប្បញ្ញត្តិជាតិនៅពេលអនាគតផងដែរ។

ឧត្តមានុវត្តន៍អន្តរជាតិ ក៏មានតួនាទីសំខាន់ក្នុងការលើកកម្ពស់កេរ្តិ៍ឈ្មោះជាតិក្នុងសហគមន៍អន្តរជាតិផងដែរ។ នៅក្នុងបរិបទអន្តរជាតិសព្វថ្ងៃ គុណភាពនៃប្រព័ន្ធច្បាប់របស់ប្រទេសមួយ មិនត្រូវបានវាយតម្លៃតាមការមាននៃបទប្បញ្ញត្តិផ្លូវការប៉ុណ្ណោះទេ តែត្រូវបានវាស់តាមថាតើបទប្បញ្ញត្តិ និងស្ថាប័នទាំងនោះស្របនឹងវិធីសាស្ត្រអភិបាលកិច្ច និងបទប្បញ្ញត្តិដែលមានភាពជឿជាក់នៅកម្រិតអន្តរជាតិដែរឬទេ។ វិនិយោគិន ស្ថាប័នហិរញ្ញវត្ថុ អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍន៍ ជាញឹកញាប់យកស្តង់ដារអន្តរជាតិជាមូលដ្ឋានសម្រាប់វាយតម្លៃភាពជឿជាក់ ភាពចាស់ទុំ និងប្រសិទ្ធភាពនៃក្របខ័ណ្ឌច្បាប់ និងស្ថាប័នរបស់ប្រទេសមួយ។ ដូច្នេះ កម្រិតដែលប្រព័ន្ធច្បាប់ជាតិឆ្លុះបញ្ចាំងពីឧត្តមានុវត្តន៍ល្អដែលត្រូវបានទទួលស្គាល់ជាសកល មានឥទ្ធិពលជាក់ស្តែងលើការជឿទុកចិត្តពីសំណាក់វិនិយោគិន កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ លក្ខខណ្ឌហិរញ្ញប្បទាន និងកេរ្តិ៍ឈ្មោះអន្តរជាតិរបស់ប្រទេសមួយ។

ទោះជាយ៉ាងណាក៏ដោយ ឧត្តមានុវត្តន៍អន្តរជាតិមិនគួរត្រូវបានចម្លង ឬអនុវត្តតាមដោយផ្ទាល់ដោយគ្មានការពិចារណានោះទេ។ តម្លៃពិតប្រាកដរបស់ឧត្តមានុវត្តន៍អន្តរជាតិ មិនស្ថិតនៅលើការចម្លងទម្រង់ពីក្រៅនោះទេ ប៉ុន្តែស្ថិតនៅលើការកែសម្រួល និងការសម្របឱ្យស្របនឹងបរិបទជាតិ។ ការកែទម្រង់ច្បាប់ដែលមានប្រសិទ្ធភាព ត្រូវការការវាយតម្លៃយ៉ាងម៉ត់ចត់លើរចនាសម្ព័ន្ធរដ្ឋធម្មនុញ្ញ សមត្ថភាពស្ថាប័ន ប្រពៃណីច្បាប់ អាទិភាពអភិវឌ្ឍន៍ និងស្ថានភាពអនុវត្តជាក់ស្តែង។ ដូច្នេះ ការប្រើប្រាស់ឧត្តមានុវត្តន៍អន្តរជាតិ ត្រូវផ្អែកលើការពិចារណាជាយុទ្ធសាស្ត្រ ដើម្បីធានាថាគំរូពីក្រៅត្រូវបានបំលែងទៅជាការរៀបចំរបស់ជាតិដែលមានទាំងភាពជឿជាក់នៅកម្រិតអន្តរជាតិ និងភាពអាចអនុវត្តបានក្នុងបរិបទជាតិ។ នៅពេលមានការកែសម្រួលយ៉ាងសមស្រប ឧត្តមានុវត្តន៍អន្តរជាតិទាំងនេះអាចរួមចំណែកមិនត្រឹមតែដល់

ការធ្វើទំនើបកម្មផ្នែកច្បាប់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដល់សង្គតិភាព និងភាពធន់របស់ប្រព័ន្ធច្បាប់ជាតិផងដែរ។

សម្រាប់កម្ពុជា ឧត្តមានុវត្តន៍អន្តរជាតិទាំងនេះមានសារៈសំខាន់សម្រាប់ការពង្រឹងប្រព័ន្ធច្បាប់ និងសមត្ថភាពក្នុងការឆ្លើយតបទៅនឹងតម្រូវការជាតិនិងអន្តរជាតិ។ ខណៈពេលដែលកម្ពុជាចូលរួមកាន់តែជិតស្និទជាមួយក្របខ័ណ្ឌសេដ្ឋកិច្ច ច្បាប់ និងស្ថាប័ននៅកម្រិតតំបន់និងសកល ប្រព័ន្ធច្បាប់ជាតិត្រូវបានរំពឹងថានឹងដំណើរការដោយមានភាពតម្លាភាព អាចព្យាករណ៍បាន និងអនុលោមភាពជាមួយវិធីសាស្ត្រដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ។ នេះមិនមានន័យថា កម្ពុជាត្រូវចម្លងគំរូបរទេសដោយគ្មានការពិចារណានោះទេ ប៉ុន្តែមានន័យថា កម្ពុជាគួរត្រូវស្វែងរក វាយតម្លៃ និងឧត្តមានុវត្តន៍អន្តរជាតិដែលអាចជួយលើកកម្ពស់គុណភាពច្បាប់ កែលម្អប្រសិទ្ធភាពអភិបាលកិច្ច គាំទ្រកិច្ចសហប្រតិបត្តិការអន្តរជាតិ និងបង្កើនការជឿទុកចិត្តលើប្រព័ន្ធច្បាប់កម្ពុជា។ ក្នុងន័យនេះ ឧត្តមានុវត្តន៍អន្តរជាតិជាមូលដ្ឋានសំខាន់មួយក្នុងការកសាងក្របខ័ណ្ឌប្រព័ន្ធច្បាប់កម្ពុជាដែលមានបូរណភាព។

### ១.១.៤ សេចក្តីត្រូវការរបស់វិនិយោគិនបរទេស និងដៃគូពាណិជ្ជកម្មអន្តរជាតិ

ក្នុងសេដ្ឋកិច្ចសកលនាពេលច្ចុប្បន្ន វិនិយោគិនបរទេស និងដៃគូពាណិជ្ជកម្មអន្តរជាតិ មិនសម្រេចចិត្តវិនិយោគ ឬធ្វើពាណិជ្ជកម្មដោយផ្អែកតែទៅលើទំហំទីផ្សារ ធនធានធម្មជាតិ តម្លៃកម្លាំងពលកម្ម ឬទីតាំងភូមិសាស្ត្រប៉ុណ្ណោះទេ។ ការសម្រេចចិត្តរបស់ពួកគេ ក៏អាស្រ័យយ៉ាងខ្លាំងលើគុណភាព ភាពអាចព្យាករណ៍បាន និងភាពជឿជាក់នៃក្របខ័ណ្ឌច្បាប់ និងស្ថាប័នរបស់ប្រទេសដែលពួកគេមានបំណងវិនិយោគ និងធ្វើជាដៃគូពាណិជ្ជកម្មផងដែរ ហើយករណីភាគច្រើន ក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មតម្រូវឱ្យរដ្ឋដៃគូអនុវត្តតាមស្តង់ដារ GRP ជាដើម។ ក្នុងន័យនេះ ប្រព័ន្ធច្បាប់ដើរតួនាទីសំខាន់ក្នុងការបង្កើតការយល់ឃើញថា ប្រទេសណាមួយអាចជាទិសដៅដែលមានភាពជឿទុកចិត្ត ស្ថិរភាព និងមានសមត្ថភាពប្រកួតប្រជែងសម្រាប់ការវិនិយោគ ពាណិជ្ជកម្ម និងកិច្ចសហប្រតិបត្តិការអាជីវកម្មរយៈពេលវែង។ ដូច្នេះ សេចក្តីត្រូវការរបស់វិនិយោគិនបរទេស និងដៃគូពាណិជ្ជអន្តរជាតិ គឺជាប្រភពសំខាន់មួយនៃកត្តាខាងក្រៅដែលជំរុញការអភិវឌ្ឍ និងការកែទម្រង់ប្រព័ន្ធច្បាប់ជាតិ។

ជាដំបូង វិនិយោគិនបរទេស និងដៃគូពាណិជ្ជកម្មអន្តរជាតិ រមែងរំពឹងឱ្យប្រព័ន្ធច្បាប់មួយមានភាពច្បាស់លាស់ ភាពប្រាកដប្រជា និងភាពអាចព្យាករណ៍បាន។ ពួកគេត្រូវការយល់ដឹងច្បាស់អំពីច្បាប់ និងបទប្បញ្ញត្តិដែលគ្រប់គ្រងការចូលទីផ្សារ ការចុះបញ្ជីអាជីវកម្ម ការផ្តល់អាជ្ញាបណ្ណ ពន្ធដារ គយ ការងារ ការប្រើប្រាស់ដីធ្លី ការផ្ទេរប្រាក់បរទេស ការប្រកួតប្រជែង អនុលោមភាពតាមបទប្បញ្ញត្តិបរិស្ថាន ការដោះស្រាយវិវាទ និងការចាកចេញពីទីផ្សារ។ ក្របខ័ណ្ឌច្បាប់ដែលមានភាពមិនច្បាស់លាស់ បទប្បញ្ញត្តិផ្ទុយគ្នា ការបែងចែកសមត្ថកិច្ចមិនច្បាស់ ឬការអនុវត្តរដ្ឋបាលដែលមិនអាចព្យាករណ៍បាន អាចបង្កើនហានិភ័យ និងថ្លៃដើមប្រតិបត្តិការសម្រាប់អាជីវកម្ម។ ផ្ទុយទៅវិញ ប្រព័ន្ធច្បាប់ដែលមានសង្គតិភាព ងាយស្រួលក្នុង

ការចូលប្រើប្រាស់ និងមានការអនុវត្តដោយស្មើភាព អាចបង្កើតការជឿទុកចិត្តថាសកម្មភាពសេដ្ឋកិច្ចអាចប្រព្រឹត្តទៅក្នុងក្របខ័ណ្ឌដែលមានស្ថិរភាព និងផលចំណេញ។

លើសពីនេះ វិនិយោគិនបរទេសរំពឹងយ៉ាងខ្លាំងអំពីការការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ពួកគេ។ វិនិយោគិនជាទូទៅត្រូវការការធានាថា ទ្រព្យសម្បត្តិ កិច្ចសន្យា ការវិនិយោគ ទ្រព្យសកម្មអាជីវកម្ម និងប្រតិបត្តិការអាជីវកម្មរបស់ពួកគេ នឹងត្រូវបានការពារដោយច្បាប់ ហើយសកម្មភាពរដ្ឋដែលប៉ះពាល់ដល់ផលប្រយោជន៍ទាំងនេះ នឹងត្រូវគ្រប់គ្រងដោយបទប្បញ្ញត្តិច្បាស់លាស់ និងនីតិវិធីប្រកបដោយយុត្តិធម៌។ នេះរួមបញ្ចូលទាំងការរំពឹងទុកអំពីនីតិវិធីត្រឹមត្រូវ ការផ្តល់សំណងដោយស្មើភាព ការមិនរើសអើង និងដំណើរការយន្តការដោះស្រាយវិវាទដោយយុត្តធម៌។ ដៃពាណិជ្ជកម្មអន្តរជាតិ ក៏រំពឹងដូចគ្នាថា កាតព្វកិច្ចពាណិជ្ជកម្មនឹងអាចអនុវត្តបាន កិច្ចសន្យានឹងត្រូវគោរព និងមានយន្តការផ្លូវច្បាប់សម្រាប់ដោះស្រាយការបំពាន ឬវិវាទពាណិជ្ជកម្មយ៉ាងមានប្រសិទ្ធភាព។

វិនិយោគិនបរទេស និងដៃគូពាណិជ្ជកម្មអន្តរជាតិ ក៏ផ្តល់សារៈសំខាន់យ៉ាងខ្លាំងលើតម្លាភាពនៃបទប្បញ្ញត្តិ និងប្រសិទ្ធភាពនៃការគ្រប់គ្រងរដ្ឋបាលផងដែរ។ ពួកគេរំពឹងថា បទប្បញ្ញត្តិ និងតម្រូវការរដ្ឋបាលនានា ត្រូវមានផ្សព្វផ្សាយជាសាធារណៈ ងាយស្រួលក្នុងការស្វែងរក មានការពន្យល់ច្បាស់លាស់ មានស្ថិរភាព និងត្រូវបានអនុវត្តដោយគ្មានភាពស្មុគស្មាញ ឬភាពមិនច្បាស់លាស់។ នីតិវិធីដូចជា ការផ្តល់អាជ្ញាបណ្ណ ការអនុញ្ញាត គយ ពន្ធ កាតព្វកិច្ចរាយការណ៍ ការត្រួតពិនិត្យ និងការអនុលោមតាមបទប្បញ្ញត្តិ ត្រូវអនុវត្តតាមនីតិវិធីដែលមានភាពច្បាស់លាស់ និងមានពេលវេលាសមស្រប។ សមត្ថភាពរបស់អាជីវកម្មក្នុងការទទួលបានព័ត៌មានដែលអាចទុកចិត្តបាន ព្យាករណ៍ផលប៉ះពាល់ផ្នែកច្បាប់ និងធ្វើអន្តរកម្មជាមួយស្ថាប័នសាធារណៈតាមនីតិវិធីដែលមានតម្លាភាព គឺមានសារៈសំខាន់ដូចគ្នានឹងខ្លឹមសារនៃច្បាប់ផ្ទាល់ផងដែរ។

បន្ថែមពីនេះ វិនិយោគិនបរទេសក៏កាន់តែផ្តល់សារៈសំខាន់លើការសម្របសម្រួលរបស់ប្រព័ន្ធច្បាប់ជាមួយស្តង់ដារអន្តរជាតិស្តីពីសុចរិតភាពនៃអាជីវកម្ម និងសុចរិតភាពហិរញ្ញវត្ថុ។ នេះរួមមានការរំពឹងទុកអំពីវិធានការប្រឆាំងអំពើពុករលួយ ការគ្រប់គ្រងប្រឆាំងការលាងលុយ ស្តង់ដារអភិបាលកិច្ចសាជីវកម្ម តម្លាភាពកម្មសិទ្ធិ អនុលោមតាមបទប្បញ្ញត្តិពន្ធ ស្តង់ដារការងារ ការការពារបរិស្ថាន ការការពារអ្នកប្រើប្រាស់ និងការគ្រប់គ្រងទិន្នន័យ។ នៅពេលដែលប្រតិបត្តិការអាជីវកម្មកាន់តែមានលក្ខណៈសកល និងត្រូវគោរពតាមបទប្បញ្ញត្តិដែលមានលក្ខណៈឆ្លងដែន វិនិយោគិនកាន់តែយកចិត្តទុកដាក់លើថាតើប្រព័ន្ធច្បាប់របស់ប្រទេសមួយមានសមត្ថភាពគ្រប់គ្រាន់ក្នុងការគាំទ្រប្រតិបត្តិការអាជីវកម្មដែលមានភាពស្របច្បាប់ សុចរិត និងស្របតាមស្តង់ដារអន្តរជាតិដែរឬទេ។

ម្យ៉ាងវិញទៀត កត្តាសំខាន់ដែលវិនិយោគិន និងដៃគូពាណិជ្ជអន្តរជាតិយកចិត្តទុកដាក់ គឺប្រសិទ្ធភាពនៃយន្តការការពារ និងដោះស្រាយវិវាទ។ ពួកគេជាទូទៅចង់ឃើញក្របខ័ណ្ឌច្បាប់ដែលអាចកាត់បន្ថយការកើតមានវិវាទ តាមរយៈភាពច្បាស់លាស់នៃច្បាប់ ការសម្របសម្រួលស្ថាប័ន និងការគ្រប់គ្រងរដ្ឋ

បាលដែលមានយុត្តិធម៌។ ទោះជាយ៉ាងណាក៏ដោយ នៅពេលដែលវិវាទកើតឡើង ពួកគេរំពឹងថានឹងមានយន្តការដោះស្រាយវិវាទដែលមានយុត្តិធម៌ មានប្រសិទ្ធភាព អាចអនុវត្តបាន និងមានពេលវេលាសមស្រប មិនថាតាមរយៈតុលាការ មជ្ឈត្តការ សន្ទានកម្ម ឬនីតិវិធីរដ្ឋបាលផ្សេងៗឡើយ។ ភាពជឿជាក់នៃប្រព័ន្ធដោះស្រាយវិវាទ មានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់ប្រតិបត្តិការដែលមានលក្ខណៈឆ្លងដែន ព្រោះការជឿទុកចិត្តផ្នែកច្បាប់មិនអាស្រ័យត្រឹមតែការមានបទប្បញ្ញត្តិប៉ុណ្ណោះទេ ប៉ុន្តែអាស្រ័យលើសមត្ថភាពជាក់ស្តែងក្នុងការអនុវត្តសិទ្ធិ និងទទួលបានសំណងតាមផ្លូវច្បាប់។

ដៃគូពាណិជ្ជកម្មអន្តរជាតិក៏វាយតម្លៃប្រព័ន្ធច្បាប់របស់ប្រទេសមួយតាមរយៈសមត្ថភាពក្នុងការគាំទ្រពាណិជ្ជកម្មអន្តរជាតិ និងភាពជឿជាក់នៃសង្វាក់ផ្គត់ផ្គង់ផងដែរ។ នេះរួមមានគុណភាពនៃច្បាប់គយ និងការគ្រប់គ្រងគយ នីតិវិធីសម្រួលពាណិជ្ជកម្ម ស្តង់ដារផលិតផល តម្រូវការស្លាកសញ្ញា ការគ្រប់គ្រងការនាំចូល និងនាំចេញ បទប្បញ្ញត្តិសុខាភិបាល និងអនាម័យ ការការពារកម្មសិទ្ធិបញ្ញា បទប្បញ្ញត្តិដឹកជញ្ជូន និងការត្រៀមខ្លួនសម្រាប់ពាណិជ្ជកម្មឌីជីថល។ ប្រព័ន្ធច្បាប់ដែលមានភាពរាយប៉ាយ ឬពិបាកក្នុងការប្រើប្រាស់ អាចបង្កើតភាពមិនប្រាកដប្រជា មិនត្រឹមតែសម្រាប់វិនិយោគិនប៉ុណ្ណោះទេ ប៉ុន្តែសម្រាប់អ្នកទិញ អ្នកផ្គត់ផ្គង់ អ្នកចែកចាយ និងដៃគូពាណិជ្ជកម្មផងដែរ។

សម្រាប់កម្ពុជា សេចក្តីរំពឹងទុកទាំងនេះមានសារៈសំខាន់ខ្លាំង នៅពេលដែលកម្ពុជាកំពុងខិតខំពង្រឹងតួនាទីរបស់ខ្លួនជាទិសដៅវិនិយោគ ពង្រីកពាណិជ្ជកម្មអន្តរជាតិ និងបង្កើនសមាហរណកម្មក្នុងទីផ្សារតំបន់ និងសកល គុណភាពនៃប្រព័ន្ធច្បាប់ និងស្ថាប័នជាកត្តាយុទ្ធសាស្ត្រសំខាន់។ វិនិយោគិន និងដៃគូពាណិជ្ជកម្មអន្តរជាតិ នឹងវាយតម្លៃកម្ពុជា មិនត្រឹមតែតាមឱកាសសេដ្ឋកិច្ចប៉ុណ្ណោះទេ ប៉ុន្តែតាមភាពប្រាកដប្រជាផ្នែកច្បាប់ សង្គតិភាពនៃបទប្បញ្ញត្តិ ភាពជឿជាក់នៃស្ថាប័ន ប្រសិទ្ធភាពរដ្ឋបាល និងភាពអាចទុកចិត្តបាននៃប្រព័ន្ធដោះស្រាយវិវាទផងដែរ។

ដូច្នេះ សេចក្តីរំពឹងទុករបស់វិនិយោគិនបរទេស និងដៃពាណិជ្ជអន្តរជាតិ ជាកត្តាគោលនយោបាយសំខាន់មួយក្នុងការកសាងក្របខ័ណ្ឌប្រព័ន្ធច្បាប់កម្ពុជា។ ប្រព័ន្ធច្បាប់ដែលមានតម្លាភាព អាចព្យាករណ៍បាន ការពារសិទ្ធិ មាននីតិវិធីយុត្តិធម៌ មានការសម្របសម្រួលស្ថាប័នល្អ និងស្របនឹងការអនុវត្តអាជីវកម្មអន្តរជាតិ អាចជួយលើកកម្ពស់ភាពទាក់ទាញ ភាពជឿជាក់ និងភាពធន់រឹងរបស់កម្ពុជា ក្នុងបរិបទសកល។ ផ្ទុយទៅវិញ ប្រព័ន្ធច្បាប់ដែលនៅតែមានភាពរាយប៉ាយ មិនច្បាស់លាស់ ឬពិបាកក្នុងការប្រើប្រាស់ អាចបន្ថយការជឿទុកចិត្ត បង្កើនថ្លៃដើមប្រតិបត្តិការ និងបន្ថយសមត្ថភាពរបស់កម្ពុជា ក្នុងការទទួលបានអត្ថប្រយោជន៍ពេញលេញពីសមាហរណកម្មសេដ្ឋកិច្ចអន្តរជាតិ។ ដូច្នេះ ការយល់ដឹង និងការឆ្លើយតបទៅនឹងសេចក្តីរំពឹងទុករបស់វិនិយោគិន និងដៃពាណិជ្ជកម្មអន្តរជាតិ គឺជាផ្នែកសំខាន់មួយក្នុងការពង្រឹងប្រព័ន្ធច្បាប់កម្ពុជាសម្រាប់នាពេលអនាគត។

### ១.១.៥ សេចក្តីត្រូវការរបស់ជនបរទេស

នៅក្នុងពិភពលោកមានការតភ្ជាប់គ្នាយ៉ាងជិតស្និទ្ធ ប្រព័ន្ធច្បាប់របស់ប្រទេសមួយ មិនត្រូវបានវាយតម្លៃត្រឹមតែដោយរដ្ឋាភិបាល វិនិយោគិន ឬស្ថាប័នអន្តរជាតិប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដោយបុគ្គលបរទេសដែលធ្វើដំណើរមកទស្សនា ស្នាក់នៅ ធ្វើការ សិក្សា ឬចូលរួមសកម្មភាពផ្សេងៗនៅក្នុងប្រទេសនោះផងដែរ។ ភ្ញៀវបរទេស និងអ្នកស្នាក់អាស្រ័យបរទេស គឺជាក្រុមភាគីពាក់ព័ន្ធមួយសំខាន់។ ទោះបីជាការរំពឹងទុករបស់ពួកគេខុសពីវិនិយោគិន ឬអ្នកធ្វើពាណិជ្ជកម្មក៏ដោយ ក៏វាមានសារៈសំខាន់ដូចគ្នាសម្រាប់ការកំណត់ភាពជឿជាក់ ភាពទាក់ទាញ និងកេរ្តិ៍ឈ្មោះអន្តរជាតិរបស់ប្រព័ន្ធច្បាប់ជាតិ។ ដូច្នេះ សេចក្តីរំពឹងទុករបស់ភ្ញៀវបរទេស និងអ្នកស្នាក់អាស្រ័យបរទេស ជាផ្នែកមួយសំខាន់នៃបរិបទសកលដែលប្រព័ន្ធច្បាប់ជាតិមួយត្រូវគិតគូផងដែរ។

ជាទូទៅ ភ្ញៀវបរទេស និងអ្នកស្នាក់អាស្រ័យបរទេស តែងរំពឹងនូវក្របខ័ណ្ឌច្បាប់មួយដែលមានស្ថិរភាព សណ្តាប់ធ្នាប់ និងភាពអាចព្យាករណ៍បានក្នុងកម្រិតសមស្រប រំពឹងឱ្យរដ្ឋធានាការរក្សាសន្តិសុខសាធារណៈ ការពារសុវត្ថិភាពផ្ទាល់ខ្លួន ការគោរពសិទ្ធិមូលដ្ឋាន និងការផ្តល់ភាពប្រាកដប្រជាផ្នែកច្បាប់ក្នុងការប្រាស្រ័យទាក់ទងជាមួយអាជ្ញាធរសាធារណៈ អ្នកផ្តល់សេវាឯកជន និយោជក ម្ចាស់ផ្ទះជួល ស្ថាប័នអប់រំ និងបុគ្គល ឬអង្គភាពផ្សេងៗ។ ជាធម្មតា បុគ្គលបរទេសដែលចូលមក ឬស្នាក់នៅក្នុងប្រទេសណាមួយ រំពឹងថាច្បាប់ និងនីតិវិធីដែលពាក់ព័ន្ធនឹងអន្តោប្រវេសន៍ ទិដ្ឋាការ ការចុះបញ្ជី ការស្នាក់នៅ ការអនុញ្ញាតការងារ ការធ្វើដំណើរ សុខាភិបាលសាធារណៈ ការស្នាក់នៅ និងការប្រើសេវាសាធារណៈ នឹងមានភាពច្បាស់លាស់ តម្លាភាពជាសាធារណៈ និងត្រូវបានអនុវត្តដោយយុត្តិធម៌ និងងាយយល់។ នៅពេលដែលច្បាប់មិនច្បាស់ នីតិវិធីមិនមានសង្គតិភាព ឬការអនុវត្តមានលក្ខណៈមិនស្មើភាព នោះការជឿទុកចិត្តលើក្របខ័ណ្ឌច្បាប់របស់ប្រទេសនោះនឹងត្រូវបានប៉ះពាល់ជាអវិជ្ជមាន។

ភ្ញៀវបរទេស និងអ្នកស្នាក់អាស្រ័យបរទេស ក៏រំពឹងថានឹងទទួលបានដំណោះស្រាយដោយស្មើភាពនៅចំពោះមុខច្បាប់ និងការការពារផ្លូវច្បាប់ក្នុងកម្រិតសមស្របផងដែរ។ ទោះបីជាពួកគេមិនមានស្ថានភាពផ្លូវច្បាប់ដូចជាពលរដ្ឋជាតិគ្រប់ករណីក៏ដោយ ក៏ពួកគេជាទូទៅរំពឹងថាប្រព័ន្ធច្បាប់នឹងការពារពួកគេចំពោះអំពើហិង្សា ការក្លែងបន្លំ ការកេងប្រវ័ញ្ច ការរើសអើង ការប្រើអំណាចមិនត្រឹមត្រូវ និងការរំលោភលើសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ពួកគេ។ ពួកគេក៏រំពឹងថានឹងអាចចូលដំណើរការយន្តការបណ្តឹងនីតិវិធីរដ្ឋបាល ការការពារពីសំណាក់នគរបាល ការស្វែងរកយុត្តិធម៌តាមតុលាការ និងយន្តការដោះស្រាយវិវាទផ្សេងៗ នៅពេលដែលមានវិវាទ ឬការខូចខាតកើតឡើង។ ប្រព័ន្ធច្បាប់ដែលមិនអាចផ្តល់ការការពារដែលងាយស្រួល និងយុត្តិធម៌សម្រាប់បុគ្គលបរទេស អាចប៉ះពាល់អវិជ្ជមានដល់កេរ្តិ៍ឈ្មោះរបស់ប្រទេសក្នុងផ្នែកសុវត្ថិភាព បដិសណ្ឋារកិច្ច យុត្តិធម៌ និងភាពជឿជាក់លើស្ថាប័ន។

សម្រាប់កម្ពុជា សេចក្តីរំពឹងទុកទាំងនេះកាន់តែមានសារៈសំខាន់ នៅពេលដែលកម្ពុជាកំពុងពង្រីកការចូលរួមក្នុងក្របខ័ណ្ឌអន្តរជាតិ ទេសចរណ៍អន្តរជាតិ ការងារបរទេស ការផ្លាស់ប្តូរការអប់រំ កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងពាណិជ្ជកម្មអន្តរជាតិ ចំនួន និងភាពចម្រុះនៃជនបរទេសដែលធ្វើអន្តរកម្មជាមួយប្រព័ន្ធច្បាប់ជាតិនឹងកើនឡើង។ បទពិសោធន៍របស់ពួកគេ នឹងត្រូវកំណត់ដោយភាពច្បាស់លាស់នៃច្បាប់អន្តោប្រវេសន៍ ភាពងាយស្រួលក្នុងការប្រើព័ត៌មានសាធារណៈ ភាពយុត្តិធម៌នៃការអនុវត្តច្បាប់ ប្រសិទ្ធភាពនៃនីតិវិធីរដ្ឋបាល និងភាពជឿជាក់នៃយន្តការការពារផ្លូវច្បាប់។ បញ្ហាទាំងនេះមិនត្រឹមតែប៉ះពាល់ដល់អារម្មណ៍ និងការជឿទុកចិត្តរបស់បុគ្គលនោះទេ ប៉ុន្តែថែមទាំងប៉ះពាល់ដល់រូបភាពអន្តរជាតិទំនុកចិត្តសង្គម ភាពស្របច្បាប់នៃស្ថាប័ន និងភាពទាក់ទាញរបស់កម្ពុជាជាទិសដៅសម្រាប់ទេសចរណ៍ ការស្នាក់នៅ ការងារ ការសិក្សា និងកិច្ចសហប្រតិបត្តិការអន្តរជាតិ។

ដូច្នេះ សេចក្តីរំពឹងទុករបស់ភ្ញៀវបរទេស និងអ្នកស្នាក់អាស្រ័យបរទេស ជាកត្តាគោលនយោបាយសំខាន់មួយក្នុងការអភិវឌ្ឍក្របខ័ណ្ឌប្រព័ន្ធច្បាប់កម្ពុជា។ ប្រព័ន្ធច្បាប់ដែលអាចធានាសុវត្ថិភាព ភាពយុត្តិធម៌ ភាពងាយស្រួលក្នុងការប្រើប្រាស់ ភាពអាចព្យាករណ៍បាន និងការការពារសិទ្ធិជាក់ស្តែងសម្រាប់បុគ្គលបរទេស អាចជួយពង្រឹងភាពជឿជាក់របស់កម្ពុជានៅលើឆាកអន្តរជាតិ និងគាំទ្រគោលដៅជាតិនានា ដូចជា ទេសចរណ៍ វិនិយោគ ការអប់រំ ការចល័តកម្លាំងពលកម្ម និងកិច្ចសហប្រតិបត្តិការអន្តរជាតិ។ ផ្ទុយទៅវិញ បរិយាកាសច្បាប់ដែលពិបាកយល់ មិនមានសង្គតភាព មាននីតិវិធីស្មុគស្មាញ ឬមិនអាចការពារសិទ្ធិបានយ៉ាងមានប្រសិទ្ធភាព អាចបន្ថយការជឿទុកចិត្ត និងធ្វើឱ្យកម្ពុជាខ្សោយសមត្ថភាពប្រកួតប្រជែងក្នុងបរិបទសកលដែលកាន់តែមានការប្រកួតប្រជែង និងការតភ្ជាប់គ្នាខ្លាំងឡើង។ ដូច្នេះ ការយកចិត្តទុកដាក់លើបទពិសោធន៍ផ្នែកច្បាប់របស់ភ្ញៀវបរទេស និងអ្នកស្នាក់អាស្រ័យបរទេស គឺជាផ្នែកសំខាន់មួយនៃការពង្រឹងប្រព័ន្ធច្បាប់ជាតិ។

### ១.១.៦ យន្តការវាយតម្លៃអភិបាលកិច្ចអន្តរជាតិ

នៅក្នុងបរិបទសកលនាពេលបច្ចុប្បន្ន គុណភាពនៃប្រព័ន្ធច្បាប់ និងស្ថាប័នរបស់ប្រទេសមួយ មិនត្រូវបានវាយតម្លៃត្រឹមតែតាមរយៈរចនាសម្ព័ន្ធរដ្ឋធម្មនុញ្ញ ច្បាប់ដែលបានអនុម័ត ឬគោលនយោបាយផ្លូវការប៉ុណ្ណោះទេ តែក៏ត្រូវបានវាយតម្លៃតាមរយៈយន្តការវាយតម្លៃអភិបាលកិច្ចអន្តរជាតិជាច្រើន ដែលមានគោលបំណងវាស់វែងអំពី ប្រសិទ្ធភាពនៃការអនុវត្តអំណាចសាធារណៈ ការអនុវត្តច្បាប់ជាក់ស្តែង និងសមត្ថភាពរបស់ស្ថាប័នរដ្ឋ ក្នុងទិដ្ឋភាពនីតិរដ្ឋ ការទទួលខុសត្រូវ តម្លាភាព គុណភាពបទប្បញ្ញត្តិ ការប្រឆាំងអំពើពុករលួយ បរិយាកាសធុរកិច្ច ស្ថិរភាព និងលទ្ធផលអភិវឌ្ឍន៍ជាទូទៅ។ យន្តការវាយតម្លៃទាំងនេះបានក្លាយជាផ្នែកមួយសំខាន់នៃបរិបទសកល ដែលតាមរយៈនោះប្រទេសនានាត្រូវបានត្រួតពិនិត្យ វាយតម្លៃ និងប្រៀបធៀបដោយភាគីខាងក្រៅ។

យន្តការវាយតម្លៃអភិបាលកិច្ចអន្តរជាតិ មិនមានលក្ខណៈដូចគ្នាទាំងអស់នោះទេ ហើយក៏មិនមានក្របខ័ណ្ឌផ្លូវច្បាប់ដូចគ្នាទាំងអស់ផងដែរ។ មួយចំនួនជាដំណើរការត្រួតពិនិត្យផ្លូវការដែលបង្កើតឡើងក្រោមក្របខ័ណ្ឌអន្តរជាតិ ឬពហុភាគី ខណៈដែលមួយចំនួនទៀតមានទម្រង់ជាសូចនាករប្រមូលផ្តុំ សន្ទស្សន៍ផ្អែកលើការយល់ឃើញ ឧបករណ៍ប្រៀបធៀបប្រតិបត្តិការ ប្រព័ន្ធពិនិត្យដោយសមាជិកដូចគ្នា ឬសេចក្តីវិភាគស្ថិតិដែលត្រូវបានបង្កើតឡើងដោយស្ថាប័នអន្តរជាតិ មជ្ឈមណ្ឌលស្រាវជ្រាវ ឬបណ្តាញគោលនយោបាយផ្សេងៗ។ ទោះបីមានភាពខុសគ្នាទាំងនេះក៏ដោយ យន្តការទាំងនេះមានតួនាទីស្រដៀងគ្នា គឺផ្តល់ក្របខ័ណ្ឌវាយតម្លៃជាប្រព័ន្ធសម្រាប់វាស់វែងគុណភាព ភាពជឿជាក់ និងប្រសិទ្ធភាពនៃអភិបាលកិច្ច និងបរិយាកាសច្បាប់របស់ប្រទេសមួយ និងអាចប្រៀបធៀបបានទាំងតាមពេលវេលា និងរវាងប្រទេសនានា។ តាមរយៈដំណើរការនេះ វិនិយោគិន ដៃគូអភិវឌ្ឍន៍ រដ្ឋបរទេស ស្ថាប័នអន្តរជាតិ សង្គមស៊ីវិល និងសហគមន៍អន្តរជាតិទូទៅអាចកំណត់ការយល់ឃើញរបស់ពួកគេលើកេរ្តិ៍ឈ្មោះរបស់ប្រទេសណាមួយ។

លក្ខណៈសំខាន់មួយនៃយន្តការទាំងនេះ គឺការផ្តោតលើការអនុវត្តជាក់ស្តែងនៃប្រព័ន្ធច្បាប់ និងស្ថាប័ន មិនមែនត្រឹមតែទម្រង់ផ្លូវការនៃច្បាប់ប៉ុណ្ណោះទេ។ និយាយម្យ៉ាងទៀត គឺមិនត្រឹមតែសួរថា តើមានច្បាប់នៅលើក្រដាសឬអត់នោះទេ ប៉ុន្តែសួរថា តើអំណាចរដ្ឋត្រូវបានកំណត់ដោយច្បាប់ឬទេ តើស្ថាប័នមានតម្លាភាព និងអនុវត្តស្មើភាពឬទេ តើអំពើពុករលួយត្រូវបានគ្រប់គ្រងឬទេ តើប្រព័ន្ធបទប្បញ្ញត្តិមានប្រសិទ្ធភាពឬទេ តើយុត្តិធម៌មានភាពងាយស្រួល និងអព្យាក្រឹតឬទេ និងតើរដ្ឋបាលសាធារណៈអាចគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមបានយ៉ាងមានប្រសិទ្ធភាពឬទេ។ ការបែងចែកនេះមានសារៈសំខាន់ ពីព្រោះប្រព័ន្ធច្បាប់មួយអាចមានរចនាសម្ព័ន្ធលម្អិតតាមទ្រឹស្តី ប៉ុន្តែអាចនៅតែខ្សោយក្នុងការអនុវត្ត មានភាពបែកបាក់ក្នុងប្រតិបត្តិការ ឬមានលទ្ធផលមិនមានសង្គតិភាព។ ដូច្នេះ យន្តការវាយតម្លៃអន្តរជាតិកាន់តែផ្តោតលើប្រសិទ្ធភាពជាក់ស្តែង ភាពជឿជាក់នៃស្ថាប័ន និងបទពិសោធន៍អនុវត្តក្នុងស្ថានភាពជាក់ស្តែង។

យន្តការទាំងនេះពាក់ព័ន្ធនឹងវិស័យគោលនយោបាយជាច្រើន មួយចំនួនផ្តោតជាចម្បងលើនីតិរដ្ឋ រួមទាំងភាពយុត្តិធម៌ ភាពងាយស្រួលក្នុងការប្រើប្រាស់ និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌រដ្ឋប្បវេណី និងព្រហ្មទណ្ឌ ការគ្រប់គ្រងអំណាចរដ្ឋ និងការការពារសិទ្ធិមូលដ្ឋាន។ មួយចំនួនទៀតផ្តោតលើអំពើពុករលួយ ភាពសុចរិតសាធារណៈ និងកម្រិតដែលការសម្រេចចិត្តរដ្ឋត្រូវរងឥទ្ធិពលដោយការប្រើអំណាចមិនត្រឹមត្រូវ ឬដោយប្រព័ន្ធទទួលខុសត្រូវដែលនៅមានកម្រិត។ មួយចំនួនផ្សេងទៀតវាស់វែងគុណភាពបទប្បញ្ញត្តិ ប្រសិទ្ធភាពរដ្ឋាភិបាល បរិយាកាសធុរកិច្ច ការផ្តល់សេវាសាធារណៈ ភាពប្រកួតប្រជែងសេដ្ឋកិច្ច ស្ថិរភាព សុខុមាលភាពសង្គម និងសមត្ថភាពនៃការច្នៃប្រឌិត។ ជារួម ឧបករណ៍វាយតម្លៃទាំងនេះផ្តល់រូបភាពច្រើនទិដ្ឋភាពអំពីការប្រព្រឹត្តទៅនៃប្រព័ន្ធច្បាប់ និងអភិបាលកិច្ចរបស់ប្រទេសមួយ ជាក់ស្តែង និងអំពីចំណុចខ្លាំង ឬចំណុចខ្សោយដែលអាចមាន។

យន្តការវាយតម្លៃអភិបាលកិច្ចអន្តរជាតិ ក៏មានឥទ្ធិពលដល់ការជឿទុកចិត្តរបស់ភាគីខាងក្រៅលើស្ថាប័នរដ្ឋ ការសម្រេចចិត្តរបស់វិនិយោគិន និងពាណិជ្ជករ លក្ខខណ្ឌនៃកិច្ចសហប្រតិបត្តិការជាមួយដៃគូ

អភិវឌ្ឍន៍ និងស្ថាប័នហិរញ្ញវត្ថុ ហើយជួយដឹកនាំការពិភាក្សាគោលនយោបាយ ការកំណត់អាទិភាពកែទម្រង់ និងការវិភាគប្រៀបធៀប។ លទ្ធផលនៃការវាយតម្លៃអភិបាលកិច្ចអាចប៉ះពាល់មិនត្រឹមតែកេរ្តិ៍ឈ្មោះអន្តរជាតិរបស់ប្រទេសមួយប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងប៉ះពាល់ដល់កម្រិតជឿទុកចិត្តលើប្រព័ន្ធច្បាប់ កម្រិតហានិភ័យសម្រាប់ការធ្វើអាជីវកម្ម និងភាពជឿជាក់នៃបរិយាកាសច្បាប់ទូទៅផងដែរ។

ទោះជាយ៉ាងណា យន្តការទាំងនេះក៏ត្រូវយល់ដោយប្រុងប្រយ័ត្នផងដែរ។ មិនមានសន្ទស្សន៍ ឬការវាយតម្លៃណាមួយដែលអាចបង្ហាញបានពេញលេញអំពីភាពស្មុគស្មាញនៃប្រព័ន្ធច្បាប់ និងស្ថាប័នរបស់ប្រទេសមួយឡើយ។ វិធីសាស្ត្រវាស់វែងមានភាពខុសគ្នា សូចនាករខ្លះអាចផ្អែកលើការសន្មត់ ឬមានកម្រិតកំណត់ ហើយយន្តការមួយចំនួនក៏ពឹងផ្អែកផ្នែកលើការយល់ឃើញ ការស្ទង់មតិអ្នកជំនាញ ឬទិន្នន័យស្ថាប័នជាក់លាក់ផងដែរ។ ដូច្នេះ ការវាយតម្លៃអភិបាលកិច្ចអន្តរជាតិ មិនគួរត្រូវបានយកជាការវិនិច្ឆ័យចុងក្រោយដោយឡែកឡើយ។ ផ្ទុយទៅវិញ វាគួរត្រូវបានប្រើជាឧបករណ៍សម្គាល់ទិសដៅ ដែលអាចជួយបង្ហាញលំនាំ បង្ហាញចំណុចដែលត្រូវពិចារណា ជួយសម្រួលការរៀនពីបទពិសោធន៍ប្រទេសផ្សេង និងជួយគាំទ្រការវិភាគជាក់លាក់ក្នុងស្រុក។ នៅពេលប្រើប្រាស់យ៉ាងប្រុងប្រយ័ត្ន វាអាចក្លាយជាឧបករណ៍មានតម្លៃសម្រាប់ការវិនិច្ឆ័យបញ្ហាអភិបាលកិច្ច និងកំណត់អាទិភាពសម្រាប់ការកែទម្រង់ច្បាប់ និងស្ថាប័ន។

សម្រាប់កម្ពុជា យន្តការវាយតម្លៃអភិបាលកិច្ចអន្តរជាតិ មានសារៈសំខាន់ខ្លាំងចំពោះការខិតខំពង្រឹងប្រព័ន្ធច្បាប់ និងកែទម្រង់អភិបាលកិច្ច។ ខណៈពេលដែលកម្ពុជាពង្រីកការចូលរួមក្នុងក្របខ័ណ្ឌអន្តរជាតិ ការអនុវត្តច្បាប់ និងស្ថាប័នរបស់កម្ពុជា កាន់តែត្រូវបានត្រួតពិនិត្យ និងវាយតម្លៃតាមរយៈសូចនាករអន្តរជាតិដែលពាក់ព័ន្ធនឹងនីតិរដ្ឋ ការគ្រប់គ្រងអំពើពុករលួយ គុណភាពបទប្បញ្ញត្តិ បរិយាកាសធុរកិច្ច ប្រសិទ្ធភាពស្ថាប័ន និងលទ្ធផលអភិវឌ្ឍន៍។ យន្តការទាំងនេះមិនត្រឹមតែមានឥទ្ធពលដល់កេរ្តិ៍ឈ្មោះជាតិនោះទេ តែក៏ជាមូលដ្ឋានដ៏មានប្រយោជន៍សម្រាប់ការវាយតម្លៃលើកិច្ចដំណើរការជាក់ស្តែងនៃប្រព័ន្ធច្បាប់កម្ពុជា និងវិស័យណាដែលត្រូវការការយកចិត្តទុកដាក់បន្ថែមក្នុងបរិបទនៃការអភិវឌ្ឍប្រព័ន្ធច្បាប់រយៈពេលវែង។

ដូច្នេះ យន្តការវាយតម្លៃអភិបាលកិច្ចអន្តរជាតិ ជាកត្តាគោលនយោបាយសំខាន់មួយក្នុងការកសាងក្របខ័ណ្ឌប្រព័ន្ធច្បាប់កម្ពុជា ដែលបង្ហាញថា តើបទប្បញ្ញត្តិច្បាប់ត្រូវបានបំលែងទៅជាការអនុវត្តស្ថាប័នយ៉ាងដូចម្តេច និងថាតើប្រព័ន្ធអាចបង្កើតការជឿទុកចិត្ត ភាពអាចព្យាករណ៍បាន ភាពយុត្តិធម៌ និងការអនុវត្តមានប្រសិទ្ធភាពបានយ៉ាងដូចម្តេច។ នៅពេលប្រើប្រាស់ត្រឹមត្រូវ យន្តការទាំងនេះអាចគាំទ្រគិតគូជាយុទ្ធសាស្ត្រ ការកែទម្រង់ផ្អែកលើភស្តុតាង និងការសម្របសម្រួលល្អប្រសើររវាងការអភិវឌ្ឍច្បាប់ ការកែទម្រង់អភិបាលកិច្ច និងគោលដៅអភិវឌ្ឍជាតិរបស់កម្ពុជា។ ដូច្នេះ យន្តការវាយតម្លៃអភិបាលកិច្ចអន្តរជាតិ គឺជាផ្នែកសំខាន់មួយសម្រាប់ការស្វែងយល់ វាយតម្លៃ និងពង្រឹងប្រព័ន្ធច្បាប់កម្ពុជា ក្នុងបរិបទសកលសម័យបច្ចុប្បន្ន។

### ១.១.៧ បច្ចេកវិទ្យា

នាពេលបច្ចុប្បន្ន បច្ចេកវិទ្យា និងឌីជីថលូបនីយកម្ម បានក្លាយជាកត្តាចលករសំខាន់មួយដែលជំរុញអន្តរកម្មផ្នែកច្បាប់ និងស្ថាប័ន។ ការវិវត្តន៍យ៉ាងឆាប់រហ័សនៃហេដ្ឋារចនាសម្ព័ន្ធឌីជីថល ប្រតិបត្តិការអេឡិចត្រូនិក ការគ្រប់គ្រងដោយផ្អែកលើទិន្នន័យ បញ្ញាសិប្បនិម្មិត សេដ្ឋកិច្ចឌីជីថល សេវាឌីជីថលឆ្លងដែន និងសន្តិសុខសាយប័រ បាននឹងកំពុងផ្លាស់ប្តូររបៀបដែលរដ្ឋធ្វើបទប្បញ្ញត្តិលើសកម្មភាពសេដ្ឋកិច្ច គ្រប់គ្រងសេវាសាធារណៈ ការពារសិទ្ធិ គ្រប់គ្រងហានិភ័យ និងធ្វើអន្តរកម្មជាមួយបុគ្គល និងពាណិជ្ជកម្ម។ ដូច្នេះ ប្រព័ន្ធច្បាប់កាន់តែត្រូវឆ្លើយតបមិនត្រឹមតែចំពោះបញ្ហាអភិបាលកិច្ចបែបប្រពៃណីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងចំពោះផលប៉ះពាល់ផ្នែកបទប្បញ្ញត្តិដែលកើតឡើងពីការវិវត្តន៍បច្ចេកវិទ្យាផងដែរ។ ក្នុងន័យនេះ បច្ចេកវិទ្យា និងឌីជីថលូបនីយកម្ម មិនមែនជាបញ្ហាបច្ចេកទេសរបស់ការធ្វើទំនើបកម្មប៉ុណ្ណោះទេ ប៉ុន្តែជាកត្តាសំខាន់ក្នុងការអភិវឌ្ឍប្រព័ន្ធច្បាប់សម័យទំនើប។

បច្ច័យដ៏សំខាន់មួយនៃឌីជីថលូបនីយកម្ម គឺការផ្លាស់ប្តូរកម្មវត្ថុ វិធីសាស្ត្រ និងល្បឿននៃការរៀបចំបទប្បញ្ញត្តិច្បាប់។ បច្ចេកវិទ្យាថ្មីៗបានបង្កើតទម្រង់សកម្មភាពសេដ្ឋកិច្ច និងសង្គមថ្មីៗ ដែលមិនតែងតែអាចសម្របចូលទៅក្នុងប្រភេទច្បាប់បែបប្រពៃណី ដូចជា ពាណិជ្ជកម្មឌីជីថល កិច្ចសន្យាអនឡាញ ការផ្ទេរទិន្នន័យឆ្លងដែន ការទូទាត់តាមប្រព័ន្ធឌីជីថល ឯកសារអេឡិចត្រូនិក សេវាផ្អែកលើថ្នាលឌីជីថល ទ្រព្យសកម្មឌីជីថល ប្រព័ន្ធសម្រេចចិត្តដោយស្វ័យប្រវត្តិ និងប្រព័ន្ធបញ្ញាសិប្បនិម្មិត។ ការវិវត្តន៍ទាំងនេះបង្កើតទាំងឱកាស និងបញ្ហាប្រឈមផ្នែកបទប្បញ្ញត្តិ។ មួយផ្នែក វាអាចបង្កើនប្រសិទ្ធភាព កាត់បន្ថយថ្លៃដើមប្រតិបត្តិការ ពង្រីកការប្រើប្រាស់ កែលម្អសមត្ថភាពរដ្ឋ និងគាំទ្រការច្នៃប្រឌិត។ ផ្នែកមួយទៀត វាអាចបង្កើតភាពមិនប្រាកដប្រជាផ្នែកច្បាប់ ចន្លោះក្នុងការអនុវត្ត បញ្ហាការប្រើប្រាស់បច្ចេកវិទ្យាមិនត្រឹមត្រូវ ហានិភ័យសាយប័រ ការប្រមូលផ្តុំអំណាចឌីជីថល ភាពងាយរងគ្រោះនៃទិន្នន័យ និងបញ្ហាក្នុងការកំណត់ការទទួលខុសត្រូវ។ ដូច្នេះ ប្រព័ន្ធច្បាប់ត្រូវអភិវឌ្ឍឱ្យទាន់សម័យ ដើម្បីធានាថាការអភិវឌ្ឍបច្ចេកវិទ្យាអាចប្រព្រឹត្តទៅក្នុងក្របខ័ណ្ឌនៃភាពស្របច្បាប់ យុត្តិធម៌ សុវត្ថិភាព និងការជឿទុកចិត្តជាសាធារណៈ។

បច្ចេកវិទ្យា និងឌីជីថលូបនីយកម្ម ក៏មានបច្ច័យដល់ការប្រព្រឹត្តទៅផ្ទៃក្នុងរបស់រដ្ឋផងដែរ ដែលស្ថាប័នសាធារណៈកាន់តែត្រូវបានរំពឹងឱ្យផ្តល់សេវាឌីជីថល គ្រប់គ្រងព័ត៌មានតាមប្រព័ន្ធអេឡិចត្រូនិក ប្រើប្រាស់ទិន្នន័យឱ្យមានប្រសិទ្ធភាព សម្របសម្រួលការងាររវាងស្ថាប័ន និងកែលម្អការឆ្លើយតបចំពោះប្រជាពលរដ្ឋ និងអាជីវកម្មតាមរយៈថ្នាលឌីជីថល។ តុលាការ និយតករ ស្ថាប័នរដ្ឋបាល អាជ្ញាធរអនុវត្តច្បាប់ គយ ពន្ធ និងស្ថាប័នផ្តល់សេវាសាធារណៈផ្សេងៗ សុទ្ធតែត្រូវបានប៉ះពាល់ដោយការវិវត្តន៍នេះ។ ដូច្នេះ ប្រព័ន្ធច្បាប់មិនត្រឹមតែត្រូវមានសមត្ថភាពក្នុងការធ្វើបទប្បញ្ញត្តិលើសេដ្ឋកិច្ចឌីជីថលប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវគាំទ្រការអនុវត្តអភិបាលកិច្ចឌីជីថលនៅក្នុងស្ថាប័នសាធារណៈផងដែរ។ នេះតម្រូវឱ្យមានក្របខ័ណ្ឌច្បាប់ដែលគ្របដណ្តប់លើបញ្ហាដូចជា ឯកសារអេឡិចត្រូនិក អត្តសញ្ញាណឌីជីថល ការភ្ជាប់

ប្រព័ន្ធរវាងស្ថាប័ន នីតិវិធីអនឡាញ តម្លាភាពរដ្ឋបាល ការគ្រប់គ្រងទិន្នន័យ ភស្តុតាងឌីជីថល សន្តិសុខសាយប័រ និងការធានាសុវត្ថិភាពនៃការសម្រេចចិត្តដែលប្រើបច្ចេកវិទ្យា។

បទដ្ឋានគោលនយោបាយសំខាន់មួយនៃឌីជីថលូបនីយកម្ម គឺការរក្សាសមតុល្យរវាងភាពច្នៃប្រឌិត និងការការពារ។ បច្ចេកវិទ្យាថ្មីៗ ជាពិសេសបញ្ញាសិប្បនិម្មិត និងប្រព័ន្ធដែលផ្អែកលើទិន្នន័យ មានសក្តានុពលខ្លាំងសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច ការធ្វើទំនើបកម្មរដ្ឋ និងការកែលម្អការធ្វើសេចក្តីសម្រេចចិត្ត។ ទោះជាយ៉ាងណា វាក៏បង្កើតបញ្ហាផ្នែកច្បាប់ និងសីលធម៌ ពាក់ព័ន្ធនឹងឯកជនភាព ការការពារទិន្នន័យផ្ទាល់ខ្លួន ការរើសអើងដោយប្រព័ន្ធស្វ័យប្រវត្តិ សិទ្ធិអ្នកប្រើប្រាស់ តម្លាភាព និងការទទួលខុសត្រូវចំពោះការខូចខាត។ ដូចគ្នានេះដែរ ការកើនឡើងនៃពាណិជ្ជកម្មឌីជីថល និងហិរញ្ញវត្ថុឌីជីថល បង្កើតឱកាសសម្រាប់ការចូលរួមសេដ្ឋកិច្ចកាន់តែទូលំទូលាយ ប៉ុន្តែក៏តម្រូវឱ្យមានការការពារខ្លាំងជាងមុនប្រឆាំងនឹងការក្លែងបន្លំ ឧក្រិដ្ឋកម្មសាយប័រ ហិរញ្ញវត្ថុខុសច្បាប់ និងការប្រើប្រាស់ប្រព័ន្ធមិនត្រឹមត្រូវផងដែរ។ ដូច្នេះ ប្រព័ន្ធច្បាប់សម័យទំនើបត្រូវមានសមត្ថភាពគាំទ្រការអភិវឌ្ឍបច្ចេកវិទ្យា និងធានាការការពារប្រយោជន៍សាធារណៈ និងជំនឿទុកចិត្តរបស់សង្គម។

ឌីជីថលូបនីយកម្មក៏ពាក់ព័ន្ធនឹងការសម្របសម្រួលផ្លូវច្បាប់ឆ្លងដែនផងដែរ រួមមានពាណិជ្ជកម្មឌីជីថល ប្រតិបត្តិការអេឡិចត្រូនិក សេវាអនឡាញ ការគ្រប់គ្រងទិន្នន័យ និងសន្តិសុខសាយប័រ ដែលមិនអាចកំណត់នៅក្នុងព្រំដែនជាតិតែមួយបានទេ។ ដូច្នេះ រដ្ឋត្រូវអភិវឌ្ឍក្របខ័ណ្ឌច្បាប់ដែលស្របគ្នាជាមួយស្តង់ដារអន្តរជាតិ និងតម្រូវការនៃការអន្តរកម្មឆ្លងដែន។ ពាណិជ្ជករ វិនិយោគិន អ្នកផ្តល់សេវា និងបុគ្គលដែលចូលរួមក្នុងសកម្មភាពឌីជីថល រំពឹងឱ្យប្រព័ន្ធច្បាប់ផ្តល់ភាពច្បាស់លាស់លើប្រតិបត្តិការអេឡិចត្រូនិក ការប្រើប្រាស់ទិន្នន័យ កាតព្វកិច្ចសន្តិសុខសាយប័រ ការគ្រប់គ្រងថ្នាលឌីជីថល ការការពារអ្នកប្រើប្រាស់ និងសុពលភាពផ្លូវច្បាប់នៃឯកសារ និងកិច្ចព្រមព្រៀងឌីជីថល។

សម្រាប់កម្ពុជា បច្ចេកវិទ្យា និងឌីជីថលូបនីយកម្ម កាន់តែមានសារៈសំខាន់ក្នុងការអភិវឌ្ឍប្រព័ន្ធច្បាប់ជាតិ។ នៅពេលដែលកម្ពុជាកំពុងអភិវឌ្ឍរដ្ឋាភិបាលឌីជីថល ពាណិជ្ជកម្មអេឡិចត្រូនិក បច្ចេកវិទ្យាហិរញ្ញវត្ថុ សេវាឌីជីថល និងការតភ្ជាប់ទូរគមនាគមន៍ ប្រព័ន្ធច្បាប់ត្រូវប្រឈមមុខនឹងតម្រូវការកាន់តែខ្លាំងក្នុងការគ្រប់គ្រងសកម្មភាពថ្មីៗ ការពារសិទ្ធិ និងប្រយោជន៍សាធារណៈ និងបង្កើតបរិយាកាសឌីជីថលដែលមានសុវត្ថិភាព និងជឿជាក់បាន។ នេះរួមមានការកែលម្អភាពច្បាស់លាស់ផ្នែកច្បាប់ក្នុងវិស័យប្រតិបត្តិការអេឡិចត្រូនិក រដ្ឋបាលឌីជីថល សន្តិសុខសាយប័រ ការគ្រប់គ្រងទិន្នន័យ ការការពារអ្នកប្រើប្រាស់ ភស្តុតាងឌីជីថល សកម្មភាពវេទិកាឌីជីថល និងបច្ចេកវិទ្យាថ្មីៗ ដូចជា បញ្ញាសិប្បនិម្មិត។

ដូច្នេះ បច្ចេកវិទ្យា និងឌីជីថលូបនីយកម្ម ជាកត្តាគោលនយោបាយសំខាន់មួយក្នុងការអភិវឌ្ឍក្របខ័ណ្ឌប្រព័ន្ធច្បាប់កម្ពុជា។ ប្រព័ន្ធច្បាប់ដែលអាចឆ្លើយតបទៅនឹងការផ្លាស់ប្តូរបច្ចេកវិទ្យាដែលមានគោលការណ៍ មានការសម្របសម្រួល និងមានទិសដៅឆ្ពោះទៅអនាគត អាចគាំទ្រភាពច្នៃប្រឌិត កែលម្អ

ការផ្តល់សេវាសាធារណៈ ពង្រឹងប្រសិទ្ធភាពបទប្បញ្ញត្តិ និងលើកកម្ពស់ភាពប្រកួតប្រជែង និងភាពធន់រឹងរបស់កម្ពុជានៅក្នុងបរិបទសកល។ ផ្ទុយទៅវិញ ប្រព័ន្ធច្បាប់ដែលនៅតែមានភាពរាយប៉ាយ ឬមិនសម្របខ្លួនទៅនឹងបរិបទឌីជីថល អាចបង្កើតភាពមិនប្រាកដប្រជា បន្ថយការការពារសាធារណៈ និងកាត់បន្ថយសមត្ថភាពរបស់កម្ពុជាក្នុងការទទួលបានអត្ថប្រយោជន៍ពីសេដ្ឋកិច្ចឌីជីថល។ ដូច្នេះ ការយកចិត្តទុកដាក់លើកត្តាបច្ចេកវិទ្យា គឺជាផ្នែកសំខាន់ក្នុងការកំណត់ និងពង្រឹងប្រព័ន្ធច្បាប់កម្ពុជាសម្រាប់ពេលអនាគត។

## ១.២. បរិបទរបស់កម្ពុជា

ក្រៅពីការពិចារណាអំពីបរិបទសកល ការកសាងប្រព័ន្ធច្បាប់មួយដែលមានបូរណភាពគឺអាស្រ័យជាចម្បងទៅលើបរិបទជាតិ។ មូលដ្ឋានរដ្ឋធម្មនុញ្ញ របៀបវារៈនយោបាយរបស់រដ្ឋាភិបាល យន្តការកែទម្រង់ច្បាប់ វឌ្ឍនភាពនៃការអភិវឌ្ឍនជាតិ ធនធានមនុស្ស និងសេចក្តីត្រូវការរបស់សង្គម ជាកត្តាផ្ទៃក្នុងសំខាន់សម្រាប់ការកសាងប្រព័ន្ធច្បាប់ដែលឆ្លើយតបទៅនឹងតម្រូវការសង្គម ធានានិរន្តរភាពអភិបាលកិច្ចជាតិ និងជាយានជម្រុញការសម្រេចបាននូវចក្ខុវិស័យជាតិរយៈពេលវែង។ ហេតុនេះ ការកសាងប្រព័ន្ធច្បាប់ពុំផ្អែកត្រឹមគោលការណ៍ធម្មនុញ្ញប៉ុណ្ណោះទេ តែក៏ត្រូវឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងរបស់សង្គម និងចក្ខុវិស័យសម្រាប់អនាគត។

រដ្ឋធម្មនុញ្ញជាច្បាប់កំពូលរបស់រដ្ឋដែលកំណត់នូវគោលការណ៍គ្រឹះនៃកសាងប្រព័ន្ធច្បាប់ សម្រាប់អភិបាលកិច្ចរដ្ឋនិងសង្គមទាំងមូល ព្រមទាំងកិច្ចការអន្តរជាតិ។ សម្រាប់អភិបាលកិច្ចរដ្ឋ រដ្ឋធម្មនុញ្ញបានកំណត់អំពីអធិបតេយ្យភាពជាតិ បូរណភាពដែនដី ប្រព័ន្ធនយោបាយ ប្រព័ន្ធសេដ្ឋកិច្ច ប្រព័ន្ធរដ្ឋបាល និងការបែងចែកអំណាច។ ចំពោះអភិបាលកិច្ចសង្គម រដ្ឋធម្មនុញ្ញបានកំណត់អំពីសិទ្ធិមូលដ្ឋានរបស់ ពលរដ្ឋ ភាសាផ្លូវការ និងសាសនារដ្ឋ។ រីឯកិច្ចការអន្តរជាតិ រដ្ឋធម្មនុញ្ញបានកំណត់គោលការណ៍ដែល ត្រូវធានាធម្មនុញ្ញភាពចំពោះរាល់ការចូលរួមក្នុងក្របខ័ណ្ឌអន្តរជាតិ។ គោលការណ៍គ្រឹះទាំងនេះជាមូលដ្ឋានក្នុងការរៀបចំក្របខ័ណ្ឌច្បាប់ និងស្ថាប័នគោលនៅក្នុងប្រព័ន្ធច្បាប់ជាតិ។

ការវិវត្តន៍នៃប្រព័ន្ធច្បាប់ក៏អាស្រ័យទៅតាមរបៀបវារៈនយោបាយរបស់ប្រមុខដឹកនាំនៅតាមនីតិកាលនីមួយៗក្រោយពីទទួលបានការផ្តល់សេចក្តីទុកចិត្តពីសង្គមទាំងមូលតាមរយៈការបោះឆ្នោត។ របៀបវារៈនយោបាយទាំងនេះរួមមានចក្ខុវិស័យជាតិ កម្មវិធីនយោបាយ យុទ្ធសាស្ត្រនិងផែនការជាតិ ក្របខ័ណ្ឌច្បាប់។ របៀបវារៈនយោបាយនេះគ្របដណ្តប់លើគ្រប់ទិដ្ឋភាពរបស់ប្រទេសជាតិទាំងមូលទាំង ការការពារជាតិ និងការអភិវឌ្ឍជាតិ ដែលជាមូលដ្ឋានគ្រឹះសំខាន់សម្រាប់ការអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ ស្របតាមចក្ខុវិស័យរបស់ប្រមុខដឹកនាំ។ ដូចនេះការកែទម្រង់ និងការប្រព្រឹត្តទៅនៃប្រព័ន្ធច្បាប់មាន តួនាទីជាចលករក្នុងការសម្រេចឱ្យបាននូវចក្ខុវិស័យទាំងនេះ។

ក្រៅពីនេះការកែទម្រង់ និងការវិវត្តន៍នៃប្រព័ន្ធច្បាប់ក៏ចាំបាច់ត្រូវឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងរបស់សង្គមទាំងមូល។ ការអនុវត្តកម្មវិធីនយោបាយ ឬច្បាប់ដែលមានខ្លឹមសារ តែពុំសមស្រប និងឆ្លើយតបទៅនឹងស្ថានភាពនិងតម្រូវការជាក់ស្តែង នោះនឹងនាំឱ្យខ្លឹមសារទាំងនោះមានត្រឹមតែក្នុងក្រដាសតែពុំប្រែក្លាយទៅជាការអនុវត្តនោះទេ។ វឌ្ឍនភាពនៃការអភិវឌ្ឍន៍សង្គមជាតិ និងស្ថានភាព ធនធានមនុស្សនៅក្នុងសង្គម ជាកត្តាសំខាន់ក្នុងការធានារដ្ឋមានសមត្ថភាពក្នុងការអនុវត្ត និងប្រជាពល រដ្ឋមានលទ្ធភាពក្នុងការប្រតិបត្តិកម្មវិធីនយោបាយនិងច្បាប់ប្រកបដោយប្រសិទ្ធភាព។ ក្នុងន័យនេះ ការកសាងក្របខ័ណ្ឌប្រព័ន្ធច្បាប់ចាំបាច់ត្រូវឆ្លើយតបទៅនឹងស្ថានភាពនិងតម្រូវការសង្គមជាក់ស្តែងផងដែរ។

ដើម្បីរៀបចំក្របខ័ណ្ឌប្រព័ន្ធច្បាប់កម្ពុជាឱ្យមានប្រសិទ្ធិភាព គ្រប់ជ្រុងជ្រោយ និងឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់សង្គម យើងត្រូវពិនិត្យមើលលើបរិបទជាតិដែលជះឥទ្ធិពលលើប្រព័ន្ធច្បាប់ក្នុងនោះរួមមាន គោលនយោបាយ រដ្ឋធម្មនុញ្ញ សេដ្ឋកិច្ច សង្គម និងទិសដៅអភិវឌ្ឍន៍ជាតិ។ ប្រព័ន្ធច្បាប់មិនត្រឹមតែជាសំណុំនៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តប៉ុណ្ណោះទេ ប៉ុន្តែជាផ្នែកមួយនៃការកសាងរដ្ឋ ការកំណត់គោលនយោបាយសាធារណៈ ការបង្កើតនិងពង្រឹងស្ថាប័ន ការវិវត្តនៃសេដ្ឋកិច្ចនិងសង្គម ព្រមទាំងការលើកកម្ពស់សមត្ថភាពធនធានមនុស្សក្នុងវិស័យច្បាប់ផងដែរ។ ក្នុងបរិបទកម្ពុជា ការកសាង ការកែទម្រង់ និងដំណើរការនៃប្រព័ន្ធច្បាប់ត្រូវផ្អែកដោយផ្ទាល់ និងដោយប្រយោលពីឯកសារគោលនយោបាយជាតិធំៗ ក្របខ័ណ្ឌបទដ្ឋានគតិយុត្ត របៀបវារៈកំណែទម្រង់ស្ថាប័ន និងបរិបទអភិវឌ្ឍន៍ជាក់ស្តែងរបស់ប្រទេស។

សម្រាប់កម្ពុជាក្នុងដំណើរឆ្ពោះទៅការសម្រេចបាននូវបូរណភាពនៃប្រព័ន្ធច្បាប់ ចាំបាច់ត្រូវអនុលោមតាមគោលការណ៍គ្រឹះដែលមានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញ របៀបវារៈនយោបាយរួមមាន កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៧សម្រាប់ការកសាងនិងការពារជាតិ ២០២៣-២០២៨ ចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់ រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល និងក្របខ័ណ្ឌគតិយុត្តនៃការកែទម្រង់។ ក្រៅពីនោះ ប្រព័ន្ធច្បាប់កម្ពុជាក៏ត្រូវឆ្លើយតបទៅនឹងស្ថានភាព សង្គមនិងសេដ្ឋកិច្ចជាក់ស្តែងផងដែល។

ក្នុងបរិបទនេះ ការកសាងប្រព័ន្ធច្បាប់កម្ពុជាដែលមានភាពច្បាស់លាស់ សង្គតិភាព និងពេញលេញពុំត្រឹមជាការរៀបរចនាសម្ព័ន្ធស្របតាមរដ្ឋធម្មនុញ្ញនោះទេ តែត្រូវធានាសមត្ថភាពរបស់ប្រព័ន្ធ ទាំងមូលដើម្បីអនុវត្តកម្មវិធីនយោបាយរបស់រដ្ឋាភិបាលតាមនីតិកាលនីមួយៗ ព្រមទាំងនិងតម្រូវការ សង្គមជាក់ស្តែង។ ក្របខ័ណ្ឌប្រព័ន្ធច្បាប់នេះនឹងធានាប្រសិទ្ធភាព ប្រក្រតីភាព និងនិរន្តរភាពនៃអភិបាល កិច្ចរដ្ឋនិងសង្គមប្រកបដោយបរិយាបន្ននិងភាពធន់ ព្រមទាំងជាយានដ៏សំខាន់សម្រាប់សម្រេចបាននូវ ចក្ខុវិស័យវែងឆ្ងាយរបស់ជាតិទាំងមូល។

### ១.២.១ រដ្ឋធម្មនុញ្ញ

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន មានអាយុកាល ៣៣ ឆ្នាំ និងបានឆ្លងកាត់ការធ្វើវិសោធនកម្មចំនួន ១១ លើក។ រដ្ឋធម្មនុញ្ញនេះបានកំណត់ឱ្យកម្ពុជាជាព្រះរាជាណាចក្រ អាស្រ័យរដ្ឋធម្មនុញ្ញជារដ្ឋឯករាជ្យ មិនអាចបំបែកបាន មានភាសាខ្មែរជាភាសាជាតិ សាសនាព្រះពុទ្ធជាសាសនារដ្ឋ និងមានបូរណភាពដែនដីក្នុងផ្ទៃក្រឡា ១៨១ ០៣៥ គីឡូម៉ែត្រក្រឡា។ ក្នុងនោះផងដែរ រដ្ឋធម្មនុញ្ញបានកំណត់ឱ្យប្រទេសកម្ពុជាប្រកាន់យករបបប្រជាធិបតេយ្យសេរីពហុបក្ស ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ និងគោលការណ៍បែងចែកអំណាចជាអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។

ក្នុងពេលដូចគ្នានេះ រដ្ឋធម្មនុញ្ញក៏ធានាសិទ្ធិមនុស្សមូលដ្ឋានផងដែរ តាមរយៈការកំណត់ឱ្យមានអនុលោមភាពជាមួយសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស និងអនុសញ្ញាសំខាន់ៗអន្តរជាតិជាច្រើន រួមមាន អនុសញ្ញាស្ដីពីសិទ្ធិពលរដ្ឋ និងនយោបាយ អនុសញ្ញាស្ដីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ព្រមទាំងអនុសញ្ញាស្ដីពីសិទ្ធិកុមារ និងសិទ្ធិនារី។ ការកំណត់នេះបង្ហាញពីការប្ដេជ្ញាចិត្តរបស់រដ្ឋក្នុងការធានាការគោរពសិទ្ធិមនុស្ស និងការសម្របសម្រួលប្រព័ន្ធច្បាប់ជាតិឱ្យស្របទៅនឹងស្តង់ដារអន្តរជាតិ។

លើសពីនេះ រដ្ឋធម្មនុញ្ញក៏បានកំណត់អំពីស្ថាប័នឯករាជ្យសំខាន់ៗមួយចំនួន ដើម្បីធាននានិរន្តរភាព និងការគោរពរដ្ឋធម្មនុញ្ញ រួមមាន ក្រុមប្រឹក្សាធម្មនុញ្ញ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងឧត្តមក្រុមប្រឹក្សារាជសម្បត្តិ។ ស្ថាប័នទាំងនេះមានតួនាទីសំខាន់ក្នុងការពង្រឹងគោលការណ៍នីតិរដ្ឋ ការធានាប្រព័ន្ធប្រជាធិបតេយ្យ និងការគ្រប់គ្រងរដ្ឋអំណាចឱ្យស្ថិតនៅក្រោមក្របខ័ណ្ឌច្បាប់។

ការកំណត់ខាងលើបង្ហាញថា រដ្ឋធម្មនុញ្ញមានតួនាទីជាឯកសារគោលដំបូងក្នុងការកំណត់**និ**ម្មាបនកម្ម និងគោលការណ៍មូលដ្ឋាននៃប្រព័ន្ធច្បាប់ជាតិ។ ទោះជាយ៉ាងណា រដ្ឋធម្មនុញ្ញមិនបានរៀបចំលម្អិតអំពីរចនាសម្ព័ន្ធ និងក្របខ័ណ្ឌប្រព័ន្ធច្បាប់ទាំងមូលនោះទេ។ ក្នុងន័យនេះ បន្ទាប់ពីស្ថាប័នធម្មនុញ្ញត្រូវបានបង្កើតឡើង និងច្បាប់មូលដ្ឋាននានាត្រូវបានអនុម័ត ការរៀបចំក្របខ័ណ្ឌប្រព័ន្ធច្បាប់ឱ្យមានលក្ខណៈច្បាស់លាស់ សង្គតិភាព និងមានប្រសិទ្ធភាព កាន់តែមានសារៈសំខាន់។ ការរៀបចំបែបនេះ ធានាថាប្រព័ន្ធច្បាប់ជាតិអាចដំណើរការបានប្រកបដោយសមត្ថភាព ស្ថិរភាព និងអាចឆ្លើយតបទៅនឹងតម្រូវការកាន់តែច្រើននៃសង្គម និងស្ថានភាពសេដ្ឋកិច្ច សង្គម និងនយោបាយដែលកាន់តែមានភាពស្មុគស្មាញ។

### ១.២.២ ចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០

ចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០ គឺជាការបង្ហាញពីឆន្ទៈបំណងដ៏មោះមុតរបស់ថ្នាក់ដឹកនាំជាតិក្នុងការប្រែក្លាយកម្ពុជាទៅជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ ចក្ខុវិស័យនេះបង្ហាញពីទិសដៅវែងឆ្ងាយនៃការអភិវឌ្ឍជាតិ ដែលផ្ដោតលើការកសាងប្រទេសមួយមានសេដ្ឋកិច្ចរឹងមាំ សង្គមសុខដុមរមនា និងប្រព័ន្ធគ្រប់គ្រងរដ្ឋប្រកបដោយប្រសិទ្ធភាព ស្របតាមគោលការណ៍នីតិរដ្ឋ និងការអភិវឌ្ឍប្រកបដោយចីរភាព។

ចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០ ត្រូវបានកំណត់ដូចតទៅ៖ នៅមុនដំណាច់ឆ្នាំ ២០៥០, កម្ពុជានឹងក្តាប់យកមកវិញនូវមោទនភាពជាតិដែលធ្លាប់រុងរឿងពីអតីតកាល ជាមួយនឹងការកសាងជាតិទំនើបមួយដ៏រស់រវើក, ជារដ្ឋរឹងមាំ និងប្រជាធិបតេយ្យ ដែលមានឯករាជ្យ, អធិបតេយ្យ និង បូរណភាពទឹកដីពេញលេញ ហើយមានកិត្យានុភាពខ្ពស់ត្រដែត, ស្មើភាព និងស្មើសិទ្ធិលើឆាកអន្តរជាតិ, ជាប្រទេសមានចំណូល ខ្ពស់, មានសេដ្ឋកិច្ចធន់មាំ ប្រកបដោយបរិយាបន្ន និងចីរភាព, ជាប្រទេសដែលមានប្រជាជនរស់នៅក្នុង សុខសន្តភាព, សេចក្តីថ្លៃថ្នូរ និងសុភមង្គល, មានកម្រិតជីវភាពខ្ពស់សមរម្យ, និង មានចំណេះដឹងខ្ពស់ ប្រកបដោយនវានុវត្ត និង សីលធម៌ប្រពៃ, ទទួលបានយុត្តិធម៌សង្គម, ស្មើសិទ្ធិ និង ស្មើឱកាស ក្នុងសង្គម ជាតិ ព្រមទាំងមានអត្តសញ្ញាណជាតិដ៏បវរ និង ភាពចម្រើនលូតលាស់ ក្នុងបរិស្ថាន សង្គម, រូបវន្ត និង ធម្មជាតិ ប្រកបដោយភាពសុខុដុមរមនា, មានវប្បធម៌សម្បូរបែប និងសង្គមបរិយាបន្ន។

ការសម្រេចបាននូវចក្ខុវិស័យនេះ ទាមទារឱ្យមានប្រព័ន្ធគ្រប់គ្រងរដ្ឋ និងស្ថាប័នសាធារណៈដែលមានប្រសិទ្ធភាព ព្រមទាំងប្រព័ន្ធច្បាប់ជាតិដែលមានលក្ខណៈច្បាស់លាស់ សង្គតិភាព និងអាចគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងនវានុវត្ត។ ប្រព័ន្ធច្បាប់មានតួនាទីសំខាន់ក្នុងការបង្កើតបរិយាកាសស្ថិរភាព និងភាពជឿជាក់សម្រាប់ការវិនិយោគ ការអភិវឌ្ឍវិស័យឯកជន ការគ្រប់គ្រងធនធានជាតិ ការការពារបរិស្ថាន និងការធានាសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋ។ ក្នុងន័យនេះ ការអភិវឌ្ឍ និងការរៀបចំប្រព័ន្ធច្បាប់ជាតិឱ្យមានលក្ខណៈសមស្រប សង្គតភាព និងមានប្រសិទ្ធភាព គឺជាមូលដ្ឋានសំខាន់មួយសម្រាប់គាំទ្រដល់ការសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០ និងការបង្កើតសង្គមមួយដែលមានស្ថិរភាព វិបុលភាព និងយុត្តិធម៌សង្គម។

### ១.២.៣ កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា សម្រាប់ការកសាង និង ការការពារមាតុភូមិ ឆ្នាំ២០២៣-២០២៨

កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា សម្រាប់ការកសាង និងការពារមាតុភូមិ ឆ្នាំ២០២៣–២០២៨ គឺជារបៀបវារៈគោលនយោបាយជាតិដ៏សំខាន់ សម្រាប់ចាប់ផ្តើមបេសកកម្មជាប្រវត្តិសាស្ត្រក្នុងការបម្រើជាតិ មាតុភូមិ និងប្រជាជន បន្ទាប់ពីទទួលបានការគាំទ្រពីសង្គមទាំងមូលតាមរយៈដំណើរការបោះឆ្នោតតាមបែបប្រជាធិបតេយ្យ។ កម្មវិធីនយោបាយនេះកំណត់ទិសដៅសំខាន់សម្រាប់ការអភិវឌ្ឍជាតិ និងការគ្រប់គ្រងរដ្ឋ ក្នុងរយៈពេល៥ឆ្នាំខាងមុខ ដោយផ្អែកលើគោលការណ៍នីតិរដ្ឋ ការគោរពរដ្ឋធម្មនុញ្ញ និងការអភិវឌ្ឍប្រទេសប្រកបដោយស្ថិរភាព និងចីរភាព។

កម្មវិធីនយោបាយនេះបានកំណត់នូវគោលដៅធំៗជាយុទ្ធសាស្ត្រ របស់រាជរដ្ឋាភិបាលរួមមាន៖ ១- ការពារសន្តិភាព, ការពារឯករាជ្យ, អធិបតេយ្យ, បូរណភាពទឹកដី និង ការពាររាល់សមិទ្ធផលនៃសង្គមជាតិ ឱ្យបានគង់វង្សស្ថិតស្ថេរ, ២- កសាងព្រះរាជាណាចក្រកម្ពុជា ជារដ្ឋប្រជាធិបតេយ្យសេរី ពហុបក្ស ដ៏ជឿនលឿន និង រឹងមាំ ដែលផ្អែកលើច្បាប់, មានសេដ្ឋកិច្ចរីកចម្រើន ប្រកបដោយចីរភាព និង សមធម៌,

ប្រជាជនមានជីវភាពសម្បូរសប្បាយ រស់នៅយ៉ាងសុខដុមរមនា ប្រកបដោយកិត្តិយស, សេចក្តីថ្លៃថ្នូរ និង មានការគោរពសិទ្ធិមនុស្ស, ៣- កសាងប្រព័ន្ធគាំពារសង្គមប្រកបដោយបរិយាប័ន្ន, ប្រសិទ្ធភាព និង ចីរភាពហិរញ្ញវត្ថុ ដែលធានាការផ្តល់ការគាំពារដល់ប្រជាជន ក្នុងការឆ្លើយតបចំពោះហានិភ័យសេដ្ឋកិច្ច, ហានិភ័យសុខភាពសាធារណៈ និងភាពងាយរងគ្រោះផ្សេងៗ ដែលកើតឡើងពីការប្រែប្រួលលក្ខខណ្ឌនៃការងារ និង ការរស់នៅ, ៤- ជម្រុញការអនុវត្ត "កម្ពុជាគ្មានមីនត្រឹមឆ្នាំ២០២៥" និងកាត់បន្ថយគ្រាប់មិនទាន់ផ្ទុះឱ្យបានជាអតិបរមា, និង៥- បន្តអនុវត្តនយោបាយការបរទេសឯករាជ្យ ដោយផ្អែកលើច្បាប់, កសាងមិត្តភាព និងកិច្ចសហប្រតិបត្តិការល្អប្រសើរ រវាងព្រះរាជាណាចក្រកម្ពុជាជាមួយប្រទេសទាំងអស់នៅលើសកលលោក និង អង្គការអន្តរជាតិនានា ហើយចូលរួមយ៉ាងសកម្ម ចំពោះបុព្វហេតុសន្តិភាព, ស្ថិរភាព, សន្តិសុខ, និង វិបុលភាព ក្នុងតំបន់ និង ពិភពលោក។

ការកំណត់គោលដៅយុទ្ធសាស្ត្រទាំងនេះ មិនត្រឹមតែជាទិសដៅនយោបាយសម្រាប់ការគ្រប់គ្រងរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានន័យសំខាន់ចំពោះការអភិវឌ្ឍ និងការរៀបចំប្រព័ន្ធច្បាប់ជាតិផងដែរ។ ការអនុវត្តគោលដៅទាំងនេះតម្រូវឱ្យមានប្រព័ន្ធច្បាប់ដែលមានលក្ខណៈច្បាស់លាស់ សង្គតិភាព និងមានប្រសិទ្ធភាព ដើម្បីគាំទ្រដល់ការគ្រប់គ្រងរដ្ឋ ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងការធានាសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋ។ ក្នុងន័យនេះ ប្រព័ន្ធច្បាប់ជាតិមានតួនាទីសំខាន់ក្នុងការប្រែក្លាយគោលនយោបាយរបស់រាជរដ្ឋាភិបាលទៅជាវិធានការច្បាប់ និងគោលការណ៍គ្រប់គ្រងជាក់ស្តែង តាមរយៈការបង្កើត កែសម្រួល និងអនុវត្តច្បាប់នានា ក្នុងវិស័យសន្តិសុខជាតិ សេដ្ឋកិច្ច សង្គម ការគាំពារសង្គម បរិស្ថាន និងកិច្ចសហប្រតិបត្តិការអន្តរជាតិ។ ដូច្នេះ ការអភិវឌ្ឍប្រព័ន្ធច្បាប់ឱ្យមានលក្ខណៈសមស្រប និងសង្គតិភាព គឺជាផ្នែកសំខាន់មួយក្នុងការគាំទ្រដល់ការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល និងការធានាថាគោលដៅអភិវឌ្ឍជាតិអាចសម្រេចបានយ៉ាងមានប្រសិទ្ធភាព និងចីរភាព។

### ១.២.៤ យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១

យុទ្ធសាស្ត្របញ្ចកោណ ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព គឺជាយុទ្ធសាស្ត្រអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ចរយៈពេលវែងរបស់រាជរដ្ឋាភិបាល ដែលត្រូវអនុវត្តជាបន្តបន្ទាប់ចំនួន ៥ ដំណាក់កាល។ យុទ្ធសាស្ត្រនេះមានគោលបំណងដឹកនាំដំណើរការអភិវឌ្ឍប្រទេសជាតិឱ្យឆ្ពោះទៅរកកំណើនសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន សមធម៌ និងចីរភាព ព្រមទាំងការលើកកម្ពស់សមត្ថភាពប្រកួតប្រជែង និងភាពធន់នៃសេដ្ឋកិច្ចជាតិ ក្នុងបរិបទនៃការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនៃសេដ្ឋកិច្ច និងបរិស្ថានសកល។

ក្នុងនោះ យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ត្រូវបានកំណត់ជារបៀបវារៈគោលនយោបាយសង្គម សេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា សម្រាប់អនុវត្តក្នុងរយៈពេល ៥ ឆ្នាំ ដោយមានគោលបំណងការពារ ថែរក្សា និងពូនជ្រំសមិទ្ធផលជាតិដែលសម្រេចបានក្នុងអតីតកាល ព្រមទាំងកសាង

មូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍបន្តឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០ ដែលមានគោលដៅប្រែក្លាយកម្ពុជាទៅជាប្រទេសមានចំណូលខ្ពស់ ប្រកបដោយអរិយធម៌រុងរឿង និងសង្គមសុខុដុមរមនា។

យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ បន្តផ្តោតជាសំខាន់លើរបៀបវារៈធានា "ប្រសិទ្ធភាព និងសមិទ្ធកម្ម" តាមរយៈការអនុវត្តអភិក្រម "ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់" ដែលមានគោលបំណងពង្រឹងប្រសិទ្ធភាព និងភាពស្អាតស្អំក្នុងការគ្រប់គ្រងរដ្ឋបាលសាធារណៈ។ ជាមួយគ្នានេះផងដែរ យុទ្ធសាស្ត្រនេះក៏ផ្អែកលើអភិក្រម "ដវភាពនៃប្រព័ន្ធតួអង្គតែមួយ" (Dynamics of Stakeholder System) ដែលផ្តោតលើការសហការរវាងស្ថាប័នរដ្ឋ វិស័យឯកជន និងសង្គមស៊ីវិល ក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃការអភិវឌ្ឍជាតិ។

ទន្ទឹមនឹងនេះ យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ក៏បានកំណត់អាទិភាពគន្លឹះចំនួន៥ គឺ "មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា" ដែលជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋ។ គោលដៅចម្បងនៃយុទ្ធសាស្ត្រនេះ មួយវិញគឺការរក្សាចលនាការណ៍នៃសុខសន្តិភាព កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍជារួម និងមួយវិញទៀតគឺការកសាង និងពង្រឹងមូលដ្ឋានគ្រឹះសម្រាប់ជំរុញសម្ទុះនៃការអភិវឌ្ឍប្រទេសជាតិ។

ក្នុងន័យនេះ យុទ្ធសាស្ត្របញ្ចកោណក៏ផ្តោតលើការកសាងភាពធន់នៃវិស័យសំខាន់ៗចំនួន៥ រួមមានភាពធន់នៃវិស័យសាធារណៈ វិស័យសេដ្ឋកិច្ច វិស័យហិរញ្ញវត្ថុ វិស័យមូលធនមនុស្ស និងសង្គម ព្រមទាំងភាពធន់នៃវិស័យបរិស្ថាន និងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។

ការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍ដ៏ទូលំទូលាយនេះ ទាមទារឱ្យមានប្រព័ន្ធគ្រប់គ្រងរដ្ឋដែលមានប្រសិទ្ធភាព និងប្រព័ន្ធច្បាប់ជាតិដែលមានលក្ខណៈច្បាស់លាស់ ស៊ីសង្វាក់គ្នា និងអាចគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។ ប្រព័ន្ធច្បាប់មានតួនាទីសំខាន់ក្នុងការបង្កើតក្របខ័ណ្ឌច្បាប់សម្រាប់ការគ្រប់គ្រងវិស័យសាធារណៈ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ការលើកកម្ពស់ការវិនិយោគ ការគ្រប់គ្រងធនធានធម្មជាតិ និងការពង្រឹងធនធានមនុស្ស។ ជាមួយគ្នានេះផងដែរ ប្រព័ន្ធច្បាប់ក៏មានតួនាទីក្នុងការធានាថាការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍ត្រូវបានអនុវត្តដោយមានភាពថ្លៃថ្នូរ ប្រសិទ្ធភាព និងស្របតាមគោលការណ៍នីតិរដ្ឋ។ ក្នុងន័យនេះ ការរៀបចំ និងការអភិវឌ្ឍប្រព័ន្ធច្បាប់ជាតិឱ្យមានសង្គតិភាព និងមានសមត្ថភាពគាំទ្រដល់ការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍជាតិ គឺជាកត្តាសំខាន់មួយសម្រាប់ធានាការអនុវត្តយុទ្ធសាស្ត្របញ្ចកោណឱ្យសម្រេចបានប្រកបដោយប្រសិទ្ធភាព និងចីរភាព។

### ១.២.៥ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល នីតិកាលទី២ នៃរដ្ឋសភា

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនេះ គឺជាផែនទីបង្ហាញផ្លូវសម្រាប់គ្រប់តួអង្គអភិវឌ្ឍទាំងអស់ និងជាឧបករណ៍សំខាន់សម្រាប់ការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ព្រមទាំងវិធានការគន្លឹះ

ទាំង៥ ដើម្បីជំរុញកំណើនសេដ្ឋកិច្ច បន្តបង្កើតការងារ និងធានាការបែងចែកផ្លែផ្កានៃការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយសមធម៌។ ផែនការនេះក៏មានគោលបំណងពង្រឹងប្រសិទ្ធភាពនៃស្ថាប័នសាធារណៈ និងរក្សាចីរភាពនៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមផងដែរ។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនេះ ត្រូវបានរៀបចំដោយកំណត់នូវសកម្មភាពអាទិភាព កម្មវិធី និងគម្រោងតាមវិស័យ ព្រមទាំងសូចនាករសមិទ្ធកម្មគន្លឹះនានា ដើម្បីតម្រង់ទិស និងបង្កភាពងាយស្រួលដល់គ្រប់តួអង្គពាក់ព័ន្ធក្នុងការអនុវត្តផែនការអភិវឌ្ឍជាតិដ៏សំខាន់នេះ។ ក្នុងនោះក៏បានបញ្ចូលយន្តការសម្រាប់ជំរុញការអនុវត្ត ការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃ ដើម្បីធានាថាការអនុវត្តគោលនយោបាយ និងកម្មវិធីអភិវឌ្ឍន៍អាចដំណើរការបានយ៉ាងមានប្រសិទ្ធភាព និងស្របតាមគោលដៅដែលបានកំណត់។

ជាមួយគ្នានេះផងដែរ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបានរៀបរាប់អំពីដំណើរវិវឌ្ឍនៃស្ថានភាពម៉ាក្រូសេដ្ឋកិច្ចក្នុងរយៈពេល៥ឆ្នាំកន្លងទៅ និងកំណត់ក្របខ័ណ្ឌទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ចសម្រាប់រយៈពេល៥ឆ្នាំទៅមុខ តាមរយៈការវិភាគ និងការព្យាករ។ ក្នុងនោះបានរំលេចអំពីកត្តាសំខាន់ៗ ដូចជាកំណើនសេដ្ឋកិច្ច អនិកម្មភាព អតិផរណា ស្ថានភាពហិរញ្ញវត្ថុសាធារណៈ និងស្ថានភាពវិស័យក្រៅប្រទេស។ ផែនការនេះក៏បានចង្អុលបង្ហាញអំពីវិធានការ សកម្មភាព កម្មវិធី និងគម្រោងអាទិភាពនានារបស់ក្រសួង និងស្ថាប័នដែលទទួលខុសត្រូវក្នុងការអនុវត្តក្នុងនីតិកាលទី៧ នៃរដ្ឋសភា។

បន្ថែមពីនេះ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ក៏បានប៉ាន់ស្មានអំពីតម្រូវការធនធានហិរញ្ញវត្ថុសម្រាប់ការអនុវត្តវិធានការ និងសកម្មភាពនានា ដោយរំលេចពីតម្រូវការវិនិយោគសរុប ទាំងពីប្រភពវិស័យសាធារណៈ និងប្រភពវិស័យឯកជន ព្រមទាំងប្រភពហិរញ្ញប្បទានពីក្នុង និងក្រៅប្រទេស។ ទន្ទឹមនឹងនេះ ផែនការនេះក៏បានកំណត់យន្តការសម្រាប់ការអនុវត្ត ការតាមដាន ត្រួតពិនិត្យ ការវាយតម្លៃ និងការគ្រប់គ្រងហានិភ័យ ដើម្បីធានាជោគជ័យនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា។

ការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិដ៏ទូលំទូលាយនេះ ទាមទារឱ្យមានប្រព័ន្ធគ្រប់គ្រងរដ្ឋដែលមានប្រសិទ្ធភាព និងប្រព័ន្ធច្បាប់ជាតិដែលមានលក្ខណៈច្បាស់លាស់ ស៊ីសង្វាក់គ្នា និងអាចគាំទ្រដល់ការអនុវត្តគោលនយោបាយ និងកម្មវិធីអភិវឌ្ឍន៍នានា។ ប្រព័ន្ធច្បាប់មានតួនាទីសំខាន់ក្នុងការបង្កើតក្របខ័ណ្ឌសម្រាប់ការគ្រប់គ្រងវិស័យសាធារណៈ ការរៀបចំថវិកាជាតិ ការលើកកម្ពស់ការវិនិយោគ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការគ្រប់គ្រងធនធានជាតិ។ ជាមួយគ្នានេះ ប្រព័ន្ធច្បាប់ក៏មានតួនាទីក្នុងការធានាថាការអនុវត្តផែនការអភិវឌ្ឍន៍ត្រូវបានអនុវត្តដោយមានតម្លាភាព ប្រសិទ្ធភាព និងស្របតាមគោលការណ៍នីតិរដ្ឋ។ ក្នុងន័យនេះ ការរៀបចំ និងការអភិវឌ្ឍប្រព័ន្ធច្បាប់ជាតិឱ្យមានសង្គតភាព និងអាចគាំទ្រ

ដល់ការគ្រប់គ្រង និងការអនុវត្តគោលនយោបាយអភិវឌ្ឍជាតិ គឺជាកត្តាសំខាន់មួយសម្រាប់ធានាថាការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិអាចសម្រេចបានយ៉ាងមានប្រសិទ្ធភាព និងចីរភាព។

### ១.២.៦ ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល

រាជរដ្ឋាភិបាលបានសម្រេចដាក់ឱ្យអនុវត្ត "ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល" ដោយកំណត់ចក្ខុវិស័យថា "គ.ក.ច. ជានិម្មាបនករនៃប្រព័ន្ធច្បាប់ និងវប្បធម៌នីតិរដ្ឋ ដោយផ្អែកលើគុណតម្លៃប្រវត្តិសាស្ត្ររបស់កម្ពុជា និងគុណតម្លៃសាកល"។ ក្របខ័ណ្ឌយុទ្ធសាស្ត្រនេះមានគោលបំណងសំខាន់ក្នុងការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធច្បាប់ជាតិ ព្រមទាំងលើកកម្ពស់វប្បធម៌នីតិរដ្ឋក្នុងសង្គមកម្ពុជា។

ក្នុងនោះ ក្របខ័ណ្ឌយុទ្ធសាស្ត្រនេះបានកំណត់ខឿនសំខាន់ចំនួន ៤ រួមមានៈ ១- ពិនិត្យានុភាវូបនីយកម្មគតិយុត្ត, ២- សុខដុមភាវូបនីយកម្មគតិយុត្ត, ៣- ឯកសណ្ឋានូបនីយកម្មនៃប្រព័ន្ធច្បាប់, និង ៤- បូរណភាពនៃប្រព័ន្ធច្បាប់ និងចីរភាពនៃវប្បធម៌នីតិរដ្ឋ។ ខឿនទាំងនេះមានគោលបំណងធានាថាប្រព័ន្ធច្បាប់ជាតិមាន**សង្គតភាព** មានគុណភាព និងអាចឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍន៍របស់ប្រទេសក្នុងបរិបទសង្គម សេដ្ឋកិច្ច និងបច្ចេកវិទ្យាដែលកំពុងផ្លាស់ប្តូរយ៉ាងឆាប់រហ័ស។

ដើម្បីសម្រេចបាននូវចក្ខុវិស័យនេះក្នុងរយៈពេល២០ឆ្នាំ យុទ្ធសាស្ត្រគន្លឹះចំនួន ៤ ត្រូវបានដាក់ចេញរួមមានៈ ១- ដឹកនាំ និងសម្របសម្រួលការចងក្រង និងផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត, ២- ដឹកនាំ និងសម្របសម្រួលការរៀបចំក្របខ័ណ្ឌតាក់តែងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត, ៣- ដឹកនាំ និងសម្របសម្រួលការពិនិត្យ និងវាយតម្លៃគុណភាព និងប្រសិទ្ធភាពនៃការតាក់តែង និងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត, និង ៤- ដឹកនាំ និងសម្របសម្រួលការរៀបចំក្របខ័ណ្ឌសម្រាប់ការដោះស្រាយវិវាទគតិយុត្ត និងការការពារនីត្យានុកូលភាព។ ដើម្បីគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រគន្លឹះទាំងនេះ យន្តការស្ថាប័នចំនួន ៣ ត្រូវបានបង្កើតឡើង រួមមាន ក្រុមការងារកែទម្រង់ច្បាប់នៅក្នុងក្រសួង-ស្ថាប័ននានា គណៈកម្មការជាតិការពារនីត្យានុកូលភាព និងគណៈកម្មការជាតិភាសាច្បាប់។ យន្តការទាំងនេះមានតួនាទីសំខាន់ក្នុងការគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ច្បាប់ និងការពង្រឹងគុណភាពនៃប្រព័ន្ធច្បាប់ជាតិ។

ក្នុងនោះ អគ្គលេខាធិការដ្ឋាន គ.ក.ច. នឹងបំពេញតួនាទីជាស្នូលក្នុងការដឹកនាំ និងសម្របសម្រួលយុទ្ធសាស្ត្រគាំទ្រនានា រួមមានៈ ១- រៀបចំផែនការសកម្មភាពតាមដំណាក់កាលនីមួយៗ, ២- រៀបចំស្តង់ដាប្រតិបត្តិការងារសម្រាប់អនុវត្តយុទ្ធសាស្ត្រគន្លឹះទាំង៤, ៣- រៀបចំប្រព័ន្ធឌីជីថលូបនីយកម្មសម្រាប់គាំទ្រការអនុវត្តយុទ្ធសាស្ត្រក្នុងយុគសម័យឌីជីថល, និង ៤- រៀបចំផែនការអភិវឌ្ឍស្ថាប័នសម្រាប់គ.ក.ច.។

ឯកសារក្របខ័ណ្ឌយុទ្ធសាស្ត្រនេះ ដូច្នេះមានតួនាទីជាត្រីវិស័យសំខាន់សម្រាប់ការកសាងបូរណភាពនៃប្រព័ន្ធច្បាប់ និងការពង្រឹងចីរភាពនៃវប្បធម៌នីតិរដ្ឋ ដោយផ្អែកលើគុណតម្លៃប្រវត្តិសាស្ត្ររបស់កម្ពុជា និង

គុណតម្លៃសាកល។ ការអនុវត្តយុទ្ធសាស្ត្រនេះក៏មានគោលបំណងចូលរួមគាំទ្រដល់ការសម្រេចយុទ្ធសាស្ត្របញ្ចកោណ និងការសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០ ក្នុងការប្រែក្លាយកម្ពុជាទៅជាប្រទេសមានចំណូលខ្ពស់ ដែលមានសង្គមរឹងមាំ សេដ្ឋកិច្ចរីកចម្រើន និងមានវិបុលភាពខ្ពស់។ ក្នុងន័យនេះ ការអនុវត្តកម្មវិធីកែទម្រង់ច្បាប់ និងការកសាងវប្បធម៌នីតិរដ្ឋ គឺជាមូលដ្ឋានសំខាន់សម្រាប់ការអភិវឌ្ឍប្រព័ន្ធច្បាប់ជាតិឱ្យមានសង្គតិភាព មានគុណភាព និងអាចគាំទ្រដល់ការគ្រប់គ្រងរដ្ឋ និងការអភិវឌ្ឍប្រទេសជាតិបានយ៉ាងប្រសិទ្ធភាព និងចីរភាព។

### ១.២.៧ ក្របខ័ណ្ឌបទដ្ឋានគតិយុត្ត និងស្ថាប័នសម្រាប់ការរៀបចំ និងកែទម្រង់ច្បាប់

ក្រៅពីឯកសារគោលនយោបាយនានា ប្រព័ន្ធច្បាប់កម្ពុជាក៏ត្រូវបានកំណត់ដោយបទដ្ឋានគតិយុត្ត និងស្ថាប័នជាក់លាក់ ដែលរៀបចំរចនាសម្ព័ន្ធ និងនីតិវិធីសម្រាប់ការរៀបចំច្បាប់ ការតាក់តែង ការសម្របសម្រួល ការពិនិត្យ ការផ្សព្វផ្សាយ និងការកែទម្រង់ច្បាប់។ ក្នុងបរិបទនេះ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការកែទម្រង់ច្បាប់ អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់ច្បាប់ និងសេចក្តីណែនាំស្តីពីនីតិវិធី និងវិធីសាស្ត្ររៀបចំតាក់តែងច្បាប់ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត បានជះឥទ្ធិពលដោយផ្ទាល់លើដំណើរការកែទម្រង់ច្បាប់ និងការកសាងប្រព័ន្ធច្បាប់ជាតិ។

ជាក់ស្តែង ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី និងបទដ្ឋានពាក់ព័ន្ធនឹងទីស្តីការគណៈរដ្ឋមន្ត្រី មានសារៈសំខាន់យ៉ាងខ្លាំង ព្រោះវាបានរៀបចំតួនាទីរបស់អំណាចនីតិប្រតិបត្តិក្នុងការសម្របសម្រួលដំណើរការគោលនយោបាយ និងដំណើរការច្បាប់។ តួនាទីនេះរួមមានការពិនិត្យសេចក្តីព្រាងច្បាប់ ការសម្របសម្រួលអន្តរក្រសួង-ស្ថាប័ន និងការរៀបចំការផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត។ ដោយហេតុនេះ បទដ្ឋានទាំងនេះមានឥទ្ធិពលដោយផ្ទាល់លើគុណភាព សង្គតិភាព និងភាពងាយស្រួលក្នុងការចូលប្រើប្រាស់ច្បាប់នៅទូទាំងប្រព័ន្ធរដ្ឋបាលសាធារណៈ។

ជាមួយគ្នានេះ ព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការកែទម្រង់ច្បាប់ និងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់ច្បាប់ ក៏មានសារៈសំខាន់ផងដែរ ព្រោះវាបានបង្កើតយន្តការសម្របសម្រួលជាតិមួយ សម្រាប់ដឹកនាំ តាមដាន និងជំរុញដំណើរការកែទម្រង់ច្បាប់។ តាមរយៈយន្តការនេះ កិច្ចការកែទម្រង់ច្បាប់ត្រូវបានសម្របសម្រួលនៅកម្រិតជាតិ ដើម្បីជៀសវាងភាពបែកខ្ញែកនៃការរៀបចំច្បាប់តាមវិស័យ ឬតាមស្ថាប័នផ្សេងៗ។

ចំណែកគោលការណ៍ណែនាំស្តីពីការនីតិវិធីនិងវិធាននៃការតាក់តែងតាំងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតដែលត្រូវបានប្រកាសឱ្យអនុវត្តដោយអនុក្រឹត្យលេខ១៧០ អនក្រ.បក មានតួនាទីសំខាន់ក្នុងការកសាងគុណភាពនៃប្រព័ន្ធច្បាប់ ព្រោះវាបានកំណត់ស្តង់ដារ ទម្រង់ និងលំដាប់

នីតិវិធីសម្រាប់ការតាក់តែងច្បាប់។ ការកំណត់ស្តង់ដារទាំងនេះជួយធានាថាការតាក់តែងច្បាប់អាចឆ្លើយតបទៅនឹងតម្រូវការនយោបាយ និងសង្គម មានទម្រង់ត្រឹមត្រូវ មានសង្គតិភាព និងអាចអនុវត្តបានក្នុងការអនុវត្តជាក់ស្តែង។

ក្នុងន័យនេះ បរិបទបទដ្ឋានគតិយុត្ត និងយន្តការកែទម្រង់ច្បាប់ មិនមែនជាការរៀបចំបច្ចេកទេសប៉ុណ្ណោះទេ ប៉ុន្តែជាផ្នែកសំខាន់មួយក្នុងការធានាថាប្រព័ន្ធច្បាប់កម្ពុជាមានលក្ខណៈទំនើប មានប្រសិទ្ធភាព និងមានសន្តិសុខគតិយុត្ត។ ការរៀបចំក្របខ័ណ្ឌស្ថាប័ន និងនីតិវិធីទាំងនេះ គឺជាមូលដ្ឋានសម្រាប់ការកសាងប្រព័ន្ធច្បាប់ជាតិដែលមានសង្គតិភាព មានគុណភាព និងអាចគាំទ្រដល់ការគ្រប់គ្រងរដ្ឋ និងការអភិវឌ្ឍប្រទេសជាតិបានយ៉ាងមានប្រសិទ្ធភាព។

### ១.២.៨ ស្ថានភាពសេដ្ឋកិច្ច សង្គម និងស្ថាប័ន

ចាប់ពីចុងទសវត្សរ៍ ១៩៩០ មក កម្ពុជាបានឆ្លងកាត់ដំណើរផ្លាស់ប្តូរដ៏សំខាន់មួយ ពីប្រទេសដែលស្ថិតក្នុងសភាពផុយស្រួយក្រោយជម្លោះ ទៅរកស្ថិរភាពនយោបាយ កំណើនសេដ្ឋកិច្ច និងការកសាងស្ថាប័នរដ្ឋ។ ក្នុងរយៈពេលជាងពីរទសវត្សរ៍កន្លងមកនេះ កម្ពុជាបានសម្រេចបានកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ការពង្រឹងស្ថាប័នរដ្ឋ និងការកែលម្អជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ សេដ្ឋកិច្ចកម្ពុជាបានផ្លាស់ប្តូរពីសេដ្ឋកិច្ចក្រោយជម្លោះដែលពុំសូវមានសកម្មភាពផលិតកម្ម ទៅរកសេដ្ឋកិច្ចទីផ្សារដែលមានការរីកចម្រើនក្នុងវិស័យឧស្សាហកម្ម កសិកម្ម សេវាកម្ម និងពាណិជ្ជកម្ម។

ការរីកចម្រើនសេដ្ឋកិច្ចនេះត្រូវបានគាំទ្រដោយការចូលរួមយ៉ាងសកម្មរបស់កម្ពុជាក្នុងប្រព័ន្ធសេដ្ឋកិច្ចតំបន់ និងសកល ដូចជាការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក និងការចូលរួមក្នុងសហគមន៍អាស៊ាន។ ជាមួយនឹងការរីកចម្រើននៃសេដ្ឋកិច្ចទីផ្សារ វិស័យឯកជន ការវិនិយោគ និងពាណិជ្ជកម្មអន្តរជាតិ បានក្លាយជាកម្លាំងសំខាន់សម្រាប់ការអភិវឌ្ឍជាតិ។ ក្នុងពេលដូចគ្នានេះ សង្គមកម្ពុជាក៏បានក្លាយជាសង្គមដែលមានភាពស្មុគស្មាញកាន់តែខ្លាំង ដោយមានការកើនឡើងនៃសកម្មភាពសេដ្ឋកិច្ច ការអភិវឌ្ឍទីក្រុង ការប្រើប្រាស់បច្ចេកវិទ្យា និងការចូលរួមក្នុងសេដ្ឋកិច្ចឌីជីថល។

បរិបទនៃការផ្លាស់ប្តូរនេះមានសារៈសំខាន់យ៉ាងខ្លាំងចំពោះការអភិវឌ្ឍប្រព័ន្ធច្បាប់ ព្រោះប្រព័ន្ធច្បាប់មិនអាចអភិវឌ្ឍដោយឡែកនោះទេ ប៉ុន្តែអភិវឌ្ឍទៅតាមដំណាក់កាលនៃការកសាងរដ្ឋ និងតម្រូវការអភិវឌ្ឍន៍របស់សង្គម។ សន្តិភាពពេញលេញបានក្លាយជាមូលដ្ឋានសម្រាប់ការកសាងស្ថាប័នរដ្ឋ កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់តុលាការ ការគ្រប់គ្រងសេដ្ឋកិច្ច និងការអភិវឌ្ឍច្បាប់។

នៅពេលដែលសេដ្ឋកិច្ចកម្ពុជាកាន់តែរីកចម្រើន ស្ថាប័នរដ្ឋកាន់តែស្មុគស្មាញ និងការចូលរួមក្នុងតំបន់ និងសកលកាន់តែស៊ីជម្រៅ តម្រូវការចំពោះប្រព័ន្ធច្បាប់ក៏កាន់តែកើនឡើងផងដែរ។ ប្រព័ន្ធច្បាប់ត្រូវបានរំពឹងឱ្យមិនត្រឹមតែថែរក្សាសណ្តាប់ធ្នាប់សង្គមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កើតក្របខ័ណ្ឌច្បាប់សម្រាប់កា

វិនិយោគ និងពាណិជ្ជកម្ម រៀបចំច្បាប់សម្រាប់វិស័យសេដ្ឋកិច្ចថ្មីៗ គាំទ្រការផ្ដល់សេវាសាធារណៈ និង បង្កើនជំនឿសាធារណៈលើស្ថាប័នរដ្ឋ។ ក្នុងន័យនេះ ការអភិវឌ្ឍប្រព័ន្ធច្បាប់ឱ្យមានលក្ខណៈសមស្រប និងមានសមត្ថភាពឆ្លើយតបទៅនឹងការផ្លាស់ប្តូរនៃសង្គម និងសេដ្ឋកិច្ច គឺជាកត្តាសំខាន់មួយសម្រាប់ការ គាំទ្រដល់ការអភិវឌ្ឍប្រទេសជាតិប្រកបដោយស្ថិរភាព និងចីរភាព។

### ១.២.៩ ការអប់រំ និងធនធានមនុស្ស

បរិបទអប់រំ និងធនធានមនុស្ស មានសារៈសំខាន់ចំពោះប្រព័ន្ធច្បាប់ ព្រោះគុណភាព ប្រសិទ្ធភាព និងភាពជឿទុកចិត្តបាននៃប្រព័ន្ធច្បាប់ ពឹងផ្អែកយ៉ាងខ្លាំងលើមូលដ្ឋានធនធានមនុស្សរបស់ប្រទេស។ កម្រិតអប់រំទូទៅ សមត្ថភាពឧត្តមសិក្សា គុណភាពអប់រំផ្នែកច្បាប់ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ សុទ្ធតែ ប៉ះពាល់ដោយផ្ទាល់ដល់គុណភាពនៃការតាក់តែងច្បាប់ ការជម្រះក្តី ការវិនិច្ឆ័យផ្នែកច្បាប់ ការយល់ដឹង និងការគោរពច្បាប់របស់សាធារណជន។

យោងតាមរបាយការណ៍អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាឆ្នាំ២០២៣ របស់ក្រសួងផែនការអត្រាអក្ខរ កម្មមនុស្សពេញវ័យអាយុ ១៥ ឆ្នាំឡើងទៅនៅកម្ពុជាក្នុងឆ្នាំ ២០២៣ មានប្រហែល ៨៥.៥% ក្នុងនោះ ស្ត្រី ៨១.៤% និងបុរស ៨៩.៩%។ បើគិតលើប្រជាជនអាយុ ៦ ឆ្នាំឡើងទៅអត្រាអក្ខរកម្មសរុបមាន ៨៤.៤% ហើយប្រជាជនអាយុ ៦ ឆ្នាំឡើងទៅដែលមិនធ្លាប់ចូលសាលាមានប្រហែល ៩.៣%។ ក្នុង កម្រិតឧត្តមសិក្សា ប្រព័ន្ធអប់រំកម្ពុជា មាន ១៣២ គ្រឹះស្ថានឧត្តមសិក្សា នៅឆ្នាំ ២០២២ ក្នុងនោះមាន ៤៨ សាធារណៈ និង ៨៤ ឯកជន ហើយមាននិស្សិតសរុប ១៧៥,៩៦២ នាក់។

ដោយឡែកសម្រាប់ការអប់រំផ្នែកច្បាប់កម្ពុជាមានសកលវិទ្យាល័យដែលមានកម្មវិធីសិក្សាច្បាប់ជាង ២០ សកលវិទ្យាល័យរដ្ឋ/ឯកជនសម្រាប់ថ្នាក់បរិញ្ញាបត្ររយៈពេល៤ឆ្នាំ។ នៅឆ្នាំសិក្សា ២០១៩–២០២០ មាននិស្សិតនីតិសាស្ត្រថ្នាក់បរិញ្ញាបត្រប្រហែល ១៨,៤០០ នាក់ ស្មើប្រហែល ៧% នៃនិស្សិតបរិញ្ញាបត្រ សរុបទាំងមូល។

ជាងនេះទៀតសម្រាប់ក្របខ័ណ្ឌគុណវុឌ្ឍិដើម្បីវាស់វែងគុណភាពអប់រំក្របខ័ណ្ឌអាស៊ានវិញ កម្ពុជាពុំ ទាន់មានកម្មវិធីថ្នាក់បរិញ្ញាបត្រច្បាប់ដែលបានទទួលស្គាល់ដោយក្របខ័ណ្ឌគុណវុឌ្ឍិអាស៊ាននៅឡើយទេ ពោលគឺមានតែ ៣ កម្មវិធីប៉ុណ្ណោះដែលចំនួនមានចំនួនតិចតួចបើប្រៀបធៀបជាមួយបណ្តាប្រទេស អាស៊ានដទៃក្នុងនោះរួមមាន៖ ប្រទេសឥណ្ឌូនេស៊ី មានកម្មវិធីចំនួន ២៤៩ មានក្របខ័ណ្ឌគុណវុឌ្ឍិអាស៊ា នក្នុងនោះមានកម្មវិធីច្បាប់ចំនួន ១០, ប្រទេសឡាវ មានកម្មវិធីចំនួន ៨ មានក្របខ័ណ្ឌគុណវុឌ្ឍិអាស៊ាន ក្នុងនោះមានកម្មវិធីច្បាប់ចំនួន ៣, ប្រទេសម៉ាឡេស៊ី មានកម្មវិធីចំនួន ២៨ មានក្របខ័ណ្ឌគុណវុឌ្ឍិអាស៊ា នក្នុងនោះមានកម្មវិធីច្បាប់ចំនួន ១, ប្រទេសថៃ មានកម្មវិធីចំនួន ១៨៣ មានក្របខ័ណ្ឌគុណវុឌ្ឍិអាស៊ាន ក្នុងនោះមានកម្មវិធីច្បាប់ចំនួន ១, ប្រទេសហ្វីលីពីន មានកម្មវិធីចំនួន ៣០៨ មានក្របខ័ណ្ឌគុណវុឌ្ឍិអា

ស៊ាន, ប្រទេសវៀតណាម មានកម្មវិធីចំនួន ៦៦៣ មានក្របខ័ណ្ឌគុណវុឌ្ឍិអាស៊ានក្នុងនោះមានកម្មវិធីច្បាប់ចំនួន ១៣។

តាមទស្សនៈនៃការកសាងប្រព័ន្ធច្បាប់ កម្ពុជាមិនត្រូវការតែច្បាប់ និងស្ថាប័នប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវការមូលដ្ឋានធនធានមនុស្សដែលមានគុណភាពផងដែរ។ នេះរួមមាន ការពង្រឹងគុណភាពអប់រំផ្នែកច្បាប់ ការបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ ចៅក្រម ព្រះរាជអាជ្ញា មេធាវី និងអ្នកជំនាញផ្នែកនីតិបច្ចេកទេស ការលើកកម្ពស់ស្តង់ដារវិជ្ជាជីវៈ និងការជំរុញការទទួលស្គាល់គុណភាពអប់រំ និងការបណ្តុះបណ្តាលឱ្យកាន់តែប្រសើរ។

### ១.២.១០ ការចាកចេញពីប្រទេសអភិវឌ្ឍតិចតួចនៅឆ្នាំ ២០២៩

កម្ពុជាត្រូវបានអង្គការសហប្រជាជាតិកំណត់ឱ្យចាកចេញពីប្រភេទប្រទេសអភិវឌ្ឍតិចតួច (Least Developed Countries – LDC) នៅថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០២៩ បន្ទាប់ពីមហាសន្និបាតអង្គការសហប្រជាជាតិអនុម័តសេចក្តីសម្រេចនៅថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០២៤ និងផ្តល់រយៈពេលត្រៀមចំនួន ៥ ឆ្នាំ ដើម្បីធានាការផ្លាស់ប្តូរនេះប្រកបដោយស្ថិរភាព។ ការចាកចេញពីឋានៈប្រទេសអភិវឌ្ឍតិចតួច គឺជាចំណុចសំខាន់មួយក្នុងដំណើរអភិវឌ្ឍរបស់កម្ពុជា ដែលបង្ហាញពីការរីកចម្រើនផ្នែកសេដ្ឋកិច្ច សង្គម និងស្ថាប័នរដ្ឋក្នុងរយៈពេលជាងពីរទសវត្សរ៍កន្លងមកនេះ។

ទោះជាយ៉ាងណា ការផ្លាស់ប្តូរនេះក៏នាំមកនូវបញ្ហាប្រឈមថ្មីៗផងដែរ។ បញ្ហាសំខាន់សម្រាប់កម្ពុជាមិនមែនជាការបាត់បង់អត្ថប្រយោជន៍ភ្លាមៗនោះទេ ប៉ុន្តែជាការផ្លាស់ប្តូរពីរបបអនុគ្រោះពិសេសសម្រាប់ប្រទេស LDC ទៅកាន់របបពាណិជ្ជកម្មដែលផ្អែកលើលក្ខខណ្ឌថ្មី ស្តង់ដារខ្ពស់ និងសមត្ថភាពប្រកួតប្រជែងក្នុងទីផ្សារអន្តរជាតិ។ ជាមួយនឹងការចាកចេញពីឋានៈ LDC កម្ពុជានឹងបាត់បង់យន្តការអនុគ្រោះពាណិជ្ជកម្មមួយចំនួន ក៏ដូចជាប្រភពហិរញ្ញប្បទានអនុគ្រោះ ដែលធ្លាប់ផ្តល់ជំនួយដល់ប្រទេសអភិវឌ្ឍតិចតួច។

សម្រាប់ប្រព័ន្ធច្បាប់កម្ពុជា ការផ្លាស់ប្តូរនេះមានន័យថា ប្រទេសត្រូវការប្រព័ន្ធច្បាប់ដែលមានគុណភាពនិយតកម្មខ្ពស់ មានភាពជឿទុកចិត្តបាន និងស្របតាមស្តង់ដារអន្តរជាតិ។ នេះរួមបញ្ចូលទាំងការពង្រឹងច្បាប់ពាណិជ្ជកម្ម និងច្បាប់ពាណិជ្ជកម្មអន្តរជាតិ ការអភិវឌ្ឍនិយតកម្មពាក់ព័ន្ធនឹងស្តង់ដារផលិតកម្ម និងពាណិជ្ជកម្ម ការពង្រឹងយន្តការដោះស្រាយវិវាទ ការកែលម្អសមត្ថភាពអនុវត្តច្បាប់ និងការបង្កើតបរិយាកាសច្បាប់ដែលមានភាពអាចព្យាករបានសម្រាប់វិនិយោគ និងធុរកិច្ច។

ក្នុងន័យនេះ ការចាកចេញពីឋានៈប្រទេសអភិវឌ្ឍតិចតួច គួរត្រូវបានយល់ឃើញថា មិនមែនជាសូចនាករអភិវឌ្ឍន៍តែមួយមុខនោះទេ ប៉ុន្តែជាការធ្វើតេស្តលើភាពរឹងមាំ និងភាពត្រៀមខ្លួនរបស់ប្រព័ន្ធ

ច្បាប់កម្ពុជា ក្នុងការគាំទ្រកំណើនសេដ្ឋកិច្ច ចីរភាពនៃការអភិវឌ្ឍ និងសមត្ថភាពប្រកួតប្រជែងរបស់ប្រទេសក្នុងបរិបទសេដ្ឋកិច្ច និងពាណិជ្ជកម្មអន្តរជាតិដែលកាន់តែស្មុគស្មាញ។

### ១.២.១១ ការរំពឹងទុករបស់ប្រជាពលរដ្ឋក្នុងបរិបទសន្តិភាព

ក្នុងបរិបទសន្តិភាពពេញលេញ ការរំពឹងទុករបស់ប្រជាពលរដ្ឋចំពោះរដ្ឋ និងប្រព័ន្ធច្បាប់បានផ្លាស់ប្តូរយ៉ាងសំខាន់។ ប្រសិនបើក្នុងស្ថានភាពសង្គ្រាម ឬដំណាក់កាលក្រោយជម្លោះ រដ្ឋតែងផ្តោតជាចម្បងលើការរក្សាសន្តិសុខ ស្ថិរភាព និងការឆ្លើយតបបន្ទាន់ចំពោះបញ្ហាសង្គមនានា នោះក្នុងសម័យសន្តិភាព ប្រជាពលរដ្ឋរំពឹងថាការគ្រប់គ្រងរដ្ឋត្រូវប្រព្រឹត្តទៅដោយផ្អែកលើគោលការណ៍នីតិរដ្ឋ នីត្យានុកូលភាព និងនីតិវិធីត្រឹមត្រូវ។ ការគ្រប់គ្រងរដ្ឋត្រូវមានភាពថ្លៃថ្នូរ មានតម្លាភាព និងអាចទទួលខុសត្រូវបានចំពោះសាធារណៈ។

ការរំពឹងទុកនេះ មិនមែនសំដៅលើការមានច្បាប់កាន់តែច្រើនប៉ុណ្ណោះទេ ប៉ុន្តែសំដៅលើការមានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលមានគុណភាព គ្រប់គ្រាន់ ច្បាស់លាស់ និងសង្គតិភាព ព្រមទាំងត្រូវបានអនុវត្តយ៉ាងមានប្រសិទ្ធភាព។ ប្រជាពលរដ្ឋរំពឹងថាច្បាប់ត្រូវមានភាពអាចព្យាករបាន មានស្ថិរភាព និងអាចចូលប្រើប្រាស់បានសម្រាប់មនុស្សគ្រប់រូប។ ជាមួយគ្នានេះ ការអនុវត្តច្បាប់ត្រូវមានភាពស្មើភាព និងមិនលម្អៀង ដើម្បីធានាថាបុគ្គល និងស្ថាប័នទាំងអស់ស្ថិតក្រោមការគ្រប់គ្រងរបស់ច្បាប់ដូចគ្នា។

លើសពីនេះ ក្នុងសង្គមសន្តិភាព ប្រជាពលរដ្ឋក៏រំពឹងថារដ្ឋនឹងពង្រឹងយន្តការដើម្បីធានាការទទួលបានយុត្តិធម៌ និងការការពារសិទ្ធិ និងសេរីភាពមូលដ្ឋាន។ នេះរួមមានការពង្រឹងប្រព័ន្ធតុលាការ ការកែលម្អសេវាយុត្តិធម៌ ការធានាការចូលដល់យុត្តិធម៌ និងការលើកកម្ពស់ការយល់ដឹងអំពីច្បាប់ក្នុងសង្គម។ ប្រព័ន្ធច្បាប់ត្រូវមានសមត្ថភាពដោះស្រាយវិវាទយ៉ាងមានប្រសិទ្ធភាព កាត់បន្ថយភាពអយុត្តិធម៌ និងបង្កើនទំនុកចិត្តរបស់ប្រជាពលរដ្ឋចំពោះស្ថាប័នរដ្ឋ។

ក្នុងន័យនេះ នៅក្នុងសម័យសន្តិភាព ប្រព័ន្ធច្បាប់កម្ពុជាត្រូវផ្លាស់ប្តូរពីតួនាទីជាឧបករណ៍សម្រាប់រក្សាសណ្តាប់ធ្នាប់មូលដ្ឋាន ទៅជាក្របខ័ណ្ឌសំខាន់សម្រាប់គ្រប់គ្រងរដ្ឋ និងសង្គម។ ប្រព័ន្ធច្បាប់ត្រូវមានសមត្ថភាពគាំទ្រអភិបាលកិច្ចល្អ គាំទ្រការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ការពារសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋ និងបង្កើនទំនុកចិត្តសាធារណៈលើស្ថាប័នរដ្ឋ។ ដូច្នេះ ការកសាងប្រព័ន្ធច្បាប់ដែលមានគុណភាព មានសង្គតិភាព និងអាចឆ្លើយតបទៅនឹងតម្រូវការរបស់សង្គមក្លាយជាកត្តាសំខាន់មួយសម្រាប់ការពង្រឹងនីតិរដ្ឋ និងការគ្រប់គ្រងរដ្ឋប្រកបដោយប្រសិទ្ធភាព។

## ២. សនិទានភាព

### ២.១. បញ្ហាប្រឈម

ស្របតាមចក្ខុវិស័យកម្ពុជា ២០៥០ និងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ កម្ពុជាត្រូវការប្រព័ន្ធច្បាប់ដែលមានភាពច្បាស់លាស់ សង្គតិភាព បូរណភាព សន្តិសុខគតិយុត្ត ភាពអាចព្យាករណ៍បាន និងភាពអាចអនុវត្តបានខ្ពស់ ដើម្បីគាំទ្រការអភិវឌ្ឍជាតិ ការពង្រឹងអភិបាលកិច្ច ការការពារសិទ្ធិ និងសេរីភាព ការទាក់ទាញវិនិយោគ និងការធ្វើសមាហរណកម្មអន្តរជាតិ។ ទោះជាយ៉ាងណា ស្ថានភាពបច្ចុប្បន្នបង្ហាញថា ប្រព័ន្ធច្បាប់កម្ពុជានៅតែប្រឈមនឹងបញ្ហាប្រឈមសារវន្តជាច្រើន ទាំងលើផ្នែកខ្លឹមសារនៃច្បាប់ រចនាសម្ព័ន្ធស្ថាប័ន យន្តការអនុវត្ត សមត្ថភាពវិជ្ជាជីវៈ និងឧបករណ៍គាំទ្រ។ បញ្ហាទាំងនេះមិនត្រឹមតែប៉ះពាល់ដល់គុណភាពនៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តប៉ុណ្ណោះទេ ប៉ុន្តែក៏ប៉ះពាល់ដល់ប្រសិទ្ធភាពនៃការគ្រប់គ្រងរដ្ឋ ការអនុវត្តគោលនយោបាយសាធារណៈ ការការពារសិទ្ធិ និងទំនុកចិត្តសាធារណៈលើប្រព័ន្ធច្បាប់ផងដែរ។

#### ២.១.១ សង្គតិភាពនៃច្បាប់ជាធរមាន

ប្រព័ន្ធច្បាប់បច្ចុប្បន្ននៅមិនទាន់ធានាបាននូវសង្គតិភាពនៃច្បាប់ជាធរមាន។ នៅក្នុងវិស័យច្បាប់តែមួយ ឬរវាងវិស័យច្បាប់ផ្សេងៗ នៅតែមានការប្រើប្រាស់ពាក្យច្បាប់ទស្សនាទានច្បាប់ និងការកំណត់ខ្លឹមសារដែលមិនស៊ីសង្វាក់គ្នា។ បទប្បញ្ញត្តិមួយចំនួនប្រើពាក្យផ្សេងៗគ្នាសម្រាប់ន័យតែមួយ ឬប្រើពាក្យតែមួយសម្រាប់ន័យខុសៗគ្នា ហើយនៅខ្លះទៀតក៏មានអភិក្រមនៃការបកស្រាយខ្លឹមសារមិនដូចគ្នា។ ស្ថានភាពនេះបណ្តាលឱ្យកើតមានភាពស្រពេចស្រពិលក្នុងការអនុវត្ត កាត់បន្ថយសន្តិសុខគតិយុត្ត និងធ្វើឱ្យប្រព័ន្ធច្បាប់ពិបាកដំណើរការជាប្រព័ន្ធតែមួយដែលមានបូរណភាព។

#### ២.១.២ សង្គតិភាពនៃមធ្យោបាយតាក់តែង

ការរៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្តមួយចំនួននៅតែមាននិន្នាការរងឥទ្ធិពលពីជំនួយផ្នែកច្បាប់ ជំនាញការច្បាប់ ឬប្រព័ន្ធច្បាប់បរទេស ដោយមិនទាន់មានឧបករណ៍វាយតម្លៃគ្រប់គ្រាន់អំពីភាពសមស្រប និងភាពចាំបាច់ ស្របទៅនឹងបរិបទសង្គម សេដ្ឋកិច្ច វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ និងវឌ្ឍនភាពបច្ចេកវិទ្យារបស់កម្ពុជា នឹងមិនទាន់ផ្សាភ្ជាប់ជាក់ស្តែងទៅនឹងលក្ខខណ្ឌអនុវត្ត សមត្ថភាពស្ថាប័ន និងតម្រូវការពិតប្រាកដរបស់សង្គម។ បញ្ហានេះធ្វើឱ្យគុណភាពនៃការតាក់តែងច្បាប់ និងភាពអាចអនុវត្តបាននៃច្បាប់នៅមិនទាន់សមស្របនឹងទិសដៅអភិវឌ្ឍជាតិ។

### ២.១.៣ គម្លាតរវាងគោលនយោបាយ ច្បាប់ និងបទប្បញ្ញត្តិអនុវត្ត

គោលនយោបាយ និងយុទ្ធសាស្ត្រជាតិបានកំណត់ទិសដៅយ៉ាងច្បាស់ប៉ុន្តែការប្រែក្លាយទៅជាច្បាប់ និងបទប្បញ្ញត្តិអនុវត្តនៅមិនទាន់ពេញលេញ មិនទាន់ទាន់ពេលវេលា ឬមិនទាន់មានសង្គតិភាពគ្នា។ ទោះបីច្បាប់ត្រូវបានអនុម័តហើយក៏ដោយ ក៏នៅតែមានភាពយឺតយ៉ាវ ឬចន្លោះខ្វះខាតក្នុងការរៀបចំអនុក្រឹត្យ ប្រកាស សេចក្តីណែនាំ ឬយន្តការប្រតិបត្តិចាំបាច់ផ្សេងៗ។ ជាផលវិបាក យើងមានច្បាប់តែក្នុងទម្រង់ផ្លូវការប៉ុណ្ណោះ ប៉ុន្តែមិនទាន់អាចបង្កើតលទ្ធផលជាក់ស្តែងស្របតាមគោលបំណងគោលនយោបាយដែលបានរំពឹងទុក។

### ២.១.៤ ភាពមិនច្បាស់លាស់នៃបទដ្ឋាន និងការបកស្រាយច្បាប់

ខ្លឹមសារបទដ្ឋានមួយចំនួននៅតែមានលក្ខណៈទូទៅ ឬមិនបានកំណត់ឱ្យច្បាស់លាស់គ្រប់គ្រាន់ដែលអាចបណ្តាលឱ្យមានការបកស្រាយខុសៗគ្នា អាស្រ័យលើទស្សនវិជ្ជាច្បាប់ អភិក្រមច្បាប់ និងបទពិសោធន៍អនុវត្តផ្សេងៗគ្នា។ ស្ថានភាពនេះកាន់តែស្មុគស្មាញឡើងនៅក្នុងបរិបទដែលប្រព័ន្ធច្បាប់កម្ពុជាបានអភិវឌ្ឍក្រោមឥទ្ធិពលនៃប្រព័ន្ធច្បាប់ប្រពៃណី ប្រព័ន្ធច្បាប់ស៊ីវិល និងប្រព័ន្ធច្បាប់អង់គ្លូសាក់សុង។ បើគ្មានគោលការណ៍ ឬឧបករណ៍ណែនាំបកស្រាយដែលមានសង្គតិភាពទេ ភាពមិនច្បាស់លាស់នេះអាចប៉ះពាល់ដល់ការអនុវត្តឱ្យស្មើគ្នា ភាពអាចព្យាករណ៍បាននៃច្បាប់ និងទំនុកចិត្តលើប្រព័ន្ធយុត្តិធម៌ និងរដ្ឋបាលសាធារណៈ។

### ២.១.៥ ប្រសិទ្ធភាពនៃការអនុវត្ត និងយន្តការតាមដានវាយតម្លៃ

បច្ចុប្បន្ននេះកម្ពុជានៅមិនទាន់មានយន្តការជាក់លាក់ និងគ្រប់ជ្រុងជ្រោយសម្រាប់ពិនិត្យ និងវាយតម្លៃគុណភាពនៃការតាក់តែង សង្គតិភាពនៃបទដ្ឋាន សុក្រឹតភាពនៃការបកស្រាយខ្លឹមសារដែលមិនច្បាស់លាស់ និងប្រសិទ្ធភាពជាក់ស្តែងនៃការអនុវត្តច្បាប់នៅឡើយ។ កង្វះយន្តការបែបនេះធ្វើឱ្យពិបាកកំណត់ថា តើបទដ្ឋានដែលបានអនុម័តកំពុងសម្រេចបានគោលបំណងរបស់ខ្លួនដែរឬទេ តើមានផលវិបាកណាមួយដែលរារាំងឬទេ និងតើត្រូវការការកែសម្រួលបន្ថែមនៅចំណុចណាខ្លះ។ ជាផលវិបាកប្រព័ន្ធច្បាប់នឹងបន្តពង្រីកខ្លួនទៅមុខដោយខ្វះយន្តការតាមដាន និងវាយតម្លៃ និងខ្វះមូលដ្ឋានភស្តុតាងសម្រាប់ការកែទម្រង់។

### ២.១.៦ រចនាសម្ព័ន្ធស្ថាប័ន និងការបែងចែកតួនាទីភារកិច្ច

ការបែងចែក និងកំណត់តួនាទីភារកិច្ចលើការងាររៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត រវាងអង្គភាពជំនាញបច្ចេកទេស និងអង្គភាពទទួលបន្ទុកនីតិកម្ម នៅមិនទាន់មានភាពច្បាស់លាស់គ្រប់គ្រាន់នៅឡើយ។ ស្ថានភាពនេះអាចបង្កឱ្យមានទំនាស់ផលប្រយោជន៍ក្នុងដំណើរការកសាងច្បាប់ និងប៉ះពាល់ដល់ការគោរពតួនាទី និងភារកិច្ចតាមគោលការណ៍នីត្យានុកូលភាព តក្កវិជ្ជាគតិយុត្ត និងប្រតិតុល្យភាពនៃមុខងារ។ លើសពីនេះ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ មិនទាន់មានយន្តការច្បាស់លាស់ និងស្តង់ដាររួមសម្រាប់ការរៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនៅឡើយ។ បញ្ហានេះមានសារៈសំខាន់ជាពិសេសក្នុងបរិបទនៃការផ្ទេរមុខងារ និងធនធានពីរដ្ឋបាលថ្នាក់ជាតិទៅរដ្ឋបាលថ្នាក់ក្រោមជាតិដែលទាមទារឱ្យមានការកំណត់អំណាច សមត្ថកិច្ច ទំនួលខុសត្រូវ និងយន្តការអនុវត្តឱ្យបានច្បាស់លាស់ និងស៊ីសង្វាក់គ្នា។

### ២.១.៧ ពិនិត្យានុភាពវូបនីយកម្មគតិយុត្ត និងឌីជីថលូបនីយកម្ម

ការផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនៅមិនទាន់មានប្រសិទ្ធភាព និងមិនទាន់ទូលំទូលាយគ្រប់គ្រាន់ ខណៈឌីជីថលូបនីយកម្មផ្លូវការនៃមូលដ្ឋានទិន្នន័យច្បាប់ ការបោះពុម្ពផ្សាយ និងការស្វែងរកព័ត៌មានច្បាប់នៅមិនទាន់ពេញលេញ។ ជាផលវិបាក ភាគីពាក់ព័ន្ធនានា រួមទាំងមន្ត្រីអនុវត្តច្បាប់ អ្នកប្រកបវិជ្ជាជីវៈច្បាប់ វិស័យឯកជន និងប្រជាពលរដ្ឋ អាចជួបការលំបាកក្នុងការទទួលបានព័ត៌មានច្បាប់ថ្មីៗ ទំនុកចិត្តលើប្រភពផ្លូវការ និងការយល់ដឹងដូចគ្នាអំពីខ្លឹមសារច្បាប់។

### ២.១.៨ សមត្ថភាពធនធានមនុស្ស កិច្ចសហការ និងឧបករណ៍អភិបាលកិច្ចគាំទ្រ

សមត្ថភាពរបស់ធនធានមនុស្ស និងអង្គភាពទទួលបន្ទុកការងារច្បាប់ និងនីតិកម្ម នៅមានកម្រិតទាំងផ្នែកចំណេះដឹងបច្ចេកទេស ជំនាញវិភាគ ជំនាញតាក់តែង និងបទពិសោធន៍អនុវត្ត។ ជាមួយគ្នានេះ កិច្ចសហការ និងអន្តរសកម្មរវាងតួអង្គអនុវត្តច្បាប់នានា នៅមិនទាន់ស្របតាមអភិក្រមជាប្រព័ន្ធតួអង្គតែមួយនៅឡើយ ដែលប៉ះពាល់ដល់សង្គតិភាពនៃការរៀបចំ ការបកស្រាយ និងការអនុវត្តច្បាប់។ ក្រៅពីនេះ កម្ពុជាក៏នៅខ្វះឧបករណ៍អភិបាលកិច្ចគាំទ្រការអនុវត្តច្បាប់ ដូចជាកម្រងសម្រង់ មគ្គុទេសក៍នីតិសាស្ត្រ អត្ថាធិប្បាយគតិយុត្ត ព្រឹត្តិបត្រច្បាប់ និងមគ្គុទេសក៍ប្រឹក្សាច្បាប់ជាដើម ដែលជាឧបករណ៍ចាំបាច់សម្រាប់ធានាឯកភាពនៃការអនុវត្ត និងលើកកម្ពស់គុណភាពវិជ្ជាជីវៈ។

#### ២.១.៩ ក្របខ័ណ្ឌសមត្ថភាពវិជ្ជាជីវៈផ្នែកច្បាប់

បន្ថែមលើនេះ បញ្ហាប្រឈមសំខាន់មួយទៀត គឺកម្ពុជានៅមិនទាន់មានក្របខ័ណ្ឌសមត្ថភាពវិជ្ជាជីវៈផ្នែកច្បាប់ដែលមានលក្ខណៈច្បាស់លាស់ និងជាប្រព័ន្ធ សម្រាប់កំណត់សមត្ថភាពស្នូល សមត្ថភាពតាមមុខងារ កម្រិតជំនាញ ផ្លូវអភិវឌ្ឍអាជីព ស្តង់ដារបណ្តុះបណ្តាលបន្ត និងស្តង់ដារសីលធម៌វិជ្ជាជីវៈសម្រាប់អ្នកវិជ្ជាជីវៈច្បាប់។ អវត្តមាននៃក្របខ័ណ្ឌបែបនេះធ្វើឱ្យការបន្សីវវាងការអប់រំផ្នែកច្បាប់ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការអភិវឌ្ឍសមត្ថភាពក្នុងពេលបំពេញការងារ និងតម្រូវការជាក់ស្តែងនៃការអនុវត្តច្បាប់នៅមិនទាន់ស៊ីសង្វាក់គ្នា។ ជាផលវិបាក ការវាស់វែងសមត្ថភាព ការកំណត់គម្លាតជំនាញ ការរៀបចំផែនការបណ្តុះបណ្តាល ការអភិវឌ្ឍវិជ្ជាជីវៈបន្ត និងការធានាស្តង់ដារគុណភាពសម្រាប់ចៅក្រម ព្រះរាជអាជ្ញា មេធាវី មន្ត្រីនីតិកម្ម មន្ត្រីអនុវត្តច្បាប់ និងអ្នកវិជ្ជាជីវៈច្បាប់ពាក់ព័ន្ធផ្សេងទៀត នៅមានលក្ខណៈបែកខ្ញែក និងខ្វះចំណុចយោងរួម។ ក្នុងបរិបទដែលវិស័យច្បាប់កាន់តែស្មុគស្មាញ និងទាមទារជំនាញអន្តរវិស័យកាន់តែខ្ពស់ កង្វះក្របខ័ណ្ឌសមត្ថភាពវិជ្ជាជីវៈផ្នែកច្បាប់អាចកាត់បន្ថយគុណភាពនៃការអនុវត្តច្បាប់ ភាពស៊ីសង្វាក់នៃស្តង់ដារវិជ្ជាជីវៈ និងសមត្ថភាពរបស់ប្រព័ន្ធច្បាប់ក្នុងការអភិវឌ្ឍធនធានមនុស្សឱ្យស្របតាមតម្រូវការកែទម្រង់ និងតម្រូវការអភិវឌ្ឍជាតិ។

#### ២.១.១០ និម្មាបនកម្មប្រព័ន្ធច្បាប់

បច្ចុប្បន្នពុំទាន់មានឯកសារជាក់លាក់ណាមួយកំណត់អំពីនិម្មាបនកម្មនៃប្រព័ន្ធច្បាប់ជាតិទាំងមូល។ ត្បិតឯកសារនេះពុំមែនជាកាតព្វកិច្ចធម្មនុញ្ញរបស់រដ្ឋក្នុងការរៀបចំ ប៉ុន្តែអវត្តមាននៃឯកសារនេះនាំឱ្យមានការកែទម្រង់ច្បាប់ទាំងមូលហាក់ពុំទាន់មានផែនទីបង្ហាញផ្លូវគ្រប់គ្រាន់ ដើម្បីអាចឱ្យដំណើរការកែទម្រង់បានទៅដល់ទិសដៅដូចការរំពឹងទុក។ ក្នុងនោះផងដែរ អវត្តមាននៃឯកសារនេះក៏នាំឱ្យមានទស្សនៈផ្សេងៗគ្នាចំពោះប្រព័ន្ធច្បាប់ពីសំណាក់ភាគីពាក់ព័ន្ធទាំងអស់ ដែលនេះប៉ះពាល់ដល់ប្រសិទ្ធភាពនៃប្រព័ន្ធច្បាប់ជាតិទាំងមូល។

### ២.២. តម្រូវការនៃក្របខ័ណ្ឌប្រព័ន្ធច្បាប់

#### ២.២.១ ជាមូលដ្ឋានវាយតម្លៃបូរណភាពនិងសង្គតិភាពនៃប្រព័ន្ធច្បាប់

កម្ពុជាត្រូវការផែនការមេដែលមានភាពច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយ ដើម្បីធានាបូរណភាព សង្គតិភាព និងភាពពេញលេញនៃប្រព័ន្ធច្បាប់ជាតិ។ ប្រសិនបើគ្មាននិម្មាបនកម្មគោលសម្រាប់ប្រព័ន្ធច្បាប់ នោះនឹងពុំមានមូលដ្ឋានសម្រាប់ធ្វើការវាយតម្លៃអំពីស្ថានភាពបច្ចុប្បន្នទៅលើចំណុចខ្វះខាត និងមូលដ្ឋានកំណត់ដែលបញ្ជាក់ថាប្រព័ន្ធច្បាប់មានលក្ខណៈពេញលេញ។ ក្របខ័ណ្ឌប្រព័ន្ធច្បាប់នេះ ក៏ជា

មគ្គទេសន៍បង្ហាញផ្លូវដើម្បីធានាសុខដុមនីយកម្ម ឯកសណ្ឋានូបនីយកម្ម និងឈានទៅដល់ ការសម្រេចបានបូរណភាពនូវគ្រប់ធាតុផ្សំទាំងអស់នៃប្រព័ន្ធច្បាប់ទាំងមូល ដែលញ៉ាំងឱ្យប្រព័ន្ធច្បាប់ ដំណើរការជាប្រព័ន្ធតែមួយ មិនមានសភាពដាច់ដោយឡែកពីគ្នា។

### ២.២.២ ជាត្រីវិស័យនិងផែនទីបង្ហាញផ្លូវរួមអំពីប្រព័ន្ធច្បាប់

ក្របខ័ណ្ឌប្រព័ន្ធច្បាប់មានតួនាទីប្រៀបបាននឹងត្រីវិស័យនិងផែនទីសម្រាប់គ្រប់ភាគីពាក់ព័ន្ធ ទាំងអស់ តាមរយៈការបង្ហាញអំពីទិដ្ឋភាពរួម និងដំណើរការនៃប្រព័ន្ធច្បាប់ទាំងមូល រួមទាំងអន្តរកម្មរវាង ធាតុផ្សំនីមួយៗជាមួយគ្នាទៅវិញទៅមក។ តាមរយៈនេះ ក្របខ័ណ្ឌប្រព័ន្ធច្បាប់ក៏បង្កើតឱ្យមានការយល់ ដឹង និងការរំពឹងទុកពីប្រព័ន្ធច្បាប់ដូចៗគ្នាពីសំណាក់គ្រប់គាភីពាក់ព័ន្ធ ព្រមទាំងជួយសម្រួលដល់កិច្ចការសម្របសម្រួល និងអន្តរកម្មរវាងស្ថាប័នទាំងអស់។

### ២.២.៣ មូលដ្ឋានសម្រាប់កែទម្រង់

និម្មាបនកម្មនេះផ្តល់នូវក្របខ័ណ្ឌធាតុផ្សំសម្រាប់ធ្វើការវាយតម្លៃស្ថានភាពបច្ចុប្បន្ននៃប្រព័ន្ធច្បាប់កម្ពុជា។ ការវិភាគដែលមានមូលដ្ឋានច្បាស់លាស់នឹងរួមចំណែកការធ្វើកំណែទម្រង់ដោយផ្អែកលើ ភស្តុតាង ដែលអនុញ្ញាតឱ្យមានការកំណត់ច្បាស់លាស់អំពីកន្លែងឬចំណុចដែលត្រូវកែទម្រង់ រួមមានការកំណត់អំពីច្បាប់ដែលត្រូវរៀបចំថ្មី សេចក្តីណែនាំដែលត្រូវពង្រឹង ការអនុវត្តនៅក្នុងស្ថាប័នដែលត្រូវកែលម្អ រួមទាំងការកំណត់បាននូវចំណុចល្អលើយន្តការដែលមានស្រាប់។ តាមរយៈនេះ ការកែទម្រង់នឹងជានា បានខិតខំប្រឹងប្រែងនឹងផ្តោតទៅលើចំណុចជាក់លាក់ ជាយុទ្ធសាស្ត្រ និងមានសង្គតិភាព ជាជាងការកែ ទម្រង់ដែលមានលក្ខណៈដាច់ដោយឡែកពីគ្នា និងប្រតិកម្ម។

### ២.២.៤ បញ្ចៀសវិវាទតតិយុត្តរវាងស្ថាប័ន

តាមរយៈការកំណត់រចនាសម្ព័ន្ធស្ថាប័ននិងតួអង្គពាក់ព័ន្ធនៅក្នុងប្រព័ន្ធច្បាប់ ក្របខ័ណ្ឌនេះបានកំណត់អំពីតួនាទីភារកិច្ច ទំនួលខុសត្រូវ និងអន្តរកម្មក្នុងចំណោមស្ថាប័នពាក់ព័ន្ធ ព្រមទាំងតួអង្គសំខាន់ៗផងដែរ។ ភាពច្បាស់លាស់រួមចំណែកក្នុងការបញ្ចៀសវិវាទលើសមត្ថកិច្ចរវាងស្ថាប័ន និងពង្រឹងកិច្ចការសម្របសម្រួលរវាងស្ថាប័ន ព្រមទាំងពង្រឹងការទទួលខុសត្រូវរបស់ភាគីពាក់ព័ន្ធនៅក្នុងប្រព័ន្ធទាំងមូល។

### ២.២.៥ ជម្រុញការអភិវឌ្ឍន៍ជាតិ

ការកសាងប្រព័ន្ធច្បាប់មួយដែលមានបូរណភាពនិងប្រទាក់ក្រឡា នឹងពង្រឹងដំណើរការនៃប្រព័ន្ធច្បាប់ទាំងមូល ដែលតាមរយៈនេះនឹងជម្រុញឱ្យកាន់តែមានផលិតភាព ប្រសិទ្ធភាព និងសក្តិសិទ្ធភាពខ្ពស់។ លទ្ធផលនេះនឹងជម្រុញការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍រយៈពេលវែងរបស់កម្ពុជា រួមទាំង

ចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ និងពង្រឹងភាពធន់របស់សង្គមជាតិ ក្នុងការឆ្លើយតបទៅនឹងបញ្ហាប្រឈមទាំងក្នុងប្រទេស និងពីក្រៅប្រទេស។

# ៣. ទស្សនាទានគ្រឹះនៃក្របខ័ណ្ឌ

## ៣.១. និយមន័យនៃប្រព័ន្ធច្បាប់

មកដល់ពេលបច្ចុប្បន្ន ពុំទាន់មានការឯកភាពជាសកលលើនិយមន័យប្រព័ន្ធច្បាប់នោះទេ។ និយមន័យរមែងអាស្រ័យតាមទិដ្ឋភាពដែលប្រើប្រាស់សម្រាប់ការសិក្សាវិភាគជាអាទិ៍ មានទិដ្ឋភាពទស្សនវិជ្ជា ច្បាប់ ទ្រឹស្តីច្បាប់ វិទ្យាសាស្ត្រសង្គម និងវិទ្យាសាស្ត្រនយោបាយ។ ចំពោះទ្រឹស្តីច្បាប់ លោក H.LA. Hart បានផ្តោតទៅលើសុពលភាពនិងសណ្តាប់ធ្នាប់ច្បាប់ ដោយបានកំណត់និយមន័យប្រព័ន្ធច្បាប់ជាការរួមបញ្ចូលរវាងវិធានគោលនិងវិធានបន្ទាប់បន្សំ ( union of primary and secondary rules ) ដែលវិធានបន្ទាប់បន្សំក៏មានវិធានក្នុងការទទួលស្គាល់ ដែលកំណត់លក្ខណៈវិនិច្ឆ័យសម្រាប់កំណត់ច្បាប់ដែលមានសុពលភាព។

ចំពោះទិដ្ឋភាពវិទ្យាសាស្ត្រសង្គម ប្រព័ន្ធច្បាប់ពុំត្រូវបានកំណត់ត្រឹមវិធានគតិយុត្តនោះទេ ប៉ុន្តែក៏រួមបញ្ចូល ទាំងស្ថាប័ន ការអនុវត្ត និងបរិយាកាសសង្គមដែលមានប្រតិបត្តិការច្បាប់។ លោក Lawrence M. Friedman បានកំណត់ធាតុផ្សំប្រព័ន្ធច្បាប់រួមមានរចនាសម្ព័ន្ធគតិយុត្ត សារធាតុគតិយុត្ត និងវប្បធម៌គតិយុត្ត។ តាមរយៈទិដ្ឋភាពនេះ បានបង្ហាញថាច្បាប់ពុំដំណើរតាមរយៈវិធានផ្លូវការនោះទេ តែក៏តាមរយៈស្ថាប័ន ឥរិយាបថមនុស្ស និងអាកប្បកិរិយាសង្គមចំពោះច្បាប់។ តាមរយៈសិក្ខាសាលាស្តីពីប្រព័ន្ធច្បាប់កម្ពុជាកាលពីថ្ងៃទី២៧ - ២៨ ខែតុលា ឆ្នាំ២០២៥ នាខេត្តសៀមរាបកន្លងទៅនេះ អង្គសិក្ខាសាលាក៏បានបន្ថែមធាតុផ្សំមួយទៀតដែល ជាមូលដ្ឋានកំណត់ធាតុផ្សំបីខាងលើគឺ គុណតម្លៃគ្រឹះ។

រីឯពីទិដ្ឋភាពវិទ្យាសាស្ត្រនយោបាយ ប្រព័ន្ធត្រូវបានចាត់ទុកជាផ្នែកមួយនៃក្របខ័ណ្ឌស្ថាប័នសម្រាប់ ការរៀបចំ ប្រតិបត្តិការ និងពិនិត្យលើអំណាចសាធារណៈ។ ក្នុងន័យនេះ ប្រព័ន្ធច្បាប់ពុំត្រឹមជាបណ្តុំវិធានដែលមានសុពលភាពនោះទេ តែជារចនាសម្ព័ន្ធ គ្រប់គ្រង ដើម្បីធានានិត្យានុកូលភាព ការសម្របសម្រួល ការទទួលខុសត្រូវ និងការអនុវត្តសេចក្តីសម្រេចរបស់សង្គម។

ក្នុងបរិបទនៃក្របខ័ណ្ឌប្រព័ន្ធច្បាប់កម្ពុជា ពុំមាននិយមន័យដែលបានកំណត់ឱ្យបានពេញលេញកន្លងមកដែលឆ្លើយតបទៅនឹងទិដ្ឋភាពនៃអភិបាលកិច្ចរដ្ឋនិងសង្គមនេះ។ ហេតុនេះ ប្រព័ន្ធច្បាប់ពុំគួរកំណត់ត្រឹមជាបណ្តុំនៃវិធានគតិយុត្ត ឬត្រឹមជាបណ្តុំស្ថាប័នគតិយុត្ត តែគួរត្រូវបានកំណត់ជា **"ប្រព័ន្ធនៃបណ្តុំគុណតម្លៃគ្រឹះ វិធាន ស្ថាប័ន មុខងារ និងវប្បធម៌គតិយុត្ត ដែលរដ្ឋនិងសង្គមរៀបចំសណ្តាប់ធ្នាប់សាធារណៈ បញ្ញត្តិសកម្មភាព ដោះស្រាយវិវាទ ការពារសិទ្ធិ អនុវត្តគោលនយោបាយ និងរក្សានិត្យានុកូល**

**ភាព ក្នុងក្របខណ្ឌនៃអភិបាលកិច្ចនិងអភិវឌ្ឍន៍ជាតិ**"។ និយមន័យនេះរួមបញ្ចូលនិយមន័យពីទិដ្ឋភាពទស្សនវិជ្ជាច្បាប់ វិទ្យាសាស្ត្រសង្គម និងវិទ្យាសាស្ត្រនយោបាយ។

តាមរយៈការកំណត់និយមន័យខាងលើ ប្រព័ន្ធច្បាប់មានធាតុផ្សំដែលពាក់ព័ន្ធនឹងគ្នាយ៉ាងហោចណាស់ចំនួន៤ រួមមាន គុណតម្លៃគ្រឹះ, សារជាតុគតិយុត្ត, រចនាសម្ព័ន្ធគតិយុត្ត, និងវប្បធម៌គតិយុត្ត ព្រមទាំងមានយន្តការគាំទ្រអភិបាលកិច្ច។ ធាតុផ្សំនីមួយៗមិនអាចដំណើរការដោយឯកឯងបាននោះទេ ព្រោះប្រសិទ្ធ ភាពនៃប្រព័ន្ធច្បាប់អាស្រ័យមិនត្រឹមតែការមានច្បាប់ប៉ុណ្ណោះទេ ប៉ុន្តែក៏អាស្រ័យលើភាពប្រទាក់ក្រឡារបស់ស្ថាប័ន គុណភាពនៃការប្រត្តិបត្តិ និងវប្បធម៌គោរពច្បាប់នៅក្នុងសង្គមទាំងមូល។

### ៣.២. ទ្រឹស្តីនៃប្រព័ន្ធទូទៅ (General System Theory)

ក្រោយពីបានកំណត់និយមន័យនៃប្រព័ន្ធច្បាប់ខាងលើ ក្នុងបរិបទក្របខណ្ឌប្រព័ន្ធច្បាប់កម្ពុជាក៏ចាំបាច់ត្រូវស្វែងយល់អំពីទំនាក់ទំនងក្នុងចំណោមធាតុផ្សំទាំងអស់ ដំណើរការដែលធាតុផ្សំទាំងនោះប្រព្រឹត្តទៅរួមគ្នា និងការឆ្លើយតបរបស់ប្រព័ន្ធទៅនឹងការផ្លាស់ប្តូរពីផ្នែកខាងក្នុងនិងខាងក្រៅ។ ក្នុងន័យនេះ ទ្រឹស្តីស្តីពីប្រព័ន្ធទូទៅបានផ្តល់នូវទស្សនាទានមូលដ្ឋាននិងសមស្របសម្រាប់ការស្វែងយល់អំពីប្រព័ន្ធច្បាប់ឱ្យបានគ្រប់ជ្រុងជ្រោយ និងប្រកបដោយភាពប្រទាក់ក្រឡា។

ទ្រឹស្តីស្តីពីប្រព័ន្ធទូទៅ ដំណើរការដោយផ្អែកលើការសន្មត់ថាគ្រប់ប្រព័ន្ធទាំងអស់គឺកំណត់ដោយធាតុផ្សំដែលមានទំនាក់ទំនងរវាងគ្នាទៅវិញទៅមក រួមមានបរិស្ថាន (Environment), ធាតុចូល (Inputs), សមិទ្ធផល (Outputs), ផលសម្រេច (Outcomes), ផលប៉ះពាល់ (Impacts), និងការវាយតម្លៃ (Feedback Loops)។ ធាតុផ្សំទាំងនេះផ្តល់នូវវិធីសាស្ត្រច្បាស់លាស់ក្នុងការស្វែងយល់ អំពីវត្តមានរបស់ប្រព័ន្ធនៅក្នុងបរិបទទូលំទូលាយ ធនធានដែលប្រព័ន្ធទទួល កិច្ចដំណើរការនៅក្នុងប្រព័ន្ធ និងសមិទ្ធផលដែលសម្រេចបាន និងផលប៉ះពាល់ដែលមាន ព្រមទាំងការសម្របខ្លួននិងកែតម្រូវដោយខ្លួនឯងរបស់ប្រព័ន្ធ។ ជាគោលគំនិតទ្រឹស្តីនេះគឺមានសារៈប្រយោជន៍ក្នុងករណីដែលវត្ថុត្រូវបានវិភាគពុំនៅនឹងមួយកន្លែង ប៉ុន្តែមានលក្ខណៈរស់ ទំនាក់ទំនងទៅវិញទៅមក និងតែងប្រែប្រួលដោយអន្តរកម្ម ក្នុងចំណោមតួអង្គអនុវត្ត ដំណើការ និងលក្ខខណ្ឌជុំវិញ។

ការប្រើប្រាស់ទ្រឹស្តីស្តីពីប្រព័ន្ធទូទៅនេះគឺសមស្រប ព្រោះប្រព័ន្ធច្បាប់ពុំដំណើរការដោយឯកឯងពីបរិស្ថានជុំវិញនោះទេ ឬអាចដំណើរការបានដោយផ្អែកលើច្បាប់តែមួយផ្នែកប៉ុណ្ណោះនោះទេ។ ផ្ទុយទៅវិញ ប្រព័ន្ធច្បាប់រងឥទ្ធិពលពីបរិបទនយោបាយ សង្គម សេដ្ឋកិច្ច វប្បធម៌ បច្ចេកវិទ្យា និងបរិបទ អន្តរជាតិ។ ប្រព័ន្ធច្បាប់ត្រូវបានកំណត់ដោយគុណតម្លៃគ្រឹះ ហើយដំណើរការតាមរយៈស្ថាប័ន និងនីតិវិធី ដោយសម្រេចចេញជាលទ្ធផលនៃអភិបាលកិច្ច និងត្រូវឱ្យមានយន្តការសម្រាប់ពិនិត្យ កែតម្រូវ និងកែលម្អ ជាប្រចាំ។ ការប្រើប្រាស់ទ្រឹស្តីស្តីពីប្រព័ន្ធទូទៅនេះជាធម្យោបាយសម្រាប់ស្វែងយល់មិនត្រឹមតែធាតុផ្សំ នីមួយៗរបស់

ប្រព័ន្ធច្បាប់នោះទេ តែរួមទាំងទំនាក់ទំនងរវាងធាតុផ្សំទាំងនោះ ព្រមទាំងមុខងាររបស់ធាតុ ផ្សំនីមួយៗ សម្រាប់ដំណើរការប្រព័ន្ធទាំងមូល។

ដោយផ្អែកតាមមូលដ្ឋាននេះ ក្របខ័ណ្ឌទស្សនាទាននេះប្រើប្រាស់ទ្រឹស្តីស្តីពីប្រព័ន្ធទូទៅជាមធ្យោបាយសម្រាប់ការវិភាគមូលដ្ឋាននៃប្រព័ន្ធច្បាប់កម្ពុជា ដែលមានធាតុផ្សំដូចខាងក្រោម៖

- បរិស្ថាន (Environment) សំដៅដល់បរិបទទូលំទូលាយដែលមានប្រព័ន្ធដំណើរការនៅក្នុងនោះ រួមទាំងលក្ខខណ្ឌជាតិនិងខាងក្រៅដែលមានឥទ្ធិពលដល់ការអភិវឌ្ឍន៍ច្បាប់។
- ធាតុចូល (Inputs) សំដៅដល់គុណតម្លៃគ្រឹះដែលកំណត់ទិសដៅនៃប្រព័ន្ធច្បាប់។
- ដំណើរការ (Processes) សំដៅដល់ប្រតិបត្តិការក្នុងប្រព័ន្ធច្បាប់ រួមមានរចនាសម្ព័ន្ធគតិយុត្ត សារធាតុគតិយុត្ត និងវប្បធម៌គោរពច្បាប់។
- សមិទ្ធផល (Outputs) សំដៅដល់លទ្ធផលច្បាប់និងស្ថាប័នផ្ទាល់ដែលកើតចេញពីដំណាការនៃប្រព័ន្ធច្បាប់ រួមមានច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត វិធានការអនុវត្ត សកម្មភាពអនុវត្ត និងអានុភាពគតិយុត្តដែលពាក់ព័ន្ធ។
- ផលសម្រេច (Outcomes) សំដៅដល់លក្ខខណ្ឌទូលំទូលាយដែលគាំទ្រដោយប្រព័ន្ធច្បាប់ រួមមានសណ្តាប់ធ្នាប់សាធារណៈ ស្ថិរភាព ប្រសិទ្ធភាពអភិបាលកិច្ច និងការអភិវឌ្ឍន៍។
- ផលប៉ះពាល់ (Impacts) សំដៅដល់គោលបំណង់រយៈពេលវែង និងកម្រិតខ្ពស់ ដែលប្រព័ន្ធច្បាប់រួមចំណែករួមមាន យុត្តិធម៌ ភាពសុខដុមរមនា វិបុលភាព សន្តិភាព និងការពង្រឹងរដ្ឋ និងជាតិ។
- យន្តការវាយតម្លៃ (Feedback Loops) សំដៅដល់យន្តការសម្រាប់វាយតម្លៃ កែតម្រូវ កែសម្រួល និងកែលម្អប្រព័ន្ធច្បាប់ជាទៀងទាត់ ដែលធ្វើឱ្យប្រព័ន្ធច្បាប់អាចដំណើរការជាប្រព័ន្ធដែលមានលក្ខណៈរស់ ដែលត្រឹមជាបណ្តុំច្បាប់នៅនឹងមួយកន្លែង។

ការប្រើប្រាស់ទ្រឹស្តីស្តីពីប្រព័ន្ធទូទៅនៅក្នុងក្របខ័ណ្ឌទស្សនាទាននេះ បានផ្តល់នូវក្របខ័ណ្ឌសម្រាប់ការរៀបចំប្រព័ន្ធច្បាប់ក្នុងទម្រង់ប្រមូលផ្តុំ ដោយរក្សាធាតុផ្សំដែលជាគុណតម្លៃគ្រឹះ រចនាសម្ព័ន្ធខ្លឹមសារគតិយុត្ត វប្បធម៌គោរពច្បាប់ជាដើម ដែលមានសារៈសំខាន់សម្រាប់គោលបំណង នៅក្នុងក្របខ័ណ្ឌទស្សនាទាននេះព្រោះទ្រឹស្តីនេះផ្តល់មធ្យោបាយឱ្យមើលឃើញនូវប្រព័ន្ធច្បាប់ ជាបណ្តុំដែលមានទំនាក់ទំនងរវាងគ្នា ប្រែប្រួល និងវិវត្តន៍ជាប្រចាំ។ ទ្រឹស្តីនេះក៏ជួយដល់ការវិភាគ ជាប្រព័ន្ធដើម្បីកំណត់ធាតុផ្សំ ស្វែងយល់អំពីទំនាក់ទំនង វាយតម្លៃគម្លាតដែលមាន និងផ្តល់ទិសដៅ ដល់ការកែទម្រង់នាពេលអនាគត។

ក្នុងន័យនេះ ទ្រឹស្តីស្តីពីប្រព័ន្ធទូទៅត្រូវបានប្រើប្រាស់នៅក្នុងក្របខ័ណ្ឌទស្សនាទាននេះជាមូលដ្ឋានសម្រាប់វិភាគក្នុងការរៀបចំ វាយតម្លៃ និងផ្តល់ទិសដៅក្នុងការកសាងប្រព័ន្ធច្បាប់កម្ពុជាជាប្រព័ន្ធមួយដែលមានបូរណភាព ប្រទាក់ក្រឡា និងមានលក្ខណៈរស់រវើក។

# ៤. ប្រវត្តិនៃប្រព័ន្ធច្បាប់

## ៤.១. កំណើតនៃប្រព័ន្ធច្បាប់ក្នុងសង្គមមនុស្ស

ប្រវត្តិនៃប្រព័ន្ធច្បាប់ គឺជាប្រវត្តិនៃការវិវត្តរបស់សង្គមមនុស្សក្នុងការរៀបចំសណ្តាប់ធ្នាប់ កំណត់សិទ្ធិ និងកាតព្វកិច្ច និងដោះស្រាយវិវាទរវាងបុគ្គល និងបុគ្គល ឬរវាងបុគ្គល និងសហគមន៍។ នៅដំណាក់កាលដំបូងៗនៃការរស់នៅជាសហគមន៍ មនុស្សមិនទាន់មានក្រមច្បាប់ជាលាយលក្ខណ៍អក្សរដូចសម័យទំនើបទេ។ ការគ្រប់គ្រងសង្គមពឹងផ្អែកចម្បងលើបវេណី ទំនៀមទម្លាប់ ជំនឿសាសនា សីលធម៌ និងការសម្រេចរបស់ មេកន្ទ្រាញ មេក្រុម មេភូមិ ឬអ្នកមានអំណាច។ ហេតុនេះ ប្រព័ន្ធច្បាប់ដំបូងបំផុតមិនមែនចាប់ផ្តើមពីសៀវភៅក្រមទេ ប៉ុន្តែចាប់ផ្តើមពីជីវភាពសង្គម និងពីការរស់នៅរួមគ្នារបស់មនុស្ស ដែលតម្រូវឱ្យមានវិធានសម្រាប់ការពារសុខដុមរមនា និងទប់ស្កាត់ជម្លោះ។

### ៤.១.១ ការប្រែប្រួលពីទម្លាប់ទៅជាច្បាប់សរសេរ

នៅពេលសង្គមកាន់តែរីកចម្រើន ការរៀបចំរដ្ឋ ការបែងចែកអំណាច និងស្ថាប័ននានាចាប់ផ្តើមកើតមាន វិធានដែលធ្លាប់មានតែជាទម្លាប់ឬជំនឿសង្គម ក៏បានបម្លែងទៅជាវិធានគតិយុត្តដែលមានរចនាសម្ព័ន្ធកាន់តែច្បាស់។ ដំណើរនេះបង្ហាញថា ប្រវត្តិនៃប្រព័ន្ធច្បាប់ គឺជាដំណើរផ្លាស់ប្តូរពី "ច្បាប់អត់សរសេរ" ទៅ "ច្បាប់សរសេរ" ពីការគ្រប់គ្រងតាមទម្លាប់ ទៅការគ្រប់គ្រងតាមក្រមច្បាប់ និងពីការប្រើសីលធម៌សង្គមជាគោល ទៅការប្រើរដ្ឋ និងស្ថាប័នយុត្តិធម៌ជាអ្នកធានាអនុវត្ត។ ក្នុងន័យនេះ ប្រព័ន្ធច្បាប់មិនអាចផ្តាច់ខ្លួនចេញពីប្រវត្តិសាស្ត្រ វប្បធម៌ ជំនឿ សាសនា ប្រពៃណី ទំនៀមទម្លាប់ និងទស្សនវិជ្ជារបស់សង្គមនីមួយៗបានឡើយ ពីព្រោះវិធានច្បាប់តែងតែកើតចេញពីគំនិតអំពីអ្វីដែលត្រឹមត្រូវ អ្វីដែលយុត្តិធម៌ និងអ្វីដែលសង្គមទទួលយកថាគួរត្រូវអនុវត្ត។

### ៤.១.២ ការចងក្រងជាក្រម និងការរៀបចំច្បាប់ជាប្រព័ន្ធ

នៅក្នុងប្រវត្តិនៃប្រព័ន្ធច្បាប់ ការចងក្រងជាក្រម (Codification) គឺជាជំហានសំខាន់បំផុតមួយ។ ក្រមនីយកម្មមានន័យថា ការប្រមូល និងរៀបចំបទប្បញ្ញត្តិជាប្រព័ន្ធ ដើម្បីឱ្យងាយស្រួលក្នុងការបកស្រាយ ការប្រឹក្សា និងការអនុវត្ត។ ពេលច្បាប់ត្រូវបានសរសេរ និងរៀបចំជាក្រម វាធ្វើឱ្យមានភាពច្បាស់លាស់ ឯកសណ្ឋានភាព និងសន្តិសុខគតិយុត្ត។ ជាពិសេសក្នុងប្រព័ន្ធច្បាប់ស៊ីវិល ការបង្កើតច្បាប់ត្រូវបានយល់ថាជាអំណាចផ្តាច់មុខរបស់រដ្ឋ ឬស្ថាប័ននីតិបញ្ញត្តិ។ តុលាការមានតួនាទីអនុវត្ត និងបក

ស្រាយច្បាប់ជាចម្បង មិនមែនបង្កើតច្បាប់ដោយផ្ទាល់ឡើយ។ គោលការណ៍នេះបង្ហាញថា ប្រព័ន្ធច្បាប់ទំនើបបានភ្ជាប់យ៉ាងជិតស្និទ្ធជាមួយគំនិតអធិបតេយ្យភាពរបស់រដ្ឋ និងគោលការណ៍នីតិរដ្ឋ។

### ៤.១.៣ ប្រភពច្បាប់សរសេរ និងប្រភពច្បាប់អត់សរសេរ

ទោះបីយ៉ាងណា ប្រវត្តិនៃប្រព័ន្ធច្បាប់មិនមែនជាប្រវត្តិនៃច្បាប់សរសេរតែប៉ុណ្ណោះទេ។ សូម្បីតែនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល ដែលផ្តោតលើច្បាប់ជាលាយលក្ខណ៍អក្សរ ក៏នៅតែទទួលស្គាល់ប្រភពច្បាប់អត់សរសេរ។ ក្នុងនោះមាន បវេណី ឬទម្លាប់នៃការប្រើច្បាប់ ដែលកើតពីការអនុវត្តជាប្រចាំក្នុងសង្គម, លទ្ធិ ឬ Doctrine ដែលជាការសិក្សាស្រាវជ្រាវ ការធ្វើវិចារណកម្ម និងការបកស្រាយរបស់អ្នកប្រាជ្ញផ្នែកច្បាប់, និងយុត្តិសាស្ត្រ ដែលជាសេចក្តីសម្រេចមានសំអាងហេតុរបស់តុលាការ។ ក្នុងប្រព័ន្ធច្បាប់ស៊ីវិល យុត្តិសាស្ត្រមានតួនាទីជាឧបករណ៍ជំនួយដល់ការបកស្រាយច្បាប់ នៅពេលបទប្បញ្ញត្តិមានលក្ខណៈទូលាយ ឬមិនច្បាស់លាស់។ ប៉ុន្តែនៅក្នុងប្រព័ន្ធច្បាប់អង់គ្លូសាក់សុង យុត្តិសាស្ត្រវិញក្លាយជាមូលដ្ឋានគ្រឹះនៃការដោះស្រាយវិវាទ។ ចំណុចនេះបង្ហាញថា ប្រវត្តិនៃប្រព័ន្ធច្បាប់ គឺជាប្រវត្តិនៃទំនាក់ទំនងរវាងច្បាប់សរសេរ ច្បាប់អត់សរសេរ និងស្ថាប័នអនុវត្តច្បាប់។

### ៤.១.៤ សារៈសំខាន់នៃប្រវត្តិនៃប្រព័ន្ធច្បាប់

ដូច្នេះ ប្រវត្តិនៃប្រព័ន្ធច្បាប់អាចត្រូវបានយល់ថាជាប្រវត្តិនៃការស្វែងរក "សង្គតិភាព ឯកសណ្ឋានភាព និងសុខដុមនីយកម្ម" នៅក្នុងសង្គម។ នៅសម័យដំបូង វិធានកើតពីទំនៀមទម្លាប់ និងជំនឿ, នៅសម័យរដ្ឋ វិធានត្រូវបានចងក្រងជាក្រម និងបង្កើតជាឋានានុក្រមគតិយុត្ត, ហើយនៅសម័យទំនើបប្រព័ន្ធច្បាប់ត្រូវបានពង្រីកបន្ថែមដោយយន្តការនីតិកម្ម នីតិវិធី និងស្ថាប័នយុត្តិធម៌។ ការវិវត្តទាំងមូលនេះបង្ហាញថា ច្បាប់គឺជាផលិតផលរបស់សង្គម តែជាមួយគ្នានោះ វាក៏ជាឧបករណ៍សម្រាប់កសាងសង្គមវិញផងដែរ។

## ៤.២. ប្រវត្តិនៃប្រព័ន្ធច្បាប់សកល

### ៤.២.១ ទិដ្ឋភាពទូទៅនៃប្រពៃណីច្បាប់សកល

ប្រវត្តិនៃប្រព័ន្ធច្បាប់សកល មិនមែនសំដៅលើប្រព័ន្ធច្បាប់តែមួយដែលអនុវត្តដូចគ្នាទូទាំងពិភពលោកទេ ប៉ុន្តែសំដៅលើការវិវត្តនៃប្រពៃណីច្បាប់ធំៗ ដែលបានកើតឡើងនៅតំបន់ផ្សេងៗ និងបន្តមានឥទ្ធិពលលើពិភពលោករហូតមកដល់សព្វថ្ងៃ។ តាមរយៈការសិក្សា និងកម្រងឯកសារនៃសិក្ខាសាលាស្តីពីប្រព័ន្ធច្បាប់កម្ពុជា បានបង្ហាញច្បាស់អំពីប្រព័ន្ធច្បាប់ស៊ីវិល ប្រព័ន្ធច្បាប់អង់គ្លូសាក់សុង ឬខមមិនឡូ ប្រព័ន្ធច្បាប់សាសនាហិណ្ឌូ ទស្សនវិជ្ជាចិនបុរាណ និងទស្សនវិជ្ជាពុទ្ធសាសនា ដែលសុទ្ធតែជាមូលដ្ឋានសំខាន់ៗក្នុងប្រវត្តិសាស្ត្រច្បាប់សកល។ ប្រវត្តិនេះបង្ហាញថា ច្បាប់សកលកើតមិនមែនត្រឹមតែពីរដ្ឋនិង

តុលាការទេ ប៉ុន្តែកើតពីជំនឿ ទស្សនវិជ្ជា ប្រពៃណីទំនៀមទម្លាប់ និងការកសាងអំណាចនយោបាយផង ដែរ។

### ៤.២.២ ប្រព័ន្ធច្បាប់ស៊ីវិល និងឫសគល់ច្បាប់រ៉ូម៉ាំង

ប្រព័ន្ធច្បាប់ស៊ីវិល (Civil Law ឬ Romano-germanique) មានឫសគល់ជ្រៅពីច្បាប់រ៉ូម៉ាំង។ ឯកសារបញ្ជាក់ថា ច្បាប់ស៊ីវិលមានប្រវត្តិចេញមកពីច្បាប់រ៉ូម៉ាំងនៅចន្លោះសតវត្សទី៦ គ.ស. ហើយក្រោយការដួលរលំនៃអាណាចក្ររ៉ូម៉ាំងខាងលិច ច្បាប់រ៉ូម៉ាំងនៅតែបន្តមានឥទ្ធិពលនៅអាណាចក្ររ៉ូម៉ាំងខាងកើត។ បន្ទាប់មក វាបានវិវត្តបន្តនៅអឺរ៉ុបតាមរយៈការសិក្សា ការចងក្រង និងការសម្របសម្រួលជាមួយទម្លាប់នានា។ ដំណាក់កាលសំខាន់ពីរដែលឯកសារលើកឡើងគឺ ស្នាដៃរបស់ Jean Domat នៅសតវត្សទី១៧ និងការធ្វើក្រមរដ្ឋប្បវេណីបារាំងឆ្នាំ១៨០៤ ឬ Code Napoléon។ ប្រព័ន្ធនេះផ្អែកលើគោលការណ៍ចម្បងដូចជា ការធ្វើក្រមនីយកម្ម អធិបតេយ្យភាពនៃច្បាប់សរសេរ និងអំណាចផ្តាច់មុខរបស់រដ្ឋក្នុងការបង្កើតច្បាប់។ លើសពីនេះ វាក៏ទទួលឥទ្ធិពលពីទស្សនវិជ្ជាសម័យ Enlightenment ដែលសង្កត់ធ្ងន់លើភាពសមហេតុផល សមភាព យុត្តិធម៌ កម្មសិទ្ធិ និងច្បាប់ធម្មជាតិ។ តាមរយៈអាណានិគមបារាំង អេស្ប៉ាញ និងព័រទុយហ្គាល់ ប្រព័ន្ធច្បាប់ស៊ីវិលបានរីករាលដាលទៅអាមេរិកឡាទីន អាហ្វ្រិក និងអាស៊ី ហើយក្លាយជាប្រព័ន្ធច្បាប់សំខាន់មួយលើសកលលោក។

### ៤.២.៣ ប្រព័ន្ធច្បាប់អង់គ្លូសាក់សុង និងតួនាទីរបស់យុត្តិសាស្ត្រ

ផ្ទុយពីប្រព័ន្ធច្បាប់ស៊ីវិល ប្រព័ន្ធច្បាប់អង់គ្លូសាក់សុង (Common Law) លេចឡើងជាលើកដំបូងនៅអង់គ្លេស។ មុនឆ្នាំ១០៦៦ ប្រទេសអង់គ្លេសនៅសម័យ Anglo-Saxon ពឹងផ្អែកលើទម្លាប់ទំនៀមទម្លាប់ក្នុងស្រុក មិនទាន់មានច្បាប់កណ្តាលឯកភាពទូទាំងប្រទេស និងមិនទាន់មានតុលាការកណ្តាលដែលអនុវត្តច្បាប់តែមួយឡើយ។ ក្រោយ Norman Conquest ឆ្នាំ១០៦៦ ស្តេច William I បានពង្រឹងអំណាចកណ្តាល និងបង្កើត Curia Regis ដែលជាតុលាការរាជវង្ស និងជាគ្រឹះសម្រាប់នីតិរូម។ ការវិវត្តសំខាន់បំផុតកើតឡើងនៅរជ្ជកាលស្តេច Henry II (១១៥៤–១១៨៩) ដែលត្រូវបានគេហៅថា "បិតានៃនីតិរូម"។ ព្រះអង្គបានបង្កើតប្រព័ន្ធចៅក្រមធ្វើដំណើរ (circuit) ការអនុវត្តច្បាប់ឱ្យមានឯកសណ្ឋានទូទាំងប្រទេស ប្រព័ន្ធ writs និងប្រព័ន្ធគណៈវិនិច្ឆ័យ។ ក្រោយមក Magna Carta ឆ្នាំ១២១៥ បានក្លាយជាឯកសារសំខាន់បំផុតមួយសម្រាប់ការអភិវឌ្ឍគោលការណ៍ due process, fair trial និង rule of law។ នៅសតវត្សរ៍ទី១៣ តុលាការ Common Pleas, King's Bench និង Exchequer បានលេចឡើងជារចនាសម្ព័ន្ធសំខាន់ៗ។ ចាប់ពីសតវត្សទី១៦ ដល់ទី១៧ ច្បាប់សមធម៌ (Equity) ក្រោមតុលាការ Chancery បានបន្ថែមវិធានការសមធម៌ឱ្យប្រព័ន្ធច្បាប់អង់គ្លូសាក់សុង។ នៅសតវត្សទី១៩ ការរួមបញ្ចូល Law និង Equity តាម Judicature Acts ឆ្នាំ ១៨៧៣–១៨៧៥ បានធ្វើឱ្យប្រព័ន្ធនេះកាន់តែពេញលេញ។ ដល់ដើមសតវត្សទី២០ ខមមិនឡមានអត្ត

សញ្ញាណច្បាស់តាមគោលការណ៍ stare decisis ប្រព័ន្ធ jury និងឯករាជ្យភាពតុលាការ ហើយបានរីកសាយភាយទៅប្រទេសជាច្រើនតាមរយៈអាណានិគមអង់គ្លេស។

### ៤.២.៤ ប្រព័ន្ធច្បាប់ហិណ្ឌូ និងគោលគំនិត Dharma

ក្រៅពីប្រព័ន្ធច្បាប់អឺរ៉ុបទាំងពីរ ប្រព័ន្ធច្បាប់សាសនាហិណ្ឌូក៏ជាមរតកច្បាប់ដ៏សំខាន់មួយនៅក្នុងប្រវត្តិនៃប្រព័ន្ធច្បាប់សកល។ វិធីសាស្ត្រនីតិកម្មរបស់ហិណ្ឌូផ្អែកលើសញ្ញាណ Dharma ដែលបង្ហាញទាំងសណ្តាប់ធ្នាប់ចក្រវាល សណ្តាប់ធ្នាប់សង្គម និងកាតព្វកិច្ចរបស់មនុស្ស។ ឯកសារបង្ហាញថា ប្រភពនៃច្បាប់ហិណ្ឌូតាម Manu មានចម្បងដូចជា Shruti ដែលជាចំណេះដឹងសក្ការៈក្នុង Vedas, Smriti ដែលជាការប្រមូលចងក្រងនៃអត្ថបទ ដូចជា Puranas, Mahābhārata, Rāmāyaṇa, Bhagavad Gita, Kalpa Sutras និង Dharmashastras, Sadachar ដែលសំដៅលើទំនៀមទម្លាប់ល្អ ឬការអនុវត្តក្នុងគ្រួសារ និងសហគមន៍, និង Swatah Prajna ដែលសំដៅលើការយល់ដឹងល្អរបស់ខ្លួនឯង។ ប្រព័ន្ធនេះបង្ហាញថា ច្បាប់មិនត្រូវបានយល់ត្រឹមតែជាបទប្បញ្ញត្តិរបស់រដ្ឋប៉ុណ្ណោះទេ ប៉ុន្តែជាផ្នែកមួយនៃទស្សនវិជ្ជា សាសនា និងសណ្តាប់ធ្នាប់សង្គម។ ចៅក្រម និងស្តេចត្រូវពឹងផ្អែកលើ Smriti និង Sadachar ជាចម្បងក្នុងការសម្រេចក្តី ហើយនៅពេលច្បាប់មិនគ្រប់គ្រាន់ ការយល់ខុសត្រូវរបស់ស្តេចអាចត្រូវបានយកមកប្រើ។ នេះបង្ហាញថា ប្រព័ន្ធច្បាប់ហិណ្ឌូជាប្រព័ន្ធដែលសម្របសម្រួលរវាងគម្ពីរ ទម្លាប់ និងអំណាចនយោបាយ។

### ៤.២.៥ ទស្សនវិជ្ជាចិនបុរាណ និងការយល់អំពីច្បាប់

នៅអាស៊ីបូព៌ា ទស្សនវិជ្ជាចិនបុរាណបានបង្កើតមូលដ្ឋានដ៏រឹងមាំសម្រាប់ច្បាប់ និងការគ្រប់គ្រង។ ឯកសារបញ្ជាក់ថា នៅរាជវង្សចូវខាងកើត ចន្លោះឆ្នាំ៧៧០ ដល់ ២៥៦ មុនគ.ស. ទស្សនវិទូជាច្រើនបានបង្កើតគំនិតស្តីពីសង្គម ច្បាប់ និងសីលធម៌។ ក្នុងចំណោមនោះ លទ្ធិខុងជឺ និងនីតិនិយម គឺមានឥទ្ធិពលខ្លាំងជាងគេ។ លទ្ធិខុងជឺ ដែលកើតឡើងនៅសតវត្សទី៦–៥ មុនគ.ស. ផ្តោតលើគុណធម៌ អាកប្បកិរិយាធ្វើពិធីសាសនា មនុស្សធម៌ ការគោរពប្រតិបត្តិរបស់កុមារ និងអភិបាលកិច្ចល្អ។ ខុងជឺ យល់ថា សណ្តាប់ធ្នាប់សង្គមកើតពីការរស់នៅតាមតួនាទីសង្គម ការគោរពចាស់ទុំ និងការប្រព្រឹត្តដោយគុណធម៌។ ផ្ទុយទៅវិញ នីតិនិយមផ្តល់អាទិភាពដល់រដ្ឋខ្លាំង ច្បាប់ឯកសណ្ឋាន ការអនុវត្តនិងទណ្ឌកម្មតឹងរ៉ឹង។ ទស្សនវិទូដូចជា Shang Yang, Han Fei និង Li Si បានជួយបង្កើតមូលដ្ឋានសម្រាប់ការបង្រួបបង្រួមរបស់រាជវង្ស Qin នៅឆ្នាំ២២១ មុនគ.ស.។ ដូច្នេះ វប្បធម៌ច្បាប់ចិនកើតឡើងពីអន្តរកម្មរវាងសីលធម៌ខុងជឺ និងសិទ្ធិអំណាចរដ្ឋបែបនីតិនិយម ដែលធ្វើឱ្យច្បាប់ត្រូវបានយល់ថាជាឧបករណ៍នៃអភិបាលកិច្ច មិនមែនត្រឹមតែជាឧបករណ៍ការពារសិទ្ធិបុគ្គលនោះឡើយ។

### ៤.២.៦ ពុទ្ធសាសនា និងមូលដ្ឋាននៃច្បាប់សង្គម

ទស្សនវិជ្ជាពុទ្ធសាសនា និងច្បាប់សង្គមក៏ជាផ្នែកសំខាន់មួយនៃប្រវត្តិនៃប្រព័ន្ធច្បាប់សកលផងដែរ ជាពិសេសក្នុងប្រទេសអាស៊ី។ ព្រះពុទ្ធសាសនាកើតនៅប្រទេសឥណ្ឌាកាលពីបុរាណ និងបន្តរីកសាយភាយទៅតំបន់ជាច្រើន។ ក្នុងឯកសារ គម្ពីរព្រះត្រៃបិដកត្រូវបានបង្ហាញថាជាឃ្លាំងផ្ទុកធម្មវិន័យ ដែលមានវិនយបិដក សុត្តន្តបិដក និងអភិធម្មបិដក។ វិនយបិដកពិសេស មានលក្ខណៈជាច្បាប់ក្រឹត្យក្រមសម្រាប់ផ្លូវប្រតិបត្តិ។ លើសពីនេះ គោលការណ៍ព្រហ្មវិហារធម៌ ទ្រឹស្តីកម្មផល អរិយសច្ច៤ ទសពិធរាជធម៌ និងគោលការណ៍អនាគតិ សុទ្ធតែបង្ហាញពីទំនាក់ទំនងជ្រាលជ្រៅរវាងសីលធម៌ និងច្បាប់សង្គម។ ព្រហ្មវិហារធម៌លើកទឹកចិត្តឱ្យច្បាប់បម្រើសុខុមាលភាពសង្គម និងការការពារក្រុមជនងាយរងគ្រោះ, ទ្រឹស្តីកម្មផលបង្កើតមូលដ្ឋាននៃការទទួលខុសត្រូវលើសកម្មភាពខ្លួន, អរិយសច្ច៤ផ្តល់ក្របខ័ណ្ឌមួយសម្រាប់យល់អំពីមូលហេតុនៃវិវាទ និងវិធីដោះស្រាយដោយសន្តិភាព, ទសពិធរាជធម៌បង្កើតគំរូនៃអភិបាលកិច្ចល្អ, ហើយគោលការណ៍អនាគតិលើកតម្កើងភាពមិនលម្អៀង និងយុត្តិធម៌។ ដូច្នេះ ពុទ្ធសាសនាមិនត្រឹមជាសាសនាទេ ប៉ុន្តែជាប្រភពនៃគំនិតច្បាប់សង្គម និងវប្បធម៌នីតិរដ្ឋផងដែរ។

### ៤.២.៧ សេចក្តីសន្និដ្ឋានអំពីប្រព័ន្ធច្បាប់សកល

សរុបមក ប្រវត្តិនៃប្រព័ន្ធច្បាប់សកលបង្ហាញថា ពិភពលោកមិនមានប្រភពច្បាប់តែមួយឡើយ។ ប្រព័ន្ធច្បាប់ស៊ីវិលបញ្ជាក់ពីអំណាចនៃក្រមនីយកម្ម និងរដ្ឋ, ប្រព័ន្ធច្បាប់អង់គ្លូសាក់សុងបញ្ជាក់ពីតួនាទីរបស់តុលាការ និងយុត្តិសាស្ត្រ, ប្រព័ន្ធច្បាប់ហិណ្ឌូបង្ហាញពីការបញ្ចូលគ្នារវាង Dharma គម្ពីរ និងទម្លាប់, ទស្សនវិជ្ជាចិនបុរាណបង្ហាញពីការប្រឈមរវាងគុណធម៌ និងអំណាចរដ្ឋ, ហើយពុទ្ធសាសនាបញ្ជាក់ថា សីលធម៌ ករុណា និងភាពមិនលម្អៀងអាចក្លាយជាមូលដ្ឋានសម្រាប់ច្បាប់ និងយុត្តិធម៌សង្គម។ នេះហើយជារូបភាពធំរបស់ប្រវត្តិនៃប្រព័ន្ធច្បាប់សកលដែលឯកសារបានបង្ហាញ។

## ៤.៣. ប្រវត្តិនៃប្រព័ន្ធច្បាប់កម្ពុជា

### ៤.៣.១ ទិដ្ឋភាពទូទៅនៃការវិវត្តនៃប្រព័ន្ធច្បាប់កម្ពុជា

ប្រវត្តិនៃប្រព័ន្ធច្បាប់កម្ពុជា មានលក្ខណៈយូរលង់ និងស្មុគស្មាញ ដោយឆ្លុះបញ្ចាំងពីការប្រែប្រួលនយោបាយ សង្គម វប្បធម៌ សាសនា និងឥទ្ធិពលបរទេសក្នុងគ្រប់សម័យកាល។ ឯកសារបានបញ្ជាក់ថា កម្ពុជា ត្រូវបានគ្រប់គ្រងដោយអង្គព្រះមហាក្សត្រជាសន្តតិវង្សជាច្រើនជំនាន់ ប្រកបដោយទសពិធរាជធម៌ និងគោរពច្បាប់ ដោយលើកតម្កើងច្បាប់ឱ្យខ្ពង់ខ្ពស់។ ក្នុងន័យនេះ ប្រវត្តិច្បាប់ខ្មែរអាចយល់បានថា ជាប្រវត្តិនៃការគ្រប់គ្រងដោយច្បាប់ តាំងពីសម័យបុរាណរហូតដល់សម័យទំនើប បើទោះបីជាទម្រង់ នីតិវិធី និងប្រភពនៃច្បាប់បានផ្លាស់ប្តូរតាមសម័យកាលក៏ដោយ។ ប្រព័ន្ធច្បាប់កម្ពុជា មិនមែនកើតឡើងភ្លាមៗនៅ

សម័យទំនើបទេ ប៉ុន្តែបានសង់លើមូលដ្ឋានច្បាប់ប្រពៃណី ទំនៀមទម្លាប់ខ្មែរ ឥទ្ធិពលឥណ្ឌា ពុទ្ធសាសនា និងបន្ទាប់មកគឺប្រព័ន្ធច្បាប់ស៊ីវិលបែបបារាំង។

### ៤.៣.២ សម័យបុរេប្រវត្តិ និងច្បាប់ប្រពៃណីខ្មែរ

នៅសម័យបុរេប្រវត្តិ ខ្មែរយើងមិនទាន់មានអក្សរសម្រាប់កត់ត្រាច្បាប់ ឬព្រឹត្តិការណ៍រស់នៅប្រចាំថ្ងៃទេ ប៉ុន្តែវាមិនមានន័យថាមនុស្សមិនមានច្បាប់ឡើយ។ តាមការសិក្សាបុរាណវិទ្យា និងនរវិទ្យា សង្គមខ្មែរបុរាណបានរស់នៅជាសហគមន៍ មានការបែងចែកជាភូមិ ស្រុក មានទំនៀមទម្លាប់ មានជំនឿលើអារក្សអ្នកតា ខ្មោចដូនតា និងមានសីលធម៌នៃការរាប់រកគ្នា។ ភស្តុតាងដូចជាការកប់សម្ភារប្រើប្រាស់ និងម្ហូបអាហារនៅក្នុងផ្នូរ បង្ហាញថាមនុស្សមានគំនិតអំពីបុណ្យ បាប គុណ ទោស និងការគោរពអ្នកស្លាប់។ នេះបង្ហាញថា ទោះបីមិនទាន់មានក្រមសរសេរក៏ដោយ សង្គមខ្មែរបុរាណមានច្បាប់ប្រពៃណី និងវិធានសង្គមរួចហើយ។ ឯកសារក៏បញ្ជាក់ថា ខ្មែរបុរាណបានបង្កើតភូមិស្រុក ចេះធ្វើកសិកម្ម ចិញ្ចឹមសត្វ ចេះរៀបចំជីវភាពសេដ្ឋកិច្ច និងមានប្រព័ន្ធរដ្ឋបាលបឋមផងដែរ។ ដូច្នេះ សម័យបុរេប្រវត្តិគឺជាមូលដ្ឋានដើមនៃប្រព័ន្ធច្បាប់ខ្មែរដែលពឹងផ្អែកលើបវេណី និងការរស់នៅរួមរបស់សហគមន៍។

### ៤.៣.៣ សម័យហ្វូណន និងការទទួលឥទ្ធិពលឥណ្ឌា

នៅសម័យហ្វូណន ចាប់ពីសតវត្សទី១ ដល់ទី៦ នៃគ.ស. ប្រព័ន្ធច្បាប់ខ្មែរចាប់ផ្ដើមទទួលឥទ្ធិពលយ៉ាងច្បាស់ពីឥណ្ឌា។ ជនជាតិឥណ្ឌាដែលមកប្រកបរបរជំនួញបាននាំយកលទ្ធិហិណ្ឌូ ព្រះពុទ្ធសាសនា ភាសាសំស្ក្រឹត និងច្បាប់ដែលគេប្រើនៅឥណ្ឌាមកជាមួយ។ ហ្វូណនកើតឡើងពីនគរតូចៗជាច្រើន ហើយព្រះរាជាតែងបញ្ជូនមន្ត្រីទៅត្រួតត្រាតាមខេត្ត និងបុរីនានា។ មន្ត្រីទាំងនេះមានភារកិច្ចទទួលពាក្យបណ្ដឹងពីប្រជារាស្ត្រ រីឯ ព្រះរាជាបើកសវនាការជាសាធារណៈ ព្រះរាជាគឺជាចៅក្រមដែលសម្រេចក្ដី។ ទោះយ៉ាងនេះក្ដី ឯកសារបង្ហាញថា សម័យហ្វូណនពុំទាន់មានវិធានច្បាប់ដែលចែងជាក់លាក់ដូចក្រមទំនើបទេ។ វិធានភាគច្រើនជាទម្លាប់ និងសីលធម៌តាមបែបសាសនា ដែលប្រជារាស្ត្រប្រកាន់យកក្នុងជីវភាពប្រចាំថ្ងៃ។ សេចក្ដីនេះមានន័យថា ប្រព័ន្ធច្បាប់ហ្វូណនគឺជាចំណុចប្រសព្វរវាងច្បាប់ប្រពៃណីខ្មែរ និងឥទ្ធិពលឥណ្ឌា។

### ៤.៣.៤ សម័យចេនឡា និងការរៀបចំរដ្ឋបាលនីតិ

នៅសម័យចេនឡា សង្គមដែលបន្សល់ទុកពីហ្វូណនត្រូវបានរក្សាទុក និងរៀបចំបន្ត។ អាណាចក្រចេនឡាត្រូវបានចែកជា៣០បុរី ដែលបុរីនីមួយៗស្ថិតក្រោមការគ្រប់គ្រងរបស់អភិបាលម្នាក់។ មន្ត្រីរាជវាំងត្រូវបានបញ្ជូនទៅត្រួតពិនិត្យ និងដាក់ទណ្ឌកម្មចំពោះការបំពាននានា។ នៅក្នុងវិស័យទំនាក់ទំនងគ្រួសារ និងមរតក ឯកសារបង្ហាញពីទម្លាប់ច្បាប់មួយចំនួនដែលគួរឱ្យកត់សម្គាល់ ដូចជា បុរសជាអ្នកចូលដណ្ដឹងស្រី កូនកម្លោះទទួលនូវមរតកពីឪពុកម្ដាយរបស់ខ្លួនដើម្បីរកផ្ទះនៅផ្សេង ហើយក្នុងករណីខ្លះទ្រព្យសម្បត្តិអាចក្លាយ

ជារបស់រដ្ឋ។ ទាំងនេះបង្ហាញថា ប្រព័ន្ធច្បាប់នៅសម័យចេនឡាមានទម្រង់ជាច្បាប់ប្រពៃណី ដែលភ្ជាប់ជាមួយរចនាសម្ព័ន្ធនយោបាយ និងការរៀបចំសង្គមតាមឋានានុក្រម។

### ៤.៣.៥ សម័យអង្គរ និងការបញ្ចូលគ្នារវាងធម៌ ទម្លាប់ និងព្រះរាជបញ្ញា

សម័យអង្គរ គឺជាដំណាក់កាលសំខាន់ខ្លាំងបំផុតមួយនៅក្នុងប្រវត្តិនៃប្រព័ន្ធច្បាប់កម្ពុជា។ ឯកសារបញ្ជាក់ថា អត្ថបទឥណ្ឌាពីបុរាណបានជះឥទ្ធិពលយ៉ាងខ្លាំងលើសម័យនេះ។ ក្នុងទស្សនៈឥណ្ឌា ច្បាប់ជាសំណុំវិធានដែលកំណត់ទំនាក់ទំនងរវាងបុគ្គល និងត្រូវបានគេអនុវត្តដោយអំណាចបង្ខិតបង្ខំ។ នៅអង្គរច្បាប់គឺជាការបញ្ចូលគ្នារវាង "ធម៌ ទម្លាប់ និងព្រះរាជបញ្ញា"។ វិធានទាំងនេះត្រូវបានចងក្រងជាអត្ថបទ ដូចជា គម្ពីរធម្មសាស្ត្រ និងជាពិសេសក្រម Manu ដែលមានឥទ្ធិពលលើការរៀបចំរឿងក្ដី កាតព្វកិច្ចរបស់ព្រះមហាក្សត្រ និងរដ្ឋបាល។ ប៉ុន្តែចំណុចដ៏សំខាន់មួយដែលឯកសារលើកឡើងគឺ នៅពេលវិធាននៃធម្មសាស្ត្រប៉ះទង្គិចជាមួយទម្លាប់របស់សង្គមខ្មែរ វិធានតាមទម្លាប់អាចត្រូវបានយកប្រើជំនួសវិញ។ នេះបង្ហាញថា អង្គរមិនបានទទួលយកច្បាប់ឥណ្ឌាទាំងស្រុងដោយគ្មានការកែសម្រួលទេ ប៉ុន្តែបានបន្សុំវាជាមួយទម្លាប់ខ្មែរ។ លើសពីនេះ ច្បាប់ និងបទប្បញ្ញត្តិត្រូវបានប្រកាសផ្សាយជាសាធារណៈតាមការប្រកូកប្រកាស ការចារលើផ្ទាំងសិលា ការដាក់តាំងនៅច្រកទ្វារ និងការចារឹកលើស្បែកសត្វ ឬបន្ទះលោហៈ។ នេះបង្ហាញពីសារៈសំខាន់របស់ការផ្សព្វផ្សាយច្បាប់ និងសន្តិសុខគតិយុត្តនៅសម័យអង្គរ។

### ៤.៣.៦ សម័យក្រោយអង្គរ និងការរៀបរៀងក្រមខ្មែរ

ក្រោយការដួលរលំសម័យអង្គរ ប្រព័ន្ធច្បាប់ខ្មែរមិនបានបាត់បង់ទាំងស្រុងឡើយ ប៉ុន្តែបានបន្តរស់ជាមួយមនុស្សដែលនៅចេះ និងចងចាំចំណេះដឹងទាំងនោះតជំនាន់ និងបានវិវត្តក្នុងទម្រង់ថ្មី និងចងក្រងឡើងវិញ។ ឯកសារស្រាវជ្រាវបានបញ្ជាក់ថា នៅសម័យក្រោយអង្គរ "ក្រមខ្មែរ" ត្រូវបានរៀបរៀងឡើងវិញក្នុងរជ្ជកាលព្រះបាទជ័យជេដ្ឋា ប្រមាណឆ្នាំ១៦២០ ដោយសារព្រះអង្គបានសង្កេតឃើញការបំពាន និងភាពអយុត្តិធម៌ជាច្រើនក្នុងជួរតុលាការ។ ការរៀបរៀងនេះបង្ហាញថា ខ្មែរមានប្រពៃណីក្រមនីយកម្មរួចមកហើយ មុនសម័យអាណានិគមបារាំង។ ក្រោយមក ក្រមខ្មែរត្រូវបានកែសម្រួលជាបន្តបន្ទាប់ក្នុងរជ្ជកាលព្រះមហាក្សត្រផ្សេងៗ ដូចជា ព្រះបាទអង្គដួង និងព្រះមហាក្សត្រក្រោយៗទៀត។ ឯកសារក៏លើកឡើងថា ប្រព័ន្ធច្បាប់កម្ពុជាត្រូវបានរៀបចំ និងកែប្រែឡើងវិញចំនួនជាច្រើនលើកនៅចន្លោះសតវត្សទី១៧ ដល់សតវត្សទី១៩។ ដូច្នេះ សម័យក្រោយអង្គរ គឺជាសម័យដែលច្បាប់ខ្មែរបន្តរក្សាទម្រង់ជាច្បាប់ប្រពៃណី និងក្រមរាជ្យ ដែលឈរលើបទពិសោធន៍សង្គមខ្មែរ។

### ៤.៣.៧ សម័យអាណានិគមបារាំង និងការបំលែងទៅប្រព័ន្ធច្បាប់ស៊ីវិល

នៅសម័យអាណានិគមបារាំង ពីឆ្នាំ១៨៦៣ ដល់១៩៥៣ ប្រព័ន្ធច្បាប់កម្ពុជាបានឆ្លងកាត់ការប្រែប្រួលដ៏ធំមួយ។ ឯកសារលើកឡើងថា ក្រមទាំងអស់មានចំនួន៥២ក្រម ហើយក្នុងនោះមាន៣៩ក្រមត្រូវបាន

ផ្សព្វផ្សាយក្នុងរជ្ជកាលព្រះបាទនរោត្តមនៅឆ្នាំ១៨៨១។ លោក Adhémard Leclère បានស្រង់បញ្ជីក្រមទាំងនេះឡើងវិញ បកប្រែជាភាសាបារាំង និងបោះពុម្ពផ្សាយក្នុងឆ្នាំ១៨៩៨ ក្រោមចំណងជើង "Les codes cambodgiens"។ ការវាយតម្លៃរបស់គាត់បង្ហាញថា ច្បាប់ខ្មែរបុរាណភាគច្រើនមិនមែនជាក្រមសរសេរដែលបង្កើតឡើងដោយវិធីសាស្ត្រទំនើបទេ ប៉ុន្តែជាការចងក្រងផ្លូវការនៃសេចក្តីសម្រេចរបស់តុលាការ និងទំនៀមទម្លាប់ដែលប្រជារាស្ត្រទទួលយក។ ទោះជាយ៉ាងណា ដំណាក់កាលសំខាន់ពិតប្រាកដនៃការបំលែងច្បាប់ខ្មែរទៅជាប្រព័ន្ធច្បាប់ស៊ីវិលកើតឡើងនៅដើមសតវត្សទី២០។ ព្រះរាជប្បញ្ញត្តិថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩១១ បានប្រកាសឱ្យប្រើក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមស្តីពីការរៀបចំតុលាការ ដែលចូលជាធរមាននៅថ្ងៃទី១ ខែកក្កដា ឆ្នាំ១៩១២។ ក្រោយមក ព្រះរាជប្បញ្ញត្តិឆ្នាំ១៩២០ បានប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណី នីតិវិធីរដ្ឋប្បវេណី និងការរៀបចំសាលាជំរះក្តីរដ្ឋប្បវេណី។ ចាប់ពីពេលនោះមក កម្ពុជាបានចាប់ផ្តើមប្រកាន់យកប្រព័ន្ធច្បាប់ Civil Law យ៉ាងពិតប្រាកដ ហើយរដ្ឋធម្មនុញ្ញដំបូងក៏បានកើតឡើងនៅឆ្នាំ១៩៤៧។

### ៤.៣.៨ ក្រោយឯករាជ្យ ដល់របបកម្ពុជាប្រជាធិបតេយ្យ

ក្រោយទទួលបានឯករាជ្យ ព្រះរាជាណាចក្រកម្ពុជាបានបន្តអភិវឌ្ឍនីតិកម្មយ៉ាងខ្លាំង។ នៅដំណាក់កាលសង្គមរាស្ត្រនិយម (១៩៥៥–១៩៧០) ឯកសារបង្ហាញថា កម្ពុជាមានសកម្មភាពនីតិកម្មខ្លាំងក្លា និងការរីកចម្រើនគួរឱ្យកត់សម្គាល់ក្នុងវិស័យនីតិសាស្ត្រ។ ពីឆ្នាំ១៩៤៧ ដល់ឆ្នាំ១៩៥៦ ក្រមរដ្ឋប្បវេណី ក្រមពាណិជ្ជកម្ម និងក្រមព្រហ្មទណ្ឌត្រូវបានប្រកាសឱ្យប្រើ ហើយមហាវិទ្យាល័យនីតិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជាក៏ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៥៧។ ប៉ុន្តែក្នុងរបបសាធារណរដ្ឋខ្មែរ (១៩៧០–១៩៧៥) សង្គ្រាមស៊ីវិលបានធ្វើឱ្យការសិក្សាស្រាវជ្រាវ និងការអភិវឌ្ឍផ្នែកច្បាប់ត្រូវផ្អាក។ បន្ទាប់មក ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥–១៩៧៩) ប្រព័ន្ធច្បាប់ដែលមានមុនត្រូវបានបំផ្លាញ និងបោះបង់ចោល ស្ទើរតែទាំងស្រុងក្នុងបំណងកសាងសង្គមកុម្មុយនីស្តឥតខ្ចោះ។ ឯកសារពណ៌នាដំណាក់កាលនេះថាជា "សង្គមមួយគ្មានច្បាប់" ដែលមិនអនុញ្ញាតឱ្យមានការសំអាងលើប្រព័ន្ធគតិយុត្តណាមួយឡើយ។

### ៤.៣.៩ ការកសាងឡើងវិញក្រោយឆ្នាំ១៩៧៩ និងក្រោយរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣

ក្រោយឆ្នាំ១៩៧៩ កម្ពុជាបានចាប់ផ្តើមកសាងប្រព័ន្ធច្បាប់ឡើងវិញ ប៉ុន្តែក្នុងទិសដៅខុសពីសម័យមុន។ នៅរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា (១៩៧៩–១៩៨៩) រដ្ឋធម្មនុញ្ញឆ្នាំ១៩៨១ បានចារឹកមនោគមវិជ្ជាកុម្មុយនីស្ត ហើយប្រព័ន្ធច្បាប់មានលក្ខណៈផ្ទុយពីប្រព័ន្ធច្បាប់គហបតី ដោយលុបបំបាត់គោលការណ៍កម្មសិទ្ធិបុគ្គល និងទុកសល់តែច្បាប់សាធារណៈជាចម្បង។ នៅសម័យរដ្ឋកម្ពុជា (១៩៨៩–១៩៩១) ការរលំរលាយនៃប្លុកកុម្មុយនីស្តបានបើកផ្លូវឱ្យមានការកែទម្រង់ថ្មីៗ ដូចជា ការទទួលស្គាល់ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ការទទួលស្គាល់ផ្នែកឯកជន និងកម្មសិទ្ធិឯកជន។ បន្ទាប់ពីកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសឆ្នាំ១៩៩១ និងដំណាក់កាលអន្តរកាល (១៩៩១–១៩៩៣) កម្ពុជាបានបង្កើតសភាធម្មនុញ្ញ និង

អនុម័តរដ្ឋធម្មនុញ្ញថ្មី នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ ដែលត្រូវបានប្រកាសឱ្យប្រើជាផ្លូវការនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។ នេះជាចំណុចរបត់ដ៏ធំមួយក្នុងការកសាងប្រព័ន្ធច្បាប់កម្ពុជាទំនើប។

#### ៤.៣.១០ អត្តសញ្ញាណនៃប្រព័ន្ធច្បាប់កម្ពុជាសម័យទំនើប

ក្រោយការបោះឆ្នោតសកលឆ្នាំ១៩៩៣ ប្រព័ន្ធច្បាប់កម្ពុជាបានត្រូវរៀបចំឡើងវិញក្នុងបរិបទនយោបាយ សេដ្ឋកិច្ច និងសង្គមថ្មី។ ឯកសារបញ្ជាក់ថា ច្បាប់សរសេរ ការចងក្រងជាក្រម និងឋានានុក្រមគតិយុត្ត គឺជាអត្តសញ្ញាណសំខាន់នៃប្រព័ន្ធច្បាប់កម្ពុជាទំនើប។ ទោះជាយ៉ាងណា កម្ពុជាមិនបានស្ថាបនាប្រព័ន្ធច្បាប់ថ្មីដោយផ្តាច់ចេញពីប្រវត្តិសាស្ត្រខ្លួនឯងទេ។ ផ្ទុយទៅវិញ វាជាការបន្សីរវាងប្រព័ន្ធច្បាប់ស៊ីវិលបែបបារាំង ប្រពៃណីច្បាប់ខ្មែរ គុណតម្លៃពុទ្ធសាសនា និងបរិការណ៍អន្តរជាតិ។ ឯកសារលើកឡើងថា ការកសាងច្បាប់ក្រោយឆ្នាំ១៩៩៣ ទទួលបានជំនួយពីបរទេសច្រើន ដូចជា បារាំងក្នុងវិស័យព្រហ្មទណ្ឌ និងជប៉ុនក្នុងវិស័យរដ្ឋប្បវេណី ប៉ុន្តែមិនមានន័យថាច្បាប់កម្ពុជាគ្រាន់តែចម្លងពីបរទេសទេ។ ខ្លឹមសារជាច្រើននៅតែបញ្ចូលគុណតម្លៃខ្មែរ បវេណី និងទម្លាប់សង្គមខ្មែរ។ ហេតុនេះ អត្តសញ្ញាណនៃប្រព័ន្ធច្បាប់កម្ពុជាសព្វថ្ងៃ គឺជាអត្តសញ្ញាណចម្រុះមួយ ដែលផ្សំឡើងពីកេរដំណែលខ្មែរ ពុទ្ធសាសនា ក្រមនីយកម្មបែបបារាំង និងការកសាងនីតិរដ្ឋក្នុងបរិបទអន្តរជាតិ។

#### ៤.៣.១១ សេចក្តីសន្និដ្ឋានអំពីប្រវត្តិនៃប្រព័ន្ធច្បាប់កម្ពុជា

សរុបចុងក្រោយ ប្រវត្តិនៃប្រព័ន្ធច្បាប់កម្ពុជា អាចសង្ខេបបានថា ជាដំណើរវិវត្តពីច្បាប់ប្រពៃណីនៃសហគមន៍បុរាណ ទៅប្រព័ន្ធច្បាប់ឥណ្ឌូ-ខ្មែរ នៅសម័យហ្វូណន ចេនឡា និងអង្គរ បន្តទៅក្រមខ្មែរនៅសម័យក្រោយអង្គរ បន្ទាប់មកបម្លែងខ្លាំងនៅសម័យអាណានិគមបារាំង និងរងការបំផ្លាញយ៉ាងធ្ងន់ធ្ងរនៅរបបកម្ពុជាប្រជាធិបតេយ្យ មុននឹងត្រូវកសាងឡើងវិញក្រោយឆ្នាំ១៩៧៩ និងជាពិសេសក្រោយឆ្នាំ១៩៩៣។ ប្រវត្តិនេះបង្ហាញថា ច្បាប់កម្ពុជាមិនមែនមានអត្តសញ្ញាណតែមួយជាប់គាំងនោះទេ ប៉ុន្តែជាប្រព័ន្ធដែលបានបន្តសម្របសម្រួលរវាងប្រវត្តិសាស្ត្រ បវេណី ជំនឿ សាសនា រដ្ឋសម័យទំនើប និងឥទ្ធិពលអន្តរជាតិជានិច្ច។

## ៥. វិធីសាស្ត្រក្នុងការរៀបចំក្របខ័ណ្ឌទស្សនាទាន

### ៥.១. សមត្ថកិច្ចរបស់គ.ក.ច.និងទិសដៅគោលនយោបាយរបស់រាជរដ្ឋាភិបាល

ការរៀបចំក្របខ័ណ្ឌទស្សនាទានស្តីពីប្រព័ន្ធច្បាប់កម្ពុជានេះធ្វើឡើងដោយផ្អែកលើសមត្ថកិច្ច របស់ គ.ក.ច. និងទិសដៅគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ក្នុងកម្រិតនយោបាយ រាជរដ្ឋាភិបាលបានដាក់ចេញនូវទិសដៅយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍន៍ និងពង្រឹងប្រព័ន្ធច្បាប់ តាមរយៈការដាក់ចេញនូវក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល។ ទិសដៅគោលនយោបាយនេះបានបញ្ជាក់អំពីសារៈសំខាន់នៃភាពប្រទាក់ក្រឡា ប្រសិទ្ធភាព និងការអភិវឌ្ឍន៍រយៈពេលវែងសម្រាប់ប្រព័ន្ធច្បាប់។ ក្នុងកម្រិតស្ថាប័ន

គ.ក.ច. ត្រូវបានប្រគល់ភារកិច្ចតាមរយៈព្រះរាជក្រឹត្យស្តីពីការបង្កើត គ.ក.ច. និងអនុក្រឹត្យស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាន គ.ក.ច. ដែលមានសមត្ថកិច្ចក្នុងការដឹកនាំ និងសម្របសម្រួលការកែទម្រង់ច្បាប់នៅក្នុងប្រព័ន្ធច្បាប់ទាំងមូល។ នៅក្នុងតួនាទីនេះ គ.ក.ច. ទទួលបន្ទុកក្នុការសម្របសម្រួលការស្រាវជ្រាវ ពិគ្រោះយោបល់ និងអភិវឌ្ឍន៍គោលនយោបាយដែលពាក់ព័ន្ធនឹងការធ្វើទំនើបកម្ម និងកែលម្អក្របខ័ណ្ឌច្បាប់។ ក្នុងន័យនេះ ក្របខ័ណ្ឌទស្សនាទាននេះពុំត្រឹមជាអត្ថបទសិក្សាស្រាវជ្រាវនោះទេ តែជាកិច្ចការរៀបចំគោលនយោបាយផ្លូវការដើម្បីអភិវឌ្ឍន៍ប្រព័ន្ធច្បាប់កម្ពុជាមួយដែលមានភាពប្រទាក់ក្រឡា និងមានបូរណភាព។

## ៥.២. ការពិគ្រោះយោបល់ និងប្រមូលផ្តុំចំណេះដឹង

ដើម្បីមានមូលដ្ឋានក្នុងការរៀបចំក្របខ័ណ្ឌទស្សនាទាននេះ គ.ក.ច. បានផ្តួចផ្តើម និងរៀបចំសិក្ខាសាលាស្តីពីប្រព័ន្ធច្បាប់កម្ពុជា (Symposium on Cambodia's Legal System) ដើម្បីជាវេទិកាសម្រាប់ការស្រាវជ្រាវ ផ្លាស់ប្តូរគំនិត និងពិគ្រោះយោបល់លើគោលនយោបាយ។ សិក្ខាសាលាបានប្រមូលផ្តុំនូវថ្នាក់ដឹកនាំរាជរដ្ឋាភិបាល មន្ត្រីសាធារណៈ សាស្ត្រាចារ្យ ចៅក្រម មេធាវី អ្នកស្រាវជ្រាវ និងអ្នកប្រាជ្ញជាតិ និងអន្តរជាតិមកពីវិស័យពាក់ព័ន្ធនានា រួមមានវិស័យច្បាប់ ប្រវត្តិសាស្ត្រ នរវិទ្យា បុរាណវិទ្យា សិលាចារិកវិទ្យា នយោបាយ អភិបាលកិច្ច និងមុខវិជ្ជាពាក់ព័ន្ធដទៃទៀត។ តាមរយៈដំណើរការនេះ សិក្ខាសាលាបានបម្រើជាវេទិកាដ៏សំខាន់សម្រាប់ការពិនិត្យមើលប្រព័ន្ធច្បាប់កម្ពុជាពីទស្សនទានចម្រុះ ដោយដកស្រង់មេរៀនពីបទពិសោធន៍ប្រៀបធៀប និងប្រវត្តិសាស្ត្រ ការកំណត់បញ្ហាផ្នែកគំនិត និងការអនុវត្តជាក់ស្តែង ព្រមទាំងការបង្កើតទស្សនទានដើម្បីគាំទ្រដល់ការរៀបចំក្របខ័ណ្ឌសម្រាប់ប្រព័ន្ធច្បាប់កម្ពុជានាពេលអនាគត។

ការស្រាវជ្រាវ និងការពិភាក្សាដេញដោលដែលកើតចេញពីសិក្ខាសាលា បានបង្កើតនូវសមិទ្ធផលស្រាវជ្រាវយ៉ាងសម្បូរបែប ដែលបានក្លាយជាមូលដ្ឋានសម្រាប់ការរៀបចំក្របខ័ណ្ឌនេះ។ ការរួមចំណែកទាំងនេះ រួមមានឯកសារស្រាវជ្រាវជាង ៧០០ ទំព័រ ដែលគ្របដណ្តប់លើប្រធានបទជិត ២០ ហើយត្រូវបានរៀបចំជាបីវិស័យចម្បង រួមមាន ប្រព័ន្ធច្បាប់ធំៗលើពិភពលោក ប្រវត្តិសាស្ត្រនៃប្រព័ន្ធច្បាប់កម្ពុជា និងអត្តសញ្ញាណនៃប្រព័ន្ធច្បាប់កម្ពុជា រួមជាមួយទិសដៅឆ្ពោះទៅរកសុក្រឹតភាពនៃប្រព័ន្ធនេះ។ លទ្ធផលទាំងនេះបានផ្តល់នូវមូលដ្ឋានគ្រឹះចំណេះដឹង និងការវិភាគដ៏សំខាន់សម្រាប់ការរៀបចំក្របខ័ណ្ឌបច្ចុប្បន្ន។ ទន្ទឹមនឹងនេះ ដំណើរការនេះក៏បានបង្ហាញឱ្យឃើញថា នៅតែមានតម្រូវការសម្រាប់ការបញ្ជាក់បន្ថែមផ្នែកគំនិតក្នុងវិស័យមួយចំនួន ដែលកត្តានេះបានជួយក្នុងការកំណត់គម្លាត និងសំណួរនានា ដែលក្របខ័ណ្ឌនេះព្យាយាមដោះស្រាយក្នុងលក្ខណៈជាប្រព័ន្ធ។

## ៥.៣. ក្របខ័ណ្ឌទ្រឹស្តីនិងការវិភាគ

**ការប្រើប្រាស់ទ្រឹស្តីប្រព័ន្ធ៖** ក្នុងកម្រិតទ្រឹស្តី ក្របខ័ណ្ឌប្រើប្រាស់ទ្រឹស្តីនៃប្រព័ន្ធទូទៅ (General System Theory) ជាមធ្យោបាយសម្រាប់ការវិភាគដើម្បីស្វែងយល់អំពីប្រព័ន្ធច្បាប់។ តាមរយៈទិដ្ឋភាពនេះ

ប្រព័ន្ធច្បាប់មិនត្រឹមជាបណ្តុំនៃវិធាន ឬស្ថាប័ននោះទេ ប៉ុន្តែជាប្រព័ន្ធប្រមូលផ្តុំដែលមានធាតុប្រទាក់ក្រឡាគ្នា និងដំណើរការក្នុងបរិបទទូលំទូលាយនៃរដ្ឋនិងសង្គម។ ក្របខ័ណ្ឌនេះក៏បានដកស្រង់ពីការពន្យល់ប្រៀបធៀប រវាងទ្រឹស្តីនៃប្រព័ន្ធទូទៅ និងប្រព័ន្ធច្បាប់ ហើយធាតុនៃប្រព័ន្ធច្បាប់រួមមាន រចនាសម្ព័ន្ធ ខ្លឹមសារ និងវប្បធម៌ និងបានដាក់បញ្ចូលបន្ថែមនូវ គុណតម្លៃគ្រឹះ (Foundational Ethos) ជាធាតុផ្សំបន្ថែមដ៏ចាំបាច់ ដែលត្រូវបានកំណត់អត្តសញ្ញាណតាមរយៈដំណើរការស្រាវជ្រាវក្នុងបរិបទកម្ពុជា។ ទស្សនាទានជាមូលដ្ឋានទាំងនេះជួយ ដល់ការស្វែងយល់អំពីប្រព័ន្ធច្បាប់ដែលមានភាពស្មុគស្មាញនៃការប្រមូលផ្តុំគុណតម្លៃ ស្ថាប័ន ប្រតិបត្តិការនៅ ក្នុងនិម្មាបនកម្មនយោបាយនិងសង្គម។

**ការវិភាគកម្រិតម៉ាក្រូ៖** ការរៀបចំក្របខ័ណ្ឌនេះក៏បានបញ្ចូលនូវការវិភាគលើបរិស្ថានជុំវិញ ដែលប្រព័ន្ធច្បាប់ដំណើរការ។ ក្នុងន័យនេះ ការវិភាគ PESTLE ត្រូវបានប្រើប្រាស់ជាឧបករណ៍គាំទ្រ ដើម្បីវាយតម្លៃកត្តាបរិស្ថានកម្រិតម៉ាក្រូខាងក្រៅដែលជះឥទ្ធិពលលើប្រព័ន្ធច្បាប់ រួមមាន នយោបាយ សេដ្ឋកិច្ច សង្គម បច្ចេកវិទ្យា ច្បាប់ និងបរិស្ថាន។ មធ្យោបាយនេះបានជួយក្នុងការដាក់ប្រព័ន្ធច្បាប់ឱ្យស្ថិតនៅក្នុងបរិបទជាតិ និងអន្តរជាតិកាន់តែទូលំទូលាយ ព្រមទាំងធានាថា ក្របខ័ណ្ឌនេះបានវិភាគមិនត្រឹមតែធាតុខាងក្នុងនៃប្រព័ន្ធច្បាប់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានគិតគូរពីលក្ខខណ្ឌជុំវិញនានាដែលជះឥទ្ធិពលលើការអភិវឌ្ឍច្បាប់ និងសមត្ថភាពរបស់ប្រព័ន្ធច្បាប់ក្នុងការឆ្លើយតបទៅនឹងតម្រូវការជាតិ។

### ៥.៣.១ វិធីសាស្ត្រស្រាវជ្រាវ

**ការស្រាវជ្រាវអំពីទ្រឹស្តីច្បាប់៖** ការស្រាវជ្រាវអំពីទ្រឹស្តីច្បាប់ត្រូវបានប្រើប្រាស់ដើម្បីវិភាគរចនាសម្ព័ន្ធនិងតក្កវិជ្ជាលម្អិតផ្ទៃក្នុងនៃប្រព័ន្ធច្បាប់រួមមាន គោលការណ៍និងទ្រឹស្តីច្បាប់ ក្របខ័ណ្ឌច្បាប់ ការរៀបចំស្ថាប័ន និងទំនាក់ទំនងនៃមែកធាងច្បាប់។ វិធីសាស្ត្រនេះផ្តល់នូវការវិភាគជាប្រព័ន្ធលើមូលដ្ឋានគ្រឹះនៃច្បាប់ និងរចនាសម្ព័ន្ធស្ថាប័ននៃប្រព័ន្ធច្បាប់កម្ពុជា។

**ការសិក្សាប្រៀបធៀប៖** ការសិក្សាប្រៀបធៀបត្រូវបានប្រើប្រាស់ដើម្បីទាញយកការសន្និដ្ឋានអំពីបទពិសោធន៍តាមបណ្តាប្រព័ន្ធច្បាប់ផ្សេងៗ និងពីតាមបណ្តាការអភិវឌ្ឍន៍ទ្រឹស្តីច្បាប់ផងដែរ។ វិធីសាស្ត្រនេះរួមចំណែកដល់ការកំណត់គំរូទស្សនាទាន ការរៀបចំស្ថាប័ន និងបទពិសោធន៍កែទម្រង់ដើម្បីជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍន៍ប្រព័ន្ធច្បាប់នៅកម្ពុជា។

**ការសំយោគ៖** លទ្ធផលដែលទទួលបានតាមរយៈការស្រាវជ្រាវទ្រឹស្តីច្បាប់ និងការសិក្សាប្រៀបធៀប នឹងត្រូវបានធ្វើសំយោគតាមរយៈការវិភាគបរិបទដោយពិចារណាទៅលើលក្ខខណ្ឌផ្នែកប្រវត្តិសាស្ត្រ នយោបាយ ស្ថាប័ន និងអភិបាលកិច្ចនៅកម្ពុជា។ ការសំយោគបរិបទនេះ ដើម្បីធានាបានថាទស្សនាទាន និងវិធីសាស្ត្រនៃការវិភាគត្រូវបានប្រើប្រាស់ដោយពិចារណាទៅលើបរិបទច្បាប់និងស្ថាប័ននៅកម្ពុជា។

### ៥.៣.២ ការស្រាវជ្រាវអំពីប្រព័ន្ធច្បាប់កម្ពុជា

ក្រៅពីការវិភាគខាងលើ ការអភិវឌ្ឍន៍ក្របខ័ណ្ឌទស្សនាទាននេះក៏អាស្រ័យទៅលើការស្រាវជ្រាវស៊ីជម្រៅទៅលើរចនាសម្ព័ន្ធ និងដំណើរការនាពេលបច្ចុប្បន្ននៃប្រព័ន្ធច្បាប់កម្ពុជា។

**បញ្ជីច្បាប់និងលិខិតបទដ្ឋានគតិយុត្តៈ** បញ្ជីច្បាប់និងលិខិតបទដ្ឋានគតិយុត្តដែលមានសុពលភាពនាពេលបច្ចុប្បន្នក៏ត្រូវបានស្រាវជ្រាវនិងរៀបចំទៅលើច្បាប់ជាគោល។ តាមយរៈនេះបញ្ជីច្បាប់ទាំងអស់នេះនិងផ្តល់លទ្ធភាពក្នុងការវិភាគអំពីបញ្ហានានារួមមានភាពប្រទាក់ក្រឡា គម្លាត ឬការស្ទួនគ្នានៅក្នុងក្របខ័ណ្ឌច្បាប់។

**បញ្ជីស្ថាប័ននិងមុខងារច្បាប់ៈ** ការស្រាវជ្រាវក៏វិភាគផងដែរទៅលើនិម្មាបនកម្មស្ថាប័ននៅក្នុងប្រព័ន្ធច្បាប់កម្ពុជា រួមមានស្ថាប័ននីតិបញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ ស្ថាប័នតុលាការ និងស្ថាប័នវិជ្ជាជីវៈ។ ក្នុងនោះផងដែរការស្រាវជ្រាវក៏បានធ្វើឡើងចំពោះមុខងារច្បាប់នានានៅក្នុងរដ្ឋបាលសាធារណៈ និងវិស័យយុត្តិធម៌ដែលរួមចំណែកដល់ដំណើរការនៃប្រព័ន្ធច្បាប់ទាំងមូល។

**កាតព្វកិច្ចអន្តរជាតិៈ** តាមរយៈការចូលរួមរបស់កម្ពុជានៅក្នុងសហគមអន្តរជាតិ ក្របខ័ណ្ឌនេះក៏បានសិក្សាផងដែរទៅលើកាតព្វកិច្ចអន្តរជាតិរបស់កម្ពុជា ដែលរួមមានកិច្ចព្រមព្រៀងអន្តរជាតិទ្វេភាគី និងពហុភាគីនិងសមាជិកភាពរបស់កម្ពុជានៅស្ថាប័នអន្តរជាតិ។ ការវិភាគនេះជួយដលការរៀបចំប្រព័ន្ធច្បាប់កម្ពុជានៅក្នុងបរិបទនៃច្បាប់អន្តរជាតិ និងនិម្មាបនកម្មអភិបាលកិច្ចសកលផងដែរ។

### ៥.៣.៣ វិធីសាស្ត្រក្នុងការរៀបចំរចនាសម្ព័ន្ធគោលគំនិត

ដើម្បីរៀបចំក្របខ័ណ្ឌនៃការវិភាគឱ្យមានលក្ខណៈជាប្រព័ន្ធ និងប្រទាក់ក្រឡាគ្នា ការសិក្សានេះក៏បានប្រើប្រាស់នូវវិធីសាស្ត្រសម្រាប់ការរៀបចំរចនាសម្ព័ន្ធគោលគំនិត ដែលត្រូវបានប្រើប្រាស់នៅក្នុងការស្រាវជ្រាវច្បាប់និងវិទ្យាស្ត្រសង្គមរួមមាន ការចាត់ថ្នាក់ (Classification) នៃវិស័យច្បាប់និងស្ថាប័ន, និងការធ្វើវត្ថិករ (Taxonomy) នៃទស្សនាទានច្បាប់ និងធាតុផ្សំនៃប្រព័ន្ធច្បាប់។ ឧបករណ៍ទាំងនេះត្រូវបានប្រើប្រាស់ដើម្បីជាវិធីសាស្ត្រដើម្បីបង្កើនភាពច្បាស់លាស់ និងភាពប្រទាក់ក្រឡានៃទស្សនាទាន ព្រមទាំងការវិភាគទាំងមូល។

ការប្រើប្រាស់វិធីសាស្ត្ររួមចូលគ្នាជាច្រើនរួមមាន សមត្ថកិច្ចស្ថាប័ននិងទិសដៅគោលនយោបាយ, ការពិគ្រោះយោបល់ជាមួយអ្នកជំនាញ, ការវិភាគដោយផ្អែកលើទ្រឹស្តីប្រព័ន្ធ, ការស្រាវជ្រាវទ្រឹស្តីច្បាប់, ការសិក្សាប្រៀបធៀប, ការសំយោគបរិបទ, និងការស្រាវជ្រាវអំពីច្បាប់ ស្ថាប័ន និងកាតព្វអន្តរជាតិ។ តាមរយៈវិធីសាស្ត្រទាំងនេះ ក្របខ័ណ្ឌនេះនឹងធានានូវភាពច្បាស់លាស់ផ្អែកទ្រឹស្តី និង ការអនុវត្តជាក់

ស្តែង ដើម្បីឱ្យឯកសារនេះក្លាយជាមូលដ្ឋានដ៏សំខាន់មួយសម្រាប់ការបន្តវាយតម្លៃ អភិវឌ្ឍន៍ និងពង្រឹងប្រព័ន្ធច្បាប់កម្ពុជានាពេលអនាគត។

# ៦. ក្របខ័ណ្ឌទស្សនាទាននៃការកសាងប្រព័ន្ធច្បាប់កម្ពុជាដែលស្នើឡើង

## ៦.១. គោលបំណងជាតិ

ដើម្បីជាមូលដ្ឋានក្នុងការរៀបចំក្របខ័ណ្ឌប្រព័ន្ធច្បាប់ដែលឆ្លើយតបទៅនឹងតម្រូវការ ការកំណត់អំពីលក្ខខណ្ឌសម្រាប់អភិវឌ្ឍន៍ជាតិគឺមានសារៈសំខាន់។ ខាងក្រោមជាការ**សាកល្បង**កំណត់នូវគោលបំណងជាតិ (National Purpose) ដែលសាមញ្ញ ងាយយល់ ងាយចាំ ដែលសំយោគពីមុខងាររបស់រដ្ឋ និងជាតិ ព្រមទាំងលំហូរនៃការអភិវឌ្ឍន៍ជាតិក្លាយទៅជាអរិយធម៌មួយដែលមានទស្សនាទានស្មុគស្មាញ។ គោលបំណងជាតិនេះជាត្រីវិស័យនាំផ្លូវក្នុងការរៀបចំក្របខ័ណ្ឌ ប្រព័ន្ធច្បាប់ ដែលបានសាកល្បងកំណត់ដូចខាងក្រោម៖

" កម្ពុជាគឺជាជាតិមួយដែល**រស់**រាន
មាន**សុខ**សន្តិភាព និងមានកម្លាំង**ខ្លាំង**ក្លា ដើម្បីការពារអាយុជីវិត
និងអធិបតេយ្យភាពរបស់ខ្លួន, រឹង**មាំ** សណ្តាប់ធ្នាប់**រៀបរយ** និងសមត្ថភាព**ច្បាស់**លាស់ ដើម្បីជានា
ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព, ឈ្លាស**វៃ ម្ចាស់ការ**លើជីវិត និងធនធាន**មានបាន** ដើម្បី
អភិវឌ្ឍដោយខ្លួនឯង, សង្គមជាតិ**រុងរឿង** ប្រពៃណី**ថ្លៃថ្នូរ** ហើយសោភណនិងបរិស្ថាន**ស្អាត** ដើម្បីក្លាយ
ជាសង្គមអរិយធម៌ទំនើប។ "

| លក្ខខណ្ឌនៃការអភិវឌ្ឍន៍ជាតិ | | |
|---|---|---|
| **លំហូរ** | **លក្ខខណ្ឌ** | **ខ្លឹមសារ** |
| អត្ថិភាព (Existence) | **រស់** (survival) | អត្ថិភាពនិងការរស់រានមានជីវិតរបស់ជាតិនិងប្រជាជន |
| | **សុខ** (peaceful) | សន្តិភាពនៅក្នុងសង្គម និងជាមួយបណ្តារដ្ឋផ្សេងៗ |
| | **ខ្លាំង** (powerful) | សមត្ថភាពក្នុងការការពារអធិបតេយ្យនិងផលប្រយោជន៍ជាតិ |

| | | |
|---|---|---|
| សន្តិសុខ (Security) | **ម៉ាំ** (strong) | រដ្ឋធន់ ប្រជាជនសុខភាពល្អ ស្ថាប័នខ្លាំង |
| | **រៀបរយ** (order) | សណ្តាប់ធ្នាប់សង្គម និងអភិបាលកិច្ចដែលអាចព្យាករណ៍បាន |
| សមត្ថភាព (Capability) | **ច្បាស់** (competent) | ចំណេះដឹង សមត្ថភាពវិជ្ជាជីវៈ និងរដ្ឋបាលមានប្រសិទ្ធភាព |
| | **ឆៃ** (wise) | ការគិតយុទ្ធសាស្ត្រ និងទិសដៅរយៈពេលវែង |
| | **ម្ចាស់ការ** (self-reliance) | លទ្ធភាពក្នុងការពឹងលើសមត្ថភាព និងធនធានផ្ទាល់ខ្លួន |
| ការអភិវឌ្ឍន៍ (Development) | **មានបាន** (rich) | វិបុលភាពសេដ្ឋកិច្ច និងទ្រព្យសម្បត្តិ |
| | **រុងរឿង** (prosper) | វប្បធម៌និងអរិយធម៌រុងរឿង និងការអភិវឌ្ឍន៍ |
| តម្លៃ (Value) | **ថ្លៃថ្នូរ** (dignified) | គុណតម្លៃសីលធម៌ កិត្តិយស និងយុត្តិធម៌សង្គម |
| | **ស្អាត** (beautiful) | បរិស្ថានរស់នៅមានអនាម័យ និងមានសោភ័ណ |

## ៦.២. ទស្សនាទាន

ក្របខ័ណ្ឌប្រព័ន្ធច្បាប់កម្ពុជាគឺជាមគ្គុទេសន៍បង្ហាញផ្លូវគ្រប់ជ្រុងជ្រោយសម្រាប់ការកសាងប្រព័ន្ធច្បាប់កម្ពុជាឱ្យទៅជាប្រព័ន្ធច្បាប់ជាតិមួយដែលឯកភាពនិងបូរណភាព តាមរយៈការកំណត់ច្បាស់លាស់អំពីរចនាសម្ព័ន្ធនិងទំនាក់ទំនងរវាងគុណតម្លៃគ្រឹះ សារជាតុគតិយុត្ត ស្ថាប័ន និងវប្បធម៌ប្រចាំថ្ងៃនៅក្នុងបរិបទនៃការគ្រប់គ្រងរដ្ឋនិងសង្គម និងមានមុខងារជាឯកសារយោងថ្នាក់ជាតិដែលរៀបរាប់ អំពីនិម្មាបនកម្ម គោលការណ៍និងដំណើរការនៃប្រព័ន្ធច្បាប់កម្ពុជា។

ក្របខ័ណ្ឌនេះត្រូវបានកសាងឡើងដោយផ្អែកលើទ្រឹស្តីនៃប្រព័ន្ធច្បាប់និងប្រព័ន្ធទូទៅ ដែលធ្វើឱ្យប្រព័ន្ធច្បាប់កម្ពុជាជាប្រព័ន្ធរស់ (living system) និងអាចកែតម្រូវដោយខ្លួនឯងបាន (self-correcting system) តាមរយៈការប្រើប្រាស់ធាតុនៃប្រព័ន្ធច្បាប់ជាគោលរួមមានគុណតម្លៃគ្រឹះ សារធាតុគតិយុត្ត ស្ថាប័ន និងវប្បធម៌ជាគោល ហើយតម្រៀបធាតុទាំងនោះតាមរចនាសម្ព័ន្ធនៃទ្រឹស្តីប្រព័ន្ធទូទៅរួមមាន ធាតុចូល (inputs) ដំណើរការ (processes) សមិទ្ធផល (outputs) ផលសម្រេច (outcomes) ផលប៉ះពាល់ (impacts) បរិស្ថាន (environment) និងយន្តការវាយតម្លៃ (feeback loops)។

ជាមួយគ្នានេះផងដែរ ផ្អែកតាមការស្រាវជ្រាវកន្លងមក ការរៀបចំឯកសារបែបនេះគឺពុំធ្លាប់មានបានធ្វើកន្លងមកនៅតាមបណ្តាប្រទេសផ្សេងៗនៅលើសកលលោកនោះទេ។ នេះពុំមែនបានន័យថាប្រទេសផ្សេងពុំមានប្រព័ន្ធច្បាប់ច្បាស់លាស់នោះទេ ពោលសម្រាប់ប្រទេសអភិវឌ្ឍន៍គឺដោយហេតុគេមានប្រព័ន្ធច្បាប់ដែលចាស់ទុំ ដែលពុំចាំបាច់មានឯកសារបែបនេះ។ សម្រាប់កម្ពុជាដែលមានប្រព័ន្ធច្បាប់ក្មេងខ្ចី ការរៀបចំឯកសារបែបនេះគឺមានសារៈសំខាន់ណាស់សម្រាប់ការអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងសបញ្ជាក់អំពីឆន្ទៈនយោបាយនិងការយកចិត្តទុកដាក់ខ្ពស់លើប្រព័ន្ធច្បាប់ទាំងមូល។

## ៦.៣. គោលបំណង

ក្របខ័ណ្ឌប្រព័ន្ធច្បាប់កម្ពុជាមានគោលបំណងសំខាន់ៗដូចខាងក្រោម៖

- ផ្តល់ជាមគ្គទេសន៍បង្ហាញផ្លូវ ឬ Blueprint ឬ Master Plan នៃប្រព័ន្ធច្បាប់កម្ពុជាតាមរយៈការកំណត់ច្បាស់លាស់នូវធាតុសំខាន់ៗ ភាពប្រទាក់ក្រឡា និងគោលការណ៍នានា។
- ផ្តល់ជាឧបករណ៍សម្រាប់វាយតម្លៃស្ថានភាពបច្ចុប្បន្ននៃប្រព័ន្ធច្បាប់កម្ពុជា ដែលផ្តល់នូវមូលដ្ឋានសម្រាប់ការវិភាគជាប្រព័ន្ធនិងគ្រប់ជ្រុងជ្រោយទៅលើច្បាប់ ស្ថាប័ន សមិទ្ធកម្ម និងការអនុវត្ត ដើម្បីកំណត់ចំណុចខ្លាំង ចំណុចខ្សោយ ចំណុចខ្វះខាត និងចំណុតដែលត្រូវកែលម្អ។
- ផ្តល់ជាមូលដ្ឋានសម្រាប់ការសម្របសម្រួលរវាងស្ថាប័ន តាមរយៈការអនុវត្តដោយផ្អែកលើឯកសារមូលដ្ឋានរួមតែមួយរវាងស្ថាប័នផ្សេងៗក្នុងការធ្វើច្បាប់ ប្រតិបត្តិច្បាប់ និងអនុវត្តច្បាប់ដើម្បីសម្រេចបាននូវចក្ខុវិស័យជាតិ។
- ផ្តល់ជាឯកសារយុទ្ធសាស្ត្រសម្រាប់ការទម្រង់និងអភិវឌ្ឍន៍ស្ថាប័ន តាមរយៈការផ្តល់ជាមូលដ្ឋានដល់ថ្នាក់ដឹកនាំ និងភាគីពាក់ព័ន្ធ ជាពិសេស គ.ក.ច. ក្នុងការកំណត់អាទិភាព

សម្រាប់ការកសាងវប្បធម៌នីតិរដ្ឋ ពង្រឹងសមត្ថភាពស្ថាប័ន និងភាពប្រទាក់ក្រឡានៃច្បាប់នៅក្នុងប្រព័ន្ធទាំងមូល។

## ៦.៤. វិសាលភាព

វិសាលភាពនៃក្របខ័ណ្ឌប្រព័ន្ធច្បាប់កម្ពុជាមានដូចខាងក្រោម៖

- គ្រប់ដណ្ដប់លើគ្រប់ទិដ្ឋភាពទាំងអស់នៃប្រព័ន្ធច្បាប់ទាំងមូល រួមមានគុណតម្លៃគ្រឹះ សារជាតុគតិយុត្ត រចនាសម្ព័ន្ធគតិយុត្ត វប្បធម៌គោរពច្បាប់ និងយន្តការវាយតម្លៃ។
- ក្របខ័ណ្ឌនេះកំណត់ប្រព័ន្ធច្បាប់ដំណើរការនៅក្នុងបរិបទទូលំទូលាយរួមមាន នយោបាយ សេដ្ឋកិច្ច សង្គម បច្ចេកវិទ្យា ទំនាក់ទំនងអន្តរជាតិ និងបរិស្ថាន ដែលបំពេញមុខងារសម្រាប់អភិបាលកិច្ចរដ្ឋនិងសង្គមទាំងមូល។
- ខ្លឹមសារទាំងអស់នៃក្របខ័ណ្ឌនេះពុំប៉ះពាល់ដល់សុពលភាពឬការអនុវត្តនៃរដ្ឋធម្មនុញ្ញ ច្បាប់និងលិខិតបទដ្ឋានគតិយុត្ត រួមទាំងការរៀបចំស្ថាប័នដែលមានស្រាប់ទាំងអស់ លុះត្រាតែមានការចាត់វិធានការតាមនីតិវិធីជាធរមាន។
- ខ្លឹមសារទាំងអស់នៃក្របខ័ណ្ឌនេះក៏ពុំប៉ះពាល់ដល់ស្ថានភាពគតិយុត្ត មុខងារ និងសមត្ថកិច្ចរបស់ស្ថាប័នទាំងអស់ដែលមានស្រាប់លុះត្រាតែមានការចាត់វិធានការតាមនីតិវិធីជាធរមាន។
- ក្របខ័ណ្ឌនេះបំពេញមុខងារជាឯកសារយោងសម្រាប់ថ្នាក់ដឹកនាំ ស្ថាប័នពាក់ព័ន្ធ អ្នកស្រាវជ្រាវ និងភាគីពាក់ព័ន្ធផ្សេងទៀតសម្រាប់ការសិក្សា វិភាគ និងកំណត់ផ្នែកដែលទាមទារឱ្យមានត្រូវកែលម្អ។

## ៦.៥. ការធ្វើបច្ចុប្បន្នភាពក្របខ័ណ្ឌជាប្រចាំ

ក្របខ័ណ្ឌប្រព័ន្ធច្បាប់កម្ពុជាជាឯកសារទន់និងរស់ ដែលនេះមានន័យថាក្រៅពីការពុំចងតាតព្វកិច្ចក្នុងការអនុវត្ត ឯកសារនេះក៏ត្រូវឆ្លងកាត់ការពិនិត្យឡើងវិញនិងធ្វើបច្ចុប្បន្នភាពជាប្រចាំ។ ដោយហេតុភាពចាំបាច់និងបន្ទាន់នៃតម្រូវការឯកសារនេះសម្រាប់ការងារកែទម្រង់ច្បាប់ និងភាពស្មុគស្មាញនៃប្រព័ន្ធច្បាប់ទាំងមូល ការរៀបចំឱ្យបានល្អឥតខ្ចោះក្នុងការរៀបចំលើកដំបូងគឺពុំអាចទៅរួចនោះទេ។ ហេតុនេះដើម្បីជានាប្រសិទ្ធភាពនិងគុណភាព ក្របខ័ណ្ឌនេះនឹងត្រូវពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពជាប្រចាំដើម្បី៖

- បញ្ចូលនូវបទពិសោធន៍ជាក់ស្តែងដែលទទួលបានតាមរយៈការអនុវត្តកម្មកែទម្រង់ច្បាប់ និងការអនុវត្តជាក់ស្តែងរបស់ស្ថាប័នពាក់ព័ន្ធ។
- វាយតម្លៃគម្លាត និងចំណុចខ្សោយនៅក្នុងក្របខ័ណ្ឌដែលត្រូវកែលម្អ ពង្រឹង និងពង្រីកបន្ថែម។
- ឆ្លើយតបទៅនឹងការវិវត្តន៍ថ្មីៗពាក់ព័ន្ធនឹងអភិបាលកិច្ច សង្គម បច្ចេកវិទ្យា និងច្បាប់អន្តរជាតិ។
- ពង្រឹងភាពប្រទាក់ក្រឡា និងប្រសិទ្ធភាពនៃប្រព័ន្ធច្បាប់កម្ពុជាជាប្រចាំ។

## ៦.៦. ចក្ខុវិស័យ

ចក្ខុវិស័យនៃក្របខ័ណ្ឌប្រព័ន្ធច្បាប់ ត្រូវបាន កំណត់នៅក្នុងចក្ខុវិស័យនិងបេសកកម្មដែលបានកំណត់នៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល ដូចខាងក្រោម៖

**" កសាងប្រព័ន្ធច្បាប់កម្ពុជាឱ្យទៅជាប្រព័ន្ធច្បាប់មួយដែលមានឯកភាព សមានគតិភាព ឧត្តមានុភាពគតិយុត្ត និងសន្តិសុខគតិយុត្ត ស្របតាមឧត្តមានុវត្តន៍អន្តរជាតិ និងបរិការណ៍កម្ពុជា ដើម្បីធានាស្ថិរភាពនិងចីរភាពនៃការកសាងរដ្ឋមួយដែលរឹងមាំ ឯករាជ្យ អធិបតេយ្យ ប្រជាធិបតេយ្យសេរីពហុបក្ស គោរពសិទ្ធ សេរីភាព និងសេចក្តីថ្លៃថ្នូររបស់មនុស្ស សមធម៌និងយុត្តិធម៌ក្នុងសង្គម វប្បធម៌ចុំថ្កើងរុងរឿង និងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារជឿនលឿន សុខុមាលភាពពលរដ្ឋ នាយុគសម័យបច្ចេកវិទ្យាទំនើប។ "**

## ៦.៧. ធាតុផ្សំស្នូលនៃប្រព័ន្ធច្បាប់

### ៦.៧.១ គុណតម្លៃគ្រឹះ

គុណតម្លៃគ្រឹះនៃប្រព័ន្ធច្បាប់ សំដៅដល់គោលការណ៍ និងទស្សនៈមូលដ្ឋានដែលកំណត់ទិសដៅ អត្តសញ្ញាណ និងគោលបំណងរួមនៃប្រព័ន្ធច្បាប់ជាតិ ជាមូលដ្ឋានទស្សនវិជ្ជា និងសីលធម៌ដែលកំណត់ទិសដៅនៃប្រព័ន្ធច្បាប់ គុណតម្លៃសម្រាប់ការគ្រប់គ្រងរដ្ឋ និងការរៀបចំសង្គមក្រោមច្បាប់។ ក្នុងន័យនេះ គុណតម្លៃគ្រឹះជាគោលការណ៍ដឹកនាំដែលផ្តល់ទិសដៅដល់ការរៀបចំខ្លឹមសារច្បាប់ ការកសាងស្ថាប័នការអនុវត្តច្បាប់ និងការអភិវឌ្ឍប្រព័ន្ធច្បាប់ជាបន្តបន្ទាប់។ គុណតម្លៃទាំងនេះត្រូវទាញចេញពីរដ្ឋធម្មនុញ្ញ ប្រវត្តិសាស្ត្រ អរិយធម៌ វប្បធម៌ និងបទពិសោធន៍អភិវឌ្ឍន៍ជាតិ ព្រមទាំងស្តង់ដារអន្តរជាតិទាក់ទងនឹងនីតិរដ្ឋ អភិបាលកិច្ចល្អ និងការអភិវឌ្ឍប្រកបដោយចីរភាព។ គុណតម្លៃគ្រឹះ មានតួនាទីជាគន្លឹះក្នុងការកំណត់ទិសដៅរយៈពេលវែងនៃប្រព័ន្ធច្បាប់។ ការកំណត់និងការបញ្ជាក់ឱ្យច្បាស់នូវគុណតម្លៃទាំងនេះ គឺមានសារៈ

សំខាន់សម្រាប់ធានាថាប្រព័ន្ធច្បាប់កម្ពុជាអាចអភិវឌ្ឍទៅជាប្រព័ន្ធដែលមានសង្គតិភាព ស្ថិរភាព និង សមត្ថភាពគាំទ្រការកសាងរដ្ឋរឹងមាំ នីតិរដ្ឋ និងការរីកចម្រើនរបស់សង្គមជាតិ។

សមាសភាគជាតុផ្សំនៃគុណតម្លៃគ្រឹះ ត្រូវបានកំណត់ចេញពីមូលដ្ឋានអត្តសញ្ញាណ និង ទិសដៅជាតិរបស់កម្ពុជារួមមានរដ្ឋធម្មនុញ្ញ ចក្ខុវិស័យកម្ពុជា ២០៥០ កម្មវិធីនយោបាយរបស់ រាជរដ្ឋាភិបាល យុទ្ធសាស្ត្របញ្ចកោណ និងការវិភាគលើលក្ខខណ្ឌជាមូលដ្ឋានសម្រាប់ការរស់រានមានជីវិត ការ រក្សាអធិបតេយ្យភាព សន្តិភាព សណ្តាប់ធ្នាប់ រដ្ឋរឹងមាំ អភិបាលកិច្ចល្អ អត្តសញ្ញាណជាតិ ការ អភិវឌ្ឍប្រកបដោយចីរភាព និងសេចក្តីថ្លៃថ្នូររបស់សង្គម។

សមាសភាគជាតុផ្សំនៃគុណតម្លៃគ្រឹះ ត្រូវបានរៀបចំតាមលំដាប់ពីគោលមូលដ្ឋានគ្រឹះ របស់រដ្ឋទៅ គុណតម្លៃដែលមានកម្រិតខ្ពស់រួមមានការរស់រានមានជីវិត អធិបតេយ្យភាព សន្តិ ភាព និងសណ្តាប់ធ្នាប់ ជាលក្ខខណ្ឌអប្បបរមាដែលប្រព័ន្ធច្បាប់មួយត្រូវមាន មុននឹងឈានដល់ គោលការណ៍ប្រជាធិបតេយ្យ សិទ្ធិ សុខុមាលភាព ឬវិបុលភាពបាន។ បន្ទាប់ពីលក្ខខណ្ឌអប្បបរមា នេះទើបឈានដល់គោលការណ៍រដ្ឋធម្មនុញ្ញ និងអភិបាលកិច្ចរួមមាននីតិរដ្ឋ ប្រជាធិបតេយ្យ និង គណនេយ្យភាព; និងបន្តទៅគុណតម្លៃអត្តសញ្ញាណ និងយុទ្ធសាស្ត្រដូចជា អត្តសញ្ញាណជាតិ អរិយ ធម៌ និងភាពម្ចាស់ការជាតិ; និងបន្តទៅគោលដៅអភិវឌ្ឍន៍ និងសីលធម៌សាធារណៈដូចជា វិបុល ភាព ចីរភាព សុចរិតភាព និងប្រយោជន៍សាធារណៈ។

ដោយផ្អែកលើទស្សនៈនេះ គុណតម្លៃគ្រឹះនៃប្រព័ន្ធច្បាប់កម្ពុជា អាចត្រូវបានរៀបចំជាជាតុផ្សំ សំខាន់ៗដូចខាងក្រោម៖

### ១. ការរស់រានមានជីវិតរបស់ជាតិ អធិបតេយ្យភាព និងនិរន្តរភាពនៃរដ្ឋធម្មនុញ្ញ

| | |
|---|---|
| • ការរស់រានមានជីវិតរបស់ជាតិ (National survival) | ប្រព័ន្ធច្បាប់ត្រូវធានាការការពារ ការបន្តមានសន្តិសុខ និងនិរន្តរភាពរបស់ជាតិ និងកម្ពុជា។ |
| • អធិបតេយ្យភាពជាតិ (Sovereignty) | ប្រព័ន្ធច្បាប់ត្រូវការពារសិទ្ធិអំណាចរបស់កម្ពុជា ក្នុងការគ្រប់គ្រងខ្លួនឯង ដោយមិនស្ថិតក្រោមការគ្រប់គ្រង ឬជ្រៀតជ្រែកពីខាងក្រៅ។ |
| • បូរណភាពទឹកដី (Territorial integrity) | ប្រព័ន្ធច្បាប់ត្រូវការពារ និងរារាំងមិនឱ្យមានការរំលោភបូរណភាពទឹកដី និងប្រព័ន្ធរបស់កម្ពុជា។ |
| • ឯកភាព និងសាមគ្គីភាពជាតិ (National unity) | ច្បាប់ត្រូវពង្រឹងនូវស្មារតីរួបរួមសាមគ្គីជាធ្លុងមួយ ដោយមានរដ្ឋធម្មនុញ្ញ ជាច្បាប់កំពូលដែលត្រូវបានគោរព និងឯកភាពទូទាំងប្រទេសកម្ពុជា។ |

- និរន្តរភាព និងស្ថិរភាពនៃរដ្ឋធម្មនុញ្ញ (Constitutional continuity) — ប្រព័ន្ធច្បាប់ត្រូវថែរក្សាការបន្តរក្សានិរន្តរភាព និងស្ថិរភាពនៃរបបរដ្ឋធម្មនុញ្ញ ទោះបីមានការប្រែប្រួល ឬវិបត្តិក៏ដោយ។
- ភាពធន់របស់ជាតិ (National resilience) — ប្រព័ន្ធច្បាប់ត្រូវជួយឱ្យជាតិអាចទប់ទល់ ស្តារឡើងវិញ និងសម្របខ្លួនចំពោះហានិភ័យ ឬវិបត្តិ ដោយមិនបាត់បង់មូលដ្ឋានរដ្ឋធម្មនុញ្ញ និងគោលដៅរបស់ជាតិ។
- ការពារខ្លួនរបស់រដ្ឋក្រោមច្បាប់ (Self-preservation under law) — រដ្ឋត្រូវការពារខ្លួនប្រកបដោយអំណាចស្របច្បាប់ និងក្នុងដែនកំណត់របស់រដ្ឋធម្មនុញ្ញ។

### ២. សន្តិភាព សណ្តាប់ធ្នាប់ និងការរួមរស់ដោយសន្តិភាព

- ការរួមរស់ដោយសន្តិភាព (Peaceful coexistence) — ប្រព័ន្ធច្បាប់ត្រូវលើកកម្ពស់ការរួមរស់ជាមួយគ្នាដោយសន្តិភាព ការគោរពគ្នាទៅវិញទៅមក និងការជៀសវាងជម្លោះហិង្សា។
- សណ្តាប់ធ្នាប់សាធារណៈក្រោមច្បាប់ (Public order under law) — សណ្តាប់ធ្នាប់សាធារណៈត្រូវថែរក្សាតាមអំណាចស្របច្បាប់ មិនមែនតាមកម្លាំង ឬធន្ទានុសិទ្ធិ។
- ការមិនប្រើអំពើហិង្សា និងសន្តិភាពសង្គម (Non-violence and civic peace) — ប្រព័ន្ធច្បាប់ត្រូវទប់ស្កាត់អំពើហិង្សា និងថែរក្សាជីវភាពសាធារណៈដែលមានសន្តិភាព និងរបៀបរៀបរយ។
- ការដោះស្រាយវិវាទដោយសន្តិវិធី (Peaceful settlement of disputes) — វិវាទគួរត្រូវបានដោះស្រាយតាមនីតិវិធីស្របច្បាប់ និងដោយមធ្យោបាយសន្តិវិធី។
- ភាពសុខដុមរមនានៅក្នុងសង្គម (Social harmony) — ប្រព័ន្ធច្បាប់ត្រូវជួយរក្សាតុល្យភាព និងទំនាក់ទំនងសុខដុមរមនារវាងក្រុមនានាក្នុងសង្គម។
- សន្តិសុខសង្គមស្របតាមច្បាប់ (Security compatible with legality) — សន្តិសុខសង្គមត្រូវធានាតាមវិធានការស្របច្បាប់ ដែលមិនបំពានគោលការណ៍នីត្យានុកូលភាព។

### ៣. នីតិរដ្ឋ និងយុត្តិធម៌

| | |
|---|---|
| • នីតិរដ្ឋ ( Rule of Law ) | អំណាចសាធារណៈ និងអំណាចឯកជនទាំងអស់ត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់ច្បាប់ មិនមែនតាមឆន្ទៈបុគ្គល។ |
| • គោលការណ៍នីត្យានុកូលភាព ( Legality ) | សកម្មភាពរដ្ឋត្រូវមានមូលដ្ឋានច្បាប់ និងអនុវត្តតាមសមត្ថកិច្ច ទម្រង់ និងនីតិវិធីដែលច្បាប់កំណត់។ |
| • រដ្ឋធម្មនុញ្ញជាច្បាប់កំពូល ( Constitutionalism ) | រដ្ឋធម្មនុញ្ញគឺជាច្បាប់ដែលដឹកនាំ កំណត់ដែនសមត្ថកិច្ច និងរៀបចំរចនាសម្ព័ន្ធអំណាចសាធារណៈទាំងមូល។ |
| • រដ្ឋាភិបាលដែលកម្រិតដោយច្បាប់ ( Limited government ) | អំណាចរដ្ឋមិនអាចប្រើប្រាស់ដោយគ្មានដែនកំណត់ទេ ប៉ុន្តែត្រូវស្ថិតនៅក្រោមច្បាប់ និងការត្រួតពិនិត្យ។ |
| • យុត្តិធម៌ និងសមភាព ( Justice and fairness ) | ប្រព័ន្ធច្បាប់ត្រូវស្វែងរកភាពត្រឹមត្រូវ សមធម៌ និងភាពសមស្របក្នុងការរៀបចំទំនាក់ទំនងសង្គម។ |
| • ការការពារសិទ្ធិ និងសេរីភាព ( Rights protection ) | ប្រព័ន្ធច្បាប់ត្រូវទទួលស្គាល់ និងការពារសិទ្ធិ និងសេរីភាពមូលដ្ឋានរបស់មនុស្ស។ |
| • សមភាពចំពោះមុខច្បាប់ ( Equality before the law ) | ប្រព័ន្ធច្បាប់ត្រូវបានអនុវត្តស្មើៗគ្នាចំពោះមនុស្សទាំងអស់ដោយមិនមានការរើសអើង។ |
| • ការត្រួតពិនិត្យអំណាចសាធារណៈតាមច្បាប់ ( Reviewability of public power ) | ការប្រើប្រាស់អំណាចសាធារណៈត្រូវអាចស្ថិតក្រោមការត្រួតពិនិត្យតាមច្បាប់ និងការគ្រប់គ្រងដោយស្ថាប័នបាន។ |

## ៤. ធម្មានុភាពនៃប្រជាធិបតេយ្យ

- ប្រជាធិបតេយ្យសេរីពហុបក្ស (Liberal multi-party democracy) — ប្រព័ន្ធច្បាប់គួរគាំទ្រការប្រកួតប្រជែងតាមបែបប្រជាធិបតេយ្យ សេរីភាពនយោបាយ និងការចូលរួមរបស់ពហុបក្ស។
- ធម្មានុភាពនៃអំណាចពលរដ្ឋ (Popular legitimacy) — អំណាចរដ្ឋត្រូវមានមូលដ្ឋានពីឆន្ទៈ និងការទទួលស្គាល់របស់ប្រជាពលរដ្ឋ។
- ការតំណាង និងការចូលរួមនយោបាយ (Representation and participation) — ប្រជាពលរដ្ឋត្រូវមានឱកាសចូលរួម និងតំណាងក្នុងដំណើរការនយោបាយ និងសាធារណៈ។
- គណនេយ្យភាពនៃអំណាចសាធារណៈ (Public Accountability) — អ្នកកាន់អំណាចសាធារណៈត្រូវទទួលខុសត្រូវចំពោះសកម្មភាព និងការសម្រេចចិត្តរបស់ខ្លួន។
- ពហុនិយមនយោបាយ (Pluralism) — ប្រព័ន្ធច្បាប់ត្រូវទទួលស្គាល់ និងអនុញ្ញាតឱ្យមានទស្សនៈនយោបាយ សង្គម និងវប្បធម៌ដែលចម្រុះគ្នាអាចរួមរស់ដោយសន្តិភាពបាន។
- បរិយាបន្ន (Inclusiveness) — ប្រព័ន្ធច្បាប់ត្រូវធានាឱ្យមានការចូលរួម និងការការពារសម្រាប់ក្រុមមនុស្សគ្រប់ប្រភេទក្នុងសង្គម។
- ការបន្តប្រជាធិបតេយ្យតាមនីតិវិធីច្បាប់ (Democratic renewal through lawful processes) — ការផ្លាស់ប្តូរ និងការបន្តនៃជីវិតប្រជាធិបតេយ្យត្រូវធ្វើតាមនីតិវិធីស្របច្បាប់ និងសន្តិវិធី។

### ៥. អត្តសញ្ញាណជាតិ រាជានិយម សាសនា និងនីរន្តរភាពនៃអរិយធម៌

- របបរាជានិយមតាមរដ្ឋធម្មនុញ្ញ (Constitutional monarchy) — ប្រព័ន្ធច្បាប់ត្រូវទទួលស្គាល់ និងការពាររបបរាជានិយមតាមរដ្ឋធម្មនុញ្ញជាផ្នែកនៃអត្តសញ្ញាណរដ្ឋធម្មនុញ្ញកម្ពុជា។
- សញ្ញានៃឯកភាពជាតិ (Symbolic unity of the nation) — ស្ថាប័ន និងនិមិត្តរូបជាតិត្រូវរួមចំណែកពង្រឹងឯកភាព និងនិរន្តរភាពរបស់ជាតិ។
- ភាពស្មោះត្រង់ចំពោះជាតិ (National allegiance) — ប្រព័ន្ធច្បាប់ត្រូវលើកកម្ពស់កាតព្វកិច្ចស្មោះត្រង់ និងការទទួលខុសត្រូវចំពោះជាតិ។

- អត្តសញ្ញាណរដ្ឋធម្មនុញ្ញ (Constitutional identity) — ប្រព័ន្ធច្បាប់ត្រូវឆ្លុះបញ្ចាំង និងថែរក្សាលក្ខណៈពិសេសនៃរដ្ឋធម្មនុញ្ញ និងសណ្តាប់ធ្នាប់នយោបាយរបស់កម្ពុជា។
- មូលដ្ឋានសាសនា និងដួងព្រលឹងអរិយធម៌ (Religious foundation / spiritual heritage) — ប្រព័ន្ធច្បាប់ត្រូវគោរពសាសនា និងគុណតម្លៃដែលជាមូលដ្ឋានគ្រឹះ ដែលកសាងនិងបន្តអភិវឌ្ឍន៍សង្គមកម្ពុជា។
- និរន្តរភាពនៃអរិយធម៌ជាតិ (Civilizational continuity) — ប្រព័ន្ធច្បាប់ត្រូវគាំទ្រការបន្តនិងការអភិរក្សអរិយធម៌ជាតិពីជំនាន់មួយទៅជំនាន់មួយ។
- ការពារបេតិកភណ្ឌជាតិ និងការចងចាំជាប្រវត្តិសាស្ត្រ (Protection of national heritage and historical memory) — ប្រព័ន្ធច្បាប់ត្រូវការពារបេតិកភណ្ឌ សម្បត្តិវប្បធម៌ និងការចង់ចាំប្រវត្តិសាស្ត្ររបស់ជាតិ។

### ៦. សមត្ថភាពរដ្ឋ ស្ថាប័នូបនីយកម្ម និងអភិបាលកិច្ចផ្អែកលើគុណាធិបតេយ្យ

- សមត្ថភាពរដ្ឋ (State capacity) — សំដៅដល់សមត្ថភាពរបស់រដ្ឋក្នុងការរៀបចំដឹកនាំនិងអនុវត្តមុខងារសាធារណៈឱ្យមានប្រសិទ្ធភាព សង្គតិភាព និងស្ថិរភាព។
- ស្ថាប័នូបនីយកម្ម (Institutionalization) — សំដៅដល់ការបង្កើត និងពង្រឹងស្ថាប័នឱ្យមានរចនាសម្ព័ន្ធ មុខងារ នីតិវិធី និងស្តង់ដារដែលច្បាស់លាស់ និងស្ថិតស្ថេរ។
- ការលើកកម្ពស់ប្រសិទ្ធភាពនៃរដ្ឋបាលសាធារណៈ (Effective public administration) — សំដៅដល់ការធានាថារដ្ឋបាលសាធារណៈអាចផ្តល់សេវា អនុវត្តច្បាប់និងសម្រេចគោលនយោបាយបានដោយប្រសិទ្ធភាព និងឆ្លើយតបទាន់ពេលវេលា។
- អភិបាលកិច្ចផ្អែកលើគុណាធិបតេយ្យ (Merit-based governance) — សំដៅដល់ការរៀបចំនិងប្រើប្រាស់ធនធានមនុស្ស និងការគ្រប់គ្រងស្ថាប័នដោយផ្អែកលើសមត្ថភាព គុណភាព និងស្នាដៃ ជាជាងការលម្អៀងផ្ទាល់ខ្លួន ឬឥទ្ធិពលមិនសមស្រប។

| | |
|---|---|
| • សមត្ថភាពវិជ្ជាជីវៈ ( Professional competence ) | សំដៅដល់ចំណេះដឹង ជំនាញ សីលធម៌ និងសមត្ថភាពអនុវត្តការងាររបស់មន្ត្រី និងអ្នកវិជ្ជាជីវៈក្នុងប្រព័ន្ធច្បាប់។ |
| • ភាពអព្យាក្រឹតរបស់រដ្ឋបាល ( Administrative impartiality ) | សំដៅដល់ការអនុវត្តតួនាទីរដ្ឋបាលដោយស្មើភាព មិនលម្អៀងនិងមិនស្ថិតក្រោមឥទ្ធិពលមិនស្របច្បាប់ ឬផលប្រយោជន៍ផ្ទាល់ខ្លួន។ |
| • សមត្ថភាពអនុវត្តច្បាប់ និងគោលនយោបាយ ( Implementation capability ) | សំដៅដល់សមត្ថភាពរបស់រដ្ឋនិងស្ថាប័នក្នុងការបំលែងច្បាប់និងគោលនយោបាយឱ្យទៅជាលទ្ធផលអនុវត្តជាក់ស្តែងប្រកបដោយប្រសិទ្ធភាព។ |

### ៧. ស្វ័យភាព ភាពម្ចាស់ការ និងការការពារជាតិ

| | |
|---|---|
| • ស្វ័យភាពនៃការគ្រប់គ្រងរដ្ឋដោយយុទ្ធសាស្ត្រ ( Strategic autonomous statecraft ) | សំដៅដល់សមត្ថភាពរបស់រដ្ឋក្នុងការកំណត់ និងអនុវត្តទិសដៅយុទ្ធសាស្ត្ររបស់ខ្លួនដោយឯករាជ្យ និងមានចក្ខុវិស័យច្បាស់លាស់។ |
| • ភាពម្ចាស់ការជាតិ ( National self-reliance ) | សំដៅដល់សមត្ថភាពរបស់ជាតិក្នុងការពឹងផ្អែកលើកម្លាំង និងធនធានរបស់ខ្លួន ដើម្បីការពារអធិបតេយ្យភាព និងសម្រេចគោលដៅជាតិ។ |
| • ការការពារអធិបតេយ្យភាពតាមរដ្ឋធម្មនុញ្ញ ( Constitutional defense of sovereignty ) | សំដៅដល់ការការពារអធិបតេយ្យភាព និងឯករាជ្យភាពរបស់រដ្ឋតាមមូលដ្ឋាន និងយន្តការដែលស្របនឹងរដ្ឋធម្មនុញ្ញ។ |
| • សន្តិសុខជាតិក្រោមច្បាប់ ( National security under law ) | សំដៅដល់ការធានាសន្តិសុខជាតិដោយផ្អែកលើច្បាប់ និងគោរពដែនកំណត់ សិទ្ធិ និងនីតិវិធីស្របច្បាប់។ |
| • ភាពធន់នឹងសម្ពាធខាងក្រៅ ( Resilience against external pressure ) | សំដៅដល់សមត្ថភាពរបស់រដ្ឋ និងប្រព័ន្ធច្បាប់ក្នុងការទប់ទល់នឹងសម្ពាធ ឥទ្ធិពល ឬហានិភ័យពីខាងក្រៅ ដោយរក្សាអធិបតេយ្យភាព និងទិសដៅជាតិ។ |

| | |
|---|---|
| • ការគ្រប់គ្រងរដ្ឋដោយទស្សនៈវែងឆ្ងាយ (Prudent statecraft and long-term orientation) | សំដៅដល់ការដឹកនាំ និងគ្រប់គ្រងរដ្ឋដោយការគិតគូរយ៉ាងប្រុងប្រយ័ត្ន មានចក្ខុវិស័យរយៈពេលវែង និងការពារផលប្រយោជន៍ជាតិយ៉ាងចីរភាព។ |

### ៨. វិបុលភាព សណ្តាប់ធ្នាប់សេដ្ឋកិច្ចទីផ្សារ និងការអភិវឌ្ឍប្រកបដោយចីរភាព

| | |
|---|---|
| • សេដ្ឋកិច្ចទីផ្សារក្រោមច្បាប់ (Market economy under law) | សំដៅដល់សណ្តាប់ធ្នាប់សេដ្ឋកិច្ចដែលដំណើរការលើ មូលដ្ឋានសេរីភាពសេដ្ឋកិច្ច ការប្រកួតប្រជែងត្រឹមត្រូវ និងការគ្រប់គ្រងតាមច្បាប់។ |
| • វិបុលភាព និងការអភិវឌ្ឍជាតិ (Prosperity and development) | សំដៅដល់ទិសដៅរបស់ប្រព័ន្ធច្បាប់ក្នុងការគាំទ្រកំណើន ស្ថិរភាព និងការរីកចម្រើនសេដ្ឋកិច្ច និងសង្គមរបស់ជាតិ។ |
| • ទិសដៅសុខុមាលភាពសង្គម (Social welfare orientation) | សំដៅដល់ការធានាថាប្រព័ន្ធច្បាប់មានទិសដៅលើកកម្ពស់សុខុមាលភាព សុវត្ថិភាពសង្គម និងគុណភាពជីវិតរបស់ប្រជាពលរដ្ឋ។ |
| • ការអភិវឌ្ឍប្រកបដោយចីរភាព (Sustainable development) | សំដៅដល់ការអភិវឌ្ឍដែលបំពេញតម្រូវការបច្ចុប្បន្ន ដោយមិនប៉ះពាល់ដល់សមត្ថភាពរបស់ជំនាន់ក្រោយក្នុងការបំពេញតម្រូវការរបស់ខ្លួន។ |
| • ការទទួលខុសត្រូវចំពោះជំនាន់ក្រោយ (Intergenerational responsibility) | សំដៅដល់កាតព្វកិច្ចរបស់រដ្ឋ និងសង្គមក្នុងការគិតគូរពីផលប៉ះពាល់រយៈពេលវែងនៃការសម្រេចចិត្តលើជំនាន់ក្រោយ។ |
| • តុល្យភាពនៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម (Balanced economic and social progress) | សំដៅដល់ការរក្សាតុល្យភាពរវាងកំណើនសេដ្ឋកិច្ច យុត្តិធម៌សង្គម ការការពារបរិស្ថាន និងសុខុមាលភាពសាធារណៈ។ |

### ៩. អភិបាលកិច្ចប្រកបដោយសីលធម៌ សុចរិតភាព និងផលប្រយោជន៍រួម

- ទំនួលខុសត្រូវសីលធម៌នៃអំណាចសាធារណៈ (Moral responsibility of public power) — សំដៅដល់កាតព្វកិច្ចសីលធម៌របស់អ្នកកាន់អំណាចសាធារណៈក្នុងការប្រើប្រាស់អំណាចដោយគោរពផលប្រយោជន៍រួម និងសេចក្តីត្រឹមត្រូវ។
- សុចរិតភាពសាធារណៈ (Public integrity) — សំដៅដល់ភាពស្មោះត្រង់ តម្លាភាព និងការប្រកាន់ខ្ជាប់ស្តង់ដារសីលធម៌ក្នុងវិស័យសាធារណៈ។
- ទិសដៅប្រឆាំងអំពើពុករលួយ (Anti-corruption orientation) — សំដៅដល់ការប្តេជ្ញាចិត្តរបស់ប្រព័ន្ធច្បាប់ក្នុងការទប់ស្កាត់ ទប់ស្កុំ និងផ្តន្ទាទោសអំពើពុករលួយគ្រប់ទម្រង់។
- ការបម្រើផលប្រយោជន៍រួម (Service to the common good) — សំដៅដល់ការតម្រង់ទិសនៃច្បាប់ និងអំណាចសាធារណៈទៅលើផលប្រយោជន៍រួមរបស់សង្គមទាំងមូល។
- ភាពដឹកនាំប្រកបដោយសីលធម៌ (Ethical leadership) — សំដៅដល់ភាពដឹកនាំដែលធ្វើជាគំរូក្នុងសុចរិតភាព គណនេយ្យភាព ការទទួលខុសត្រូវ និងការគោរពតម្លៃសាធារណៈ។
- ការទទួលខុសត្រូវចំពោះអនាគតជាតិ (Responsibility toward future generations) — សំដៅដល់កាតព្វកិច្ចក្នុងការការពារ និងថែរក្សាផលប្រយោជន៍រយៈពេលវែងរបស់ជាតិ សម្រាប់ជំនាន់បច្ចុប្បន្ន និងអនាគត។
- ការសម្រេចចិត្តផ្អែកលើផលប្រយោជន៍សាធារណៈ (Public-interest decision-making) — សំដៅដល់ការសម្រេចចិត្តរបស់ស្ថាប័នសាធារណៈដោយផ្អែកលើហេតុផលសមស្រប ផលប្រយោជន៍សាធារណៈ និងមិនលម្អៀងដោយផលប្រយោជន៍ផ្ទាល់ខ្លួន។

### ៦.៧.២ សារជាតុគតិយុត្ត

សារជាតុគតិយុត្តនៃប្រព័ន្ធច្បាប់ សំដៅដល់ខ្លឹមសារ និងរចនាសម្ព័ន្ធនៃបទដ្ឋានគតិយុត្ត ដែលកំណត់សិទ្ធិ កាតព្វកិច្ច អំណាច និងទំនាក់ទំនងគតិយុត្តនៅក្នុងសង្គម ដែលរួមបញ្ចូលទាំងប្រភពច្បាប់ គោលការណ៍គតិយុត្ត រចនាសម្ព័ន្ធនៃបទដ្ឋាន កម្មវត្ថុ និងអានុភាពនៃច្បាប់ ព្រមទាំងវិធីសាស្ត្របកស្រាយ

និងអនុវត្តច្បាប់។ ក្នុងន័យនេះ សារជាតុគតិយុត្តបង្ហាញពីការកំណត់ ការការពារ ការហាមឃាត់ដោយច្បាប់ យន្តការបណ្តឹងនិងដោះស្រាយវិវាទ និងការដាក់ទោសទណ្ឌ ដោយអនុញ្ញាតឱ្យប្រព័ន្ធច្បាប់អាចរៀបចំ និងគ្រប់គ្រងទំនាក់ទំនងនានានៅក្នុងសង្គមប្រកបដោយ សណ្តាប់ធ្នាប់ និងអាចព្យាករណ៍បាន។ ក្នុងបរិបទនេះ សារជាតុគតិយុត្តមិនត្រឹមតែជាបណ្តុំច្បាប់ធរមានប៉ុណ្ណោះទេ ប៉ុន្តែជារចនាសម្ព័ន្ធនៃបទដ្ឋានដែលមានទំនាក់ទំនង និងឋានានុក្រមច្បាស់លាស់ មានគោលការណ៍ដឹកនាំ និងមានវិធីសាស្រ្តសម្រាប់ការបកស្រាយ ការអនុវត្ត និងការកែលម្អជាបន្តបន្ទាប់។ ដូច្នេះ ការកំណត់ច្បាស់លាស់នូវធាតុផ្សំសំខាន់ៗនៃសារជាតុគតិយុត្ត គឺជាចំណុចគន្លឹះសម្រាប់ធានា សង្គតិភាពភាព បូរណភាពនៃប្រព័ន្ធច្បាប់កម្ពុជា និងគាំទ្រដល់ការអនុវត្តច្បាប់ និងការគ្រប់គ្រងរដ្ឋប្រកបដោយប្រសិទ្ធភាព។

សមាសភាគធាតុផ្សំនៃសារជាតុគតិយុត្តត្រូវបានកំណត់ចេញពីការពិចារណា និងវិភាគអំពីតម្រូវការ នៃខ្លឹមសារច្បាប់របស់ប្រព័ន្ធច្បាប់ដើម្បីអនុញ្ញាតឱ្យប្រព័ន្ធច្បាប់មួយអាចកំណត់សុពលភាព អានុភាព ទំនាក់ទំនង និងការអនុវត្តរបស់បទប្បញ្ញត្តិទាំងមូលបាន។ មូលដ្ឋាននៃការវិភាគទាំងនេះរួមមានការសិក្សាទ្រឹស្តីអំពីប្រភពច្បាប់ សុពលភាពនៃច្បាប់ ឋានានុក្រមនៃបទដ្ឋាន ប្រភេទនៃបទដ្ឋានគតិយុត្ត ការអនុវត្តច្បាប់ក្នុងពេលវេលា ទីកន្លែង និងចំពោះបុគ្គលផ្សេងៗ ព្រមទាំងវិធីសាស្រ្តបកស្រាយ ការអះអាងហេតុផល និងការធ្វើក្រមនីយកម្ម។

សមាសភាគធាតុផ្សំនៃសារជាតុគតិយុត្ត ត្រូវបានរៀបចំតាមលំដាប់តក្កវិជ្ជារបស់ច្បាប់ ដោយចាប់ផ្តើមពីសំណួរថា "អ្វីខ្លះដែលត្រូវបានចាត់ទុកជាច្បាប់" ដូច្នេះសមាសភាគធាតុផ្សំដំបូងបំផុតគឺប្រភពនៃច្បាប់ គោលការណ៍ទូទៅនៃច្បាប់ និងសុពលភាពច្បាប់។ បន្ទាប់ពីកំណត់បាននូវអ្វីដែលត្រូវចាត់ទុកជាច្បាប់រួច ការរៀបចំសមាសភាគធាតុផ្សំនឹងពិនិត្យទៅលើរចនាសម្ព័ន្ធផ្ទៃកខាងក្នុងរបស់ច្បាប់រួមមាន ឋានានុក្រមនៃច្បាប់ សិទ្ធិ កាតព្វកិច្ច អំណាច ទំនួលខុសត្រូវ និងផលប៉ះពាល់គតិយុត្ត។ បន្ទាប់មកទើបបន្តទៅកាន់សំណួរថាច្បាប់អនុវត្តនៅពេលណា កន្លែងណា ចំពោះនរណា របៀបនៃបកស្រាយ សម្របសម្រួល បង្រួបបង្រួម និងកែលម្អច្បាប់ជាប្រព័ន្ធ។

ដោយផ្អែកលើទស្សនៈនេះ សារជាតុគតិយុត្តនៃប្រព័ន្ធច្បាប់កម្ពុជា អាចត្រូវបានរៀបចំជាធាតុផ្សំសំខាន់ៗដូចខាងក្រោម៖

### ១. មូលដ្ឋានគតិយុត្ត

- ច្បាប់កំពូល (Supreme law)

  សំដៅដល់បទដ្ឋានគតិយុត្តដែលមានអានុភាពខ្ពស់បំផុតក្នុងប្រព័ន្ធច្បាប់ និងជាមូលដ្ឋានសម្រាប់សុពលភាពនៃបទដ្ឋានដទៃទៀត។

| | |
|---|---|
| • ប្រភពច្បាប់ ( Source of law ) | សំដៅដល់ទម្រង់ ឬមូលដ្ឋានដែលច្បាប់កើតឡើង និងទទួលស្គាល់ថាមានអានុភាពគតិយុត្តក្នុងប្រព័ន្ធច្បាប់។ |
| • គោលការណ៍ទូទៅនៃច្បាប់ ( General principles of law ) | ជាគោលការណ៍មូលដ្ឋានដែលណែនាំការបកស្រាយ ការអនុវត្ត និងការបំពេញចន្លោះប្រហោងក្នុងច្បាប់។ |
| • សុពលភាពច្បាប់ ( Validity of law ) | សំដៅដល់លក្ខខណ្ឌដែលធ្វើឱ្យបទដ្ឋានគតិយុត្តមួយមានអានុភាព និងត្រូវបានទទួលស្គាល់ថាជាច្បាប់ធរមាន។ |
| • ទំនាស់នៃច្បាប់ ( Conflict of law ) | សំដៅដល់ស្ថានភាពដែលបទដ្ឋាន ឬប្រព័ន្ធច្បាប់ផ្សេងៗមានការប៉ះទង្គិចគ្នា ហើយត្រូវការគោលការណ៍សម្រាប់ដោះស្រាយ។ |

## ២. វចនាសម្ព័ន្ធនៃបទដ្ឋានគតិយុត្ត

| | |
|---|---|
| • ឋានានុក្រមច្បាប់ ( Hierarchy of laws ) | សំដៅដល់លំដាប់ថ្នាក់នៃបទដ្ឋានគតិយុត្តតាមអានុភាពច្បាប់ ដើម្បីធានាសង្គតិភាព និងដោះស្រាយភាពផ្ទុយគ្នា។ |
| • ប្រភេទនិយាមគតិយុត្ត( Types of legal norm ) | សំដៅដល់ការបែងចែកបទដ្ឋានតាមលក្ខណៈ មុខងារ និងអានុភាពរបស់និយាមគតិយុត្តនោះ។ |
| • ប្រធាននីតិ ( Legal subjects ) | ដល់បុគ្គល ឬអង្គភាពដែលអាចក្លាយជាម្ចាស់សិទ្ធិ និងកាតព្វកិច្ចតាមច្បាប់។ |
| • បុគ្គលភាពគតិយុត្ត ( Legal personality ) | សំដៅដល់សមត្ថភាពតាមច្បាប់ក្នុងការកាន់កាប់សិទ្ធិ និងទទួលកាតព្វកិច្ច។ |
| • ឋានៈនិងសមត្ថភាពគតិយុត្ត ( Legal status and capacity ) | សំដៅដល់ស្ថានភាព និងសមត្ថភាពផ្លូវច្បាប់របស់បុគ្គល ឬអង្គភាពក្នុងការធ្វើសកម្មភាពគតិយុត្ត។ |

- ទំនាក់ទំនងគតិយុត្ត (Legal relations) — សំដៅដល់ទំនាក់ទំនងដែលត្រូវបានរៀបចំដោយច្បាប់ រវាងម្ចាស់សិទ្ធិ កាតព្វកិច្ច និងអំណាចគតិយុត្ត។
- អានុភាពគតិយុត្ត (Legal effects) — សំដៅដល់ផលវិបាក ឬលទ្ធផលផ្លូវច្បាប់ដែលកើតចេញពីបទដ្ឋាន ឬសកម្មភាពគតិយុត្តមួយ។
- ទណ្ឌកម្ម សំណង និងការទទួលខុសត្រូវ (Sanctions, remedies, and liabilities) — សំដៅដល់វិធានការឆ្លើយតបផ្លូវច្បាប់ចំពោះការបំពាន រួមទាំងទណ្ឌកម្ម សំណង និងទំនួលខុសត្រូវតាមច្បាប់។

### ៣. ប្រតិបត្តិការនៃច្បាប់

- ការប្រកាសឱ្យប្រើច្បាប់ (Promulgation of law) — ជានីតិវិធីផ្លូវការដែលធ្វើឱ្យច្បាប់មួយត្រូវបានទទួលស្គាល់ និងចូលក្នុងប្រព័ន្ធច្បាប់។
- ការផ្សព្វផ្សាយច្បាប់ (Publication of law) — សំដៅដល់ការបង្ហាញ ឬចេញផ្សាយអត្ថបទច្បាប់ជាសាធារណៈ ដើម្បីឱ្យអាចចូលដំណើរការ និងយល់បាន។
- ការចូលជាធរមាន (Entry into force) — សំដៅដល់ពេលដែលច្បាប់ចាប់ផ្ដើមមានអានុភាពអនុវត្តជាផ្លូវការ។
- ពេលវេលាអនុវត្តនៃច្បាប់ (Temporal application of law) — សំដៅដល់វិសាលភាពអនុវត្តរបស់ច្បាប់តាមរយៈពេល និងពេលកើតហេតុគតិយុត្ត។
- ប្រតិសកម្មនិងអប្រតិសកម្មនៃច្បាប់ (Retroactivity and non-retroactivity of law) — កំណត់ថាច្បាប់អាចឬមិនអាចអនុវត្តទៅលើអង្គហេតុដែលកើតឡើងមុនពេលច្បាប់ចូលជាធរមាន។
- ដែនដីអនុវត្តនៃច្បាប់ (Territorial application of law) — សំដៅដល់វិសាលភាពអនុវត្តរបស់ច្បាប់នៅក្នុងទឹកដីរបស់រដ្ឋ។
- អានុភាពអនុវត្តក្រៅដែនដីនៃច្បាប់ (Extraterritorial application of law) — សំដៅដល់ករណីដែលច្បាប់អាចមានអានុភាពអនុវត្តចំពោះសកម្មភាព ឬបុគ្គលក្រៅទឹកដីរដ្ឋ។

| | |
|---|---|
| • បញ្ញត្តិអន្តរកាល (Transitional provisions) | សំដៅដល់បទប្បញ្ញត្តិដែលរៀបចំការផ្លាស់ប្តូរពីរបបច្បាប់ចាស់ទៅរបបច្បាប់ថ្មី។ |
| • បញ្ញត្តិរយៈពេលកំណត់ (Sunset provisions) | សំដៅដល់បទប្បញ្ញត្តិដែលកំណត់ឱ្យច្បាប់ ឬវិធានការមួយផុតអានុភាពដោយស្វ័យប្រវត្តិនៅពេលកំណត់។ |
| • ការផ្សព្វផ្សាយផ្លូវការនៃច្បាប់ (Official publication of legal texts) | ជាយន្តការធានាថាអត្ថបទច្បាប់ដែលមានសុពលភាពត្រូវបានបោះពុម្ព និងផ្សព្វផ្សាយតាមប្រភពផ្លូវការ។ |
| • ភាសាផ្លូវការនិងច្បាប់ដើមនៃអត្ថបទច្បាប់ (Official language and authenticity of legal texts) | កំណត់ភាសាផ្លូវការ និងអត្ថបទច្បាប់ដែលត្រូវចាត់ទុកថាជាអត្ថបទដើមមានអានុភាព។ |
| • អានុភាពច្បាប់ក្នុងគ្រាអាសន្ន (Effect of law in emergency situation) | សំដៅលើរបៀបដែលអំណាច និងការធានាតាមច្បាប់ ត្រូវអនុវត្តក្នុងស្ថានភាពអាសន្ន ឬកាលៈទេសៈវិសមប្រក្រតី។ |

**៤. វិធីសាស្ត្រគតិយុត្ត**

| | |
|---|---|
| • វិធីសាស្ត្របកស្រាយច្បាប់ (Method of interpretation) | វិធីសាស្ត្របកស្រាយច្បាប់សំដៅដល់បច្ចេកទេស និងវិធីសាស្ត្រសម្រាប់កំណត់ន័យ និងគោលបំណងរបស់បទប្បញ្ញត្តិច្បាប់។ |
| • ការសំអាងហេតុផលដោយប្រៀបធៀប (Reasoning by analogy) | សំដៅដល់ការយកគោលការណ៍ ឬដំណោះស្រាយពីករណីស្រដៀងគ្នាមកអនុវត្តចំពោះករណីដែលមិនមានបទប្បញ្ញត្តិច្បាស់លាស់។ |
| • វិធីសាស្ត្របំពេញចន្លោះប្រហោងនៃច្បាប់ (Gap-filling methods) | សំដៅដល់ការបំពេញគម្លាតឬចន្លោះនៅក្នុងច្បាប់ដើម្បីអនុញ្ញាតឱ្យប្រព័ន្ធច្បាប់អាចឆ្លើយតបបានពេញលេញ។ |

- ការសំអាងហេតុផលដោយប្រើប្រាស់គោលការណ៍សមធម៌ និងគោលការណ៍ទូទៅ (Use of equity and general principles reasoning) សំដៅដល់ការប្រើគោលការណ៍សមធម៌ និងគោលការណ៍ទូទៅនៃច្បាប់ដើម្បីជួយបកស្រាយ ឬដោះស្រាយបញ្ហាគតិយុត្ត។
- អានុភាពនៃយុត្តិសាស្ត្រ (Effect of precedent) សំដៅដល់ឥទ្ធិពល ឬទម្ងន់នៃសេចក្តីសម្រេចមុនៗមកលើ ករណីសម្រេចបន្តបន្ទាប់។
- កាព្វកិច្ចក្នុងផ្តល់ភស្តុតាង (Burden of proof) សំដៅដល់ការកំណត់កាតព្វកិច្ចបង្ហាញភស្តុតាងដើម្បីគាំទ្រអំណះអំអាងរបស់ខ្លួន។
- ស្តង់ដារនៃភស្តុតាង (Standard of proof) កម្រិត ឬទម្ងន់នៃភស្តុតាងដែលច្បាប់តម្រូវឱ្យបង្ហាញ ដើម្បីបញ្ជាក់ការពិតនៅក្នុងសំណុំរឿងក្តី។

**៥. ការចងក្រងជាប្រព័ន្ធ**

- ការចាត់ចំណាត់ថ្នាក់ច្បាប់ (Classification/taxonomy of law) សំដៅដល់ការរៀបចំច្បាប់ជាប្រភេទ និងចំណាត់ថ្នាក់ដើម្បីងាយស្រួលយល់ ស្វែងរក និងអនុវត្ត។
- ក្រមនីយកម្ម (Codification) សំដៅដល់ការប្រមូល និងរៀបចំបទប្បញ្ញត្តិពាក់ព័ន្ធឱ្យក្លាយជាក្រម ឬអត្ថបទច្បាប់ដែលមានរចនាសម្ព័ន្ធច្បាស់លាស់។
- ការរួមបញ្ចូល (Consolidation) សំដៅដល់ការប្រមូលបញ្ចូលអត្ថបទច្បាប់ដែលបែកខ្ញែកគ្នា ទៅជាអត្ថបទច្បាប់តែមួយដែលបានធ្វើបច្ចុប្បន្នភាព ដោយមិនកែប្រែខ្លឹមសារសារជាតុរបស់ច្បាប់។
- វិសោធនកម្ម (Amendment) សំដៅដល់ការកែប្រែបន្ថែម ឬលុបផ្នែកណាមួយនៃច្បាប់ធរមាន។
- ការយោង និងអាគតដ្ឋាន (Citation and referencing) សំដៅដល់វិធីសាស្ត្រយោង និងការរៀបចំអាគតដ្ឋានច្បាប់ឱ្យមានភាពច្បាស់លាស់ ស្តង់ដារ និងអាចផ្ទៀងផ្ទាត់បាន។

| | |
|---|---|
| • និយមន័យ និងសន្ទានុក្រមច្បាប់ (Definitions and legal terminology) | សំដៅដល់ការកំណត់និយមន័យ និងពាក្យបច្ចេកទេសច្បាប់ឱ្យបានច្បាស់លាស់ និងមានសង្គតិភាព។ |
| • ស្តង់ដារតាក់តែងច្បាប់ (Drafting standards) | សំដៅដល់គោលការណ៍ និងលក្ខខណ្ឌគុណភាពក្នុងការរៀបចំអត្ថបទច្បាប់។ |
| • វិធីសាស្ត្រតាក់តែងច្បាប់ (Legislative technique) | សំដៅដល់បច្ចេកទេសក្នុងការរៀបចំរចនាសម្ព័ន្ធភាសា និងខ្លឹមសារនៃបទប្បញ្ញត្តិឱ្យមានភាពត្រឹមត្រូវ និងអាចអនុវត្តបាន។ |
| • ភាពប្រទាក់ក្រឡានិងសង្គតិភាពនៃច្បាប់ (Coherence and consistency of law) | សំដៅលើការជានាទំនាក់ទំនងរបស់ច្បាប់ដែលមានភាពស៊ីចង្វាក់គ្នា មិនប្រទាំងប្រទើស មិនផ្ទុយគ្នា និងឯកភាពគ្នា។ |
| • វដ្តនៃច្បាប់ (Law lifecycle) | សំដៅដល់ជីវិតរបស់ច្បាប់ចាប់ពីការតាក់តែង អនុម័ត ផ្សព្វផ្សាយ អនុវត្ត ពិនិត្យឡើងវិញ រហូតដល់ការកែប្រែ ឬលុបចោល។ |

**៦. ទំនាក់ទំនងច្បាប់ជាតិជាមួយនិយាមផ្សេងៗ**

| | |
|---|---|
| • ការទទួលយកច្បាប់អន្តរជាតិ (Reception of international law) | សំដៅដល់របៀបដែលច្បាប់អន្តរជាតិត្រូវបានទទួលស្គាល់ បញ្ចូល ឬអនុវត្តក្នុងប្រព័ន្ធច្បាប់ជាតិ។ |
| • ជម្រើសច្បាប់ / ទំនាស់ច្បាប់អន្តរប្រព័ន្ធ (Choice of law/inter-system conflict of laws) | សំដៅដល់គោលការណ៍សម្រាប់កំណត់ថាច្បាប់ណាត្រូវអនុវត្ត នៅពេលមានទំនាក់ទំនងពាក់ព័ន្ធនឹង ប្រព័ន្ធច្បាប់ច្រើន។ |
| • ច្បាប់ទំនៀម (Customary Law) | សំដៅដល់បទដ្ឋាន ឬទម្លាប់ដែលត្រូវបានទទួលស្គាល់ថាមានតម្លៃគតិយុត្តក្នុងសហគមន៍ ឬក្នុងប្រព័ន្ធច្បាប់ជាតិ។ |

- ទំនាក់ទំនងជាមួយនិយាមផ្សេងៗ (Relationship with other normative orders)៖ professional standards, religious norm, social norms

  សំដៅដល់ទំនាក់ទំនងរវាងច្បាប់ជាតិជាមួយនិយាមផ្សេងៗ ដូចជា ស្តង់ដារវិជ្ជាជីវៈ និយាមសាសនា និងនិយាមសង្គម។

- ច្បាប់ទន់ សេចក្តីណែនាំ និងសេចក្តីណែនាំរដ្ឋបាល (Soft law, guideline, administrative instructions)

  សំដៅដល់ឯកសារ ឬវិធានដែលមិនមែនជាច្បាប់រឹង ប៉ុន្តែមានឥទ្ធិពលក្នុងការណែនាំ និងសម្របសម្រួលការអនុវត្ត។

### ៦.៧.៣ រចនាសម្ព័ន្ធគតិយុត្ត

រចនាសម្ព័ន្ធគតិយុត្តនៃប្រព័ន្ធច្បាប់ សំដៅដល់និម្មាបនកម្មស្ថាប័ន និងយន្តការស្ថាប័ននានា ដែលទទួលបន្ទុកក្នុងការកសាង បកស្រាយ ប្រតិបត្តិ និងអនុវត្តច្បាប់ ដែលរួមបញ្ចូលទាំងស្ថាប័នធម្មនុញ្ញ ស្ថាប័ននីតិបញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ ស្ថាប័នតុលាការ ស្ថាប័នអនុវត្តច្បាប់ និងស្ថាប័នវិជ្ជាជីវៈនិងអប់រំច្បាប់។ ក្នុងន័យនេះ រចនាសម្ព័ន្ធគតិយុត្តបង្ហាញពីការរៀបចំនិងបែងចែក អំណាចនិងសមត្ថកិច្ចផ្នែកច្បាប់ រវាងស្ថាប័នផ្សេងៗ ដើម្បីធានាថាប្រព័ន្ធច្បាប់អាចដំណើរការបានប្រកបដោយសណ្តាប់ធ្នាប់ ប្រសិទ្ធភាព និងគណនេយ្យភាព។ ក្នុងទ្រឹស្តីប្រព័ន្ធ រចនាសម្ព័ន្ធគតិយុត្តជាបណ្តាញស្ថាប័នដែលមានទំនាក់ទំនងប្រទាក់ក្រឡា និងបំពេញមុខងារប្រកបដោយការសម្របសម្រួលរវាងគ្នា។ ការរៀបចំរចនាសម្ព័ន្ធស្ថាប័នឱ្យមានភាពច្បាស់លាស់ និងប្រទាក់ក្រឡាគ្នា ជាកត្តាសំខាន់សម្រាប់ធានាការបែងចែកអំណាចប្រកបដោយតុល្យភាព ការអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធភាព និងការគ្រប់គ្រងរដ្ឋស្របតាមគោលការណ៍នីតិរដ្ឋ។ ដូច្នេះ ការកំណត់ និងរៀបចំធាតុផ្សំសំខាន់ៗនៃរចនាសម្ព័ន្ធគតិយុត្ត គឺមានសារៈសំខាន់ក្នុងការធានាថាប្រព័ន្ធច្បាប់កម្ពុជាអាចដំណើរការបានជាប្រព័ន្ធដែលមានសង្គតិភាព មានស្ថិរភាព និងអាចឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍជាតិ។

សមាសភាគធាតុផ្សំនៃរចនាសម្ព័ន្ធគតិយុត្ត ត្រូវបានកំណត់ដោយផ្អែកលើការវិភាគលើចំនួនស្ថាប័នទាំងអស់ដែលមានតួនាទីក្នុងការបង្កើត អនុវត្ត ត្រួតពិនិត្យ តាមដាន និងផ្តល់សេវាច្បាប់។ ការវិភាគនេះទៀតសោតក៏បានផ្អែកលើការស្រាវជ្រាវអំពីស្ថាប័ននៃប្រព័ន្ធច្បាប់កម្ពុជា ដោយប្រព័ន្ធច្បាប់មួយមិនអាចដំណើរការបានដោយមានត្រឹមតែបទប្បញ្ញត្តិនោះទេពោលគឺត្រូវការស្ថាប័នដែលទទួលបន្ទុកផ្សេងៗគ្នារួមមានស្ថានប័នត្រួតពិនិត្យធម្មនុញ្ញភាព ស្ថានប័នអនុវត្តច្បាប់ ស្ថានប័នបកស្រាយច្បាប់ ស្ថានប័នដោះស្រាយវិវាទ ស្ថានប័នបណ្តុះបណ្តាលច្បាប់ និងស្ថានប័នផ្សព្វផ្សាយច្បាប់។

សមាសភាគជាតុផ្សំនៃរចនាសម្ព័ន្ធគតិយុត្តត្រូវបានរៀបចំតាមលំដាប់មុខងារ និងលំដាប់ស្ថាប័នក្នុងរដ្ឋនៃច្បាប់រួមមានស្ថាប័នកំពូលបំផុតនៃរដ្ឋធម្មនុញ្ញ និងការបែងចែកអំណាចដែលជាមូលដ្ឋានសម្រាប់កំណត់ និងបែងចែកតួនាទីរបស់ស្ថាប័នផ្សេងៗទៀតដូចជាស្ថាប័នកសាងច្បាប់ និងស្ថាប័នត្រួតពិនិត្យធម្មនុញ្ញភាព ស្ថាប័នយុត្តិធម៌ និងអនុវត្តច្បាប់ ដូចជា តុលាការ អយ្យការ នគរបាល អាជ្ញាធរអនុវត្ត បន្ទាប់ពីនេះ ទើបបន្តពង្រីកទៅកាន់ស្ថាប័នគាំទ្រដូចជា វិជ្ជាជីវៈច្បាប់ សេវាកម្មច្បាប់ ADR ស្ថាប័នអប់រំ ស្រាវជ្រាវ និងស្ថាប័នព័ត៌មានច្បាប់។

ដោយផ្អែកលើទស្សនៈនេះ រចនាសម្ព័ន្ធគតិយុត្តនៃប្រព័ន្ធច្បាប់កម្ពុជាអាចរៀបចំជាធាតុផ្សំ សំខាន់ៗដូចខាងក្រោម៖

### ១. ស្ថាប័នធម្មនុញ្ញ និងការបែងចែកអំណាចរដ្ឋ

- ស្ថាប័នធម្មនុញ្ញ (Constitutional organs) — ស្ថាប័នដែលកំណត់ដោយរដ្ឋធម្មនុញ្ញ និងមានតួនាទីមូលដ្ឋានក្នុងការគ្រប់គ្រងអំណាចរដ្ឋ។
- ការបែងចែកអំណាច (Separation of powers) — ការបែងចែកអំណាចរបស់រដ្ឋទៅជាអំណាច នីតិបញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ ក្នុងគោលបំណង ជៀសវាងការរំលោភអំណាចគ្នាទៅវិញទៅមក។
- ការពិនិត្យនិងតុល្យភាពអំណាច (Check and balance) — យន្តការដែលធានាឱ្យស្ថាប័ននីមួយៗអាចត្រួតពិនិត្យ និងតុល្យភាពអំណាចគ្នាទៅវិញទៅមក។
- ស្ថាប័នការងាររដ្ឋធម្មនុញ្ញ (Constitutional guardianship institutions) — ស្ថាប័នដែលទទួលខុសត្រូវក្នុងការការពាររដ្ឋធម្មនុញ និងបូរណភាពនៃរបបធម្មនុញ។
- ស្ថាប័នទំនាក់ទំនងគតិយុត្តអន្តរស្ថាប័ន (Inter-institutional legal relations) — ការរៀបចំទំនាក់ទំនង និងសម្របសម្រួលរវាងស្ថាប័នរដ្ឋនានាក្នុងប្រព័ន្ធរដ្ឋធម្មនុញ។
- ស្ថាប័នមានអំណាចក្នុងគ្រាអាសន្ននិងពិសេស (Emergency and exceptional powers) — សំដៅទៅលើអំណាចពិសេសដែលមានក្នុងពេលមានអាសន្ន ដែលស្ថិតក្រោមច្បាប់កំណត់ និងការពារ ធម្មនុញ្ញភាព។

### ៣. ស្ថាប័នកសាងច្បាប់

- ស្ថាប័ននីតិបញ្ញត្តិ (Legislative Body) — ស្ថាប័ននីតិបញ្ញត្តិជាតិដែលទទួលបន្ទុកពិភាក្សា អនុម័ត និងត្រួតពិនិត្យច្បាប់ និងគោលនយោបាយសាធារណៈ។
- ស្ថាប័នរៀបចំច្បាប់នៃអំណាចប្រតិបត្តិ (Executive law-preparation institutions) — សំដៅលើស្ថាប័នក្នុងអំណាចប្រតិបត្តិដែលទទួលខុសត្រូវរៀបចំ និងសម្របសម្រួលសេចក្តីព្រាងច្បាប់ និងបទប្បញ្ញត្តិ។
- អង្គភាពតាក់តែងច្បាប់ (Legislative drafting units) — ជាអង្គភាពឯកទេសដែលបម្លែងគោលនយោបាយ និងទិសដៅកំណែទម្រង់ ទៅជាអត្ថបទច្បាប់ដែលមានរចនាសម្ព័ន្ធគតិយុត្តច្បាស់លាស់។
- ស្ថាប័នពិនិត្យនិងធានាសុខដុមនីយកម្ម (Legal review and harmonization bodies) — សំដៅលើស្ថាប័នដែលពិនិត្យសេចក្តីព្រាងបទប្បញ្ញត្តិ ដើម្បីធានានីត្យានុកូលភាព សង្គតិភាព និងការសម្របសម្រួលជាមួយច្បាប់ដទៃ។
- អង្គភាពទទួលបន្ទុកលិខិតបទដ្ឋានគតិយុត្ត (Bodies responsible for subordinate legislation) — សំដៅលើអង្គភាពដែលមានសមត្ថកិច្ចរៀបចំ ឬចេញលិខិតបទដ្ឋានក្រោមច្បាប់ តាមអំណាចដែលច្បាប់ផ្តល់។
- ស្ថាប័នប្រកាសឱ្យប្រើនិងផ្សព្វផ្សាយច្បាប់ (Promulgation and publication institutions) — សំដៅលើអង្គភាពធានាថាច្បាប់ត្រូវបានប្រកាស និងផ្សព្វផ្សាយជាផ្លូវការ។
- ស្ថាប័នសម្របសម្រួលនិងកែទម្រង់ច្បាប់ (Regulatory coordination and reform bodies) — សំដៅលើស្ថាប័នដែលសម្របសម្រួលការកែលម្អបទប្បញ្ញត្តិ ការកែទម្រង់ច្បាប់ និងការធ្វើឱ្យប្រព័ន្ធច្បាប់ទាន់សម័យ។

### ៣. ស្ថាប័នពិនិត្យធម្មនុញ្ញភាព និងគ្រប់គ្រង់ច្បាប់

- តុលាការធម្មនុញ្ញ (Constitutional court) — ស្ថាប័នដែលពិនិត្យភាពស្របរដ្ឋធម្មនុញ្ញនៃច្បាប់ និងសកម្មភាពរបស់រដ្ឋ។

- យន្តការពិនិត្យបច្ចេកទេស (Technical review mechanisms) — សំដៅលើនីតិវិធី ឬដំណើរការឯកទេសសម្រាប់ពិនិត្យគុណភាពបច្ចេកទេស នីត្យានុកូលភាព និងភាពត្រឹមត្រូវនៃសេចក្ដីព្រាងបទប្បញ្ញត្តិ។
- ការពិនិត្យធម្មនុញ្ញភាពនៃច្បាប់ (Review of constitutionality of laws) — ដំណើរការត្រួតពិនិត្យថាតើច្បាប់ដែលបានអនុវត្តស្របនឹងរដ្ឋធម្មនុញ្ញដែរឬទេ។
- ការពិនិត្យនិត្យានុកូលភាពនៃលិខិតបទដ្ឋានគតិយុត្ត (Review of legality of subordinate legislation) — សំដៅលើការពិនិត្យថាតើ បទប្បញ្ញត្តិក្រោមច្បាប់ ឬលិខិតបទដ្ឋានផ្សេងៗ ស្របនឹងច្បាប់ថ្នាក់លើ និងអំណាចដែលបានប្រគល់ឬទេ។
- ស្ថាប័នដោះស្រាយវិវាទបោះឆ្នោត (Electoral dispute adjudication institutions) — ជាស្ថាប័នដែលទទួលបន្ទុកដោះស្រាយវិវាទកើតចេញពីការបោះឆ្នោត ឬដំណើរការបោះឆ្នោត។
- មុខងារប្រឹក្សាការបកស្រាយរដ្ឋធម្មនុញ្ញ (Advisory constitutional interpretation functions) — សំដៅលើមុខងារផ្ដល់យោបល់ ឬការណែនាំអំពីការបកស្រាយរដ្ឋធម្មនុញ្ញ ដើម្បីជួយស្ថាប័នរដ្ឋអនុវត្តអំណាចបានត្រឹមត្រូវ។

### ៤. ប្រព័ន្ធតុលាការ និងស្ថាប័នដោះស្រាយវិវាទ

- ឋានានុក្រមស្ថាប័នតុលាការ (Court hierarchy) — សំដៅលើរចនាសម្ព័ន្ធលំដាប់ថ្នាក់នៃតុលាការតាមកម្រិតសមត្ថកិច្ច និងអំណាចវិនិច្ឆ័យ។
- តុលាការយុត្តាធិការទូទៅ (General jurisdiction courts) — សំដៅដល់តុលាការដែលដោះស្រាយវិវាទទូទៅគ្រប់ប្រភេទ។
- តុលាការជំនាញ (Specialized courts) — ជាតុលាការដែលមានសមត្ថកិច្ចកំណត់លើវិស័យជាក់លាក់ ឬប្រភេទសំណុំរឿងឯកទេស។
- រចនាសម្ព័ន្ធតុលាការឧទ្ធរណ៍ (Appellate structure) — សំដៅដល់ការរៀបចំផ្លូវប្ដឹងឧទ្ធរណ៍ ដែលតាមរយៈនោះ ការសម្រេចចិត្តត្រូវបានពិនិត្យឡើងវិញដោយតុលាការជាន់ខ្ពស់។

- តុលាការកំពូល (Supreme court) — ជាតុលាការថ្នាក់ខ្ពស់បំផុតក្នុងប្រព័ន្ធតុលាការទូទៅ ដែលមានតួនាទីពិនិត្យសេចក្ដីសម្រេចចុងក្រោយ និងដឹកនាំសង្គតិភាពយុត្តិសាស្ត្រ។
- រដ្ឋបាលតុលាការ (Court administration) — សំដៅលើការគ្រប់គ្រងផ្នែករដ្ឋបាល បុគ្គលិក ថវិកា និងការគាំទ្របច្ចេកទេសសម្រាប់ដំណើរការរបស់តុលាការ។
- យន្តការបែងចែកសំណុំរឿងនិងគ្រប់គ្រងសំណុំរឿង (Case allocation and case management mechanisms) — សំដៅលើវិធាន និងប្រព័ន្ធសម្រាប់បែងចែកសំណុំរឿង និងគ្រប់គ្រងដំណើរការសំណុំរឿងឱ្យមានប្រសិទ្ធភាព តម្លាភាព និងអព្យាក្រឹតភាព។

### ៥. អភិបាលនៃប្រព័ន្ធកិច្ចតុលាការ

- ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម (Supreme council of magistracy) — ជាស្ថាប័នទទួលបន្ទុកអភិបាលកិច្ចវិស័យតុលាការ ស្ថានភាពចៅក្រម និងការធានាឯករាជ្យភាពនៃអំណាចតុលាការ។
- អង្គភាពតែងតាំង និងដំឡើងមុខតំណែង (Appointment and promotion bodies) — សំដៅដល់ស្ថាប័ន ឬយន្តការដែលទទួលបន្ទុកក្នុងការជ្រើសរើស តែងតាំង និងដំឡើងមុខតំណែងចៅក្រម ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យច្បាស់លាស់ សមត្ថភាព វិជ្ជាជីវៈ សុចរិតភាព និងគោលការណ៍ឯករាជ្យភាពតុលាការ។
- ស្ថាប័នទទួលបន្ទុកលើវិន័យចៅក្រម (Judicial discipline institutions) — សំដៅលើស្តង់ដារសីលធម៌ និងយន្តការវិន័យដែលគ្រប់គ្រងការប្រព្រឹត្តរបស់ព្រះរាជអាជ្ញា។
- អង្គភាពអធិការកិច្ច និងក្រមសីលធម៌ចៅក្រម (Judicial ethics and inspection bodies) — សំដៅដល់អង្គភាពដែលទទួលបន្ទុកត្រួតពិនិត្យការពង្រឹងការគោរពក្រមសីលធម៌ និងការតាមដានការប្រព្រឹត្តរបស់ចៅក្រម ដើម្បីធានាសុចរិតភាព ឯករាជ្យភាព និងទំនុកចិត្តសាធារណៈលើប្រព័ន្ធតុលាការ។

- អង្គភាពរដ្ឋបាលនិងផែនការតុលាការ ( Bodies for judicial administration and planning ) — សំដៅដល់អង្គភាពដែលទទួលបន្ទុកលើការគ្រប់គ្រងរដ្ឋបាល ការរៀបចំធនធាន ការធ្វើផែនការ និងការគាំទ្រប្រតិបត្តិការរបស់តុលាការ ដើម្បីធានាថាប្រព័ន្ធតុលាការអាចដំណើរការបានប្រកបដោយប្រសិទ្ធភាព និងស្ថិរភាព។
- យន្តការពិនិត្យការបំពេញមុខងារនិងសុចរិតភាពរបស់តុលាការ ( Judicial performance and integrity mechanisms ) — សំដៅដល់យន្តការសម្រាប់វាយតម្លៃគុណភាព ប្រសិទ្ធភាព និងសុចរិតភាពក្នុងការបំពេញមុខងាររបស់តុលាការ និងចៅក្រម ដើម្បីពង្រឹងគណនេយ្យភាព និងធានាទំនុកចិត្តសាធារណៈ។
- យន្តការបែងចែកសំណុំរឿងនិងគ្រប់គ្រងសំណុំរឿង ( Case allocation and case management mechanisms ) — សំដៅដល់នីតិវិធី និងប្រព័ន្ធសម្រាប់បែងចែកសំណុំរឿងទៅចៅក្រម ឬអង្គជំនុំជម្រះ និងសម្រាប់គ្រប់គ្រងដំណើរការសំណុំរឿងចាប់ពីការទទួល រហូតដល់ការសម្រេច ដោយធានាភាពត្រឹមត្រូវ តម្លាភាព ប្រសិទ្ធភាព និងការពារការជ្រៀតជ្រែកមិនសមស្រប។

### ៥. ប្រព័ន្ធអយ្យការ

- ស្ថាប័នអយ្យការគ្រប់ជាន់ថ្នាក់ ( Prosecution offices at all level ) — សំដៅលើលំដាប់អំណាច ការត្រួតពិនិត្យ និងការទទួលខុសត្រូវផ្ទៃក្នុងរបស់អយ្យការ។
- ឋានានុក្រមអយ្យការ ( Prosecutorial hireracy ) — សំដៅដល់រចនាសម្ព័ន្ធថ្នាក់នៃអង្គភាពអយ្យការដែលរៀបចំតាមលំដាប់អំណាច និងសមត្ថកិច្ច ដើម្បីធានាការសម្របសម្រួល ការត្រួតពិនិត្យ និងសង្គតិភាពក្នុងការអនុវត្តតួនាទី។
- ទំនាក់ទំនងរវាងអយ្យការនិងតុលាការ ( Relationship between prosecution and judiciary ) — សំដៅលើទំនាក់ទំនងដែលច្បាប់កំណត់រវាងអយ្យការ និងតុលាការ ក្នុងដំណើរការយុត្តិធម៌។

- ទំនាក់ទំនងរវាងអយ្យការនិងនគបាល (Relationship between prosecution and police) — សំដៅលើទំនាក់ទំនងសម្របសម្រួល និងត្រួតពិនិត្យរវាងអយ្យការ និងនគរបាល ក្នុងការស៊ើបអង្កេត និងអនុវត្តច្បាប់។
- ឆន្ទានុសិទ្ធិអយ្យការ និងទិសដៅគោលនយោបាយ (Prosecutorial discretion and policy direction) — សំដៅដល់សិទ្ធិ និងអំណាចរបស់អយ្យការ ក្នុងការសម្រេចចិត្តអំពីការចោទប្រកាន់ ការបន្ត ឬបញ្ឈប់នីតិវិធី តាមបរិបទនៃច្បាប់ និងគោលនយោបាយ ដោយផ្អែកលើគោលការណ៍យុត្តិធម៌ ប្រសិទ្ធភាព និងផលប្រយោជន៍សាធារណៈ។
- ឯករាជ្យភាពនៃអយ្យការ (Prosecutorial independence) — សំដៅលើកម្រិតដែលការសម្រេចរបស់អយ្យការត្រូវបានការពារពីការជ្រៀតជ្រែកមិនសមរម្យ។
- វិន័យ និងក្រមសីលធម៌ (Prosecutorial discipline and ethics) — សំដៅលើស្តង់ដារសីលធម៌ និងយន្តការវិន័យដែលគ្រប់គ្រងការប្រព្រឹត្តរបស់ព្រះរាជអាជ្ញា។
- អង្គភាពអយ្យការជំនាញ (Specialized prosecution units) — ជាអង្គភាពអយ្យការដែលមានភារកិច្ចលើប្រភេទសំណុំរឿងជាក់លាក់ ឬវិស័យអនុវត្តច្បាប់ពិសេស។

### ៧. ស្ថាប័នស៊ើបអង្កេត នគរបាល និងអនុវត្តច្បាប់

- ស្ថាប័ននគរបាល (Police institutions) — សំដៅដល់ស្ថាប័នអនុវត្តច្បាប់ដែលមានតួនាទីរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ការពារសិទ្ធិ និងសុវត្ថិភាពរបស់ប្រជាពលរដ្ឋ និងអនុវត្តច្បាប់តាមបណ្តោយនីតិវិធីស្របច្បាប់។
- អង្គភាពស៊ើបអង្កេតព្រហ្មទណ្ឌ (Criminal investigation bodies) — សំដៅដល់អង្គភាពដែលទទួលបន្ទុកស៊ើបអង្កេតបទល្មើសប្រព្រឹត្តឡើង ដោយប្រមូលភស្តុតាង ស្វែងរកអង្គហេតុ និងកំណត់ជនសង្ស័យ ដើម្បីគាំទ្រដល់ការចោទប្រកាន់តាមច្បាប់។

- នគរបាលយុត្តិធម៌ (Judicial police) — សំដៅដល់នគរបាលដែលអនុវត្តមុខងារស៊ើបអង្កេត និងសកម្មភាពពាក់ព័ន្ធក្រោមការដឹកនាំ និងការត្រួតពិនិត្យរបស់អយ្យការ និងតុលាការ។
- នគរបាលយុត្តិធម៌ជំនាញ (Specialized judicial police) — សំដៅដល់អង្គភាពនគរបាលដែលមានជំនាញពិសេសក្នុងវិស័យជាក់លាក់ ដូចជា ឧក្រិដ្ឋកម្មហិរញ្ញវត្ថុ អំពើពុករលួយ ឧក្រិដ្ឋកម្មបច្ចេកវិទ្យា ឬបទល្មើសធ្ងន់ធ្ងរ។
- ការទទួលខុសត្រូវនិងត្រួតពិនិត្យលើនគរបាល (Police accountability and oversight) — សំដៅដល់យន្តការធានាថានគរបាលអនុវត្តអំណាចដោយស្របច្បាប់ មានគណនេយ្យភាព និងអាចត្រូវបានត្រួតពិនិត្យ ពិនិត្យឡើងវិញ ឬទទួលខុសត្រូវក្នុងករណីមានការបំពាន។
- ស្ថាប័នទទួលបន្ទុកកោសល្យវិច្ច័យនិងពិនិត្យភស្តុតាង (Forensic and evidentiary support institutions) — សំដៅដល់អង្គភាពបច្ចេកទេសដែលមានតួនាទីវិភាគភស្តុតាងវិទ្យាសាស្ត្រ ដើម្បីគាំទ្រដល់ការស៊ើបអង្កេត និងដំណើរការតុលាការ។
- ការសម្របសម្រួលព័ត៌មានព្រហ្មទណ្ឌនិងស៊ើបអង្កេត (Criminal intelligence and investigative coordination) — សំដៅដល់យន្តការប្រមូល បែងចែក និងចែករំលែកព័ត៌មានពាក់ព័ន្ធនឹងបទល្មើស និងសកម្មភាពស៊ើបអង្កេត រវាងស្ថាប័ននានា ដើម្បីបង្កើនប្រសិទ្ធភាព និងសម្របសម្រួលការងារ។

### ៧. ការដោះស្រាយវិវាទរដ្ឋបាល និងការការពារនីត្យានុកូលភាព

- តុលាការរដ្ឋបាល (Administrative court) — ស្ថាប័នដោះស្រាយវិវាទរដ្ឋបាល។
- យន្តការបណ្តឹងនិងពិនិត្យសកម្មភាពរដ្ឋបាល (Complaint and review mechanisms against administrative action) — វិធីសាស្ត្រអនុញ្ញាតឱ្យបណ្តឹងប្រឆាំងនឹងសកម្មភាពរដ្ឋបាល។

- ការការពារនីត្យានុកូលភាពលើសេចក្ដីសម្រេចអំណាចប្រតិបត្តិ ( Legality control over executive decisions ) — សំដៅដល់យន្តការដែលធានាថាសេចក្ដីសម្រេច និងសកម្មភាពរបស់អំណាចប្រតិបត្តិ ត្រូវស្ថិតក្រោមច្បាប់ មានមូលដ្ឋានច្បាប់ច្បាស់លាស់ និងអាចត្រូវបានពិនិត្យឡើងវិញក្នុងករណីមានការបំពាននីត្យានុកូលភាព។
- យន្តការដោះស្រាយវិវាទលើច្បាប់សាធារណៈ ( Public law dispute-resolution mechanisms ) — សំដៅដល់យន្តការ និងនីតិវិធីសម្រាប់ដោះស្រាយវិវាទរវាងបុគ្គល ឬអង្គភាពឯកជន ជាមួយអំណាចសាធារណៈ ដែលពាក់ព័ន្ធនឹងការអនុវត្តច្បាប់សាធារណៈ និងសកម្មភាពរដ្ឋបាល។
- ស្ថាប័នពិនិត្យលើទណ្ឌកម្មរដ្ឋបាល ( Administrative sanctions review institutions ) — សំដៅដល់ស្ថាប័ន ឬយន្តការដែលមានតួនាទីពិនិត្យឡើងវិញនូវទណ្ឌកម្មរដ្ឋបាល ដើម្បីធានាថាវាត្រូវបានអនុវត្តដោយស្របច្បាប់ មានសមាមាត្រ និងគោរពសិទ្ធិរបស់អ្នកដែលរងផលប៉ះពាល់។
- អង្គភាពត្រួតពិនិត្យតាមបែប Ombudsman ( Ombudsman-type review ) — ស្ថាប័នជួយពលរដ្ឋក្នុងការពារសិទ្ធិពីអំណាចរដ្ឋ។

### ៩. ស្ថាប័នវិជ្ជាជីវៈច្បាប់ និងសេវាកម្មច្បាប់

- គណៈមេធាវី ( Bar association ) — ស្ថាប័នគ្រប់គ្រងវិជ្ជាជីវៈមេធាវី។
- ភ្នាក់ងារផ្ដល់សេវាកម្មច្បាប់ ( Legal service providers ) — សំដៅដល់បុគ្គល ឬអង្គភាពដែលផ្ដល់សេវាផ្នែកច្បាប់ដល់សាធារណៈ ដូចជា ការផ្ដល់ប្រឹក្សា ការតំណាង និងការគាំទ្រផ្លូវច្បាប់ ក្នុងគោលបំណងធានាការចូលដំណើរការយុត្តិធម៌។
- មន្ទីរសាការី ( Notary Public ) — សំដៅដល់មន្ត្រីសាធារណៈដែលមានសមត្ថកិច្ចក្នុងការធ្វើឱ្យអត្ថបទ ឯកសារ និងប្រតិបត្តិការគតិយុត្តមានសុពលភាពផ្លូវច្បាប់ និងអាចជាភស្តុតាងតាមច្បាប់។

- អាជ្ញាសាលា (Bailiffs) — សំដៅដល់មន្ត្រីដែលទទួលបន្ទុកអនុវត្តសេចក្តីសម្រេចរបស់តុលាការ ដូចជា ការជូនដំណឹង ការចេញបញ្ជា និងការបង្ខិតបង្ខំអនុវត្តតាមនីតិវិធីច្បាប់។
- សន្ធានការី (Mediators) — សំដៅដល់អ្នកអនុវត្តនីតិវិធីសន្ធានកម្ម ដែលជួយភាគីវិវាទឱ្យស្វែងរកដំណោះស្រាយដោយសន្តិវិធី តាមរយៈការសន្ទនា និងការសម្របសម្រួល។
- មជ្ឈត្តករ (Arbitrators) — សំដៅដល់អ្នកដែលមានអំណាចក្នុងការសម្រេចវិវាទក្រៅប្រព័ន្ធតុលាការ តាមរយៈនីតិវិធីមជ្ឈត្តការ ដែលភាគីបានយល់ព្រមជាមុន។
- ស្ថាប័នវិន័យនិងសីលធម៌វិជ្ជាជីវៈ (Professional ethics and discipline institutions) — សំដៅដល់ស្ថាប័នដែលទទួលបន្ទុកកំណត់ សម្របសម្រួល និងអនុវត្តក្រមសីលធម៌ និងវិន័យវិជ្ជាជីវៈ ដើម្បីធានាគុណភាព សុចរិតភាព និងទំនុកចិត្តលើអ្នកផ្តល់សេវាកម្មច្បាប់។

### ១០. ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

- ស្ថាប័នសន្ធានកម្ម (Mediation institutions) — សំដៅដល់ស្ថាប័នដែលរៀបចំ និងគ្រប់គ្រងនីតិវិធីសន្ធានកម្ម ដើម្បីជួយភាគីវិវាទស្វែងរកដំណោះស្រាយដោយសន្តិវិធី តាមរយៈការសម្របសម្រួល និងការពិភាក្សា។
- ស្ថាប័នមជ្ឈត្តការ (Arbitration institutions) — សំដៅដល់ស្ថាប័នដែលរៀបចំ និងគ្រប់គ្រងនីតិវិធីមជ្ឈត្តការ ដែលអនុញ្ញាតឱ្យភាគីជ្រើសរើសមជ្ឈត្តការដើម្បីសម្រេចវិវាទក្រៅប្រព័ន្ធតុលាការ។
- ស្ថាប័នសម្រុះសម្រួល (Conciliation institutions) — សំដៅដល់ស្ថាប័នដែលផ្តល់នីតិវិធីសម្រុះសម្រួលដោយមានតួនាទីជួយភាគីស្វែងរកដំណោះស្រាយតាមរយៈការផ្តល់យោបល់ និងជំរុញឱ្យមានការព្រមព្រៀង។

| | |
|---|---|
| • អង្គភាពដោះស្រាយវិវាទសហគមន៍ (Community dispute-resolution bodies) | សំដៅដល់អង្គភាពនៅកម្រិតមូលដ្ឋាន ដែលដោះស្រាយវិវាទដោយសន្តិវិធី ដោយផ្អែកលើទំនៀមទម្លាប់ សហគមន៍ និងការសម្របសម្រួលក្នុងតំបន់។ |
| • រចនាសម្ព័ន្ធ ADR នៅតុលាការ (Court-annexed ADR structures) | សំដៅដល់យន្តការ ADR ដែលត្រូវបានបញ្ចូល ឬភ្ជាប់ជាមួយប្រព័ន្ធតុលាការ ដើម្បីជួយដោះស្រាយវិវាទមុន ឬក្នុងអំឡុងពេលដំណើរការតុលាការ។ |
| • យន្តការទទួលស្គាល់និងអនុវត្តរវាង ADR និងតុលាការ (Recognition and enforcement links between ADR and courts) | សំដៅដល់យន្តការដែលធានាថាលទ្ធផលនៃ ADR អាចត្រូវបានទទួលស្គាល់ និងអនុវត្តតាមផ្លូវច្បាប់ ដោយភ្ជាប់ជាមួយប្រព័ន្ធតុលាការ។ |

## ១១. ស្ថាប័នអប់រំ ស្រាវជ្រាវ និងចំណេះដឹងច្បាប់

| | |
|---|---|
| • សាកលវិទ្យាល័យ និងមហាវិទ្យាល័យច្បាប់ (Law faculties and universities) | សំដៅដល់ស្ថាប័នអប់រំកម្រិតឧត្តម ដែលផ្តល់ការបណ្តុះបណ្តាលផ្នែកច្បាប់ជាមូលដ្ឋាន បង្កើតចំណេះដឹងទ្រឹស្តី និងបង្កើតជំនាញវិជ្ជាជីវៈសម្រាប់អ្នកសិក្សា។ |
| • សាលាបណ្តុះបណ្តាលចៅក្រម (Judicial training schools) | សំដៅដល់ស្ថាប័នដែលបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពចៅក្រម ដើម្បីធានាការអនុវត្តយុត្តិធម៌ប្រកបដោយឯករាជ្យភាព សុចរិតភាព និងវិជ្ជាជីវៈ។ |
| • សាលាបណ្តុះបណ្តាលអយ្យការ (Prosecution training schools) | សំដៅដល់ស្ថាប័នដែលបណ្តុះបណ្តាលព្រះរាជអាជ្ញា និងបុគ្គលិកអយ្យការ ដើម្បីអនុវត្តតួនាទីចោទប្រកាន់ដោយស្របច្បាប់ និងមានប្រសិទ្ធភាព។ |
| • សាលានគរបាល (Police academies) | សំដៅដល់ស្ថាប័នបណ្តុះបណ្តាលនគរបាល ដែលផ្តល់ជំនាញវិជ្ជាជីវៈ សីលធម៌ និងសមត្ថភាពអនុវត្តច្បាប់ក្នុងការរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ។ |

| | |
|---|---|
| • សាលាបណ្ដុះបណ្ដាលមេធាវី ( Bar training schools ) | សំដៅដល់ស្ថាប័នដែលបណ្ដុះបណ្ដាលមេធាវី ដើម្បីធានាសមត្ថភាពក្នុងការផ្ដល់សេវាកម្មច្បាប់ និងការពារសិទ្ធិប្រជាពលរដ្ឋ។ |
| • ស្ថាប័នអប់រំច្បាប់បន្ត ( Continuing legal education institutions ) | សំដៅដល់ស្ថាប័នដែលផ្ដល់ការបណ្ដុះបណ្ដាលបន្ត ដើម្បីធ្វើបច្ចុប្បន្នភាពចំណេះដឹង និងជំនាញរបស់អ្នកវិជ្ជាជីវៈច្បាប់។ |
| • វិទ្យាស្ថានតាក់តែងច្បាប់និងស្រាវជ្រាវកែទម្រង់ច្បាប់ ( Legislative drafting and law reform research institutes ) | សំដៅដល់ស្ថាប័នដែលស្រាវជ្រាវ និងអភិវឌ្ឍគោលនយោបាយច្បាប់ ព្រមទាំងគាំទ្រការតាក់តែង និងកែទម្រង់ច្បាប់ឱ្យមានគុណភាព និងសង្គតិភាព។ |
| • ស្ថាប័នបោះពុម្ពច្បាប់ និងចងក្រងច្បាប់ ( Legal publishing and law-reporting institutions ) | សំដៅដល់ស្ថាប័នដែលទទួលបន្ទុកបោះពុម្ពផ្សព្វផ្សាយ និងចងក្រងច្បាប់ និងយុត្តិសាស្ត្រ ដើម្បីធានាការចូលដំណើរការព័ត៌មានច្បាប់ និងការអភិវឌ្ឍចំណេះដឹងច្បាប់។ |

### ១២. ស្ថាប័នទទួលបន្ទុកលើក្របខ័ណ្ឌគុណវុឌ្ឍិ និងសមត្ថភាព

| | |
|---|---|
| • ស្តង់ដារគុណវុឌ្ឍិសម្រាប់ចៅក្រម ( Qualification standards for judges ) | សំដៅដល់លក្ខខណ្ឌ និងស្តង់ដារដែលត្រូវបំពេញសម្រាប់ការចូលបម្រើ និងបន្តមុខងារជាចៅក្រម រួមមានចំណេះដឹងច្បាប់ សមត្ថភាពវិជ្ជាជីវៈ សីលធម៌ និងភាពសមរម្យក្នុងការអនុវត្តយុត្តិធម៌។ |
| • ស្តង់ដារគុណវុឌ្ឍិសម្រាប់ព្រះរាជអាជ្ញា ( Qualification standards for prosecutors ) | សំដៅដល់លក្ខខណ្ឌសម្រាប់ជ្រើសរើស និងបន្តមុខងារព្រះរាជអាជ្ញា ដែលត្រូវមានសមត្ថភាពច្បាប់ សមត្ថភាពវិភាគ និងសុចរិតភាពក្នុងការអនុវត្តតួនាទីចោទប្រកាន់។ |
| • ស្តង់ដារគុណវុឌ្ឍិសម្រាប់មេធាវីនិងអ្នកប្រកបវិជ្ជាជីវៈច្បាប់ ( Qualification standards for lawyer and legal professionals ) | សំដៅដល់ស្តង់ដារសម្រាប់ការចូល និងអនុវត្តវិជ្ជាជីវៈច្បាប់ ដើម្បីធានាថាអ្នកផ្ដល់សេវាកម្មច្បាប់មានសមត្ថភាព និងគោរពសីលធម៌វិជ្ជាជីវៈ។ |

- ប្រព័ន្ធប្រឡងចូល និងជ្រើសរើស (Entry examinations and recruitment systems) — សំដៅដល់យន្តការជ្រើសរើសបុគ្គលចូលក្នុងវិជ្ជាជីវៈច្បាប់ ដោយផ្អែកលើការប្រឡង និងលក្ខណៈវិនិច្ឆ័យច្បាស់លាស់ ដើម្បីធានាគុណភាព និងសមត្ថភាព។
- ស្ថាប័នវាយតម្លៃសមត្ថភាព (Performance evaluation institutions) — សំដៅដល់ស្ថាប័ន ឬយន្តការដែលវាយតម្លៃការបំពេញមុខងារ និងសមត្ថភាពរបស់អ្នកវិជ្ជាជីវៈច្បាប់ ដើម្បីធានាប្រសិទ្ធភាព និងគណនេយ្យភាព។
- ក្របខ័ណ្ឌអភិវឌ្ឍសមត្ថភាព (Framework for Competency Development) — សំដៅដល់គោលការណ៍ និងយន្តការសម្រាប់អភិវឌ្ឍជំនាញ និងសមត្ថភាពរបស់អ្នកវិជ្ជាជីវៈច្បាប់ជាបន្តបន្ទាប់។
- យន្តការផ្តល់វិញ្ញាបនបត្រ (Licensing mechanisms) — សំដៅដល់យន្តការដែលអនុញ្ញាតឱ្យបុគ្គលអាចអនុវត្តវិជ្ជាជីវៈច្បាប់បាន ដោយផ្អែកលើការផ្តល់អាជ្ញាបណ្ណ និងការគោរពស្តង់ដារដែលបានកំណត់។

### ១៣. ស្ថាប័នទទួលបន្ទុកព័ត៌មានច្បាប់ និងផ្សព្វផ្សាយច្បាប់

- រាជកិច្ច (Official Gazette) — ប្រភពផ្លូវការសម្រាប់ផ្សព្វផ្សាយច្បាប់។
- មូលទិន្នន័យច្បាប់សាធារណៈ (Public legal databases) — ប្រព័ន្ធទិន្នន័យច្បាប់ជាសាធារណៈ។
- អង្គភាពចងក្រងនិងផ្សព្វផ្សាយសេចក្តីសម្រេចតុលាការ (Case reporting and jurisprudence publication bodies) — ការបោះពុម្ព និងផ្សព្វផ្សាយសេចក្តីសម្រេចតុលាការ។
- បណ្ណសារដ្ឋានច្បាប់ (Legislative archives) — ការរក្សាទុកឯកសារច្បាប់។
- អង្គភាពសេវាព័ត៌មានច្បាប់សម្រាប់សាធារណៈ (Public legal information services unit) — ការផ្តល់ព័ត៌មានច្បាប់ដល់សាធារណៈជន។

| | |
|---|---|
| • ស្ថាប័នសម្រាប់ចំណេះដឹងច្បាប់មូលដ្ឋានសម្រាប់ពលរដ្ឋ ( Institutions for civic legal literacy )។ | ការលើកកម្ពស់ការយល់ដឹងច្បាប់ក្នុងសង្គម។ |

### ៦.៧.៤ វប្បធម៌គោរពច្បាប់

វប្បធម៌គោរពច្បាប់នៃប្រព័ន្ធច្បាប់ សំដៅដល់បរិយាកាសសង្គម និងវិជ្ជាជីវៈ ដែលកំណត់របៀបដែលច្បាប់ត្រូវបានយល់ ទទួលស្គាល់ គោរព និងអនុវត្តនៅក្នុងសង្គម ដែលរួមបញ្ចូលទាំងទស្សនៈ អាកប្បកិរិយា និងទម្លាប់របស់ប្រជាពលរដ្ឋ ស្ថាប័នរដ្ឋ និងអ្នកប្រកបវិជ្ជាជីវៈផ្នែកច្បាប់ ទាក់ទងនឹងការគោរពច្បាប់ ការប្រើប្រាស់យន្តការគតិយុត្ត និងការជឿទុកចិត្តលើស្ថាប័នយុត្តិធម៌។ ក្នុងន័យនេះ វប្បធម៌គោរពច្បាប់បង្ហាញថា ប្រព័ន្ធច្បាប់មិនត្រឹមតែមានជាបទដ្ឋាន និងស្ថាប័នប៉ុណ្ណោះទេ ប៉ុន្តែត្រូវការការគាំទ្រពីសង្គម និងសហគមន៍វិជ្ជាជីវៈ ដើម្បីឱ្យច្បាប់អាចដំណើរការបានប្រកបដោយប្រសិទ្ធភាពក្នុងការអនុវត្តជាក់ស្តែង។ ក្នុងទ្រឹស្តីប្រព័ន្ធ វប្បធម៌គោរពច្បាប់គឺជាធាតុសំខាន់មួយដែលភ្ជាប់រវាងសារធាតុគតិយុត្ត និងរចនាសម្ព័ន្ធគតិយុត្តស្ថាប័ន ជាមួយនឹងអាកប្បកិរិយា និងការយល់ដឹងរបស់សង្គម។ វប្បធម៌ដែលលើកកម្ពស់នីតិរដ្ឋ សុចរិតភាព វិជ្ជាជីវៈ និងការគោរពច្បាប់ នឹងជួយបង្កើនទំនុកចិត្តសាធារណៈលើស្ថាប័នយុត្តិធម៌ និងធានាថាច្បាប់ត្រូវបានអនុវត្តប្រកបដោយសមភាព និងប្រសិទ្ធភាព។ ដូច្នេះ ការកំណត់ និងការលើកកម្ពស់ធាតុផ្សំសំខាន់ៗនៃវប្បធម៌គោរពច្បាប់ គឺមានសារៈសំខាន់សម្រាប់ការកសាងប្រព័ន្ធច្បាប់កម្ពុជាដែលមានភាពរឹងមាំ មានទំនុកចិត្ត និងអាចគាំទ្រការអភិវឌ្ឍសង្គមជាតិប្រកបដោយសន្តិភាព និងយុត្តិធម៌។

សមាសភាគធាតុផ្សំវប្បធម៌គោរពច្បាប់ ត្រូវបានកំណត់ដោយផ្អែកលើមូលដ្ឋានថាច្បាប់មិនអាចអនុវត្តបានតាមរយៈនៅតែក្នុងអត្ថបទនិងស្ថាប័នទេប៉ុន្តែត្រូវអនុវត្តដោយផ្អែកជាមួយអាកប្បកិរិយា ស្មារតី និងទម្លាប់អនុវត្តរបស់មនុស្ស និងសង្គម។ ជារួមសមាសភាគធាតុផ្សំវប្បធម៌គោរពច្បាប់ ត្រូវបានសំយោគដោយផ្អែកលើមូលដ្ឋានគំនិតថា តើច្បាប់ត្រូវការលក្ខខណ្ឌសង្គម និងវិជ្ជាជីវៈអ្វីខ្លះ ដើម្បីអាចអនុវត្តប្រកបដោយប្រសិទ្ធិភាព? ដែលចម្លើយនៃសំណួរនេះអាចអនុញ្ញាតឱ្យយើងកំណត់បាននូវសមាសភាគធាតុផ្សំរួមមាន វប្បធម៌នីត្យានុកូលភាព សម្បជញ្ញៈ សិទ្ធិ ជំនឿសាធារណៈលើស្ថាប័នយុត្តិធម៌ ការយល់ដឹងអំពីច្បាប់របស់ពលរដ្ឋ វិជ្ជាជីវៈរបស់អ្នកអនុវត្តច្បាប់រួមមានចៅក្រម ព្រះរាជអាជ្ញា មេធាវី មន្ត្រីរដ្ឋបាល ព្រមទាំងក្រមសីលធម៌ សុចរិតភាពស្ថាប័ន វប្បធម៌អនុលោមភាពរបស់ធុរកិច្ច និងវប្បធម៌ដោះស្រាយវិវាទដោយសន្តិវិធី។

សមាសភាគធាតុផ្សំនៃវប្បធម៌គោរពច្បាប់ ត្រូវបានរៀបចំតាមលំដាប់ពីកម្រិតទូទៅនៃសង្គម ទៅកម្រិតវិជ្ជាជីវៈនិងស្ថាប័នរួមមានការយល់ដឹង និងការទទួលស្គាល់ច្បាប់របស់សាធារណជន ជំនឿសាធារណៈលើស្ថាប័នយុត្តិធម៌ សមត្ថភាពពលរដ្ឋក្នុងការប្រើប្រាស់ និងការពារសិទ្ធិរបស់ខ្លួន វប្បធម៌វិជ្ជាជីវៈ និងសីលធម៌របស់អ្នកអនុវត្តច្បាប់ និងស្ថាប័ន; ហើយបញ្ចប់ដោយវប្បធម៌អនុលោមភាព និងវប្បធម៌ដោះស្រាយវិវាទដោយសន្តិវិធី។ ជារួមសមាសភាគធាតុផ្សំត្រូវរៀបជា

លំដាប់វឌ្ឍពី "ការយល់ដឹង" ទៅ "ការជឿទុកចិត្ត" ទៅ "ការអនុវត្តតាម" និង "ការអនុវត្តប្រកបដោយសីលធម៌"។

ដោយផ្អែកលើទស្សនៈនេះ វប្បធម៌គោរពច្បាប់នៃប្រព័ន្ធច្បាប់កម្ពុជាអាច រៀបចំជាធាតុផ្សំ សំខាន់ៗ ដូចខាងក្រោម៖

### ១. វប្បធម៌និត្យានុកូលភាព

| | |
|---|---|
| • ការគោរពច្បាប់ ( Respect for law ) | សំដៅដល់ទស្សនៈ និងអាកប្បកិរិយាដែលទទួលស្គាល់ថាច្បាប់ត្រូវតែគោរព និងអនុវត្តជាគោលក្នុងសង្គម។ |
| • ការទទួលយករបស់សង្គមចំពោះនីត្យានុកូលភាព ( Social acceptance of legality ) | សំដៅដល់ការទទួលស្គាល់ជាសាធារណៈថាការប្រើអំណាច និងការដោះស្រាយបញ្ហាត្រូវធ្វើតាមច្បាប់។ |
| • ការបដិសេធការសម្រេចតាមចិត្តនិងនិទណ្ឌភាព ( Reject of arbitrariness and impunity ) | សំដៅដល់វប្បធម៌ដែលមិនទទួលយកការប្រើអំណាចតាមចិត្ត ឬការរួចផុតពីការទទួលខុសត្រូវដោយគ្មានមូលដ្ឋានច្បាប់។ |
| • វប្បធម៌អនុលោមភាពប្រចាំថ្ងៃ ( Everyday compliance culture ) | សំដៅដល់ទម្លាប់នៃការអនុវត្ត និងគោរពច្បាប់ជាប្រចាំក្នុងជីវិតរស់នៅ និងក្នុងសកម្មភាពសង្គម។ |
| • ការជ្រើសយកដំណោះស្រាយផ្លូវច្បាប់ជាងកម្លាំងបាយក្រៅផ្លូវការ ( Preference for lawful resolution over informal coercion ) | សំដៅដល់និន្នាការនៃការជ្រើសប្រើវិធានការស្របច្បាប់ជំនួសឱ្យការគំរាមកំហែង ការបង្ខិតបង្ខំ ឬសម្ពាធក្រៅប្រព័ន្ធច្បាប់។ |

### ២. ការយល់ដឹង

| | |
|---|---|
| • ការយល់ដឹងអំពីច្បាប់របស់សាធារណៈជន ( Public understanding of law ) | សំដៅដល់កម្រិតដែលប្រជាពលរដ្ឋយល់អំពីតួនាទី មុខងារ និងអត្ថន័យរបស់ច្បាប់ និងស្ថាប័នក្នុងសង្គម។ |

| | |
|---|---|
| • ការយល់ដឹងអំពីសិទ្ធិ (Rights consciousness) | សំដៅលើការយល់ដឹង និងការយល់តម្លៃអំពីសិទ្ធិ និងសេរីភាពផ្ទាល់ខ្លួន។ |
| • ទស្សនៈចំពោះសមភាពនិងយុត្តិធម៌ (Perception of fairness and justice) | សំដៅដល់ការយល់ឃើញរបស់សាធារណៈអំពីភាពត្រឹមត្រូវ សមធម៌ និងភាពសមស្របនៃច្បាប់ និងស្ថាប័នយុត្តិធម៌។ |
| • អាកប្បកិរិយាចំពោះការទាមទារសិទ្ធិនិងប្រើប្រាស់វិធានការ (Attitudes toward claiming rights and using remedies) | សំដៅដល់ឆន្ទៈ និងទម្លាប់របស់បុគ្គលក្នុងការប្រើយន្តការច្បាប់ដើម្បីការពារ ឬអនុវត្តសិទ្ធិរបស់ខ្លួន។ |

### ៣. ជំនឿពីសាធារណៈជន និងធម្មានុភាពនៃស្ថាប័នយុត្តិធម៌

| | |
|---|---|
| • ជំនឿលើតុលាការនិងចៅក្រម (Trust in courts and judges) | សំដៅដល់ទំនុកចិត្តរបស់សាធារណៈលើតុលាការ និងចៅក្រមអាចសម្រេចក្តីដោយឯករាជ្យ ត្រឹមត្រូវ និងយុត្តិធម៌។ |
| • ជំនឿលើនគរបាល និងព្រះរាជអាជ្ញា (Trust in police and prosecutors) | សំដៅដល់ទំនុកចិត្តរបស់សាធារណៈលើលើនគរបាល និងព្រះរាជអាជ្ញាក្នុងការអនុវត្តមុខងាររបស់ខ្លួនដោយស្របច្បាប់ និងសុចរិតភាព។ |
| • ជំនឿលើស្ថាប័នយុត្តិធម៌រដ្ឋបាល (Trust in administrative justice bodies) | សំដៅដល់ទំនុកចិត្តរបស់សាធារណៈលើស្ថាប័នយុត្តិធម៌រដ្ឋបាលអាចការពារសិទ្ធិ និងត្រួតពិនិត្យអំណាចរដ្ឋបានប្រកបដោយប្រសិទ្ធភាព។ |
| • ឆន្ទៈក្នុងការសហការជាមួយស្ថាប័នយុត្តិធម៌ (Willingness to cooperate with justice institutions) | សំដៅដល់ឆន្ទៈរបស់សាធារណៈក្នុងការផ្តល់ព័ត៌មាន គោរពនីតិវិធី និងសហការជាមួយស្ថាប័នយុត្តិធម៌។ |

### ៤. សមត្ថភាពច្បាប់របស់ពលរដ្ឋ

| | |
|---|---|
| • ចំណេះដឹងច្បាប់ (Legal literacy) | សំដៅដល់ចំណេះដឹងមូលដ្ឋានរបស់ប្រជាពលរដ្ឋអំពីច្បាប់ សិទ្ធិ កាតព្វកិច្ច និងនីតិវិធីសំខាន់ៗ។ |

| | |
|---|---|
| • សមត្ថភាពក្នុងការកំណត់បញ្ហាផ្លូវច្បាប់ (Ability to identify legal problems) | សំដៅដល់សមត្ថភាពរបស់បុគ្គលក្នុងការវិភាគលើរកបញ្ហាផ្លូវច្បាប់ ដើម្បីស្វែងរកដំណោះផ្លូវច្បាប់។ |
| • សមត្ថភាពក្នុងការស្វែងរកការប្រឹក្សានិងដំណោះស្រាយ (Ability to seek advice and remedies) | សំដៅដល់សមត្ថភាពក្នុងការស្វែងរកជំនួយផ្នែកច្បាប់ ឬយន្តការសមស្របសម្រាប់ដោះស្រាយវិវាទ។ |
| • ការលើកកម្ពស់ច្បាប់នៅក្នុងសហគមន៍ (Community legal empowerment) | សំដៅដល់ការពង្រឹងសមត្ថភាពសហគមន៍ឱ្យយល់ និងប្រើច្បាប់ដើម្បីការពារផលប្រយោជន៍រួម និងដោះស្រាយបញ្ហា។ |
| • ការអប់រំនិងផ្សព្វផ្សាយច្បាប់ជាសាធារណៈ (Public legal education and awareness) | សំដៅដល់កិច្ចខិតខំផ្សព្វផ្សាយ និងបង្រៀនច្បាប់ដល់សាធារណៈ ដើម្បីបង្កើនការយល់ដឹង និងចូលរួមអនុវត្តច្បាប់។ |

**៥. វប្បធម៌គោរពច្បាប់របស់អ្នកវិជ្ជាជីវៈ**

| | |
|---|---|
| • វប្បធម៌ចៅក្រម (Judicial culture) | សំដៅដល់តម្លៃ អាកប្បកិរិយា និងវិជ្ជាជីវៈដែលកំណត់របៀបដែលចៅក្រមបំពេញតួនាទីរបស់ខ្លួន។ |
| • វប្បធម៌អយ្យការ (Prosecutorial culture) | សំដៅដល់តម្លៃ អាកប្បកិរិយា និងវិជ្ជាជីវៈដែលដឹកនាំការអនុវត្តតួនាទីរបស់អយ្យការ។ |
| • វប្បធម៌មេធាវី (Bar culture) | សំដៅដល់តម្លៃ អាកប្បកិរិយា និងវិជ្ជាជីវៈដែលកំណត់ការអនុវត្តតួនាទីរបស់មេធាវីក្នុងការពារសិទ្ធិ និងយុត្តិធម៌។ |
| • វប្បធម៌រដ្ឋបាល (Administrative legal culture) | សំដៅដល់តម្លៃ អាកប្បកិរិយា និងវិជ្ជាជីវៈសម្រាប់មន្ត្រីរដ្ឋបាលអនុវត្តតួនាទីរបស់ខ្លួន។ |
| • ការបើកទូលាយចំពោះការកែទម្រង់និងទំនើបកម្ម (Openness to reform and modernization) | សំដៅដល់ឆន្ទៈរបស់អ្នកវិជ្ជាជីវៈ និងស្ថាប័នក្នុងការទទួលយកការកែលម្អ ការច្នៃប្រឌិត និងស្តង់ដារថ្មីៗ។ |

**៦. ក្រមសីលធម៌និងសុចរិតភាពវិជ្ជាជីវៈ និងក្រមសីលធម៌ស្ថាប័ន**

| | |
|---|---|
| • ក្រមសីលធម៌ចៅក្រម (Judicial ethics) | សំដៅដល់គោលការណ៍សីលធម៌ដែលគ្រប់គ្រងអាកប្បកិរិយា និងការសម្រេចចិត្តរបស់ចៅក្រម។ |
| • ក្រមសីលធម៌អយ្យការ (Prosecutorial ethics) | សំដៅដល់គោលការណ៍សីលធម៌ដែលគ្រប់គ្រងអាកប្បកិរិយាសម្រាប់ការអនុវត្តតួនាទីរបស់អយ្យការ។ |
| • ក្រមសីលធម៌មេធាវី (Legal profession ethics) | សំដៅដល់គោលការណ៍សីលធម៌ដែលគ្រប់គ្រងអាកប្បកិរិយារបស់មេធាវីក្នុងការប្រកបវិជ្ជាជីវៈ។ |
| • វិធានប្រឆាំងអំពើពុករលួយ (Anti-curruption rules) | សំដៅដល់បទដ្ឋាន និងវិធានការដែលមានគោលបំណងទប់ស្កាត់ និងផ្ដន្ទាទោសអំពើពុករលួយ។ |
| • ការយល់ដឹងអំពីទំនាស់ផលប្រយោជន៍ (Conflict-of-interest awarenes) | សំដៅដល់ការយល់ដឹង និងការប្រុងប្រយ័ត្នចំពោះស្ថានភាពដែលផលប្រយោជន៍ផ្ទាល់ខ្លួនអាចប៉ះពាល់ដល់ការបំពេញតួនាទីជាសាធារណៈ ឬវិជ្ជាជីវៈ។ |
| • វប្បធម៌ហ៊ាននិយាយ និងរាយការណ៍ (Whistleblowing and speaking-up culture) | សំដៅដល់បរិយាកាសដែលលើកទឹកចិត្តឱ្យមានការរាយការណ៍អំពីអំពើមិនត្រឹមត្រូវ ឬការបំពានដោយគ្មានការភ័យខ្លាច។ |
| • ការបើកចំហរបស់អង្គភាពចំពោះបញ្ហាក្រមសីលធម៌ (Organizational openness to ethical concerns) | សំដៅដល់សមត្ថភាពរបស់ស្ថាប័នក្នុងការទទួលស្គាល់ ពិចារណា និងឆ្លើយតបចំពោះបញ្ហាក្រមសីលធម៌។ |
| • ការដឹកនាំប្រកបដោយសុចរិតភាពនៅក្នុងស្ថាប័ន (Integrity leadership within institutions) | សំដៅដល់ភាពដឹកនាំដែលធ្វើជាគំរូល្អក្នុងសុចរិតភាព គណនេយ្យភាព និងការគោរពគោលការណ៍ច្បាប់។ |

### ៦. វប្បធម៌គោរពបទប្បញ្ញត្តិ និងនីត្យានុកូលភាពរបស់ធុរកិច្ច

| | |
|---|---|
| • វប្បធម៌អនុលោមភាពរបស់ធុរកិច្ច (Business compliance culture) | សំដៅដល់ទម្លាប់ និងស្តង់ដារនៃការអនុវត្តបទប្បញ្ញត្តិច្បាប់ដោយស្មោះត្រង់នៅក្នុងសហគ្រាស និងអង្គការធុរកិច្ច។ |

- ជំនឿនិងភាពអាចព្យាករណ៍បានលើបទប្បញ្ញត្តិ ( Regulatory trust and predictability ) — សំដៅដល់ទំនុកចិត្តថាបទប្បញ្ញត្តិមានស្ថិរភាពច្បាស់លាស់ និងអាចទុកចិត្តបានសម្រាប់សកម្មភាពសេដ្ឋកិច្ច។
- រដ្ឋបាលសាមញ្ញនិងងាយស្រួលប្រើប្រាស់ ( Administrative simplicity and usability ) — សំដៅដល់បរិយាកាសបទប្បញ្ញត្តិដែលងាយយល់ងាយអនុវត្ត និងមិនបង្កើតបន្ទុកមិនចាំបាច់។
- ឆន្ទៈក្នុងការស្វ័យរាយការណ៍និងសហការរបស់ក្រុមហ៊ុន ( Willingness of firms to self-report and cooperate ) — សំដៅដល់ឆន្ទៈរបស់អង្គភាពធុរកិច្ចក្នុងការរាយការណ៍ដោយស្ម័គ្រចិត្ត និងសហការជាមួយអាជ្ញាធរ។
- វិធានប្រឆាំងការសូកប៉ាន់និងបន្លំ ( Anti-bribery and anti-fraud compliance norms ) — សំដៅដល់ស្តង់ដារនិងវិធានផ្ទៃក្នុងសម្រាប់ទប់ស្កាត់អំពើសូកប៉ាន់ និងបន្លំក្នុងប្រតិបត្តិការធុរកិច្ច។
- នីត្យានុកូលភាពនៅក្នុងទីផ្សារនិងប្រតិបត្តិការពាណិជ្ជកម្ម ( Legality in markets and commercial transactions ) — សំដៅដល់ការអនុវត្តសកម្មភាពសេដ្ឋកិច្ច និងពាណិជ្ជកម្មដោយស្របតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ។

### ៧. វប្បធម៌ដោះស្រាយវិវាទ និងសន្តិភាពសង្គម

- និន្នាការក្នុងការស្វែងរកដំណោះស្រាយផ្លូវច្បាប់ ( Propensity to seek lawful remedies ) — សំដៅដល់ទម្លាប់ ឬឆន្ទៈក្នុងការស្វែងរកដំណោះស្រាយតាមផ្លូវច្បាប់ពេលមានវិវាទ ឬការរំលោភសិទ្ធិ។
- អាកប្បកិរិយាចំពោះការដោះស្រាយតាមប្រព័ន្ធតុលាការ ( Attitudes toward litigation ) — សំដៅដល់ទស្សនៈរបស់សង្គមចំពោះការប្រើប្រាស់តុលាការជាវិធានដោះស្រាយវិវាទ។

| | |
|---|---|
| • ការទទួលយកសន្ទានកម្មនិងការសម្រុះសម្រួល (Acceptance of mediation and conciliation) | សំដៅដល់ការទទួលស្គាល់ថាវិធានការដោះស្រាយវិវាទដោយសន្តិវិធីអាចមានតម្លៃ និងប្រសិទ្ធភាព។ |
| • ការដោះស្រាយវិវាទសហគមន៍ដោយសន្តិភាព (Community-based peaceful dispute handling) | សំដៅដល់ការដោះស្រាយបញ្ហាវិវាទនៅកម្រិតសហគមន៍ដោយជៀសវាងអំពើហិង្សា និងការបង្ខិតបង្ខំ។ |
| • ការបញ្ចៀសអំពើហឹង្សា ការសងសឹក និងបង្ខិតបង្ខំផ្លូវច្បាប់លើសលប់ (Avoidance of violence, revenge, and extra-legal coercion) | សំដៅដល់វប្បធម៌ដែលបដិសេធការដោះស្រាយវិវាទតាមរយៈអំពើហិង្សា ការសងសឹក ឬសម្ពាធក្រៅច្បាប់។ |
| • ភាពស្របច្បាប់ក្នុងសង្គមនៃការសះជា និងផ្សះផ្សារ (Social legitimacy of compromise and settlement) | សំដៅដល់ការទទួលស្គាល់សង្គមថាការសះជា និងផ្សះផ្សារជាវិធីសមស្រប និងមានតម្លៃក្នុងការស្តារសន្តិភាពសង្គម។ |

### ៦.៧.៥ យន្តការវាយតម្លៃ

យន្តការវាយតម្លៃនៃប្រព័ន្ធច្បាប់ សំដៅដល់ដំណើរការ និងឧបករណ៍នានា ដែលអនុញ្ញាតឱ្យប្រព័ន្ធច្បាប់អាចត្រួតពិនិត្យ វាយតម្លៃ និងកែលម្អខ្លួនឯងជាបន្តបន្ទាប់ ដែលរួមបញ្ចូលទាំងយន្តការតាមដាន ការវាយតម្លៃប្រសិទ្ធភាពនៃច្បាប់ និងស្ថាប័ន ការប្រមូលទិន្នន័យ និងព័ត៌មានគតិយុត្ត ការទទួលមតិយោបល់ពីសង្គម និងការពិនិត្យឡើងវិញនៃច្បាប់ជាធរមាន។ ក្នុងន័យនេះ យន្តការវាយតម្លៃបង្ហាញថាប្រព័ន្ធច្បាប់ជាប្រព័ន្ធរស់រវើកដែលអាចរៀនពីបទពិសោធន៍ អាចឆ្លើយតបទៅនឹងបញ្ហាប្រឈមថ្មីៗ និងអាចកែតម្រូវខ្លួនឯងដើម្បីធានាប្រសិទ្ធភាព និងសង្គតិភាពរបស់ច្បាប់។ ក្នុងទស្សនៈប្រព័ន្ធ យន្តការវាយតម្លៃមានតួនាទីសំខាន់ក្នុងការបង្កើត "feedback loop" ដែលភ្ជាប់រវាងការបង្កើតច្បាប់ ការអនុវត្តច្បាប់ និងការកែលម្អច្បាប់។ តាមរយៈយន្តការទាំងនេះ ស្ថាប័នរដ្ឋ និងសង្គមអាចសង្កេតឃើញបញ្ហា គម្លាត ឬភាពអសង្គតិភាពនៃច្បាប់ និងអាចធ្វើការកែតម្រូវតាមនីតិវិធីសមស្រប។ ដូច្នេះ ការកំណត់ និងការអភិវឌ្ឍយន្តការវាយតម្លៃដែលមានប្រសិទ្ធភាព គឺជាកត្តាសំខាន់សម្រាប់ធានាថាប្រព័ន្ធច្បាប់កម្ពុជាអាចដំណើរការបានជាប្រព័ន្ធដែលមានប្រសិទ្ធភាព ទំនើប និងអាចឆ្លើយតបទៅនឹងការវិវត្តន៍នៃសង្គម និងសេដ្ឋកិច្ចជាតិ។

សមាសភាគជាគុផ្សំនៃយន្តការវាយតម្លៃ ត្រូវបានកំណត់ដោយផ្អែកលើគោលគំនិតថា ប្រព័ន្ធច្បាប់ត្រូវតែជាប្រព័ន្ធរស់ដែលអាចពិនិត្យខ្លួនឯង កែតម្រូវខ្លួនឯង និងឆ្លើយតបនឹងបរិបទដែលផ្លាស់ប្តូរបាន។ សមាសភាគជាគុផ្សំត្រូវបានជ្រើសរើសដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមដែលបានវិនិច្ឆ័យថាកម្ពុជានៅខ្វះយន្តការតាមដាន និងវាយតម្លៃគុណភាពនៃការតាក់តែង ការបកស្រាយ និងការអនុវត្តច្បាប់។ សមាសភាគជាគុផ្សំរួមមាន គោលការណ៍នៃប្រព័ន្ធច្បាប់រស់ សូចនាករ និងរបាយការណ៍សាធារណៈ ការតាមដានជាបន្តបន្ទាប់ ប្រព័ន្ធព្រមានមុន ការធ្វើច្បាប់ផ្អែកលើភស្តុតាង ការពិនិត្យឡើងវិញក្រោយការអនុវត្ត ការត្រួតពិនិត្យរបស់សភា យន្តការបណ្តឹង និងដំណោះស្រាយរដ្ឋបាល ការធ្វើអធិការកិច្ចឯករាជ្យ សវនកម្ម ហេដ្ឋារចនាសម្ព័ន្ធទិន្នន័យ និងព័ត៌មានច្បាប់ ព្រមទាំងការបណ្តុះបណ្តាលបន្ត និងការពិនិត្យប្រព័ន្ធជាវដ្តជាតិ។

សមាសភាគជាគុផ្សំនៃយន្តការវាយតម្លៃនេះត្រូវបានរៀបចំតាមវដ្តនៃការកែលម្អប្រព័ន្ធ រួមមាន សូចនាករ និងរបាយការណ៍សាធារណៈ ការតាមដានជាបន្តបន្ទាប់ ការព្រមានមុន ការពិនិត្យឡើងវិញ និងការធ្វើច្បាប់ផ្អែកលើភស្តុតាង ដើម្បីបម្លែងព័ត៌មានទៅជាការកែលម្អហើយចុងក្រោយទើបរៀបចំទៅកាន់យន្តការត្រួតពិនិត្យ បណ្តឹង អធិការកិច្ច សវនកម្ម ទិន្នន័យ និងការបណ្តុះបណ្តាលបន្ត ដែលធ្វើឱ្យប្រព័ន្ធអាចកែតម្រូវខ្លួនឯងបានជាប្រព័ន្ធបាន។

ដោយផ្អែកលើទស្សនៈនេះ យន្តការវាយតម្លៃនៃប្រព័ន្ធច្បាប់កម្ពុជា អាចរៀបចំជាជាគុផ្សំសំខាន់ៗដូចខាងក្រោម៖

## ១. គោលការណ៍ប្រព័ន្ធច្បាប់រស់

| | |
|---|---|
| • គោលការណ៍ប្រព័ន្ធច្បាប់រស់ (Living legal system principle) | សំដៅដល់ការយល់ថាប្រព័ន្ធច្បាប់មិននៅកន្លែងនឹងប៉ុន្តែអភិវឌ្ឍ និងផ្លាស់ប្តូរតាមបរិបទ និងបទពិសោធន៍។ |
| • ភាពស្មោះត្រង់ចំពោះរដ្ឋធម្មនុញ្ញ និងគោលបំណងសាធារណៈ (Constitutional fidelity and public purpose) | សំដៅដល់ការធានាថាការកែប្រែ និងអនុវត្តច្បាប់ត្រូវស្របតាមរដ្ឋធម្មនុញ្ញ និងបម្រើផលប្រយោជន៍សាធារណៈ។ |
| • សមត្ថភាពបត់បែនក្រោមគោលការណ៍នីត្យានុកូលភាព (Adaptability under legality) | សំដៅដល់សមត្ថភាពក្នុងការកែតម្រូវច្បាប់ដោយរក្សាគោលការណ៍នីត្យានុកូលភាព។ |
| • ការកែតម្រូវ និងរៀនសូត្រជាបន្តបន្ទាប់ (Continuous correction and learning) | សំដៅដល់ការកែលម្អប្រព័ន្ធច្បាប់ជាបន្តបន្ទាប់ដោយផ្អែកលើបទពិសោធន៍ និងទិន្នន័យ។ |
| • កាតព្វកិច្ចថែរក្សាសង្គតិភាព ប្រសិទ្ធភាព និងធម្មានុភាព (Duty to preserve | សំដៅដល់កាតព្វកិច្ចក្នុងការរក្សាប្រព័ន្ធច្បាប់ឱ្យមានសង្គតិភាព មានប្រសិទ្ធភាព និងទទួលស្គាល់ពីសង្គម។ |

coherence, effectiveness, and legitimacy )

## ២. ក្របខ័ណ្ឌសូចនាករ ការប្រៀបធៀប និងការរាយការណ៍សាធារណៈ

| | |
|---|---|
| • សូចនាករប្រព័ន្ធច្បាប់ជាតិ ( National legal system indicators ) | សំដៅដល់សូចនាករដែលវាស់វែងស្ថានភាព និង គុណភាពនៃប្រព័ន្ធច្បាប់ជាតិ។ |
| • របាយការណ៍ប្រចាំឆ្នាំ ឬរបាយការណ៍តាមវគ្គ "ស្ថានភាពប្រព័ន្ធច្បាប់ជាតិ" ( Annual or periodic "State of the Legal System" report ) | របាយការណ៍ជាប្រចាំដែលបង្ហាញពីសមិទ្ធផល បញ្ហា និងនិន្នាការរបស់ប្រព័ន្ធច្បាប់។ |
| • ផ្ទាំងតាមដានប្រសិទ្ធភាព ( Performance dashboards ) | ឧបករណ៍បង្ហាញទិន្នន័យសម្រាប់តាមដានប្រសិទ្ធភាពស្ថាប័ន និងការអនុវត្តច្បាប់។ |
| • សូចនាករនីតិរដ្ឋ និងយុត្តិធម៌ ( Rule-of-law and justice indicators ) | សូចនាករដែលវាស់កម្រិតនីតិរដ្ឋ និងយុត្តិធម៌ក្នុងសង្គម។ |
| • ការប្រៀបធៀបសាធារណៈ និងការវិភាគនិន្នាការ ( Public benchmarking and trend analysis ) | ការវិភាគប្រៀបធៀបដើម្បីយល់ពីការវិវត្តន៍ និងសមិទ្ធផល។ |
| • ការផ្សព្វផ្សាយទិន្នន័យសមិទ្ធកម្មស្ថាប័ន ( Publication of institutional performance data ) | ការចែករំលែកទិន្នន័យសម្រាប់បង្កើនតម្លាភាព និងគណនេយ្យភាព។ |

## ៣. ការតាមដានជាបន្តបន្ទាប់ ការវិភាគប្រព័ន្ធច្បាប់ និងការព្រមានមុន

| | |
|---|---|
| • ការតាមដានជាបន្តបន្ទាប់ ឬតាមវគ្គ ( Real-time or periodic monitoring ) | ការតាមដានដំណើរការអនុវត្តច្បាប់ និងស្ថាប័នជាប្រចាំ។ |
| • សូចនាករព្រមានមុន ( Early-warning indicators ) | ឧបករណ៍សម្រាប់កំណត់ហានិភ័យ ឬបញ្ហាមុនឈានដល់ស្ថានភាពធ្ងន់ធ្ងរ។ |

| | |
|---|---|
| • ការរកឃើញគន្លឹះរាំងស្ទះផ្នែកច្បាប់ និងស្ថាប័ន (Detection of legal and institutional bottlenecks) | ការស្វែងរកចំណុចរាំងស្ទះក្នុងប្រព័ន្ធច្បាប់ និងស្ថាប័ន។ |
| • ការជូនដំណឹងអំពីការបរាជ័យនៃការអនុវត្ត ឬ ហានិភ័យសិទ្ធិជាប្រព័ន្ធ (Alerts on implementation failure or systemic rights risks) | ជាការបង្ហាញបញ្ហាដែលកើតឡើងក្នុងការអនុវត្តច្បាប់ដែលឈានដល់ការបរាជ័យនៃការអនុវត្តច្បាប់ |
| • នីតិវិធីឆ្លើយតបកែតម្រូវរហ័ស (Rapid corrective-response protocols) | វិធានការឆ្លើយតបរហ័សដើម្បីដោះស្រាយបញ្ហាបន្ទាន់។ |
| • នីតិវិធីបង្កើនកម្រិតឆ្លើយតបចំពោះបញ្ហាប្រព័ន្ធធ្ងន់ធ្ងរ (Escalation procedures for urgent legal dysfunction) | ការបង្កើនកម្រិតការឆ្លើយតបនៅពេលបញ្ហាមានស្ថានភាពធ្ងន់ធ្ងរ។ |

### ៤. ការកសាងច្បាប់ផ្អែកលើភស្តុតាង និងការវាយតម្លៃបទប្បញ្ញត្តិ

| | |
|---|---|
| • ការវាយតម្លៃផលប៉ះពាល់មុនចេញច្បាប់ (Ex ante impact assessment) | ការវាយតម្លៃផលប៉ះពាល់មុនពេលអនុម័តច្បាប់។ |
| • សេចក្តីថ្លែងអំពីគោលបំណង និងទ្រឹស្តីនៃការផ្លាស់ប្តូរ (Statement of objectives and theory of change) | ជាការពន្យល់ច្បាស់អំពីអ្វីដែលច្បាប់នឹងសម្រេច និងរបៀបដែលច្បាប់នឹងដំណើរការ។ |
| • តម្រូវការបញ្ជាក់ហេតុផលក្នុងការតាក់តែងច្បាប់ (Reason-giving requirements) | ការតម្រូវឱ្យពន្យល់ហេតុផលក្នុងការបង្កើតច្បាប់។ |
| • ការកំណត់លទ្ធផលដែលរំពឹងទុក (Requirement to specify expected outcomes) | ការកំណត់លទ្ធផលដែលច្បាប់នឹងត្រូវសម្រេច។ |

### ៥. ការពិនិត្យឡើងវិញក្រោយអនុវត្ត និងការគ្រប់គ្រងទិន្នន័យច្បាប់

- ការពិនិត្យច្បាប់ក្រោយអនុវត្ត (Ex post legislative review) — ការវាយតម្លៃប្រសិទ្ធភាពច្បាប់ក្រោយពេលអនុវត្ត។
- មាត្រាពិនិត្យឡើងវិញដោយស្វ័យប្រវត្តិ (Automatic review clauses) — ការកំណត់ឱ្យមានការពិនិត្យឡើងវិញដោយស្វ័យប្រវត្តិ។
- មាត្រាផុតកំណត់ (Sunset clauses) — ជាបញ្ញត្តិដែលធ្វើឱ្យច្បាប់ផុតសុពលភាព លុះត្រាតែមានការបន្តសុពលភាព។
- ការពិនិត្យទិន្នន័យច្បាប់តាមវដ្ត (Periodic stock reviews) — ជាការពិនិត្យសរុបលើច្បាប់ដែលមានស្រាប់ ដើម្បីវាយតម្លៃភាពសមស្រប និងភាពចាំបាច់។
- ជម្រើសលុប កែប្រែ ឬរួមបញ្ចូលច្បាប់ (Repeal, amendment, or consolidation options) — ការកែប្រែ ឬលុបច្បាប់ដែលមិនសមស្រប។
- ការផ្សព្វផ្សាយលទ្ធផលការពិនិត្យ (Publication of review findings) — ការចែករំលែកលទ្ធផលវាយតម្លៃទៅសាធារណៈ។

## ៦. ការត្រួតពិនិត្យសភា និងធម្យោបាយវាយតម្លៃបែបប្រជាធិបតេយ្យ

- ការត្រួតពិនិត្យច្បាប់ដោយគណៈកម្មការសភា (Committee scrutiny of enacted laws) — ជាការត្រួតពិនិត្យច្បាប់ក្រោយអនុម័ត ដើម្បីវាយតម្លៃប្រសិទ្ធភាព និងបញ្ហា។
- វេទិកាសួរដេញដោល និងការស៊ើបអង្កេតរបស់សភា (Hearings and inquiries) — ជាដំណើរការប្រមូលភស្តុតាង និងពិនិត្យបញ្ហាប្រព័ន្ធច្បាប់។
- ការសួរសំណួរដល់ក្រសួង និងស្ថាប័នរដ្ឋ (Questioning of ministries and agencies) — ជាការទាមទារឱ្យអង្គភាពអនុវត្តច្បាប់ពន្យល់អំពីការអនុវត្តរបស់ខ្លួន។

- ការទទួលមតិយោបល់សាធារណៈ ( Public submissions and petitions ) ឱកាសឱ្យសាធារណៈចូលរួមក្នុងការកែលម្អច្បាប់។

### ៧. មតិយោបល់ពីតុលាការ និងសង្គតិភាពយុត្តិសាស្ត្រ

- មតិយោបល់ពីសាលក្រម ( Feedback from judgments ) សេចក្តីសម្រេចតុលាការជួយបញ្ជាក់បញ្ហាច្បាប់ និងផ្តល់មតិត្រឡប់ទៅប្រព័ន្ធច្បាប់។
- ការសុខដុមនីយកម្មយុត្តិសាស្ត្រ ( Case-law harmonisation ) ជាវិធីសាស្ត្រដើម្បីធានាថាយុត្តិសាស្ត្រមានសង្គតិភាព។
- មូលដ្ឋានទិន្នន័យយុត្តិសាស្ត្រ ( Jurisprudence databases ) ការប្រមូល និងផ្សព្វផ្សាយសេចក្តីសម្រេចតុលាការ។
- មុខងារបង្រួបបង្រួមយុត្តិសាស្ត្រ ( Supreme court guidance ) ជាតួនាទីក្នុងការបង្រួបបង្រួម និងគោលការណែនាំទូទៅយុត្តិសាស្ត្រ ។

### ៨. អធិការកិច្ច សវនកម្ម និងការតាមដានឯករាជ្យ

- ស្ថាប័នត្រួតពិនិត្យឯករាជ្យ ( Independent oversight bodies ) ស្ថាប័នត្រួតពិនិត្យក្រៅប្រព័ន្ធអនុវត្តច្បាប់។
- សវនកម្ម និងអធិការកិច្ច ( Audit and inspection ) ការត្រួតពិនិត្យប្រសិទ្ធភាព និងសុចរិតភាព។
- ការតាមដានអនុសាសន៍ ( Follow-up mechanisms ) ការតាមដានការអនុវត្តអនុសាសន៍។
- គណនេយ្យភាពចំពោះការមិនអនុវត្ត ( Accountability for non-compliance ) ការទាមទារទំនួលខុសត្រូវពេលមិនអនុវត្តអនុសាសន៍។

### ៩. តម្លាភាព ទិន្នន័យយុត្តិធម៌ និងហេដ្ឋារចនាសម្ព័ន្ធចំណេះដឹង

- ប្រព័ន្ធព័ត៌មានច្បាប់ ( Legal information systems ) ប្រព័ន្ធផ្តល់ព័ត៌មានច្បាប់ជាសាធារណៈ។

- អភិបាលកិច្ចទិន្នន័យយុត្តិធម៌ (Justice data governance) ការគ្រប់គ្រងទិន្នន័យច្បាប់ឱ្យមានគុណភាព និងសុវត្ថិភាព។
- មូលដ្ឋានទិន្នន័យសំណុំរឿង (Case databases) ការប្រមូលទិន្នន័យសំណុំរឿងសម្រាប់វិភាគ។
- ការភ្ជាប់ប្រព័ន្ធទិន្នន័យ (Interoperability) ការភ្ជាប់ទិន្នន័យរវាងស្ថាប័ន។
- មូលដ្ឋានចំណេះដឹង និងបទពិសោធន៍ (Knowledge repositories) ការរក្សាទុក និងចែករំលែកបទពិសោធន៍សម្រាប់ការរៀនសូត្រ។

# ៧. ការរៀបចំក្របខ័ណ្ឌប្រព័ន្ធច្បាប់កម្ពុជា

## ៧.១. ដំណើរការនៃការរៀបចំ

ការរៀបចំក្របខ័ណ្ឌប្រព័ន្ធច្បាប់កម្ពុជា គ្រោងអនុវត្តតាមដំណាក់កាល និងលំដាប់នីតិវិធីដែលមានលក្ខណៈច្បាស់លាស់ ស្របតាមគោលការណ៍ដឹកនាំ និងយន្តការពាក់ព័ន្ធរបស់ទីស្ដីការគណៈរដ្ឋមន្ត្រី។ ជាជំហានដំបូងសេចក្ដីព្រាងក្របខ័ណ្ឌទស្សនទាននេះ ត្រូវដាក់ជូនគណៈកម្មាធិការកំណែទម្រង់ច្បាប់ ដើម្បីពិនិត្យ ផ្ដល់យោបល់ និងអនុម័ត។ ក្នុងដំណាក់កាលនេះ គ.ក.ច. នឹងពិចារណាទៅលើតម្រូវការ ទិសដៅទ្រឹស្ដី វិសាលភាព គោលដៅ និងវិធីសាស្ត្រក្នុងការរៀបចំក្របខ័ណ្ឌនៃការកសាងប្រព័ន្ធច្បាប់កម្ពុជា។

បន្ទាប់ពីក្របខ័ណ្ឌទស្សនទានត្រូវបានអនុម័ត ក្រុមការងាររៀបចំក្របខ័ណ្ឌនៃការកសាងប្រព័ន្ធច្បាប់នឹងត្រូវបានបង្កើតឡើងដើម្បីដឹកនាំនិងសម្របសម្រួលដំណើរការនៃការតាក់តែងនេះ ដែលមានរចនាសម្ព័ន្ធដូច ខាងក្រោម៖

- ក្រុមការងារស្នូល ដែលមានសមាសភាពថ្នាក់ដឹកនាំ និងអ្នកជំនាញជាន់ខ្ពស់ ដែលទទួលបន្ទុកក្នុងការផ្ដល់ការណែនាំជាយុទ្ធសាស្ត្រ ទិសដៅគោលនយោបាយ ការពិនិត្យ ទៅ លើខ្លឹមសារ និងការធ្វើសេចក្ដីសម្រេចចិត្ត និង
- ក្រុមការងារបច្ចេកទេស ដែលបំពេញមុខងារជាសេនាធិការជូនដល់ក្រុមការងារស្នូល និងមានទំនួលខុសត្រូវក្នុងការស្រាវជ្រាវ តាក់តែង ចងក្រង វិភាគបច្ចេកទេស ពិគ្រោះយោបល់ និងកិច្ចការលេខាធិការ។

ក្រោមពីក្រុមការងារត្រូវបានង្កើតឡើង នោះដំណើរការរៀបចំផ្លូវការនៃក្របខ័ណ្ឌនៃការកសាងប្រព័ន្ធច្បាប់កម្ពុជា នឹងត្រូវចាប់ផ្តើម។ ក្របខ័ណ្ឌទស្សនាទាននេះនឹងក្លាយជាឯកសារគ្រឹះមូលដ្ឋានសម្រាប់ដំណើរការនេះ តាមរយៈការផ្តល់ជាទិសដៅគោលនយោបាយ មូលដ្ឋានផ្នែកទ្រឹស្តី និងគោលការណ៍នានាដែលចាំបាច់ សម្រាប់ការតាក់តែង។

ក្រោយពីការតាក់តែងត្រូវបានបញ្ចប់ សេចក្តីព្រាងក្របខ័ណ្ឌនៃការកសាងប្រព័ន្ធច្បាប់កម្ពុជានឹងត្រូវដាក់ឆ្លង យន្តការត្រួតពិនិត្យនៃទីស្តីការគណៈរដ្ឋមន្ត្រី។ ដំណើរការពិនិត្យនេះរួមមានការពិនិត្យបច្ចេកទេសជាមួយ វិស័យពាក់ព័ន្ធ ការពិគ្រោះយោបល់អន្តរក្រសួង និងតាមយន្តការផ្សេងៗទៀតក្នុងករណីចាំបាច់។ ក្រោយពីបានបញ្ចប់ដំណើរការត្រួតពិនិត្យនេះ សេចក្តីព្រាងក្របខ័ណ្ឌនៃការកសាងប្រព័ន្ធច្បាប់កម្ពុជានឹងត្រូវដាក់ឆ្លង គណៈរដ្ឋមន្ត្រីដើម្បីពិនិត្យនិងអនុម័ត និងការដាក់ឱ្យអនុវត្តជាផ្លូវការ។

## ៧.២. អភិបាលកិច្ចនៃកិច្ចការរៀបចំ

ការរៀបចំក្របខ័ណ្ឌនៃការកសាងប្រព័ន្ធច្បាប់កម្ពុជាតម្រូវឱ្យមានការរៀបចំអភិបាលកិច្ចច្បាស់លាស់ ដើម្បី ធានាការដឹកនាំផ្នែកនយោបាយ គុណភាពភាពបច្ចេកទេស ការសម្របសម្រួល និងប្រសិទ្ធភាព។ ក្នុងន័យ នេះ សេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងាររៀបចំក្របខ័ណ្ឌទស្សនាទានប្រព័ន្ធច្បាប់នឹងត្រូវបានបង្កើត ឡើងក្រោយពីក្របខ័ណ្ឌនៃការកសាងនេះត្រូវបានអនុម័តដោយ គ.ក.ច.។

### ៧.២.១ ក្រុមការងារស្នូល

ក្រុមការងារស្នូលមានសមាសភាពពីសំណាក់ថ្នាក់ដឹកនាំ និងអ្នកជំនាញជាន់ខ្ពស់ដែលមានសមត្ថកិច្ច និងឯកទេសចាំបាច់សម្រាប់ណែនាំកិច្ចការតាក់តែង និងមានតួនាទីភារកិច្ចចម្បងរួមមាន៖

- ផ្តល់ទិសដៅគោលនយោបាយនិងយុទ្ធសាស្ត្រ
- ពិនិត្យការរៀបចំខ្លឹមសារនៅក្នុងក្របខ័ណ្ឌប្រព័ន្ធច្បាប់
- ពិនិត្យនិងសម្រេចលើសេចក្តីព្រាង
- ដោះស្រាយបញ្ហាពាក់ព័ន្ធនឹងគោលនយោបាយឬទស្សនាទាន ដែលកើតចេញពីការតាក់តែង
- ធានាអនុលោមភាពជាមួយនឹងគោលដៅនៃការកែទម្រង់ច្បាប់ និងការអភិវឌ្ឍន៍ជាតិ

### ៧.២.២ ក្រុមការងារបច្ចេកទេស

ក្រុមការងារបច្ចេកទេសបំពេញមុខងារជាសេនាធិការដល់ក្រុមការងារស្នូល និងមានតួនាទីភារកិច្ចរួមមាន៖

- ស្រាវជ្រាវច្បាប់និងគោលនយោបាយ
- តាក់តែង និងកែសម្រួលអត្ថបទ
- ប្រមូល និងចងក្រងឯកសារនានា
- ជួយរៀបចំការពិគ្រោះយោបល់ និងទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធ
- បំពេញការងារផ្នែករដ្ឋបាលនិងលេខាធិការ

សមិទ្ធផលដែលរៀបចំដោយក្រុមការងារបច្ចេកទេសត្រូវដាក់ជូនក្រុមការងារស្នូលដើម្បីពិនិត្យផ្តល់យោបល់ និងទិសដៅក្នុងដំណាក់កាលនៃការតាក់តែងនីមួយៗ។

## ៧.៣. ក្របខ័ណ្ឌពេលវេលា

ការរៀបចំក្របខ័ណ្ឌប្រព័ន្ធច្បាប់កម្ពុជានេះគ្រោងបញ្ចប់ក្នុងរយៈពេល ៦ (ប្រាំមួយ) ខែ។ ក្នុងរយៈពេល ៣ ខែដំបូងគឺផ្តោតលើការតាក់តែង ក្រោយពីការអនុម័តលើក្របខ័ណ្ឌទស្សនាទាន និងការបង្កើតក្រុមការងារ។ ក្នុងកំឡុងពេលនេះ ក្រុមការងារត្រូវស្រាវជ្រាវ រៀបចំសេចក្តីព្រាងក្របខ័ណ្ឌ ព្រមទាំងពិនិត្យ និងកែតម្រូវ។ ក្រោយពីសេចក្តីព្រាងត្រូវបានតាក់តែងរួចរាល់ ជំហានបន្ទាប់គឺផ្តោតលើការត្រួតពិនិត្យនៅក្នុងយន្តការទីស្តីការគណៈរដ្ឋមន្ត្រី។ នៅក្នុងយន្តការនេះរួមមាន រយៈពេលសម្រាប់ការពិនិត្យបច្ចេកទេស និងរយៈពេលពិគ្រោះយោបល់អន្តរក្រសួង និងបន្តដោយការដាក់ឆ្លងចុងក្រោយទៅគណៈរដ្ឋមន្ត្រីសម្រាប់ការពិនិត្យនិងសម្រេច។

ក្របខ័ណ្ឌពេលលាខាងលើគឺស្របតាមតម្រូវការរបស់ គ.ក.ច. ក្នុងការមានឯកសារជាផែនទីបង្ហាញផ្លូវសម្រាប់ដឹកនាំការកែទម្រង់ច្បាប់ លទ្ធផលស្រាវជ្រាវដែលបានសម្រេចកន្លងមកស្រាប់ និងរយៈពេលសម្រាប់ពិនិត្យដើម្បីធានាគុណភាពនៃឯកសារដ៏សំខាន់នេះ។ ឯកសារក្របខ័ណ្ឌនេះពុំមែនជាឯកសារសម្រេចនោះទេ តែជាឯកសាររស់ ដែលត្រូវធ្វើបច្ចុប្បន្នកម្មជាប្រចាំដើម្បីឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងក្នុងការអនុវត្ត និងធ្វើឱ្យឯកសារនេះកាន់តែប្រសើរឡើងដោយមានសមត្ថភាពឆ្លើយតបទៅនឹងការប្រែប្រួលសង្គមជាក់ស្តែង។

| ដំណាក់កាល | សកម្មភាព | ពេលវេលា |
|---|---|---|

| | | |
|---|---|---|
| ដំណាក់កាលទី១ | សេចក្តីព្រាងក្របខ័ណ្ឌទស្សនាស្តីពីក្របខ័ណ្ឌប្រព័ន្ធច្បាប់ត្រូវបានដាក់ឆ្លង គ.ក.ច. ដើម្បីពិនិត្យ និងសម្រេច | ខែទី ០ |
| ដំណាក់កាលទី២ | ក្រុមការងាររៀបចំក្របខ័ណ្ឌប្រពន្ធច្បាប់កម្ពុជាត្រូវបានបង្កើត | ខែទី ០ |
| ដំណាក់កាលទី៣ | ការស្រាវជ្រាវ ការតាក់តែង ការពិគ្រោះយោបល់និងកែតម្រូវផ្ទៃក្នុងក្រុមការងារលើក្របខ័ណ្ឌប្រព័ន្ធច្បាប់កម្ពុជា | ខែទី ១-៣ |
| ដំណាក់កាលទី៤ | ការត្រួតពិនិត្យបច្ចេកទេសនៅក្នុងយន្តការទីស្តីការគណៈរដ្ឋមន្ត្រី | ខែទី ៤ |
| ដំណាក់កាលទី៥ | ការពិនិត្យនិងពិគ្រោះយោបល់អន្តរក្រសួងនៅក្នុងយន្តការទីស្តីការគណៈរដ្ឋមន្ត្រី | ខែទី ៥ |
| ដំណាក់កាលទី៦ | ការដាក់ឆ្លងគណៈរដ្ឋមន្ត្រីដើម្បីពិនិត្យចុងក្រោយ និងសម្រេច | ខែទី ៦ |

## ៧.៤. លក្ខខណ្ឌគុណវុឌ្ឍិ

ដោយកត្តានៃសារៈសំខាន់និងភាពស្មុគស្មាញនៃកិច្ចការនេះ សមាជិកនៃក្រុមការងារគួរមានគុណវុឌ្ឍិ និងសមត្ថភាពសមស្របសម្រាប់តួនាទីភារកិច្ចនិងការទទួលខុសត្រូវរៀងៗខ្លួន។ នៅក្នុងនោះក្រុមការងារ គួរមានសមាជិកដែលមានចំណេះដឹងជ្រៅជ្រះ និងបទពិសោធន៍នៅក្នុងការងារផ្នែកស្រាវជ្រាវច្បាប់, តាក់តែងច្បាប់, គោលនយោបាយសាធារណៈនិងអភិបាលកិច្ច, កែទម្រង់ច្បាប់, ស្ថាប័ននិងការអភិវឌ្ឍន៍ច្បាប់នៅកម្ពុជា, និងការសិក្សាស្រាវជ្រាវប្រៀបធៀប និងវិភាគ។

សមាជិកនីមួយៗគួរមានចំណេះដឹងជ្រៅជ្រះអំពីប្រព័ន្ធច្បាប់កម្ពុជា និងរចនាសម្ព័ន្ធស្ថាប័ន ព្រមទាំងការយល់ដឹងអំពីកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល។ ក្នុងនោះសមាជិក គួរមានសមត្ថភាពក្នុងការវិភាគទ្រឹស្តីនិងច្បាប់ ស្រាវជ្រាវ តាក់តែងនិងសំយោគ ព្រមទាំងការសម្របសម្រួលជាមួយក្រសួងស្ថាប័ន អ្នកជំនាញ និងភាគីពាក់ព័ន្ធ។ សមាជិកគ្រប់រូបចាំបាច់ត្រូវមានវិជ្ជាជីវៈក្នុងការបំពេញការងារវិន័យ សុចរិតភាព រក្សាការសម្ងាត់ និងសមត្ថភាពក្នុងការបំពេញការងារទាន់ពេលវេលាដែលបានកំណត់ដោយការទទួលខុសត្រូវខ្ពស់ស្របតាមក្របខ័ណ្ឌពេលវេលា។

### ៧.៥. លទ្ធផលរំពឹងទុក

លទ្ធផលរំពឹងទុកនៃដំណើរការនេះគឺការរៀបចំសេចក្តីព្រាងក្របខ័ណ្ឌប្រព័ន្ធច្បាប់កម្ពុជាដែលមានលក្ខណៈពេញលេញ ប្រទាក់ក្រឡា និងគុណភាពគ្រប់គ្រាន់សម្រាប់ពិនិត្យនិងសម្រេច។ ក្របខ័ណ្ឌប្រព័ន្ធច្បាប់កម្ពុជាពុំត្រឹមជាឯកសារដែលកំណត់អំពីធាតុផ្សំនៃប្រព័ន្ធច្បាប់នោះទេ ប៉ុន្តែក៏ កំណត់នូវទិសដៅ យុទ្ធសាស្ត្រក្នុងការអនុវត្តដើម្បីពង្រឹងគុណភាព ភាពប្រទាក់ក្រឡា ប្រសិទ្ធភាព និងបូរណភាពនៃប្រព័ន្ធ ទាំងមូល ព្រមទាំងកំណត់ច្បាស់លាស់នូវយន្តការសម្រាប់តាមដានត្រួតពិនិត្យសម្រាប់ការអភិវឌ្ឍន៍ និងកែលម្អប្រព័ន្ធច្បាប់ជាប្រចាំ។ ក្រោយពីបញ្ចប់ដំណើរការតាក់តែង និងពិនិត្យពិច័យផ្ទៃក្នុងនៃ ក្រុមការងាររៀបចំ សេចក្តីព្រាងនៃក្រប ខ័ណ្ឌនេះនឹងត្រូវ ដាក់ឆ្លងយន្តការត្រួតពិនិត្យនៃទីស្តីការគណៈរដ្ឋមន្ត្រី និងឆ្លងការពិនិត្យសម្រេច ចុងក្រោយដោយគណៈរដ្ឋមន្ត្រី។

## ៨. សេចក្តីសន្និដ្ឋាន

ការកសាងប្រព័ន្ធច្បាប់ជាតិមួយដែលមានសង្គតិភាព បូរណភាព និងប្រសិទ្ធភាព គឺជាកិច្ចការយុទ្ធសាស្ត្រដ៏សំខាន់សម្រាប់ការកសាងរដ្ឋរឹងមាំ នីតិរដ្ឋ និងការអភិវឌ្ឍជាតិប្រកបដោយចីរភាព។ នៅក្នុងបរិបទនៃការវិវត្តន៍ឆាប់រហ័សនៃសេដ្ឋកិច្ច សង្គម បច្ចេកវិទ្យា និងទំនាក់ទំនងអន្តរជាតិ ប្រព័ន្ធច្បាប់មិនអាចត្រឹមតែជាបណ្តុំច្បាប់ និងស្ថាប័នដាច់ដោយឡែកពីគ្នានោះទេ ប៉ុន្តែត្រូវតែជាប្រព័ន្ធមួយដែលមានសមាហរណកម្ម និងដំណើរការរួមគ្នា ក្នុងគោលបំណងធានាសន្តិសុខគតិយុត្ត ស្ថិរភាពនយោបាយ ការគ្រប់គ្រងរដ្ឋប្រកបដោយប្រសិទ្ធភាព និងការការពារសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋ។

ឯកសារក្របខ័ណ្ឌទស្សនាទាននេះ បានប្រើប្រាស់ដាក់ទ្រឹស្តីប្រព័ន្ធទូទៅ និងប្រព័ន្ធច្បាប់សម្រាប់ការស្វែងយល់និងវិភាគអំពី "ប្រព័ន្ធច្បាប់កម្ពុជា"។ តាមរយៈទស្សនៈនេះ ប្រព័ន្ធច្បាប់ជាប្រព័ន្ធរស់មួយដែលមានធាតុផ្សំទាក់ទងគ្នា និងអន្តរសកម្មគ្នា ដោយរួមបញ្ចូលទាំង គុណតម្លៃគ្រឹះ (Foundational Ethos) ដែលកំណត់ទិសដៅ និងអត្តសញ្ញាណរបស់ប្រព័ន្ធច្បាប់, សារធាតុគតិយុត្ត (Legal Substance) ដែលកំណត់ខ្លឹមសារនៃបទដ្ឋានគតិយុត្ត, រចនាសម្ព័ន្ធគតិយុត្ត (Legal Structure) ដែលបង្ហាញពីនិម្មាបនកម្មស្ថាប័ននៃប្រព័ន្ធច្បាប់, វប្បធម៌គោរពច្បាប់ (Legal Culture) ដែលធានាថាច្បាប់មានអត្ថន័យក្នុងការអនុវត្តជាក់ស្តែង និង យន្តការវាយតម្លៃ (FeedbackLoops) ដែលធ្វើឱ្យប្រព័ន្ធច្បាប់អាចត្រួតពិនិត្យ កែលម្អ និងអភិវឌ្ឍខ្លួនឯងជាបន្តបន្ទាប់។

ការបង្កើតក្របខ័ណ្ឌប្រព័ន្ធច្បាប់ជាតិនេះ មានគោលបំណងបង្កើតមូលដ្ឋានគំនិត និងនិម្មាបនកម្ម រួមសម្រាប់ការសិក្សា វាយតម្លៃ និងកែលម្អប្រព័ន្ធច្បាប់កម្ពុជា ដែលជាឧបករណ៍សម្រាប់ ការវិភាគវាយតម្លៃបញ្ហានៃប្រព័ន្ធច្បាប់ ការសម្របសម្រួលនិងសង្គតិភាពនៃច្បាប់ជាធរមាន ការរៀបចំគោលនយោបាយ និងការកែទម្រង់ច្បាប់ ការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្សផ្នែកច្បាប់ ការកែលម្អប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងការគ្រប់គ្រងរដ្ឋ។

ជាមួយគ្នានេះ ក្របខ័ណ្ឌនេះក៏អាចធ្វើជាឯកសារយោងសម្រាប់ការអភិវឌ្ឍន៍ឧបករណ៍វាយតម្លៃប្រព័ន្ធច្បាប់ជាតិ ដូចជា ការបង្កើតសូចនាករប្រព័ន្ធច្បាប់ ការរៀបចំរបាយការណ៍ "ស្ថានភាពប្រព័ន្ធច្បាប់ជាតិ" ជាប្រចាំ ការតាមដានការអនុវត្តច្បាប់ និងការពិនិត្យឡើងវិញនៃច្បាប់ជាធរមាន ដែលនឹងជួយបង្កើតយន្តការសម្រាប់ការកែលម្អប្រព័ន្ធច្បាប់ដោយផ្អែកលើភស្តុតាង និងការសិក្សាបច្ចេកទេសជាបន្តបន្ទាប់។

ការអនុវត្តក្របខ័ណ្ឌនេះ ទាមទារការចូលរួម និងការសហការរបស់ស្ថាប័នជាច្រើន រួមមានស្ថាប័នធម្មនុញ្ញ ស្ថាប័នរដ្ឋបាល តុលាការ ស្ថាប័នវិជ្ជាជីវៈច្បាប់ ស្ថាប័នអប់រំ និងស្រាវជ្រាវ ព្រមទាំងសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍។ ដំណើរការនេះជាទស្សនៈវែងឆ្ងាយ និងការរៀបចំជាប្រព័ន្ធ ដើម្បីធានាថាប្រព័ន្ធច្បាប់កម្ពុជាអាចឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍជាតិ និងបរិបទអន្តរជាតិដែលកំពុងផ្លាស់ប្តូរយ៉ាងឆាប់រហ័ស។

ជាសេចក្តីសន្និដ្ឋាន ការរៀបចំក្របខ័ណ្ឌទស្សនាទានស្តីពីប្រព័ន្ធច្បាប់កម្ពុជា គឺជាជំហានដំបូងសម្រាប់ការកសាងទស្សនវិជ្ជា និងនិម្មាបនកម្មរួមនៃប្រព័ន្ធច្បាប់ជាតិ។ តាមរយៈការបញ្ជាក់គុណតម្លៃគ្រឹះ ការរៀបចំខ្លឹមសារគតិយុត្ត ការកំណត់រចនាសម្ព័ន្ធស្ថាប័ន ការពង្រឹងវប្បធម៌គោរពច្បាប់ និងការបង្កើតយន្តការវាយតម្លៃជាប្រព័ន្ធ កម្ពុជាអាចបន្តអភិវឌ្ឍប្រព័ន្ធច្បាប់មួយដែលមានភាពទំនើប ប្រមូលផ្តុំ និងអាចទុកចិត្តបាន ដើម្បីគាំទ្រដល់ការកសាងរដ្ឋរឹងមាំ នីតិរដ្ឋ និងការអភិវឌ្ឍជាតិប្រកបដោយចីរភាពក្នុងសតវត្សទី២១។

## ឧបសម្ព័ន្ធ ១. បញ្ជីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន

| ល.រ | នីតិកាល | ចំនួន |
|---|---|---|
| ១. | នីតិកាលទី១ | ៩២ |
| ២. | នីតិកាលទី២ | ៨៤ |
| ៣. | នីតិកាលទី៣ | ១៤១ |
| ៤. | នីតិកាលទី៤ | ៩១ |
| ៥. | នីតិកាលទី៥ | ១០៥ |
| ៦. | នីតិកាលទី៦ | ១២២ |
| ៧. | នីតិកាលទី៧ | ៥២ |
| សរុប | | ៦៨៧ |

| ល.រ | នីតិកាលទី១ (១៩៩៣ ដល់ ១៩៩៨) | ផ្សេងៗ |
| ៣៧. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការកែសម្រួលអនុក្រឹត្យលេខ៣០៩ អនក្រ.បក ស្តីពីការ គ្រប់គ្រងនិងការចាត់ចែងសេវាបង្រៀនក្នុងគ្រឹះស្ថានមបមសិក្សាសាធារណៈ | | |
| ៣៨. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការកែសម្រួលអនុក្រឹត្យលេខ១៧៤ អនក្រ.បក ស្តីពីអាហា រូបករណ៍និងរបប ឧបត្ថម្ភជីវភាពអន្តេវាសិក សម្រាប់សិស្ស និស្សិតសិក្សាតាមគ្រឹះស្ថាន សិក្សាសាធារណៈ | | |
| ៣៩. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការកែសម្រួលអនុក្រឹត្យលេខ៣៤ អនក្រ.បក ស្តីពីការផ្តល់ អាហារូបករណ៍ដល់សិស្សក្រីក្រជួបការលំបាកនៅបឋមសិក្សានិងមធ្យមសិក្សាចំណោះទូទៅ | | |
| ៤០. | សេចក្តីព្រាងក្របខណ្ឌគោលនយោបាយជាតិស្តីពីការអប់រំ | | |
| ៤១. | សេចក្តីព្រាងគោលនយោបាយជាតិស្តីពីការផ្តល់អាហារតាមសាលារៀន | | |

| ល.រ | សេចក្តីព្រាងលិខិតបទដ្ឋានគតិយុត | សម្រាប់ឆ្នាំ | ផ្សេងៗ |
|---|---|---|---|
| ៤២. | សេចក្តីព្រាងគោលនយោបាយស្តីពីការផ្តល់អាហារូបករណ៍ ឧបត្ថម្ភធន និងឥណទានសម្រាប់អ្នកសិក្សាចំណេះទូទៅ | | |
| ៤៣. | សេចក្តីព្រាងគោលនយោបាយជាតិស្តីពីកម្មវិធីសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេស | | |
| **១២. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** | | | |
| ១. | សេចក្តីព្រាងច្បាប់ស្តីពីកិច្ចគាំពារសិទ្ធិជនមានពិការភាព | | |
| ២. | សេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារកុមារ | | |
| ៣. | សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈវិជ្ជាជីវៈសង្គមកិច្ច | | |
| ៤. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការធ្វើសមាហរណកម្ម និងការដំឡើងរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន | | |
| ៥. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងកម្លាំងសេវាសង្គម | | |
| ៦. | សេចក្តីព្រាងអនុក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈកម្លាំងសេវាសង្គម | | |
| ៧. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងមណ្ឌលថែទាំ និងស្តារនីតិសម្បទាជន វិបល្លាសស្មារតី | | |
| ៨. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងមណ្ឌលសំចត និងស្តារនីតិសម្បទាជនរងគ្រោះ ប៉ោយប៉ែត | | |
| ៩. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំទិវាជាតិសង្គមកិច្ច | | |
| ១០. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ កែវផុស | | |
| ១១. | សេចក្តីព្រាងវិសោធនកម្មអនុក្រឹត្យលេខ៤១៦ អនក្រ.តត ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៩ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ | | |

| ល.រ | សេចក្តីព្រាងលិខិតបទដ្ឋានគតិយុត | សម្រាប់ឆ្នាំ | ផ្សេងៗ |
|---|---|---|---|
| ១២. | សេចក្តីព្រាងវិសោធនកម្មអនុក្រឹត្យលេខ២៣៣ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ ស្តីពីការបង្កើតវិទ្យាស្ថានជាតិសង្គមកិច្ច | | |
| ១៣. | សេចក្តីព្រាងវិសោធនកម្មអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាសកម្មភាពជនពិការ | | |
| ១៤. | សេចក្តីព្រាងវិសោធនកម្មអនុក្រឹត្យលេខ៩០ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៧ នៃអនុក្រឹត្យលេខ១១៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦ ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមណ្ឌលរបស់រដ្ឋ | | |
| ១៥. | សេចក្តីព្រាងវិសោធនកម្មកែសម្រួលមាត្រា១០ នៃអនុក្រឹត្យលេខ១៣៧ អនក្រ.បក ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១១ ស្តីពីរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅ តាមសហគមន៍ | | |
| ១៦. | សេចក្តីព្រាងវិសោធនកម្មអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិជនពិការ | | |
| ១៧. | សេចក្តីព្រាងវិសោធនកម្មអនុក្រឹត្យលេខ១៥៨ អនក្រ.បក ស្តីពីការបង្កើតគណៈកម្មាធិការជាតិកម្ពុជា ដើម្បីមនុស្សចាស់ | | |
| ១៨. | សេចក្តីព្រាងគោលនយោបាយជាតិស្តីពីគ្រួសារ | | |
| ១៩. | សេចក្តីព្រាងគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ | | |
| ២០. | សេចក្តីព្រាងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០២៤-២០២៨ | | |
| ២១. | រៀបចំនីតិវិធីបញ្ជូនរបាយការណ៍ដំបូងស្តីពីការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនមានពិការភាពនៅកម្ពុជាជូនគណៈកម្មាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិជនមានពិការភាព | | |

| ល.រ | សេចក្តីព្រាងលិខិតបទដ្ឋានគតិយុត | សម្រាប់ឆ្នាំ | ផ្សេងៗ |
|---|---|---|---|
| ២២. | សេចក្តីព្រាងកែសម្រួលសេចក្តីសម្រេចលេខ១៣១ សសរ ស្តីពីការតែងតាំងសមាស ភាពគណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់ | | |
| ២៣. | សេចក្តីព្រាងសេចក្តីសម្រេចស្តីពីការតែងតាំងសមាសភាពគណៈកម្មការការពារកុមារថ្នាក់ជាតិ | | |
| **១៣. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់** | | | |
| ១. | សេចក្តីព្រាងច្បាប់ភូមិបាលថ្មី | | |
| ២. | សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំដែនដីនិងនគរូបនីយកម្ម | | |
| ៣. | សេចក្តីព្រាងច្បាប់ស្តីពីលំនៅឋាន | | |
| ៤. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | | |
| ៥. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងការអភិវឌ្ឍនគរូបនីយកម្មតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា | | |
| ៦. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងអ្នកជំនាញក្នុងវិស័យសំណង់ដែលមិនទាន់បានបង្កើតគណៈវិជ្ជាជីវៈ | | |
| ៧. | សេចក្តីព្រាងអនុក្រឹត្យស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការគ្រប់គ្រងនិងត្រួតពិនិត្យការងារ ៧ សាងសង់ឬរុះរើ | | |
| ៨. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មការដោះស្រាយ ៨ វិវាទសំណង់ | | |
| ៩. | សេចក្តីព្រាងអនុក្រឹត្យស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការអនុញ្ញាតកែសម្រួលគម្រោងប្លង់ ឬអនុក្រឹត្យស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការសិក្សាគម្រោងប្លង់ | | |
| ១០. | សេចក្តីព្រាងអនុក្រឹត្យស្តីពីក្រមសីលធម៌សម្រាប់អ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ | | |
| ១១. | សេចក្តីព្រាងអនុក្រឹត្យស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការព្យួរ និងការដកហូតលិខិត អនុញ្ញាតបង្កើតមន្ទីរពិសោធន៍សំណង់ក្នុងគោលដៅសិក្សា ស្រាវជ្រាវ និងបណ្តុះបណ្តាល | | |

| ល.រ | សេចក្តីព្រាងលិខិតបទដ្ឋានគតិយុត | សម្រាប់ឆ្នាំ | ផ្សេងៗ |
|---|---|---|---|
| ១២. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការកំណត់ប្រើប្រាស់និងអាស្រ័យផលលើដីរដ្ឋនៅក្រៅតំបន់៣ នៃតំបន់ទន្លេសាប ក្នុងភូមិសាស្ត្រខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងខេត្តកំពង់ធំ | | |
| ១៣. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងទិន្នន័យសុរិយោដីឌីជីថល | | |
| ១៤. | សេចក្តីព្រាងអនុក្រឹត្យស្តីពីនីតិវិធីនៃការផ្តល់សេវាសុរិយោដីតាមអនឡាញ | | |
| ១៥. | សេចក្តីព្រាងអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច | | |
| ១៦. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិនាមភូមិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា | | |
| ១៧. | ក្របខណ្ឌយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍទីក្រុង ឬគោលនយោបាយជាតិស្តីពីនគរូបនីយកម្ម | | |
| ១៨. | សេចក្តីព្រាងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍវិស័យសំណង់ | | |
| **១៤. ក្រសួងធនធានទឹក និងឧតុនិយម** | | | |
| ១. | សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា | ២០២៣-២០២៨ | |
| ២. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងធនធានទឹកនិងឧតុនិយម | ២០២៣-២០២៨ | |
| ៣. | សេចក្តីព្រាងអនុក្រឹត្យស្តីពីអាង្វាបណ្ណទឹក | ២០២៣-២០២៨ | |
| ៤. | សេចក្តីព្រាងអនុក្រឹត្យស្តីពីគុណភាពទឹក | ២០២៣-២០២៨ | |
| ៥. | សេចក្តីព្រាងគោលនយោបាយជាតិលើវិស័យធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា (ធ្វើបច្ចុប្បន្នកម្មថ្មី) | ២០២៣-២០២៨ | |
| **១៥. ក្រសួងព័ត៌មាន** | | | |
| ១. | សេចក្តីព្រាងច្បាប់ស្តីពីរបបសារព័ត៌មាន | | |
| ២. | សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន | | |
| ៣. | សេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងព័ត៌មានក្លែងក្លាយ | | |

| ល.រ | សេចក្តីព្រាងលិខិតបទដ្ឋានគតិយុត | សម្រាប់ឆ្នាំ | ផ្សេងៗ |
|---|---|---|---|
| ៤. | សេចក្តីព្រាងច្បាប់ស្តីពីសោតទស្សន៍ | | |
| ៥. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងព័ត៌មាន | | |
| ៦. | សេចក្តីព្រាងអនុក្រឹត្យស្តីពីទិវាសារព័ត៌មានជាតិ អន្តរជាតិ និងប្រព័ន្ធផ្សព្វផ្សាយសោតទស្សន៍ | | |
| ៧. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីរបបសារព័ត៌មាន | | |
| ៨. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន | | |
| ៩. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់សោតទស្សន៍ | | |
| ១០. | សេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យព័ត៌មាននិងសោតទស្សន៍ | | |
| ១១. | សេចក្តីព្រាងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍទូរទស្សន៍ឌីជីថល | | |
| **១៦. ក្រសួងយុត្តិធម៌** | | | |
| ១. | សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មក្រមព្រហ្មទណ្ឌ | ២០២៤ | |
| ២. | សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌ | ២០២៤ | |
| ៣. | សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងនិងប្រមូលទ្រព្យសម្បត្តិត្រឡប់មកវិញ | ២០២៤ | |
| ៤. | សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសាលាជម្រះក្តីពាណិជ្ជកម្ម និង បទប្បញ្ញត្តិនីតិវិធីពាណិជ្ជកម្ម | ២០២៤ | |
| ៥. | សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសាលាជម្រះក្តីការងារ និងបទប្បញ្ញត្តិនីតិវិធីការងារ | ២០២៤ | |
| ៦. | សេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈសាការី | ២០២៤ | |
| ៧. | សេចក្តីព្រាងច្បាប់ស្តីពីកិច្ចការជំនួយផ្នែកច្បាប់ | ២០២៥ | |
| ៨. | សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មក្រមរដ្ឋប្បវេណី | ២០២៧ | |

| ល.រ | សេចក្តីព្រាងលិខិតបទដ្ឋានគតិយុត | សម្រាប់ឆ្នាំ | ផ្សេងៗ |
|---|---|---|---|
| ៩. | សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មក្រមនីតិវិធីរដ្ឋប្បវេណី | ២០២៧ | |
| ១០. | សេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈក្រឡាបញ្ជី | ២០២៤ | |
| ១១. | សេចក្តីព្រាងច្បាប់ស្តីពីច្បាប់ពាក់ព័ន្ធនឹងវិស័យរដ្ឋបាលតុលាការ សំដៅលើកកម្ពស់ | ២០២៤ | |
| ១២. | សេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈអាជ្ញាសាលា | ២០២៤ | |
| ១៣. | ប្រសិទ្ធភាពនៃការអនុវត្តតុលាការឌីជីថល | ២០២៤ | |
| ១៤. | សេចក្តីព្រាងច្បាប់ស្តីពីការចាត់ចែងជាបណ្តោះអាសន្ននូវវត្ថុចាប់យក | ២០២៤ | |
| ១៥. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការកែសម្រួលសមាសភាពគណៈកម្មការថ្នាក់ជាតិពិនិត្យ និង វាយតម្លៃបញ្ជីឈ្មោះទណ្ឌិតស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស | ២០២៤ | |
| ១៦. | សេចក្តីព្រាងអនុក្រឹត្យស្តីពីបែបបទ និងលក្ខខណ្ឌនៃការជ្រើសរើសមន្ត្រីជំនាញផ្នែកច្បាប់(មាត្រា៩ ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ) | ២០២៤ | |
| ១៧. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រង និងចាត់ចែងថវិកាសាលាជម្រះក្តី និងអយ្យការ អមសាលាជម្រះក្តី (មាត្រា៧៩ ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ) | ២០២៤ | |
| ១៨. | កិច្ចព្រមព្រៀងកិច្ចសហប្រតិបត្តិការនៃការយោគយល់គ្នាលើវិស័យរដ្ឋបាលតុលាការរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋកូរ៉េ | ២០២៤ | |
| ១៩. | កិច្ចព្រមព្រៀងវិសោធនកម្មសន្ធិសញ្ញាអាស៊ានស្តីពីការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ | ២០២៤ | |
| ២០. | សេចក្តីព្រាងសន្ធិសញ្ញាអាស៊ានស្តីពីបត្យាប័ន | ២០២៤ | |
| ២១. | កិច្ចព្រមព្រៀងសន្ធិសញ្ញា និងអនុសញ្ញាស្តីពីការផ្ទេរទណ្ឌិតរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតឡាវ | ២០២៤ | |

| ល.រ | សេចក្តីព្រាងលិខិតបទដ្ឋានគតិយុត | សម្រាប់ឆ្នាំ | ផ្សេងៗ |
|---|---|---|---|
| ២២. | សន្ធិសញ្ញា និងកិច្ចព្រមព្រៀងស្តីពីការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌរវាង ព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋឥណ្ឌា | ២០២៤ | |
| ២៣. | សន្ធិសញ្ញា និងកិច្ចព្រមព្រៀងស្តីពីការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋតួកគី | ២០២៤ | |
| ២៤. | សន្ធិសញ្ញា និងកិច្ចព្រមព្រៀងស្តីពីការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋបេឡារុស | ២០២៤ | |
| ២៥. | សន្ធិសញ្ញានិងអនុសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋឥណ្ឌា សន្ធិសញ្ញា និងអនុសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋតួកគី | ២០២៤ | |
| ២៦. | សន្ធិសញ្ញា និងអនុសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋ បេឡារុស | ២០២៤ | |
| ២៧. | សន្ធិសញ្ញា និងអនុសញ្ញាស្តីពីការផ្ទេរទណ្ឌិតរវាងព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋកូរ៉េ | ២០២៤ | |
| ២៨. | សន្ធិសញ្ញា និងអនុសញ្ញាស្តីពីការផ្ទេរទណ្ឌិតរវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជា ណាចក្របែលហ្ស៊ិក | ២០២៤ | |
| ២៩. | សន្ធិសញ្ញា និងអនុសញ្ញាស្តីពីការផ្ទេរទណ្ឌិតរវាងព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋតួកគី | ២០២៤ | |
| ៣០. | សន្ធិសញ្ញា និងអនសញ្ញាស្តីពីការផ្ទេរទណ្ឌិតរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប៉េរ៉ូ | ២០២៤ | |
| **១៧. ក្រសួងអធិការកិច្ច** | | | |
| ១. | សេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច | ២០២៤ | រង់ចាំសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអធិការកិច្ចចូលជាធរមាន |

| ល.រ | សេចក្ដីព្រាងលិខិតបទដ្ឋានគតិយុត | សម្រាប់ឆ្នាំ | ផ្សេងៗ |
|---|---|---|---|
| ២. | សេចក្ដីព្រាងច្បាប់ស្ដីពីបណ្ដឹងតវ៉ា | ២០២៧ | |
| ៣. | សេចក្ដីព្រាងច្បាប់ស្ដីពីបណ្ដឹងបរិហារ | ២០២៧ | |
| ៤. | សេចក្ដីព្រាងអនុក្រឹត្យស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអធិការកិច្ច | ២០២៤ | ត្រៀមដាក់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី |
| ៥. | សេចក្ដីព្រាងអនុក្រឹត្យស្ដីពីនីតិវិធីនៃការអនុវត្តសេចក្ដីសម្រេចលើលទ្ធផលអធិការកិច្ច | ២០២៤ | |
| ៦. | សេចក្ដីព្រាងអនុក្រឹត្យស្ដីពីស្លង់ដាអធិការកិច្ច | ២០២៤ | |
| ៧. | សេក្ដីព្រាងអនុក្រឹត្យស្ដីពីក្រមសីលធម៌វិជ្ជាជីវៈ និងក្រមប្រតិបត្តិមន្ត្រីអធិការកិច្ច | ២០២៤ | |
| ៨. | សេចក្ដីព្រាងអនុក្រឹត្យស្ដីពីអធិការកិច្ច | ២០២៥ | |
| ៩. | សេចក្ដីព្រាងអនុក្រឹត្យស្ដីពីភារកិច្ចនិងសិទ្ធិអំណាចរបស់ស្ថាប័នអធិការកិច្ច | ២០២៥ | |
| ១០. | សេចក្ដីព្រាងអនុក្រឹត្យស្ដីពីនីតិវិធីនៃការរៀបចំផែនការរួមស្ដីពីអធិការកិច្ច | ២០២៦ | |
| ១១. | សេចក្ដីព្រាងអនុក្រឹត្យស្ដីពីឯកសណ្ឋាន និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ច | ២០២៦ | |
| ១២. | សេចក្ដីព្រាងគោលនយោបាយជាតិស្ដីពីអធិការកិច្ច | ២០២៤ | |
| **១៨. ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍** | | | |
| ១. | សេចក្ដីព្រាងច្បាប់ស្ដីពីសេវាប្រៃសណីយ៍ | ២០២២-២០២៥ | |
| ២. | សេចក្ដីព្រាងច្បាប់ស្ដីពីសន្តិសុខសាយប័រ | ២០២២-២០២៥ | កំពុងស្ថិតក្នុងនីតិវិធីនៅទីស្ដីការគណៈរដ្ឋមន្ត្រី |
| ៣. | សេចក្ដីព្រាងច្បាប់ស្ដីពីកិច្ចការពារទិន្នន័យបុគ្គល | ២០២២-២០២៥ | |
| ៤. | សេចក្ដីព្រាងច្បាប់ស្ដីពីរដ្ឋាភិបាលឌីជីថល | ២០២២-២០២៥ | |

| ល.រ | សេចក្តីព្រាងលិខិតបទដ្ឋានគតិយុត | សម្រាប់ឆ្នាំ | ផ្សេងៗ |
|---|---|---|---|
| ៥. | សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីទូរគមនាគមន៍ | ២០២២-២០២៥ | |
| ៦. | សេចក្តីព្រាងច្បាប់ស្តីពីបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន | ២០២២-២០២៥ | |
| ៧. | សេចក្តីព្រាងច្បាប់ស្តីពីវលកវិទ្យុ | ២០២៤-២០២៧ | |
| ៨. | សេចក្តីព្រាងច្បាប់ស្តីពីសុវត្ថិភាពអនឡាញ | ២០២៤-២០២៧ | |
| ៩. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ (វិសោធនកម្មអនុក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៩) | ២០២២-២០២៤ | |
| ១០. | សេចក្តីព្រាងអនុក្រឹត្យស្តីពីពិន័យអន្តរការណ៍ក្នុងវិស័យទូរគមនាគមន៍ | ២០២២-២០២៤ | |
| ១១. | សេចក្តីព្រាងអនុក្រឹត្យស្តីពីគោលការណ៍នៃការបង្កើតអង្គភាពបដិវត្តកម្មឌីជីថលនៅតាមក្រសួង ស្ថាប័ន | ២០២៣-២០២៤ | |
| ១២. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការសន្តិសុខឌីជីថល | ២០២៣-២០២៤ | |
| ១៣. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសន្តិសុខសាយប័រកម្ពុជា | ២០២៣-២០២៤ | |
| ១៤. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រង ការសាងសង់ និងការប្រើប្រាស់ស្ថានីយផ្កាយ រណបលើដី | ២០២៤-២០២៦ | |
| ១៥. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងបណ្តាញខ្សែកាបអុបទិកក្រោមបាតសមុទ្រ | ២០២៥-២០២៦ | |
| ១៦. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការគ្រប់គ្រងប្រព័ន្ធមូលទិន្នន័យហេដ្ឋារចនា សម្ព័ន្ធរូបវន្តថ្នាក់ជាតិ | ២០២៦-២០២៨ | |
| ១៧. | សេចក្តីព្រាងអនុក្រឹត្យស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រី អធិការកិច្ចប្រៃសណីយ៍ | ២០២៥-២០២៦ | |
| ១៨. | សេចក្តីព្រាងអនុក្រឹត្យស្តីពីកម្មវិធី និងមូលនិធិកាតព្វកិច្ចសេវាប្រៃសណីយ៍សកល | ២០២៥-២០២៦ | |
| ១៩. | សេចក្តីព្រាងអនុក្រឹត្យស្តីពីពិន័យអន្តរការណ៍ពាក់ព័ន្ធនឹងបទល្មើសក្នុងវិស័យ ប្រៃសណីយ៍ | ២០២៥-២០២៦ | |
| ២០. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការដាក់ឱ្យប្រើថ្នាលដឹកជញ្ជូនបញ្ញើរួម | ២០២៥-២០២៦ | |
| **១៩. ក្រសួងសុខាភិបាល** | | | |

| ល.រ | សេចក្ដីព្រាងលិខិតបទដ្ឋានគតិយុត | សម្រាប់ឆ្នាំ | ផ្សេងៗ |
|---|---|---|---|
| ១. | សេចក្ដីព្រាងច្បាប់ស្ដីពីសុខភាពផ្លូវចិត្ត | | |
| ២. | សេចក្ដីព្រាងច្បាប់ស្ដីពីការគ្រប់គ្រងឱសថ (រៀបចំវិសោធនកម្មឡើងវិញ) | | |
| ៣. | សេចក្ដីព្រាងច្បាប់ស្ដីពីការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ | | |
| ៤. | សេចក្ដីព្រាងច្បាប់ស្ដីពីការគ្រប់គ្រងគ្រឿងសម្អាង | | |
| ៥. | សេចក្ដីព្រាងច្បាប់ស្ដីពីការត្រួតពិនិត្យផលិតផលគ្រឿងស្រវឹង | | |
| ៦. | សេចក្ដីព្រាងច្បាប់ស្ដីពីការគ្រប់គ្រងឈាម និងផលិតផលឈាម | | |
| ៧. | សេចក្ដីព្រាងច្បាប់ស្ដីពីសុខាភិបាលឌីជីថល | | |
| ៨. | សេចក្ដីព្រាងព្រះរាជក្រឹត្យស្ដីពីការបង្កើតគណៈវិជ្ជាជីវៈសុខភាពផ្លូវចិត្ត | | |
| ៩. | សេចក្ដីព្រាងព្រះរាជក្រឹត្យគាំទ្រដល់ការអនុវត្តច្បាប់គ្រប់គ្រងឱសថ | | |
| ១០. | សេចក្ដីព្រាងព្រះរាជក្រឹត្យគាំទ្រដល់ការអនុវត្តច្បាប់គ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ | | |
| ១១. | សេចក្ដីព្រាងព្រះរាជក្រឹត្យគាំទ្រដល់ការអនុវត្តច្បាប់គ្រប់គ្រងគ្រឿងសំអាង | | |
| ១២. | សេចក្ដីព្រាងអនុក្រឹត្យស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល (រៀបចំកែសម្រួលឡើងវិញ) | | |
| ១៣. | សេចក្ដីព្រាងអនុក្រឹត្យស្ដីពីការបង្កើតនាយកដ្ឋានសុខភាពផ្លូវចិត្ត និងការបំពានគ្រឿង ញៀន(រៀបចំកែសម្រួលឡើងវិញ) | | |
| ១៤. | សេចក្ដីព្រាងអនុក្រឹត្យស្ដីពីមន្ទីរពេទ្យព្យាបាលជំងឺរបេង របស់មជ្ឈមណ្ឌលជាតិកំចាត់ រោគរបេងនិងហង់សិនប្រែក្លាយទៅជាមន្ទីរពេទ្យជាតិព្យាបាលជំងឺសួត និងផ្លូវដង្ហើម | | |
| ១៥. | សេចក្ដីព្រាងអនុក្រឹត្យស្ដីពីការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្របូរាណ | | |

| ល.រ | សេចក្តីព្រាងលិខិតបទដ្ឋានគតិយុត | សម្រាប់ឆ្នាំ | ផ្សេងៗ |
|---|---|---|---|
| ១៦. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងការផ្តល់សេវាសុខាភិបាលតាមបែបវេជ្ជសាស្ត្រ បូរាណ | | |
| ១៧. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការអនុវត្តវិធានការចំពោះការតាំងលក់បារីវាយ | | |
| ១៨. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការចែកចាយ ការលក់ និងទីកន្លែងលក់ផលិតផលថ្នាំជក់ | | |
| ១៩. | សេចក្តីព្រាងអនុក្រឹត្យស្តីពីប្រាក់ពិន័យអន្តរការណ៍ចំពោះអំពើល្មើសនឹងច្បាប់ស្តីពីការ ត្រួតពិនិត្យផលិតផលថ្នាំជក់នៅកម្ពុជា | | |
| ២០. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតមូលនិធិសុខភាពត្រួតពិនិត្យផលិតផលថ្នាំជក់ | | |
| ២១. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិសុខភាពត្រួតពិនិត្យ ផលិតផលថ្នាំជក់សម្រាប់ការប្រយុទ្ធប្រឆាំងនឹងការប្រើប្រាស់ផលិតផលថ្នាំជក់ | | |
| ២២. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការកែសម្រួលមាត្រា៧ នៃអនុក្រឹត្យលេខ១៤៩ អនក្រ.បកចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥ ស្តីពីការបោះពុម្ពសារព្រមានសុខភាពជាភាសាខ្មែរ | | |
| ២៣. | សេចក្តីព្រាងអនុក្រឹត្យស្តីពីវិធានការហាមការផ្សព្វផ្សាយពាណិជ្ជកម្ម ការលើកកម្ពស់ការ លក់និងឧបត្ថម្ភកម្មវិធីដោយឧស្សាហកម្មគ្រឿងស្រវឹងនិងជារូបភាពលើកញ្ចប់ផលិតផលថ្នាំជក់ | | |
| ២៤. | សេចក្តីព្រាងអនុក្រឹត្យស្តីពីនីតិវិធីសម្រាប់ផ្តល់លិខិតមូលហេតុនៃមរណភាព (មរណ ភាពបណ្តាលមកពីគ្រោះមហន្តរាយធម្មជាតិ ឬគ្រោះអាសន្នទ្រង់ទ្រាយធំ) | | |
| ២៥. | សេចក្តីព្រាងអនុក្រឹត្យគាំទ្រដល់ការអនុវត្តច្បាប់គ្រប់គ្រងឱសថ | | |
| ២៦. | សេចក្តីព្រាងអនុក្រឹត្យគាំទ្រដល់ការអនុវត្តច្បាប់គ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ | | |
| ២៧. | សេចក្តីព្រាងអនុក្រឹត្យគាំទ្រដល់ការអនុវត្តច្បាប់គ្រប់គ្រងគ្រឿងសំអាង | | |

## ២០. ក្រសួងសាធារណការ និងដឹកជញ្ជូន

| ល.រ | សេចក្តីព្រាងលិខិតបទដ្ឋានគតិយុត | សម្រាប់ឆ្នាំ | ផ្សេងៗ |
| --- | --- | --- | --- |
| ១. | សេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធទឹកកង្វក់ | ២០២៣-២០២៨ | ត្រៀមដាក់ប្រជុំគណៈរដ្ឋមន្ត្រី |
| ២. | សេចក្តីព្រាងច្បាប់ស្តីពីការដឹកជញ្ជូនតាមផ្លូវទឹក | ២០២៣-២០២៨ | ចប់គណៈរដ្ឋមន្ត្រី ២៦/មករា/២០២៤ ចូលជាធរមាន |
| ៣. | សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រង និងអភិវឌ្ឍន៍ភស្តុភារកម្មណៈរដ្ឋមន្ត្រី ២៦/មករា/២០២៤ ចប់គណៈរដ្ឋ | ២០២៣-២០២៨ | |
| ៤. | សេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ | ២០២៣-២០២៨ | |
| ៥. | សេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពីផ្លូវថ្នល់ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៤ | ២០២៣-២០២៨ | |
| ៦. | សេចក្តីព្រាងច្បាប់ស្តីពីផ្លូវដែក | ២០២៣-២០២៨ | |
| ៧. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងលើការប្រើប្រាស់ដីចំណីផ្លូវនៅតាមបណ្តាញផ្លូវថ្នល់ | ២០២៣-២០២៨ | |
| ៨. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងផ្លូវឆ្លងកាត់និងដីចំណីផ្លូវដែកត្រៀមដាក់ប្រជុំគណៈរដ្ឋមន្ត្រី | ២០២៣-២០២៨ | |
| ៩. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការកែសម្រួលអនុក្រឹត្យលេខ៨៦ អនក្រ.បក ចុះថ្ងៃទី៨ ខែ កក្កដា ឆ្នាំ២០១៥ ស្តីពីការកំណត់ល្បឿនសម្រាប់យានជំនិះ | ២០២៣-២០២៨ | |
| ១០. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការកែសម្រួលអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៣ខែតុលា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន | ២០២៣-២០២៨ | |
| ១១. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការកែសម្រួលអនុក្រឹត្យលេខ១៤១ អនក្រ.បក ចុះថ្ងៃទី៣១ ១១ ខែសីហា ឆ្នាំ ២០០៩ ស្តីពីការបង្កើតគណៈកម្មការដឹកនាំត្រួតពិនិត្យយានយន្តដឹកជញ្ជូន លើសទម្ងន់កំណត់ | ២០២៣-២០២៨ | |
| ១២. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងគ្រឿងចក្រគ្រប់ប្រភេទនៅព្រះរាជាណាចក្រកម្ពុជា | ២០២៣-២០២៨ | |
| ១៣. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងឋបនីយភណ្ឌផែ | ២០២៣-២០២៨ | |

| ល.រ | សេចក្តីព្រាងលិខិតបទដ្ឋានគតិយុត | សម្រាប់ឆ្នាំ | ផ្សេងៗ |
|---|---|---|---|
| ១៤. | សេចក្តីព្រាងអនុក្រឹត្យស្តីពីមុខងារផ្លូវថ្នល់ និងចំណាត់ថ្នាក់ផ្លូវថ្នល់ | ២០២៣-២០២៨ | |
| **២១. ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ** | | | |
| ១. | សេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ | | |
| ២. | សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល | | |
| ៣. | សេចក្តីព្រាងអនុក្រឹត្យលេខ៩៨ អនក្រ.បក ចុះថ្ងៃទី១០ ខែកញ្ញាឆ្នាំ២០០២ ស្តីពីការអនុវត្តកិច្ចការពារបេតិកភណ្ឌវប្បធម៌ | | |
| ៤. | សេចក្តីព្រាងអនុក្រឹត្យលេខ៩៨ អនក្រ.បក ចុះថ្ងៃទី១០ ខែកញ្ញាឆ្នាំ២០០២ ស្តីពីការអនុវត្តកិច្ចការពារបេតិកភណ្ឌវប្បធម៌ | | |
| ៥. | សេចក្តីព្រាងអនុក្រឹត្យស្តីពីទិវាជាតិអ្នកនិពន្ធ | | |
| ៦. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មការជាតិយូណេស្កូកម្ពុជា | | |
| **២២. ក្រសួងកិច្ចការនារី** | | | |
| ១. | សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និង កិច្ចការពារជនរងគ្រោះ | ២០២៣-២០២៨ | |
| ២. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកិច្ចការនារី | ២០២៣-២០២៨ | |
| ៣. | សេចក្តីព្រាងអនុក្រឹត្យស្តីពីរូបសញ្ញារបស់ក្រសួងកិច្ចការនារី | ២០២៣-២០២៨ | |
| ៤. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី | ២០២៣-២០២៨ | |
| ៥. | សេចក្តីព្រាងគោលនយោបាយជាតិស្តីពីសមភាពយេនឌ័រឆ្នាំ២០២៤-២០៣៤ | ២០២៣-២០២៨ | |

| ល.រ | សេចក្តីព្រាងលិខិតបទដ្ឋានគតិយុត | សម្រាប់ឆ្នាំ | ផ្សេងៗ |
|---|---|---|---|
| ៦. | សេចក្តីព្រាងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីលើកទី៤ | ២០២៣-២០២៨ | |
| **២៣. ក្រសួងទេសចរណ៍** | | | |
| ១. | សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីទេសចរណ៍ | ២០២៣-២០២៦ | |
| ២. | សេចក្តីព្រាងច្បាប់ស្តីពីអេកូទេសចរណ៍ | ២០២៣-២០២៨ | |
| ៣. | សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/០៦១១/៦១៤ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត | ២០២៣-២០២៤ | |
| ៤. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការកែសម្រួលអនុក្រឹត្យលេខ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍ | ២០២៣-២០២៤ | |
| ៥. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការកែសម្រួលអនុក្រឹត្យលេខ១៤៨ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសាលាវិជ្ជាជីវៈទេសចរណ៍ ទៅ ជាអនុក្រឹត្យស្តីពីការបង្កើតសាលាវិជ្ជាជីវៈទេសចរណ៍ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល | ២០២៣-២០២៤ | |
| ៦. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការកែសម្រួលអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៤ ស្តីពីការផ្តល់ចំណាត់ថ្នាក់សណ្ឋាគារនិងសេវាកម្មស្នាក់នៅទេសចរណ៍ | ២០២៣-២០២៤ | |
| ៧. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការកែសម្រួលអនុក្រឹត្យលេខ១៩១ អនក្រ.បក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ ស្តីពីមគ្គុទេសក៍ទេសចរណ៍ | ២០២៣-២០២៤ | |
| ៨. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការកែសម្រួលអនុក្រឹត្យលេខ១៩៩ អនក្រ.បក ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីឯកសណ្ឋាន សញ្ញាសក្តិ និងសញ្ញាសម្គាល់របស់មន្ត្រីអគ្គាធិការដ្ឋានទេសចរណ៍ | ២០២៣-២០២៤ | |

| ល.រ | សេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត | សម្រាប់ឆ្នាំ | ផ្សេងៗ |
|---|---|---|---|
| ៩. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការកែសម្រួលអនុក្រឹត្យលេខ៥៧ អនក្រ.បក ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាភិបាលសិក្សា ទីផ្សារនិងផ្សព្វផ្សាយទេសចរណ៍កម្ពុជា | ២០២៣-២០២៤ | អនុក្រឹត្យលេខ២៥ អនក្រ.បក ចុះថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៤ |
| ១០. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការកែសម្រួលអនុក្រឹត្យលេខ១៩១ អនក្រ.បក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ | ២០២៣-២០២៤ | |
| ១១. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការកែសម្រួលអនុក្រឹត្យលេខ៤០ អនក្រ.បក ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៩ ស្តីពីតំបន់ទេសចរណ៍ពិសិដ្ឋ | ២០២៣-២០២៤ | |
| ១២. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតពានរង្វាន់ពិសេសសម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍ | ២០២៣-២០២៤ | |
| ១៣. | សេចក្តីព្រាងអនុក្រឹត្យស្តីពីចាត់ចែងនិងគ្រប់គ្រងមូលនិធិអេកូទេសចរណ៍ | ២០២៣-២០២៦ | |
| ១៤. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសហគមន៍ទេសចរណ៍និង អេកូទេសចរណ៍ | ២០២៣-២០២៦ | |
| ១៥. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការដោះស្រាយវិវាទទេសចរណ៍ | ២០២៣-២០២៦ | |
| ១៦. | សេចក្តីព្រាងគោលនយោបាយស្តីពីទេសចរណ៍ពិសិដ្ឋ | ២០២៣-២០២៤ | |
| ១៧. | សេចក្តីព្រាងអនុក្រឹត្យមួយចំនួនគាំទ្រគោលនយោបាយស្តីពីទេសចរណ៍ពិសិដ្ឋ | ២០២៣-២០២៤ | |
| **២៤. ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ** | | | |
| ១. | សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការងារ | | |
| ២. | សេចក្តីព្រាងច្បាប់ស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ | | |
| ៣. | សេចក្តីព្រាងច្បាប់ស្តីពីសុវត្ថិភាពនិងសុខការងារ | | |
| ៤. | សេចក្តីព្រាងច្បាប់ស្តីពីទេសន្តរប្រវេសន៍ការងារ | | |

| ល.រ | សេចក្តីព្រាងលិខិតបទដ្ឋានគតិយុត | សម្រាប់ឆ្នាំ | ផ្សេងៗ |
|---|---|---|---|
| ៥. | សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនាំការអនុវត្តផ្នែកប្រាក់ សោធនសម្រាប់បុគ្គលនៃវិស័យសាធារណៈ | | |
| ៦. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាធនាភិបាលសន្តិសុខសង្គមនៃបេឡាជាតិសន្តិសុខសង្គម | | |
| ៧. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងថវិកា ហិរញ្ញវត្ថុ និងគណនេយ្យនៃបេឡាជាតិ សន្តិសុខសង្គម | | |
| ៨. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការពង្រីកវិសាលភាពរបបសន្តិសុខសង្គម ផ្នែកហានិភ័យ ការងារ និងផ្នែកថែទាំសុខភាពសម្រាប់បុគ្គលដែលស្ថិតនៅក្នុងវិស័យសាធារណៈ | | |
| ៩. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការតែងតាំងក្រុមប្រឹក្សាភិបាលនៃបេឡាជាតិសន្តិសុខសង្គម អាណត្តិទី២ | | |
| ១០. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការកែសម្រួលសមាសភាពគណៈកម្មការអន្តរក្រសួងសម្រាប់ ដឹកនាំ ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរនិង ការងារ ឆ្នាំ២០១៥-២០២៥ | | |
| ១១. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងហត្ថពលកម្មបរទេស | | |
| ១២. | សេចក្តីព្រាងគោលនយោបាយជាតិស្តីពីទេសន្តរប្រវេសន៍ការងារ | | |
| ១៣. | សេចក្តីព្រាងគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំ២០១៧-២០២៥ | | |
| ១៤. | សេចក្តីព្រាងគោលនយោបាយស្តីពីសុវត្ថិភាពនិងសុខភាពការងារ | | |
| ១៥. | សេចក្តីព្រាងបច្ចុប្បន្នភាពគោលនយោបាយជាតិស្តីពីមុខរបរនិងការងារ | | |
| **២៥. ក្រសួងមុខងារសាធារណៈ** | | | |
| ១. | សេចក្តីព្រាងច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល | ២០២៥-២០២៧ | |

| ល.រ | សេចក្តីព្រាងលិខិតបទដ្ឋានគតិយុត | សម្រាប់ឆ្នាំ | ផ្សេងៗ |
|---|---|---|---|
| ២. | សេចក្តីព្រាងច្បាប់ស្តីពីសេវាសាធារណៈ | ២០២៥-២០២៧ | |
| ៣. | សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃអង្គសុខាភិបាល | ២០២៤-២០២៥ | |
| ៤. | សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃអង្គអប់រំ | ២០២៤-២០២៥ | |
| ៥. | សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃអង្គរដ្ឋបាល | ២០២៥-២០២៦ | |
| ៦. | សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃអង្គបច្ចេកទេស | ២០២៥-២០២៦ | |
| ៧. | សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃអង្គការទូត | ២០២៥-២០២៦ | |
| ៨. | សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីរាជការស៊ីវិល | ២០២៤ | |
| ៩. | សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីក្រមប្រតិបត្តិមន្ត្រីរាជការស៊ីវិល | ២០២៤-២០២៥ | លេខ៣៧ អនក្រ.បក ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៤ |
| ១០. | សេចក្តីព្រាងអនុក្រឹត្យស្តីពីគុណវុឌ្ឍិវិជ្ជាជីវៈមន្ត្រីធនធានមនុស្ស | ២០២៥-២០២៦ | |
| ១១. | សេចក្តីព្រាងអនុក្រឹត្យស្តីពីគុណវុឌ្ឍិមុខតំណែងគ្រប់គ្រង | ២០២៥-២០២៦ | |
| ១២. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការកែប្រែតម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រី រាជការនៃព្រះរាជាណាចក្រកម្ពុជា | ២០២៥-២០២៨ | |
| ១៣. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការដំឡើងប្រាក់កម្រៃប្រចាំខែជូនមន្ត្រីជាប់កិច្ចសន្យា | ២០២៥-២០២៨ | |
| ១៤. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការកែប្រែនិងការដំឡើងប្រាក់បំណាច់មុខងារមន្ត្រីរាជការស៊ីវិល | ២០២៥-២០២៨ | |
| ១៥. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការកែប្រែនិងការដំឡើងប្រាក់បំណាច់មុខងារយោធិននៃកងយោធពលខេមរភូមិន្ទ | ២០២៥-២០២៨ | |
| ១៦. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការកែប្រែនិងការដំឡើងប្រាក់បំណាច់មុខងារមន្ត្រីនគរបាលជាតិកម្ពុជា | ២០២៥-២០២៨ | |
| ១៧. | សេចក្តីព្រាងអនុក្រឹត្យស្តីពីការកែប្រែនិងការដំឡើងប្រាក់បំណាច់មុខងារមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ | ២០២៥-២០២៨ | |

| ល.រ | សេចក្ដីព្រាងលិខិតបទដ្ឋានគតិយុត | សម្រាប់ឆ្នាំ | ផ្សេងៗ |
|---|---|---|---|
| ១៨. | សេចក្ដីព្រាងអនុក្រឹត្យស្ដីពីការដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែចំពោះសមាជិកក្រុមប្រឹក្សា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មន្ត្រីភូមិ និងការិយាល័យប្រជាពលរដ្ឋ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ | ២០២៥-២០២៨ | |
| ១៩. | សេចក្ដីព្រាងអនុក្រឹត្យស្ដីពីការផ្ដល់ប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីចូលឆ្នាំថ្មីប្រពៃណីជាតិ និងពិធីបុណ្យភ្ជុំបិណ្ឌ | ២០២៥-២០២៨ | |
| ២០. | សេចក្ដីព្រាងអនុក្រឹត្យស្ដីពីការដាក់ឱ្យអនុវត្តនិយាមនីតិវិធីប្រតិបត្តិសម្រាប់ការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិល | ២០២៤ | ចូលជាធរមាន |
| ២១. | សេចក្ដីព្រាងអនុក្រឹត្យស្ដីពីការប្រឡងប្រជែងជ្រើសរើសមន្ត្រីបច្ចេកទេស | ២០២៤ | |
| ២២. | សេចក្ដីព្រាងអនុក្រឹត្យស្ដីពីការរៀបចំការពិពណ៌នាមុខតំណែងសម្រាប់មន្ត្រីរាជការស៊ីវិលនៃក្រសួង ស្ថាប័នថ្នាក់ជាតិ | ២០២៤-២០២៥ | |
| ២៣. | សេចក្ដីព្រាងអនុក្រឹត្យស្ដីពីការដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម | ២០២៤-២០២៥ | |

## ឧបសម្ព័ន្ធ ៦. ជំនួយស្មារតីទាក់ទងនឹងការកសាងប្រព័ន្ធច្បាប់កម្ពុជា

### ១.១. សារគន្លឹះអំណាន់អភិក្រមប្រព័ន្ធច្បាប់កម្ពុជា

ផ្អែកតាមក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល បានកំណត់ចក្ខុវិស័យថា *«ជានាស្ថិរភាពនិងចីរភាពនៃការកសាងរដ្ឋមួយដែលរឹងមាំ ឯករាជ្យ អធិបតេយ្យ ប្រជាធិបតេយ្យ សេរីពហុបក្ស គោរពសិទ្ធិ សេរីភាព និងសេចក្ដីថ្លៃថ្នូររបស់មនុស្ស សមធម៌និងយុត្តិធម៌ក្នុងសង្គម វប្បធម៌ចុំថ្កើងរុងរឿង និងប្រព័ន្ធសេដ្ឋកិច្ចទីផ្សាររជឿនលឿន សុខុមាលភាពពលរដ្ឋ នាយុគសម័យបច្ចេកវិទ្យាទំនើប»* និងកំណត់បេសកកម្មរបស់គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ថា *«ដឹកនាំ និងសម្របសម្រួលការកែទម្រង់ច្បាប់កម្ពុជា ឱ្យទៅជាប្រព័ន្ធច្បាប់មួយដែលមានឯកភាព ប្រសិទ្ធភាព សមានគតិភាព ឧត្តមានុភាពគតិយុត្ត និងសន្តិសុខគតិយុត្ត ស្របតាមឧត្តមានុវត្តន៍អន្តរជាតិ និងបរិការណ៍កម្ពុជា»*។

តាមរយៈខ្លឹមសារនៃចក្ខុវិស័យនេះ គេអាចកំណត់ដោយសង្ខេបថា *«ចក្ខុវិស័យនៃកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល គឺដើម្បីកសាងរដ្ឋនិងជាតិមួយរឹងមាំ និងមានភាពធន់ តាមរយៈការកែទម្រង់ច្បាប់»* រីឯបេសកកម្មរបស់គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់វិញ គេអាចកំណត់បានថា *«ការដឹកនាំកែទម្រង់ច្បាប់កម្ពុជា ជាយន្តការឆ្ពោះទៅរកបូរណភាពនៃប្រព័ន្ធច្បាប់»* ដោយត្រូវបំពេញលក្ខខ័ណ្ឌគន្លឹះចំនួន ៥ រួមមាន (១) ឯកភាព (២) ប្រសិទ្ធភាព (៣) សមានគតិភាព (៤) ឧត្តមានុភាពគតិយុត្ត និង (៥) សន្តិសុខគតិយុត្ត។

## ១.១.១ តារាងម៉ាទ្រិចនៃការរៀបចំអក្ខរអភិក្រមប្រព័ន្ធច្បាប់

| អក្ខរ | អភិក្រម | ទ្រឹស្តីប្រព័ន្ធ | ខណ្ឌនៃច្បាប់ | គោលគំនិតនៃធាតុផ្សំប្រព័ន្ធច្បាប់ | បេសកកម្ម (=) | ខ្លឹមសារ |
|---|---|---|---|---|---|---|
| ស១ | សច្ចាធិដ្ឋាន (ឆន្ទៈនយោបាយ)<br>Policy Commitment | វិភាគបរិស្ថាន<br>PESTLE | ការផ្តួចផ្តើមគំនិត | បរិស្ថាន<br>Environment | ចក្ខុវិស័យ បង្កើតបានបេសកកម្មខាងក្រោមៈ | - ការសច្ចា និងការប្តេជ្ញាចិត្តផ្នែកឆន្ទៈនយោបាយ ឆ្ពោះទៅសម្រេចឱ្យបាននូវបូរណភាពនៃប្រព័ន្ធច្បាប់កម្ពុជា និងវប្បធម៌នីតិរដ្ឋ |
| | | ធាតុចូល<br>Inputs | ការពិគ្រោះយោបល់ និងការវាយតម្លៃ<br>(Consultation & RIA) | គុណតម្លៃគ្រឹះ (មូលដ្ឋាន)<br>Foundational Ethos | | |
| ស២ | សុខដុមនីយកម្ម<br>Harmonization/Uniformity | ដំណើរការ<br>Processes | ការតាក់តែងបទប្បញ្ញត្តិ | - សារជាតុគតិយុត្ត<br>- រចនាសម្ព័ន្ធគតិយុត្ត<br>- វប្បធម៌គោរពច្បាប់ | ឯកភាព | - ច្បាប់ជាតិ និងច្បាប់អន្តរជាតិ<br>- សម្រក (Deregulation)<br>- សម្រាំង (Better Regulation)<br>- បទប្បញ្ញត្តិល្អ (WTO's GRP)<br>- ធ្វើឱ្យប្រព័ន្ធច្បាប់មានឯកភាពគ្នា |
| ស៣ | ស័ក្តិសិទ្ធិភាព<br>Efficiency | សមិទ្ធផល<br>Outputs | អនុម័ត និងប្រកាសឱ្យប្រើបទប្បញ្ញត្តិ | - លទ្ធផលច្បាប់<br>- លទ្ធផលស្ថាប័ន<br>- ឧបករណ៍គតិយុត្តិ | ប្រសិទ្ធភាព | - សម្រួល (Governance & Digitalization)<br>- ច្បាប់មានគុណភាពខ្ពស់<br>- វប្បធម៌គោរពច្បាប់ |
| ស៤ | សមានគតិភាព<br>Consistency/Coherence | ផលសម្រេច<br>Outcomes | ការអនុវត្ត និងលទ្ធផលនៃការអនុវត្ត | - សណ្តាប់ធ្នាប់សាធារណៈ<br>- សន្តិភាព និងស្ថិរភាព<br>- ប្រសិទ្ធភាព | សមានគតិភាព | - ស៊ីចង្វាក់គ្នា<br>- ស្របគ្នា<br>- សង្គតិភាព<br>- អភិបាលកិច្ច និងការអភិវឌ្ឍន៍ |
| ស៥ | សុនីត្យានុភាព<br>Legal Supremacy | ផលប៉ះពាល់<br>Impacts | ប្រសិទ្ធផល | - តម្លាភាព ស្មើភាព យុត្តិធម៌<br>- ប្រព័ន្ធច្បាប់បរិបូរណ៍<br>- នីតិរដ្ឋ | ឧត្តមានុភាពគតិយុត្ត | - បូរណភាពនៃប្រព័ន្ធច្បាប់កម្ពុជា<br>- វប្បធម៌នីតិរដ្ឋ<br>- ជាតិរឹងមាំ និងសេដ្ឋកិច្ចរីកចម្រើន |
| ស៦ | សន្តិសុខគតិយុត្ត<br>Legal Security | ព័ត៌មានត្រឡប់<br>Feedback | ការវាយតម្លៃឡើងវិញ និងការកែលម្អ | - យន្តការវាយតម្លៃ<br>- ឧបករណ៍វាយតម្លៃបទប្បញ្ញត្តិ | សន្តិសុខគតិយុត្ត | - ភាពច្បាស់លាស់ ស្ថិរភាព និងអាចប៉ាន់ប្រមាណទុកជាមុនបាន ដើម្បីកសាងជំនឿទុកចិត្ត និងស្ថិរភាពយូរអង្វែង |

## ១.២. គុណតម្លៃស្នូល

ជាក់ស្តែង កម្ពុជាធ្លាប់ត្រូវបានល្បីទូទាំងសកលលោកថាជាវាលពិឃាត បានប្រែក្លាយខ្លួនទៅប្រទេសឯករាជ្យ ដែលមានសន្តិភាព ស្ថិរភាពនយោបាយ មាននីតិរដ្ឋ ស្របតាមគោលការណ៍រដ្ឋធម្មនុញ្ញជាប្រទេសដែលប្រកាន់យករបបដឹកនាំតាមបែបលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ដែលអាចធានាអះអាងនូវសេរីភាពពេញបរិបូរណ៍របស់ពលរដ្ឋក្នុងការអនុវត្តសិទ្ធិសេរីភាព និងករណីកិច្ចរបស់ខ្លួននៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ។ ក្រោយពីទទួលបានលទ្ធផលនៃនយោបាយឈ្នះៗរបស់រាជរដ្ឋាភិបាលកម្ពុជាបានសមាហរណកម្មពេញលក្ខណៈ ក្នុងការគ្រប់គ្រងកម្ពុជាបានដើរតួនាទីយ៉ាងសំខាន់លើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធការកសាងធនធានមនុស្ស និងការសម្រេចបាននូវស្ថិរភាពនៃកំណើនសេដ្ឋកិច្ច ដែលកើតចេញពីវិស័យកសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម និងបានត្រៀមខ្លួនរួចជាស្រាច់ក្នុងការសម្រេចចង្ខុវិស័យឆ្នាំ២០៥០ក្លាយខ្លួនជាប្រទេសមានប្រាក់ចំណូលកម្រិតខ្ពស់។

### ១.២.១ សន្តិសុខជាតិ

- **<u>ការពារជាតិ</u>** ដែនអធិបតេយ្យជាតិៈ ផ្តោតការយកចិត្តទុកដាក់លើយុទ្ធសាស្ត្រ និងវិធានការចាំបាច់មួយចំនួន ដើម្បីប្រឆាំងនឹងបដិវត្តន៍ពណ៌ អំពើភេរវកម្ម ឧក្រិដ្ឋកម្មឆ្លងដែន ឧក្រិដ្ឋកម្មព័ត៌មានវិទ្យា ការគំរាមកំហែងចំពោះអធិបតេយ្យភាព និងបូរណភាពទឹកដី
- **<u>ឯកភាពជាតិ និងសាមគ្គីភាព</u>**ៈ ការធានាបាននូវការរួមគ្នាកសាងជាតិ ដើម្បីបម្រើទៅដលឧត្តមប្រយោជន៍ជាតិ និងប្រជាជន ទប់ស្កាត់នឹងឧបាយកលនានាក្នុងគោលបំណងធ្វើបដិវត្តន៍ពណ៌ ការធ្វើរដ្ឋប្រហារផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ ពង្រឹងសាមគ្គីភាពគ្រប់គណបក្សនយោបាយ
- **<u>ស្ថិរភាព</u>**ៈ ការពារ និងទប់ស្កាត់ បានទាន់ពេលវេលា និងមានប្រសិទ្ធភាព លើការប៉ុនប៉ងបង្កអស្ថិរភាពគ្រប់រូបភាពក្នុងគោលបំណងបំផ្លាញនូវរាល់សមិទ្ធផលនានាដែលកម្ពុជាសម្រេចបានយ៉ាងលំបាក។ ការពង្រឹងការអនុវត្តយ៉ាងតឹងរឹងនូវរដ្ឋធម្មនុញ្ញ ដែលផ្តោតជាពិសេសលើលទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស និងស្ថិរភាពនយោបាយ
- **<u>សន្តិសុខសង្គមៈ</u>** ការរស់នៅប្រកបដោយសុខដុមនីយកម្ម គ្មានការគំរាមកំហែង ការរំលោភបំពានសិទ្ធិសេរីភាព ការរស់នៅប្រកបដោយសុខសុវត្ថិភាពនៅក្នុងភូមិឃុំ ការចូលរួមពីអាជ្ញាធរមូលដ្ឋានមានភាពសកម្ម ធានាបាននូវការអនុវត្តច្បាប់ប្រកបដោយយុត្តិធម៌
- **<u>គោលនយោបាយការបរទេសៈ</u>** ផ្តោតការយកចិត្តទុកដាក់លើគោលជំហរដោះស្រាយបញ្ហាតាមបែបការទូត និងផ្លូវច្បាប់ ការពង្រឹងយន្តការទំនាក់ទំនងទ្វេភាគី និងត្រីភាគី កសាងកិច្ចសហប្រតិបត្តិការដ៏ល្អជាមួយបណ្តាប្រទេសជាច្រើននៅក្នុងសកលលោក ដើរតួនាទីកាន់តែសកម្ម និងសំខាន់ក្នុងកិច្ចការតំបន់ និងសកលដោយស្មើភាព ស្មើសិទ្ធិព្រំទាំងទទួលបានទំនុកចិត្ត និងការគាំទ្រលើឆាកអន្តរជាតិក្នុងជំរុញរបៀបវារៈសន្តិភាព និងសន្តិសុខ។

- **<u>សន្តិសុខសាយប័រ៖</u>** ការពង្រឹងប្រព័ន្ធការពារទូរគមនាគមន៍ឱ្យមានភាពរឹងមាំ រក្សាបាននូវការសម្ងាត់នានារបស់ជាតិ រៀបចំរចនាសម្ព័ន្ធនៃប្រព័ន្ធគ្រប់គ្រងទិន្នន័យដោយរក្សាទុកក្នុងលក្ខណៈសុវត្ថិភាព និងជាប្រចាំ ការគ្រប់គ្រងហានិភ័យដោយប្រសិទ្ធភាព អនុវត្តយន្តការត្រួតពិនិត្យប្រកបភាពច្បាស់លាស់និងមានការទទួលខុសត្រូវខ្ពស់ បង្កើតមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យ និងស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្មដោយតម្កល់ទំនុកប្រជាជន និងជាតិជាអាទិភាពចំបង
- **<u>សន្តិសុខថាមពល៖</u>** ការរក្សាបាននូវទំនិញជាយន្តសាស្ត្ររួមមាន ថាមពលអគ្គិសនី ប្រេងឥន្ទនៈ ឧស្ម័ន, ការបន្តរក្សាលំនឹងថ្លៃ និងពិនិត្យលទ្ធភាពនៃការបញ្ចុះតម្លៃ ជំរុញការប្រើប្រាស់ឡើងវិញឱ្យអស់ពីលទ្ធភាព
- **<u>ការត្រៀមលក្ខណៈសម្រាប់គ្រោះមហន្តរាយ៖</u>** ការយកចិត្តទុកដាក់រៀបចំឱ្យមានជាប្រព័ន្ធរួមក្នុងការប្រកាសអាសន្ន ការធានាបាននូវទីទួលសុវត្ថិភាពសម្រាប់ប្រជាពលរដ្ឋក្នុងគ្រាមានអាសន្ន រក្សាបាននូវលក្ខណៈសម្បត្តិគ្រប់គ្រាន់នូវវត្ថុមានជំនួយជាសម្ភារៈសង្គ្រោះ ត្រៀមបង្ការ បន្សាំ កាត់បន្ថយគ្រោះថ្នាក់មុនពេលមានគ្រោះមហន្តរាយដែលបង្កឡើងដោយគ្រោះធម្មជាតិ ឬមនុស្ស ការត្រៀមលក្ខណៈក្នុងការស្តារឡើងវិញក្រោយពេលមានគ្រោះមហន្តរាយ។
- **សុវត្ថិភាព** (Safety Needs)៖ តម្រូវការសម្រាប់ការការពារពីគ្រោះថ្នាក់ ការរំលោភបំពាន និងអស្ថិរភាព

នៅកម្រិតនេះ តម្លៃស្នូលរួមមាន សន្តិសុខ យុត្តិធម៌ និងសណ្តាប់ធ្នាប់។ ប្រទេសដែលសង្កត់ធ្ងន់លើសុវត្ថិភាព តែងតែកសាងរបបដឹកនាំដ៏រឹងមាំ និងការពារពលរដ្ឋពីអំពើហិង្សា អំពើពុករលួយ និងអស្ថិរភាពសង្គម។

### ១.២.២ នីតិរដ្ឋ

តម្រូវការទំនាក់ទំនងសង្គម The need for social connection and meaningful relationships.

- **<u>កែលម្អប្រព័ន្ធច្បាប់ និងមានភាពច្បាស់លាស់៖</u>** ពង្រឹង និងកែសម្រួលច្បាប់ដើម្បីធានាគោលការណ៍នីតិរដ្ឋត្រូវបានអនុវត្តដោយភាពច្បាស់លាស់ និងងាយស្រួលសម្រាប់អាជ្ញាធរ និងពលរដ្ឋ, ផ្តល់ឯកសារច្បាប់ច្បាស់លាស់ និងស្របតាមស្តង់ដាអន្តរជាតិ ដើម្បីកាត់បន្ថយការភ័ន្តច្រលំ និងការរើសអើងក្នុងការអនុវត្តច្បាប់
- **<u>នីត្យានុកូលភាព៖</u>** ការគោរពច្បាប់ជាតិ និងអន្តរជាតិ ស្របតាមអនុសញ្ញា សន្ធិសញ្ញា កតិកាសញ្ញា អន្តរជាតិ
- **<u>បង្កើនសមត្ថភាព និងឯករាជ្យភាពនៃស្ថាប័នតុលាការ៖</u>** ជំរុញឱ្យមានការបង្រៀនការបណ្តុះបណ្តាលមន្ត្រីសាធារណៈ និងតុលាការ ដើម្បីកែលម្អការអនុវត្តច្បាប់ដោយគ្មានការរើសអើង, លើកកម្ពស់ឯករាជ្យ

ភាពតុលាការ និងគណនេយ្យភាពរាជរដ្ឋាភិបាលដើម្បីធានាថាអំណាចត្រូវបានគ្រប់គ្រងដោយសមភាព និងស្របតាមច្បាប់។

- <u>**ផ្សព្វផ្សាយ និងបង្រៀនវប្បធម៌នីតិរដ្ឋក្នុងសង្គម៖**</u> អប់រំប្រជាពលរដ្ឋអំពីសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួនតាមរយៈកម្មវិធីសាលារៀន និងប្រព័ន្ធព័ត៌មានសាធារណៈ, ជំរុញការយល់ដឹងអំពីតម្លៃវប្បធម៌ខ្មែរ ដែលគាំទ្រនីតិរដ្ឋ រួមមានយុត្តិធម៌ សមភាព និងការគោរពច្បាប់។
- <u>**អនុវត្តយុទ្ធសាស្ត្របញ្ចកោណជំនាក់កាលទី១ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ និងក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល៖**</u> អនុវត្តយុទ្ធសាស្ត្របញ្ចកោណជំនាក់កាលទី១ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ដើម្បីបង្កើនការសម្របសម្រួលរវាងស្ថាប័នច្បាប់ អាជ្ញាធរ និងសង្គម, តាមដាន និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រនីតិរដ្ឋជាប្រចាំ ដើម្បីធានាថាបញ្ហាប្រឈមត្រូវបានដោះស្រាយប្រកបដោយប្រសិទ្ធភាព។
- <u>**លើកកម្ពស់ការចូលរួមសង្គម៖**</u> បង្កើនឱកាសឱ្យប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិល វិស័យឯកជន ចូលរួមក្នុងការគ្រប់គ្រង និងត្រួតពិនិត្យការអនុវត្តច្បាប់, ជំរុញវប្បធម៌នៃសិទ្ធិសេរីភាពប្រជាពលរដ្ឋ និងការចូលរួមក្នុងការកំណត់គោលការណ៍សាធារណៈ ដើម្បីកសាងសង្គមដែលផ្អែកលើច្បាប់ និងគោលការណ៍នីតិរដ្ឋ។

### ១.២.៣ សេដ្ឋកិច្ច

តម្រូវការទំនាក់ទំនងសង្គម The need for social connection and meaningful relationships.

- <u>**កំណើនសេដ្ឋកិច្ច**</u> (ក្នុង និងក្រៅប្រព័ន្ធ, GDP ១).ឧស្សាហកម្ម ២).ទេសចរណ៍ ៣).កសិកម្ម ៤).សំណង់ ៥).សេវាកម្ម ៦).ថាមពល )
- <u>**សេដ្ឋកិច្ចទីផ្សារសេរី**</u>
- <u>**លើកទឹកសហគ្រាសធនតូច និងមធ្យម**</u> (ផ្តោតលើការអនុគ្រោះពន្ធ,ហិរញ្ញប្បទាន,ជំរុញផលិតកម្មក្នុងស្រុក (SME)
- <u>**បង្កើតការងារជូនប្រជាជន៖**</u> ជំរុញទីផ្សារការងារតាមរយៈការរក្សា ការបង្កើត ការបង្កើនការងារដល់កម្មករ និយោជិត ទាំងក្នុងនិងក្រៅប្រព័ន្ធសំដៅដល់ការបង្កើនប្រាក់ចំណូល ទ្រទ្រង់ជីវភាពសមរម្យ និងកាត់បន្ថយភាពក្រីក្ររបស់ពលរដ្ឋ, រៀបចំផែនការវិនិយោគបន្ថែម
- <u>**ជំរុញការប្រើប្រាស់ក្នុងស្រុក និងកាត់បន្ថយអតិផរណា**</u>
- <u>**ភ័ស្តុភារ និងឡូជីស្ទីក**</u>
- <u>**ពាណិជ្ជកម្មអន្តរជាតិ**</u>
- <u>**គោលនយោបាយរូបិយវត្ថុ**</u>(អត្រាការប្រាក់,អត្រាប្តូរប្រាក់,ជំរុញការប្រើប្រាស់ប្រាក់រៀល,ការផ្គត់ផ្គង់រូបិយវត្ថុ Money supply)

- **<u>ទីផ្សារមូលប័ត្រ</u>**
- **<u>កាត់បន្ថយអត្រាជនក្រីក្រ</u>**
- **<u>ទុនបម្រុងរាជរដ្ឋាភិបាល</u>**
- **<u>កំណើននៃការវិនិយោគ</u>**
- **<u>ការអប់រំ និងអភិវឌ្ឍធនធានមនុស្ស</u>**

### ១.២.៤ អត្តសញ្ញាណជាតិ

- **<u>រាជានិយម៖</u>** ការគោរពព្រះមហាក្សត្រ, ព្រះរាជាគង់ប្រថាប់ជានិមិត្តរូបជាតិ
- **<u>ប្រវត្តិសាស្ត្រជាតិ៖</u>** បញ្ចូលចំណេះដឹងអំពីប្រវត្តិសាស្ត្រទៅក្នុងកម្មវិធីសិក្សាគ្រប់កម្រិតទាំងអស់, ផ្សព្វផ្សាយនូវគុណតម្លៃប្រវត្តិសាស្ត្រនៃអតីតកាលរបស់អាណាចក្រខ្មែរដ៏រុងរឿង និងមានការជៀសវាងលើការជាន់ជានប្រវត្តិសាស្ត្រ ជំរុញឱ្យមានការចងរួមនូវប្រវត្តិសាស្ត្រកម្ពុជាដែលមានតាំងពីសម័យបុរាណ រហូតមកដល់ពេលបច្ចុប្បន្ន បង្កើតមជ្ឈមណ្ឌលតម្កល់ឯកសារប្រវត្តិសាស្ត្រសម្រាប់សាធារណៈជនក្នុងការស្វែងយល់
- **<u>ភាសា ជំនឿ សាសនា ប្រពៃណី ទំនៀមទម្លាប់៖</u>** រៀបចំឱ្យមានផែនទីបង្ហាញផ្លូវ ដើម្បីបណ្ដុះទម្លាប់មានសីលធម៌ គុណធម៌ និងសុជីវធម៌ ដល់សិស្ស និងយុវជនទាំងក្នុង និងក្រៅប្រព័ន្ធអប់រំ,
- **<u>សិល្បៈ វប្បធម៌ ស្ថាបត្យកម្ម៖</u>** បណ្ដុះទស្សនៈ មនសិការជាតិ និងឧត្តមគតិវិជ្ជមាន ក្នុងការអភិរក្ស ការអភិវឌ្ឍ សិល្បៈ វប្បធម៌ជាតិ
- **<u>ទស្សនៈវិទ្យា និងចំណេះដឹងខ្មែរ</u>**
- **<u>សង្គម៖</u>** ការលើកកម្ពស់ការគោរព សីលធម៌,តម្លៃស្ត្រី សេចក្ដីថ្លៃថ្នូរក្នុងគ្រួសារ និងសង្គមខ្មែរ
- **<u>ការអភិរក្សវប្បធម៌ និងសម្បត្តិបេតិកភណ្ឌ៖</u>** ការលើកកម្ពស់ការយល់ដឹងអំពីអត្តសញ្ញាណជាតិ និងភាពជាម្ចាស់ ក្នុងការអភិរក្ស និងអភិវឌ្ឍវប្បធម៌ជាតិ ជំរុញការច្នៃប្រឌិតវប្បធម៌ថ្មីៗ ដោយរក្សារចនាបទខ្មែរ និងឈរលើមូលដ្ឋានអត្តសញ្ញាណជាតិ ការលើកកម្ពស់ការចូលរួមពីសំណាក់ព្រឹទ្ធាចារ្យសិល្បៈដែលជាមរតកមនុស្សរស់ និងការបណ្ដុះអ្នកបន្តវេនសិល្បៈករបុរាណ និងការពង្រឹងការចូលរួមអនុវត្តពីមហាជន

### ១.២.៥ សុខុមាលភាពពលរដ្ឋ

- តម្រូវការសរីរវិទ្យា (Physiological Needs)៖ ជាតម្រូវការជីវសាស្ត្រមូលដ្ឋានដែលចាំបាច់សម្រាប់ការរស់រានមានជីវិតរបស់មនុស្ស។
- សុខុមាលភាពប្រជាពលរដ្ឋត្រូវបានលើកមកបង្ហាញក្នុង SDG 17, សេចក្ដីប្រកាសជាសាកល, ...
- **ព្រះរាជាណាចក្រកម្ពុជាមានគុណតម្លៃស្នូលកម្រិតរដ្ឋដូចជា៖**
  - **<u>សន្តិសុខស្បៀង</u>**៖ រៀបចំស្បៀងបម្រុងនៅក្នុងការប្រើប្រាស់ក្នុងប្រទេសមិនឱ្យមានការខ្វះខាត ធានាបាននូវអតិផរណានៃតម្លៃស្បៀងក្នុងគ្រាមានអាសន្ន ជំរុញការផលិតនៅក្នុងស្រុកជៀសវាងការពឹងផ្អែកស្បៀងពីបរទេស

- **<u>បរិស្ថាន៖</u>** ការពង្រឹងការអភិរក្សាការគ្រប់គ្រង និងការការពារ និងអភិវឌ្ឍប្រកបដោយសុខដុមនីយ កម្ម និងចីរភាព នូវប្រព័ន្ធអេកូឡូស៊ីសំខាន់ៗរបស់កម្ពុជា តាមរយៈការបន្តគ្រប់គ្រងធនធានព្រៃឈើ និងសត្វព្រៃដោយរក្សាគម្របព្រៃឈើឱ្យបានលើស៦០% នៃផ្ទៃប្រទេស ការស្ដារព្រៃឈើឡើងវិញ ការទប់ស្កាត់, ការថែរក្សាបរិស្ថាន កាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិច ជំរុញការប្រើប្រាស់ និងកែច្នៃឡើងវិញនូវកាកសំណល់ដែលអាចប្រើប្រាស់ឡើងវិញ បន្ថែមចំនួនបង្គន់សាធារណៈ អប់រំពលរដ្ឋអំពីការចេះទុកដាក់សំរាម និងមិនចោលសំរាមផ្ដេសផ្ដាស់
- **<u>ទឹកស្អាត និងប្រព័ន្ធអនាម័យ៖</u>** បង្កើតផែនការស្ដីពីការផ្គត់ផ្គង់ទឹកស្អាត ដើម្បីសម្រេចការប្រើប្រាស់បាន ១០០% ទូទាំងប្រទេស លើកទឹកចិត្តដល់វិស័យឯកជនក្នុងវិនិយោគវិស័យទឹកស្អាត ការពង្រឹង និងសម្របសម្រួលនីតិវិធីក្នុងការស្នើសុំអាជ្ញាបណ្ណផលិតទឹកស្អាត ក្នុងគោលបំណងគ្រប់គ្រង អភិវឌ្ឍ និងដោះស្រាយបញ្ហាប្រឈមនានា សំដៅដល់ការធានាសន្តិសុខទឹក។
- **<u>ប្រព័ន្ធសុខាភិបាលសាធារណៈ៖</u>** ការពង្រីករបបថែទាំសុខភាពរបស់ ប.ស.ស ទាំងកម្មករ និយោជិត និងសម្រាប់មន្ត្រីសាធារណៈ ដែលគ្របដណ្ដប់បន្ថែមដល់សមាជិកគ្រួសារ
- **<u>ការការពារតាមផ្លូវច្បាប់</u>**
- **<u>លទ្ធភាពទទួលបានលំនៅឋាន</u>**
- **<u>ទទួលបានប្រាក់ចំណូលខ្ពស់</u>**
- **<u>ហេដ្ឋារចនាសម្ព័ន្ធ</u>** (អគ្គិសនី, ហេដ្ឋារចនាសម្ព័ន្ធឌីជីថល,នគរូបនីយកម្ម)

## ១.៣. ប្រព័ន្ធច្បាប់សកល និងបរិបទនៃប្រព័ន្ធច្បាប់ខ្មែរ

### ១.៣.១ ប្រព័ន្ធច្បាប់ស៊ីវិល

#### ១.៣.១.១ សញ្ញាណប្រព័ន្ធច្បាប់ស៊ីវិល

ប្រព័ន្ធច្បាប់ស៊ីវិល Civil Law ឬ Romano-germanique) គឺជាប្រព័ន្ធច្បាប់មួយប្រភេទដែលមានលក្ខណៈពិសេសមួយគឺពឹងផ្អែកទៅលើ ក្រមច្បាប់ និងច្បាប់ដែលបានចែងជាលាយលក្ខណ៍អក្សរ ហើយអត្ថបទគតិយុត្តត្រូវបានរៀបចំ ដោយមានលក្ខណៈជារចនាសម្ព័ន្ធ ដើម្បីងាយស្រួលពិនិត្យ និងប្រឹក្សា[១]។ ចរិកលក្ខណៈនៃច្បាប់នេះគឺទទួលឥទ្ធិពល និងទម្រង់នៃច្បាប់រ៉ូម ដោយបន្ស៊ីជាមួយនឹងប្រពៃណីទំនៀមទម្លាប់ សង្គម វប្បធម៌ ជំនឿសាសនា នៃសង្គមមនុស្សរស់នៅក្នុងតំបន់របស់ខ្លួន[២]។ ប៉ុន្តែច្បាប់នៃអាណាចក្ររ៉ូមជាប្រភេទច្បាប់ដែលឥតសរសេរភាគច្រើនគឺជាវិធានជំនឿសាសនា ដែលត្រូវបានយកមកផ្សំជាមួយនឹងបវេណីរបស់ក្រុមកុលសម្ព័ន្ធអាឡឺម៉ង់ (barbares) ដែលឈរលើមូលដ្ឋានយុត្តិធម៌ និងភាពស្មើភាពគ្នាចំពោះមុខច្បាប់[៣]។ ការវិវត្តសំខាន់ៗគួរឱ្យកត់សម្គាល់នៅក្នុងប្រវត្តិនៃច្បាប់ស៊ីវិលត្រូវបានចាប់អារម្មណ៍នៅក្នុងដំណាក់កាលពីរ សំខាន់គឺ៖ ទី១) នៅក្នុងស្នាដៃរបស់ Jean Domat នៅក្នុងស.វ.ទី១៧ ទាក់ទងទៅនឹង « *des lois civiles dans leur ordre naturel* » និងទី២) ការធ្វើក្រមរដ្ឋប្បវេណី ឆ្នាំ១៨០៤ របស់បារាំង (Code Napoléon)។

គោលការណ៍សំខាន់ៗ នៃប្រព័ន្ធច្បាប់ស៊ីវិលមានដូចខាងក្រោម[៤]៖

- គោលការណ៍ច្បាប់មានលក្ខណៈជាលាយលក្ខណ៍អក្សរ (Principle of Codification)៖ ច្បាប់ត្រូវបង្កើតឡើងដោយការសរសេរជាក្រម
- គោលការណ៍នៃអធិបតេយ្យភាពច្បាប់ (Supremacy of Written Law)៖ ស្ថាប័នតុលាការត្រូវអនុវត្តតាមច្បាប់ដែលមានជាធរមាន និងសេចក្ដីសម្រេចរបស់តុលាការមិនត្រូវចាត់ទុកជាប្រភពនៃច្បាប់នោះទេ។
- គោលការណ៍ផ្ដាច់មុខរបស់រដ្ឋក្នុងការបង្កើតច្បាប់ (Legislative Sovereignty)៖ មានតែរដ្ឋសភាប៉ុណ្ណោះដែលមានសិទ្ធិក្នុងការបង្កើតច្បាប់ ចំណែកតុលាការមានតួនាទីអនុវត្តច្បាប់។

---

[១] «ច្បាប់សរសេរ ( Droit Continental) មានមូលដ្ឋាននៃច្បាប់របស់អាណាចក្ររ៉ូម៉ាំង ដែលជាការសំយោគ និងចងក្រងបវេណីនៅក្នុងតំបន់ជាបទប្បញ្ញត្តិជាលាយលក្ខណ៍អក្សរ», Maroun BOUSTANY, Docteur en Droit de la Faculté de Droit de l'Université La Sagesse, Les Grands systèmes juridiques contemporains, Actes du Colloque international, le ១១,១២ Févier ២០១៦, P.៣០.

[២] Les Lois Civils dans leur ordre naturel, Jean Domat en ១៦៣៩, Rétablir par Universitas Ottaviensis en ១៨២៨, P.២៣.

[៣] ប្រភពឯកសារដដែល។

[៤] គេហទំព័រ៖ https://cours-de-droit.net/grands-systemes-juridique-romano-germanique-common-law/

ប្រព័ន្ធច្បាប់ស៊ីវិលមានប្រវត្តិចេញមកពីច្បាប់រ៉ូម៉ាំង នៅចន្លោះសតវត្សទី៦ គ.ស នៅសម័យអាណាចក្ររ៉ូម៉ាំង។ បន្ទាប់ពីការដួលរលំនៃអាណាចក្ររ៉ូម៉ាំងខាងលិច នា សតវត្ស ៤៧៦ គ.ស. ច្បាប់រ៉ូម៉ាំងនៅតែមានឥទ្ធិពលនៅអាណាចក្ររ៉ូម៉ាំងខាងកើត។ បន្ទាប់មក នៅអឺរ៉ុបខាងលិច ច្បាប់រ៉ូម៉ាំងត្រូវបានជំនួសដោយច្បាប់ប្រពៃណីជនជាតិអាល្លឺម៉ង់ ប៉ុន្តែច្បាប់រ៉ូម៉ាំងនៅតែមានឥទ្ធិពលតាមរយៈសាសនាគ្រិស្ត និងស្ថាប័នច្បាប់។ ប្រព័ន្ធច្បាប់នេះត្រូវបានវិវត្តតាមរយៈអាណានិគមបារាំង អេស្ប៉ាញ និងព័រទុយហ្គាល់ ប្រព័ន្ធច្បាប់ស៊ីវិលបានរីករាលដាលទៅកាន់អាមេរិកឡាទីន អាហ្វ្រិក និងអាស៊ី ជាដើម។

ប្រព័ន្ធច្បាប់ស៊ីវិល (Civil Law System) ត្រូវបានបង្កើតឡើងដោយផ្អែកលើគំនិតទស្សនវិជ្ជាមួយចំនួនដែលឆ្លុះបញ្ចាំងពីតម្លៃសង្គម និងគោលការណ៍នៃយុត្តិធម៌។ គំនិតទាំងនេះមានឫសគល់ជ្រៅក្នុងប្រវត្តិសាស្ត្រ និងបានវិវត្តតាមពេលវេលា ដោយទទួលឥទ្ធិពលពីច្បាប់រ៉ូម៉ាំង ទស្សនវិជ្ជាអឺរ៉ុប និងសម័យទំនើប។ ខាងក្រោមនេះជាគំនិតទស្សនវិជ្ជាសំខាន់ៗ ដែលជាមូលដ្ឋានសម្រាប់ការបង្កើតប្រព័ន្ធច្បាប់ស៊ីវិលៈ

- គំនិតអំពីភាពសមហេតុផល និងប្រព័ន្ធ (Rationality and Systematization)
    - គោលគំនិតៈ ប្រព័ន្ធច្បាប់ស៊ីវិលផ្តោតលើការរៀបចំច្បាប់ឱ្យមានលក្ខណៈជាប្រព័ន្ធ និងផ្អែកលើហេតុផល។ គំនិតនេះទទួលឥទ្ធិពលពីទស្សនវិជ្ជាសម័យ Enlightenment ដែលសង្កត់ធ្ងន់លើហេតុផល និងការរៀបចំបែបវិទ្យាសាស្ត្រ។
    - ឥទ្ធិពលៈ ទស្សនវិទូដូចជា Montesquieu និង Rousseau បានជំរុញឱ្យមានការបង្កើតច្បាប់ដែលច្បាស់លាស់ និងអាចអនុវត្តបានជាសកល។ ក្រម Napoleon (១៨០៤) ជាឧទាហរណ៍មួយដែលឆ្លុះបញ្ចាំងពីការព្យាយាមរៀបចំច្បាប់ឱ្យមានភាពស៊ីសង្វាក់គ្នា និងផ្អែកលើគោលការណ៍សមហេតុផល។ ឧទាហរណ៍ៈ ការបង្កើត Corpus Juris Civilis ក្នុងសម័យអធិរាជ Justinian I (សតវត្សទី៦) បានបង្កើតប្រព័ន្ធច្បាប់រ៉ូម៉ាំងដែលរៀបចំជាលក្ខណៈប្រព័ន្ធ ដោយផ្អែកលើគោលការណ៍ហេតុផល។
- គំនិតអំពីអធិបតេយ្យភាពរបស់រដ្ឋ (State Sovereignty and Legislative Authority)
    - គោលគំនិតៈ នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល ច្បាប់ត្រូវបានបង្កើតឡើងដោយរដ្ឋ ឬស្ថាប័ននីតិបញ្ញត្តិ ដែលតំណាងឱ្យឆន្ទៈរបស់ប្រជាជន។ នេះឆ្លុះបញ្ចាំងពីគំនិតអំពីអធិបតេយ្យភាពជាតិ និងអំណាចនីតិបញ្ញត្តិ។
    - ឥទ្ធិពលៈ ទស្សនវិទូដូចជា Jean-Jacques Rousseau បានលើកឡើងពី "កិច្ចសន្យាសង្គម" (Social Contract) ដែលច្បាប់ជាការបង្ហាញនៃឆន្ទៈទូទៅរបស់ប្រជាជន ហើយរដ្ឋមានសិទ្ធិអំណាចក្នុងការបង្កើតច្បាប់។

- ឧទាហរណ៍៖ ក្រម Napoleon ត្រូវបានបង្កើតឡើងក្រោមការដឹកនាំរបស់ណាប៉ូឡេអុង ដើម្បីបង្រួបបង្រួមច្បាប់នៅបារាំង ដោយផ្អែកលើអធិបតេយ្យភាពរបស់រដ្ឋ និងគោលការណ៍សមភាព។

- គំនិតអំពីសមភាព និងយុត្តិធម៌ (Equality and Justice)
  - គោលគំនិត៖ ប្រព័ន្ធច្បាប់ស៊ីវិលសង្កត់ធ្ងន់លើគោលការណ៍សមភាពមុខច្បាប់ ដែលបុគ្គលទាំងអស់ត្រូវបានអនុវត្តច្បាប់ស្មើគ្នា ដោយមិនគិតពីស្ថានភាពសង្គម។
  - ឥទ្ធិពល៖ នេះជាផលផ្លែផ្កានៃសម័យ Enlightenment ដែលបានប្រឆាំងនឹងប្រព័ន្ធសក្តិភូមិ (feudalism) និងឯកសិទ្ធិរបស់អភិជន។ ទស្សនវិទូដូចជា Voltaire បានជំរុញឱ្យមានច្បាប់ដែលផ្តល់យុត្តិធម៌សម្រាប់ទាំងអស់គ្នា។
  - ឧទាហរណ៍៖ ក្រម Napoleon បានលុបបំបាត់ឯកសិទ្ធិរបស់អភិជន និងបានបង្កើតគោលការណ៍សមភាពក្នុងការបែងចែកចាយមរតក និងកិច្ចសន្យា។
- គំនិតអំពីកម្មសិទ្ធិ និងសេរីភាពបុគ្គល (Property and Individual Liberty)
  - គោលគំនិត៖ ប្រព័ន្ធច្បាប់ស៊ីវិលផ្តល់សារៈសំខាន់ដល់ការការពារកម្មសិទ្ធិឯកជន និងសេរីភាពបុគ្គល ដែលជាគោលការណ៍ស្នូលនៃទស្សនវិជ្ជាសេរីនិយម (Liberalism)។
  - ឥទ្ធិពល៖ ទស្សនវិទូដូចជា John Locke បានសង្កត់ធ្ងន់លើសិទ្ធិក្នុងកម្មសិទ្ធិ និងសេរីភាពបុគ្គល ដែលត្រូវបានបញ្ចូលទៅក្នុងក្រមច្បាប់ស៊ីវិល។ ឧទាហរណ៍៖ ក្រម Bürgerliches Gesetzbuch (BGB) របស់អាល្លឺម៉ង់ (១៩០០) ផ្តល់ការការពារយ៉ាងរឹងមាំដល់កម្មសិទ្ធិឯកជន និងសេរីភាពក្នុងកិច្ចសន្យា ដែលជួយជំរុញសេដ្ឋកិច្ចទីផ្សារសេរី។
- គំនិតអំពីច្បាប់ធម្មជាតិ (Natural Law)
  - គោលគំនិត៖ គំនិតនៃច្បាប់ធម្មជាតិបានដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតប្រព័ន្ធច្បាប់ស៊ីវិល ដោយជឿថាមានគោលការណ៍ច្បាប់ជាសកលដែលផ្អែកលើហេតុផល និងសីលធម៌។
  - ឥទ្ធិពល៖ ទស្សនវិទូដូចជា Thomas Aquinas និង Hugo Grotius បានបញ្ចូលគំនិតនៃច្បាប់ធម្មជាតិទៅក្នុងប្រព័ន្ធច្បាប់ ដែលបានជះឥទ្ធិពលដល់ Corpus Juris Civilis និងក្រមច្បាប់ជាច្រើនទៀត។ឧទាហរណ៍៖ គោលការណ៍នៃ "pacta sunt servanda" (កិច្ចព្រមព្រៀងត្រូវតែគោរព) ដែលជាគោលការណ៍ច្បាប់ធម្មជាតិ ត្រូវបានបញ្ចូលទៅក្នុងក្រមច្បាប់ស៊ីវិល។
- គំនិតអំពីភាពស៊ីសង្វាក់គ្នា និងឯកភាព (Harmony and Uniformity)
  - គោលគំនិត៖ ប្រព័ន្ធច្បាប់ស៊ីវិលមានគោលបំណងបង្កើតភាពឯកភាពនៃច្បាប់នៅក្នុងប្រទេស ឬតំបន់មួយ ដើម្បីកាត់បន្ថយជម្លោះ និងភាពខុសគ្នាក្នុងការអនុវត្ត។

- ឥទ្ធិពលៈ គំនិតនេះទទួលឥទ្ធិពលពីច្បាប់រ៉ូម៉ាំង និងការព្យាយាមរបស់រដ្ឋជាតិនៅអឺរ៉ុបដើម្បីបង្រួបបង្រួមច្បាប់ក្នុងសម័យកណ្ដាល និងសម័យទំនើប។ ឧទាហរណ៍ៈ ការបង្កើតក្រមច្បាប់នៅប្រទេសអេស្ប៉ាញ និងប៉ទុយហ្គាល់ក្នុងអំឡុងសម័យអាណានិគមបានជួយបង្រួបបង្រួមច្បាប់នៅក្នុងអាណានិគមរបស់ខ្លួន។

សម្រាប់ប្រព័ន្ធច្បាប់ស៊ីវិលនៅក្នុងប្រព័ន្ធច្បាប់កម្ពុជាៈ ចរឹតលក្ខណៈសារជាតុ ចរឹតលក្ខណៈនីតិវិធី និងចរឹតលក្ខណៈស្ថាប័នគតិយុត្ត

### ១.៣.១.២ ប្រភពនៃនីតិនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល

នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល (Civil Law System) បទប្បញ្ញត្តិច្បាប់ និងវិធានគតិយុត្តអាចអនុវត្តបានលុះត្រាតែបទប្បញ្ញត្តិទាំងនោះស្ថិតនៅជាធរមាន។ ប៉ុន្តែប្រភពនៃនីតិ នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល មានពីរប្រភពគឺ ទី១) ច្បាប់សរសេរជាលាយលក្ខណ៍អក្សរ ទី២) ប្រភពច្បាប់អត់សរសេរ។

**ទី១) ប្រភពច្បាប់សរសេរជាលាយលក្ខណ៍អក្សរមានចរឹតលក្ខណៈដូចតទៅៈ**

- **ការចងក្រងជាក្រម** (Codification) សំដៅដល់ជាសំណុំវិធាននៃបទប្បញ្ញត្តិទាំងឡាយត្រូវបានរៀបចំ ជាប្រព័ន្ធ និងជារចនាសម្ព័ន្ធ ដើម្បីងាយស្រួលក្នុងការបកស្រាយ និងធ្វើការប្រឹក្សា។ ជាស្ដែងនៅក្នុងប្រព័ន្ធច្បាប់កម្ពុជាទំនើប ក្រមនីយកម្មត្រូវបានឃើញមានវត្តមាននៅក្នុងកម្ពុជាដំបូងបំផុត ដោយ ព្រះរាជប្បញ្ញត្តិចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩១១ ដែលបានប្រកាសឱ្យប្រើក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមស្ដីអំពីការរៀបចំតុលាការ[៥] និងត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី១ ខែកក្កដា ឆ្នាំ១៩១២។
- **នីតិកម្ម** (Legislation) សំដៅដល់កិច្ចការនៃការកសាងច្បាប់តាមនីតិវិធីនៃការកសាងច្បាប់ និងត្រូវបានអនុម័តដោយស្ថាប័ននីតិបញ្ញត្តិមានជាអាទិ៍ៈ រដ្ឋសភា (សភាជាន់ទាប) និងព្រឹទ្ធសភា (សភាជាន់ខ្ពស់) និយាដោយឡែកនៅកម្ពុជា កិច្ចការនីតិកម្មបែបទំនើបត្រូវបានឃើញមានវត្តមានពេញទំហឹងនៅក្នុងឆ្នាំ១៩១០ ដែលមានមូលដ្ឋានពីសន្ធិសញ្ញាកម្ពុជា-បារាំង ព្រះបាទនរោត្តមបានសន្យា ទទួលយកនូវគ្រប់កំណែទម្រង់រដ្ឋបាល យុត្តាធិការ ហិរញ្ញវត្ថុ និងពាណិជ្ជកម្ម។[៦]

---

[៥] Introduction au droit Cambogien, par M. AVILLANEDA Loic, Mlle BALIVET Béatrice, Mme CHANG Sinath, M. KAN Channmeta, M. KOEUT Rith, M. THENG Chan-Sangvar, Coordination par Mlle Béatrice BALIVET, Publication en ១៩៩៩, P.១៥.

[៦] Etienne AYMONIER, "le Cambodge" Paris, Ernest LEROUX, ៣vol., ១៩៩០ à ១៩០៤, p.៧៩, in Marion SIMONET, Thèse Lyon ៣, p.៤៩.

- **លិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់** (Textes règlementarires) សំដៅដល់លិខិតបទដ្ឋានគតិយុត្តដាក់ចុះដោយអង្គនីតិប្រតិបត្តិជាអនុលោមភាពទៅលើច្បាប់ជាធរមាន មានជាអាទិ៍៖ ព្រះរាជក្រឹត្យ ព្រះរាជក្រម អនុក្រឹត្យ ប្រកាស ដីកា សារាចរ និងសម្រេច[៧]។ លិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់នេះ មានចរឹកលក្ខណៈពីរ (២) យ៉ាង៖ ១) ចរឹកលក្ខណៈជាលិខិតរដ្ឋបាល (le actes non-décisioires) សំដៅដល់លិខិត ធ្វើឡើងក្នុងគោលបំណងដើម្បីសម្រួលដល់កិច្ចនិតិវិធីរដ្ឋបាល មានដូចជាការជូនដំណឹង ការតែងតាំង ការផ្លាស់ប្តូរនិងការដកហូតតួនាទីភារកិច្ច និងបទបញ្ជារបស់រាជរដ្ឋាភិបាលឱ្យ ក្រសួង ស្ថាប័ន អាជ្ញាធរមានសមត្ថភាព ទាំងរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ចាត់វិធានការរដ្ឋបាលទៅលើបញ្ហាចំពោះមុខណាមួយនៅក្នុងករណីដែលគ្មានច្បាប់ចែ ការណ៍នេះមិនបង្កើតអានុភាព គតិយុត្ត ឬមិនមានអានុភាពគតិយុត្តទូទៅឡើយ[៨] និង២)ចរឹកលក្ខណៈជាច្បាប់ (les actes décisioires) សំដៅដល់លិខិតគតិយុត្តបង្កើតឡើងក្នុងគោលបំណងនៅក្នុងការបកស្រាយច្បាប់ ហើយអាចអានុភាព គតិយុត្តចងនៅក្នុងច្បាប់ជាធរមាន និងអានុភាពអនុវត្តនៅទូទាំងប្រទេស ពោលគឺការបង្កើតកាតព្វកិច្ចនៅក្នុងចំណងគតិយុត្តក្រោមទម្រង់ជាលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ ទាំងរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ[៩]។

**ទី២) ប្រភពច្បាប់អត់សរសេរ មានចរឹតលក្ខណៈដូចតទៅ៖**

ចរឹកលក្ខណៈអត់សរសេរនៃច្បាប់ ស្ថិតនៅក្នុងសតិសម្បជញ្ញៈរបស់មនុស្សពោលគឺជាច្បាប់ធម្មជាតិ (*jus naturalis*)[១០] ហេតុនេះ បវេណី ឬទម្រាប់នៃការប្រើច្បាប់ លទ្ធិ និងយុត្តិសាស្ត្រ គឺជាផ្នែកមួយនៃនីតិ ដែលជាប្រភពច្បាប់អត់សរសេរ។

- បវេណី ឬទម្លាប់នៃការប្រើច្បាប់ (Custom)៖ ពាក្យថាបវេណីនៅក្នុងន័យទូលាយសំដៅវិធានដែលប្រើប្រាស់នៅក្នុងសង្គមមួយជាច្បាប់សម្រាប់ដោះស្រាយទៅលើព្រឹត្តិការណ៍គតិយុត្ត (វិវាទ) នៅក្នុងករណីគ្មានច្បាប់ចែង[11]។ នៅក្នុងន័យចង្អៀត គឺជាប្រភពនៃច្បាប់អត់សរសេរ

---

[៧] Introduction au droit Cambogien, par M. AVILLANEDA Loic, Mlle BALIVET Béatrice, Mme CHANG Sinath, M. KAN Channmeta, M. KOEUT Rith, M. THENG Chan-Sangvar, Coordination par Mlle Béatrice BALIVET, Publication en ១៩៩៩, P.៧០, ៧១, ៧២, ៧៣.

[៨] Fiche ៣៩. Les actes administratifs unilatéraux non déscisioires en ២០១៩, par Yves Broussolle, P.២៤១ à ២៤៤.

[៩] Fiche ៣៨., Idem, P.២៣៣ à ២៤០.

[១០] វិធានគតិយុត្តគ្រប់គ្រងទំនាក់ទំនងរបស់មនុស្សនៅក្នុងសង្គម ជីវភាពរបស់មនុស្សនៅក្នុងសង្គម ហេតុនេះ នីតិគឺជាវិទ្យាសាស្ត្រ សិក្សាអំពីសង្គមមនុស្ស (Le droit tendant à régir la vie des hommes en société), Introduction général au droit, Précis DALLOZ, Publié en François Terré professeur à l'université Panthéon-Assas (Paris II), P.២១.

[១១] *Idem, P.១៧៩*

ទំនៀមទម្លាប់គឺជាផ្នែកមួយជំនួយទៅដល់ការបកស្រាយច្បាប់ ទាមទារឱ្យមានការបកស្រាយអាស្រ័យតទៅតាមគោលបំណង គោលដៅរបស់ច្បាប់ ប៉ុន្តែ ទំនៀមទម្លាប់មានតួនាទីតិចតួចជាងនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល បើធៀបនឹងប្រព័ន្ធច្បាប់អង់គ្លូសាក់សង់ ( Common Law )។ ទំនៀមទម្លាប់អាចត្រូវបានទទួលស្គាល់ជាប្រភពច្បាប់ ប្រសិន បើវាមិនផ្ទុយនឹងច្បាប់ ឬច្បាប់លក្ខន្តិកៈ និងមានការអនុវត្ត ជាប្រចាំ។ ជាក់ស្តែងសង្គមខ្មែរ គឺជាសង្គមមួយ ពោរពេញទៅដោយប្រពៃណីទំនៀមទម្លាប់ ដែលចាក់ឫសយ៉ាងជ្រៅទៅក្នុងសង្គមខ្មែរ ជាពិសេសពិធីជំនឿសាសនាផ្សេងៗ ជំនឿទៅលើបុណ្យបាប នៅក្នុងសម័យបុរាណមន្ត្រីរាជការដែលបំពានទៅនឹងពាក្យសម្បថត្រូវធ្លាក់នរក ៣២ជាន់ជាដើម[12] ឧទាហរណ៍៖ នៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ បានបញ្ញត្តិអំពីទេវតារក្សាស្វេតឆ័ត្រ។ ជាក់ស្តែងនៅក្នុងវិស័យធុរកិច្ច ការដោះស្រាយវិវាទត្រូវបានធ្វើឡើងដោយផ្អែកលើបវេណី ច្បាប់របស់អ្នកជំនួញ[13] ( *Lex Mercatoria*)។ សម្រាប់ទម្លាប់ខ្មែរ ចូលចិត្តប្រើវិធានក្នុងសម្រុះសម្រួល ឬការផ្សះផ្សា ដែលចាប់ផ្តើមឡើងនៅកម្រិតភូមិស្រុក ជាផ្នែកមួយនៃដំណើរការច្បាប់[14]។

- លទ្ធិ ( General Principles of Law/ Doctrine ) នៅក្នុងន័យទូលាយសំដៅដល់ទស្សនវិជ្ជា ការយល់ឃើញអំពីបញ្ហាណាមួយ។ នៅក្នុងន័យចង្អៀត ( *opinion dictorum* ) សំដៅដល់ការសិក្សាស្រាវជ្រាវការស្វែង យល់អំពីនីតិរបស់អ្នកប្រាជ្ញ មាន សាស្ត្រាចារ្យច្បាប់ អ្នកច្បាប់ មេធាវី បេក្ខភាពបណ្ឌិត បណ្ឌិត ជាដើម[15]។ បើទោះបីជាលទ្ធិ មិនមែនជាប្រភពផ្ទាល់នៃនីតិដូចជាបវេណី នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល ការស្រាវជ្រាវ បានផ្តល់យោបល់ ការធ្វើវិចារណកម្មរបស់អ្នកទស្សនវិជ្ជាច្បាប់ ជាពិសេស បណ្ឌិតច្បាប់ សាស្ត្រាចារ្យច្បាប់ គឺពិតជាជះឥទ្ធិពលដល់ការបកស្រាយច្បាប់ និងការអនុវត្តច្បាប់ ផ្អែកតាមមូលហេតុនៃការធ្វើវិចារណកម្មទាំងនោះ[16]។ ជាការពិតលទ្ធិ មកអាចឈរតែឯងដោយគ្មាន បវេណី និងយុត្តិសាស្ត្រឡើយ។

---

១២ Introduction au droit Cambogien, par M. AVILLANEDA Loic, Mlle BALIVET Béatrice, Mme CHANG Sinath, M. KAN Channmeta, M. KOEUT Rith, M. THENG Chan-Sangvar, Coordination par Mlle Béatrice BALIVET, Publication en ១៩៩៩, P៨២.

១៣ B. GOLDMAN, la *lex mercatoria* dans les contrats et l'arbitrage internationaux, JDI ១៩៧៩. P.១៥ et suivants.

១៤ ប្រព័ន្ធច្បាប់កម្ពុជា មជ្ឈមណ្ឌល អភិវឌ្ឍន៍ធនធានច្បាប់កម្ពុជា ដោយ បណ្ឌិត សុក ស៊ីផាន់ណា និងបណ្ឌិត សារិន ដេណ្ឌា បកប្រែ និងកែសម្រួលជាភាសាខ្មែរដោយ អ្នកស្រី ខៀវ មាលី ឆ្នាំ១៩៩៩, ទំព័រ៣១។

១៥ J. BONNECASE, La pensé juridique francaise de ១៨០៤ à l'heure présente, ២ vol. ១៩៣៣.

១៦ Introduction général au droit, Précis DALLOZ, Publié en François Terré professeur à l'université Panthéon-Assas ( Paris II ), P.២០៦.

- យុត្តិសាស្ត្រ (Jurisprudences) នៅក្នុងន័យទូលាយយុត្តិសាស្ត្រសំដៅដល់ការគិតការបកស្រាយច្បាប់ ការដោះស្រាយវិវាទរបស់អ្នកច្បាប់ទៅលើព្រឹត្តិការណ៍គតិយុត្តណាមួយតាមរយៈការធ្វើវិចារណកម្ម និងការផ្តល់ហេតុផលផ្ទាល់ខ្លួន ជាពិសេសអ្នកប្រកបវិជ្ជាជីវៈច្បាប់ មានចៅក្រម មេធាវី ជាដើម។ នៅក្នុងន័យចង្អៀត យុត្តិសាស្ត្រ សំដៅដល់សេចក្តីសម្រេចដោយសំអាងហេតុរបស់តុលាការ ដើម្បីឱ្យសេចក្តីសម្រេចរបស់តុលាការមួយចាត់ទុកថាជាយុត្តិសាស្ត្របានលុះត្រាតែបំពេញលក្ខខណ្ឌ ដូចតទៅ៖ ១) សេចក្តីសម្រេចបង្កើតជាគោលការណ៍ទូទៅ (les arrets de principe) ពោលគឺជាសេចក្តីសម្រេចមួយដែលសំអាងហេតុរបស់ចៅក្រមកើតចេញវិចារណកម្មទៅលើអង្គសេចក្តី ត្រូវបាន ប្រើប្រាស់ជាជំនួយដល់ការបកស្រាយច្បាប់ ជាពិសេសបង្ហាញអំពីធន្ទះទូទៅរបស់សង្គម។ ២) សេចក្តីសម្រេចទៅលើរឿងក្តីថ្មី (Relativité de la chose jugée) ចៅក្រមមានសិទ្ធិអំណាចនៅក្នុងការជំនុំជម្រះក្តីនៅក្នុងព្រំដែនកំណត់នៃរឿងក្តីចៅក្រមធ្វើការជំនុំជម្រះក្តីនោះ ជាគម្រូសម្រាប់ចៅក្រមនៅក្នុងការបកស្រាយ និងចេញសេចក្តីសម្រេចទៅលើរឿងក្តីប្រហាក់ប្រហែលគ្នាក្រោយៗមកទៀត[17] ។ ៣) សេចក្តីសម្រេចចេញដោយយុត្តាធិការជាន់ខ្ពស់ (les juridictions supérieures) ដែលបង្កើតអានុភាពបង្កើត កែប្រែ និងលុបចោលអានុភាពនៃសេចក្តីសម្រេចរបស់តុលាការថ្នាក់ក្រោម តាមរយៈចរឹតលក្ខណៈដាច់ខាត និងចាប់បង្ខំនៅក្នុងសេចក្តីសម្រេចនោះ។ ៤) សេចក្តីសម្រេចគំរូ (fonction contentieuse) សំអាងហេតុរបស់ចៅក្រមបានធ្វើវិចារណកម្មយ៉ាងហ្មត់ចត់ទៅលើអង្គហេតុ និងអង្គច្បាប់[18] នីតិនិពន្ធមិនអាចកំណត់នូវភាពស្មុគស្មាញនៅក្នុងព្រឹត្តិការណ៍គតិយុត្តមួយនោះទេ។

នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល យុត្តិសាស្ត្រគឺជាផ្នែកមួយជំនួយដល់ការបកស្រាយច្បាប់ នៅពេលច្បាប់នោះមានលក្ខណៈទូលាយពេក ឬមានលក្ខណៈមិនច្បាស់លាស់ ដោយឡែកនៅក្នុងប្រព័ន្ធអង់គ្លូសាក់សុងយុត្តិសាស្ត្រជាមូលដ្ឋានគ្រឹះក្នុងការដោះស្រាយវិវាទ។

### ១.៣.១.៣ គុណសម្បត្តិ និងគុណវិបត្តិនៃប្រព័ន្ធច្បាប់ស៊ីវិល

### ក. គុណសម្បត្តិនៃប្រព័ន្ធច្បាប់ស៊ីវិល

គុណសម្បត្តិនៃប្រព័ន្ធច្បាប់ស៊ីវិលស្ថិតនៅត្រង់ភាពច្បាស់លាស់នៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលត្រូវបានចារឹកជាលាយលក្ខណ៍អក្សរ ក្រោមទម្រង់ជាក្រម ជាច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដែល

---

[១៧] Ce principe comporte une seule exception : en cas de cassation d'une décision par les chambres réunies de la Cour de cassation, ou, à présent, par l'Assemblée plénière, la juridiction de renvoi doit se ranger à l'opinion de la cour de cassation (*supra*, n°១១៤)

[១៨] G. Mart, la distinction du fait et du droit, thèse Toulouse, ១៩២៩ , C. MARRUD, La notion de dénaturation en droit privé, thèse Nancy, éd. ១៩៧៤ , M. ROTONDI, Considération en «fait » et en « droit », RTD civ. ១៩៧៧, p.១ et suivants.

បង្កើតចំណងគតិយុត្ត និងបង្កើតអានុភាពអនុវត្ត ជាប្រព័ន្ធច្បាប់មួយដែលមានចរឹកលក្ខណៈសត្យានុម័ត ដែលមើលឃើញ ព្រមទាំងអាចកំណត់នូវនិយាមសម្រាប់ការប្រតិបត្តិនៅក្នុងសង្គម ដែលមានលក្ខណៈត្រឹមត្រូវ និងមានក្រឹត្យក្រមច្បាស់លាស់ ជាបន្ទាល់សម្រាប់ការប្រតិបត្តិនៅក្នុងសង្គម។ ជាក់ស្តែងឋានានុក្រមគតិយុត្ត ជានានូវគោលការណ៍នីត្យានុកូលភាព សុវត្ថិភាពគតិយុត្ត និងសន្តិសុខគតិយុត្ត ដែលឋានានុក្រមទាំងនោះមានដូចតទៅៈ ទី១) រដ្ឋធម្មនុញ្ញជាច្បាប់កំពូល ទី២) ច្បាប់ និងទី៣) លិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ ដែលចាំបាច់ត្រូវធានាឱ្យបាននូវនីត្យានុកូលភាព និងអនុលោមភាព នៃអត្ថបទគតិយុត្តទាំងនោះ។ ចំណុចដែលគួរឱ្យកត់សម្គាល់នៃគុណសម្បត្តិប្រព័ន្ធច្បាប់ស៊ីវិលគឺគោលការណ៍សេរីភាព គ្មានច្បាប់ចែងគឺគ្មានបទល្មើស បុគ្គលម្នាក់ៗទទួលខុសត្រូវតែទៅលើអំពើអនីត្យានុកូលដែលខ្លួនបានប្រព្រឹត្តតែប៉ុណ្ណោះ។

## ខ. គុណវិបត្តិនៃប្រព័ន្ធច្បាប់ស៊ីវិល

គុណវិបត្តិនៃប្រព័ន្ធច្បាប់ស៊ីវិល ច្បាប់កើតចេញពីលើមកវិញចេញអង្គការចាត់តាំងមកវិញ មានន័យថានៅពេលអ្នកធ្វើច្បាប់រកឃើញបញ្ហាចំពោះមុខណាមួយ នីតិពន្ធច្បាប់ផ្តើមធ្វើការគិតគូរទៅលើវិធានគតិយុត្ត និងវិធីសាស្ត្រនៅក្នុងការដោះស្រាយវិវាទ ប៉ុន្តែមិនទាន់មានលក្ខណៈគ្រប់គ្រាន់ដែលអាចឆ្លើយតបទៅនឹងកាលៈទេសៈ ស្ថានភាព ជាក់ស្តែង ជាពិសេសការវិវត្តរបស់សង្គម ដោយហេតុថា ការអនុវត្តច្បាប់ផ្អែកទៅលើវិធានគតិយុត្តជាធរមាន។ ប្រព័ន្ធច្បាប់ស៊ីវិលគឺជាប្រព័ន្ធរឹង រាល់ការបកស្រាយច្បាប់ និងការដោះស្រាយវិវាទគតិយុត្តត្រូវធ្វើឡើងដោយផ្អែកលើបទបញ្ញត្តិច្បាប់ជាធរមាន ហេតុនេះពិបាកក្នុងការស្វែងហេតុផល និងភាពបត់បែនក្នុងការអនុវត្តច្បាប់ទៅតាមកាលៈទេសៈ និងករណីជាក់ស្តែង។ នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល មិនអាចធ្វើការដាក់ទណ្ឌកម្ម ឬពិនិត្យដោយគ្មានច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តជាធរមានឡើយ។ ជាក់ស្តែង នៅក្នុងប្រព័ន្ធច្បាប់ប្រភេទនេះ យុត្តិសាស្ត្រមិនមែនជាវិធានគតិយុត្ត ដែលត្រូវយកទៅអនុវត្ត និងយកទៅធ្វើការគ្រប់គ្រងសណ្តាប់ធ្នាប់សាធារណៈ និងធ្វើការគ្រប់គ្រងសង្គមឡើយ ប៉ុន្តែវាគ្រាន់តែជាផ្នែកមួយជាជំនួយទៅដល់ការបកស្រាយច្បាប់តែប៉ុណ្ណោះ។ ក្រៅពីនេះ នីតិវិធីនៃការកសាងច្បាប់នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលមានលក្ខណៈស្មុគស្មាញ នឹងចំណាយពេលវេលាយូរ ពេលខ្លះគឺជាគុណវិបត្តិដែលមិនអាចឆ្លើយតបទៅនឹងសភាពការណ៍សង្គមជាក់ស្តែង ភាពតឹងរឹងនេះបង្កបញ្ហាស្មុគស្មាញ ជាពិសេសគម្លាតរវាងនិយាមសង្គម និងនិយាមច្បាប់។ ករណីប្រភេទកម្ពុជា នៅក្នុងឆ្នាំ២០១៩ ដោយសារគ្មានច្បាប់ យើងមិនអាចធ្វើការដាក់ទណ្ឌកម្មទៅលើបុគ្គលដែលល្មើសទៅនឹងវិធានរបស់ក្រសួងសុខាភិបាលស្តីពីការទប់ស្កាត់ការរីកសាយភាយ និងរីករាលដាលនៃជម្ងឺ COVID ១៩ ឡើយហេតុនេះ រាជរដ្ឋាភិបាលបានដាក់ចុះនូវអនុក្រឹត្យលេខ៣៧ អនក្រ.បក. ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៥ ដើម្បីធ្វើការពិនិត្យអន្តការណ៍ទៅលើបុគ្គលដែលមិនគោរពទៅតាមវិធានរបស់ក្រសួងសុខាភិបាល នេះជាការដោះស្រាយបញ្ហាបន្ទាន់ និងចំពោះមុខ ទម្រាំច្បាប់ស្តីពីការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និង

ប្រកបដោយគ្រោះថ្នាក់ផ្សេងទៀត ត្រូវបានប្រកាសឱ្យប្រើ និងចូលជាធរមាននៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១។

### ១.៣.១.៤ ទិដ្ឋភាពនៃប្រព័ន្ធច្បាប់ស៊ីវិលនៅក្នុងប្រព័ន្ធច្បាប់កម្ពុជា

នៅក្នុងចរិតលក្ខណៈនៃប្រព័ន្ធស៊ីវិល (ប្រព័ន្ធច្បាប់សរសេរ) ការតាក់តែងបទប្បញ្ញត្តិធ្វើឡើងឈរលើធាតុផ្សំ ៣សំខាន់ៗគឺៈ ១) ចរិតលក្ខណៈនីតិវិធី (les éléments de procédure) ២) ចរិតលក្ខណៈសារជាតុ (les éléments substentiels) ៣) ចរិតលក្ខណៈស្ថាបនូបនីយកម្ម (les éléments institutions juridiques)។

១) ចរិតលក្ខណៈនីតិវិធី សំដៅដល់សំណុំវិធីមានចរិតលក្ខណៈនីតិវិធីដែលអនុញ្ញាតឱ្យមានការអនុវត្ត ឬចង្អុលបង្ហាញការអនុវត្តច្បាប់សាធារតុ ពោលគឺជាមធ្យោបាយគាំទ្រដល់ការអនុវត្ត និងជម្រុញឱ្យច្បាប់សារជាតុបង្កើតអានុភាពគតិយុត្ត។ ច្បាប់នីតិវិធីមិនសំដៅដល់តែបែបបទនីតិវិធី ដំណើការដោះស្រាយវិវាទតាមផ្លូវតុលាការឡើយ ប៉ុន្តែនីតិវិធី នៅក្នុងន័យនេះ សំដៅដល់មធ្យោបាយដែលរុញឱ្យច្បាប់សាធារតុមានអានុភាព ទៅលើបញ្ហាជាក់លាក់ណាមួយ ឬទៅលើបុគ្គលណាម្នាក់ តាមរយៈបុគ្គលដែលទទួលបាននីតិសម្បទាពីក្នុងនាមជានគរបាលយុត្តិធម៌។ ការណ៍នេះ ជានានូវសិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់ និងដោយគ្មានការរើសអើងស្របតាមសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សក្របខ័ណ្ឌសហប្រជាជាតិឆ្នាំ១៩៤៨ និយាយដោយឡែកសម្រាប់កម្ពុជាមានចែងនៅក្នុងវាក្យខ័ណ្ឌទី២ មាត្រា៣១ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា[១៩]។

២) ចរិតលក្ខណៈសារជាតុ សំដៅដល់បណ្តុំនៃឋានានុក្រមគតិយុត្តជាមូលដ្ឋានគ្រឹះ ដែលកំណត់អំពីសិទ្ធិ និងកាតព្វកិច្ចរបស់បុគ្គលម្នាក់ៗ ជាពិសេសចំណងគតិយុត្តទៅនឹងរដ្ឋ ឬអាចនិយាយបានថាជាគ្រប់វិធានគតិយុត្តជាធរមានជាមូលដ្ឋានគ្រឹះ។ ជាការពិតនៅក្នុងចរិតលក្ខណៈនៃច្បាប់សាធារតុ ផ្សំឡើងដោយធាតុផ្សំពីរ សំខាន់ៗគឺៈ ទី១) នីតិវត្ថុវិស័យសំដៅដល់សំណុំវិធានទាំងឡាយមានគោលបំណងគ្រប់គ្រងទំនាក់ទំនងរបស់បុគ្គលនៅក្នុងសង្គម ព្រមទាំងជានានូវសណ្តាប់ធ្នាប់សាធារណៈ ពោលគឺមានគោលបំណងដោះស្រាយបញ្ហានៅក្នុងសង្គម។ ទី២) នីតិអត្តវិស័យ សំដៅដល់សំណុំវិធានកំណត់អំពីសិទ្ធិរបស់បុគ្គលម្នាក់ៗក្នុងនាមជាប្រធាននៃនីតិទៅលើទំនាក់ទំនងគតិយុត្តលើកម្មសិទ្ធិ ឬទំនាក់ទំនងជាមួយបុគ្គល ព្រមទាំងសិទ្ធិទទួលការការពារទៅលើអំពើព្យសនកម្ម ពោលគឺជានីតិផ្សាភ្ជាប់ទៅនឹងចរិតលក្ខណៈធម្មជតិរបស់មនុស្សដែលចាំបាច់ត្រូវទទួលបានការការពារក្នុងសេចក្តីថ្លៃថ្នូរជាមនុស្ស[២០]។

---

[១៩] Le Droit substantial et droit processuel, Revu lexsociété, Cedric CHAPELLE, Docteur en droit privé-Juriste Docteur du CERDP Université Cote d'Azur, P.៣.

[២០] *Idem*, P.៥.

៣) ចរិតលក្ខណៈស្ថាបនូបនីយកម្ម សំដៅដល់សំណុំវិធានកំណត់អំពីការរៀបចំ រចនាសម្ព័ន្ធ និងស្ថាប័ន ដែលទទួលបាននីតិសម្បទាក្នុងនាមជានគរបាលយុត្ត ឬអំណាចតុលាការ ដែលជានាការដោះស្រាយបញ្ហាជាក់ក្នុងសង្គម ឬបញ្ហាជាក់លាក់របស់រដ្ឋ ពោលគឺធ្វើយ៉ាងណាជានាឱ្យបាននូវសណ្ដាប់ធ្នាប់សាធារណៈ សន្តិសុខគតិយុត្ត និងដំណើការប្រព្រឹត្តរបស់សង្គម តាមរយៈវិធាន និងនីតិវិធីនៃការដោះស្រាយវិវាទដោយអាជ្ញាធរមានសមត្ថកិច្ច ឬបុគ្គលទទួលបាននីតិសម្បទា[៧១]។

សម្រាប់ប្រព័ន្ធច្បាប់ស៊ីវិលនៅក្នុងប្រព័ន្ធច្បាប់កម្ពុជា គឺជាប្រព័ន្ធច្បាប់មួយដែលត្រូវបានយកមកបន្សុំជាមួយនឹងប្រព័ន្ធច្បាប់ប្រពៃណីដែលមានសម្រាប់នៅក្នុងដោយអាណានិគមបារាំង ប៉ុន្តែសញ្ញាណនេះត្រូវបានបំផ្លាញចោលទាំងស្រុងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (កម្ពុជាឆ្នាំសូន្យ) ក្រោយឆ្នាំ១៩៧៩ កម្ពុជាចាប់ផ្ដើមកសាងប្រព័ន្ធច្បាប់របស់ខ្លួនឡើងវិញ ហើយរបត់ថ្មីមួយគឺក្រោយការបង្កើតរដ្ឋាភិបាលស៊ីវិលនៅក្នុងឆ្នាំ១៩៩៣ ប្រព័ន្ធច្បាប់កម្ពុជាថ្មីមួយត្រូវបានរៀបចំឡើងដោយផ្សារភ្ជាប់ទៅនឹងទិដ្ឋភាពនយោបាយ សេដ្ឋកិច្ច សង្គម បរវេណី ស្របតាមតម្លៃប្រវត្តិសាស្ត្រកម្ពុជា និងបរិការណ៍អន្តរជាតិ។ ចរិកលក្ខណៈបទប្បញ្ញត្តិសរសេរ និងការសងក្រងជាក្រម ឋានានុក្រមគតិយុត្ត គឺជាអត្តសញ្ញាណនៃប្រព័ន្ធច្បាប់កម្ពុជា ប៉ុន្តែការកសាងច្បាប់របស់កម្ពុជា ជាបទពិសោធន៍ធ្វើឡើងតាមការតម្រូវរបស់ម្ចាស់ជំនួយ និងទៅតាមជំនាញការបរទេស ដែលធ្វើឱ្យគ្មានសាមញ្ញកម្មនៃអត្ថបទគតិយុត្ត ឧទាហរណ៍៖ ករណីក្រមព្រហ្មទណ្ឌទទួលបានជំនួយពីបារាំង ក្រមរដ្ឋប្បវេណី ទទួលបានជំនួយពីជប៉ុន បច្ចេកស័ព្ទមួយចំនួនត្រូវបានបង្កើតថ្មី និងត្រូវបានខ្ចីពីបរទេស ប៉ុន្តែមិនមានន័យថា អត្ថបទគតិយុត្តទាំងនោះត្រូវបានចម្លងទាំងស្រុងពីបរទេស គឺមានការបញ្ចូលគុណតម្លៃជាខ្មែរនៅក្នុងនោះផងដែរ ឧទាហរណ៍ ពិធីកំដាប់ពាក្យ បទហៅអ្នកដទៃតាមទីសាធារណៈជាដើម ការណ៍នេះបង្ហាញថាយើងយកគម្រូនូវចរិកលក្ខណៈនីតិ ប៉ុន្តែចរិតលក្ខណៈសារជាតុយើងបញ្ចូលគុណតម្លៃជាខ្មែរមួយចំនួននៅក្នុងនោះ។ សម្រាប់ចរិកលក្ខណៈស្ថាប័ន នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា យើងមិនបានមាននិយាមក្នុងការកំណត់ឱ្យបានច្បាស់លាស់ ដើម្បីធ្វើការតាមដានត្រូវពិនិត្យ និងវាយតម្លៃ ទៅលើអត្ថបទគតិយុត្តទាំងនោះ ធ្វើឱ្យមានវិវាទសមត្ថកិច្ច ជាច្រើនរវាងក្រសួង ស្ថាប័ន។

ប្រព័ន្ធច្បាប់កម្ពុជានេះត្រូវបានរៀបចំ និងធ្វើការកែប្រែឡើងវិញ ចំនួន ៤លើកនៅចន្លោះស.វ. ទី១៧ ដល់ ស.វ.ទី១៩ ក្នុងរាជព្រះបាទជ័យជេដ្ឋាទី២ ព្រះបាទជ័យជេដ្ឋាទី៣ ព្រះបាទអង្គឌួង និងព្រះបាទនរោត្តម។

[៧១] Fiches de Culture juridique, Fiche ១០. L'institution Par Jean-Philippe Tricoit, P. ៧១ à ៧៦.

### ១.៣.១.៥ ការបង្កើត ការបកស្រាយ និងការអនុវត្តច្បាប់នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល

នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល (Civil Law System) ការបង្កើតច្បាប់ ការបកស្រាយច្បាប់ និងការអនុវត្តច្បាប់មានលក្ខណៈជាប្រព័ន្ធ និងផ្អែកជាចម្បងលើក្រមច្បាប់ (codified laws)។ ខាងក្រោមនេះជាការពន្យល់លម្អិតអំពីដំណើរការទាំងបីនេះ៖

- ការបង្កើតច្បាប់ (Law-Making)
  - អ្នកបង្កើតច្បាប់៖ នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល ច្បាប់ត្រូវបានបង្កើតឡើងជាចម្បងដោយស្ថាប័ននីតិបញ្ញត្តិ (ឧ. រដ្ឋសភា) ដែលតំណាងឱ្យឆន្ទៈរបស់ប្រជាជន។ នេះឆ្លុះបញ្ចាំងពីគំនិតអធិបតេយ្យភាពរបស់រដ្ឋ។
  - លក្ខណៈពិសេស៖ ការបង្កើតច្បាប់ផ្ដោតលើភាពច្បាស់លាស់ និងឯកភាព ដើម្បីធានាថាច្បាប់អាចអនុវត្តបានជាសកលនៅក្នុងប្រទេស។
- ការបកស្រាយច្បាប់ (Interpretation of Law)
  - អ្នកបកស្រាយ៖ ការបកស្រាយច្បាប់ជាទូទៅជាភារកិច្ចរបស់ចៅក្រម និងអ្នកប្រាជ្ញផ្នែកច្បាប់ (legal scholars)។ ទោះជាយ៉ាងណា នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល ចៅក្រមមានសិទ្ធិបកស្រាយតិចតួចជាងនៅក្នុងប្រព័ន្ធច្បាប់អង់គ្លូសាក់សង់ (Common Law)។
  - របៀបបកស្រាយ៖
    - ផ្អែកលើក្រមច្បាប់៖ ចៅក្រមត្រូវបកស្រាយច្បាប់ដោយផ្អែកលើអត្ថបទនៃក្រម ឬច្បាប់ គោលបំណងគឺដើម្បីអនុវត្តច្បាប់ឱ្យស៊ីសង្វាក់នឹងអត្ថន័យដើម។
    - គោលការណ៍ទូទៅនៃច្បាប់ (General Principles of Law)៖ ប្រសិនបើក្រមច្បាប់មិនគ្របដណ្ដប់លើករណីជាក់លាក់ ចៅក្រមអាចប្រើគោលការណ៍ទូទៅ ដូចជា យុត្តិធម៌ ឬសុចរិតភាព។
    - ការបកស្រាយបែបប្រពៃណី៖ ការបកស្រាយច្បាប់ច្រើនតែផ្អែកលើប្រពៃណីច្បាប់រ៉ូម៉ាំង និងការសិក្សារបស់អ្នកប្រាជ្ញផ្នែកច្បាប់។
    - នីតិវិធីបកស្រាយ៖ ចៅក្រមប្រើវិធីសាស្ត្រដូចជា ការបកស្រាយតាមអក្សរ (literal interpretation) ការបកស្រាយតាមបរិបទ (contextual interpretation) ឬការបកស្រាយតាមគោលបំណង (purposive interpretation)។
  - លក្ខណៈពិសេស៖ ការបកស្រាយនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលមានភាពរឹងមាំជាងប្រព័ន្ធច្បាប់ទូទៅ ព្រោះចៅក្រមមិនអាចបង្កើតច្បាប់ថ្មី ប៉ុន្តែអាចបកស្រាយក្នុងក្របខ័ណ្ឌនៃច្បាប់។

- ការអនុវត្តច្បាប់ (Application of Law)
  - អ្នកអនុវត្តៈ ចៅក្រម និងស្ថាប័នតុលាការជាអ្នកអនុវត្តច្បាប់ចម្បង។ មន្ត្រីសាធារណៈក៏មានតួនាទីក្នុងការអនុវត្តច្បាប់នៅក្នុងវិស័យរដ្ឋបាល។
  - របៀបអនុវត្តៈ
    - ដំណើរការតុលាការៈ នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល ដំណើរការតុលាការជាទូទៅជាបែបស៊ើបអង្កេត (inquisitorial) ដែលចៅក្រមដើរតួនាទីសកម្មក្នុងការស៊ើបអង្កេតករណី និងស្វែងរកភស្តុតាង ជាជាងពឹងផ្អែកលើភាគីទាំងសងខាងដូចនៅក្នុងប្រព័ន្ធច្បាប់ទូទៅ (adversarial system)។
    - ផ្អែកលើក្រមច្បាប់ៈ ចៅក្រមអនុវត្តច្បាប់ដោយផ្អែកលើអត្ថបទនៃក្រម ឬច្បាប់លក្ខន្តិកៈ។ ឧទាហរណ៍ៈ នៅក្នុងករណីជម្លោះកិច្ចសន្យា ចៅក្រមនឹងយោងទៅលើក្រមស៊ីវិលដើម្បីសម្រេច។
    - សេចក្តីសម្រេចៈ សេចក្តីសម្រេចរបស់ចៅក្រមមិនបង្កើតជាសេចក្តីសម្រេចគំរូដែលចងភ្ជាប់តុលាការផ្សេងទៀតទេ។ ទោះជាយ៉ាងណា សេចក្តីសម្រេចរបស់តុលាការជាន់ខ្ពស់អាចមានឥទ្ធិពលជាគោលការណ៍ណែនាំ។
    - ទំនៀមទម្លាប់ និងអនុសញ្ញាអន្តរជាតិៈ នៅក្នុងករណីដែលក្រមច្បាប់មិនគ្របដណ្តប់ ទំនៀមទម្លាប់ ឬអនុសញ្ញាអន្តរជាតិ (ឧ. សន្ធិសញ្ញាស្តីពីសិទ្ធិមនុស្ស) អាចត្រូវបានអនុវត្ត។
  - លក្ខណៈពិសេសៈ ការអនុវត្តច្បាប់មានភាពឯកភាព និងផ្តោតលើការអនុលោមតាមក្រមច្បាប់។ ចៅក្រមមានតួនាទីតិចតួចក្នុងការបង្កើតច្បាប់ថ្មី ប៉ុន្តែផ្តោតលើការអនុវត្តច្បាប់ដែលមានស្រាប់។

### ១.៣.១.៦ ប្រពៃណីក្រមនីយកម្ម

ក្រមនីយកម្ម គឺជាដំណើរការនៃការរៀបចំជារចនាសម្ព័ន្ធ និងប្រមូលចងក្រងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ជាប្រព័ន្ធរចនាសម្ព័ន្ធ ឬប្រែក្លាយទៅជាអត្ថបទក្រម ឬការប្រមូលផ្តុំបញ្ចូលគ្នារវាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តតាមវិស័យទៅជាអត្ថបទគតិយុត្តតែមួយ ក្រោមទម្រង់ជាអត្ថបទគតិយុត្តថ្មីមួយ។ នៅក្នុងចរិកលក្ខណៈស្ថាប័ន ក្រមនីយកម្មសំដៅដល់ការប្រមូលចងក្រង និងរៀបចំលំដាប់ដោយអត្ថបទគតិយុត្ត ដើម្បីរៀបចំជារចនាសម្ព័ន្ធអត្ថបទគតិយុត្តជាក់លាក់ ដែលអាចត្រូវបានអនុវត្តព្រឹត្តិការណ៍គតិយុត្តជាក់លាក់។ ពាក្យថាក្រម ត្រូវបានរកឃើញនៅក្នុងអាណាចក្ររ៉ូម ពីពាក្យថា *codex* សំដៅដល់ Code Justinien ក្រោមការដឹកនាំរបស់អធិរាជ Byzantin Justinien I នៅក្នុងស.វ.ទី៦ នៃគ.ស. ។ ក្រមនេះ គឺជាអត្ថបទចងក្រងនៃរដ្ឋធម្មនុញ្ញក្រោមការគ្រប់គ្រងរបស់អធិរាជមុនៗ ការរៀបចំទៅតាមខ្លឹមសារ ប្រធានបទ និងជាការ

បង្ហាញអំពីការខិតខំប្រឹងប្រែងធ្វើក្រមនីយកម្មនៃច្បាប់រ៉ូម៉ាំង[២២]។ គោលបំណងនៃការធ្វើក្រមនីយកម្មត្រូវបានធ្វើនៅក្នុងទូទាំងអឺរ៉ុប ដែលជាអតីតទឹកដីរបស់ចក្រភពរ៉ូម៉ាំង គឺធ្វើប្រមូលចងក្រងបវេណីចាស់ៗ ដើម្បីបង្កើតជាសសរស្ដំ និងជាភ័ស្ដុតាងតាមរយៈផ្នែកតាមអត្ថបទគតិយុត្តដែលត្រូវបានរៀបចំ ជាក់ស្ដែងការចងក្រងបវេណីនៃបារាំងខាងជើង ក្នុងសម័យស្ដេច Charles VII[២៣]។ នៅក្នុងច្បាប់ទំនើបរបស់ខ្មែរ ក្រមរដ្ឋប្បវេណីដំបូងរបស់បារាំង ត្រូវបានផ្ដល់សច្ចាប័ននៅក្នុងឆ្នាំ១៩២០ ដែលត្រូវបានកែប្រែពីក្រមណាប៉ូឡេអ៊ុង ឆ្នាំ១៨០៤ ដែលត្រូវបានបកជាក្រមរដ្ឋប្បវេណីខ្មែរ នៅក្នុងឆ្នាំ១៩៦៧ ដើម្បីងាយស្រួលអនុវត្ត និងឱ្យប្រជាជនខ្មែរបានយល់។

ក្រមគឺជាដំណើការក្នុងការចងក្រងអត្ថបទគតិយុត្ត មានជាអាទិ៍៖ ច្បាប់ (textes législatives) និងលិខិតបទដ្ឋានគតិយុត្តក្រមច្បាប់ (textes règlementaires) យុត្តិសាស្ត្រ បវេណី ដែលជាជំនួយទៅដល់ការពន្យល់ ការបកស្រាយ និងការអនុវត្តច្បាប់ឱ្យទៅជាអត្ថបទគតិយុត្តថ្មីមួយ ដោយធ្វើការបែងចែកទៅជាគន្ថី ជាផ្នែក ជាជំពូក ជាកថាខណ្ឌ ដោយមានលក្ខណៈប្រទាក់ក្រឡាគ្នា ច្បាស់លាស់ និងងាយស្រួលប្រឹក្សាប្រើប្រាស់ជាវិធានគោលដើម្បីគ្រប់គ្រងទំនាក់ទំនងគតិយុត្តនៅក្នុងវិស័យជាក់លាក់[២៤]។ នៅក្នុងក្រមនីយកម្មរបស់បារាំងក្រមនេះបែងចែកជាពីរ ប្រភេទគឺ៖ ១) ក្រមធំ ( Maxi-codes) ដែលបានលក្ខណៈទូលាយ ធំ និងអាចប្រឹក្សាបានងាយស្រួល និងក្រមតូច (Mini-codes) ដែលប្រមូលផ្ដុំតែច្បាប់ចំនួនពីរនៅក្នុងវិស័យ ជាក់លាក់ប៉ុណ្ណោះ[២៥]។ ការធ្វើក្រមនីយកម្ម ផ្ដើមចេញពីការប្រមូលចងក្រងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាននៅក្នុងវិស័យពាក់ព័ន្ធ ហើយដាក់ច្បាប់អក្សរកាត់ទៅខាងមុខមាត្រា ឬ បទប្បញ្ញត្តិទាំងនោះដើម្បីសម្គាល់ចរិកលក្ខណៈនៃបទប្បញ្ញត្តិទាំងនោះ[២៦]។

តើប្រព័ន្ធច្បាប់ស៊ីវិលដោះស្រាយជម្លោះកាតព្វកិច្ចរវាងច្បាប់ជាតិ និងច្បាប់អន្តរជាតិយ៉ាងដូចម្ដេច?

ការដោះស្រាយវិវាទរវាងច្បាប់ជាតិ និងច្បាប់អន្តរជាតិ នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល ត្រូវគិតទៅលើយុត្តាធិការ ច្បាប់អន្តរជាតិនឹងចងកាតព្វកិច្ចរដ្ឋមួយដែលជាប្រធាននៃនីតិអន្តរជាតិលុះត្រាតែ ក្រោយពេលអ្នកតំណាងស្របច្បាប់របស់រដ្ឋមួយបានយល់ព្រមចុះកិច្ចព្រម ឬបានអនុម័តទៅលើលិខិតតូបករណ៍អន្តរជាតិចាំបាច់ត្រូវផ្ដល់សច្ចាប័ន (*Pata Sunt Servenda*)តាមនីតិវិធីផ្ទៃក្នុងស្របតាមច្បាប់ជាតិរបស់ប្រទេស

---

[២២] P. Bourdieu, « Habitus, code et codification », Actes de la recherche en sciences sociales, ១៩៨៦, P.៤១.

[២៣] La codification, Académie des Sciences et Lettres de Montpellier, Rémy CABRILLAC Professeur a l'Université de Montpellier, Faculté de Droit et de Science Politique, Séance du ១៧ mai ២០២១, P.៥.

[២៤] ១.៤.២. Codification, Guide de légistique, ៣ème édition, P.៣.

[២៥] ១.៤.២. Codification, Guide de légistique, ៣ème édition, P.៧.

[២៦] ជាបទពិសោធន៍របស់បារាំងគេដាក់ពាក្យ LO នៅខាងមុខមាត្រាដើម្បីសម្គាល់ច្បាប់រៀបចំអង្គការ ឬច្បាប់អង្គិន, L សម្រាប់ច្បាប់ធម្មតា, D ឬ D* សម្គាល់ក្រឹត្យចេញដោយគណៈរដ្ឋមន្ត្រី, R ឬ R* ក្រឹត្យឆ្លងកាត់ការផ្ដល់យោបល់របស់គណៈរដ្ឋមន្ត្រី។

ខ្លួន[២៧]។ នៅក្នុងទ្រឹស្តីជាសាកលស្តីពីឋានានុក្រមគតិយុត្តអន្តរជាតិ រដ្ឋគឺជាប្រធាននៃនីតិអន្តរជាតិចម្បង បើគ្មានរដ្ឋក៏គ្មានច្បាប់អន្តរជាតិ ក៏គ្មានសណ្តាប់ធ្នាប់គតិយុត្តអន្តរជាតិដែរ ហើយនេះរដ្ឋធម្មនុញ្ញនៃរដ្ឋនីមួយៗ មានតម្លៃខ្ពស់ជាងធម្មនុញ្ញ និងលិខិតូបករណ៍អន្តរជាតិដទៃទៀត[២៨] ដែលត្រូវចរឹកនៅក្នុងលក្ខន្តិកៈបង្កើតនៃអង្គការ អន្តរជាតិទាំងក្រោមទម្រង់ជា អង្គការសហប្រតិបត្តិការអន្តររដ្ឋាភិបាល (Intergovernmental Organization) ឬស្ថាប័នដែលមានឋានានុក្រមខ្ពស់ជាងរដ្ឋ (Supreme National Organization)។ ដោយហេតុថាប្រព័ន្ធច្បាប់ស៊ីវិល គឺជាប្រព័ន្ធច្បាប់សរសេរ ហើយនេះលិខិតូបករណ៍អន្តរជាតិមិនអាចយកទៅអនុវត្តដោយផ្ទាល់នៅក្នុងឋានានុក្រមគតិយុត្តនៃប្រព័ន្ធច្បាប់ជាតិឡើយ ពោលគឺការប្រកាន់យកនូវប្រព័ន្ធទ្វិកនិយម[២៩] (Dualisme)។ ការអនុម័តច្បាប់ដើម្បីអនុវត្តលិខិតតូបករណ៍អន្តរជាតិ ដែលរដ្ឋនោះបានចុះ និយាយដោយឡែក ព្រះរាជាណាចក្រកម្ពុជា គឺជាកាតព្វកិច្ចចាំបាច់ និងដាច់ខាត ព្រមទាំងចាំបាច់ត្រូវបង្កើតច្បាប់ជាតិដើម្បីអនុវត្តទៅលើលិខិតូបករណ៍អន្តរជាតិទាំងនោះ។ នៅក្នុងករណីមានវិវាទសមត្ថកិច្ចរវាងច្បាប់អន្តរជាតិ និងច្បាប់ជាតិ ត្រូវពិនិត្យមើលទៅលើវិធាននៃការដោះស្រាយវិវាទដោយត្រូវពិនិត្យទៅលើច្បាប់ជាតិពាក់ព័ន្ធ ជាមុនសិន នៅក្នុងករណីច្បាប់ជាតិជាធរមានមិនបានកំណត់អំពីវិធានដោះស្រាយវិវាទសមត្ថកិច្ចច្បាប់ ទៅត្រូវពិនិត្យទៅលើលិខិតូបករណ៍អន្តរជាតិពាក់ព័ន្ធ ដើម្បីកំណត់អំពីវិធានដោះស្រាយវិវាទច្បាប់[៣០]។

តើការដោះស្រាយវិវាទគតិយុត្តក្នុងប្រព័ន្ធច្បាប់ស៊ីវិលប្រព្រឹត្តទៅយ៉ាងដូចម្តេច?

ចំ. វិវាទគតិយុត្ត និយាយដោយឡែកនៅក្នុងបរិបទនៃកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា សំដៅដល់ការជាន់សមត្ថកិច្ចរវាងក្រសួង ស្ថាប័ន អង្គភាព រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិពាក់ព័ន្ធ ដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ទៅលើវិស័យជាក់លាក់ ដែលត្រូវបានកំណត់នៅក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ ការដោះស្រាយវិវាទគតិយុត្តនេះផ្សារភ្ជាប់ទៅនឹងការការបកស្រាយច្បាប់ ដែលត្រូវបានធ្វើឡើងក្រោមទម្រង់ជាលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់មាន ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ដីកា សារាចរ សម្រេច ជាដើម ចាំបាច់ត្រូវធានាឱ្យបាននូវនីត្យានុកូលភាព និងអនុលោមភាព ទៅលើច្បាប់ និងឋានានុក្រមគតិយុត្ត ជាធរមាន ត្រូវរៀបចំឱ្យក្របខ័ណ្ឌទស្សនាទាននៃការដោះស្រាយវិវាទគតិយុត្តឱ្យបានច្បាស់លាស់។

---

[២៧] Vienna Convention in ១៩៨៦ on the law of treaties, article ១០, P.b.

[២៨] « ការធ្វើវិចារណកម្មរបស់ Thomas Hobbes, Contract Social ou Principe du Droit Politique par Jean-Jacques Rousseau» La souveraineté en et de droit international, Petit exercice de démystification, Samantha Besson, P.៤១៣.

[២៩] «នៅក្នុងប្រព័ន្ធទ្វិកនិយម (Dualisme) ឋានានុក្រមគតិយុត្តអន្តរជាតិ និងឋានានុក្រមគតិយុត្តជាតិ គឺជាឋានានុក្រមគតិយុត្តពីរដាច់ដោយឡែកពីគ្នា» សេចក្តីសម្រេចក្រុមប្រឹក្សាធម្មនុញ្ញបារាំង ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៧៥។

[៣០] Article១៧, ១៨ , Vienna Convention on ២៣ may ១៩៦៩ entry into force on ២៧ January ១៩៨០.

#### ១.៣.១.៧ ប្រព័ន្ធច្បាប់ស៊ីវិលធានានូវសង្គតិភាព ឯកសណ្ឋានភាព និង សុខដុមនីយកម្ម

ដើម្បីធានានូវសង្គតិភាព ឯកសណ្ឋានភាព និងសុខដុមរមនានៃច្បាប់ ចាំបាច់៖

- រៀបចំឱ្យមានក្រមនីយកម្មតាមវិស័យ
- រៀបចំសទ្ទានុក្រមតាមវិស័យ
- រៀបចំមគ្គទេសក៍សិល្បសាស្ត្រនីតិកម្ម
- រៀបចំមគ្គទេសក៍សិល្បសាស្ត្រនីតិសាស្ត្រ
- យន្តការអន្តរវិស័យ៖
    - គណៈកម្មាធិការជាតិភាសាច្បាប់
    - គណៈកម្មាធិការជាតិការពារនីត្យានុកូលភាព។

សម្រាប់ការធានានូវសង្គមតិភាព ឯកសណ្ឋានភាព និងសុខដុមនីយកម្មនៃប្រព័ន្ធច្បាប់កម្ពុជា ចាំបាច់ត្រូវគិតគូរទៅលើគុណតម្លៃកម្ពុជា ដោយត្រូវបន្សីជាមួយនឹងឧតមានុវត្តអន្តរជាតិ មានន័យថាការបង្កើតច្បាប់ ការបកស្រាយច្បាប់ និងការអនុវត្តច្បាប់ត្រូវឈរលើមូលដ្ឋានទស្សនវិជ្ជាច្បាប់ និងបវេណីខ្មែរ ទើបធានាបាននូវយុត្តិធម៌សង្គម និងសុខដុមនីយកម្មសង្គម។ យុត្តិធម៌តាមផ្លូវច្បាប់ និងយុត្តិធម៌សង្គម ត្រូវដើរទន្ទឹមគ្នា ទើបអាចបំពេញគន្លាតសង្គមបាន ពុំនោះទេមិនអាចធានានូវស្ថិរភាព និការអភិវឌ្ឍប្រកបដោយបរិយាបន្នបានឡើយ ហើយកត្តាអយុត្តិធម៌សង្គម និងអយុត្តិធម៌តាមផ្លូវច្បាប់ ជាផ្នែកមួយនាំឱ្យប៉ះពាល់ដល់សុខសន្តិភាព ផងដែរ។

ការសម្រេចបានមហិច្ឆតាក្លាយជាប្រទេសដែលមានចំណូលខ្ពស់នៅក្នុងឆ្នាំ២០២៥ ដូចបានកំណត់នៅក្នុងយុត្តិសាស្ត្របច្ចកោណ ជាពិសេសដំណាក់កាលទី១ នៃរាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា កិច្ចការកែទម្រង់ច្បាប់ដែលមានលក្ខណៈជាប្រព័ន្ធ និងមានលក្ខណៈស្ថាប័នចាំបាច់ត្រូវធ្វើ ព្រមទាំងរៀបចំយន្តការនៃការកែទម្រង់ឱ្យបានច្បាស់លាស់។

### ១.៣.២ ប្រព័ន្ធច្បាប់អង់គ្លូសាក់សុង

#### ១.៣.២.១ ការវិវត្តន៍នៃប្រព័ន្ធច្បាប់អង់គ្លូសាក់សុង

ប្រព័ន្ធច្បាប់អង់គ្លូសាក់សុង (Common Law) លេចឡើងជាដំបូងនៅក្នុងប្រទេសអង់គ្លេស ចេញពីការអនុវត្តនៅមជ្ឈិមសម័យដំបូង និងបានវិវត្តន៍ជាបណ្តើរៗចូលទៅក្នុងប្រព័ន្ធច្បាប់ជាច់ដោយឡែកមួយនៅសតវត្សទី ១៩ ។ ឫសគល់នៃប្រព័ន្ធច្បាប់ ខមមិនឡ ជាប់ទាក់ទងនឹងផ្នែកខ្លះនៅក្នុងទំនៀមទម្លាប់ដូចជា ច្បាប់អង់គ្លូសាក់សុង Anglo-Saxon និងតាមរយៈគំនិតផ្តួចផ្តើមរបស់ស្តេចរបស់ជនជាតិNorman ក្នុងឆ្នាំ ១០៦៦។ បែបបទច្បាប់របស់ Anglo-Saxon មុនឆ្នាំ ១០៦៦ គឺមានលក្ខណៈពឹងផ្អែកលើទម្លាប់

ទំនៀមទម្លាប់ មិនមានការកំណត់ជារួម រីឯការវិនិច្ឆ័យត្រូវបានអនុវត្តតាមតុលាការក្នុងស្រុក (hundred និង shire moots) ដោយគ្មានចៅក្រមវិជ្ជាជីវៈ ឬកំណត់ត្រាច្បាប់ជាលាយលក្ខណ៍អក្សរ។ ការអនុវត្តយុត្តិធម៌កាលនោះមានលក្ខណៈសាមញ្ញ ដោយប្រើនីតិវិធីដូចជា *compurgation* (ការបញ្ជាក់ដោយសច្ចា) និង *trial by ordeal* (ការសាកល្បងតាមរយៈវិធីសាស្ត្រពិសោធន៍) ដើម្បីកំណត់កំហុសឬទំនួលខុសត្រូវ។ ច្បាប់ដំបូងៗនេះត្រូវបានកត់ត្រា ក្នុងក្រមច្បាប់របស់ស្តេច Anglo-Saxon ប៉ុន្តែមិនមានសង្គតិភាពក្នុងការអនុវត្តនោះទេ។ ចំណុចសំខាន់គឺ ក្នុងសម័យ Anglo-Saxon អង់គ្លេសមិនមានច្បាប់ជារួម ឬច្បាប់កណ្ដាលតែមួយ និងមិនមានមិនមានតុលាការកណ្ដាលណាមួយដើម្បីអនុវត្តច្បាប់ឯកភាពលើទូទាំងប្រទេស។ ទោះជាយ៉ាងនេះក្តី បន្ទាប់ពីការឈ្នះនៃ Norman Conquest នៅឆ្នាំ ១០៦៦ ប្រព័ន្ធច្បាប់នៅអង់គ្លេស បានផ្លាស់ប្តូរ។

ជ័យជំនះរបស់ពួកន័រមេន Norman ក្រោមការដឹកនាំរបស់ស្តេច William I (William the Conqueror) នៅក្នុងឆ្នាំ ១០៦៦ បាននាំមកនូវអំណាចកណ្ដាលដ៏រឹងមាំសម្រាប់ស្ថាប័នព្រះមហាក្សត្រ និងរចនាសម្ព័ន្ធសក្តិភូមិដែលរឹងមាំជាងមុន (feudal structures) ដែលបានបង្កើតជាមូលដ្ឋានសម្រាប់ឯកភាពនៃប្រព័ន្ធច្បាប់។ បើទោះបីជាស្តេច William បានគោរពច្បាប់ទំនៀមទម្លាប់មួយចំនួនរបស់ Anglo-Saxonក៏ដោយ ប៉ុន្តែទ្រង់បានបង្កើតតុលាការកណ្ដាលឬតុលាការរាជវង្ស (Curia Regis) ដែលជាប្រភពនៃការផ្តល់យុត្តិធម៌។ អំណាចរបស់ព្រះមហាក្សត្រគឺ ពឹងផ្អែកទៅលើការត្រួតពិនិត្យលើច្បាប់ និងតុលាការដែលជាមូលដ្ឋាននៃនីតិរួម (common law)។ តុលាការរាជាវង្ស (Curia Regis) ដែលមានមន្ត្រីរាជការ ពួកវណ្ណៈខ្ពស់បានធ្វើដំណើរតាមព្រះមហាក្សត្រដើម្បីផ្តល់យុត្តិធម៌ជូនប្រជាជន។ ទោះជាយ៉ាងនេះក្តី រហូតដល់ពាក់កណ្ដាលសតវត្សរ៍ទី ១២ ការអនុវត្តយុត្តិធម៌របស់រាជ្យ នៅតែមានលក្ខណៈមិនទៀងទាត់ (ad hoc) និងមានដែនកំណត់ត្រឹមតែផ្នែកភូមិសាស្ត្រ ដែលព្រះមហាក្សត្រស្ថិតនៅក្នុងពេលនោះ។

មកដល់រជ្ជកាលនៃការធ្វើកំណែទម្រង់របស់ស្តេច Henry II (ឆ្នាំ ១១៥៤–១១៨៩) ជាព្រឹត្តិការណ៍សំខាន់នៅក្នុងកំណែទម្រង់ដែលបង្កើតនូវប្រព័ន្ធច្បាប់អង់គ្លូសាក់សុងរបស់អង់គ្លេស។ ស្តេច Henry II ដែលត្រូវបានគេហៅថា "the Father of the Common Law" ឬ "បិតានៃនីតិរួម" បានអនុវត្តកំណែទម្រង់ដ៏ទូលំទូលាយ ដែលបានបង្កើតប្រព័ន្ធតុលាការដែលមានឥទ្ធិពល និងឯកភាពទូទាំងប្រទេសអង់គ្លេស។ ក្នុងឆ្នាំ ១១៦៦ ព្រះអង្គបានប្រកាស Assize of Clarendon ដែលជាបទបញ្ញត្តិសំខាន់បំផុត ក្នុងការផ្លាស់ប្តូរទម្រង់នីតិវិធីច្បាប់។ បទបញ្ញត្តិនេះបានបង្កើតតុលាការរាជ្យ (*royal justices* ឬ *justices in eyre*) ដោយមានចៅក្រមធ្វើដំណើរ (circuit) ទៅទូទាំងប្រទេស ដើម្បីស្តាប់សវនាការ មិនមែនជាតុលាការរួមជាមួយព្រះមហាក្សត្រតែមួយកន្លែងទេ។ ចៅក្រមទាំងនេះ មានភារកិច្ចអនុវត្តច្បាប់ឲ្យមានឯកសណ្ឋាន ស៊ីសង្វាក់គ្នា នៅគ្រប់តំបន់ជាជាងការពឹងផ្អែកលើទំនៀមទម្លាប់ក្នុងស្រុក ឬច្បាប់ប្រពៃណីជាក់លាក់ចំពោះតំបន់នីមួយៗ។

ស្ថាប័នតុលាការរបស់ស្តេច ឬ King's court or Curia Regis មិនមែនគ្រាន់តែជាតុលាការប៉ុណ្ណោះទេ ប៉ុន្តែជាក្រុមប្រឹក្សាកណ្តាលរបស់ស្តេច ដែលដើរតួនាទីជាស្ថាប័ននៃទីប្រឹក្សារបស់ក្រុមវណ្ណៈខ្ពស់ (aristocratic) បព្វជិត និងមន្ត្រីរាជការសំខាន់ៗ ដើម្បីជួយគ្រប់គ្រង ត្រួតពិនិត្យអាណាចក្រ ប្រឹក្សាយោបលើផ្នែកច្បាប់ រដ្ឋបាល ហិរញ្ញវត្ថុ និងយុត្តិធម៌។ ក្នុងនោះ ស្តេច Henry II បានឲ្យ"General Eyres" ធ្វើដំណើរចេញពីតំបន់មួយទៅតំបន់មួយៗដើម្បីស្តាប់វិវាទ និងអនុវត្តច្បាប់របស់ស្តេចទៅគ្រប់កន្លែងដែលពួកគេទៅ ដើម្បីធានាថា ការអនុវត្តនៅមូលដ្ឋានទាំងអស់ស្គាល់និងគោរពតាមស្តង់ដារស្របគ្នា។ ហេតុនេះ សេចក្តីសម្រេចដែលធ្វើឡើងដោយចៅក្រមទាំងនោះត្រូវបានកត់ត្រាទុក និងជួយបង្កើតតួអង្គជំនុំជម្រះនៃសំណុំរឿង សម្រាប់យកមកប្រើសម្រាប់សំណុំរឿងក្នុងរយៈពេលខាងមុខ។

ស្តេច Henry II នាំយកប្រព័ន្ធច្បាប់សរសេរ ឬដីកា (writ-system) ដែលជួយសម្រួលដល់ប្រជាជនក្នុងការទទួលបានយុត្តិធម៌។ ច្បាប់សេរសេរនៅក្នុងប្រព័ន្ធនេះ សំដៅដល់ការចេញដីកា(writ) ដែលសរសេរជាលាយលក្ខអក្សរផ្លូវការពីព្រះមហាក្សត្រ ដែលកោះហៅបុគ្គលណាម្នាក់ឲ្យចូលខ្លួន ឬផ្តន្ទាទោសតាមច្បាប់។ បន្ថែមពីនេះ ស្តេច បានដាក់បញ្ចូលនូវប្រព័ន្ធគណៈវិនិច្ឆ័យ (Jury) បង្កើតឡើងដោយមានសមាសភាពបុរសចំនួន ១២នាក់ មកស្បថថា នឹងនិយាយអ្វីដែលជាការពិតអំពីអ្វីដែលពួកគេបានដឹងទាក់ទងនឹងករណីជាក់លាក់ ឬបទពិសោធន៍ជាក់ស្តែងជាក់ពង្រាយនៅតាមតំបន់។ ប្រព័ន្ធគណៈវិនិច្ឆ័យនេះបានប្រើប្រាស់ដំបូងបំផុត ដើម្បីធ្វើចោទប្រកាន់ក្នុងបទឧក្រិដ្ឋជន ឬជនសង្ស័យ ជាជាងកំណត់អំពីអំពើប្រព្រឹត្តបទល្មើស(ប្រព័ន្ធនេះនឹងវិវត្តន៍នៅពេលក្រោយ)។ នេះ គឺជាការផ្លាស់ប្តូរមួយដ៏សំខាន់ដោយពីមុន វិធីសាស្ត្រនៃការកាត់សេក្តីធ្វើឡើងតាមច្បាប់ប្រពៃណី និង សាសនា ដោយជឿជាក់ថាមានការចូលរួមពីព្រះ។

ច្បាប់ផ្លូវការ ដែលបង្កើតឡើងដោយតុលាការកណ្តាលនៅ Westminster រួមមានសាលក្រមនិងបទបញ្ញត្តិ (*assizes*) ជំនួសការប្រើច្បាប់ទំនៀមទម្លាប់ក្នុងតំបន់។ ការជំនួសច្បាប់នៅក្នុងតំបន់ដោយ ព្រះរាជា និង សេចក្តីសម្រេចតុលាការ (royal edicts and judicial precedents) ដែលមាន€កសណ្ឋានភាពជាប្រព័ន្ធតែមួយដែលធ្វើឲ្យមានការអនុវត្តស្របគ្នានៅទូទាំងប្រទេស។

បន្ទាប់ពីរជ្ជកាលស្តេចហេរីទី២ ប្រព័ន្ធច្បាប់អង់គ្លូសាក់សុង របស់អង់គ្លេស បានរីកចម្រើនជាបន្តបន្ទាប់។ នៅក្នុងឆ្នាំ ១២១៥ ស្តេចចន នៃប្រទេសអង់គ្លេសនៅ Runnymede រងការបះបោរពីពួកវណ្ណៈអភិជនប្រឆាំងនឹងការរំលោភបំពានអំណាចរបស់ស្តេចលើការទារពន្ធហួសប្រមាណ ទើបពួកវណ្ណៈអភិជនទាំងនោះបង្ខំស្តេចចនឲ្យឡាយព្រហ្មលេខាលើMagna Carta ដើម្បីកម្រិតសិទ្ធិអំណាចរបស់ស្តេច និងរបៀបដែលព្រះមហាក្សត្រគ្រប់គ្រងរដ្ឋមិនហួសអំពីពីច្បាប់ចែង។ គោលការណ៍នេះបង្កើតឲ្យមាន នីតិរដ្ឋ (Rule of Law) ដែលទប់ស្កាត់ការរំលោភបំពានអំណាចរបស់ស្តេច។[៣១] Magna Carta ឆ្នាំ ១២១៥ គឺ

---

៣១

ជាឯកសារមានសារៈសំខាន់បំផុតក្នុងយុគសម័យនេះ ព្រោះវាមិនត្រឹមតែបញ្ជាក់សិទ្ធិសំខាន់ៗនៃប្រជាពលរដ្ឋ (substantive rights) ប៉ុណ្ណោះទេ ប៉ុន្តែមានឥទ្ធិពលលើនីតិវិធីតុលាការផងដែរ។ ដូចមានចែងនៅក្នុង Magna Carta៖

"No free man shall be seized or imprisoned or stripped of his rights…except by the lawful judgment of his equals or by the law of the land.[៣២]

To no one will we sell, to no one deny or delay, the right or justice.[៣៣]

Common pleas shall not follow our court, but shall be held in some fixed place".[៣៤]

គោលការណ៍ទាំងពីរនេះ គឺជាឫសគល់នៃដំណើរការយុត្តិធម៌(Due process) ការកាត់សេចក្ដីដោយយុត្តិធម៌ (Fair Trial) និងភាពស្មើគ្នាចំពោះមុខច្បាប់ (equal justice under law) នៅក្នុងតុលាការ។ នេះមានន័យថា ស្ដេចមិនអាចដាក់ទណ្ឌកម្មជនណាមួយដោយមិនមានតុលាការសម្រេចសេចក្ដី និងមិនមានការស៊ើបសំណួក ឬការបដិសេធន៍មិនផ្ដល់យុត្តិធម៌សម្រាប់ប្រជាជននោះឡើយ។ មួយវិញ Magna Carta ប្រការ១៧ បានកំណត់ថា វិវាទរវាងពលរដ្ឋ (common pleas) ត្រូវតែសវនាការនៅកន្លែងថេរ (fixed place)។[៣៥] កន្លែងថេរ សំដៅលើទីដែលចុងចោទគួរតែត្រូវបង្ហាញខ្លួន[៣៦] ដែលខុសប្លែកពីតុលាការរបស់ស្ដេច។ រឿងក្ដីប្រភេទនេះ ជារឿងបុគ្គលដែលមិនជាប់ទាក់ទងនឹងស្ដេច។ ពីមុន ចៅក្រមត្រូវ អមព្រះមហាក្សត្រទៅគ្រប់ទីកន្លែង ជាពិសេសគឺកន្លែងដែលព្រះមហាក្សត្រអាស្រ័យនៅ។ ប៉ុន្តែក្រោយពីមាន Magna Carta ចៅក្រមដែលមិនជាប់ពាក់ព័ន្ធនឹងរឿងដែលទាក់ទងនឹងព្រះមហាក្សត្រមិនតម្រូវឲ្យដើរតាមព្រះមហាក្សត្រទៀតនោះទេ មានន័យថា ចៅក្រមដែលដោះស្រាយរឿងស៊ីវិល ឬវិវាទឯកជនត្រូវមានទីតាំងដាក់លាក់ដើម្បីប្រជាជនអាចដាក់ពាក្យបណ្ដឹង ហើយចុងចោទអាចមកបង្ហាញខ្លួនទៅទីតាំងជាក់លាក់ណាមួយ[៣៧]។

---

[៣២] *Magna Carta, Clause ៣៩.*

[៣៣] *Magna Carta, Clause ៤០.*

[៣៤] *Magna Carta, Clause ១៧.*

[៣៥] "Early Law Courts," Parliament.uk, ២០២៤, https://www.parliament.uk/about/living-heritage/building/pala ce/westminsterhall/government-and-administration/early-law-courts/. (last visited ០៨ Oct.២០២៥).

[៣៦] John Baker, *Introduction to English Legal History* (Oxford University Press, ២០១៩), ២២.

[៣៧] John Baker, *Introduction to English Legal History* (Oxford University Press, ២០១៩), ២២-២៣.

នៅសតវត្សរ៍ទី ១៣ តុលាការចម្បងពីរបានលេចឡើង គឺទី១) តុលាការ Common Pleas សម្រាប់ករណីស៊ីវិលធម្មតា ទី២) តុលាការ King's Bench សម្រាប់ករណីពាក់ព័ន្ធនឹងអំណាចរបស់ព្រះមហាក្សត្រ និងបទល្មើសធ្ងន់ធ្ងរ (*pleas of the Crown*)។[៣៨] បន្ថែមពីនេះ គឺតុលាការរបស់ស្តេច ឬ តុលាការ **Exchequer** សម្រាប់ដោះស្រាយករណីពាក់ព័ន្ធនឹងប្រាក់ចំណូលរាជវង្ស និងពន្ធ។ តុលាការទាំងនេះបែងចែកសមត្ថកិច្ចតាមប្រភេទជម្លោះ ប៉ុន្តែរួមគ្នាពួកវាបានគ្រប់គ្រងនិងអនុវត្តច្បាប់នៃនីតិរួមរបស់អង់គ្លេសដែលកំពុងរីកចម្រើន។ ចៅក្រម និងមន្ត្រីតុលាការនៅមជ្ឈិមសម័យ ក៏បានបង្កើតប្រព័ន្ធសរសេរព្រះរាជបណ្តឹង (Royal writ system)ដែលជាលិខិតបញ្ជាដែលមានទម្រង់ស្តង់ដារ ប្រើសម្រាប់ស្នើសុំអំណាចវិនិច្ឆ័យពីតុលាការរាជវង្ស ដែលនៅចុងសតវត្សទី១២ និងទី១៣ បានកំណត់ទម្រង់នៃសកម្មភាពផ្លូវច្បាប់ (forms of action) ដែលភាគីជម្លោះអាចប្រើបាន។

មកដល់ចុងមជ្ឈិមសម័យ ច្បាប់ខមមិនឡ(common law) បានក្លាយជាប្រព័ន្ធច្បាប់សំខាន់បំផុតនៅអង់គ្លេស បើទោះបីជាប្រព័ន្ធនេះរួមជាមួយនឹងប្រព័ន្ធច្បាប់ផ្សេងទៀតដូចជា ច្បាប់សាសនា (canon law) នៅតុលាការសាសនា និង ច្បាប់ប្រពៃណីក្នុងតំបន់ (local customary law) នៅតុលាការម៉ាណ័រ (manor courts) ក៏ដោយ។

ចាប់ពីសតវត្សទី ១៦ ដល់ទី ១៧ គឺជាពេលវេលាដែលច្បាប់នៃនីតិរួម (Common Law) ត្រូវបានលូតលាស់និងមានឥទ្ធិពល។ ការរីកចម្រើននៃ តុលាការ Chancery ដែលត្រូវបានបង្កើតនៅសតវត្សទី១៥ និងធ្វើឱ្យមានទម្រង់ផ្លូវការនៅសតវត្សទី១៦ បាននាំមកនូវប្រព័ន្ធស្របច្បាប់ផ្ទាល់ខ្លួនមួយឈ្មោះថា Equity ដើម្បីសម្រួលការប្រើប្រាស់បណ្តឹង (writs) នៃច្បាប់ខមមិនឡ។

ច្បាប់សមធម៌ (Equity jurisprudence) ដែលដឹកនាំដោយ Lord Chancellor អាចចេញបញ្ជាដូចជា injunctions ឬវិធានការសមធម៌ផ្សេងៗ នៅពេលដែលតុលាការខមមិនឡមិនអាចផ្តល់យុត្តិធម៌បាន។ នេះបានបង្កើតប្រព័ន្ធច្បាប់ពីរដំណាក់កាល គឺ "Law" និង "Equity"។ នៅពេលខ្លះ វិវាទកើតឡើងរវាងចៅក្រមតុលាការខមមិនឡ និងតុលាការ Chancery។ ដូចជាករណីជម្លោះនៅឆ្នាំ ១៦១៦ រវាង Chief Justice Sir Edward Coke និង Lord Chancellor Ellesmere ដែលបញ្ចប់ដោយការទទួលស្គាល់អំណាចរបស់តុលាការ Chancery ឱ្យអាចលើកលែងឬលើកលែងសេចក្តីសម្រេចរបស់តុលាការច្បាប់ខមមិនឡ នៅពេលដែលមានអសមធម៌កើតឡើង។ តុលាការខមមិនឡខ្លួនឯងដែលដឹកនាំដោយអ្នកច្បាប់ដ៏ល្បីដូចជា Coke ក៏បានអះអាងអំពីឯករាជ្យភាពរបស់ខ្លួនពីរាជវង្សផងដែរ។ ការប៉ះទង្គិចអំណាចនៅសតវត្សទី ១៧ រវាងព្រះមហាក្សត្រស្ទួអាត (Stuart monarchs) និងតុលាការ រួមទាំងរដ្ឋសភា បាននាំឱ្យកើត

---

[៣៨] "Early Law Courts," Parliament.uk, ២០២៤, [https://www.parliament.uk/about/living-heritage/building/pala ce/westminsterhall/government-and-administration/early-law-courts/](https://www.parliament.uk/about/living-heritage/building/palace/westminsterhall/government-and-administration/early-law-courts/). (last visited ០៨ Oct.២០២៥).

មានគំនិតរឹងមាំអំពី គោលការណ៍នៃអធិបតេយ្យភាពច្បាប់ឬនីតិរដ្ឋ (Rule of Law) ដែលថា "សូម្បីតែព្រះមហាក្សត្រផងដែរ ក៏ស្ថិតនៅក្រោមអំណាចនៃច្បាប់ដែរ"។ ដូចដែល Sir Edward Coke បាននិយាយថា៖ "The King ought not to be under any man but under God and the law." ឬ ស្តេចមិនគួរតែស្ថិតនៅក្រោមអំណាចមនុស្សណាម្នាក់ទេ ប៉ុន្តែស្ថិតនៅក្រោមព្រះ និងច្បាប់។ ជ័យជំនះរបស់សភា និងច្បាប់នៃដំណោះស្រាយ (១៧០១) បានពង្រឹងឯករាជ្យភាពរបស់តុលាការដោយធានាឱ្យចៅក្រមកាន់តំណែងដោយឯករាជ្យ ជាជាងការពេញចិត្តរបស់ព្រះមហាក្សត្រ។

ក្នុងសតវត្សទី ១៩ ប្រព័ន្ធច្បាប់អង់គ្លូសាក់សុងអង់គ្លេស (English Common Law) បានឆ្លងកាត់ការវិវឌ្ឍន៍សំខាន់ៗជាច្រើនរួមទាំងការផ្លាស់ប្តូរដ៏សំខាន់បំផុតមួយគឺការរួមបញ្ចូលគ្នារវាង **ច្បាប់ខមមិនឡ (Law)** និង **ច្បាប់សមធម៌** (Equity) តាមរយៈ ច្បាប់ Judicature Acts ឆ្នាំ ១៨៧៣ ដល់១៨៧៥។ ច្បាប់ទាំងនេះបានបញ្ចូលប្រវត្តិសាស្ត្រនៃតុលាការខមមិនឡ ដូចជា King's Bench, Common Pleas និង Exchequer ជាមួយនឹង តុលាការ Chancery ចូលជារចនាសម្ព័ន្ធតុលាការតែមួយ ដែលមានឈ្មោះថា Supreme Court of Judicature ដែលមានសមាសភាពជា High Court of Justice និង Court of Appeal។ ការធ្វើបដិប្រិត្តនេះ បានលុបបំបាត់ទម្រង់ក្តីចាស់ៗ និងបង្កើត តុលាការជាន់ខ្ពស់តែមួយ (High Court) ដែលអាចអនុវត្តបានទាំងវិធានការផ្លូវច្បាប់ និងសមធម៌។ ការរួមបញ្ចូលនេះមានន័យថា ភាគីជម្លោះអាចទទួលបានការដោះស្រាយទាំងស្រុងក្នុងសវនាការតែមួយ ហើយចៅក្រមអាចអនុវត្តគោលការណ៍ទាំងពីរប្រភេទ (Law និង Equity) ដើម្បីផ្តល់យុត្តិធម៌។

ដល់ចុងសតវត្សទី ១៩ និងដើមសតវត្សទី ២០ ច្បាប់សភា (Statute Law) ក៏បានក្លាយជាផ្នែកសំខាន់មួយនៃប្រព័ន្ធច្បាប់ ដោយរដ្ឋសភាបានចេញច្បាប់ជាច្រើនក្នុងវិស័យដូចជា ច្បាប់ព្រហ្មទណ្ឌ និងច្បាប់ពាណិជ្ជកម្ម ដែលបន្ថែមលើច្បាប់ខមមិនឡដើម។ ទោះជាយ៉ាងណា វិស័យស្នូលដូចជា កិច្ចសន្យា (Contract) អំពើអនីត្យានុកូល(Tort) និង ទ្រព្យសម្បត្តិ (Property) នៅតែត្រូវបានគ្រប់គ្រងយ៉ាងខ្លាំងដោយ គោលការណ៍នៃយុត្តិសាសាស្ត្រតុលាការ (Judicial Precedent)។

ជារួម នៅដើមសតវត្សទី ២០ ប្រព័ន្ធ ច្បាប់ខមមិនឡ (Common Law System) បានវិវត្តន៍ចាប់តាំងពីមជ្ឈិមសម័យរបស់អង់គ្លេស រហូតក្លាយទៅជាប្រព័ន្ធច្បាប់ពេញលេញ មានលក្ខណៈពិសេសដោយគោលការណ៍ stare decisis (គោលការណ៍តាមបុព្វហេតុតុលាការ) ប្រព័ន្ធជំនុំជម្រះដោយប្រជាជន (jury system) និង តុលាការឯករាជ្យ ដែលបន្តឥទ្ធិពលរបស់ខ្លួនតាមរយៈអាណិគមរបស់អង់គ្លេស។

### ១.៣.២.២ ប្រព័ន្ធច្បាប់នៅចក្រភពអង់គ្លេស

ប្រព័ន្ធច្បាប់នៅចក្រភពអង់គ្លេសសព្វថ្ងៃមានលក្ខណៈ ពហុប្រព័ន្ធ (Pluralistic System) ប៉ុន្តែក្នុងគ្រឹះស្នូលនៃប្រព័ន្ធច្បាប់នៅតែជាច្បាប់ខមមិនឡ (Common Law) និងច្បាប់សមធម៌ (Equity)។ ប្រភពច្បាប់សំខាន់ៗនៅអង់គ្លេស និងវ៉េលស៍ រួមមាន៖ ទី១) ច្បាប់សភា (Acts of Parliament) ទី២

ច្បាប់រង ឬច្បាប់អនុវត្តន៍ (Delegated or Secondary Legislation) ដូចជា បទបញ្ជា ឬបញ្ញាផ្សេងៗ ដែលចេញក្រោមអំណាចនៃច្បាប់សភា និងទី៣ ច្បាប់នៃនីតិរូម ដូចជាសេចក្តីសាលក្រម សេចក្តីសម្រេចតុលាការជាដើម។ បន្ថែមពីនេះ ចាប់តាំងពីឆ្នាំ ១៩៧៣ ដល់ ២០២០ ច្បាប់សហភាពអឺរ៉ុប (European Union Law) ក៏ជាប្រភពច្បាប់ផ្ទាល់តាមរយៈ European Communities Act ១៩៧២ ដែលអនុញ្ញាតឲ្យបទបញ្ញត្តិ និងបទបញ្ជារបស់អឺរ៉ុបមានប្រសិទ្ធិភាពនៅក្នុងចក្រភពអង់គ្លេស។ បន្ទាប់ពី Brexit ច្បាប់អឺរ៉ុបត្រូវបានដកចេញ ឬបំលែងទៅជាច្បាប់ជាតិ។ ប្រភពសំខាន់មួយទៀតគឺ អនុសញ្ញាសិទ្ធិមនុស្សអឺរ៉ុប (European Convention on Human Rights – ECHR) ដែលត្រូវបានបញ្ចូលចូលក្នុងច្បាប់អង់គ្លេសតាមរយៈ Human Rights Act ១៩៩៨។ ច្បាប់នេះតម្រូវឲ្យតុលាការបកស្រាយច្បាប់ស្របតាមសិទ្ធិមនុស្សក្រោមអនុសញ្ញា។ គួរបញ្ជាក់ផងដែរថា ចក្រភពអង់គ្លេស មិនមានរដ្ឋធម្មនុញ្ញជាលាយលក្ខអក្សរ (Unwritten Constitution) ទេ ប៉ុន្តែអាស្រ័យលើបញ្ចូលគ្នានៃច្បាប់សំខាន់ៗ (Statutes) ដូចជា *Magna Carta*, *Bill of Rights ១៦៨៩*, *Parliament Acts*, គោលការណ៍ច្បាប់នៃនីតិរូម (Common Law Principles) ដូចជា ការត្រួតពិនិត្យសកម្មភាពរដ្ឋាភិបាលដោយតុលាការ (*Judicial Review*) និងរដ្ឋធម្មនុញ្ញ (Constitutional Conventions)។

ប្រព័ន្ធច្បាប់អង់គ្លូសាក់សុងនៅអង់គ្លេស មានតួនាទីបំពេញចន្លោះរវាងច្បាប់សភា និងវិស័យមួយចំនួនដូចជា កិច្ចសន្យា (Contracts) ឬ អំពើអនីត្យានុកូល(Torts) ដែលជាមូលដ្ឋានគ្រឹះសម្រាប់ច្បាប់សភាដែលបានចេញច្បាប់បន្ថែម។ ប្រព័ន្ធតុលាការនៅអង់គ្លេស និងវេលស៍មានចែកជាលំដាប់ជាថ្នាក់ គឺ **១.** *Magistrates' Courts* សម្រាប់ករណីព្រហ្មទណ្ឌកម្រិតស្រាល និងករណីស៊ីវិលមួយចំនួន។ ២. *County Courts* សម្រាប់ជម្លោះស៊ីវិលទូទៅ និងការកាត់ក្តីជាប្រចាំ។ **កម្រិតបន្ទាប់:** *Crown Court* សម្រាប់ក្តីព្រហ្មទណ្ឌធ្ងន់ (មានជំនុំជម្រះដោយប្រជាជន) និងស្តាប់អំពាវនាវពី Magistrates' Courts។ *High Court of Justice* សម្រាប់ក្តីស៊ីវិលធំៗ និងការត្រួតពិនិត្យសកម្មភាពរដ្ឋាភិបាល (*Judicial Review*)។

លក្ខណៈសំខាន់មួយនៃប្រព័ន្ធច្បាប់អង់គ្លូសាក់សុងអង់គ្លេសគឺ ឯករាជ្យភាពតុលាការ (Judicial Independence)។ តាម Act of Settlement ១៧០១ ចៅក្រមអង់គ្លេសមានសិទ្ធិរក្សាតំណែងរបស់ខ្លួន (មិនអាចដកចេញបាន លុះត្រាតែមានការសម្រេចសភា)។ បន្ថែមមកទៀត Constitutional Reform Act ២០០៥ បានបំបែកតុលាការចេញពីរដ្ឋសភា ដោយបង្កើត Judicial Appointments Commission ដើម្បីជ្រើសរើសចៅក្រមឯករាជ្យ។ តុលាការអង់គ្លេស មិនមានសិទ្ធិអំណាចក្នុងការបដិសេធឬលុបចោលច្បាប់គោលបាននោះទេ ដោយសារអធិបតេយ្យភាពរបស់រដ្ឋសភា ប៉ុន្តែពួកគេអាចបដិសេធមិនអនុវត្តច្បាប់ក្រោមបង្គាប់ ប្រសិនបើជ្រុលហួសហេតុ និងអាចចេញសេចក្តីប្រកាសនៃភាពមិនស៊ីគ្នានៅក្រោមច្បាប់សិទ្ធិមនុស្ស ប្រសិនបើច្បាប់រដ្ឋសភាខ្ទាស់គ្នាជាមួយសិទ្ធិមនុស្ស ដែលជាប្រភេទនៃការត្រួតពិនិត្យផ្នែកទន់ដែលឱ្យសភាផ្លាស់ប្តូរច្បាប់។ ចៅក្រមមានតួនាទីសំខាន់នៅក្នុងការអភិវឌ្ឍន៍ច្បាប់ (develop

case law) តាមរយៈសេចក្តីសម្រេចរបស់តុលាការ លុះត្រាតែសភាពចេញច្បាប់ផ្ទុយ។ ហេតុនេះ រដ្ឋសភា មានសិទ្ធិអំណាចការអនុម័តច្បាប់ថ្មី ឬធ្វើវិសោធនកម្មច្បាប់ដែលមានស្រាប់ ដើម្បីកែប្រែ ឬកែប្រែច្បាប់ដែលបង្កើតឡើងដោយចៅក្រម។

### ១.៣.២.៣ ប្រព័ន្ធច្បាប់អង់គ្លូសាក់សុងនៅសហរដ្ឋអាមេរិក

ប្រភពច្បាប់នៅក្នុងប្រព័ន្ធច្បាប់អង់គ្លូសាក់សុងឬប្រព័ន្ធនៃនីតិរួម មានប្រភពចេញពី ទំនៀមទម្លាប់ឬច្បាប់ឥតសរសេរ ដែលប្រភពចម្បងនៃច្បាប់រួមមាន រដ្ឋធម្មនុញ្ញ ច្បាប់(statute) និងសេចក្តីសម្រេចរបស់តុលាការ (case law) ជាន់ខ្ពស់ដែលបង្កើតជាគំរូចម្បងចងកាតព្វកិច្ចតុលាការជាន់ទាបឲ្យគោរពតាម (under the doctrine of *stare decisis*) ។ ឧទាហរណ៍នៅសហរដ្ឋអាមេរិក ប្រភពដែលជាមូលដ្ឋានចម្បងមានចំនួន៤ គឺរដ្ឋធម្មនុញ្ញ ច្បាប់(ច្បាប់នៃរដ្ឋសហព័ន្ធនិងរដ្ឋ ឬ federal and state statutes) បទបញ្ញត្តិរដ្ឋបាល និង ច្បាប់យុត្តិសាស្ត្រ (case law)។[៣៩] រដ្ឋធម្មនុញ្ញគឺជាច្បាប់កំពូលរបស់ប្រទេស ហើយច្បាប់ណាមួយដែលផ្ទុយនឹងរដ្ឋធម្មនុញ្ញមិនមានប្រសិទ្ធភាពនៅក្នុងការអនុវត្ត (*Marbury v. Madison*, ១៨០៣)។

ស្ថាប័ន និង តួអង្គនៃច្បាប់៖ ប្រព័ន្ធច្បាប់អង់គ្លូសាក់សុង វិវត្តន៍ទៅតាមសេចក្តីសម្រេចតុលាការ ជាជាងច្បាប់ដែលអនុម័តដោយអង្គនីតិបញ្ញត្តិ។ ច្បាប់ភាគច្រើន ធ្វើឡើងតាមសេចក្តីសម្រេចរបស់តុលាការដែលស្គាល់ជា ករណីយុត្តិសាស្ត្រ (Precedent)។ នៅក្នុងតុលាការ ចៅក្រមដើរតួនាទីជាអាជ្ញាកណ្តាលនៅចំពោះមុខភាគីជម្លោះ។ បើទោះបីជាប្រព័ន្ធច្បាប់នៅខមិនឡ ផ្តោតសំខាន់លើចៅក្រមជាអ្នកបង្កើតច្បាប់មួយចំនួនក៏ដោយ ក៏ប្រព័ន្ធច្បាប់នេះនៅតែពឹងផ្អែកលើច្បាប់ (statutes) ដែលអនុម័តដោយ អង្គនីតិបញ្ញត្តិ ហើយចៅក្រមក៏មានតួនាទីនៅក្នុងការបកស្រាយពីរបៀបដែលច្បាប់របស់ស្ថាប័ននីតិប្បញ្ញត្តិនៅក្នុងសំណុំរឿងរបស់បុគ្គលម្នាក់ៗ។ នៅក្នុងប្រទេសអាមេរិក នីតិវិធីតុលាការដំណើរការជា ប្រតិប័ក្ស (adversarial) ដោយចៅក្រមស្តាប់សាវនាការ ជាជាងសកម្មក្នុងការស៊ើបអង្កេត(inquisitorial)ឲ្យគូភាគីទាំងនៅក្នុងសំណុំរឿងរដ្ឋប្បវេណី និងសំណុំរឿងព្រហ្មទណ្ឌ។ គូភាគីត្រូវបង្ហាញខ្លួនចំពោះមុខចៅក្រមដែលជាអ្នកសម្របសម្រួល និងមានសិទ្ធិតំណាងដោយមេធាវីនៅក្នុងសវនាការ។ មេធាវី មានតួនាទីសកម្មក្នុងការតំណាងឲ្យកូនក្តី ការបង្ហាញភស្តុតាង និងទឡ្ហីករណ៍ច្បាប់នៅក្នុងតុលាការ។ ក្នុងនោះ គណៈវិនិច្ឆ័យភាគីច្រើនគឺជាបុគ្គលទូទៅដែលមិនមានការបណ្តុះបណ្តាលផ្នែកច្បាប់ ប៉ុន្តែអាចសម្រេចលើភាពពិតប្រាដកនៃអង្គហេតុ។ ផ្អែកលើភស្តុតាងដែលមាន គណៈវិនិច្ឆ័យអាចធ្វើការសម្រេចចិត្តថាតើជនជាប់ចោទពិតជាមានទោសឬយ៉ាងណា។នៅក្នុងករណីដែលរកឃើញថាមានទោស ចៅក្រមនឹងសម្រេចសេចក្តីជា

---

[៣៩] U.S. Department of justice, "National Security Division Office of Justice for Victims of Overseas Terrorism | International Legal Systems - an Introduction," www.justice.gov, April ២៤, ២០២៣, https://www.justice.gov/nsd-ovt/international-legal-systems-introduction. (accessed ១១ September ២០២៥)

ការពិន័យជាប្រាក់ ឬបទល្មើសទៅលើជនជាប់ចោទផ្អែកលើសាលក្រមប្រកាសទោសរបស់គណៈវិនិច្ឆ័យ។ គណៈវិនិច្ឆ័យនៅក្នុងប្រព័ន្ធខមមិនឡ ត្រូវបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញ ឬក្នុងច្បាប់ក្នុងប្រទេសដូចជាមួយចំនួនដូចជា សហរដ្ឋអាមេរិក ចក្រភពអង់គ្លេស និង អូស្រ្តាលី ប៉ុន្តែប្រទេសមួយចំនួនដូចជា សិង្ហបុរី[៤០] មិនមានវត្តមានគណៈវិនិច្ឆ័យនៅក្នុងសវនាការនោះទេ។[៤១]

### ១.៣.២.៤ ប្រព័ន្ធច្បាប់សាសនាហិណ្ឌូ

វិធីសាស្ត្រនីតិកម្មរបស់ហិណ្ឌូ អាចកំណត់អត្តសញ្ញាណបានថាជាបណ្តុំនៃទស្សនៈវប្បធម៌បុរាណណាដែលមានចរឹកលក្ខណៈជា «**ហិណ្ឌូ**»។[42] នៅក្នុងសង្គមឥណ្ឌាបច្ចុប្បន្ន ប្រព័ន្ធច្បាប់ហិណ្ឌូត្រូវបានគេបដិសេធនិត្យានុកូលភាព ដោយចាត់ទុកច្បាប់ហិណ្ឌូថាជាការប្រព័ន្ធដែលលើកដំកើនការរើសអើងតាមរយៈការប្រើប្រាស់ប្រព័ន្ធវណ្ណៈ និងមានគំនិតជាច្រើនដែលហួសសម័យនៅយុគ្គថ្មីនេះ ដោយសារទំនាក់ទំនងយ៉ាងជិតស្និតរវាងប្រព័ន្ធច្បាប់ហិណ្ឌូ និងសាសនា។[43] ប៉ុន្តែ ទស្សនៈប្រព័ន្ធច្បាប់ហិណ្ឌូនៅតែបន្តមានឥទ្ធិពលទៅលើរចនាសម្ព័ន្ធទាំងមូលនៃក្រមរដ្ឋប្បវេណី ក្រមព្រហ្មទណ្ឌ និងរដ្ឋធម្មនុញ្ញឆ្នាំ១៩៥០ នៃសង្គមឥណ្ឌាបច្ចុប្បន្ន។[44] ដូចនេះ ប្រព័ន្ធច្បាប់ហិណ្ឌូនៅតែជាធាតុផ្សំមួយ របស់ឥណ្ឌា និងអាស៊ីខាងត្បូង ហើយពុំមានកម្មវិធីកែទម្រង់ច្បាប់ណាមួយទេ ដែលអាចលប់បំបាត់សញ្ញាណនេះទាំងស្រុងនោះទេ។[45]

#### ក. ទស្សនៈវិទ្យាហិណ្ឌូ ដែលប្រើប្រាស់នៅក្នុងប្រព័ន្ធច្បាប់ហិណ្ឌូ

- ការប្រើប្រាស់ *Dharma* នៅក្នុងទស្សនាទានច្បាប់ហិណ្ឌូៈ[46]

---

[៤០] Jason Odering, "Library Guides: Southeast Asian Region Countries Law: Singapore," unimelb.libguides.com, September ៩, ២០២៥, https://unimelb.libguides.com/c.php?g=៩៣០១៨៣&p=៦៧២២០០៩. ((accessed ១១ September ២០២៥)

[៤១] U.S. Department of justice, "National Security Division Office of Justice for Victims of Overseas Terrorism | International Legal Systems - an Introduction," www.justice.gov, April ២៤, ២០២៣, https://www.justice.gov/nsd-ovt/international-legal-systems-introduction (accessed ១១ September ២០២៥).

[៤២] Werner Mensk, 'Hindu Law' (២០១០) ១៦៤ Law & Justice - the Christian Law Review ៤៥.

[៤៣] Ibid.

[៤៤] Ibid.

[៤៥] Ibid.

[៤៦] Ludo Rocher, 'Hindu Conceptions of Law' (១៩៧៨) ២៩(៦) Hastings Law Journal ១២៨៣.

- នៅក្នុងន័យភាសាវិទ្យា *dharma* បានមកពីឫសពាក្យ *dhr* ឬ *dhar* បូកជាមួយនឹងពាក្យma ដែលផ្គុំចូលគ្នាបានន័យថាផ្លូវមួយដែលអង្គត្រូវតែប្រកាន់ខ្ជាប់, ទ្រទ្រង់, ប្រព្រឹត្ត, និង រក្សាទុកនូវការវិវត្តទាំងឡាយនៃនិយណ្ឌសាស្ត្រដែលបានសរសេរជាភាសាសំស្ក្រឹត
- នៅកម្រិតចក្រវាល *dharma* គឺជាផ្លូវមួយដែលអង្គត្រូវទ្រទ្រង់អ្វីទាំងអស់, ជាផ្លូវដែលចក្រវាល(ឬលំនឹងនៅចក្រវាល)ត្រូវបានទ្រទ្រង់។
- នៅកម្រិតមីក្រូ *dharma* គឺជាផ្លូវដែលធាតុសំខាន់ៗនៃចក្រវាលធ្វើវិភាគទានក្នុងការទ្រទ្រង់លំនឹងជារួម។ ធាតុនីមួយៗមាន *dharma* របស់ខ្លួន ដែលត្រូវហៅថា *svadharma*។ នៅពេលដែលធាតុទាំងអស់នៅក្នុងចក្រវាលបំពេញនូវតួនាទី *svadharma* រៀងខ្លួនលំនឹងជារួមនឹងមិនត្រូវបានប៉ះពាល់ឡើយ ប៉ុន្តែនៅពេលដែលធាតុណាមួយមានទង្វើដែលឃ្លាតពី *dharma* (ដែលហៅថា *adharma*) នោះលំនឹងនឹងត្រូវបានប៉ះពាល់។

## ខ. ប្រភពនៃច្បាប់នៅក្នុងប្រព័ន្ធច្បាប់ហិណ្ឌូ

ទោះបីជាមានអ្នកសិក្សាស្រាវជ្រាវជាច្រើនទទួលស្គាល់ថាសាសនា និងវប្បធម៌ហិណ្ឌូមួយចំនួនមានរូបរាងជាច្បាប់សរសេរ ឬយុត្តិសាស្ត្រក៏ដោយ[47] ប៉ុន្តែមានសិក្សាស្រាវជ្រាវមួយចំនួនបាននិយាយថាវាជាប្រភពដែលច្បាប់បានមក។[48] ច្បាប់ហិណ្ឌូ ជាប្រព័ន្ធនៃទំនាមទម្លាប់ និងវិធានដែលបានសង្កេតមើលក្នុងរយៈពេលវែង ដែលបានចារឹកនៅក្នុងអត្ថបទសំស្ក្រឹត និងហិណ្ឌូជាច្រើន ដូចមានភស្តុតាងនៅក្នុងព្រះមហាក្សត្រ រក្សាទុកលិខិតបទដ្ឋានគតិយុត្តទាំងនេះដល់បច្ចុប្បន្ន។[49] វិធាននៃច្បាប់ហិណ្ឌូអាចរកបាននៅក្នុង ប៉ុន្តែអត្ថបទទាំងនេះមានវាធានផ្សេងទៀតជាច្រើន។[៥០]

យោងតាម *Manu* ប្រភពនៃប្រព័ន្ធច្បាប់ហិណ្ឌូមានដូចជា៖[51]

---

[៤៧] Wermer Menski, 'Hindu Law as a "Religious" System' in Andrew Huxley (ed), *Religion, Law and Tradition - Comparative Studies in Religious Law* (Routledge ២០០៦) ១១១.

[៤៨] Prema Kumari, 'Sources of Hindu Law' (២០២៣) ៥(២) Indian Journal of Law and Legal Research ១, ២.

[៤៩] Ibid.

[៥០] Ibid.

[៥១] Jose Nandhikkara and B Kuppuswamy, 'A Modern Review of Hindu Dharma' (១៩៧៥) ១(១&២) Journal of Dharma ១១៨, Keshav Jha, 'Sources of Hindu Law: A Comprehensive View' (២០១៩) ៦(២) International Journal of Research and Analytical Reviews ៥៩២.

- ***Shruti*** (ឬ *Sruti*) means មានន័យថាជា «អ្វីដែលបានឮ» ហើយនៅក្នុងបរិបទទស្សនវិទ្យាហិណ្ឌូ និងឥណ្ឌា ពាក្យនេះបានន័យថាជាបណ្ដុំនៃចំណេះដឹងដែលត្រូវបានលាតត្រដាងទៅ *Rishis* សម័យបុរាណ (ដែលត្រូវបានហៅថា *drishtaa* ឬអ្នកមើលឃើញ) ដែលអាចស្ដាប់ពាក្យរបស់អាទិទេពតាមរយៈការវិបស្សនា និងការវិន័យរបស់ពួកគេ។[52] ដំបូងឡើយ ចំណេះដឹងទាំងនេះគឺស្ថិតក្នុងទម្រង់ជាមុខបាឋ(ចំណេះដឹងដែលបានពីការទន្ទេញតមាត់គ្នា) ហើយក្រោយមកត្រូវបានកត់ត្រាទុកក្នុងទម្រង់ជា ***Vedas***[53] ដែលជាគម្ពីរដែលមានអំណាចគតិយុត្តជាងគេ និងត្រូវបានចាត់ទុកថាជាសក្ការៈបំផុត និងពុំមានប្រភពមកពីមនុស្សណាមួយទេ។ *Vedas* ធំៗមាន ៤ គឺ *Rig Veda*, *Sama Veda*, *Yajur Veda* និង *Atharva Veda* ដែលអត្ថបទនីមួយៗមានមុខងារខុសៗគ្នា។
- ***Smriti*** មានន័យថាជា «អ្វីដែលត្រូវបានចងចាំ» ហើយវាជាលទ្ធផលនៃការប្រមូលចងក្រងនៃ *Shruti*។ ប្រភេទនៃ *Smritis* មានដូចជា:[54]

(i) ប្រភេទ ***Puranas***: *Smriti* ប្រភេទនេះមានអត្ថបទចំនួន១៨ក្បាល ប៉ុន្តែអត្ថបទសំខាន់ៗមានដូចជា *Markandeyapurana*, *Shiva Purana*, *Bhagavata Purana*, *Agni Purana* និង *Vishnu Purana*

(ii) ប្រភេទវីរកថាទាំង២រួមមាន ***Mahābhārata*** និង ***Rāmāyaṇa***

(iii) ប្រភេទ **the *Bhagavad Gita*** និង **the *Tantras*** ដែលជាក្បួនតម្រាដែលសរសេរអំពីអាថ៌កំបាំងនៃពិធីសាសនារបស់សាសនិក Tantra

(iv) ប្រភេទ ***Kalpa Sutras***: ជាសៀវភៅដែលសរសេរអំពី «គោលការណ៍គ្រឹះនៃច្បាប់ជាសក្ការៈ»[55] និងត្រូវបានចែកជា៣ផ្នែកគឺ (១) *Shrauta Sutras* ជាផ្នែកសម្រាប់ពិធីផ្សេងៗនៅក្នុងគម្ពីរ *Vedas* (២) *Grhya Sutras* ជាផ្នែកសម្រាប់ពិធីកម្មទូទៅ និង(៣) *Dharma Sutras* ផ្នែកដែលបរិយាយអំពីចារឹកលក្ខណៈរបស់មនុស្សដែលមានភាពសមស្រប (appropriate human behaviors)

---

៥២ Praveen Singh, 'Shruti and Smriti' in Rukmini Bhaya Nair and Peter Ronald DeSouza (eds), *Keywords for India: A Conceptual Lexicon for the ២១st Century* (Bloomsbury Publishing Plc ២០២០) ៤១៩.

៥៣ The term Veda comes from the Sanskrit root 'vid' which means 'to know' and implies divine knowledge.

៥៤ Singh (n ៧).

៥៥ 'Maxims on sacred law'

(v) ប្រភេទ ***Dharmashastras***: អត្ថបទសំខាន់ៗរួមមាន *Manu Smṛiti* (ជាគម្ពីរលើច្បាប់ស្តីពីសន្តាប់ធ្នាប់សង្គម និងជីវិតដែលល្អ) និង *Yajnavlakya Smṛiti* ។

- ***Sadachar*** (ទំនៀមទម្លាប់ល្អ): *Yajnavalkya* បានសរសេរថាទំនៀមទម្លាប់, ការអនុវត្ត ឬការប្រតិបត្តិនៅក្នុងគ្រួសារ ត្រូវចាត់ទុកថាមានអនុភាពស្មើនឹងច្បាប់។[56] ដូចនេះ *Sadachar* មានអនុភាពលើសពីទំនៀមសង្គម ដោយត្រូវបានចាត់ទុកថាជាប្រភពមួយនៃច្បាប់ ដែលអាចយកមកដោះស្រាយនៅតុលាការបាន។[57] *Sadachar* រាប់បញ្ចូលទាំង ទំនៀមទម្លាប់តំបន់ កុលសម្ព័ន្ធ និងគ្រួសារ។[58]
- ***Swatah Prajna*** (ការយល់ដឹងល្អរបស់ខ្លួនឯង): សញ្ញាណនេះសំដៅលើអ្វីដែលអាចទទួលយកបានតាមរយៈការយល់ដឹងរបស់ខ្លួនដែលកើតពីចេតនាដែលល្អ។[59] ក្រោយពីក្រមនីយកម្មនៃ *Smritis* តាមរយៈការប្រមូលចងក្រង បញ្ហាមួយចំនួនបានកើតឡើង ដោយបទប្បញ្ញត្តិមួយចំនួន មានអសង្គតភាព, មិនច្បាស់លាស់, និងពិបានយល់ រួមទាំងចំណុចដែលមិនបានគ្រប ដណ្តប់ដោយ *Smritis* ។[60] ដូចនេះ ការបកស្រាយច្បាប់តម្រូវឱ្យមានការមើលលើសពីច្បាប់ ពោលគឺសច្ចានុមតិពីមនុស្សដែលមានគុណធម៌។[61]

ចំណុចទាំងអស់ខាងលើ ត្រូវបានប្រកាសដោយ *Manu* ថាតស្តុតាងចត្វាគុណនៃ *Dharma* ។[62] នៅពេលដែលតុលាការធ្វើសេចក្តីសម្រេចលើសំណុំរឿង ចៅក្រមមិនអាចរំពឹងលើ *Swatah Prajna* និង *Shruti* ទាំងស្រុងបានទេ ពីព្រោះ *Swatah Prajna* មានលក្ខណៈប្រធានវិស័យនិយម ហើយ *Shruti* ពុំសូវមានបទប្បញ្ញត្តិច្បាប់នោះទេ។[63] ដូចនេះ ចៅក្រមត្រូវពឹងផ្អែកលើប្រភពនៃច្បាប់ដែលមានលក្ខណៈវត្ថុវិស័យនិយមដូចជា *Smriti* និង *Sadachar*។[៦៤] កំណត់ត្រាបានបង្ហាញថា នៅពេលដែលស្តេចធ្វើសង្គ្រាមឈ្នះ

---

[៥៦] Nandhikkara and Kuppuswamy (n ៦) ១១៩

[៥៧] Ibid.

[៥៨] Ibid ១២០.

[៥៩] M Rama Jois, *Legal and Constitutional History of India: Ancient Legal, Judicial and Constitutional System* (Universal Law Pub ២០០៤) ១៤.

[៦០] Ibid ៤៥.

[៦១] Ibid.

[៦២] Nandhikkara and Kuppuswamy (n ៦) ១១៩.

[៦៣] Ibid.

[៦៤] Ibid.

លើដែនដីថ្មី ទំនៀមទម្លាប់នៅតំបន់នោះនឹងត្រូវបានរក្សាទុកដើម្បីប្រតិបត្តិ។[65] *Gautama* និង *Manu* បានបរិយាយថា ការងាររចម្បងរបស់ស្តេចគឺការកាត់ក្តីដ៏យុត្តិធម៌តាមការប្រើប្រាស់ទំនៀមទម្លាប់តាមតំបន់ និងក្រុមនានា ហើយនៅពេលដែលប្រភពនៃច្បាប់ទាំង២ មានវិវាទគតិយុត្តនឹងមានអនុភាពជាង។[66] នៅក្នុងករណីដែល *Shruti*, *Smritis*, និង *Sadachar* មិនគ្រប់គ្រាន់ ការសម្រេចក្តីត្រូវអាស្រ័យលើការយល់ខុសត្រូវរបស់ស្តេច (*Swatah Prajna*) ដោយវិភាគទៅលើអង្គហេតុ និងករណីផ្សេងៗរបស់សំណុំរឿង។[67] *Swatah Prajna* ក៏ត្រូវបានប្រើប្រាស់ផងដែរក្នុងករណីដែលមានភស្តុតាងមិនគ្រប់គ្រាន់នៅក្នុងសំណុំរឿង។[68]

### ១.៣.២.៥ ទស្សនវិជ្ជាចិនបុរាណ

ទំនៀមនិងទស្សនវិជ្ជាច្បាប់ចិនបុរាណ នៅតែបន្តជះឥទ្ធិពលលើរចនាសម្ព័ន្ធសង្គម និងរដ្ឋបាលរបស់ប្រទេសចិនមកដល់ពេលបច្ចុប្បន្ន។ ទស្សនវិទូជាច្រើនក្រុមនៅក្នុងរាជវង្សចូវខាងកើត (ចន្លោះពី៧៧០ ដល់២៥៦ មុនគ.ស.) បានផ្តល់មូលដ្ឋានបញ្ញាដ៏សំបូរបែប ដែលជះឥទ្ធិពលលើច្បាប់ សីលធម៌ និងស្ថាប័នរបស់ចិន។ ក្នុងចំណោមក្រុមទាំងនោះ លទ្ធិខុងជឺ (Confucianism) និងនីតិនិយម (Legalism) បានចូលរួមចំណែកគួរឱ្យកត់សម្គាល់លើច្បាប់ ការគ្រប់គ្រង និងការដោះស្រាយវិវាទក្នុងប្រទេសចិន។ អត្ថបទនេះស្រាវជ្រាវមូលដ្ឋាននៃទស្សនវិជ្ជាបុរាណចិន, គោលគំណិតនៃលិទ្ធិខុងជឺ និងនីតិនិយម, ទំនាក់ទំនងរវាងទស្សនវិជ្ជាទាំងនេះ និងច្បាប់និងសង្គម, និងភាពខុសគ្នារវាងប្រព័ន្ធច្បាប់បុរាណនិងសម័យទំនើប។

#### ក. លទ្ធិខុងជឺ

លទ្ធិខុងជឺ គឺជារបៀបរស់នៅដែលត្រូវបានផ្សព្វផ្សាយដោយខុងជឺនៅសតវត្សទី៦-៥ មុនគ.ស. ហើយត្រូវបានប្រជាជនចិនអនុវត្តតាមជាងពីរសហស្សវត្សរ៍។ ទោះបីបានផ្លាស់ប្តូរពីមួយពេលទៅមួយពេលវេលា លទ្ធិនេះនៅតែជាសារជាតុនៃការសិក្សា ប្រភពនៃតម្លៃ និងក្រមសង្គមនៃចិន។ ឥទ្ធិពលរបស់វាក៏បានបន្តពង្រីកទៅបណ្តាប្រទេសដទៃទៀត ជាពិសេសប្រទេសកូរ៉េ ជប៉ុន និងវៀតណាម។

លទ្ធិខុងជឺគឺជាចរន្តទស្សនវិជ្ជាដែលបានរីកចម្រើននៅក្នុងប្រទេសចិន គឺជាផលវិបាកនៃសម័យកាលនៃការចលាចលសង្គមដែលគេស្គាល់ថាជាសម័យសង្គ្រាមនៅសហរដ្ឋអាមេរិក។ ដូច្នេះទស្សនវិទូខុងជឺបានគិតថាដំណោះស្រាយចំពោះបញ្ហាអនាធិបតេយ្យគឺត្រូវវិលត្រឡប់ទៅរកទំនៀមទម្លាប់ចិនបុរាណមុនពេលដែលការភាន់ច្រឡំសង្គមបានផ្ទុះឡើង។ ដល់ទីបញ្ចប់នេះគាត់បានស្រាវជ្រាវទំនៀមទម្លាប់វប្បធម៌

---

៦៥ Ibid.

៦៦ Ibid.

៦៧ Rama Jois (n ១៥) ១៧.

៦៨ Ibid ៥៥៤.

បុរាណរបស់ចិននិងកែសម្រួលសៀវភៅជាច្រើនស្តីពីប្រវត្តិសាស្ត្រនិងអក្សរសាស្ត្របុរាណ។ នៅក្នុងស្នាដៃទាំងនេះគាត់បានសង្កត់ធ្ងន់លើសារៈសំខាន់នៃអាកប្បកិរិយាប្រកបដោយគុណធម៌ដែលជាអ្នកគិតដំបូងគេ។ ការគិតប្រកបដោយក្រមសីលធម៌របស់គាត់ភាគច្រើនផ្តោតលើប្រធានបទជាក់លាក់ចំនួនបួនគឺឥរិយាបថធ្វើពិធីសាសនាមនុស្សមនុស្សឧត្តមភាពការគោរពប្រតិបត្តិកុមារនិងអភិបាលកិច្ចល្អ។

លទ្ធិខុងជឺបានបង្កើតច្បាប់ពិធីសាសនា និងការគ្រប់គ្រងយ៉ាងជ្រាលជ្រៅនៅក្នុងប្រទេសចិនបុរាណដែលជះឥទ្ធិពលក្នុងសង្គមចិន ដូចខាងក្រោម៖

**អាកប្បកិរិយាធ្វើពិធីសាសនា៖** អ្វីដែលសំខាន់បំផុតក្នុងចំណោមការបង្រៀនរបស់ខុងជឺគឺការប្រកាន់ខ្ជាប់នូវបទដ្ឋាននិងទំនៀមទំលាប់សង្គម។ សម្រាប់គាត់ការធ្វើពិធីនិងប្រពៃណីគឺជាការបិទដែលអាចមើលឃើញដែលភ្ជាប់សង្គមជាមួយគ្នា។

**មនុស្សជាតិនិងមនុស្សពូកែ៖** យោងទៅតាមគោលការណ៍នេះមនុស្សជាតិគឺជាអាកប្បកិរិយានៃសេចក្តីសប្បុរសសេចក្តីសប្បុរសនិងភាពថ្លៃថ្នូរចំពោះអ្នកដទៃ។ ដើម្បីទទួលបានគុណធម៌សេចក្តីថ្លៃថ្នូរនិងការអត់ធ្មត់ត្រូវតែមានការអភិវឌ្ឍ។

**ការគោរពប្រតិបត្តិកុមារនិងអភិបាលកិច្ចល្អ៖** ខុងជឺបានលើកឡើងថាមានទំនាក់ទំនងចំនួន ៥ ដែលដឹកនាំសណ្តាប់ធ្នាប់សង្គមគឺៈឪពុកនិងកូនប្រុសបងប្រុសនិងប្អូនប្រុសប្តីនិងប្រពន្ធមិត្តចាស់និងមិត្តភក្តិវ័យក្មេងនិងជាអ្នកគ្រប់គ្រងនិងប្រធានបទ។

សកម្មភាពនីមួយៗពាក់ព័ន្ធនឹងឧត្តមភាពនិងអ្នកក្រោមបង្គាប់ហើយភារកិច្ចពិសេសត្រូវបានទាមទារដោយភាគីទាំងពីរ។ តាមរបៀបនេះអ្នកក្រោមបង្គាប់មានកាតព្វកិច្ចបង្ហាញការគោរពប្រតិបត្តិនិងអ្នកពូកែបង្ហាញភាពសប្បុរស។

**ភាពល្អរបស់មនុស្ស៖** គោលការណ៍នេះត្រូវបានគាំទ្រដោយម៉ែនស៊ីស (៣៩០-៣០៥ មុនគ. ស.) អ្នកដើរតាមលទ្ធិខុងជឺនិយម។ យោងទៅតាមចំណុចនេះគំនិតនិងដួងចិត្តមានទំនោរទៅរកភាពល្អខាងសីលធម៌។ Mencius បានអះអាងថាអំពើអាក្រក់គឺជាលទ្ធផលនៃឥទ្ធិពលសង្គមអាក្រក់ដែលកាត់បន្ថយកម្លាំងខាងសីលធម៌ធម្មជាតិ។ ភាពរឹងមាំនោះមកពីគុណធម៌សីលធម៌ធម្មជាតិជាក់លាក់ចំនួនបួនគឺការអាណិតការអាម៉ាស់ការគោរពនិងការយល់ព្រម។

## ខ. នីតិនិយម

ផ្ទុយទៅវិញ ច្បាប់និយមផ្តល់អាទិភាពដល់ការគ្រប់គ្រងរដ្ឋខ្លាំង ច្បាប់ឯកសណ្ឋាន និងការដាក់ទណ្ឌកម្មតឹងរ៉ឹង។ នីតិនិយម គឺជាទស្សនវិជ្ជាចិន ដែលបានទទួលមានភាពតម្លៃក្នុងរយៈពេលជាតិក្នុងសង្គ្រាម (៤៧៥–២២១ មុនគ.ស.) ហើយតាមរយៈឥទ្ធិពលនៃទស្សនវិទូ Shang Yang, Li Si និង Hanfeizi ដែលបានកសាងមូលដ្ឋានគំនិតសម្រាប់រដ្ឋកាលនៃព្រះចៅអធិរាជជាលើកដំបូងក្នុងប្រទេសចិន គឺ Qin (២២១–២០៧ មុនគ.ស.)

- Shang Yang (d. ៣៣៨ BCE)៖ តស៊ូមតិសម្រាប់ការធ្វើមជ្ឈិមកម្ម កំណែទម្រង់កសិកម្ម និងក្រមព្រហ្មទណ្ឌដ៏ធ្ងន់ធ្ងរ។
- ហានហ្វី (គ.ស.២៨០–២៣៣ មុនគ.ស.)៖ ប្រព័ន្ធច្បាប់និយមជុំវិញហ្វា (ច្បាប់) ស៊ូ (បច្ចេកទេសរដ្ឋបាល) និងស៊ី (អំណាច)។
- លី ស៊ី (២៨០–២០៨ មុនគ.ស)៖ បានអនុវត្តកំណែទម្រង់អ្នកច្បាប់ក្រោមរាជវង្ស Qin រួមទាំងការធ្វើស្តង់ដារនៃទម្ងន់ វិធានការ និងការសរសេរ។

**ឥទ្ធិពលលើប្រទេសចិន**

- បានបើកការបង្រួបបង្រួមរបស់រាជវង្ស Qin នៃប្រទេសចិន (២២១ មុនគ.ស.)។
- កំណែទម្រង់សេដ្ឋកិច្ចពង្រឹងវិស័យកសិកម្ម និងចំណូលរដ្ឋ។
- ស្តង់ដារវប្បធម៌បានលើកកម្ពស់សមាហរណកម្មជាតិ ប៉ុន្តែបានទប់ស្កាត់ភាពចម្រុះនៃបញ្ញា។
- ការដាក់ទណ្ឌកម្មដ៏ឃោរឃៅជំរុញឱ្យមានការអន់ចិត្ត រួមចំណែកដល់ការដួលរលំ Qin។

### ១.៣.៣ ប្រព័ន្ធច្បាប់បុរាណធៀបនឹងប្រព័ន្ធច្បាប់ទំនើបរបស់ចិន

**ប្រព័ន្ធច្បាប់បុរាណ៖**

- ច្បាប់មានទំនាក់ទំនងនឹងសីលធម៌ និងពិធីសាសនា។
- ការសង្កត់ធ្ងន់លើឋានានុក្រម តួនាទីសង្គម និងភាពសុខដុមរមនាលើសិទ្ធិបុគ្គល។
- ច្បាប់មើលឃើញថាជាឧបករណ៍នៃអភិបាលកិច្ច មិនមែនយុត្តិធម៌ទេ។

ប្រព័ន្ធច្បាប់ទំនើបរបស់ចិន (PRC, កំណែទម្រង់ក្រោយឆ្នាំ ១៩៧៨):

- ផ្អែកលើប្រពៃណីច្បាប់រដ្ឋប្បវេណី ក្រមនីយកម្ម និងស្ថាប័នតុលាការ។
- ការគ្រប់គ្រងបក្សរឹងមាំ លាយបញ្ចូលគ្នានូវមនោគមវិជ្ជាម៉ាក្សនិយម ជាមួយនឹងក្របខ័ណ្ឌច្បាប់ទំនើប។
- សេចក្តីផ្តើមនៃច្បាប់ផ្អែកលើសិទ្ធិ (ឧ. ក្រមរដ្ឋប្បវេណី ២០២១) និងតុលាការជំនាញ។
- ច្បាប់មានមុខងារជាឧបករណ៍នយោបាយ និងក្របខណ្ឌច្បាប់ ដែលឆ្លុះបញ្ចាំងឱ្យឃើញពីការបន្តជាមួយប្រពៃណីអ្នកច្បាប់។

ជារួម ទស្សនវិជ្ជាចិនបុរាណ ជាពិសេសលទ្ធិខុងជឺ និងច្បាប់និយម បានបង្កើតមូលដ្ឋានគ្រឹះនៃច្បាប់ និងការគ្រប់គ្រងរបស់ចិន។ ខណៈពេលដែលលទ្ធិខុងជឺបានផ្តល់អាទិភាពដល់សីលធម៌គុណធម៌ និងភាពសុខដុមរមនាក្នុងសង្គម ច្បាប់និយមបានសង្កត់ធ្ងន់លើច្បាប់ សិទ្ធិអំណាច និងការដាក់ទណ្ឌកម្ម។ អន្តរកម្មនៃទំនៀមទំលាប់ទាំងនេះបានបង្កើតនូវវប្បធម៌ច្បាប់ដ៏ប្លែកមួយ ដែលច្បាប់បានបម្រើការគ្រប់គ្រងជាជាងសិទ្ធិបុគ្គល។ សព្វថ្ងៃនេះ ប្រព័ន្ធច្បាប់របស់ប្រទេសចិនទំនើបរួមបញ្ចូលជាតុផ្សំនៃទំនៀមទម្លាប់បុរាណ និងគំរូច្បាប់សកល ដែលឆ្លុះបញ្ចាំងពីការបន្តនៃកេរដំណែលទស្សនវិជ្ជា។

### ១.៣.៤ ទស្សនវិជ្ជាពុទ្ធសាសនា និងច្បាប់សង្គម

ព្រះពុទ្ធសាសនាបានលេចឡើងនូវនិកាយទាំងពីរដែលគេហៅថា ហីនយាន និងមហាយាន ដែលសុទ្ធសឹងជាសាសនាបានកើតនៅឥណ្ឌា នៅសម័យដើមមុនគ្រិស្តសករាជ។ សាសនានេះ ត្រូវបានជនជាតិខ្មែរគោរពបូជាជាខ្លាំងតាមរយៈអាទិទេពដែលមានធម៌ករុណា (ព្រះពោធិសត្វ) ព្រះពុទ្ធសាសនាមានលទ្ធិហីនយាន (ថេរវាទ) និងមហាយានបានចូលប្រតិស្ថានក្នុងអតីតនគរខ្មែរតាំងពីយ៉ាងហោចណាស់ក៏នៅពេលជំណាលគ្នានឹងព្រហ្មញ្ញសាសនាដែរ បើតាម ភស្តុតាងបដិមាសាស្ត្រ។ នៅសតវត្សរ៍ (៥-៦) ទំនងពុទ្ធសាសនានិកាយហីនយានមានតួនាទីយ៉ាងសំខាន់។ នៅលើសិលាចារឹកតាព្រហ្មភាសាសំស្ក្រឹតសតវត្សរ៍ទី៦ គេបាននមស្សការចំពោះព្រះជិន(ស្រី) ព្រះធម៌ និងព្រះសង្ឃ ដែលជាភ្នាក់ងារកាន់អំណាចខាងសាសនានេះ នៅមុនពេលគេនមស្សការចំពោះព្រះខាងព្រហ្មញ្ញសាសនា។ មានតែក្នុងនិកាយហីនយានទេ ដែលគេគោរពចំពោះសរណៈវត្ថុទាំងបីនេះ។ បើសាសនានិកាយមហាយានឃើញមានព្រះលាយចម្រុះជាមួយនឹងហីនយាន ដូចជានៅលើសិលាចារឹកប្រាសាទអំពិលរលើង K.163 ក្នុងស្រុកស្ទោងជាភាសាខ្មែរ គេធ្វើបទនមស្សការចំពោះត្រៃសរណគមន៍ មានជាអាទិ៍ ព្រះអវលោកិតេស្វរៈ ព្រះសាស្តា ឬព្រះពុទ្ធ និងព្រះស្រីអារ្យមេត្រី។ ក្រៅពីនេះ ក៏នៅមានសិលាចារឹកដទៃទៀត ដូចជា សិលាចារឹកព្រៃវៀរដែលជាចំណាររបស់ព្រះអរិយភិក្ខុសង្ឃពីអេង្គក្នុងត្រកូលក្សត្រ មិនបាននមស្សការចំពោះព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃឡើយ។ មានសិលាចារឹកសតវត្សរ៍ទី៧-៨ ខ្លះទៀត សរសេរជាភាសាបាលី ដោយដកស្រង់គាថាពីក្នុងគម្ពីរព្រះត្រៃបិដក។ ក្នុងចំណោមនោះ មានមួយចារឹកលើខ្នងព្រះពុទ្ធរូបតែម្តង។[69]

បច្ចុប្បន្ននេះ កម្ពុជា ជាប្រទេសដែលប្រជាជនភាគច្រើន កាន់ពុទ្ធសាសនាបែបថេរវាទ។ ពុទ្ធសាសនាត្រូវបានកំណត់ជាសាសនារបស់រដ្ឋ ដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ហើយសាសនាដ៏មានតម្លៃនេះបានជ្រាបចូលយ៉ាងជ្រៅក្នុងអត្តសញ្ញាណ វប្បធម៌ និងអភិបាលកិច្ចខ្មែរ ជាច្រើនជំនាន់មកហើយ។ អស់រយៈពេលច្រើនសតវត្សកន្លងមកនេះ គោលការណ៍ពុទ្ធសាសនា បានជះឥទ្ធិពលដល់ច្បាប់

---

[៦៩] វង់ សុជាវ៉ា និងណុប សុខា. ២០១២. *ប្រវត្តិសាស្ត្រខ្មែរ៖ សម្រាប់សិក្សាថ្នាក់មូលដ្ឋាន*. ភ្នំពេញ: សាកលវិទ្យាល័យភូមិន្ទភ្នំពេញ, ទំព័រ ៣១។

ទំនៀមទម្លាប់ និយាមសង្គម ឥរិយាបថ ផ្នត់គំនិត ជំនឿ វិធីជីវិត។ល។ ដែលគេអាចឃើញជាក់ស្តែងតាមរយៈចំនួនវត្តអារាម និងព្រះសង្ឃពុទ្ធសាសនានៅកម្ពុជាបច្ចុប្បន្ន។ នៅមុនពេលច្បាប់អាណានិគមបារាំង (ប្រព័ន្ធច្បាប់ស៊ីវិល) ត្រូវបានណែនាំឱ្យអនុវត្តនៅសតវត្សទី១៩ ប្រភពច្បាប់កម្ពុជាបានពឹងផ្អែកដោយច្រើន លើក្រមច្បាប់ដែលទទួលឥទ្ធិពលពីអត្ថបទ ឬគម្ពីរពុទ្ធសាសនា ឬទទួលឥទ្ធិពលដោយផ្ទាល់ពីគោលការណ៍ពុទ្ធសាសនា (ពុទ្ធប្បញ្ញត្តិ) និងព្រះរាជក្រឹត្យ (រាជប្បញ្ញត្តិ) ដែលមិនខុសគ្នាពីរបបសម្បូណ៌ាផ្លាសិទ្ធិរាជ្យ នៅប្រទេសនានាក្បែរខាងកម្ពុជានោះទេ។

តើទស្សនវិជ្ជាពុទ្ធសាសនា មានឥទ្ធិពលដូចម្តេចខ្លះដល់ច្បាប់សង្គម? តើពុទ្ធសាសនាបានរួមចំណែកដូចម្តេចខ្លះក្នុងការសាងច្បាប់ ការអនុវត្តច្បាប់ ការកសាងបូរណភាពនៃប្រព័ន្ធច្បាប់កម្ពុជា និងចីរភាពនៃវប្បធម៌នីតិរដ្ឋនៅកម្ពុជា?

### ១.៣.៤.១ តើអ្វីជាគោលការណ៍សំខាន់ៗនៃពុទ្ធសាសនា?

ក្នុងពុទ្ធសាសនា គម្ពីរព្រះត្រៃបិដក ជាឃ្លាំងផ្ទុកពុទ្ធវចនៈ គឺវចនៈនៃអង្គព្រះសម្ពុទ្ធ (pensée du bouddha) ដែលទ្រង់ទេសនាទូន្មានរវាង៤៥ វស្សា ចាប់តាំងពីទ្រង់បានត្រាស់ដឹងព្រះសម្មាសម្ពោធិញ្ញាណរហូតមកដល់ទ្រង់បរិនិព្វាន។ វចនៈដែលទ្រង់សម្តែងនេះហៅថា ធម្មវិន័យ ដែលព្រះអង្គសម្តែងបញ្ញត្ត។ ធម្មវិន័យនេះមាន៣ចំណែកគឺ សុត្តន្ត វិន័យ អភិធម្ម ទាំង៣នេះ ព្រះថេរៈទាំងឡាយបានសង្គាយនា (ផ្ទៀងផ្ទាត់) ចងក្រង ហើយដាក់មួយក្រុមៗហៅថា បិដក ឬព្រះត្រៃបិដក "កញ្ជើបី" (Triple Corbeille)។ ពាក្យថាបិដកនេះ បើប្រែថាទូ ឬ បណ្ណាល័យ ក៏សឹងតែបានដែរ ។ បើប្រៀបធៀបមើលឃើញថា គម្ពីរព្រះត្រៃបិដកនេះ មានចំនួនច្រើនជាងគម្ពីរវេទច្រើនណាស់ ច្រើនជាងគម្ពីរប៊ីប ១១ ដងច្រើនជាងគម្ពីរកូរអានជាអនេក។ គម្ពីរព្រះត្រៃបិដកមាន៣ចំណែកគឺ វិនយបិដក (១៣ភាគ) សុត្តន្តបិដក (៦៤ភាគ) និងអភិធម្មបិដក (៣៣ភាគ)។ គម្ពីរទាំង៣នេះ មានអដ្ឋកថា ដីកា យោជនា ប្រកបទៀតផង។

- វិនយបិដក ជាគម្ពីរស្តីពីច្បាប់ក្រឹត្យក្រម (Discipline) ដែលអង្គព្រះសម្ពុទ្ធទ្រង់បញ្ញត្ត ទ្រង់អនុញ្ញាត ទុកសម្រាប់ជាផ្លូវប្រតិបត្តិរបស់ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា។
- សុត្តន្តបិដក ជាគម្ពីរស្តីពីសូត្រ (Aphorisme) ដែលអង្គព្រះសម្ពុទ្ធទ្រង់ត្រាសទេសនាក្នុងសម័យផ្សេងៗ។ មានសូត្រខ្លះ ព្រះអរិយសាវ័កសម្តែង ដូចព្រះសារីបុត្តត្ថេរ ព្រះមោគ្គល្លានត្ថេរ ព្រះអានន្ទត្ថេរ។
- អភិធម្មបិដក ជាគម្ពីរស្តីពីធម៌មានអាថ៌ជ្រាលជ្រៅល្អិតសុខុមបំផុត (Métaphysique) បានដល់ទស្សនវិជ្ជាព្រះសម្ពុទ្ធ ដែលមានអាថ៌គម្ពីរភាព ជាអត្ថបទផ្ទុយពីសុត្តន្តបិដក ដែលមានតែអត្ថបទមានអាថ៌រាក់ៗ គឺសុត្តន្តបិដក ជា វោហារទេសនា (Parole Conventionnelle), ឯអភិធម្មបិដក

ជាបរមត្ថទេសនា (Parole definitive) ស្តីពី ចិត្ត (conscience) ចេតសិក (Mental concomitant) រូប (Matière) និព្វាន។[70]

### ក. ព្រហ្មវិហារធម៌ (មេត្តា និងករុណា)

ព្រហ្មវិហារធម៌ មាន៤ប្រការគឺ៖

- មេត្តា សេចក្តីស្រឡាញ់
- ករុណាសេចក្តីអាណិតអាសូរ
- មុទិតា ចិត្តទោរទន់
- ឧបេក្ខា ចិត្តជាកណ្តាល។

តើព្រហ្មវិហារធម៌ ជាពិសេស មេត្តា និងករុណា មានទំនាក់ទំនងដូចម្តេចចំពោះការកសាងច្បាប់សង្គម?

ច្បាប់ទាក់ទងនឹងសុខុមាលភាពសង្គម ការការពារក្រុមជនងាយរងគ្រោះ និងការស្តារនីតិសម្បទាអ្នកប្រព្រឹត្តបទល្មើសនានា សុទ្ធតែបានឆ្លុះបញ្ចាំងនូវគំនិតពុទ្ធសាសនាស្តីពីសេចក្តីស្រឡាញ់ និងអាណិតអាសូរមនុស្សជាតិ។ បទប្បញ្ញត្តិនៅក្នុងច្បាប់ស្តីពីគ្រួសារ ពិតជាបានឆ្លុះបញ្ចាំងនូវសីលធម៌ពុទ្ធសាសនាទាក់ទងសង្គហធម៌របស់ឳពុកម្តាយចំពោះកូនចៅ។ បទប្បញ្ញត្តិស្តីពីការការពារអនីតិជន ឆ្លុះបញ្ចាំងនូវគំនិតពុទ្ធសាសនាអំពីព្រហ្មវិហារធម៌ ពោលគឺសេចក្តីស្រឡាញ់ សេចក្តីអាណិតអាសូរ សេចក្តីសង្គ្រោះ និងការយកចិត្តទុកដាក់ ដែលសង្គមត្រូវអនុវត្តចំពោះកុមារ ដែលជាទំពាំងស្នងឫស្សី។

### ខ. ទ្រឹស្តីកម្មផល

ពុទ្ធសាសនាបានបញ្ជាក់ថា បុគ្គលសាបព្រោះពូជណា រមែងទទួលបាននូវផ្លែផ្កាបែបនោះ។ បុគ្គលធ្វើអំពោះល្អរមែនទទួលបានផលល្អ រីឯបុគ្គលប្រព្រឹត្តអំពើអាក្រក់រមែងទទួលបានផលអាក្រក់។

តើទ្រឹស្តីកម្មផល មានទំនាក់ទំនងដូចម្តេចចំពោះការកសាងច្បាប់សង្គម?

នៅក្នុងពុទ្ធសាសនា គេជឿថា គ្រប់សកម្មភាពតែងតែមានផល (កម្ម-វិបាក)។ ប្រជាជនខ្មែរក៏បានប្រើប្រាស់គំនិតនេះ ដើម្បីដាក់ការទទួលខុសត្រូវលើសកម្មភាពរបស់បុគ្គល ដោយមិនមែនភ្ជាប់ត្រឹមតែការទទួលខុសត្រូវចំពោះច្បាប់សង្គមប៉ុណ្ណោះទេ ថែមទាំងការទទួលខុសត្រូវផ្នែកសីលធម៌ផងដែរ។ គេអាចឃើញទិដ្ឋភាពនេះទាំងនៅក្នុងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ និងរដ្ឋប្បវេណី និងផ្នែកសីលធម៌សង្គម តាមរយៈការរិះគន់ធ្ងន់ៗចំពោះបុគ្គលដែលប្រព្រឹត្តបទល្មើសនានា ។

ពាក្យថាកម្ម ប្រែថា អំពើ ឬសកម្មភាព (កាយ វាចា ចិត្ត) ដែលនឹងត្រូវទទួលផលតបមកវិញ ដែលហៅថា វិបាក ឬផល (*vipāka*)។

---

[៧០] ប៉ាង ខាត់, *ព្រះត្រៃបិដកជាភាសាខ្មែរ*, ឆ្នាំ១៩៧០, ភ្នំពេញ: ពុទ្ធសាសនបណ្ឌិត្យ, ទំព័រ២-៦។

ជាគោលការណ៍ៈ

- អំពើល្អ➔ លទ្ធផលល្អ, អំពើអាក្រក់➔ លទ្ធផលអាក្រក់ (សេចក្ដីទុក្ខ) នៅក្នុងលោកនេះ និងលោកខាងមុខ។
- សម្រាប់សង្គមៈ កម្ម បង្កើតនូវក្រមសីលធម៌ ដែលថា បុគ្គលគ្រប់រូបត្រូវទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន។

សង្គមកម្ពុជាមើលឃើញថា សកម្មភាពខុសច្បាប់ (ចោរកម្ម អំពើហិង្សា ការកេងប្រវ័ញ្ចជា អាទិ៍) ជាការប្រព្រឹត្តអំពើបាប ដែលធ្វើឱ្យអ្នកប្រព្រឹត្ត និងសង្គម ទទួលរងនូវសេចក្ដីទុក្ខលំបាក។ សីលធម៌ពុទ្ធសាសនាពាក់ព័ន្ធនឹងការទទួលខុសត្រូវផ្នែកសីលធម៌នេះ នាំឱ្យមានការគោរពច្បាប់ និងទម្លាក់ចោលការប្រព្រឹត្តខុសច្បាប់ ដោយសារការភ័យខ្លាចអំពីទណ្ឌកម្មទាំងក្នុងបច្ចុប្បន្នជាតិ និងអនាគតជាតិ។ ទ្រឹស្ដីកម្មផលនេះគាំទ្រគំនិតថា យុត្តិធម៌មិនអាចចៀសវាងបានទេ ពោលគឺ បើទោះជាច្បាប់រដ្ឋមិនបានអនុវត្តលើបុគ្គលនោះក៏ដោយ អំពើបាបមិនអាចគេចវេសពីផលបាបបានទេ។

**ប្រៀបធៀបទ្រឹស្ដីកម្មផល និងច្បាប់សង្គម**

| ច្បាប់សង្គម | ទ្រឹស្ដីកម្មផល |
|---|---|
| *រដ្ឋធម្មនុញ្ញ ១៩៩៣* | |
| ភាពស្មើគ្នាចំពោះមុខច្បាប់ (មាត្រា៣១) | ភាពមិនលម្អៀង (បុគ្គលគ្រប់រូបនឹងទទួលផលកម្មដែលខ្លួនបានប្រព្រឹត្ត) |
| សិទ្ធិទទួលបានការព្យាបាល (មាត្រា៧២) | ទាក់ទងនឹងទ្រឹស្ដីកម្មផលនៅត្រង់ការទទួលខុសត្រូវចំពោះសកម្មភាពដែលជះឥទ្ធិពលលើអ្នកដទៃ |
| *ក្រមព្រហ្មទណ្ឌ ២០០៩* | |
| ទោសប្បញ្ញត្តិចំពោះបទហិង្សាដោយចេតនា (មាត្រា២១៧), អំពើលួច (មាត្រា៣៥៣), បទឆបោក (មាត្រា៣៧៧) ។ល។ | ឆ្លុះបញ្ចាំងនូវគោលការណ៍របស់កម្មផលដែលថា អំពើដែលប៉ះពាល់អ្នកដទៃ នឹងទទួលបានផលអវិជ្ជមាន |
| *ក្រមរដ្ឋប្បវេណី ២០០៧* | |
| បញ្ញត្តិស្ដីពីកិច្ចសន្យា និងអំពើអនីត្យានុកូល | ឆ្លុះបញ្ចាំងនូវហេតុ និងផលរបស់ហេតុ ពោលគឺការប្រព្រឹត្តខុសដូចជា ការបំពានកិច្ចសន្យា ឬការបង្កព្យសនកម្ម ត្រូវតែមានសំណង។ នេះស្របទៅ |

| | |
|---|---|
| | នឹងទ្រឹស្តីកម្មផលស្តីពីហេតុ និងផល (cause and effect) |

ជារួម សម្រាប់មូលដ្ឋានសីលធម៌ ទ្រឹស្តីកម្មផលបញ្ជាក់អំពីការទទួលខុសត្រូវលើសកម្មភាពខ្លួនឯងផ្ទាល់ ដោយពង្រឹងការទទួលខុសត្រូវផ្នែកច្បាប់។ សម្រាប់ភាពសុខដុមរមនានៃសង្គម ទ្រឹស្តីកម្មផល និងច្បាប់សង្គម មានគោលដូចគ្នាគឺការពារកុំឱ្យមានជម្លោះ និងលើកតម្កើងសណ្តាប់ធ្នាប់សង្គម តាមរយៈការការបង្ហាញអំពីទោសទណ្ឌ ឬផលវិជ្ជមាន ផ្អែកលើអំពើរបស់បុគ្គល។

**គ. អរិយសច្ច៤**

- ទុក្ខសច្ច សេចក្តីទុក្ខ
- សមុទយសច្ច ហេតុដែលនាំឱ្យកើតទុក្ខ
- និរោធសច្ច ការរំលត់សេចក្តីទុក្ខ
- មគ្គសច្ច មាគ៌ាឆ្ពោះទៅរកការរំលត់ទុក្ខ

តើអរិយសច្ច មានទំនាក់ទំនងដូចម្តេចខ្លះនឹងច្បាប់សង្គម?

អរិយសច្ច៤ *(ចត្តារិ អរិយសច្ចានិ)* គឺជាមូលដ្ឋានគ្រឹះនៃពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ហើយអរិយសច្ចនេះ ក៏អាចយកមកអនុវត្តជាក្របខ័ណ្ឌសម្រាប់ដោះស្រាយវិវាទ ទាំងវិវាទបុគ្គលផ្ទាល់ខ្លួន ទាំងវិវាទសង្គម ឬវិវាទពាក់ព័ន្ធនឹងច្បាប់ ដូចខាងក្រោម៖

**អរិយសច្ចទី១៖ សេចក្តីទុក្ខ**

ក្នុងការដោះស្រាយវិវាទ គេត្រូវទទួលស្គាល់ថា សេចក្តីទុក្ខ ការមិនពេញចិត្ត និងភាពតានតឹង មានពិតប្រាកដនៅក្នុងវិវាទគ្រប់ប្រភេទ។ ជំហាននេះ តម្រូវឱ្យគូភាគីទទួលស្គាល់នូវអត្ថិភាពនៃវិវាទ និងផលប៉ះពាល់ជាអវិជ្ជមានរបស់វិវាទ ដូចជា ការខឹងក្រោធ ការមិនទុកចិត្តគ្នា ភាពអយុត្តិធម៌ និងអំពើហិង្សា ជាដើម។ នៅក្នុងប្រពៃណីខ្មែរ ព្រះសង្ឃតែងតែចាប់ផ្តើមផ្សះផ្សាវិវាទ ដោយឱ្យភាគីសារភាពអំពីការឈឺចាប់ និងព្យសនកម្មទាំងឡាយដែលកើតចេញពីជម្លោះនោះ។

**អរិយសច្ចទី២៖ សមុទយ** (ហេតុដែលនាំឱ្យកើតទុក្ខ)

ក្នុងការដោះស្រាយវិវាទ គេត្រូវកត់សម្គាល់នូវឫសគល់នៃវិវាទ ពោលគឺ លោភ (សេចក្តីលោភលន់) ទោស (កំហឹង) និងមោហ (វង្វេង)។ ក្នុងសង្គមកម្ពុជា ប្រភេទនៃវិវាទមានដូចជា វិវាទដីធ្លី អំពើហិង្សាក្នុងគ្រួសារ ការកេងបន្លំ ការប្រណែនគ្នា ការយល់ច្រឡំ ជាដើម។ ការដោះស្រាយវិវាទតាមមាគ៌ាពុទ្ធសាសនាតម្រូវឱ្យតាមដាន និងឈ្វេងយល់ស៊ីជម្រៅអំពីមូលហេតុនៃវិវាទដូចជាសេចក្តីលោភលន់ កំហឹង និងការយល់ច្រឡំ របស់មនុស្ស មិនមែនផ្អែកតែទៅលើមូលហេតុផ្ទៃក្រៅដែលបង្កទៅជាជម្លោះនោះទេ។

**អរិយសច្ចទី៣៖ និរោធ** (ការរំលត់ទុក្ខ)

នៅក្នុងការដោះស្រាយវិវាទ គេត្រូវកត់សម្គាល់ថា សន្តិភាពពិតជាអាចកើតមាននៅពេលមូលហេតុនៃវិវាទត្រូវបានដកចេញ។ គោលគំនិតនេះឆ្លើយតបទៅនឹងការផ្សះផ្សា ការអភ័យទោស និងការសម្រុះសម្រួល ពោលគឺ ការស្តារឡើងវិញនូវសុខដុមភាព ឬសាមគ្គីភាពរវាងគូភាគី។ ការអនុវត្តសន្ធានកម្មនៅកម្ពុជា ជាពិសេសសន្ធានកម្មដែលធ្វើឡើងដោយព្រះសង្ឃ ឬចាស់ព្រឹទ្ធាចារ្យ មានគោលបំណងបញ្ចប់នូវអរិភាព និងស្តារឡើងវិញនូវចំណងសមាគ្គីភាពសហគមន៍ មិនមែនផ្តោតតែទៅលើការឈ្នះចាញ់ក្តីទេ។

**អរិយសច្ចទី៤៖ មគ្គ** (មាគ៌ាឆ្ពោះទៅរកការរំលត់ទុក្ខ)

ក្នុងការដោះស្រាយវិវាទ គេត្រូវដើរតាមជំហានអនុវត្តន៍ដែលគេហៅថា អដ្ឋង្គិកមគ្គ ឬ មាគ៌ាប្រកបដោយអង្គ៨ប្រការ ដូចខាងក្រោម៖

- **សម្មាទិដ្ឋិ ការយល់ត្រូវ៖** ការមើលឃើញវិវាទពីគ្រប់ជ្រុងនៃទស្សនៈរបស់ភាគី
- **សម្មាសង្កប្ប ការត្រិះរិះត្រូវ៖** ការចូលរួមចរចាដោយសុច្ឆន្ទៈ មិនមែនដោយចេតនាសងសឹកទេ
- **សម្មាវាចា សំដីត្រូវ៖** ការចៀសវាងសំដីកុហក ឬ ពាក្យទ្រគោះ នៅក្នុងការសន្ទនា
- **សម្មាកម្មន្ត ការងារត្រូវ៖** ការធ្វើសកម្មភាពប្រកបដោយអហិង្សា និងសមរម្យ
- **សម្មាអាជីវ ការចិញ្ចឹមជីវិតត្រូវ៖** ការធានាថាកិច្ចព្រមព្រៀងទាំងឡាយប្រកបដោយសីលធម៌ និងចីរភាព
- **សម្មាវាយាម សេចក្តីព្យាយាមត្រូវ៖** ការរក្សាបាននូវការតស៊ូអត់ធ្មត់ក្នុងការសន្ទនា
- **សម្មាសតិ ការតម្កល់ស្មារតី៖** ការស្គាល់ច្បាស់អំពីអារម្មណ៍របស់ភាគីនៅក្នុងការសន្ទនា
- **សម្មាសមាធិ ការតម្កល់ចិត្តត្រូវ៖** ការផ្តោតលើសន្តិភាពយូរអង្វែង ជាជាងលាភសក្ការៈរយៈពេលខ្លី ។

## ង. ទសពិធរាជធម៌ (ធម្មរាជា ឬ ធម្មិករាជ)

ក្នុងប្រទេសឥណ្ឌា ដែលជាប្រភពនៃពុទ្ធសាសនា ពាក្យថាក្សត្រ ឬ វណ្ណៈក្សត្រ ពុំមែនសំដៅតែទៅលើក្សត្រដែលសោយរាជ្យនោះទេ។ ពាក្យថាក្សត្រ មានន័យក្នុងឋានៈជាអ្នកដែលមានមុខនាទីក្នុងការគ្រប់គ្រងប្រទេស គ្រប់គ្រងខេត្ត ជាទ័ពចម្បាំង ជាមន្ត្រីរាជការគ្រប់ជាន់ថ្នាក់។ បើនិយាយតាមភាសាបច្ចុប្បន្ន បានដល់រដ្ឋាភិបាល គណៈរដ្ឋមន្ត្រី និង មន្ត្រីរាជការទាំងពួង។

ទសពិធរាជធម៌ មានទាំងអស់ ១០ ប្រការគឺ:

- ទាន ការឱ្យទាន
- សីល ការប្រព្រឹត្តល្អ
- បរិច្ចាគ ការបរិច្ចាគ
- អាជ្ជវៈ ការស្មោះត្រង់
- មទ្ទវៈ ការទន់ភ្លន់
- តបៈ ការដុតកិលេស
- អក្កោធនៈ ការមិនក្រោធ

- អវិហិង្សា		ការមិនបៀតបៀន
- ខន្តី		ការអត់ធន់
- អវិរោធនៈ		ការមិនធ្វើខុស ។

តើទសពិធរាជធម៌មានទំនាក់ទំនងដូចម្តេចខ្លះនឹងច្បាប់សង្គម?

ទំនាក់ទំនងរវាងទសពិធរាជធម៌និងច្បាប់សង្គមប្រព្រឹត្តទៅដូចខាងក្រោម៖

១) ការឱ្យទាន (ទាន)៖ ព្រះរាជាត្រូវឱ្យទានដល់ប្រជារាស្ត្រ ដើម្បីសុខុមាលភាពរបស់ប្រជារាស្ត្រ។ ស្របនឹងរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ រដ្ឋមានកាតព្វកិច្ចផ្តល់ការអប់រំ ការថែទាំសុខភាព និងការគាំពារសង្គម ដល់ប្រជាពលរដ្ឋ (មាត្រា៦៥ -៧៣) ។

២) ការប្រព្រឹត្តល្អ (សីល)៖ ព្រះរាជាត្រូវមានសីលធម៌ ហើយអនុវត្តជាគំរូដល់ប្រជារាស្ត្រ។ សីលធម៌នេះឆ្លុះបញ្ចាំងជាមួយនឹងច្បាប់កម្ពុជាបច្ចុប្បន្ន តាមរយៈវិធានប្រឆាំងអំពើពុករលួយ ក្រមសីលធម៌របស់មន្ត្រីរាជការសាធារណៈ និងស្មារតីរដ្ឋធម្មនុញ្ញពាក់ព័ន្ធនឹងអភិបាលកិច្ចល្អ។

៣) ការលះបង់ (ការបរិច្ចាគ)៖ ព្រះរាជាត្រូវមានឆន្ទៈលះបង់ប្រយោជន៍ផ្ទាល់ខ្លួន ដើម្បីប្រយោជន៍សាធារណៈ។ ស្របនឹងគោលការណ៍នៃសេវាធារណៈ និងកាតព្វកិច្ចរដ្ឋ ការលះបង់នេះឆ្លុះបញ្ចាំងនៅក្នុងច្បាប់ទាំងឡាយដែលតម្រូវឱ្យមន្ត្រីផ្តល់អាទិភាពលើសុខុមាលភាពរបស់ពលរដ្ឋជាងលាភសក្ការៈផ្ទាល់ខ្លួន។

៤) ការស្មោះត្រង់ (អាជ្ជវៈ)៖ ព្រះរាជាត្រូវគ្រងរាជ្យដោយភាពស្មោះត្រង់។ ភាពស្មោះត្រង់នេះឆ្លុះបញ្ចាំងក្នុងការកសាងច្បាប់នៅកម្ពុជាពាក់ព័ន្ធនឹងសក្ខីកម្មប្រកបដោយភាពស្មោះត្រង់ ភាពស្មោះត្រង់ក្នុងអភិបាលកិច្ច និងតម្លាភាព។

៥) ការទន់ភ្លន់ (មទ្ទវៈ)៖ ព្រះរាជាបុគ្គលសុភាពរាបសារ និងប្រកបដោយករុណាធម៌។ ភាពទន់ភ្លន់ប្រកបដោយករុណានេះភ្ជាប់ទៅនឹងប្រពៃណីនៃការផ្សះផ្សាវិវាទនៅក្នុងច្បាប់ស្តីពីគ្រួសារ ការផ្សះផ្សាវិវាទក្នុងសហគមន៍ និងទំនៀមដោះស្រាយវិវាទនៅកម្ពុជា។

៦) ការដុតកិលេស (តបៈ)៖ ព្រះរាជាត្រូវគ្រប់គ្រងខ្លួនឱ្យល្អ ពោលគឺ ត្រូវអនុវត្តការអត់ធ្មត់ និងការគ្រប់គ្រងខ្លួនឯងចៀសវាងភាពប្រណីតហួសហេតុ និងការត្រេកត្រអាលក្នុងកាមគុណ។ ការដុតកិលេសនេះភ្ជាប់ទៅនឹងច្បាប់កម្ពុជាអំពីរបៀបរស់នៅប្រកបដោយភាពសមរម្យ និងភាពសាមញ្ញរបស់មន្ត្រីសាធារណៈ ព្រមទាំងការជៀសវាងការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋដោយខុសបំណង។

៧) ការមិនក្រោធ (អក្កោធនៈ)៖ ព្រះរាជាត្រូវចៀសវាងនូវកំហឹងខឹងក្រោធ ការសងសឹក និងភាពឃោរឃៅ។ ការមិនខឹងក្រោធឆ្លុះបញ្ចាំងនៅក្នុងច្បាប់កម្ពុជាពាក់ព័ន្ធនឹងការហាមប្រាមការប្រើប្រាស់អំពើហិង្សា ការសម្លាប់ដោយការសងសឹកគ្នា និងការដាក់ទោសទណ្ឌហួសប្រមាណ។

៨) ការមិនបៀតបៀន (អវិហិង្សា)៖ ព្រះរាជាត្រូវរក្សាការពារអាយុជីវិតប្រជារាស្ត្រដោយសេចក្តីករុណា និងមិនបៀតបៀនអាយុជីវិតរបស់ប្រជារាស្ត្រ។ ការមិនបៀតបៀននេះឆ្លុះបញ្ចាំងនៅក្នុងច្បាប់ព្រហ្មទណ្ឌនិងច្បាប់

នានាពាក់ព័ន្ធនឹងឃាតកម្ម ការរំលោភបំពានសិទ្ធិមនុស្ស ជាដើម និងច្បាប់នានាពាក់ព័ន្ធនឹងការការពារអាយុជីវិត និងសេចក្ដីថ្លៃថ្នូរ។

៩) ការអត់ធន់ (ខន្តិ)៖ ព្រះរាជាត្រូវមានសេចក្ដីអត់ធន់ និងចេះអត់ឱន ពោលគឺ ចេះអត់ធ្មត់នៅពេលជួបភាពលំបាក និងទទួលយកការរិះគន់។ អត់ធ្មត់ជាជំនួយសម្រាប់ការដោះស្រាយជម្លោះដោយសន្តិភាព មិនបង្កការវាយប្រហារ ឬសងសឹក។ ច្បាប់សង្គមកម្ពុជាគ្រប់គ្រងអំពើហិង្សា និងប្រឆាំងអំពើឧក្រិដ្ឋ ដូច្នេះការអនុវត្តការអត់ធ្មត់ជួយជំរុញមិនឱ្យបំពានច្បាប់។ ការអត់ធន់ជាគុណសម្បត្តិដែលលើកស្ទួយការរស់នៅដោយសន្តិភាព និងការគោរពច្បាប់។

១០) ការមិនធ្វើខុស (អវិរោធនៈ)៖ ព្រះរាជាត្រូវរក្សាយុត្តិធម៌ ការពារច្បាប់ និងចៀសវាងភាពលម្អៀង។ ការមិនធ្វើខុសនេះបង្ហាញនូវអត្តសញ្ញាណគោលការណ៍នីតិរដ្ឋ (Rule of Law) នៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា (មាត្រា ៥១)ឯករាជ្យភាពនៃតុលាការ និងភាពស្មើគ្នាចំពោះមុខច្បាប់ (មាត្រា ៣១)។

**ច. គោលការណ៍អនាគតិ**

- មិនលម្អៀងព្រោះស្រឡាញ់
- មិនលម្អៀងព្រោះស្អប់
- មិនលម្អៀងព្រោះភ័យខ្លាច
- មិនលម្អៀងព្រោះល្ងង់ ។

តើគោលការណ៍អនាគតិ មានទំនាក់ទំនងដូចម្ដេចខ្លះចំពោះច្បាប់ និងយុត្តិធម៌សង្គម?

គោលការណ៍អនាគតិនៃពុទ្ធសាសនាមានទំនាក់ទំនងនឹងច្បាប់ និងយុត្តិធម៌សង្គមដូចខាងក្រោម៖

**១) គោលការណ៍អនាគតិដែលមានក្នុងរដ្ឋធម្មនុញ្ញ៖** ប្រជាពលរដ្ឋទាំងអស់មានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ ដោយមិនគិតពីពូជសាសន៍ ពណ៌សម្បុរ ភេទ ជាដើម (មាត្រា៣១), ច្បាប់ធានាការពារប្រឆាំងនឹងការរើសអើង និងការកាត់ក្ដីដោយអយុត្តិធម៌ នៅក្នុងនីតិវិធីតុលាការ (មាត្រា៣៨) និងអំណាចតុលាការជាអំណាចឯករាជ្យ និងធានាអនាគតិ និងការពារសិទ្ធិ សេរីភាពរបស់ប្រជាពលរដ្ឋ (មាត្រា១២៨ថ្មី)។

**២) គោលការណ៍អនាគតិឆ្លុះបញ្ចាំងក្នុងច្បាប់កម្ពុជា៖**

- ក្រមនីតិវិធីព្រហ្មទណ្ឌ (២០០៧)៖ ក្រមនីតិវិធីព្រហ្មទណ្ឌបានតម្រូវឱ្យមានយុត្តិធម៌ ភាពមិនលម្អៀង និងតម្លាភាព។
- ក្រមរដ្ឋប្បវេណី (២០០៧)៖ រក្សានូវសមភាពចំពោះសិទ្ធិពលរដ្ឋ កិច្ចសន្យា និងកាតព្វកិច្ច។
- ក្រមនីតិវិធីរដ្ឋប្បវេណី (២០០៦)៖ គោលការណ៍អនាគតិស្របនឹងគោលការណ៍ចំពោះមុខដែលមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ដោយភាគីមិនអាចត្រូវបានជំនុំជម្រះដោយ

មិនបានសាកសួរ ឬកោះហៅឡើយ។ មួយវិញទៀត តុលាការត្រូវប្រឹងប្រែងរ៉ាប់រងបណ្តឹងឱ្យទទួលបានយុត្តិធម៌យ៉ាងឆាប់រហ័ស និងប្រកបដោយសុចរិត និងស្មោះត្រង់។

ជារួម គោលការណ៍អនាគតិជួយពង្រឹងវប្បធម៌នៃនីតិរដ្ឋ ដោយធានាថា យុត្តិធម៌មិនត្រូវបានបំភាន់ ឬរំលោភបំពាន ដោយទ្រព្យសម្បត្តិ អំណាច ឬទំនាក់ទំនងផ្ទាល់ខ្លួនឡើយ។

## ជ. វត្តអារាមពុទ្ធសាសនាក្នុងសង្គមខ្មែរ

ការគោរពពុទ្ធសាសនានេះ មានតាំងពីសម័យបុរាណ គឺតាំងពីមុនសម័យអង្គរទៅទៀត។ ការគោរពពុទ្ធសាសនាតៗគ្នារាប់សតវត្សរ៍បែបនេះ បានធ្វើឱ្យទស្សនវិជ្ជាពុទ្ធសាសនា ជ្រួតជ្រាប ជិតជាប់ក្នុងផ្នត់ចិត្តគំនិតរបស់ប្រជាពលរដ្ឋខ្មែរទូទាំងប្រទេស។ ផ្នត់ចិត្តគំនិតនេះ បានក្លាយទៅជា "*ទស្សនៈរួម របស់ជាតិ*" ដែលមនុស្សខ្មែរសព្វថ្ងៃមានពីកំណើត។ ទោះអ្នកនោះ មិនបានទៅ វត្តរៀនធម៌អាថ៌ក៏ដោយ ក៏ទស្សនៈព្រះពុទ្ធដែលបន្តពីឪពុកម្តាយ បានជ្រាបចូលទៅដល់បុត្រធីតារួចស្រេចទៅហើយ ហើយមិនអាចធ្វើឱ្យប្តូរផ្លាស់បានដោយងាយៗឡើយ។ ជាពិសេស ប្រជាពលរដ្ឋជាកសិកររស់នៅតាមជនបទ រមែងផ្សារភ្ជាប់ខ្លួនគេទៅនឹងវត្តអារាមនិងជួយទ្រទ្រង់វត្តឱ្យមានជីវិតជានិច្ចនិរន្តរ៍រហូតតមក។ ទីណាមានប្រជារាស្ត្រខ្មែររស់នៅ ទីនោះមានវត្ត។[៧១]

តើវត្តអារាមបានផ្តល់អ្វីខ្លះដល់ប្រជាជនខ្មែរ?

- វត្តអារាមជាទីតាំងនៃពុទ្ធសាសនា ដែលជាពឹងពុំនាក់របស់ប្រជាជនគ្រប់ៗរូប ។
- វត្តអារាមជាមន្ទីរពេទ្យផ្លូវចិត្តរបស់ពុទ្ធបរិស័ទជើងវត្ត ។
- វត្តជាកន្លែងជាកន្លែងជ្រកកោនរបស់អ្នកកម្សត់ទុគ៌ត។
- វត្តជាជម្រកនិរភ័យរបស់សត្វម្រឹគីម្រឹគា បក្សាបក្សីនិងមច្ឆជាតិនិង ជាកន្លែងរក្សាការពារពូជឈើព្រៃឱ្យគង់វង្ស។ វត្តជាសួនច្បារ ជាអារាម ជា រមណីយដ្ឋាន អាចលំហែអារម្មណ៍បាន។
- វត្តជារណ្តៅដែលគេកប់ចោលនូវទំនាស់ទាស់ទែងគ្នា ជាកមន្លែងដែលមនុស្សទាំងអស់មានភាពស្មើគ្នា។
- វត្តជាចំណុចកណ្តាលនៃឆ្លងសាមគ្គីភាពជាតិ និងប្រជាធិបតេយ្យ។
- វត្តជាកន្លែងការពារសិទ្ធិរបស់ប្រជាជនដែរ។
- វត្តជាមជ្ឈមណ្ឌលវប្បធម៌របស់ប្រជាជន ។

### ១.៣.៤.២ តួនាទីពុទ្ធសាសនាក្នុងការកសាងច្បាប់ និងការអនុវត្តច្បាប់សង្គម

## ក. សម័យមុនអាណានិគមបារាំង

---

[៧១] យី ធន់, *វត្តអារាមជាមជ្ឈមណ្ឌលវប្បធម៌របស់ប្រជារាស្ត្រខ្មែរ*, ១៩៩៤, ភ្នំពេញ: កម្ពុជសុរិយា ។

ដូចបានបញ្ជាក់ខាងលើ មុនពេលបារាំងចូលមកត្រួតត្រានៅសតវត្សទី១៩ ច្បាប់និងសណ្តាប់ធ្នាប់សង្គមខ្មែរទទួលឥទ្ធិពលយ៉ាងស៊ីជម្រៅពីពុទ្ធសាសនាបែបថេរវាទ។

- មូលដ្ឋានសីលធម៌នៃការបង្កើតច្បាប់

ច្បាប់និងនិយាមសង្គមមានឫសគល់ចេញពីគោលការណ៍ពុទ្ធសាសនាដូចជា ធម៌ករុណា និងធម៌អហិង្សាជាដើម។ នៅសម័យមុន យុត្តិធម៌សង្គមមិនមែនគ្រាន់តែជាតួនាទីរបស់រដ្ឋប៉ុណ្ណោះទេ ប៉ុន្តែគេមើលឃើញថា វាបានចាក់ជ្រៅចូលក្នុងផ្នត់គំនិតរបស់ជនជាតិខ្មែរ ដែលជឿថា ការធ្វើអំពើទុច្ចរិតនឹងនាំឱ្យឱ្យពួកគេរងទុក្ខវេទនាក្នុងឋាននរកជាដើម។

- ទស្សនៈស្តីពីធម្មរាជា ឬធម្មិករាជ

ព្រះមហាក្សត្រ ត្រូវគេហៅថាជាធម្មរាជា ឬធម្មិករាជ ដែលមានន័យថា ទ្រង់គ្រប់គ្រងប្រទេសជាតិដោយទសពិធរាជធម៌ ហើយធម្មានុរូបរបស់ព្រះអង្គអាស្រ័យលើការបដិបត្តិតាមគោលការណ៍ពុទ្ធសាសនា ពោលគឺ រាជធម៌ទាំង១០ប្រការ មានទានជាដើមនោះឯង។

- ព្រះសង្ឃជាផ្នែកនៃសណ្តាប់ធ្នាប់សង្គម

បព្វជិតពុទ្ធសាសនា បានដើរតួនាទីយ៉ាងសំខាន់ជាសន្ធានការី អ្នកអប់រំ និងជាទីប្រឹក្សាផ្នែកសីលធម៌។ អ្នកភូមិទាំងឡាយទទួលយកឱវាទពីព្រះសង្ឃក្នុងការដោះស្រាយជម្លោះមុនពេលសម្រេចចិត្តទៅតុលាការ។ វត្តអារាមជាមជ្ឈមណ្ឌលនៃសណ្តាប់ធ្នាប់សង្គម ការអប់រំ និងការជួបជុំគ្នារបស់សហគមន៍។

- អត្ថបទច្បាប់ខ្មែរ

គម្ពីរព្រះត្រៃបិដក និងសៀវភៅពុទ្ធសាសនាជាច្រើន មានខ្លឹមសារអប់រំគុណធម៌ សីលធម៌ ចរិយាធម៌ និងការអប់រំទាំងផ្លូវកាយនិងផ្លូវចិត្ត ដែលសុទ្ធតែជាមូលដ្ឋាននៃការកសាងវប្បធម៌ និងអរិយធម៌ ជាពិសេសកសាងមនុស្សនៅក្នុងសង្គមឱ្យប្រកបដោយចំណេះដឹង គុណធម៌ និងសីលធម៌។ អត្ថបទខ្មែរជាច្រើនបានរួមបញ្ចូលគ្នារវាងសីលធម៌ពុទ្ធសាសនា និងច្បាប់ទំនៀម ដែលមានឥទ្ធិពលលើច្បាប់នានាដូចជាច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ សន្តតិកម្ម ទ្រព្យសម្បត្តិ និងការកំណត់ទោសទណ្ឌ។

## ខ. សម័យក្រោយអាណានិគមបារាំង

នៅក្រោយសម័យអាណានិគមបារាំង ពុទ្ធសាសនានៅតែបន្តមានឥទ្ធិពលលើការកសាងច្បាប់សង្គមកម្ពុជា ដូចខាងក្រោម៖

- ការទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញ

រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ (មាត្រា៤៣) ប្រកាសថា ពុទ្ធសាសនាជាសាសនារបស់រដ្ឋ។ ការទទួលស្គាល់ជាផ្លូវការនេះធានាថា ពុទ្ធសាសនានៅតែជាត្រីវិស័យផ្នែកសីលធម៌សម្រាប់អភិបាលកិច្ច និងការប្រព្រឹត្តកិច្ចក្នុងសង្គម។

- ច្បាប់គ្រួសារ និងសហគមន៍

ច្បាប់សង្គមជាច្រើន ជាពិសេស ច្បាប់ពាក់ព័ន្ធនឹងគ្រួសារ អាពាហ៍ពិពាហ៍ និងសន្តតិកម្ម នៅតែបន្តឆ្លុះបញ្ចាំងនូវតម្លៃពុទ្ធសាសនា សេចក្ដីស្មោះត្រង់ គារវធម៌ ករុណាធម៌ និងការទទួលខុសត្រូវ។ ជម្លោះនៅតាមសហគមន៍ជារឿយៗត្រូវបានដោះស្រាយក្រៅផ្លូវការដោយព្រះសង្ឃ ចាស់ទុំ ឬ ការសម្រុះសម្រួលនៅកម្រិតមូលដ្ឋាន ដែលឆ្លុះបញ្ចាំងនូវវិធីសាស្ត្រដោះស្រាយវិវាទតាមបែបពុទ្ធសាសនា។

- ការកសាងសន្តិភាព និងការផ្សះផ្សា

បន្ទាប់ពីសម័យកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ពុទ្ធសាសនាដើរតួជាកម្លាំងព្យាបាលរបួសផ្លូវចិត្តរបស់ប្រជាជនកម្ពុជា និងការផ្សះផ្សាជាតិ។ ព្រះសង្ឃបានចូលរួមការព្យាបាលផ្លូវចិត្ត ពិធីសម្រុះសម្រួល និងជាមគ្គុទេសក៍សីលធម៌ សម្រាប់ការស្ដារឡើងវិញនូវសណ្ដាប់ធ្នាប់សង្គម។

- សម័យទំនើប

ខណៈពេលដែលច្បាប់រដ្ឋរៀបចំឡើងដោយស្ថាប័នផ្លូវការ ពុទ្ធសាសនាបន្តមានឥទ្ធិពលលើការប្រតិបត្តិសីលធម៌ជាសាធារណៈ៖

  - យុទ្ធនាការប្រឆាំងអំពើពុករលួយជារឿយៗ យកសីលធម៌ពុទ្ធសាសនាមកប្រើប្រាស់
  - ការផ្សះផ្សាវិវាទនៅតាមសហគមន៍ឆ្លុះបញ្ចាំងនូវករុណាធម៌ និងសេចក្ដីអត់ឱនលើទោសទណ្ឌដែលលក្ខណៈធ្ងន់ធ្ងរ។

ជារួម នៅសម័យទំនើបនេះ ពុទ្ធសាសនាមិនផ្ដល់ឱ្យដោយផ្ទាល់នូវច្បាប់ ឬក្រមសម្រាប់ ប្រទេសជាតិទេ ប៉ុន្តែពុទ្ធសាសនាផ្ដល់ឱ្យនូវមូលដ្ឋានវប្បធម៌ និងសីលធម៌នៃការបង្កើតច្បាប់ ដែលលើកស្ទួយសន្តិភាព ការផ្សះផ្សាជាតិ និងសុជីវធម៌មនីយកម្មសង្គម។

### ១.៣.៤.៣ ពុទ្ធសាសនា និងការកសាងសេដ្ឋកិច្ច សង្គម និងវប្បធម៌ខ្មែរ

#### ក. សេដ្ឋកិច្ច

- មូលដ្ឋានសីលធម៌ចំពោះឥរិយាបថសេដ្ឋកិច្ច

ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធដូចជា ភក្ដីភាព ការលះបង់លោភៈ និងគោលការណ៍នៃសម្មាអាជីវៈមានឥទ្ធិពលលើគំនិតរបស់ប្រជាជនទៅលើថាតើគេគួរប្រព្រឹត្តយ៉ាងដូចម្ដេចចំពោះសកម្មភាពសេដ្ឋកិច្ចដូចជា ការជួញដូរ កសិកម្ម និងការធ្វើពាណិជ្ជកម្ម។ សីលធម៌ពុទ្ធសាសនាចូលរួមកាត់បន្ថយការកេងប្រវ័ញ្ច ហើយលើកកម្ពស់ការទុកចិត្តគ្នាក្នុងសកម្មភាពសេដ្ឋកិច្ច។

- សេដ្ឋកិច្ចវត្តអារាម

វត្តអារាមមានតួនាទីជាមជ្ឈមណ្ឌលសេដ្ឋកិច្ចនៅមូលដ្ឋាន។ ការបរិច្ចាគទានរបស់ពុទ្ធបរិស័ទ បានជួយទំនុកបម្រុងព្រះសង្ឃ ហើយជាលទ្ធផលត្រឡប់មកវិញ វត្តអារាមបានផ្ដល់ការអប់រំ ពិធីកម្មនានា និងសេវាសម្រាប់សហគមន៍។

- សីលធម៌ផ្នែកកសិកម្ម

ពិធីបុណ្យ និងពិធីកម្មបែបពុទ្ធសាសនា ជារឿយៗភ្ជាប់ទៅនឹងប្រក្រតិទិនកសិកម្ម ដោយធ្វើឱ្យមានសុខដុមនីយកម្មជាមួយនឹងធម្មជាតិ និងជំរុញឱ្យអនុវត្តកសិកម្មប្រកបដោយចីរភាព។

- កម្មវិធីសប្បុរសធម៌ និងការចែករំលែក

ពិធីបុណ្យនានាបានលើកទឹកចិត្តឱ្យមានការឱ្យទាន ការចែករំលែកទ្រព្យសម្បត្តិពីអ្នកមានទ្រព្យទៅជនក្រីក្រ និងការរក្សាតុល្យភាពសង្គម។

## ខ. សង្គម

- សណ្តាប់ធ្នាប់សង្គមតាមរយៈសីលធម៌

ពុទ្ធសាសនាជាត្រីវិស័យសីលធម៌សម្រាប់សង្គមខ្មែរ ពោលគឺគោលការណ៍ទាំងឡាយដូចជាករុណាធម៌ អហិង្សាធម៌ និងការគោរពចាស់ទុំ ដែលនាំឱ្យសង្គមមានស្ថិរភាព។

- ប្រព័ន្ធអប់រំ

ជាប្រពៃណី វត្តអារាមគឺជាមជ្ឈមណ្ឌលនៃការរៀនសូត្រ ការបង្រៀនអក្សរសាស្ត្រ ភាសាបាលី ភាសាខ្មែរ និងទស្សនវិជ្ជាពុទ្ធសាសនា។ ជាប្រវត្តិសាស្ត្រ ថ្នាក់ដឹកនាំខ្មែរជាច្រើនបានទទួលការអប់រំពីវត្តអារាម។

- ការដោះស្រាយវិវាទ

ជារឿយៗ ព្រះសង្ឃដើរតួនាទីជាសន្ធានការីក្នុងជម្លោះសហគមន៍ ដោយអនុវត្តតាមសីលធម៌ពុទ្ធសាសនាទាក់ទងនឹងសុខដុនីយកម្ម និងការសម្រុះសម្រួល។

- សាមគ្គីភាពសង្គម

ពិធីកម្មរួមគ្នា កម្មវិធីបុណ្យ និងសកម្មភាពបំពេញកុសលនានា ជួយពង្រឹងអត្តសញ្ញាណរួម និងសាមគ្គីភាព ដោយកាត់បន្ថយភាពប្រេះស្រាំក្នុងសង្គម។

## គ. វប្បធម៌

- សិល្បៈ និងស្ថាបត្យកម្ម

វត្តអារាម គំនូរ និងចម្លាក់ខ្មែរ ឆ្លុះបញ្ចាំងនូវលោកធាតុវិទ្យា និងសោភ័ណវិទ្យារបស់ពុទ្ធសាសនា។

- ភាសា និងអក្សរសាស្ត្រ

អត្ថបទពុទ្ធសាសនាមានឥទ្ធិពលលើអក្សរសាស្ត្រខ្មែរ កំណាព្យ និងរឿងនិទានបែបសីលធម៌ (ទសជាតក៍ បញ្ញាសជាតក៍) ។

- ពិធីបុណ្យ និងប្រពៃណី

ពិធីបុណ្យសំខាន់ៗដូចជាភ្ជុំបិណ្ឌ និងបុណ្យចូលឆ្នាំថ្មី បានដាក់បញ្ចូលខ្លឹមសារពុទ្ធសាសនាដោយបង្កើតទៅជាអត្តសញ្ញាណជាតិ។

- តម្លៃ និងគតិលោក

ទស្សនៈពុទ្ធសាសនាស្តីពីអនិច្ចតាធម៌ ទ្រឹស្តីកម្មផល និងការចាប់កំណើតជាថ្មី ជាមគ្គទេសក៍នៃឧត្តមគតិរបស់ជនជាតិខ្មែរចំពោះការរស់នៅ សេចក្តីស្លាប់ និងសីលធម៌ ដែលជះឥទ្ធិពលដល់ឥរិយាបថវប្បធម៌តាមរយៈភាពអត់ធ្មត់ ភាពធន់ និងការចេះទទួលយកការពិត។

### ១.៣.៤.៤ ទំនាក់ទំនងរវាងសីលធម៌ពុទ្ធសាសនា និងច្បាប់សង្គម

| **តើសីលធម៌ពុទ្ធសាសនាមានទំនាក់ទំនងដូចម្តេចខ្លះចំពោះច្បាប់សង្គម**? | | | |
|---|---|---|---|
| **សីល៥** | **កល្យាណធម៌៥** | **ច្បាប់សង្គម** | **សិទ្ធិមនុស្ស** |
| វៀរចាកការសម្លាប់ | មេត្តាករុណា | បទឃាតកម្ម បទហិង្សាដោយចេតនា | សិទ្ធិរស់រានមានជីវិត |
| វៀរចាកការលួច | សម្មាអាជីវៈ | បទលួច, បទឆបោក, បទកេងបន្លំ | សិទ្ធិមានកម្មសិទ្ធិ |
| វៀរចាកប្រព្រឹត្តខុសក្នុងកាម | សទារសន្តោស | ឯកពន្ធភាព | សិទ្ធិការពារមិនអោយគេយកធ្វើជាខ្ញុំកញ្ជះ (ទាសីតណ្ហា) |
| វៀរចាកការនិយាយកុហក | សច្ចៈ | គោលការណ៍សុចរិតនិងភាពស្មោះត្រង់ | សិទ្ធិទទួលពត៌មានពិត ឬសិទ្ធិមានសេចក្តីថ្លៃថ្នូរ សិទ្ធិមានសេរីភាពបញ្ចេញមតិ |
| វៀរចាកការផឹកគ្រឿងស្រវឹង | សតិ | -មិនធ្វេសប្រហែស | សិទ្ធិមានសន្តិសុខ សង្គម និងសន្តិភាពផ្ទាល់ខ្លួន កាតព្វកិច្ចចំពោះសហគមន៍ |

### ១.៣.៤.៥ ពុទ្ធសាសនា និងអត្តសញ្ញាណច្បាប់ខ្មែរ

ពុទ្ធសាសនាពិតជាបានផ្តល់វិភាគទានយ៉ាងច្រើនសន្ធឹកសន្ធាប់ក្នុងគំនិតច្បាប់នៅកម្ពុជា ស្ទើរតែគ្រប់សម័យកាលទាំងអស់៖

**ក. សម័យកាលមុនអាណានិគមបារាំង**

- ប្រពៃណីធម្មរាជា៖ ព្រះមហាក្សត្រត្រូវគេទុកចិត្តថា ទ្រង់គ្រប់គ្រងដឹកនាំប្រទេសប្រកបដោយធម៌ពោលគឺសីលធម៌ពុទ្ធសាសនា។ នេះបង្កើតបានអត្តសញ្ញាណច្បាប់ ដែលមិនមែនជាឧបករណ៍នៃអំណាចទេ ប៉ុន្តែជាកាតព្វកិច្ចសីលធម៌សម្រាប់ជានាយុត្តិធម៌ សេចក្តីករុណា និងភាពសុខដុមរមនា។
- ឥទ្ធិពលនៃបញ្ចសីល (សីល៥)៖ ច្បាប់ប្រឆាំងនឹងការសម្លាប់ ការលួចឆក់ប្លន់ អំពើផិតក្បត់ ការកុហកការបោកប្រាស់ និងភាពប្រមឹកបាត់បង់សតិស្មារតីនាំឱ្យកើតការប្រមាទ ត្រូវបានឆ្លុះបញ្ចាំងនឹងសីលធម៌ពុទ្ធសាសនា។ ច្បាប់សង្គមគឺការឆ្លុះបញ្ចាំងនូវសិក្ខាបទទាំងឡាយនៃពុទ្ធសាសនាដែលធ្វើឱ្យមើលឃើញថា ការបង្កើតច្បាប់គឺជាការបន្តដំណើរនៃសីលធម៌ពុទ្ធសនា។
- ច្បាប់ទំនៀមតាមភូមិ និងតួនាទីរបស់ព្រះសង្ឃ៖ ព្រះសង្ឃបង្រៀនអក្សរសាស្ត្រ សីលធម៌ និងផ្សះផ្សាវិវាទ ដោយធានាថា ច្បាប់ជាធរមានឆ្លុះបញ្ចាំងអំពីតម្លៃពុទ្ធសាសនាស្តីពីការផ្សះផ្សានិងអហិង្សាធម៌។ ច្បាប់ទំនៀម (ព្រះរាជក្រម និងវិធានតាមភូមិ) បានបញ្ចូលគុណធម៌ពុទ្ធសានាដូចជា ករុណាធម៌ និងបុណ្យកុសល។
- សមាហរណកម្មជាមួយវប្បធម៌ខ្មែរ៖ ពិធីកម្មពុទ្ធសាសនាបានផ្សារភ្ជាប់ជាមួយនឹងជីវិតរបស់សហគមន៍ខ្មែរ ការទទួលមរតក អាពាហ៍ពិពាហ៍ ពិធីបុណ្យសព និងកិច្ចសន្យានានា ជារឿយៗបានរួមបញ្ចូលនូវសមាសធាតុពុទ្ធសាសនា។ ដូចនេះ ទោះច្បាប់ជាប្រព័ន្ធដែលដាច់ដោយឡែកពីសាសនាមែន ប៉ុន្តែវាត្រូវគេមើលឃើញថា ជាផ្នែកនៃមូលដ្ឋានសីលធម៌សាសនាក្នុងការកសាងសង្គម។

**ខ. សម័យអាណានិគមបារាំង និងក្រោយអាណានិគម**

- អាណានិគមបារាំងបានរៀបចំក្រមរដ្ឋប្បវេណី ដែលយកគំរូតាមច្បាប់បារាំង។ ប៉ុន្តែពុទ្ធសាសនានៅបន្តមានឥទ្ធិពលលើអត្តសញ្ញាណនៃច្បាប់ទំនៀម ជាពិសេសច្បាប់ស្តីពីគ្រួសារ និងការផ្សះផ្សាវិវាទ។ ជារឿយៗ ប្រជាជនពេញចិត្តដោះស្រាយវិវាទនៅកម្រិតភូមិ ឬវត្តអារាម ដែលចង្អុលបង្ហាញដោយសីលធម៌ពុទ្ធសាសនា ជាងការពឹងផ្អែកលើតុលាការអាណានិគម។
- ក្រោយបានឯករាជ្យ៖ ពុទ្ធសាសនាត្រូវបានអនុម័តថាជាសាសនារបស់រដ្ឋ។ មេដឹកនាំប្រទេសជាតិបានលើកយកសីលធម៌ពុទ្ធសាសនាដើម្បីធម្មានុរូបកម្មនៃច្បាប់ រក្សាអត្តសញ្ញាណច្បាប់ដែលផ្សារភ្ជាប់នឹងសីលធម៌ និងភាពសុខដុមរមនានៃសហគមន៍ មិនមែនគ្រាន់តែបង្កើតក្រមច្បាប់ផ្លូវការប៉ុណ្ណោះទេ។

### គ. សម័យបច្ចុប្បន្ន

- រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣ បានកំណត់យកពុទ្ធសាសនាជាសាសនារបស់រដ្ឋ(មាត្រា៤៣)។ ការដាក់បញ្ចូលពុទ្ធសាសនាបែបនេះគឺជាផ្នែកនៃអត្តសញ្ញាណច្បាប់ទំនើប។
- វប្បធម៌ច្បាប់៖ ទោះបីកម្ពុជាអនុវត្តតាមប្រព័ន្ធច្បាប់ស៊ីវិល ដោយសារឥទ្ធិពលបារាំងក៏ដោយ ការអនុវត្តច្បាប់នៅតែឆ្លុះបញ្ចាំងពីតម្លៃពុទ្ធសាសនា ដូចខាងក្រោម៖
    - ការផ្សះផ្សាមុននីតិវិធីនានានៅតុលាការ ឆ្លុះបញ្ចាំងនូវគំនិតស្តីពីការសម្រុះសម្រួលតាមបែបពុទ្ធសាសនា
    - យុត្តិធម៌ប្រត្យាស្ថាបនា (restorative justice) ក្នុងសហគមន៍ បានផ្សារភ្ជាប់ទៅនឹងករុណាធម៌របស់ពុទ្ធសាសនា។
    - ការគោរពចាស់ទុំ និងអាជ្ញាធរ នៅក្នុងគ្រួសារ និងច្បាប់សង្គមមានឫសចេញពីឋានានុក្រមស្តីពីការគោរពរបស់ពុទ្ធសាសនា។
- សិទ្ធិមនុស្ស និងនីតិរដ្ឋ៖ ទស្សនៈពុទ្ធសាសនាស្តីពីសេចក្តីថ្លៃថ្នូរ ករុណា និងអហិង្សា បានផ្តល់នូវកញ្ចក់សីលធម៌ និងច្បាប់ទំនើបផ្អែកលើសិទ្ធិមនុស្ស ដែលត្រូវបានបកស្រាយ និងទទួលយកក្នុងសង្គមកម្ពុជា។

### ១.៣.៥ ប្រវត្តិច្បាប់ខ្មែរសង្ខេប

យោងតាមប្រវត្តិសាស្ត្រខ្មែរ ប្រទេសកម្ពុជាត្រូវបានគ្រប់គ្រងដោយអង្គព្រះមហាក្សត្រជាសន្តតិវង្សច្រើនជំនាន់ ប្រកបដោយទសពិធរាជធម៌ និងគោរពច្បាប់ ដោយទ្រង់លើកតម្កើងច្បាប់ឱ្យខ្ពង់ខ្ពស់ដាក់លើព្រះសិរសា។ ក្នុងន័យនេះ កម្ពុជាត្រូវបានគ្រប់គ្រងអនុលោមតាមច្បាប់ ឬ គ្រប់គ្រងដោយច្បាប់ (Rule of Law) តាំងពីសម័យបុរាណ រហូតដល់បច្ចុប្បន្ន។ នេះមានន័យថា កម្ពុជាមានប្រវត្តិច្បាប់ជាយូរលង់ ដែលស្របតាមសម័យកាលនីមួយៗ តាមសម័យកាលនៃប្រវត្តិសាស្ត្រកម្ពុជា ជាអាទិ៍ សម័យបុរេប្រវត្តិ សម័យហ្វូណន សម័យចេនឡា សម័យអង្គរ សម័យក្រោយអង្គរ សម័យអាណានិគមបារាំង និងសម័យក្រោយអាណានិគមរហូតដល់បច្ចុប្បន្ន។

#### ១.៣.៥.១ សម័យបុរេប្រវត្តិ

សម័យបុរេប្រវត្តិ សំដៅដល់សម័យកាលនៃការវិវត្ត និងការកកើតមនុស្សលើភាពផែនដី ដោយមានការបែងចែកជាអំបូរមនុស្សប្រមាណ២,៨ មីលានឆ្នាំ រហូតដល់មានការបង្កើត ចន្លោះ៣៣០០ឆ្នាំមុន គ.ស. ដែលត្រូវបានហៅថា យុគថ្ម សម័យបុរេប្រវត្តិនេះ ត្រូវបានបែកចែកជាច្រើនដំណាក់កាល៖ ១) យុគ្គថ្មបំបែក (la Paléolithique) ២) យុគ្គថ្មបំបែកក្លាយ (la Mésolithique) និងយុគ្គថ្មរំលីង (la Néolithique) ។

## ក. យុគ្គថ្មបំបែក (la Paléolithique)

យុគ្គថ្មបំបែក គឺជាសម័យកាលមួយដែលមនុស្សចាប់ផ្តើមយកថ្មគ្រួសធ្វើជាឧបករណ៍សម្រាប់ប្រើប្រាស់បម្រើឱ្យជីវភាពប្រចាំថ្ងៃរបស់ខ្លួន។ យុគ្គថ្មបំបែកដែលមានអាយុថាប់ពី ៦០០.០០០ឆ្នាំ ដល់ ១២០.០០០ឆ្នាំ មុនគ.ស. អាចត្រូវបានចាត់ទុកថាជាដើមសម័យអារ្យធម៌ខ្មែរ ដោយផ្អែកលើសម្ភារប្រើប្រាស់នៅក្នុងសម័យនេះ សម្ភារជាឧបករណ៍ត្រូវបានរកឃើញមាន ពូថៅ ឬពន្លាកជាដើម[៧២] ភាគច្រើនជាគ្រួសដែលគេប្រទះឃើញនៅតាមដងទន្លេ ឬមាត់ទន្លេងផ្សេងៗ។ ការចាប់ផ្តើមបំបែកថ្មធ្វើជាឧបករណ៍មុតស្រួចនេះ ត្រូវបានរកគេសន្មត់ថាកើតឡើងនៅក្នុងពាក់កណ្តាលសម័យទឹកកករលាយ (Pléistocene) គិតចាប់ពី ១០០.០០០ឆ្នាំមុន។ សម័យកាលនេះគឺជាសម័យកាលដែលមនុស្សបរិភោគសាច់ឆៅជាអាហារ ដោយហែកស្បែកសត្វដោយធ្មេញទទេ បេះស្លឹកឈើ ឬគាស់រកមើមឈើតាមព្រៃភ្នំ មិនទាន់ការដាំដំណាំហូបផ្លែ និង/ចិញ្ចឹមសត្វពាហនៈឡើយ។[៧៣] គេពុំទាន់រកឃើញនូវប្រព័ន្ធរដ្ឋបាល ព្រំដែននយោបាយ ឬការបែងចែកជាតិសាសន៍នៅឡើយ។ ការវិវត្ត និងការរីកចម្រើនផ្នែកខាងវប្បធម៌ផ្តើមតាមរយៈការឃើញភ្លើងសម្រាប់ចម្អិនម្ហូបអាហារ។

ដំណាក់កាលទី២ ចាប់ពី១២០.០០០ ដល់១២.០០០ ឆ្នាំមុនគ.ស. មនុស្សចាប់ផ្តើមយកថ្មធម្មជាតិមកបំបែកជាពីរ ឬជាបី ដើម្បីយកមុខស្រួចមកធ្វើជាអាវុធ មនុស្សចាប់ផ្តើមចេះចាំថ្មមកធ្វើជាស្នាប់ដៃមានរូបសំប៉ែត បំបែកថ្មតូចៗ ដូចជាខ្វោសជាដើមសម្រាប់កោសស្បែកសត្វ ឬរចនាគ្រឿងឧបករណ៍ផ្សេងៗ មានដូចជា ពូថៅមានរូបរាងជាត្រីកោណ ចតុកោណ ឬចតុកោណកែង មានលក្ខណៈប្រណិតជាងមុន។ កំណាយបុរាណវិទ្យារកឃើញនូវឧបករណ៍ប្រើប្រាស់ សំណល់ម្ហូបអាហារ ដូចជាឆ្អឹងសត្វជាដើមភ្ជាប់ជាមួយនឹងឆ្អឹងខ្មោច បញ្ជាក់ថា មនុស្សចេះគោរពសព ចេះសែនព្រេនបុព្វបុរសរបស់គេដែលបានចែកឋានទៅ ប៉ុន្តែមនុស្សមិនទាន់ចេះធ្វើសេដ្ឋកិច្ចនៅឡើយទេ[៧៤]។

## ខ. យុគ្គថ្មបំបែកក្លាយ (la Mésolithique)

សម័យកាលនេះចាប់ពី ១២.០០០ ដល់៨.០០០ឆ្នាំមុន គ.ស. ភ័ស្តុតាងតាមរយៈកំណាយនៅតាមគុហាភ្នំ គេឃើញសម្ភារប្រើប្រាស់ធ្វើអំពីថ្មនៅក្នុងស្រទាប់ដី លាយឡំជាមួយគ្រោងឆ្អឹង ដោយសម្ភារប្រើប្រាស់ទាំងនោះមានលក្ខណៈ ស្តើងជាងមុន។ លលាដ៍ក្បាលមនុស្សដែលគេរកឃើញមានលក្ខណៈជាឥណ្ឌូណេស៊ីអែន ខ្មែរ-មន មិនខុសពីខ្មែរលើ ឬខ្មែរសព្វថ្ងៃទេ នេះគឺសន្មត់ថាជាបុព្វបុរសរបស់ជនជាតិខ្មែរសព្វថ្ងៃ។ មនុស្សចាប់ផ្តើមចេះស៊ីគ្រាប់ធុញ្ញជាតិព្រៃ ចាប់ផ្តើមចេះរំលីងថ្ម ឬផ្សាំងសត្វព្រៃ ចាបផ្តើមចេះធ្វើ

---

[៧២] ប្រវត្តិសាស្ត្រប្រទេសកម្ពុជា ពីបុព្វសម័យដល់ស.វ.ទី៨ ដោយបណ្ឌិត មីសែល ត្រាណេ បោះពុម្ពផ្សាយឆ្នាំ១៩៩៦ ទំព័រ២១។

[៧៣] ប្រភពឯកសារដដែល ទំព័រ២២។

[៧៤] ប្រភពឯកសារដដែល ទំព័រ២៤។

សេដ្ឋកិច្ច ដោយជនជាតិខ្មែរដើម ឬខ្មែរ-មន នៅចុងយុគ្គនេះ ចាប់ផ្តើមធ្វើឆ្នាំងចានពីដីដុត ប៉ុន្តែពុំទាន់មានគុណភាពនៅឡើយទេ[75]។

## គ. យុគ្គថ្មរំលីង (la Néolithique)

ចាប់ពីឆ្នាំ ៨.០០០ ដល់ ២.០០០ ឆ្នាំមុនគ.ស. អ្នកបុរេវិទូភាគច្រើចាត់ទុកសម័យនេះជាសម័យបដិវត្តន៍ផ្នែកសេដ្ឋកិច្ច ដោយមនុស្សចាប់ផ្តើមធ្វើសេដ្ឋកិច្ច មានការផ្លាស់ប្តូរផ្នែកសេដ្ឋកិច្ចសង្គម ជាភ័ស្តុតាងមនុស្សចាប់ផ្តើមចេះដាំរុក្ខជាតិ ដូចជាស្រូវ ជាដើម។ សម្រាប់ខ្មែរបុរាណក្នុងសម័យនោះ ចេះធ្វើកសិកម្ម ចិញ្ចឹមសត្វ ចេះបូជាសពដោយកប់ក្នុងផ្នូរនូវគ្រឿងអលង្ការ ឬឧបករណ៍ផ្សេងៗគ្រប់បែបយ៉ាង។ សំណល់បុរាណវិទ្យាបង្ហាញឱ្យឃើញថា ខ្មែរបុរាណចូលធ្វើផ្ទះខ្ពស់ពីដី ហើយរស់នៅផ្តុំជាភូមិស្រុក ខ្លះទៀតក៏បន្តរស់នៅក្នុងរូងភ្នំ ឬខ្ពស់រាប។ មនុស្សចេះត្បាញសំពត់ប៉ឹង ធ្វើគ្រឿងអលង្ការ ដូចជាទងការ ឬក្រសាលធ្វើអំពីក្លុក ខ្យង ឈើ ឆ្អឹង ថ្ម និងដីដុត ជាដើម។ អ្វីដែលគួរឱ្យកត់សម្គាល់គឺបច្ចេកទេសរំលីថ្មដោយខ្មែរបុរាណ ដូចជាពូថៅមានលក្ខណៈរលោង ត្បាល់និងអង្រែ និងរូបសត្វដែលគេបានរកឃើញក្នុងស្ថានីយ៍បុរេ[76]។

មនុស្សចាប់ផ្តើមមានជំនឿដោយគោរពបូជាបុព្វបុរស គោរពទៅលើសត្វដែលខ្លួនយល់ឃើញថាជាសន្តតិវង្សដើម មានដូចជា ទុង កុក ត្រី ត្រកួត ពស់ ប្រើស... ដែលគេឃើញមាននៅក្នុងផ្នូរសព។ នៅក្នុងរាជពង្សាវតារខ្មែរ ជាពិសេសភាគទី១ គេឃើញមានការពណ៌នាពីសត្វត្រកួតនិងកុជង្គនាគ ដែលគេសន្មត់ថាជាជំនឿរបស់មនុស្សខ្មែរបុរាណមុនពេលក្លិង្គចូលស្រុក។

នៅចុងសម័យនេះឧបករណ៍ប្រើប្រាស់ចាប់ផ្តើមធ្វើឡើងពីលោហជាតុ ដែលខ្មែរចាប់ផ្តើមស្គាល់រ៉ែ ហើយមកធ្វើជា កណ្តៀវ លំពែង កងជើង កងដៃ ត្រូវបានរកឃើញធ្វើពីសំរិទ្ធិឬស្ពាន់ គេរកឃើញពណ៌យកមកផាត់លើភាជន៍ដី ដើម្បីឱ្យមានទ្រង់ទ្រាយល្អប្រណិត។

## ឃ. សម័យលោហជាតុ (la Métallurgie)

ចាប់ពីឆ្នាំ២.០០០ ដល់ ១០០ឆ្នាំ មុនគ.ស. ក្នុងសម័យនេះសម្ភារប្រើប្រាស់ភាគច្រើនធ្វើអំពីស្ពាន់ ដែក សំរិទ្ធ ទង់ដែង សំណ និងភក់។ ជាភ័ស្តុតាងគឺការយកដីឥដ្ឋទៅធ្វើជាត្រា ហើយនៅលើមុខត្រាគេឆ្លាក់រូប ឬក្បាច់ក្បូរ ហើយយកទៅប្រថាប់នៅលើសំពត់ជាលំអ។ ឧទាហរណ៍៖ បុរេស្ថានីយ៍សំរោងសែន អន្លង់ផ្តៅ ម្លូព្រៃ ល្អាងព្រៃកឆ្លូង សាហ្វិញ ស្ទឹងឡុក កោះអណ្តើក និងអូកែវ ជាដើម។ សម័យនេះ គេអាចធ្វើការប្រៀបធៀបជាមួយនឹងជីវភាពរបស់ប្រជាជនខ្មែរនៅតាមទីជនបទ នាពេលបច្ចុប្បន្ន ដែលពុំមានវប្បធម៌អឺរ៉ុបហូរចូល[77]។

## ង. ច្បាប់ និងប្រព័ន្ធរដ្ឋបាលខ្មែរនៅសម័យបុរេប្រវត្តិ

[75] ប្រវត្តិសាស្ត្រប្រទេសកម្ពុជា ពីបុព្វសម័យដល់ស.វ.ទី៨ ដោយបណ្ឌិត មីសែល ត្រាណេ បោះពុម្ពផ្សាយឆ្នាំ១៩៩៦ ទំព័រ២៥។

[76] ប្រភពឯកសារដដែល ទំព័រ២៦។

[77] ប្រវត្តិសាស្ត្រប្រទេសកម្ពុជា ពីបុព្វសម័យដល់ស.វ.ទី៨ ដោយបណ្ឌិត មីសែល ត្រាណេ បោះពុម្ពផ្សាយឆ្នាំ១៩៩៦ ទំព័រ២៧។

ខ្មែរមានការចេះដឹង មានវប្បធម៌និងអរិយធម៌តាំងពីមុនពេលដែលក្លឹង្គចូល វប្បធម៌ អរិយធម៌ និងប្រព័ន្ធរដ្ឋបាលទាំងនោះត្រូវបានរកឃើញប្រទេសកម្ពុជា និងអតីតទឹកដីខ្មែរនាពេលបច្ចុប្បន្ន មានដូចខាងក្រោមៈ

- ចេះប្រើឧបករណ៍ គ្រឿងអលង្ការធ្វើអំពីថ្ម
- ចេះរំលីងថ្ម ដើម្បីធ្វើពូថៅ ពន្លាក ញញួរ
- ចេះឆ្លាក់ធ្វើពុម្ពថ្មសម្រាប់ធ្វើកងដៃ កងជើង និងក្រវិលត្រចៀកសំរិទ្ធិ
- ចេះប្រើឆ្អឹងសត្វសម្រាប់ធ្វើគ្រឿងអលង្កា ផ្លែសន្ទូច ចុងព្រួញ
- ចេះសូនដីធ្វើលិង្គរូបបុព្វបុរសសម្រាប់បូជា
- ចេះត្បាញកញ្ជើ កន្ត្រក ឈ្នាង នឹងឬស្សី វល្លិ៍ ផ្តៅ
- ចេះប្រើសំបកខ្យងធ្វើអង្កាំ ទំហូ ការត្រចៀក ផ្លែសន្ទូច និងចិញ្ចៀនដៃ
- ចេះប្រើដីដុតសម្រាប់ធ្វើផ្ទាំង ចាន ក្អម ចានទាប ចានមានជើង ចានក្រឡូម រូបសត្វ ត្បាល់ ក្រសាលត្រចៀក ត្រា។ល។
- ចេះផាត់ពណ៌ឆ្នាំ និងក្រឡធ្វើអំពីដីដុត ជាសញ្ញានិមិត្តរូបនៃឈាម ឬជីវិត
- ចេះស្លលង្ហិន សំរិទ្ធ ដែក សម្រាប់ធ្វើកណ្តៀវ ពន្លាក ពូថៅ ខ្សែករ កងដៃ កងជើង ដួង ផ្លែសន្ទូច ចុងព្រួញ
- ចេះបង្កើតរបាំប្រជាប្រិយ៍ ដូចជា របាំត្រុដ របាំកន្សោង ជាដើម សម្រាប់រាំថ្វាយដូនតា ថែរក្សាភូមិស្រុក
- ចេះបង្កើតភូមិស្រុក ដោយបានសង់ផ្ទះខ្ពស់ពីដី សម្រាប់ការពារនិងសត្វ សាហាវ ឬទឹកជំនន់
- ចេះធ្វើស្រែនិងទឹកជំនន់ ចេះប្រើ គោ ក្របីជាយានជំនិះ ឬសម្រាប់ ភ្ជួរស្រែ ចេះធ្វើគ្រឿងភ្លេង និងប្រើទូក
- ចេះប្រើផ្សូង ធ្វើប្រហុក ទឹកត្រី ស្រា ទឹកត្នោត ជូរ
- ចេះផ្សាំងសត្វព្រៃឱ្យក្លាយទៅជាសត្វស្រុក ដូចជា ដំរី គោ ក្របី ឆ្កែ មាន់។ល។
- ចេះបូជាសព នៅក្រោមផ្ទាំងថ្មធំៗ ក្នុងក្ពាមឈូស ឬក្នុងក្រឡធ្វើអំពីដីដុត។ល។

ខ្មែរយើងមានជំនឿតាំងពីមុនពេលក្លឹង្គចូលម្ល៉េះ ដោយជឿទៅលើអារក្ស អ្នកតា ខ្មោចដូនតជំនឿនេះនាំឱ្យមានការរាប់រកគ្នាយ៉ាងស្មោះត្រង់នៅតាមភូមិស្រុក មានសាមគ្គីភាពគ្នា មានភាពស្និទស្នាលនៅក្នុងសង្គម នាំឱ្យមនុស្សស្គាល់បុណ្យ ស្គាល់បាប ស្គាល់សេចក្តីល្អ អាក្រក់។

ទំនៀមទម្លាប់ គឺការចូលចិត្ត ការនិយមនូវរបស់អ្វីមួយ ហើយរបស់នោះត្រូវបានផ្តិតជាប់ទៅនឹងជីវភាពរបស់មនុស្ស ជាពិសេសជំនឿ ខ្មោច អារក្ស អ្នកតា ឬជំនឿលើធម្មជាតិ។ ឧទាហរណ៍ៈ កាលណាគេឃើញផ្កាយដុះកន្ទុយគេសន្និដ្ឋានថាស្រុកពិតជាកើតកោលាហលពុំខាន ដូចជាមានសង្គ្រាម ឬទឹកជំនន់។

បើទោះបីជាមិនមានអក្សរសម្រាប់ធ្វើការកត់ត្រាក្បួនខ្នាតក៏ដោយ នៅក្នុងសម័យបុរេប្រវត្តិ តែភ័ស្តុតាងនៃការកប់សម្ភារប្រើប្រាស់ ម្ហូបអាហារក្នុងផ្នូរបង្ហាញថាខ្មែរបុរាណមានសីលធម៌ក្នុងទម្លាប់គោរពអ្នក

ស្លាប់ ដែលអាចសន្និដ្ឋានបានថា ជាការដឹងខុស ដឹងត្រូវ ដឹងគុណ ដឹងទោស ដឹងបុណ្យ ដឹងបាប ដោយគេជឿថាអ្នកស្លាប់នឹងបានទទួលសម្ភារ អាហារទាំងនោះសម្រាប់ប្រើប្រាស់នៅបរលោក[78]។

ទស្សនវិជ្ជារបស់មនុស្សនាសម័យបុរេ ក៏ជាកត្តាជះឥទ្ធិពលដល់ការរស់នៅរបស់មនុស្ស និងសកម្មភាពរបស់មនុស្សនៅក្នុងសង្គមដែរ ទាក់ទងទៅនឹងការត្រិះរិះពិចារណារបស់មនុស្ស។ ទស្សនវិជ្ជារបស់មនុស្សនាសម័យនោះគឺការព្យាយាមពន្យល់មនុស្សអំពីកំណើតរបស់សត្វលោកឬមនុស្សតាមទស្សនៈរបស់ខ្លួន ភាគច្រើនទាក់ទងនឹងទេវកថានៅក្នុងរឿងព្រេងជាដើម។ ឧទាហរណ៍៖ កាលដែលបុព្វបុរសយើងកប់ខ្មោចឱ្យអង្គុយចោងហោងក្នុងក្រឡ បញ្ជាក់ថា មនុស្សដែលស្លាប់ទៅ អាចចាត់ទុកថាជាទារកនៅក្នុងផ្ទៃម្ដាយមុននឹងកើត។ បើគេយកខ្មោចទៅកប់ក្នុងដី ដូចទារនៅក្នុងផ្ទៃម្ដាយ គេជឿថាជីវិតមិនសាបសូន្យក្រោយពេលស្លាប់ឡើយ ដោយព្រលឹងត្រូវចាប់ជាតិឡើងវិញ[79]។

ព្រះពុទ្ធសាសនាមហាយានត្រូវបានគេសន្និដ្ឋានថា ត្រូវបានខ្មែរបុរាណគោរពប្រតិបត្តិតាំងពីសម័យមុនពេលក្លឹង្គចូលទៅទៀត ដោយហេតុថាក្រោយព្រះពុទ្ធបរិនិព្វានទៅប្រមាណ ២១៨ឆ្នាំ ព្រះរាជាមួយអង្គព្រះនាមព្រះបាទធម្មាសោកមហារាជ គ្រងរាជនៅក្នុងរាជធានីបាតលិបុត្តនៃមគធរដ្ឋ បានចាត់ឱ្យមានការផ្សព្វផ្សាយព្រះពុទ្ធសាសនាទៅកាន់បច្ចន្តប្បទេសនានាក្រៅពីដែនដីមជ្ឈិមប្រទេស និងបានឧបត្ថម្ភឱ្យមានការធ្វើតតិយសង្គាយនា នៅព.ស.២៣៤ ដោយទ្រង់ហៅថា «*បើកនាំងសកលលោកហើយបំភ្លឺឱ្យប្រជានិករបានស្គាល់ពុទ្ធសាសនាតាំងពីសម័យកាលនោះមក*»។ នៅក្នុងសម័យកាលនោះមានព្រះសោណត្ថេរ និងព្រះឧត្តរត្ថេរ បាននិមន្តមកកាន់ដែនដីសុវណ្ណភូមិ គេមិនអាចកំណត់ថានៅចន្លោះចិន និងឥណ្ឌាកន្លែងណាជាដែនដីសុវណ្ណភូមិណាស់ ដោយហេតុថាប្រទេសនីមួយៗនៅក្នុងតំបន់អាស៊ីអាគ្នេយ៍សុទ្ធតែចាត់ទុកព្រះថេរៈទាំងពីរអង្គ ជាប្រពៃណីបុរាណរបស់ប្រទេសរៀងៗខ្លួន [80] ។ នៅត្រង់ចំណុចនេះយើងអាចសន្និដ្ឋានបានថា ព្រះពុទ្ធសាសនាមហាយានគឺត្រូវបានខ្មែរបុរាណគោរពប្រតិបត្តិ។

នៅក្នុងសម័យបុរេប្រវត្តិយើងមិនមានការបង្កើតអក្សរធ្វើការកត់ត្រា ទៅលើព្រឹត្តិការណ៍ សកម្មភាពរស់ប្រចាំថ្ងៃ ច្បាប់ ទម្លាប់របស់មនុស្សនៅក្នុងសម័យនោះឡើយ ហេតុនេះការស្វែងយល់អំពីច្បាប់ប្រពៃណីរបស់មនុស្សនៅក្នុងសម័យនោះធ្វើឡើងតាមរយៈការសិក្សាស្វែងយល់ទៅលើបុរាណវិទ្យា នៅតាមស្ថានីយ៍បុរេប្រវត្តិ និងការសិក្សាអំពីនរវិទ្យាតែប៉ុណ្ណោះ។ ការសិក្សាទៅលើចំណុចទាំងនេះ អាចឱ្យយើងស្វែងយល់អំពីរបៀបរបបក្នុងការរស់នៅ ប្រព័ន្ធរដ្ឋបាល និងការគ្រប់គ្រងរដ្ឋបាលរបស់មនុស្សនៅសម័យបុរេ។ យោងតាមសាស្ត្រាចារ្យបណ្ឌិត Louis Assier-Andrieu បណ្ឌិតផ្នែកនរវិទ្យាពីសាលាសិក្សាធិការជាន់ខ្ពស់ វិទ្យាសាស្ត្រសង្គមទីក្រុងប៉ារីសឆ្នាំ១៩៨០ និងជាបណ្ឌិតច្បាប់ពីសាកលវិទ្យា Toulouse 1 Capitole ឆ្នាំ១៩៨៥ បានលើកឡើងថា «*បាតុភូតគតិយុត្ត និងទីកន្លែងដែលជាមជ្ឈដ្ឋាននៃសង្គមមនុស្សត្រូវបានបង្ហាញតាមរយៈន*

---

៧៨ ប្រវត្តិសាស្ត្រប្រទេសកម្ពុជា ពីបុព្វសម័យដល់ស.វ.ទី៨ ដោយបណ្ឌិត មីសែល ត្រាណេ បោះពុម្ពផ្សាយឆ្នាំ១៩៩៦ ទំព័រ១៣។

៧៩ ប្រភពឯកសារដដែល ទំព័រ១៤។

៨០ សៀវភៅចក្ខុវិស័យព្រះពុទ្ធសាសនា រៀបរៀងដោយ សាមណេរ អគ្គសិរីវិមលញ្ញណ លី ប៊ុនលីន ឆ្នាំ២០១២ ទំព័រទី៩។

*វិទ្យា*»[81]។ នីតិគឺជាសញ្ញាណមានលក្ខណៈជាសកល ហេតុជាតុផ្សំរបស់នីតិមានភាពចម្រុះអាស្រ័យទៅលើវប្បធម៌ មជ្ឈដ្ឋានសង្គម និងសម័យកាលរស់នៅរបស់មនុស្ស។ នីតិគឺជាផ្នែកមួយនៃជីវភាពរបស់នៅរបស់មនុស្ស ជាផ្នែកមួយនៃសេដ្ឋកិច្ចសង្គម «*ការរស់នៅរបស់មនុស្សនៅក្នុងសង្គមត្រូវផ្សារភ្ជាប់ទៅនឹងច្បាប់*»។ ច្បាប់គឺជាមូលដ្ឋានគ្រឹះសម្រាប់ដឹកនាំសង្គម សម្រាប់សង្គមខ្មែរនាសម័យបុរេប្រវត្តិគឺផ្អែកទៅលើភាសា និងវប្បធម៌[82]។ ការគ្រប់គ្រង រដ្ឋបាលរបស់ខ្មែរ វប្បធម៌ និងប្រព័ន្ធច្បាប់របស់ខ្មែរបុរាណត្រូវបានអនុវត្តលាយឡំគ្នាតាមប្រព័ន្ធរបស់ឥណ្ឌានៅពេលក្លឹង្គចូលស្រុកនៅដើមស.វ.ទី១ នៃគ.ស.[83]។ វប្បធម៌របស់ប្រជាជាតិអាស៊ីអាគ្នេយ៍ទទួលឥទ្ធិពលពីវប្បធម៌ធំៗពីរ គឺៈ វប្បធម៌ចិន និងវប្បធម៌ឥណ្ឌា ជាក់ស្តែងការគ្រប់គ្រងរដ្ឋ និងប្រព័ន្ធរដ្ឋបាលរបស់ខ្មែរនាសម័យបុរេប្រវត្តិ សម័យត្រៀមអង្គរ ការគ្រប់គ្រងរដ្ឋបាលរបស់រដ្ឋត្រូវបានធ្វើតាមការគ្រប់គ្រងបែបស្តេចចក្រពត្តិ ដែលជាការគ្រប់គ្រងបែបឥណ្ឌា ផ្សំជាមួយនឹងវប្បធម៌ និងអរិយធម៌គ្រឹះរបស់ខ្មែរ ដែលនៅក្នុងនោះវប្បធម៌ឥណ្ឌាបានហូលចូលមកដែនដីសុវណ្ណភូមិ មុនការចូលមកដល់នៃវប្បធម៌ចិននៅក្នុងសម័យហ្វូណន[84]។

ការគ្រប់គ្រងរដ្ឋ និងច្បាប់ទម្លាប់នៅសម័យនោះការគោរពប្រតិបត្តិទៅលើច្បាប់ប្រពៃណី (customary) មូលដ្ឋានគ្រឹះនៃការគ្រប់គ្រងរដ្ឋនៅក្នុងសម័យហ្វូណន និងនៅក្នុងសម័យចេនឡា ដែលជាសម័យកាលត្រៀមអង្គរ ត្រូវបានគេប្រើប្រាស់ជាមូលដ្ឋានគ្រឹះក្នុងការសន្មត់ទៅលើប្រព័ន្ធនៃការគ្រប់គ្រងរដ្ឋ និងច្បាប់ទម្លាប់រស់នៅរបស់មនុស្សខ្មែរនាសម័យបុរេប្រវត្តិ។ នៅក្នុងនោះគេបានសិក្សាទៅលើការរីកសាយភាយនៃវប្បធម៌ឥណ្ឌាទៅក្នុងឧបទ្វីបឥណ្ឌូចិន ជាពិសេស ទៅក្រុមអំបូរមនុស្សអូស្ត្រូអាស៊ីដែលរស់នៅក្នុងឧបទ្វីបឥណ្ឌូចិន ដែលការណ៍នេះបានចាប់ផ្តើមរីកសាយភាយនៅក្នុងសម័យយុគ្គថ្មរំលីង ដោយប្រព័ន្ធរដ្ឋបាលនោះមេនិយម ពោលគឺស្ត្រីជាធំ (matriarchate) ព្រមទាំងមានការគោរពទៅលើសត្វដែលគេជឿថាជាបុព្វបុរសរបស់មនុស្ស (Totemic beliefs) ដែលជាសម័យកាលនៃ Pre-Aryan India[85]។

អរិយធម៌ Aryan ត្រូវបានរីកសាយភាយទៅលើឧបទ្វីបឥណ្ឌូចិន តាមរយៈវប្បធម៌នៃការដាំដុះ ធ្វើស្រែ ចម្ការ ការចិញ្ចឹមសត្វ និងការប្រើប្រាស់គោក្របី ចាប់ផ្តើមចេះប្រើប្រាស់លោហៈធាតុ ចំណេះដឹងប្រើប្រាស់ត្រីវិស័យ ដោយមានជំនឿសាសនាគោរពទៅលើព្រះ មានទឹក ដី ភ្លើង ខ្យល់[86]។

---

[៨១] Les Droit dans la société humaine, Louis Assier-Andrieu, in ១៩៩៧, P.៤៦១.

[៨២] Thèse Doctorat "Culturalisme et historiographie du Cambodge ancien : a propos de la hiérarchisation des sources de l'histoire Khmère ", Éric Bourdonneau, le ៣ Avril, ២០២០, P.៤១.

[៨៣] *Idem*, P. ៤១

[៨៤] Idem, P.៤៣

[៨៥] The Indianized States of Soudest-Asia,៣rd Edition G. Coedes, edited by Walter F. Vella Translated by Susan Brown Cowing in ១៩៦៣, P.៨

[៨៦] *Idem,* P.៩

សរុបមក នៅក្នុងសម័យបុរេប្រវត្តិ ខ្មែរយើងរស់នៅជាសហគមន៍មានការបែងចែកជាភូមិ ស្រុក មាន ប្រព័ន្ធរដ្ឋបាល និងច្បាប់ផ្ទាល់ខ្លួនមុនពេលក្លឹង្គចូល នៅដើមស.វ.ទី១ នៃគ.ស. បើទោះបីជាពុំទាន់មានអក្សរ កត់ត្រា ប៉ុន្តែច្បាប់ប្រពៃណីទាំងនេះ គឺជាមូលដ្ឋាននាំឱ្យមានការបង្កើតអាណាចក្រហ្វូណន នៅដើមស.វ.ទី ១ នៃគ.ស.។

### ១.៣.៥.២ សម័យហ្វូណន (ពីសតវត្សទី១ ដល់ទី៦នៃ គ.ស.)

ហ្វូណនមានទំនាក់ទំនងច្រើនជាមួយឥណ្ឌា។ នៅពេលមកប្រកបរបរជំនួញនៅហ្វូណន ជនជាតិ ឥណ្ឌាក៏បាននាំយកមកជាមួយនូវសាសនារបស់គេ គឺលទ្ធិហិណ្ឌូ និងព្រះពុទ្ធសាសនា និងភាសាសំស្ក្រឹត ព្រមច្បាប់ទាំងឡាយដែលគេប្រើនៅប្រទេសឥណ្ឌា។ ឥណ្ឌាក៏មានឥទ្ធិពលផងដែរផ្នែកនយោបាយ និង សេដ្ឋកិច្ចទៅលើអាណាចក្រហ្វូណនទាំងមូល។ អាណាចក្រហ្វូណនកើតពីនគរតូចៗជាច្រើន។ នគរខ្លះក៏ មានឯករាជ្យត្រឹមត្រូវ នគរខ្លះទៀតក៏ស្ថិតនៅជាចំណុះគេ។ ព្រះរាជាតែងបញ្ជូនមន្ត្រីរបស់ព្រះអង្គទៅ ត្រួតត្រាតាមខេត្ត តាមបុរី ផ្សេងៗ។ មន្ត្រីទាំងនោះមានភារៈជាអ្នកទទួលពាក្យបណ្តឹងរបស់ប្រជារាស្ត្រ ដែលប្តឹងអំពីការធ្វើបាបពីសំណាក់អ្នកគ្រប់គ្រងនៅទីនោះមកលើខ្លួន។ នៅពេលមានព្រះរាជសវនាការជា សាធារណៈ ព្រះរាជាគឺជាចៅក្រម ដែលធ្វើការសម្រេចបិទផ្លូវតវ៉ា។ នៅហ្វូណនមានទោសតែពីរប្រភេទ ប៉ុណ្ណោះ។ បើទោសស្រាលគឺគេដាក់ទណ្ឌកម្មធម្មតា រីឯទោសធ្ងន់គឺគេចាប់ជនជាប់ចោទគ្រវែងទៅឱ្យសត្វ សាហាវស៊ី ដើម្បីបង្ហាញពីពិរុទ្ធភាពរបស់គេ។ ប្រសិនបើក្នុងរយៈពេល៣ថ្ងៃ សត្វមិនស៊ីជននោះទេ ជន នោះនឹងត្រូវបានដោះលែងនិងប្រកាសថាគ្មានទោស។ លទ្ធិទេវរាជ ទំនាក់ទំនងជាមួយជនជាតិឥណ្ឌានៅ មានបន្សល់ទុកនូវផលវិបាកផ្សេងៗទៀត។ នៅសម័យហ្វូណនស្រីៗត្រូវទៅចូលដណ្តឹងប្រុសៗដើម្បីឱ្យ ដូចទៅនឹងអ្វីដែលក្សត្រីយ៍ហ្វូណនបានធ្វើ។ នេះជាប្រពៃណីមួយនៅក្នុងចំណោមបណ្តាច្បាប់ដែលគេស្គា ល់។ តាមពិតពុំមានវិធានច្បាប់ណាកំណត់ជាក់លាក់នៅហ្វូណននោះទេ វាគ្រាន់តែជាទម្លាប់មួយ និងជា សីលធម៌តាមបែបសាសនាមួយដែលត្រូវបានប្រជារាស្ត្រប្រកាន់យកក្នុងជីវភាពប្រចាំថ្ងៃ។[៨៧]

### ១.៣.៥.៣ សម័យចេនឡា (សតវត្សទី៦ ដល់ទី៩ នៃគ.ស.)

ការរៀបចំសង្គមដែលបន្សល់ទុកពី ហ្វូណនត្រូវបានរក្សាទុក។ អាណាចក្រចេនឡាត្រូវបានចែក ជា៣០ បុរី ហើយបុរីនីមួយៗស្ថិតនៅក្រោមការគ្រប់គ្រងរបស់អភិបាលម្នាក់។ មន្ត្រីរាជវាំងជាច្រើនត្រូវបាន បញ្ជូនទៅតាមបុរីទាំងនោះ ដើម្បីធ្វើការត្រួតពិនិត្យ និងដាក់ទណ្ឌកម្មចំពោះការបំពាននានា។ នៅសម័យ ចេនឡាបុរសជាអ្នកចូលដណ្តឹងស្រី គឺមិនដូចសម័យហ្វូណនទេ។ នៅពេលរៀបអាពាហ៍ពិពាហ៍ កូនក ម្លោះតែងទទួលនូវមរតកពីឪពុកម្តាយរបស់ខ្លួនដើម្បីរកផ្ទះនៅផ្សេង។ ប្រសិនបើឪពុកម្តាយអនិច្ចកម្មមុន

---

[៨៧] សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, *សេចក្តីផ្តើមនៃនីតិកម្ពុជា*, ទំព័រ ៣-២០។

ថ្ងៃអាពាហ៍ពិពាហ៍របស់កូន មរតកត្រូវបានមកកូនទាំងអស់។ បើកូនប្រុសរៀបការមុនមរណភាពឪពុកម្តាយ មរតកដែលនៅសល់នឹងក្លាយទៅជាទ្រព្យសម្បត្តិរបស់រដ្ឋ។

### ១.៣.៥.៤ សម័យអង្គរ (សតវត្សទី៩ ដល់ទី ១៥ នៃគ.ស.)

អត្ថបទឥណ្ឌាពីបុរាណ បានជះឥទ្ធិពលយ៉ាងខ្លាំងក្លាចំពោះសម័យអង្គរ។ នៅក្នុងទស្សនៈឥណ្ឌា ច្បាប់គឺជាពាក្យសម្រាប់សម្គាល់សំណុំវិធានទាំងឡាយ ដែលកំណត់ដោយអាជ្ញាបញ្ញានូវទំនាក់ទំនងរវាងបុគ្គល និងបុគ្គល ហើយការគោរពវិធានទាំងនេះតម្រូវឱ្យបុគ្គលទទួលការបង្ខំខាងក្រៅ ឬលើរូបរាងកាយ។ ច្បាប់នៅសម័យនោះ គឺជាលទ្ធផលនៃការបញ្ចូលគ្នានូវវិធានបីយ៉ាង ដែលមានកម្លាំងបង្ខិតបង្ខំពិសេសដោយឡែកខុសៗគ្នាគឺធម៌ ទម្លាប់ និងព្រះរាជបញ្ញា។ ច្បាប់ទាំងអស់ត្រូវបានចងក្រងជាអត្ថបទ ដូចជាគម្ពីរធម្មសាស្រ្ត (Dharmasastras) ដោយសរសេរជាពាក្យកាព្យ ដែលក្នុងនោះមានការរៀបរាប់ពីបញ្ញាច្បាប់ជាច្រើន។ ស្នាដៃដែលល្បីល្បាញបំផុត គឺក្រមម៉ានូ (Manu ឬ Manavadharmasastra ឬ Manusmrti)[៨៨]។ ច្បាប់ Manu ភាគច្រើនកើតពីទំនៀមទម្លាប់របស់ពួកព្រាហ្មណ៍ដែលរស់នៅក្នុងតំបន់មួយភាគខាងជើងប្រទេសឥណ្ឌា និងខ្លះទៀត គឺជាវិធានរបស់ព្រះពុទ្ធសាសនា។ គោលបំណងនៃកម្រងវិធាននេះ ជាពិសេសក្រម Manu គឺសម្រាប់គ្រប់គ្រងទំនាក់ទំនងរវាងបុគ្គល និងបុគ្គល និងស្នើនូវដំណោះស្រាយមួយចំនួនចំពោះជម្លោះរវាងបុគ្គល និងបុគ្គល។ ក្រម Manu បានធ្វើចំណាត់ថ្នាក់យ៉ាងមានរបៀបនូវប្រភេទរឿងក្តីដែលអាចដាក់ថ្វាយព្រះរាជាសម្រាប់ព្រះអង្គសម្រេចក្តី។ ក្រមនេះក៏មានចែងពីគោលការណ៍មួយចំនួន ដែលទាក់ទងទៅនឹងកិច្ចការ និងវិធានផ្សេងៗសម្រាប់ព្រះមហាក្សត្រសម្រាប់រដ្ឋបាល និងសម្រាប់យុត្តាធិការ។ នៅពេលដែលជាតិមួយទទួលឥទ្ធិពលពីឥណ្ឌា ហើយប្រកាន់យកវិធាននៃគម្ពីរធម្មសាស្រ្ត (Dharmasastras) មកអនុវត្តនោះ វិធានទាំងអស់ខាងលើ នឹងមកត្រួតគ្នាជាមួយទំនៀមទម្លាប់ផ្ទាល់របស់ជាតិនោះមែន តែមិនប្រឆាំងគ្នាឡើយ[៨៩]។ ការដោះស្រាយវិវាទទៅតាមទំនៀមទម្លាប់ដូនតានៅតែអាចបន្តធ្វើបាន ហើយវិធាននៅក្នុងគម្ពីរធម្មសាស្រ្តក៏មិនជំទាស់ ឬបន្ទោសអ្វីដែរ[៩០] ។ ធម្មប្បញ្ញត្តិទាំងនោះនឹងក្លាយទៅជាវិធានច្បាប់ គឺនៅពេលដែលសេចក្តីរបស់វាត្រូវបានមនុស្សម្នាទទួលស្គាល់

---

[៨៨] ភាគខាងដើមនៃក្រម Manu មានពន្យល់ថា ក្រមនេះមានប្រវត្តិចេញពីការបង្រៀនរបស់ទេវៈកំពូលមួយអង្គទៅដល់ Manu ដែលកើតចេញពីព្រះព្រហ្ម។ ការបង្រៀននេះត្រូវ Manu បង្រៀនទៅឱ្យបណ្ឌិតម្នាក់ហៅថា Bhrgu ។ Manu បានស្នើឱ្យ Bhrgu បញ្ជូនចំណេះដឹងនេះទៅដល់បណ្ឌិត ៩ នាក់ទៀត។ អត្ថបទដែលសូត្រដោយ Bhrgu ដែលត្រូវបានចងក្រងជាក្រមសម្រាប់មនុស្សលោក ហៅថា Manu នេះឯង។

[៨៩] Louis Frederic "ជីវភាពប្រចាំថ្ងៃនៅឧបទ្វីបឥណ្ឌូចិននាសម័យអង្គរ ៨០០-១៣០០" Hachette ១៩៨១ ទំព័រ ៨៩ ។

[៩០] Manu ចែងថា អ្នកដែលគោរពតាមទម្លាប់ដូនតារបស់ខ្លួន វាមិនចង្រៃនោះទេ។ Manu ថែមទាំងបានស្នើឱ្យព្រះរាជាស្វែងយល់អំពីទំនៀមទម្លាប់នៃវណ្ណៈផ្សេងៗរបស់ប្រទេស របស់សាជីវកម្ម ឬរបស់គ្រួសារ ហើយនិងកំណត់អំពីកាតព្វកិច្ចសម្រាប់មនុស្សម្នាក់ៗទៅតាមទំនៀមទម្លាប់នោះទៀតផង។

និងយកទៅអនុវត្ត។ ក្នុងករណីមានជម្លោះរវាងវិធាន និងវិធាន វិធានដែលចេញមកពីគម្ពីរធម្មសាស្ត្រា នឹងមិនត្រូវបានគេយកមកអនុវត្តទេ ហើយវិធានតាមទម្លាប់ត្រូវយកប្រើជំនួសវិញ។[៩១]

ច្បាប់ និងបទប្បញ្ញត្តិទាំងឡាយ ត្រូវធ្វើការប្រកាសផ្សាយជាធារណៈ តាមរយៈមធ្យោបាយជាច្រើនដូចជា ការដើរប្រកូកប្រកាសដោយមន្ត្រីសាធារណៈ ការចារលើផ្ទាំងសិលា ការដាក់តាំងផ្សាយនៅតាមច្រកទ្វារចូលប្រាសាទ ក្លោងទ្វារចូលព្រះរាជវាំង ឬទីកន្លែងសក្ការៈបូជាជាដើម។ វិធានទាំងនេះត្រូវបានចារឹកនៅលើស្បែកសត្វ ដូចជា ក្តាន់ រមាំង រួចហើយគេលាបវានឹងខ្មុកម្រ័ក្សឱ្យខ្មៅ។ ដោយឡែកវិធានពិសេស ត្រូវបានចារឹកនៅលើបន្ទះមាស ប្រាក់ ឬទង់ដែង ហើយត្រូវបានរក្សាទុកក្នុងអគារពិសេស ឬក្នុងបណ្ណាល័យ ដែលសាងសង់នៅក្នុងបរិវេណប្រាសាទធំៗ ឬក្នុងព្រះបរមរាជវាំង។[៩២]

### ១.៣.៥.៥ សម័យក្រោយអង្គរ (១៤៦៣ ដល់ ១៨៦៣ នៃគ.ស.)

គេដឹងថា "ក្រមខ្មែរ" ត្រូវបានរៀបរៀងក្នុងរជ្ជកាលព្រះបាទជ័យជេដ្ឋា។ ព្រះអង្គបានសម្រេចព្រះទ័យតាក់តែងជាក្រមនេះ នៅគ.ស. ១៦២០ ដោយព្រះអង្គសង្កេតឃើញមានការបំពាននិងភាពអយុត្តិធម៌ជាច្រើនក្នុងជួរតុលាការ។ មួយឆ្នាំមុនពេលព្រះអង្គសោយទីវង្គត ក្រមចំនួន២៤ ត្រូវបានគេធ្វើបច្ចុប្បន្នភាពរួចរាល់[៩៣]។ ព្រះមហាក្សត្រក្រោយៗមកទៀត ដែលបានចូលរួមកែសម្រួលក្រមទាំងនោះមាន ព្រះបាទជ័យជេដ្ឋាទី២ (១៦១៨-១៦២៥) ព្រះបាទអង្គសូរជ័យជេស្ឋា (១៦៧៥-១៧០៦) និងព្រះបាទអង្គដួង (១៨៤៧-១៨៦០)។ ច្បាប់ខ្លះ ត្រូវបានកែសម្រួលពីពីរទៅបីដងគិតចាប់ពីសតវត្សទី១៧ មក។ នៅពេលដែលព្រះអង្គឡើងគ្រងរាជសម្បត្តិនៅថ្ងៃទី៧ ខែមីនា គ.ស. ១៨៤៨ ព្រះអង្គបានចាប់ផ្តើមការងារដោយមិនបង្អង់ ដោយព្រះអង្គឆ្លៀតពេលដែលស្រុកមានសន្តិភាពដើម្បីកសាងប្រទេសឡើងវិញលើគ្រប់ វិស័យ។ ចាប់ពីឆ្នាំ១៨៥៣ ទៅ ព្រះអង្គសម្រេចបញ្ជាឱ្យគេសើរើ ក្រមទាំងអស់ឡើងវិញដោយព្រះអង្គចូលរួមក្នុងកិច្ចការនេះដោយផ្ទាល់ ដោយបន្តធ្វើរហូតដល់ព្រះអង្គសោយទីវង្គតនៅឆ្នាំ ១៨៦០ ។[៩៤]

### ១.៣.៥.៦ សម័យអាណានិគមបារាំង (១៨៦៣-១៩៥៣)

ក្រមទាំងអស់មានចំនួន៥២ ក្រម ក្នុងនោះមានក្រម៣៩ ត្រូវបានផ្សព្វផ្សាយក្នុងរជ្ជកាលព្រះបាទនរោត្តម ក្នុងគ.ស. ១៨៨១។ លោក Adhemard Leclerc ដែលជារេស៊ីដង់បារាំងប្រចាំកម្ពុជា បានស្រង់បញ្ជីក្រមនោះឡើងវិញបានចំនួន ៣៣ ក្រម។ អត្ថបទទាំងអស់នៅក្នុងក្រមទាំងនោះ ហាក់ដូចជាមិនមែន

---

[៩១] សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, *សេចក្តីផ្តើមនៃនីតិកម្ពុជា*, ទំព័រ ៣-២០។

[៩២] គង់ ប៊ុនជី, នីតិធុរកិច្ច, ២០១៤, ទំព័រ ៧។

[៩៣] ឃិន សុខ "Le Cambodge entre Siam et Vietnam", Collection de textes et de documents sur l'Indochine, EFEO, ១៩៩១. ។

[៩៤] សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, *សេចក្តីផ្តើមនៃនីតិកម្ពុជា*, ទំព័រ ៣-២០។

ជាអត្ថបទច្បាប់តែម្តងទេ តែវាដូចជាការចងក្រងប្រមូលផ្តុំជាផ្លូវការនូវសេចក្តីសម្រេចរបស់តុលាការដែលធ្វើឡើងនៅពេលវិវាទត្រូវបានបញ្ជូនឡើងដល់ព្រះមហាក្សត្រ ពោលគឺពេលព្រះរាជសវនាការសាធារណៈដែលជាប្រពៃណីសល់ពីសម័យអង្គរមក។ ក្រមទាំងនេះត្រូវបានបាត់បង់មួយចំនួនដោយសារសង្គ្រាមពីអតីតកាល។ រហូតមកដល់សម័យបច្ចុប្បន្ននេះ យើងសង្កេតឃើញក្រមទាំននោះនៅសេសសល់ចំនួន២៧ប៉ុណ្ណោះ ដែលមានជាអាទិ៍ ក្រមចោរ (ច្បាប់ស្តីពីមនុស្សខូច) ក្រមទោសាភរិយា (ច្បាប់ស្តីពីកំហុសរបស់ប្រពន្ធ) ក្រមតុលាការ (ច្បាប់ស្តីពីចៅក្រម) ក្រមរាជក្រឹត្យសង្គ្រី (ច្បាប់ស្តីពីការបំពានលើទម្លាប់និងបវេណី) ក្រមព្រះធម្មសថ (ច្បាប់ព្រះ) ក្រមអន្តាភាស (ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម) ក្រមព្រះធម្មនុញ្ញ (ច្បាប់ស្តីពីសមាសភាពតុលាការ) ក្រមកត់សំនួន (ច្បាប់ស្តីពីរបៀបសួរចម្លើយសាក្សី) ក្រមតំណាងកូនក្តី (ច្បាប់ស្តីពីការធ្វើតំណាងឱ្យកូនក្តីនៅតុលាការ) ក្រមឧទ្ធរណ៍ (ច្បាប់ស្តីពីបណ្តឹងឧទ្ធរណ៍) ក្រមក្បត់សឹក (ច្បាប់ស្តីពីអំពើក្បត់ជាតិក្នុងសង្គ្រាម) ក្រមអាជ្ញាហ្លួង (ច្បាប់ស្តីពីប្រេសិតរបស់ព្រះរាជា) ក្រមទាសករ (ច្បាប់ស្តីពីទាសករ) ក្រមពហ៊ុលទេព (ច្បាប់ស្តីពីជនបទ) ក្រមបៀរ (ច្បាប់ស្តីពីល្បែងស៊ីសង) ក្រមន្ទីរបាល (ច្បាប់ស្តីពីពិធីការ) ក្រមព្រះរាជខ័ន្ត (ព្រះរាជបញ្ញាថ្មីៗ ក្រមនេះចេញក្នុងរជ្ជកាលព្រះបាទអង្គដួង) ក្រមសេះ (ច្បាប់ស្តីពីសេះ ក្រមមត៌ក (ច្បាប់ស្តីពីសន្តតិកម្ម) ក្រមពួក (ច្បាប់ស្តីពីចៅក្រម) ក្រមចក្រី (ច្បាប់ស្តីពីដំរី) ក្រមស្រុក (ច្បាប់ធម្មនុញ្ញរបស់អាណាចក្រ) និងក្រមរាជនិស្ស័យ (វិធានអត្តចរិតរបស់ក្សត្រ)។[៩៥]

លោក Adhémard Leclère បានលើកឡើងថា ច្បាប់ខ្មែរមិនទាន់បានចងក្រងជាក្រមដោយប្រជាពលរដ្ឋខ្មែរទេ ហើយជារឿយៗ សេចក្តីសម្រេចរបស់តុលាការ ព្រមទាំងការងារគ្រប់គ្រងរដ្ឋដោយព្រះរាជាមន្ត្រី និងដោយអភិបាលខេត្ត ត្រូវធ្វើឡើងដោយផ្អែកលើទំនៀមទម្លាប់។ អត្ថបទច្បាប់បុរាណមានបន្តិចបន្តួច ហើយពិបាកស្វែងរកទៀត។ ប្រជាពលរដ្ឋខ្មែរស្ទើរតែមិនដែលបានមើលអត្ថបទច្បាប់ទាំងនោះផង។ ប៉ុន្តែច្បាប់ទាំងនេះបានស្ថិតនៅក្នុងមនសិការរបស់ជនជាតិខ្មែរ ហើយគ្របដណ្តប់លើការរៀបចំរដ្ឋបាលខ្មែរទាំងមូល។ ច្បាប់ទាំងនោះបង្កើតគោលការណ៍យុត្តិធម៌ ដែលត្រូវបានយកទៅអនុវត្តដោយសាលាជម្រះក្តី។[៩៦]

លោក Adhémard Leclère បានបកប្រែអត្ថបទច្បាប់ខ្មែរជាច្រើនទៅជាភាសាបារាំង និងបោះពុម្ពផ្សាយនៅឆ្នាំ១៨៩៨ ដោយដាក់ចំណងជើងថា "Les codes cambodgiens" ។ លោកបានឱ្យតម្លៃយ៉ាងខ្ពស់ថា ប្រទេសកម្ពុជាធ្លាប់ជាប្រទេសនីតិរដ្ឋមួយ ដែលធ្លាប់មានច្បាប់យ៉ាងសម្បូណ៌បែបសម្រាប់គ្រប់គ្រង តាំងពីមនុស្សរហូតដល់សត្វ ដូចជា ក្រមសេះ ក្រមដំរី ឬក្រមចក្រី។[៩៧]

---

[៩៥] សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចៈ សេចក្តីផ្តើមនៃនីតិកម្ពុជា ឆ្នាំ២០០៦ រោងពុម្ព Funan ភ្នំពេញ ទំព័រ ១៤។

[៩៦] Adhémard Leclère, Recherches sur la législation cambodgienne : droit privé, Paris, Ernest Leroux, ១៨៩០, p. X.

[៩៧] វង់ សុជាត៉ា និង ណុប សុខា, *ប្រវត្តិសាស្ត្រខ្មែរៈសម្រាប់ថ្នាក់មូលដ្ឋាន*, សាកលវិទ្យាល័យភូមិន្ទភ្នំពេញ, ភ្នំពេញ, ២០១២, ទំព័រ៧។

កិច្ចការនីតិកម្មបានចាប់ផ្តើមដំណើរការពេញទំហឹងនៅដើមឆ្នាំ ១៩១០[៩៨]។ មុននេះ ប្រព័ន្ធច្បាប់ដែលអនុវត្តលើដែនដីអាណាព្យាបាលបារាំងទាំងមូល គឺប្រព័ន្ធច្បាប់ចាស់របស់ខ្មែរ។ នៅក្នុងសន្ធិសញ្ញា-បារាំង ព្រះបាទនរោត្តម បានសន្យាទទួលយកនូវគ្រប់កំណែទម្រង់រដ្ឋបាល យុត្តាធិការ ហិរញ្ញវត្ថុ និងពាណិជ្ជកម្ម ដែលប្រទេសបារាំងគ្រោងនឹងធ្វើ។ *ការងារចងក្រងជាក្រមនេះ ចាប់ផ្តើមដំបូងបំផុតដោយព្រះរាជប្បញ្ញត្តិចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩១១ ដែលបានប្រកាសឱ្យប្រើក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមស្តីពីការរៀបចំតុលាការ ក្រមទាំងនេះចូលជាធរមាននៅទូទាំងប្រទេសនៅថ្ងៃទី១ ខែ កក្កដា ឆ្នាំ១៩១២។* ថ្ងៃចូលជាធរមាននេះ គឺជាថ្ងៃកំណត់ឱ្យប្រទេសកម្ពុជាចាប់ផ្តើមប្រកាន់យកប្រព័ន្ធច្បាប់ Civil Law មកប្រើប្រាស់ពិតប្រាកដ។ កម្មវិធីកំណែទម្រង់ដ៏ធំមួយបានសម្រេចជាស្ថាពរនៅឆ្នាំ១៩២០។ ព្រះរាជប្បញ្ញត្តិចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩២០ បានប្រកាសឱ្យប្រើក្រមថ្មីមួយចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ១៩២០ តទៅ គឺក្រមរដ្ឋប្បវេណី នីតិវិធីរដ្ឋប្បវេណី និងការរៀបចំសាលាជំរះក្តីរដ្ឋប្បវេណី។ ក្រមនេះត្រូវបានប្រកាសឱ្យប្រើម្តងរួចហើយ ដោយព្រះរាជប្បញ្ញត្តិមួយមុន ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩១៥។ ស្នាដៃនីតិកម្មរបស់បារាំងតាមរយៈកំណែទម្រង់ដ៏ធំធេងនេះ បានធ្វើឱ្យច្បាប់ខ្មែរក្លាយទៅជាសមាជិកនៃក្រុមបណ្តាប្រទេស ដែលប្រកាន់យកប្រព័ន្ធច្បាប់ Civil Law ។[៩៩]

កម្ពុជាមានរដ្ឋធម្មនុញ្ញដំបូងនៅសម័យអាណានិគមបារាំង។ និយមន័យរបស់រដ្ឋធម្មនុញ្ញ គឺជាគោលការណ៍គ្រឹះ ជាច្បាប់កំពូលរបស់រដ្ឋដែលមានអាទិភាពជាងគេ។ លើកទីមួយនៅក្នុងប្រវត្តិសាស្ត្រសម្រាប់ប្រទេសកម្ពុជា មានរដ្ឋធម្មនុញ្ញជាលើកដំបូងនៅឆ្នាំ១៩៤៧។

សម័យក្រោយអាណានិគមបារាំងរហូតដល់បច្ចុប្បន្នមាន៤ ដំណាក់កាលដូចខាងក្រោម៖

### ១.៣.៥.៧ សង្គមរាស្ត្រនិយម (១៩៥៤-១៩៧០)

ចាប់ពីទទួលបានឯករាជ្យពីបារាំង កម្ពុជាមានសកម្មភាពនីតិកម្មយ៉ាងខ្លាំងក្លា និងការរីកចម្រើនគួរឱ្យកត់សម្គាល់ក្នុងវិស័យនីតិសាស្ត្រ។ ពីឆ្នាំ ១៩៤៧ ដល់ឆ្នាំ ១៩៥៦ ក្រមរដ្ឋប្បវេណី ក្រមពាណិជ្ជកម្ម និងក្រមព្រហ្មទណ្ឌត្រូវបានប្រកាសឱ្យប្រើ។ ទោះជាយ៉ាងណា អ្នកថ្មីកការខាងច្បាប់ និងអ្នកស្រាវជ្រាវនានា តែងពឹងផ្អែកលើអត្ថបទច្បាប់បារាំង ដើម្បីជំរុញការស្រាវជ្រាវរបស់ខ្លួនបន្តទៅមុខទៀត។ នេះគឺជាដំណាក់កាលនៃការរីកចម្រើនខាងផ្នែកបច្ចេកទេសនីតិសាស្ត្រ និងដំណាក់កាលនៃការបង្កើតមហាវិទ្យាល័យនីតិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជានៅឆ្នាំ ១៩៥៧ ។[១០០]

---

[៩៨] Etienne AYMONIER, "Le Cambodge" Paris, Ernest LEROUX, ៣ vol., ១៩០០, p. ៧៩, in Marion SIMONET, These Lyon ៣, p. ៤៩ ។

[៩៩] សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, *សេចក្តីផ្តើមនៃនីតិកម្ពុជា*, ទំព័រ ៣-២០។

[១០០] សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, សេចក្តីផ្តើមនៃនីតិកម្ពុជា, ទំព័រ ៣-២០។

### ១.៣.៥.៨ របបសាធារណរដ្ឋខ្មែរ (១៩៧០-១៩៧៥)

សង្គ្រាមស៊ីវិលគឺជាស្នូរជួងមរណៈសម្រាប់ការស្រាវជ្រាវនៅក្នុងប្រទេស។ និក្ខេបបទជាច្រើនត្រូវបានប្តូរទៅការពារនៅឯប្រទេសបារាំង។ នេះជាដំណាក់កាលមួយ ដែលការរីកចម្រើនក្នុងការពិចារណាក្នុងវិស័យច្បាប់ត្រូវបានបញ្ឈប់។

### ១.៣.៥.៩ ដំណាក់កាលកម្ពុជាប្រជាធិបតី (១៩៧៥-១៩៧៩)

ការឡើងកាន់អំណាចរបស់ពួកកម្ពុជាប្រជាធិបតីបានបណ្តាលឱ្យអាក់ខាន និងឱ្យមានការបោះបង់ចោលនូវនីតិកម្មដែលមានប្រភពពីអាណានិគម ក្នុងគោលបំណងកសាង ***"សង្គមកុម្មុយនីស្តឥតខ្ចោះ"*** មួយនៅកម្ពុជា។ លក្ខណៈពិសេសបំផុតនៃដំណាក់កាលនេះ គឺជាសង្គមមួយគ្មានច្បាប់ ដោយមានការហាមប្រាមគ្រប់ការសំអាង ឬយោងទៅលើប្រព័ន្ធគតិយុត្តណាមួយ។

### ១.៣.៥.១០ របបសាធារណរដ្ឋប្រជាមានិតកម្ពុជា (១៩៧៩-១៩៨៩)

រដ្ឋធម្មនុញ្ញអនុម័តនៅឆ្នាំ ១៩៨១ បានចារឹកមនោគមវិជ្ជាកុម្មុយនីស្តនៅក្នុងនោះ ហើយកម្ពុជាមានឈ្មោះជាផ្លូវការថា "សាធារណរដ្ឋប្រជាមានិតកម្ពុជា"។ ប្រព័ន្ធច្បាប់ដែលចេញពីទ្រឹស្តីម៉ាក្ស-លេនីនមានលក្ខណៈផ្ទុយពីប្រព័ន្ធច្បាប់គហបតី ហើយគោលការណ៍កម្មសិទ្ធិបុគ្គលត្រូវបានលប់ចោល និងបំប្លែងទៅជាគោលការណ៍សមូហភាពទៅវិញ។ ពេលនោះច្បាប់ឯកជនក៏បាត់រូបរាងបន្សល់ទុកតែច្បាប់សាធារណៈមួយគត់។

### ១.៣.៥.១១ សម័យរដ្ឋកម្ពុជា (១៩៨៩-១៩៩១)

ការរលំរលាយនៃនូវប្លុកកុម្មុយនីស្តគឺជាការចាប់ផ្តើមសករាជថ្មីសម្រាប់ប្រទេសកម្ពុជា។ នៅសម័យរដ្ឋកម្ពុជា អត្ថបទច្បាប់ជាច្រើន ពិសេសទាក់ទងនឹងវិស័យយុត្តធិការត្រូវបានអនុម័តដើម្បីឆ្លើយតបតាមតម្រូវការពីខាងក្រៅ។ ដំបូងបំផុតគឺ ព្រះពុទ្ធសាសនាត្រូវបានប្រកាសថាជាសាសនារបស់រដ្ឋ បន្ទាប់មកមានការទទួលស្គាល់ផ្នែកឯកជន ដែលជាកត្តាមួយអនុញ្ញាតឱ្យមានការរៀបចំនូវសេដ្ឋកិច្ចបែបបសេរីនិយមនៅកម្ពុជា។ ចុងក្រោយបង្អស់ គឺការទទួលស្គាល់កម្មសិទ្ធិឯកជន និងការបោះបង់ចោលសមូហភាវកម្មក្រោមរូបភាព "ក្រុមសាមគ្គី"។[១០១]

### ១.៣.៥.១២ សម័យអន្តរកាល (១៩៩១-១៩៩៣)

ក្រោយការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពនាទីក្រុងប៉ារីសនៅឆ្នាំ ១៩៩១ អង្គការសហប្រជាជាតិបានចូលអន្តរាគម ដើម្បីជួយបញ្ចប់ជម្លោះនៅកម្ពុជា។ ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ត្រូវបានបង្កើតឡើង។ ការបោះឆ្នោតបានអនុញ្ញាតឱ្យមានការបង្កើតសភាធម្មនុញ្ញមួយ ដែលមានតួនាទីអនុម័តរដ្ឋធម្មនុ

---

[១០១] សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, សេចក្តីផ្តើមនៃនីតិកម្ពុជា, ទំព័រ ៣-២០។

ញថ្មីមួយ។ រដ្ឋធម្មនុញ្ញត្រូវបានអនុម័តនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ និងប្រកាសឱ្យប្រើជាផ្លូវការនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ដោយព្រះបាទនរោត្តម សីហនុ បន្ទាប់ពីព្រះអង្គត្រូវបានសភាធម្មនុញ្ញប្រកាសឱ្យឡើងគ្រងរាជសម្បត្តិសាជាថ្មីនៅថ្ងៃនោះដែរ។[១០២]

##### ១.៣.៥.១៣ ក្រោយការបោះឆ្នោតសកល ឆ្នាំ១៩៩៣

រហូតមកដល់ឆ្នាំ២០២៥ នេះ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ត្រូវបានធ្វើវិសោធនកម្មចំនួន១១ លើក ក្នុងគោលបំណងធានាឱ្យបាននូវនិរន្តរភាពជាតិ ក៏ដូចជាការធានាការពារនូវឧត្តមប្រយោជន៍របស់ប្រទេសជាតិ និងប្រជាជនកម្ពុជា។

## ១.៤. គោលការណ៍មូលដ្ឋាននៃប្រព័ន្ធច្បាប់

### ១.៤.១ គោលការណ៍គតិយុត្ត

#### ១.៤.១.១ និយមន័យ

ការកំណត់និយមន័យនៃគោលការណ៍គតិយុត្តគឺពិតជាមានភាពលំបាក ដោយសារគោលការណ៍គតិយុត្ត ពេលខ្លះត្រូវបានចាត់ទុកថាជាបទដ្ឋានគតិយុត្ត ជួនកាលជាបទដ្ឋានគតិយុត្តទូទៅ ពេលខ្លះត្រូវបានចាត់ទុកថាជាស្តង់ដាដែលជាបង្អែកនៃវិធានគតិយុត្តទាំងឡាយ។ ការកំណត់សញ្ញាណនៃគោលការណ៍គតិយុត្តមានជាប់ពាក់ព័ន្ធនឹងការវិភាគ និងបញ្ហានានា ដែលត្រូវលើកយកមកពិចារណាមុននឹងឈានដល់ការកំណត់និយមន័យណាមួយ។ ប៉ុន្តែមធ្យោបាយងាយស្រួលបំផុតដើម្បីកំណត់គោលការណ៍គតិយុត្ត ឬសញ្ញាណគតិយុត្ត គឺដោយការយល់ដឹងពីអត្ថន័យនៃពាក្យឬកន្សោមពាក្យតាមភាសាវិទ្យា។ ក្នុងន័យនេះតាមភាសាវិទ្យា អត្ថន័យនៃពាក្យ គោលការណ៍ (Principle) មានន័យថា "សេចក្តីពិតជាមូលដ្ឋាន ច្បាប់ ឬគោលលទ្ធិមានលក្ខណៈពេញលេញដែលបានមកពីបុគ្គលណាម្នាក់ ឬបង្កើតឡើងដោយបុគ្គលណាម្នាក់, សេចក្តីពិតជាទូទៅ, គំនិតដើម, គោលគំនិត, មូលដ្ឋានគំនិត, គោលសន្មត, ការប្រមូលផ្តុំស្តង់ដាសីលធម៌ឬការវិនិច្ឆ័យ, ច្បាប់ជាមូលដ្ឋានឬការសន្មតជាមូលដ្ឋាន, វិធានអនុវត្តន៍ដែលទទួលស្គាល់ជាទូទៅ, ច្បាប់គ្រប់គ្រងលើការប្រព្រឹត្ត។" ហេតុនេះគោលការណ៍គតិយុត្ត ត្រូវបានកំណត់ន័យថា ជាស្តង់ដា ឬសំណុំស្តង់ដានៃការប្រព្រឹត្ត ឬការវិនិច្ឆ័យ ដែលត្រូវបានសន្មតថា ជាស្តង់ដាដ៏ត្រឹមត្រូវនៃការប្រព្រឹត្តសម្រាប់សង្គមមួយ ឬសម្រាប់មនុស្សជាតិទាំងមូល។

លើសពីនេះទៀត គោលការណ៍គតិយុត្ត ក៏អាចត្រូវបានចាត់ទុកថា ជាបទដ្ឋានមូលដ្ឋាន (Basic Norm) ដែលបទដ្ឋានផ្សេងទៀត ត្រូវបានបង្កើត ឬដកស្រង់ចេញមកពីបទដ្ឋានមូលដ្ឋាននេះ។ ដូចដែល Kelsen បានពណ៌នាថា រដ្ឋធម្មនុញ្ញជាបទដ្ឋានមូលដ្ឋាន ដែលមានន័យថា រដ្ឋធម្មនុញ្ញ អាចត្រូវបាន

---

[១០២] សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, *សេចក្តីផ្តើមនៃនីតិកម្ពុជា*, ទំព័រ ៣-២០ ។

កំណត់ន័យថាជាសំណុំគោលការណ៍គតិយុត្ត ដែលកំណត់ខ្លឹមសារ និងទម្រង់នៃបទដ្ឋានគតិយុត្តផ្សេងទៀតទាំងអស់។ គំនិតនេះស្រដៀងនឹងនិយមន័យរបស់ Joseph Raz (១៩៧២, ៨២៤ n៤) ដែលបានចាត់ថ្នាក់គោលការណ៍គតិយុត្ត និងវិធានគតិយុត្ត ជាបទដ្ឋានគតិយុត្តទូទៅ (general legal norms) ដែលអនុញ្ញាតឱ្យមានទាំងបទដ្ឋានគតិយុត្តជាក់លាក់ និងស្តង់ដាគតិយុត្តផ្សេងទៀតដែលមិនមែនជាបទដ្ឋាន ។[១០៣]

ម្យ៉ាងវិញទៀត គោលការណ៍គតិយុត្តគឺជាវិធាននិងទ្រឹស្តីមូលដ្ឋាន ដែលណែនាំការអនុវត្តច្បាប់ក្នុងដំណើរការតុលាការ ដើម្បីធានាឱ្យមានភាពត្រឹមត្រូវ និងយុត្តិធម៌ក្នុងនីតិវិធីច្បាប់។ គោលការណ៍ទាំងនេះរួមមានគំនិតដូចជា គោលការណ៍នីតិរដ្ឋ នីតិវិធីត្រឹមត្រូវ (due process) និងការសន្មតទុកជាមុនថាគ្មានទោស (presumption of innocence) ដែលជួយរក្សាសណ្តាប់ធ្នាប់សង្គម និងការពារសិទ្ធិបុគ្គល។ ការយល់ដឹងអំពីគោលការណ៍គតិយុត្តមានសារៈសំខាន់ខ្លាំងសម្រាប់ការយល់ច្បាស់អំពីប្រព័ន្ធច្បាប់ និងការបញ្ជាក់ពីសារៈសំខាន់នៃយុត្តិធម៌ គណនេយ្យភាព និងការគោរពតាមច្បាប់ជាធរមាន។[១០៤]

#### ១.៤.១.២ ប្រភេទនៃគោលការណ៍គតិយុត្ត

##### ក. គោលការណ៍គតិយុត្តជាមូលដ្ឋាន

គោលការណ៍ទាំងនេះតំណាងឱ្យការយល់ដឹងរបស់មនុស្សដែលត្រូវបានទទួលស្គាល់ជាទូទៅ ដោយន័យថា *"ច្បាប់ជាយុត្តិធម៌ (law as jus "just") និងច្បាប់ជាច្បាប់ (law as lex)"*។ គោលការណ៍មួយក្នុងចំណោមគោលការណ៍មូលដ្ឋានគឺ សមាមាត្រ (proportionality)។ គោលការណ៍នេះរួមបញ្ចូលស្តង់ដាមូលដ្ឋានសម្រាប់ផ្តល់យុត្តិធម៌ ដោយសារតែវាបានកំណត់នូវលក្ខខណ្ឌមូលដ្ឋានក្នុងការវិនិច្ឆ័យលើវិវាទអំពីសិទ្ធិ ដែលជាមុខងារពិតប្រាកដរបស់ប្រព័ន្ធច្បាប់។ គោលការណ៍សមាមាត្រគឺជាគោលការណ៍គន្លឹះសម្រាប់នីតិអន្តរជាតិផងដែរ នៅពេលគោលគំនិតស្តីពីសមាមាត្រដើរតួជាស្តង់ដាមួយក្នុងចំណោមស្តង់ដាវិនិច្ឆ័យគន្លឹះ (key judgement standards)។

##### ខ. គោលការណ៍គតិយុត្តមានលក្ខណៈជាសមាសធាតុ

វិធីសាស្ត្រប្រៀបធៀបគឺជាគោលការណ៍គតិយុត្តមានលក្ខណៈជាសមាសធាតុ ពីព្រោះថាគោលការណ៍នេះទាមទារការរួមបញ្ចូលចំណេះដឹងផ្នែកច្បាប់ (ចំណេះដឹងអំពីប្រព័ន្ធច្បាប់ ការយល់ដឹងអំពីគោលការណ៍ច្បាប់និងវិធាននានា និងវិធីសាស្ត្រក្នុងការផ្តល់ទឡ្ហីករណ៍និងការបកស្រាយច្បាប់) កាន់

---

[១០៣] See: https://academicus.edu.al/nr២/Academicus-MMX-២-១០៩-១១៥.pdf

[១០៤] See: https://www.studysmarter.co.uk/explanations/law/uk-legal-system/legal-principles/

តែខ្ពស់ និងជាគោលការណ៍ដែលអាចផ្ទេរឬផ្សាំបាន ពីព្រោះគេអាចយកទៅប្រើប្រាស់ឆ្លងកាត់យុត្តាធិការ គោលលទ្ធិ និងវិជ្ជាជីវៈច្បាប់ផ្សេងទៀតបាន។ វិធីសាស្ត្រប្រៀបធៀបអាចត្រូវបានប្រើប្រាស់ជាវិធីសាស្ត្របន្ថែមក្រោយការសេចក្តីសម្រេច ដើម្បីជួយពង្រឹងសេចក្តីសន្និដ្ឋានផ្នែកច្បាប់ដែលត្រូវបានសម្រេចតាមរយៈការពិចារណាផ្អែកលើការទាញហេតុផលដោយប្រើប្រាស់គោលលទ្ធិពីបុរាណ (classic doctrinal reasoning)។ ជារួម វិធីសាស្ត្រប្រៀបធៀបគឺជាគោលការណ៍សមាសធាតុ ពីព្រោះថា វិធីសាស្ត្រនេះទាមទារឱ្យរួមបញ្ចូលចំណេះដឹងច្បាប់កម្រិតទី២។

## គ. គោលការណ៍គតិយុត្តមានលក្ខណៈស្មុគស្មាញ

Arbitrage គឺជាគោលការណ៍គតិយុត្តមានលក្ខណៈស្មុគស្មាញ ពីព្រោះថា វាតម្រូវឱ្យមានការរួមបញ្ចូលចំណេះដឹងផ្នែកច្បាប់កម្រិតកាន់តែខ្ពស់ជាងគោលការណ៍ដែលបានរៀបរាប់ខាងលើ។ ជាធម្មតាវាត្រូវបានប្រើប្រាស់តិចជាងវិធីសាស្ត្រខាងលើ ហើយវិធីសាស្ត្រនេះច្រើនប្រើប្រាស់ដោយមេគំនិតច្បាប់ដែលមានជំនាញច្បាស់លាស់។ ដូចគ្នានឹងគោលការណ៍ខាងលើដែរ Arbitrage អាចផ្ទេរនិងផ្សាំបាន ដោយសារបានឆ្លងកាត់យុត្តាធិការ គោលលទ្ធិ និងវិជ្ជាជីវៈច្បាប់ផ្សេងៗ។

## ឃ. គោលការណ៍នីតិឯកជន

នៅក្នុងគោលគំនិតទស្សនវិជ្ជា លទ្ធិគ្រិស្តសាសនា និងវិទ្យាសាស្ត្រមនុស្ស ឬទម្រង់បែបសាមញ្ញៗងាយស្រួលយល់អំពី "បុគ្គល" ត្រូវបានសិក្សាតាមជ្រុងពីរ ដូចខាងក្រោម ៖

- ជ្រុងបុគ្គល (Descartes, Locke, Kant និងអ្នកដទៃទៀត)និង
- ជ្រុងសង្គមនិងទំនាក់ទំនង (Hegel, Durkheim, រួមទាំងវិស័យវិទ្យាសាស្ត្រទាំងមូល ដូចជាសង្គមវិទ្យា និងបុគ្គលនិយម) ។

ជ្រុងទាំងពីរនេះ បង្កើតជាមូលដ្ឋានសម្រាប់ការពិពណ៌នាមនុស្សក្នុងកម្រិតមូលដ្ឋានមួយ ហើយការយល់ឃើញនេះ បានបង្ហាញឱ្យឃើញច្បាស់រួចហើយ ចាប់តាំងពីសម័យ អូហ្គូស្ទីន (Saint Augustine) ដែលបានពោលថា៖ «Homo sum et inter homines vivo» (ខ្ញុំជាមនុស្ស ហើយរស់នៅក្នុងចំណោមមនុស្សទាំងឡាយ)។

ច្បាប់មានគោលបំណងដើម្បីរៀបចំទំនាក់ទំនងរវាងមនុស្សនៅក្នុងសង្គម។ វាសិក្សាអំពីមនុស្ស និងតួនាទីរបស់មនុស្សក្នុងសង្គម។ ពេលមនុស្សមានទំនាក់ទំនងគ្នា អាចកើតមានជម្លោះឡើង ដូច្នេះច្បាប់មានតួនាទីរក្សា ឬស្តារតុល្យភាព និងយុត្តិធម៌រវាងភាគីដែលពាក់ព័ន្ធ។ ពីចំណុចនេះហើយ គោលការណ៍មនុស្ស និងគោលការណ៍ច្បាប់ ក៏កើតមានឡើង។

អស់រយៈពេលជាង ២០០ ឆ្នាំមកហើយ ជាពិសេសចាប់តាំងពីបដិវត្តន៍បារាំង មូលដ្ឋាននេះ ត្រូវបានប្រើដើម្បីកំណត់តម្លៃសំខាន់ពីរ ដែលត្រូវបានទទួលស្គាល់ជាសិទ្ធិមូលដ្ឋាន។ តម្លៃទាំងពីរនេះ តំណាងឱ្យលក្ខណៈសំខាន់របស់មនុស្ស៖

- **សេរីភាព** បង្ហាញពីឯកត្តភាព និងសិទ្ធិរបស់មនុស្សម្នាក់ៗក្នុងសង្គម
- **សមភាព** បង្ហាញថាមនុស្សទាំងអស់ត្រូវបានចាត់ទុកស្មើគ្នានៅក្នុងសង្គម។

| គោលការណ៍ផ្នែកខាងក្រៅ | |
|---|---|
| គោលការណ៍មូលដ្ឋាន | គោលការណ៍បន្ថែម |
| សេរីភាព | ▪ស្វ័យភាពបុគ្គល (ស្វ័យភាពនៃឆន្ទៈ)<br>▪អ្វីគ្រប់យ៉ាងដែលត្រូវបានអនុញ្ញាត មិនត្រូវបានរារាំងទេ<br>▪សេរីភាពបុគ្គល (Dispositively)<br>▪ Vigilantibus iura |
| សមភាព | ▪ឱកាសស្មើគ្នា<br>▪រារាំងការរើសអើង<br>▪ការការពារភាគីដែលទន់ខ្សោយ (អ្នកប្រើប្រាស់ ភតិក: ។ល។) |
| តុល្យភាព-សមធម៌ | ▪ភាពសមហេតុផល (សមាមាត្រ)<br>▪ឥរិយាបថល្អ (ទំនាក់ទំនងប្រកបដោយភាពស្មោះត្រង់)<br>▪មានលក្ខណៈប្រជាធិបតេយ្យ<br>▪សនិទានភាព |

| គោលការណ៍ផ្នែកខាងក្នុង | |
|---|---|
| គោលការណ៍មូលដ្ឋាន | គោលការណ៍បន្ថែម |
| ភាពជាក់ច្បាស់ប្រាកដនៃច្បាប់<br>ស័ក្តិសិទ្ធិភាពនៃច្បាប់ | ▪ការការពារភាពស្មោះត្រង់ (ផ្អែកតាមន័យចិត្តសាស្ត្រនៃពាក្យ)<br>▪រារាំងចំពោះប្រតិសកម្ម<br>▪ការការពារសិទ្ធិដែលត្រូវទទួលបាន |

| | |
|---|---|
| | ▪ធ្វើឱ្យស្របច្បាប់ដល់លទ្ធផលរំពឹងទុក<br>▪ តម្លាភាព<br>▪ ការការពារសិទ្ធិរបស់តតិយជន<br>▪ ការការពារទុកជាមុន<br>▪ Pacta sunt servanda |

## ង. គោលការណ៍នីតិសាធារណៈ

១) អធិបតេយ្យភាពសភា៖ គោលការណ៍នេះបញ្ជាក់ថា នៅក្នុងប្រទេសដែលមានប្រព័ន្ធសភា ស្ថាប័ននីតិប្បញ្ញត្តិមានសិទ្ធិអំណាចកំពូលក្នុងការធ្វើច្បាប់ និងធ្វើវិសោធនកម្មច្បាប់ ហើយគ្មានស្ថាប័នណាមួយអាចបដិសេធ ឬធ្វើឱ្យការសម្រេចចិត្តរបស់ខ្លួនមានសុពលភាពឡើយ។

២) ការបែងចែកអំណាច៖ គោលការណ៍នេះបែងចែកមុខងាររបស់រដ្ឋជាបីផ្នែកដាច់ដោយឡែកពីគ្នា គឺ នីតិប្បញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ - ដើម្បីទប់ស្កាត់ការប្រមូលផ្តុំអំណាច និងរក្សាការត្រួតពិនិត្យ និងតុល្យភាព។

៣) ការត្រួតពិនិត្យប្រព័ន្ធតុលាការ៖ ការត្រួតពិនិត្យប្រព័ន្ធតុលាការគឺជាអំណាចរបស់តុលាការដើម្បីពិនិត្យមើលធម្មនុញ្ញភាព និងភាពស្របច្បាប់នៃសកម្មភាពនីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិ។ វាអនុញ្ញាតឱ្យប្រព័ន្ធតុលាការធ្វើកូដកម្មច្បាប់ ឬសកម្មភាពដែលមិនស្របនឹងបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញ។

៤) ធម្មនុញ្ញនិយម៖ រដ្ឋធម្មនុញ្ញនិយមសំដៅលើគោលការណ៍ និងបទដ្ឋាននានាដែលគ្រប់គ្រងរចនាសម្ព័ន្ធ អំណាច និងការកំណត់របស់រដ្ឋាភិបាល ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ។ វាធានាថារដ្ឋាភិបាលធ្វើប្រតិបត្តិការក្នុងក្របខ័ណ្ឌច្បាប់ និងស្ថាប័ន។

៥) Ultra vires៖ គោលលទ្ធិនៃ ultra vires ចែងថា ស្ថាប័នរដ្ឋាភិបាល និងមន្ត្រីមានអំណាចមានកម្រិត ហើយអាចធ្វើសកម្មភាពបានតែនៅក្នុងវិសាលភាពនៃសិទ្ធិអំណាចរបស់ពួកគេ ដូចដែលបានកំណត់ដោយច្បាប់។ សកម្មភាពណាមួយដែលលើសពីវិសាលភាពនេះត្រូវបានចាត់ទុកថាជាមោឃៈ ឬគ្មានសុពលភាព និងមិនត្រឹមត្រូវ។

៦) ការរំពឹងទុកស្របច្បាប់៖ គោលលទ្ធិនៃការរំពឹងទុកស្របច្បាប់ កំណត់ថាបុគ្គលមានការរំពឹងទុកស្របច្បាប់ថាអាជ្ញាធរសាធារណៈនឹងធ្វើសកម្មភាពដោយយុត្តិធម៌ សមហេតុផល និងស្របតាមការអនុវត្ត ឬការសន្យាដែលបានបង្កើតឡើង។

៧) សមាមាត្រ៖ គោលការណ៍នេះទាមទារឱ្យសកម្មភាព ឬវិធានការរបស់រដ្ឋាភិបាលសមាមាត្រទៅនឹងគោលបំណងដែលបានគ្រោងទុក ហើយមិនត្រូវលើសពីអ្វីដែលចាំបាច់ដើម្បីសម្រេចបានឡើយ។ វាធានាឱ្យមានតុល្យភាពរវាងការអនុវត្តអំណាចសាធារណៈ និងការការពារសិទ្ធិបុគ្គល។

៨) ផលប្រយោជន៍សាធារណៈ៖ គោលលទ្ធិនៃផលប្រយោជន៍សាធារណៈ សង្កត់ធ្ងន់ថា អាជ្ញាធរសាធារណៈគួរតែធ្វើសកម្មភាពជាប្រយោជន៍ដល់សង្គមទាំងមូល ដោយគិតដល់កត្តាមួយចំនួនដូចជាសុខុមាលភាពសាធារណៈ សុវត្ថិភាព និងប្រយោជន៍រួម។

៩) អភ័យឯកសិទ្ធិអធិបតេយ្យភាព៖ គោលការណ៍នេះកំណត់ថារដ្ឋាភិបាល ឬអធិបតេយ្យភាពមានអភ័យឯកសិទ្ធិពីការប្តឹង ឬទទួលខុសត្រូវតាមផ្លូវច្បាប់ដោយគ្មានការយល់ព្រមពីខ្លួន។ វាផ្តល់កម្រិតនៃការការពារដល់រដ្ឋាភិបាលពីបណ្តឹងរដ្ឋប្បវេណី និងការទទួលខុសត្រូវ ដែលស្ថិតនៅក្រោមការលើកលែង និងដែនកំណត់ជាក់លាក់។

១០) ដំណើរការត្រឹមត្រូវ៖ គោលការណ៍នេះធានាថាបុគ្គលម្នាក់ៗទទួលបានការព្យាបាលដោយយុត្តិធម៌ សិទ្ធិនីតិវិធី និងឱកាសដែលត្រូវបានស្តាប់មុនពេលរដ្ឋាភិបាលចាត់វិធានការដែលអាចប៉ះពាល់ដល់សិទ្ធិ ឬផលប្រយោជន៍របស់ពួកគេ។ វាធានានូវភាពយុត្តិធម៌ជាមូលដ្ឋាន និងការពារប្រឆាំងនឹងការដកហូតជីវិត សេរីភាព ឬទ្រព្យសម្បត្តិដោយបំពាន។

## ច. គោលការណ៍នីតិអន្តរជាតិ

ជាទូទៅ ច្បាប់អន្តរជាតិកំណត់នូវច្បាប់ដែលអនុវត្តចំពោះទំនាក់ទំនងរវាងរដ្ឋ។ វាក៏កំណត់ផងដែរនូវច្បាប់ស្តីពីបញ្ហាជាច្រើនដែលរដ្ឋបានព្រមព្រៀងគ្នាមានសារៈសំខាន់ជាអន្តរជាតិ។ ច្បាប់អន្តរជាតិគ្របដណ្តប់លើអ្វីៗជាច្រើន។ នេះគ្រាន់តែជាឧទាហរណ៍មួយចំនួនប៉ុណ្ណោះ៖

- សិទ្ធិមនុស្ស
- សន្តិភាព និងសន្តិសុខអន្តរជាតិ
- ពាណិជ្ជកម្មអន្តរជាតិ
- ឧក្រិដ្ឋកម្មអន្តរជាតិ (ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម)
- ច្បាប់នៃសង្គ្រាម (ត្រូវបានគេស្គាល់ផងដែរថាជាច្បាប់មនុស្សធម៌អន្តរជាតិ)

- ទំនាក់ទំនងការទូត
- បត្យាប័ន
- សន្ធិសញ្ញាវិនិយោគ
- ការអភិវឌ្ឍន៍សេដ្ឋកិច្ច
- ការប្រែប្រួលអាកាសធាតុ
- ដំណោះស្រាយជម្លោះអន្តរជាតិ
- កិច្ចការរូបិយវត្ថុអន្តរជាតិ
- សន្ធិសញ្ញាពន្ធទ្វេដង

កាតព្វកិច្ចផ្លូវច្បាប់អន្តរជាតិបានមកពីប្រភពផ្សេងៗគ្នា រួមមានសន្ធិសញ្ញា ច្បាប់ទំនៀមទម្លាប់អន្តរជាតិ គោលការណ៍ទូទៅនៃច្បាប់ និងសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិ។ រដ្ឋបុគ្គលយកវិធីសាស្ត្រផ្សេងៗគ្នាចំពោះកាតព្វកិច្ចអន្តរជាតិរបស់ពួកគេ។ អ្នកខ្លះចាត់ទុកច្បាប់អន្តរជាតិជាផ្នែកនៃច្បាប់ក្នុងស្រុករបស់ពួកគេ។ អ្នកផ្សេងទៀត (រួមទាំងចក្រភពអង់គ្លេស) មើលឃើញច្បាប់អន្តរជាតិដាច់ដោយឡែកពីគ្នាទៅនឹងច្បាប់ក្នុងស្រុក ហើយទាមទារឱ្យមានច្បាប់ក្នុងស្រុកដើម្បីអនុវត្តកាតព្វកិច្ចអន្តរជាតិ។

### ១.៤.១.៣ គោលការណ៍គតិយុត្តកម្ពុជា

#### ក. គោលការណ៍នីតិឯកជនកម្ពុជា

ច្បាប់ឯកជនកម្ពុជា ផ្អែកលើការយល់ឃើញពីមនុស្សជាពីរជ្រុង ដែលបំពេញគ្នាទៅវិញទៅមក៖

#### ១. ជ្រុងបុគ្គល

ដោយឥទ្ធិពលពីទស្សនវិទូ ដូចជា Descartes, Locke និង Kant មនុស្សត្រូវបានទទួលស្គាល់ថា៖

- ជាបុគ្គលមានហេតុផល និងសមត្ថភាពគិតពិចារណា
- មានស្វ័យភាពនៃឆន្ទៈ និងសមត្ថភាពបង្កើតទំនាក់ទំនងច្បាប់
- ជាម្ចាស់សិទ្ធិ និងកាតព្វកិច្ច

#### ២. ជ្រុងសង្គម និងទំនាក់ទំនង

ដោយឥទ្ធិពលពី Hegel, Durkheim និងតម្លៃសង្គមខ្មែរ ច្បាប់ឯកជនទទួលស្គាល់ថា មនុស្ស៖

- រស់នៅក្នុងសង្គម និងទំនាក់ទំនងជាបន្តបន្ទាប់
- មានកាតព្វកិច្ចសីលធម៌ចំពោះអ្នកដទៃ
- ត្រូវគោរពសាមគ្គីភាព សន្តិភាព និងតុល្យភាពសង្គម
- ទស្សនៈនេះ ស្របទៅនឹងពាក្យសម្តីរបស់ Saint Augustine៖

  **«ខ្ញុំជាមនុស្ស ហើយរស់នៅក្នុងចំណោមមនុស្សទាំងឡាយ»**

  ដែលក៏ស្របគ្នានឹងវប្បធម៌ខ្មែរ ដែលផ្តោតលើការរស់នៅដោយសុខដុមរមនា។

## ខ. គោលការណ៍មូលដ្ឋាននៃច្បាប់ឯកជន (គោលការណ៍ផ្នែកខាងក្រៅ)

### ១. គោលការណ៍សេរីភាព

- **ស្តង់ដារអន្តរជាតិ៖** ស្វ័យភាពនៃឆន្ទៈ និងសេរីភាពក្នុងការធ្វើកិច្ចសន្យា
  **តម្លៃខ្មែរ៖** កិត្តិយស ការទទួលខុសត្រូវ និងការគោរពអ្នកដទៃ
- ធាតុសំខាន់ៗ៖
  - ស្វ័យភាពបុគ្គល (ស្វ័យភាពនៃឆន្ទៈ)
  - អ្វីដែលច្បាប់មិនហាមឃាត់ គឺអាចធ្វើបាន
- លក្ខណៈ Dispositive នៃច្បាប់ឯកជន
  - *Vigilantibus iura* (ច្បាប់ការពារអ្នកដែលប្រុងប្រយ័ត្ន)

**ទស្សនៈកម្ពុជា៖** សេរីភាពត្រូវអនុវត្តដោយការទទួលខុសត្រូវ មិនប៉ះពាល់ដល់សិទ្ធិអ្នកដទៃ និងសន្តិភាពសង្គម។

### ២. គោលការណ៍សមភាព

- **ស្តង់ដារអន្តរជាតិ៖** សមភាពចំពោះច្បាប់ និងសមភាពជាក់ស្តែង
  **តម្លៃខ្មែរ៖** យុត្តិធម៌ និងការមិនរើសអើង
- ធាតុសំខាន់ៗ៖
  - សមភាពក្នុងសមត្ថភាពច្បាប់ និងឱកាស
  - ការហាមឃាត់ការរើសអើង
  - ការការពារភាគីដែលទន់ខ្សោយ (អ្នកប្រើប្រាស់ អ្នកជួល កម្មករ)

**ទស្សនៈកម្ពុជា៖** សមភាពមិនមែនជាសមភាពតាមទម្រង់ប៉ុណ្ណោះទេ ប៉ុន្តែជាសមភាពតាមស្ថានភាពជាក់ស្តែង។

### ៣. គោលការណ៍តុល្យភាព និងសមធម៌

- **ស្តង់ដារអន្តរជាតិ៖** សមាមាត្រ សេចក្តីស្មោះត្រង់ និងសុចរិតភាព
- **តម្លៃខ្មែរ៖** មធ្យមភាព និងការជៀសវាងជម្លោះ
- ធាតុសំខាន់ៗ៖
- ភាពសមហេតុផល និងសមាមាត្រ
- ឥរិយាបថល្អ និងសុចរិតភាពក្នុងទំនាក់ទំនង
- លក្ខណៈប្រជាធិបតេយ្យនៃច្បាប់
- សនិទានភាពក្នុងការបកស្រាយច្បាប់

➢ **ទស្សនៈកម្ពុជា៖** ច្បាប់ឯកជនមានបំណងរក្សាតុល្យភាព មិនមែនអនុវត្តតាមពាក្យពេចន៍ច្បាប់ដោយរឹងមាំតែប៉ុណ្ណោះទេ។

គ. គោលការណ៍រចនាសម្ព័ន្ធនៃច្បាប់ឯកជន (គោលការណ៍ផ្នែកខាងក្នុង)

៤. គោលការណ៍ភាពជាក់ច្បាស់ប្រាកដនៃច្បាប់

- **ស្តង់ដារអន្តរជាតិ៖** នីតិរដ្ឋ និងភាពអាចព្យាករណ៍បាន
- **តម្លៃខ្មែរ៖** ទំនុកចិត្ត និងស្ថិរភាពសង្គម
- ជាតុសំខាន់ៗ៖
  - ការការពារការរំពឹងទុកដោយសមហេតុផល
  - ការហាមឃាត់ការអនុវត្តច្បាប់ថយក្រោយ
  - ការការពារសិទ្ធិដែលទទួលបានរួច
  - តម្លាភាព និងភាពអាចចូលដំណើរការបាននៃច្បាប់
  - ការការពារសិទ្ធិតតិយជន
  - ការការពារទុកជាមុន
  - *Pacta sunt servanda* (កិច្ចសន្យាត្រូវគោរព)

➢ **ទស្សនៈកម្ពុជា៖** ភាពជាក់ច្បាស់នៃច្បាប់ គឺជាមូលដ្ឋានសម្រាប់ទំនុកចិត្ត សន្តិសុខច្បាប់ និងការអភិវឌ្ឍសេដ្ឋកិច្ច។

ច្បាប់ឯកជនកម្ពុជា មានអត្តសញ្ញាណជាប្រព័ន្ធច្បាប់បញ្ចូលគ្នាដោយទទួលយកគោលការណ៍សកល ដូចជា សេរីភាព សមភាព សេចក្តីស្មោះត្រង់ និងភាពជាក់ច្បាស់នៃច្បាប់ បញ្ចូលតម្លៃខ្មែរ ដូចជា សាមគ្គីភាព ការទទួលខុសត្រូវ សមធម៌ និងសន្តិភាព។

ដូច្នេះ ច្បាប់ឯកជនកម្ពុជាមើលមនុស្សជាបុគ្គលសេរី និងស្មើគ្នា ប៉ុន្តែរស់នៅក្នុងសង្គមដោយមានការទទួលខុសត្រូវចំពោះគ្នាទៅវិញទៅមក និងការរក្សាតុល្យភាពសង្គម។

### ១.៤.១.៤ គោលការណ៍នីតិសាធារណៈកម្ពុជា

**មូលដ្ឋានទស្សនវិជ្ជា និងនីតិរដ្ឋ**

នីតិសាធារណៈកម្ពុជា ផ្អែកលើគោលការណ៍នីតិរដ្ឋ (Rule of Law) ដែលទទួលស្គាល់ថា អំណាចរដ្ឋមិនមែនជាអំណាចផ្តាច់មុខទាំងអស់ទេ ប៉ុន្តែជាអំណាចដែលត្រូវបានកំណត់ កម្រិត និងត្រួតពិនិត្យដោយច្បាប់ ដើម្បីបម្រើផលប្រយោជន៍សាធារណៈ និងការពារសិទ្ធិមនុស្ស។ ទស្សនៈនេះ ស្របទាំងស្តង់ដារអន្តរជាតិ (ធម្មនុញ្ញនិយម ប្រជាធិបតេយ្យ និងការការពារសិទ្ធិ) និងតម្លៃខ្មែរ (យុត្តិធម៌ សន្តិភាព សាមគ្គីភាពសង្គម និងការអនុវត្តអំណាចសាធារណៈប្រកបដោយសីលធម៌)។

**គោលការណ៍មូលដ្ឋាននៃនីតិសាធារណៈកម្ពុជា**

១. គោលការណ៍អធិបតេយ្យភាពសភា

អន្តរជាតិ៖ សភាជាស្ថាប័នតំណាងប្រជាជន និងមានអំណាចធ្វើច្បាប់

តម្លៃខ្មែរ៖ ការគោរពសេចក្តីសម្រេចរួម និងឆន្ទៈប្រជាជន
នៅកម្ពុជា សភាជាស្ថាប័នមានតួនាទីស្នូលក្នុងការកំណត់គោលនយោបាយច្បាប់ ដោយឆ្លុះបញ្ចាំងឆន្ទៈរបស់ប្រជាពលរដ្ឋ។

២. គោលការណ៍ការបែងចែកអំណាច

អន្តរជាតិ៖ Separation of Powers ( Montesquieu )
តម្លៃខ្មែរ៖ ការរារាំងអំពើអំណាចហួសហេតុ និងការរក្សាតុល្យភាព
ការបែងចែកអំណាចរវាង នីតិប្បញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ គឺជាគន្លឹះក្នុងការការពារប្រជាពលរដ្ឋពីការបំពានអំណាច។

៣. គោលការណ៍ការត្រួតពិនិត្យប្រព័ន្ធតុលាការ

អន្តរជាតិ៖ Judicial Review
តម្លៃខ្មែរ៖ យុត្តិធម៌ និងភាពត្រឹមត្រូវ
តុលាការមានតួនាទីធានាថា ច្បាប់ និងសកម្មភាពរដ្ឋ ស្របនឹងរដ្ឋធម្មនុញ្ញ និងគោលការណ៍យុត្តិធម៌។

៤. គោលការណ៍ធម្មនុញ្ញនិយម

អន្តរជាតិ៖ Supremacy of the Constitution
តម្លៃខ្មែរ៖ ការគោរពច្បាប់ជាចម្បង
រដ្ឋធម្មនុញ្ញជាច្បាប់កំពូល ដែលកំណត់ព្រំដែនអំណាចរដ្ឋ និងធានាសិទ្ធិប្រជាពលរដ្ឋ។

៥. គោលការណ៍ Ultra Vires

អន្តរជាតិ៖ Limited Government
តម្លៃខ្មែរ៖ ការទទួលខុសត្រូវរបស់អាជ្ញាធរ
អាជ្ញាធរសាធារណៈអាចប្រើអំណាចបានតែនៅក្នុងវិសាលភាពដែលច្បាប់អនុញ្ញាត បើលើសពីនេះ ត្រូវចាត់ទុកថាមិនស្របច្បាប់។

៦. គោលការណ៍ការរំពឹងទុកស្របច្បាប់

អន្តរជាតិ៖ Legitimate Expectation
តម្លៃខ្មែរ៖ ទំនុកចិត្ត និងភាពស្មោះត្រង់
ប្រជាពលរដ្ឋអាចរំពឹងថា អាជ្ញាធររដ្ឋនឹងអនុវត្តដោយសមហេតុផល សុចរិតភាព និងស្របតាមការសន្យាឬការអនុវត្តជាប្រពៃណី។

៧. គោលការណ៍សមាមាត្រ

អន្តរជាតិ៖ Proportionality
តម្លៃខ្មែរ៖ មធ្យមភាព និងការមិនហួសហេតុ
វិធានការរដ្ឋត្រូវសមាមាត្រទៅនឹងគោលបំណង និងមិនបំពានសិទ្ធិបុគ្គលលើសពីអ្វីដែលចាំបាច់។

៨. គោលការណ៍ផលប្រយោជន៍សាធារណៈ

អន្តរជាតិ៖ Public Interest
តម្លៃខ្មែរ៖ ប្រយោជន៍រួម និងសុខសន្តិភាពសង្គម
អាជ្ញាធររដ្ឋត្រូវដឹកនាំសកម្មភាពរបស់ខ្លួន ដើម្បីបម្រើសង្គមទាំងមូល មិនមែនផលប្រយោជន៍បុគ្គល ឬក្រុមតូចៗឡើយ។

៩. គោលការណ៍អភ័យឯកសិទ្ធិអធិបតេយ្យភាព

អន្តរជាតិ៖ Sovereign Immunity
តម្លៃខ្មែរ៖ ការគោរពស្ថាប័នរដ្ឋ
រដ្ឋមានអភ័យឯកសិទ្ធិជាក់លាក់ ប៉ុន្តែអភ័យឯកសិទ្ធិនេះ ត្រូវអនុវត្តក្រោមដែនកំណត់ និងគោលការណ៍ទំនួលខុសត្រូវ។

១០. គោលការណ៍ដំណើរការត្រឹមត្រូវ

អន្តរជាតិ៖ Due Process of Law
តម្លៃខ្មែរ៖ យុត្តិធម៌ និងការស្តាប់គ្នា
មុនពេលរដ្ឋចាត់វិធានការណាមួយ ដែលប៉ះពាល់ដល់សិទ្ធិបុគ្គល ត្រូវជានាឱកាសស្តាប់ ការការពារខ្លួន និងនីតិវិធីយុត្តិធម៌។
នីតិសាធារណៈកម្ពុជា មានលក្ខណៈជាប្រព័ន្ធច្បាប់បញ្ចូលគ្នា៖
ទទួលយកគោលការណ៍សកល ដូចជា នីតិរដ្ឋ ប្រជាធិបតេយ្យ និងការបញ្ចូលតម្លៃខ្មែរ ដូចជា សាមគ្គីភាព យុត្តិធម៌ ការគោរពអំណាច និងប្រយោជន៍រួម។ ដោយហេតុនេះ នីតិសាធារណៈកម្ពុជា មានបេសកកម្មមូលដ្ឋានក្នុងការគ្រប់គ្រងអំណាចរដ្ឋ ធានាសិទ្ធិប្រជាពលរដ្ឋ និងរក្សាសន្តិភាពនិងស្ថិរភាពសង្គម។

### ១.៤.២ គោលការណ៍នីតិរដ្ឋខ្មែរ

តាមការសិក្សាអំពីឧត្តមានុវត្តន៍អន្តរជាតិ និងបរិការណ៍កម្ពុជា គោលការណ៍នីតិរដ្ឋកម្ពុជា គួរត្រូវបានកំណត់ដូចខាងក្រោម៖

១. នីត្យានុកូលភាព (នីតិកម្មគោរពគោលការណ៍ទាំង៨នៃនីត្យានុកូលភាព និងឋានានុក្រមនៃច្បាប់ ។

២. ភាពស្មើគ្នាចំពោះមុខច្បាប់ (ឧត្តមានុភាពនៃរដ្ឋធម្មនុញ្ញ និង ច្បាប់)

៣. ការដោះស្រាយវិវាទដោយសន្តិវិធី (នយោបាយឈ្នះ-ឈ្នះ វប្បធម៌សន្ទនា និង ផ្អែកតាមច្បាប់ជាធរមាន) = ប្រជាធិបតេយ្យតាមទស្សនវិជ្ជានយោបាយខ្មែរ

៤. អភិបាលកិច្ចល្អ (ស្នូលនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ និង ដំណាក់កាលទី២) និង ជាស្នូល (មុំទី៥) នៃយុទ្ធសាស្ត្របញ្ចកោណ (ការពង្រឹងអភិបាលកិច្ចវិស័យឯកជន និងធុរកិច្ច)

៥. ការគោរពគោលការណ៍អនាគតិ (មិនលម្អៀងព្រោះស្រឡាញ់ មិនលម្អៀងព្រោះស្អប់ មិនលម្អៀងព្រះខ្លាច និង មិនលម្អៀងព្រោះល្ងង់) ។

៦. ការគោរពនិយាមសង្គម (សីលធម៌ និង សុជីវធម៌)៖ ប្រព្រឹត្តសុចរិតធម៌១០ប្រការ ត្រូវប្រកបដោយសប្បុរិសធម៌៧ប្រការ ព្រហ្មវិហារធម៌៤ និង សង្គហធម៌៤ប្រការ = (ការគោរពសិទ្ធិមនុស្សតាមនិយាមសង្គមខ្មែរ) ។



### ១.៤.២.១ ទំនាក់ទំនងក្នុងចំណោមគោលការណ៍រដ្ឋខ្មែរ

**ក. នីត្យានុកូលភាព** (Legality / Rule of Law in Substance)

គោលការណ៍នេះផ្តោតលើភាពស្របច្បាប់ និងការគោរពច្បាប់ និងគោលការណ៍ទាំង៨នៃនីត្យានុកូលភាព។ វាជាគ្រឹះសម្រាប់គោលការណ៍ផ្សេងទៀត ដូចជា ភាពស្មើគ្នាចំពោះច្បាប់ និង ការដោះស្រាយវិវាទដោយសន្តិវិធី ពីព្រោះគ្មានច្បាប់ និងច្បាប់ស្តង់ដាត្រឹមត្រូវ វានឹងកាត់បន្ថយការអនុវត្តគោលការណ៍ទាំងអស់។

**ខ. ភាពស្មើគ្នាចំពោះមុខច្បាប់** (Equality Before Law)

គោលការណ៍នេះពាក់ព័ន្ធជាមួយនីត្យានុកូលភាព ដោយបង្ហាញថា ច្បាប់ត្រូវអនុវត្តស្មើៗគ្នា ទោះមនុស្សមានស្ថានភាពខុសគ្នាយ៉ាងណា។ វាក៏ជាគ្រឹះសម្រាប់ការអភិវឌ្ឍ អភិបាលកិច្ចល្អ និងការដោះស្រាយវិវាទដោយសន្តិវិធី ពីព្រោះការសម្រេចចិត្តត្រូវតែលើកតុល្យភាព និងមិនលម្អៀង។

**គ. ការដោះស្រាយវិវាទដោយសន្តិវិធី** (Dispute Resolution by Peaceful Means)

វាបង្កើតការតស៊ូដោយសន្តិវិធី និងជំរុញប្រជាធិបតេយ្យតាមទស្សនវិជ្ជានយោបាយខ្មែរ។ វាមានទំនាក់ទំនងជិតស្និទ្ធជាមួយភាពស្មើគ្នាចំពោះច្បាប់ និងនីត្យានុកូលភាព ពីព្រោះការដោះស្រាយត្រូវអនុវត្តតាមច្បាប់ និងយុត្តិធម៌ ដើម្បីធានាថាវិវាទទទួលបានការដោះស្រាយយ៉ាងសមស្រប។

**ឃ. អភិបាលកិច្ចល្អ** (Good Governance)

ជាធាតុសំខាន់ដែលសម្របសម្រួលការអនុវត្តគោលការណ៍ទាំងអស់។ ការរួមបញ្ចូលនីត្យានុកូលភាព ភាពស្មើគ្នាចំពោះច្បាប់ និងការដោះស្រាយវិវាទដោយសន្តិវិធី ទៅក្នុងប្រព័ន្ធអភិបាលកិច្ចគឺដើម្បីធានាថាការអនុវត្តច្បាប់មានប្រសិទ្ធភាព និងប្រកបដោយសុចរិតភាព។ អភិបាលកិច្ចនេះទៀតសោតជាស្នូលដល់យុទ្ធសាស្ត្របញ្ចកោណ (Pentagonal Strategy) និងមានទំនាក់ទំនងនឹងការកសាងវប្បធម៌នីតិរដ្ឋនៅកម្ពុជា។

**ង. ការគោរពគោលការណ៍អនាគតិ** (Impartiality / Non-bias)

ភាពស្មើគ្នាចំពោះមុខច្បាប់មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងអភិបាលកិច្ចល្អ ពីព្រោះការលម្អៀងអាចបង្កដល់បញ្ហាស្ថាប័ន និងការអនុវត្តច្បាប់ ដែលនាំឱ្យច្បាប់មិនមានប្រសិទ្ធភាព។ ទំនាក់ទំនងនេះជួយស្ថាបនាអំណាចរដ្ឋដែលមិនលម្អៀង និងធានាថាប្រជាពលរដ្ឋទទួលបានយុត្តិធម៌ស្មើដោយស្មើភាពគ្នា។

### ច. ការគោរពនិយាមសង្គម (Social Morality / Khmer Values)

និយាមសង្គមមានទំនាក់ទំនងជិតស្និទ្ធជាមួយគោលការណ៍ទាំងអស់ ពីព្រោះវាបង្កើតមូលដ្ឋានវប្បធម៌ដែលគាំទ្រនីតិរដ្ឋ។ និយាមសង្គមផ្តល់ស្តង់ដាផ្លូវចិត្តសម្រាប់ការអនុវត្តអភិបាលកិច្ចល្អ ការដោះស្រាយវិវាទដោយសន្តិវិធី និងភាពស្មើគ្នា ព្រមទាំងធានាថាប្រជាពលរដ្ឋគោរពច្បាប់ដោយស្ម័គ្រចិត្ត។

ទំនាក់ទំនងនៃគោលការណ៍ទាំង៦ ដើម្បីធានានីតិរដ្ឋនៅកម្ពុជា៖

- នីត្យានុកូលភាព និង ភាពស្មើគ្នាចំពោះច្បាប់ ជាគ្រឹះសម្រាប់ភាពយុត្តិធម៌។
- ការដោះស្រាយវិវាទដោយសន្តិវិធី និងអភិបាលកិច្ចល្អជួយសម្រួលការអនុវត្តយ៉ាងសមស្រប និងប្រកបដោយប្រសិទ្ធភាព។
- ការគោរពគោលការណ៍អនាគតិ និង និយាមសង្គមខ្មែរ ជួយធានាថាវប្បធម៌នីតិរដ្ឋមានស្ថិរភាព និងទាក់ទាញប្រជាពលរដ្ឋក្នុងការគោរពច្បាប់។

សរុបសេចក្តីមក ទំនាក់ទំនងរវាងគោលការណ៍ទាំងនេះ បង្កើតបានជាប្រព័ន្ធច្បាប់ស្ថិរភាព និងវប្បធម៌នីតិរដ្ឋដែលចងក្រងជាមួយតម្លៃខ្មែរ ដើម្បីធានានីតិរដ្ឋឱ្យមានប្រសិទ្ធភាព និងចីរភាពនៅកម្ពុជា។

### ១.៤.២.២ ការត្រួតពិនិត្យនិងវាយតម្លៃនីតិរដ្ឋខ្មែរ

ស្របតាមឧត្តមានុវត្តន៍អន្តរជាតិផង និងបរិការណ៍កម្ពុជាផង នីតិរដ្ឋកម្ពុជា គួរត្រូវបានត្រួតពិនិត្យ និងវាយតម្លៃ ផ្អែកលើគោលការណ៍នីតិរដ្ឋ ដែលកំណត់ដោយកម្ពុជា ដូចខាងក្រោម៖

#### ក. នីត្យានុកូលភាព

១) គោរពគោលការណ៍នីត្យានុកូលភាព
២) លក្ខខណ្ឌគុណភាពនៃនីត្យានុកូលភាព
៣) ឧត្តមានុភាពគតិយុត្ត
៤) អនុលោមភាពគតិយុត្ត
៥) ករណីយកិច្ចអនុវត្តច្បាប់

#### ខ. ភាពស្មើគ្នាចំពោះមុខច្បាប់

១) គោលការណ៍សមភាពអនុលោមតាមរដ្ឋធម្មនុញ្ញ
២) ការមិនរើសអើងគ្រប់រូបភាព
៣) គោលការណ៍សមធម៌សម្រាប់បុគ្គលរូប (មេធាវីពាជរដ្ឋាកិបាល...)

#### គ. ការដោះស្រាយវិវាទដោយសន្តិវិធី

១) អនុវត្តតាមនយោបាយឈ្នះ-ឈ្នះ
២) គោរពតាមវប្បធម៌សន្ទនា
៣) ការដោះស្រាយវិវាទអនុលោមតាមច្បាប់ជាតិ និងអន្តរជាតិ

#### ឃ. អភិបាលកិច្ចល្អ

១) ឯកសារក្របខ័ណ្ឌច្បាប់
២) ការការពារសិទ្ធិមនុស្ស
៣) ប្រព័ន្ធទទួលខុសត្រូវ
៤) ប្រព័ន្ធយុត្តិធម៌
៥) សមត្ថកិច្ចពង្រឹងការអនុវត្តច្បាប់ដោយមិនលម្អៀង និងមិនពុករលួយ ។

ក្នុងន័យអភិបាលកិច្ចនេះ តើគេអាចសាកល្បងដាក់បញ្ចូលគោលការណ៍ទសពិធរាជធម៌ ១០ ប្រការនៃពុទ្ធសាសនា មកដាក់បញ្ចូលបានដែរឬទេ? ក្នុងន័យនេះ ព្រះមហាក្សត្រខ្មែរសម័យបុរាណ លោកគោរពប្រតិបត្តខ្ជាប់ខ្ជួននូវទសពិធរាជធម៌នេះ ហើយតាមរយៈសិលាចារឹក គេក៏បានឃើញនូវទឹកព្រះទ័យរបស់ទ្រង់ ដោយបានចាត់ទុក "ទុក្ខរបស់រាស្ត្រជាទុករបស់ព្រះមហាក្សត្រ" ។

ក្នុងប្រទេសឥណ្ឌា ដែលជាប្រភពនៃពុទ្ធសាសនា ពាក្យថាក្សត្រ ឬ វណ្ណៈក្សត្រ ពុំមែនសំដៅតែទៅលើក្សត្រដែលសោយរាជ្យនោះទេ។ ពាក្យថាក្សត្រ មានន័យក្នុងឋានៈជាអ្នកដែលមានមុខនាទីក្នុងការគ្រប់គ្រងប្រទេស គ្រប់គ្រងខេត្ត ជាទ័ពចម្បាំង ជាមន្ត្រីរាជការគ្រប់ជាន់ថ្នាក់។ បើនិយាយតាមភាសាបច្ចុប្បន្ន បានដល់រដ្ឋាភិបាល គណៈរដ្ឋមន្ត្រី និង មន្ត្រីរាជការទាំងពួង។

ទសពិធរាជធម៌ មានទាំងអស់ ១០ ប្រការគឺ:

| | |
|---|---|
| ១) ទាន | ការឱ្យ |
| ២) សីល | ការប្រព្រឹត្តល្អ |
| ៣) បរិច្ចាគ | ការបរិច្ចាគ |
| ៤) អាជ្ជវៈ | ការស្មោះត្រង់ |
| ៥) មទ្ទវៈ | ការទន់ភ្លន់ |
| ៦) តបៈ | ការដុតកិលេស |
| ៧) អក្កោធនៈ | ការមិនក្រោធ |
| ៨) អវិហិង្សា | ការមិនបៀតបៀន |
| ៩) ខន្តី | ការអត់ធន់ |
| ១០) អវិរោធនៈ | ការមិនធ្វើខុស ។ |

## ង. ការគោរពគោលការណ៍អនាគតិ
## (យុត្តិធម៌ មិនលម្អៀង)

១) វិនិច្ឆ័យសេចក្តីផ្អែកលើច្បាប់ជាធរមាន
២) ការគោរពក្រមសីលធម៌វិជ្ជាជីវៈ
៣) វិនិច្ឆ័យសេចក្តីដោយប្រាសចាកអគតិធម៌ទាំង៤ មានឆន្ទាគតិ ទោសាគតិ ភយាគតិ និង មោហាគតិ
៤) អនុលោមតាមល្បិចចៅក្រម
៥) សេវាយុត្តិធម៌អាចពិនិត្យបាន និង ឆាប់រហ័ស

## ច. ការគោរពនិយាមសង្គមខ្មែរ

១) គោលការណ៍សីលធម៌ខ្មែរ (គោរពសុចរិតធម៌១០ ប្រការ)

- កាយកម្ម៣
- វចីកម្ម ៤
- មនោកម្ម ៣

២) គោរពសុជីវធម៌ខ្មែរ

សុជីវធម៌បែងចែកជាវត្តបទមាន ៦ គឺ

- ការស្គាល់ហេតុផលគួរមិនគួរ
- ការស្គាល់ឋានៈខ្លួននិងអ្នកដទៃ
- ការស្គាល់ប្រមាណជីវភាព
- ការស្គាល់កាលសម័យ
- ការស្គាល់ប្រជុំជននិងទីប្រជុំ
- ការស្គាល់មិត្តសំឡាញ់ ។[105]

ការគោរពគោលការណ៍សីលធម៌ និងសុជីវធម៌បែបខ្មែរ មានន័យស្មើនឹងការគោរពសិទ្ធិមនុស្ស ការសង្គ្រោះគ្នា ការរាប់អានគ្នាជាភាតរភាព និងមិត្តភាព។

### ១.៤.២.៣ បញ្ហាប្រឈមនីតិរដ្ឋនៅកម្ពុជា

យោងតាមក្របខ័ណ្ឌយុទ្ធសាស្រ្តនៃកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល ច្បាប់និងលិខិតបទដ្ឋានគតិយុត្តគាំទ្រការអនុវត្តច្បាប់ ប្រឈមនឹងបញ្ហាជាសារវន្តដូចខាងក្រោម៖

- សង្គតិភាព នៃមធ្យោបាយតាក់តែងច្បាប់ (ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តមាននិន្នាការប្រែប្រួលទៅតាមទៅតាមជំនួយផ្នែកច្បាប់/ជំនាញការច្បាប់/ប្រព័ន្ធច្បាប់បរទេសដែលមិនទាន់មានឧបករណ៍វាយតម្លៃអំពីសមានគតិភាព (ភាពសមស្រប ឬភាពចាំបាច់រវាងច្បាប់ និងស្ថានភាពសង្គម សេដ្ឋកិច្ច វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ឱ្យបានសមស្រប)។
- បញ្ញានុភាពបទដ្ឋាន ក្រោយបទដ្ឋានត្រូវបានអនុម័ត (ភាពមិនច្បាស់លាស់ខ្លឹមសារនៃបទដ្ឋានដែលនាំឱ្យមានការបកស្រាយខុសៗគ្នាអាស្រ័យទៅតាមទស្សនវិជ្ជាច្បាប់ ខុសៗគ្នានៃប្រព័ន្ធច្បាប់ខុសៗគ្នាមានប្រព័ន្ធច្បាប់ប្រពៃណី ប្រព័ន្ធច្បាប់ស៊ីវិល និងប្រព័ន្ធច្បាប់អង់គ្លូសាក់សុង។
- យន្តការផ្សព្វផ្សាយច្បាប់មិនទាន់មានប្រសិទ្ធភាព និងទូលំទូលាយ និងឌីជីថលូបនីយកម្មផ្លូវការ។
- ប្រសិទ្ធភាពនៃការអនុវត្ត (កង្វះយន្តការដាក់លាក់ ក្នុងការពិនិត្យនិងវាយតម្លៃគុណភាព និងសមានគតិយភាពនៃការតាក់តែង សុក្រឹតភាពនៃការបកស្រាយ ខ្លឹមសារបទដ្ឋានដែលមិនច្បាស់លាស់ និងប្រសិទ្ធភាពនៃការអនុវត្ត។

---

[១០៥] សុង ស៊ីវ, *សុជីវធម៌ប្រចាំគ្រួសារ*, ១៩៦៥, បោះពុម្ពលើកទី២, ១២។

- សមត្ថភាពធនធានមនុស្ស និងអង្គភាពទទួលបន្ទុកការងារច្បាប់/នីតិកម្មនៅមានកម្រិត ទាំងសត្យានុម័ត និងអត្តនោម័តិ។
- កង្វះកិច្ចសហការ និងអន្តរសកម្មរវាងតួអង្គអនុវត្តច្បាប់នានា ស្របតាមអភិក្រមជាគន្លឹះនៃយុទ្ធសាស្ត្របញ្ចកោណគឺ "ជវភាពនៃប្រព័ន្ធតួអង្គតែមួយ" ។
- កង្វះការបង្កើតឧបករណ៍អភិបាលកិច្ចគាំទ្រការអនុវត្តច្បាប់ (កម្រងសម្រង់មគ្គទេសក៍ នីតិសាស្ត្រ អត្ថបទព្រឹត្តិបត្រច្បាប់ អត្ថាធិប្បាយគតិយុត្ត មគ្គទេសក៍ប្រឹក្សាច្បាប់...) ។
- កង្វះប្រព័ន្ធវាយតម្លៃស្ថានភាពនីតិរដ្ឋនៅកម្ពុជា ។

គេអាចសន្និដ្ឋានថា បញ្ហាប្រឈមនៃកិច្ចការច្បាប់នេះមានផលប៉ះពាល់ដល់នីតិរដ្ឋនៅកម្ពុជា ពីព្រោះនីត្យានុកូលភាពជាធាតុសំខាន់នៃនីតិរដ្ឋ។

ហេតុនេះ ក្រៅពីបញ្ហាប្រឈមដែលពាក់ព័ន្ធនឹងច្បាប់និងលិខិតបទដ្ឋានគតិយុត្តគាំទ្រការអនុវត្តច្បាប់ នីតិរដ្ឋប្រឈមនឹងបញ្ហាមួយចំនួន ដូចខាងក្រោមៈ

១. បញ្ហានៃការយល់ដឹងអំពីនិយមន័យ និងខ្លឹមសារនីតិរដ្ឋ

នៅក្នុងការអនុវត្តជាក់ស្តែង គំនិត "នីតិរដ្ឋ" ត្រូវបានយល់ឃើញខុសៗគ្នា ទាំងក្នុងវិស័យច្បាប់ នយោបាយ និងអភិបាលកិច្ច ដែលបង្កឱ្យមានការច្រឡំរវាង "ការគ្រប់គ្រងដោយច្បាប់" និង "នីតិរដ្ឋ" ក្នុងន័យគុណតម្លៃ និងសិទ្ធិមនុស្ស។

២. បញ្ហានៃការបញ្ចូលគោលការណ៍នីតិរដ្ឋសកលទៅក្នុងបរិបទជាតិ

គោលការណ៍នីតិរដ្ឋដែលអភិវឌ្ឍឡើងនៅកម្រិតអន្តរជាតិ និងតំបន់ មិនតែងតែអាចអនុវត្តបានយ៉ាងពេញលេញនៅក្នុងបរិបទវប្បធម៌ សង្គម និងនយោបាយរបស់កម្ពុជា ដែលបង្កើតជាបញ្ហានៃភាពសមស្រប និងប្រសិទ្ធភាពនៃការអនុវត្ត។

៣. បញ្ហានៃការអនុវត្តគោលការណ៍នីតិរដ្ឋក្នុងប្រព័ន្ធស្ថាប័ន

ការបែងចែកអំណាច ឯករាជ្យភាពតុលាការ គណនេយ្យភាព និងភាពស្មើគ្នាចំពោះមុខច្បាប់ នៅតែប្រឈមនឹងឧបសគ្គជាក់ស្តែង ដែលប៉ះពាល់ដល់ការអនុវត្តនីតិរដ្ឋនៅកម្ពុជា។

៤. បញ្ហានៃគម្លាតរវាងច្បាប់ និងការអនុវត្ត (Law in books vs. Law in action)

ទោះបីមានក្របខ័ណ្ឌច្បាប់គ្រប់គ្រាន់ក៏ដោយ ការអនុវត្តច្បាប់ជាក់ស្តែង មិនតែងតែស្របតាមគោលការណ៍នីតិរដ្ឋ ដោយសារកត្តាស្ថាប័ន វប្បធម៌ច្បាប់ និងអភិបាលកិច្ច។

៥. បញ្ហានៃការវាយតម្លៃ និងវាស់វែងនីតិរដ្ឋ

នៅកម្ពុជា នៅតែមានកម្រិតកំណត់ក្នុងការប្រើប្រាស់សូចនាករ និងយន្តការវាយតម្លៃនីតិរដ្ឋ ដែលអាចបង្ហាញយ៉ាងច្បាស់ពីស្ថានភាពពិត និងបញ្ហាចម្បងនៃការអនុវត្តនីតិរដ្ឋ។

៦. បញ្ហាកង្វះវប្បធម៌នីតិរដ្ឋក្នុងសង្គម

ការគោរពច្បាប់ និងការយល់ដឹងអំពីសិទ្ធិ និងកាតព្វកិច្ចនៅតែមានកម្រិត ដែលបង្ហាញពីការកង្វះវប្បធម៌នីតិរដ្ឋទាំងនៅកម្រិតស្ថាប័ន និងកម្រិតប្រជាពលរដ្ឋ។

៧. បញ្ហានៃការរចនាយុទ្ធសាស្ត្រសាបព្រោះនីតិរដ្ឋ

នៅតែមានសំណួរថា តើយុទ្ធសាស្ត្រ និងយន្តការណាខ្លះ អាចមានប្រសិទ្ធភាពក្នុងការសាបព្រោះ និងកសាងវប្បធម៌នីតិរដ្ឋនៅកម្ពុជា ដោយសមស្របនឹងបរិបទជាតិ និងស្តង់ដារអន្តរជាតិ។

ដំណោះស្រាយ៖ ខាងក្រោមនេះជាសំណើ ដំណោះស្រាយជាប្រព័ន្ធ និងជាក់ស្តែង ចំពោះបញ្ហាប្រឈមនីតិរដ្ឋនៅកម្ពុជា ដោយផ្អែកលើ គោលនយោបាយរាជរដ្ឋាភិបាលកម្ពុជា បទពិសោធន៍អន្តរជាតិ និងបរិបទជាតិ (Cambodian context–sensitive approach)៖

**ដំណោះស្រាយចំពោះបញ្ហាច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត**

១. កែលម្អគុណភាពនៃការតាក់តែងច្បាប់ (Law-making quality)

- បង្កើតយន្តការវាយតម្លៃផលប៉ះពាល់ច្បាប់ (Regulatory Impact Assessment – RIA) ជាចាំបាច់ មុនពេលអនុម័តច្បាប់ និងបទដ្ឋាន។
- បញ្ចូលការវាយតម្លៃ៖
  - ភាពសមស្របនឹងសង្គម–សេដ្ឋកិច្ច–វប្បធម៌
  - ភាពចាំបាច់ និងសមាមាត្រ
- ពង្រឹងតួនាទីក្រុមការងារព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត និងអ្នកជំនាញការជាតិ ដើម្បីកាត់បន្ថយការពឹងផ្អែកលើគំរូច្បាប់បរទេស។
- គំរូអន្តរជាតិ៖ OECD, EU Better Regulation Agenda
- សមស្របនឹងគោលនយោបាយកម្ពុជា៖ យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ និងក្របខណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល។

២. កាត់បន្ថយភាពមិនច្បាស់លាស់នៃបទដ្ឋានក្រោយអនុម័ត

- បង្កើតមគ្គុទេសក៍សីល្បសាស្ត្រនីតិកម្មដោយរួមបញ្ចូលវិធីសាស្ត្រនៃការបកស្រាយច្បាប់ផ្លូវការ (Official Interpretative Guidelines)
- ពង្រឹងតួនាទីតុលាការកំពូល និងក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងការបកស្រាយគោលការណ៍។

- បណ្តុះបណ្តាលមន្ត្រីច្បាប់អំពីទស្សនវិជ្ជាច្បាប់រួម ( hybrid legal reasoning ) សម្រាប់ប្រព័ន្ធច្បាប់ចម្រុះរបស់កម្ពុជា។

៣. កែលម្អការផ្សព្វផ្សាយច្បាប់ និងឌីជីថលូបនីយកម្ម

- បង្កើតវេទិកាឌីជីថលច្បាប់ជាតិ ( National Legal Portal ) រួមមាន៖
  - ច្បាប់ថ្មីៗ
  - សេចក្តីពន្យល់
  - មគ្គុទេសក៍អនុវត្តន៍ច្បាប់។
- ផ្សព្វផ្សាយច្បាប់តាមភាសាសាមញ្ញ ( plain legal language )
- បញ្ចូលច្បាប់ជាមុខវិជ្ជាចាំបាច់ក្នុងការអប់រំនៅតាមគ្រឹះស្ថានសិក្សា និងបណ្តុះបណ្តាល។

៤. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តច្បាប់

- បង្កើត ប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តច្បាប់ ( Law Implementation Review Mechanism )
- ភ្ជាប់ការវាយតម្លៃទៅនឹង៖
  - គណនេយ្យភាព
  - វិន័យរដ្ឋបាល
  - លទ្ធផលអនុវត្តន៍។

៥. អភិវឌ្ឍសមត្ថភាពធនធានមនុស្ស

- បណ្តុះបណ្តាលជាបន្តបន្ទាប់ ( Continuous Legal Education )
- បង្កើតវិជ្ជាជីវៈនីតិកម្មជាតិ ( National Legal Profession Standards )
- ភ្ជាប់ការតម្លើងតំណែងទៅនឹងគុណាធិបតេយ្យ។

៦. ពង្រឹងកិច្ចសហការ និងអន្តរសេកម្ម

- អនុវត្តអភិក្រមជវភាពនៃប្រព័ន្ធតួអង្គតែមួយ
- បង្កើតវេទិកាអន្តរស្ថាប័នផ្នែកនីតិរដ្ឋ
- ប្រើបច្ចេកវិទ្យាឌីជីថលសម្រាប់ការចែករំលែកព័ត៌មានច្បាប់។

៧. បង្កើតឧបករណ៍អភិបាលកិច្ចគាំទ្រច្បាប់

- បង្កើត និងគាំទ្រ៖
  - ទស្សនាវដ្តីច្បាប់ជាតិ
  - អត្ថាធិប្បាយច្បាប់
  - មគ្គុទេសក៍ប្រឹក្សាច្បាប់
- លើកទឹកចិត្តការស្រាវជ្រាវច្បាប់ជាតិ ( indigenous legal scholarship )

៨. បង្កើតប្រព័ន្ធវាយតម្លៃនីតិរដ្ឋនៅកម្ពុជា

- បង្កើត Cambodia Rule of Law Index ដែលផ្អែកលើ៖
  - សូចនាករអន្តរជាតិ (អាចគំរូសហភាពអឺរ៉ុប)
  - ទិន្នន័យជាតិ និងបទពិសោធន៍មូលដ្ឋាន
- ប្រើសូចនាករនេះសម្រាប់គោលនយោបាយ និងកែទម្រង់។

ដំណោះស្រាយចំពោះបញ្ហាគោលនយោបាយ និងវប្បធម៌នីតិរដ្ឋ

១. សម្រួបនិយមន័យ និងការយល់ដឹងអំពីនីតិរដ្ឋ

បង្កើតនិយមន័យជាតិអំពី "នីតិរដ្ឋ" ដែលរួមបញ្ចូល៖

ច្បាប់

សិទ្ធិមនុស្ស

គុណតម្លៃសង្គមខ្មែរ

- បញ្ចូលក្នុងគោលនយោបាយ និងការអប់រំ។

២. សម្របគោលការណ៍សកលទៅបរិបទជាតិ

អនុវត្ត Contextualized Rule of Law Approach ពោលគឺ មិនយកគំរូអន្តរជាតិមកអនុវត្តដោយផ្ទាល់ទេ តែសម្របទៅនឹងប្រពៃណី និងស្ថានភាពជាក់ស្តែង។

៣. ពង្រឹងស្ថាប័ន និងការបែងចែកអំណាច

- ពង្រឹងឯករាជ្យភាពតុលាការ តាមរយៈ៖

គណនេយ្យភាព

សេចក្តីថ្លៃថ្នូរ

សមត្ថភាពវិជ្ជាជីវៈ

- កែលម្អយន្តការត្រួតពិនិត្យអំណាចដោយអនុវត្តតាមច្បាប់ជាធរមាន។

៤. កាត់បន្ថយគម្លាត "ច្បាប់លើក្រដាស vs ច្បាប់ក្នុងជីវិត"

- បង្កើត Law-in-Action Monitoring
- ប្រើទិន្នន័យអនុវត្តជាក់ស្តែងក្នុងការកែសម្រួលច្បាប់។

៥. កសាងវប្បធម៌នីតិរដ្ឋ

- អប់រំសិទ្ធិ និងកាតព្វកិច្ចស៊ីវិល
- លើកទឹកចិត្តការគោរពច្បាប់តាមគំរូវិជ្ជមាន (role model governance)

៦. បង្កើតយុទ្ធសាស្ត្រសាបព្រោះនីតិរដ្ឋ

- បង្កើតយុទ្ធសាស្ត្រជាតិស្តីពីវប្បធម៌នីតិរដ្ឋដោយភ្ជាប់នឹង៖
  - គោលនយោបាយ
  - ច្បាប់
  - ការអប់រំ
  - សង្គមស៊ីវិល

ជារួម នីតិរដ្ឋនៅកម្ពុជាមិនអាចផ្អែកតែការកែទម្រង់ច្បាប់ទេ ប៉ុន្តែត្រូវជាការកែទម្រង់ប្រព័ន្ធវប្បធម៌ និងអភិបាលកិច្ចទាំងមូល។ នីតិរដ្ឋនឹងក្លាយជាវប្បធម៌សង្គម មិនមែនត្រឹមតែគោលការណ៍ច្បាប់ ប្រសិនបើមានការរួមចំណែកពី រដ្ឋ (ស្ថាប័នបនានា) និងប្រជាពលរដ្ឋ ដោយសមស្របនឹងបរិបទកម្ពុជា និងស្តង់ដារអន្តរជាតិ។

## ១.៥. ធាតុផ្សំ "រចនាសម្ព័ន្ធ" នៃប្រព័ន្ធច្បាប់កម្ពុជា

ក្នុងចំណោមធាតុផ្សំសំខាន់ៗនៃប្រព័ន្ធច្បាប់ ក្នុងនោះ**រចនាសម្ព័ន្ធ** គឺជាធាតុផ្សំមួយដ៏សំខាន់។ រចនាសម្ព័ន្ធនៅទីនេះសំដៅដល់ស្ថាប័ននិងតួអង្គក្នុងវិស័យច្បាប់។ អត្ថបទនេះសិក្សាអំពីទ្រឹស្តីនិងគោលគំនិតនៃរចនាសម្ព័ន្ធច្បាប់ វិភាគអំពីតួនាទីស្ថាប័ននិងតួអង្គក្នុងវិស័យច្បាប់នៅកម្ពុជានិងទំនាក់ទំនងរបស់ស្ថាប័នទាំងនេះ សិក្សាអំពីឧត្តមានុវត្តន៍អន្តរជាតិ និងលើកអនុសាសន៍ក្នុងការរៀបចំស្ថាប័នប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងអភិបាលកិច្ចល្អ។

### ១.៥.១ ទ្រឹស្តី និងគោលគំនិតនៃរចនាសម្ព័ន្ធច្បាប់

គោលគំនិតនៃរចនាសម្ព័ន្ធច្បាប់ អាចត្រូវបានបកស្រាយផ្អែកតាមទស្សនវិជ្ជាផ្សេងៗពីគ្នា។ ក្នុងនោះ **លោក H. L. A. HART** ទស្សនវិទូផ្នែកច្បាប់ ជនជាតិអង់គ្លេស បានពន្យល់អំពីរបៀបដំណើរការនៃប្រព័ន្ធច្បាប់ តាមរយៈការកំណត់អត្តសញ្ញាណនៃវិធានច្បាប់និងស្ថាប័ន ដែលមានអំណាចក្នុងការបង្កើត ការកែប្រែ និងការអនុវត្តច្បាប់។ បន្ថែមពីលើនេះ **លោក NEIL MACCORMICK** ជាទស្សនវិទូផ្នែកច្បាប់ ជនជាតិស្កុតឡែន បានអភិវឌ្ឍបន្ថែមលើទស្សនៈនេះដោយកំណត់និយមន័យច្បាប់ថាជា បទបញ្ជាបទដ្ឋានស្ថាប័ន (Institutional Normative Order) និងផ្តោតលើតួនាទីរបស់តុលាការ ការិយាល័យ និងការអនុវត្តហេតុផលផ្នែកច្បាប់។ ចំណែក ទស្សនៈសង្គមវិទ្យារបស់**លោក NIKLAS LUHMANN** យល់ថា ច្បាប់ ជាប្រព័ន្ធសង្គមដែលពឹងផ្អែកលើខ្លួនឯង (Self-referential Social System) ហើយផ្តោតសំខាន់លើរបៀបដែលច្បាប់ដំណើរការនៅក្នុងសង្គម ជាជាងផ្តោតលើទ្រឹស្តីឬលទ្ធិនីតិវិធីច្បាប់តែមួយប៉ុណ្ណោះ។ បន្ថែមពីនេះទៀត **លោក LUDWIG VON BERTALANFFY** ជីវវិទូជនជាតិអូទ្រីសនិងទ្រឹស្តីករផ្នែកប្រព័ន្ធ បានបង្កើតទ្រឹស្តីប្រព័ន្ធទូទៅ (General Systems Theory ឬ GST) ដែលជាក្របខ័ណ្ឌវិភាគអន្តរវិស័យ (Cross-Disciplinary) សម្រាប់ការសិក្សាប្រព័ន្ធដែលមានលក្ខណៈស្មុគស្មាញ។ ទោះបីជាការវិភាគរបស់**លោក BERTALANFFY** មិនសិក្សាដោយផ្ទាល់អំពីស្ថាប័នច្បាប់ក៏ដោយ ប៉ុន្តែការសិក្សានេះនឹងប្រើដើម្បីជាគោលគំនិត នឹងត្រឹមតែជាឧបករណ៍ដើម្បីវិភាគ (Analytical Lens) ក្នុងគោលបំណងបង្ហាញឱ្យឃើញពីការពាក់ព័ន្ធគ្នា និងអន្តរកម្មរវាងស្ថាប័នប៉ុណ្ណោះ។

### ១.៥.២ ទ្រឹស្តីរបស់លោក H.L.A. HART

ទ្រឹស្តីរបស់លោក **H.L.A. HART** បានបង្កប់អត្ថន័យថា នៅក្រោមករូបភាពនៃការបង្កើតច្បាប់ ស្ថាប័នត្រូវបានបង្កើតឡើងដោយច្បាប់ និងមានស្ថានភាពផ្លូវច្បាប់តាមរយៈច្បាប់។[១០៦] ជាក់ស្តែង ស្ថាប័ន

[១០៦] H.L.A HART, The Concept of Law (Oxford: Clarendon Law Series, ១៩៦១), p៥.

ទាំងនេះត្រូវបានបង្កើតឡើងតាមរយៈវិធានច្បាប់បន្ទាប់បន្សំ (secondary rules)។ លោក Hart បានពន្យល់ថា ប្រព័ន្ធច្បាប់ដែលមានការអភិវឌ្ឍពេញលេញ មិនអាចមានតែវិធានច្បាប់ចម្បង (primary rules) តែប៉ុណ្ណោះទេ ប៉ុន្តែត្រូវការច្បាប់បន្ទាប់បន្សំផងដែរ។ វិធានច្បាប់ចម្បង ជាបទប្បញ្ញត្តិដែលកំណត់កាតព្វកិច្ចដល់បុគ្គល ដូចជាការត្រូវគោរពច្បាប់។ ចំណែកឯវិធានច្បាប់បន្ទាប់បន្សំ គឺជាបទប្បញ្ញត្តិដែលកំណត់របៀបកំណត់អត្តសញ្ញាណ កែប្រែ និងអនុវត្តវិធានច្បាប់ចម្បងទាំងនេះ។ វិធានច្បាប់បន្ទាប់បន្សំមានមុខងារដោះស្រាយបញ្ហាលើភាពមិនច្បាស់លាស់ (uncertainty) មិនអាចកែប្រែបាន (rigidity) និងគ្មានប្រសិទ្ធភាពនៅក្នុងការអនុវត្ត (inefficiency) ដែលកើតមាននៅក្នុងសង្គម។ លោក HART បានកំណត់ប្រភេទនៃវិធានច្បាប់បន្ទាប់បន្សំចំនួនបីរួមមាន វិធាននៃការទទួលស្គាល់ (rules of recognition)[១០៧] វិធាននៃការផ្លាស់ប្តូរ (rules of change) និងវិធាននៃការវិនិច្ឆ័យ (rules of adjudication)។ ជាក់ស្តែង វិធាននៃការវិនិច្ឆ័យ (rules of adjudication) និងវិធាននៃការផ្លាស់ប្តូរ (rules of change) បង្ហាញពីរបៀបដែលស្ថាប័នច្បាប់ត្រូវបានបង្កើត និងដំណើរការនៅក្នុងប្រព័ន្ធច្បាប់។ រួមគ្នា វិធានទាំងនេះ បម្លែងវិធានសង្គមសាមញ្ញទៅជាប្រព័ន្ធច្បាប់ទំនើប។ ឧទាហរណ៍ វិធាននៃការវិនិច្ឆ័យតុលាការ ដើម្បីកំណត់ថាតើវិធានណាត្រូវបានបំពាន ហើយវិធាននៃការផ្លាស់ប្តូរ បង្កើតស្ថាប័នដែលមានសិទ្ធិអំណាចក្នុងការបង្កើតច្បាប់ថ្មី[១០៨]។

### ១.៥.៣ ទ្រឹស្តីរបស់លោក NEIL MACCORMICK

ស្ថាប័នច្បាប់ (Institution of Law) សំដៅទៅលើលក្ខណៈទូទៅនៃច្បាប់ជាបទបញ្ញាបទដ្ឋានផ្លូវការ ផ្តល់សិទ្ធិអំណាចនិងជាប្រព័ន្ធ។ លោក Neil MacCormick បានកំណត់និយមន័យច្បាប់ និង"បទបញ្ញាបទដ្ឋានស្ថាប័ន"[១០៩] ដែលជាស្ថាប័នច្បាប់ គឺជាសមាសធាតុសំខាន់នៃប្រព័ន្ធវិធានផ្លូវការដែលត្រូវបានគ្រប់គ្រងដោយស្ថាប័នមួយចំនួនដូចជាតុលាការ ស្ថាប័ននីតិបញ្ញត្តិ និងកងកម្លាំងនគរបាល។[១១០] ទិដ្ឋភាព "ស្ថាប័ន" ដំណើរការនៃការធ្វើឱ្យបទបញ្ញាមានលក្ខណៈច្បាស់លាស់ និងមានលក្ខណៈផ្លូវការ ដោយផ្លាស់ប្តូរលើសពីអនុសញ្ញាទូទៅ (mere convention)។ ស្ថាប័នមិនគួរត្រូវបានកំណត់ដែនកំណត់ត្រឹមតែជាអង្គការ (organization) ប៉ុណ្ណោះទេ ប៉ុន្តែអាចត្រូវបានចាត់ថ្នាក់តាមរយៈភ្នាក់ងារស្ថាប័ន (institutional

---

[១០៧] H.L.A HART, The Concept of Law (Oxford: Clarendon Law Series, ១៩៦១), I. *The Rule of Recognition*.

[១០៨] H.L.A HART, The Concept of Law (Oxford: Clarendon Law Series, ១៩៦១), p៣.

[១០៩] Neil MacCormick, Institutions of Law (OUP Oxford, ២០០៧), p១ & p១០.

[១១០] Neil MacCormick, Institutions of Law (OUP Oxford, ២០០៧), p ១២, p៣៥.

agencies)[១១១] ការរៀបចំស្ថាប័ន (institutional arrangements)[១១២] និងកិច្ចការស្ថាប័ន (institutional things) ផងដែរ[១១៣]។ ស្ថាប័នច្បាប់ជាក់លាក់មួយ ត្រូវបានកំណត់ដោយវិធានរចនាសម្ព័ន្ធបីផ្នែក រួមមាន វិធានបង្កើត (institutive rules)[១១៤] វិធានផលវិបាកផ្លូវច្បាប់ (consequential rules)[១១៥] និងវិធានបញ្ចប់ ឬលុបចោល (terminative rules)[១១៦]។ សរុបមក ស្ថាប័នច្បាប់ គឺជាផ្នែកស្នូលមួយ ឬជាធាតុស្ថាបនាមូលដ្ឋានដ៏ជាក់ស្តែងមួយនៃប្រព័ន្ធច្បាប់ទាំងមូល។

### ១.៥.៤ ទ្រឹស្តីរបស់លោក NIKLAS LUHNAM

ស្ថាប័នច្បាប់ ដូចជាតុលាការ ដើរតួជាអ្នកធ្វើការសម្រេចចិត្តដែលមានសិទ្ធិអំណាចនៅក្នុងប្រព័ន្ធច្បាប់។[១១៧] នៅពេលដែលមានការខ្វែងគំនិតគ្នាអំពីបញ្ហាផ្លូវច្បាប់ជាក់ស្តែង តុលាការមានសិទ្ធិនៅក្នុងការធ្វើសេចក្តីសម្រេចចុងក្រោយ។[១១៨] សេចក្តីសម្រេចរបស់តុលាការត្រូវតែគោរព និង អនុវត្តជាយុត្តសាស្ត្រ ឬច្បាប់ចុងក្រោយដែលមានអនុភាព រហូតដល់មានការផ្លាស់ប្តូរដោយអាជ្ញាធរជាន់ខ្ពស់ ឬដោយច្បាប់។ តួនាទីនេះ ធានាបានថា ច្បាប់រក្សាបាននូវសណ្តាប់ធ្នាប់សង្គម ស្ថិរភាព និងភាពប្រាដកប្រជានៅក្នុងប្រព័ន្ធច្បាប់។

### ១.៥.៥ ទ្រឹស្តីរបស់លោក LUDWING WON BERTALANFFY

ទ្រឹស្តីប្រព័ន្ធទូទៅ (General Systems Theory – GST) របស់លោក LUDWIG VON BERTALANFFY គឺជាក្របខ័ណ្ឌវិភាគអន្តរវិស័យដែលសិក្សាជា "ប្រព័ន្ធ" ជាជាងការមើលឃើញផ្នែកដាច់ដោយឡែកពីគ្នា។ GST អះអាងថា បាតុភូតជាច្រើន មិនថានៅក្នុងជីវវិទ្យា រូបវិទ្យា វិស្វកម្ម ឬវិទ្យាសាស្ត្រសង្គមទេ សុទ្ធតែមានគោលការណ៍រៀបចំស្ថាប័នរួមគ្នា ទោះបីសមាសធាតុរបស់វាខុសគ្នាក៏ដោយ។ គំនិតស្នូលមួយនៃ GST គឺ «ភាពជារួម» (wholeness) ដែលមានន័យថា ប្រព័ន្ធមួយមិនអាចត្រូវបានយល់ដឹងពេញលេញ តាមរយៈការបូកបញ្ចូលផ្នែកដាច់ដោយឡែករបស់វាបានទេ ពីព្រោះអន្តរកម្មរវាងផ្នែកទាំង

---

[១១១] Neil MacCormick, Institutions of Law (OUP Oxford, ២០០៧), p៣៥.

[១១២] Ibid.

[១១៣] Neil MacCormick, Institutions of Law (OUP Oxford, ២០០៧), p៣៦.

[១១៤] Ibid.

[១១៥] Ibid.

[១១៦] Ibid.

[១១៧] Neil MacCormick, Institutions of Law (OUP Oxford, ២០០៧), p ២០២.

[១១៨] Neil MacCormick, Institutions of Law (OUP Oxford, ២០០៧), p ២៥២-២៥៤.

នោះ បង្កើតលក្ខណៈថ្មីៗដែលមិនមាននៅក្នុងផ្នែកនីមួយៗ។ លោក BERTALANFFY ក៏បានសង្កត់ធ្ងន់លើលក្ខណៈរួមគ្នានៃច្បាប់ (isomorphism of laws) មានន័យថាលំនាំនិងគម្រូរចនាសម្ព័ន្ធស្រដៀងគ្នាអាចត្រូវបានរកឃើញនៅទូទាំងវិស័យផ្សេងៗគ្នា។ គោលគំនិតសំខាន់មួយទៀតគឺប្រព័ន្ធបើកចំហ គឺប្រព័ន្ធពិតប្រាកដភាគច្រើនផ្លាស់ប្តូរបញ្ហា ថាមពល ឬព័ត៌មានជាបន្តបន្ទាប់ជាមួយបរិស្ថានរបស់ពួកគេ ហើយអាចរក្សាលំនឹងតាមរយៈតុល្យភាពថាមវន្ត ជាជាងលំនឹងថេរ។ ប្រព័ន្ធបែបនេះច្រើនតែបង្ហាញពីសមភាព (equifinality) ពួកគេអាចឈានដល់លទ្ធផលដូចគ្នាតាមរយៈផ្លូវផ្សេងៗគ្នា ហើយពួកគេគ្រប់គ្រងខ្លួនឯងតាមរយៈយន្តការមតិត្រឡប់ (feedback mechanisms)។ ដូច្នេះ GST លើកកម្ពស់វិធីនៃការគិតដ៏ទូលំទូលាយនិងថាមវន្តដែលមានប្រយោជន៍ ជាពិសេសសម្រាប់ការវិភាគប្រព័ន្ធស្មុគស្មាញមានការរៀបចំ និងប្រទាក់ក្រឡាគ្នា។ លោក BERTALANFFY អះអាងថាសារពាង្គកាយជីវសាស្ត្រគឺជាប្រព័ន្ធបើកចំហ ដែលរក្សាលំនឹងតាមរយៈដំណើរការថាមវន្ត (dynamic processes) មតិត្រឡប់ (feedback) ការគ្រប់គ្រង (regulation) និងការសម្របខ្លួន (adaptation) មិនមែនតាមរយៈតុល្យភាពថេរឡើយ (static balance)។

ដំណើរកាថាមវន្តមានន័យថា ប្រព័ន្ធជីវមានជីវិតមាននៅក្នុងលំហូរសកម្មភាពជាបន្តបន្ទាប់ ដូចជាការទទួលចូលនិងបញ្ចេញចេញ ការបង្កើតនិងការបំបែកសមាសធាតុ ស្របពេលដែលវានៅតែអាចរក្សាស្ថានភាពស្ថិរភាពទូទៅ (steady state) បាន។[១១៩] មតិត្រឡប់ សំដៅទៅលើយន្តការដែលអនុញ្ញាតឱ្យប្រព័ន្ធត្រួតពិនិត្យឥរិយាបថនិងកែសម្រួលសកម្មភាពរបស់ខ្លួន និងធ្វើឱ្យប្រព័ន្ធអាចកំណត់គោលដៅ និងអាចគ្រប់គ្រងខ្លួនឯងបាន ដូចដែលឃើញក្នុងការគ្រប់គ្រងជីវសាស្ត្រ និងប្រព័ន្ធបច្ចេកវិទ្យា។[១២០] ការគ្រប់គ្រង ពិពណ៌នាអំពីសមត្ថភាពរបស់ប្រព័ន្ធក្នុងការគ្រប់គ្រងខ្លួនឯង (self-regulation) ជាពិសេសក្នុងការរក្សាប្រព័ន្ធរំលាយអាហារនិងគ្រប់គ្រងសារពាង្គកាយ ទោះបីមានការផ្លាស់ប្តូរជានិច្ចនៅក្នុងសមាសធាតុខាងក្នុងក៏ដោយ ជាមួយនឹងមុខងារសមភាពដែលជាប្រព័ន្ធគ្រប់គ្រងដ៏សំខាន់។ ការសម្របខ្លួនសំដៅ

---

[១១៩] Ludwing von Bertalanffy, General System Theory: Foundation, Development, Applications (New York, N.Y. ១០០១៦: George Braziller, ១៩៦៨), p២៤, p២៥, p៤៣, p២៩, p១៣៤.

[១២០] Ludwing von Bertalanffy, General System Theory: Foundation, Development, Applications (New York, N.Y. ១០០១៦: George Braziller, ១៩៦៨), p១២៤, p១៣១, p១៤២.

ទៅដល់សមត្ថភាពរបស់ប្រព័ន្ធបើកក្នុងការកែប្រែនិងឆ្លើយតបនឹងលក្ខខណ្ឌឬបរិយាកាសថ្មីៗ ដោយប្រើការមេតិត្រឡប់និងសមភាពដើម្បីឈានដល់លទ្ធផលដែលមានស្ថិរភាពតាមរយៈផ្លូវផ្សេងៗគ្នា។[១២១]

### ១.៥.៦ ទ្រឹស្តីរបស់លោក LAWRENCE M. FRIEDMAN

លោក LAWRENCE M. FRIEDMAN មានទស្សនៈថា ស្ថាប័នច្បាប់មិនមែនជាអង្គភាពឯករាជ្យ និងបិតថេរទេ ប៉ុន្តែជាផ្នែកសំខាន់នៃប្រព័ន្ធច្បាប់ដែលខ្លួនវាជាប្រព័ន្ធសង្គមដែលមានទំនាក់ទំនងយ៉ាងស៊ីជម្រៅជាមួយរចនាសម្ព័ន្ធសង្គមផ្សេងទៀត។[១២២] លោក FRIEDMAN ចាត់ទុកស្ថាប័នច្បាប់ថាជាអង្គភាពប្រតិបត្តិការដែលមានព្រំដែនច្បាស់លាស់ ដែលជាសំណុំនៃអន្តរកម្ម ឬអាកប្បកិរិយា ជាជាងគ្រាន់តែជារចនាសម្ព័ន្ធរូបវន្ត។ [១២៣] ស្ថាប័នច្បាប់ត្រូវបានបង្កប់ដោយឥទ្ធិពលពីប្រព័ន្ធសង្គមផ្សេងទៀត។ ស្ថាប័នច្បាប់ត្រូវបានសម្រួចដោយកម្លាំងសង្គម ផលប្រយោជន៍និងតម្រូវការដែលសង្កត់លើពួកគេ។ ពួកគេមិនធ្វើប្រតិបត្តិការដោយស្វ័យប្រវត្តិទេ ប៉ុន្តែឆ្លុះបញ្ចាំងពីបំណងប្រាថ្នា និងអំណាចរបស់កម្លាំងសង្គមទាំងនោះដែលកំពុងទទួលរងសម្ពាធ។ ជាតុចូលដែលពួកគេទទួលបាន ដូចជាការប្តឹងផ្តល់និងការចាប់ខ្លួន។ ស្ថាប័ននេះបង្កើត សកម្មភាពស្របច្បាប់ដែលជាអាកប្បកិរិយាជាក់លាក់ដោយតួអង្គអាជ្ញាធរនៅក្នុងប្រព័ន្ធ។ សកម្មភាពទាំងនេះអាចជាការសម្រេចចិត្ត ការបញ្ជា ឬវិធានទូទៅ ដែលត្រូវបានប្រាស្រ័យទាក់ទងជាមួយ ឬដាក់លើមនុស្សនៅក្នុងសង្គម រួមទាំងការរក្សាគុណតម្លៃ ការដោះស្រាយវិវាទ ការគ្រប់គ្រងសង្គម ការបង្កើតបទដ្ឋាន ទម្លាប់និងការរក្សាកំណត់ត្រា។ វប្បធម៌គោរពច្បាប់ផ្ទៃក្នុងរបស់អ្នកវិជ្ជាជីវៈនៅក្នុងស្ថាប័នទាំងនេះ (គុណតម្លៃ មនោគមវិជ្ជា និងគោលការណ៍) ប៉ះពាល់យ៉ាងខ្លាំងដល់គម្រូនៃតម្រូវការនិងរបៀបដែលប្រព័ន្ធដំណើរការ។ វប្បធម៌នេះ ជាលទ្ធផលបន្សល់ទុកនូវរចនាសម្ព័ន្ធសង្គមរយៈពេលវែងដែលតំណាងឱ្យអំណាចនិងឥទ្ធិពលចាស់។

ជាខ្លឹមសារ សម្រាប់លោក FRIEDMAN ស្ថាប័នច្បាប់គឺជាធាតុផ្សំថាមវន្តនិងអន្តរកម្មនៃសង្គមដែលអត្ថិភាព ទម្រង់ និងមុខងាររបស់វាត្រូវបានសម្រួចជាបន្តបន្ទាប់និងឆ្លើយតបទៅនឹងបរិយាកាសសង្គម សេដ្ឋកិច្ច និងវប្បធម៌ ជាជាងស្ថាប័នមានលក្ខណៈដាច់ដោយឡែកពីគេ។

---

[១២១] Ludwing von Bertalanffy, General System Theory: Foundation, Development, Applications (New York, N.Y. ១០០១៦: George Braziller, ១៩៦៨), p៤០, p៤៦, p៧៩, p១៣១.

[១២២] Lawrence M Friedman, The Legal System (Russell Sage Foundation, ១៩៧៥), p១១.

[១២៣] Lawrence M Friedman, The Legal System (Russell Sage Foundation, ១៩៧៥), p៥.

### ១.៥.៧ ស្ថាប័ន និងតួអង្គក្នុងវិស័យច្បាប់នៅកម្ពុជា

ព្រះរាជាណាចក្រកម្ពុជាអនុវត្តនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស។ ប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន ។ អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួន តាមរយៈរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាលនិងសាលាជំរះក្តី។ អំណាចបែងចែកដាច់ពីគ្នារវាង **អំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិនិងអំណាចតុលាការ**។[១២៤] ក្នុងន័យនេះ រដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជាបង្កើតឱ្យមានប្រព័ន្ធត្រីភាគីនៃអំណាច ដែលក្នុងអំណាចនីតិបញ្ញត្តិមាន**រដ្ឋសភានិងព្រឹទ្ធសភា**, អំណាចនីតិប្រតិបត្តិមាន**រាជរដ្ឋាភិបាល គណៈរដ្ឋមន្ត្រី ក្រសួងស្ថាប័នពាក់ព័ន្ធ (រដ្ឋបាលថ្នាក់ជាតិ) និងរដ្ឋបាលថ្នាក់ក្រោមជាតិ**, និងអំណាចតុលាការមាន**តុលាការកំពូល សាលាឧទ្ធរណ៍និងសាលាដំបូង**។ ក្រៅពីនេះ មានស្ថាប័នសំខាន់ៗផ្សេងទៀតដែលរួមចំណែកគាំទ្រដំណើរការនៃប្រព័ន្ធកម្ពុជា រួមមាន**ក្រុមប្រឹក្សាធម្មនុញ្ញ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្រុមប្រឹក្សាអ្នកច្បាប់ គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ គណៈកម្មាការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា អគ្គស្នងការនគរបាលជាតិស្ថាប័នដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងស្ថាប័នបណ្តុះបណ្តាលច្បាប់**។ ស្ថាប័នទាំងអស់នេះដំណើរការដោយឯករាជ្យនិងស្វ័យភាពផង ហើយស្ថាប័នមួយចំនួនក៏មានទំនាក់ទំនងនិងអន្តរកម្មជាមួយគ្នានឹងគ្នា ដែលត្រូវដំណើរការរួមគ្នា បង្កើតបានជាប្រព័ន្ធអេកូឡូស៊ីមួយ ដើម្បីផ្តល់ជាមូលដ្ឋានគ្រឹះក្នុងប្រព័ន្ធច្បាប់កម្ពុជានាសម័យទំនើប។

#### ១.៥.៧.១ អំណាចនីតិបញ្ញត្តិ

ប្រទេសកម្ពុជាប្រកាន់យករបបសភាពីរជាន់ ដែលអំណាចនីតិបញ្ញត្តិត្រូវអនុវត្តរួមគ្នាដោយរដ្ឋសភា និងព្រឹទ្ធសភាកម្ពុជាក្រោមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ រដ្ឋសភាមានភារកិច្ចចម្បងក្នុងការផ្តួចផ្តើម ការពិភាក្សា និងការអនុម័តច្បាប់ ក៏ដូចជាការត្រួតពិនិត្យអំណាចរាជរដ្ឋាភិបាល ដើម្បីធានាបាននូវនីត្យានុកូលភាព និងការទទួលខុសត្រូវ។ ព្រឹទ្ធសភាបំពេញបន្ថែមតួនាទីនេះដោយពិនិត្យឡើងវិញនូវច្បាប់ដែលបានអនុម័តដោយរដ្ឋសភា ដែលរួមចំណែកដល់ការត្រួតពិនិត្យស្ថាប័ន ភាពស៊ីសង្វាក់គ្នា និងស្ថិរភាពដល់ដំណើរការនីតិបញ្ញត្តិ។ សភាទាំងពីរ ធានាថា ច្បាប់មានភាពស្របច្បាប់តាមបែបប្រជាធិបតេយ្យ មានសុពលភាពតាមនីតិវិធី និងស្របនឹងការគ្រប់គ្រងតាមរដ្ឋធម្មនុញ្ញនៅក្នុងប្រព័ន្ធច្បាប់កម្ពុជា។ រដ្ឋសភាបង្កើតច្បាប់ រីឯព្រឹទ្ធសភាការពារគុណភាពច្បាប់ ស្ថាប័នទាំងពីររួមគ្នាបង្កើតបានជាការទទួលខុសត្រូវស្នូលផ្នែកនីតិបញ្ញត្តិនៅក្នុងប្រព័ន្ធច្បាប់របស់ប្រទេសកម្ពុជា។ សមាជិករដ្ឋសភា សមាជិកព្រឹទ្ធសភា

---

[១២៤] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៥១ថ្មី។

និងនាយករដ្ឋមន្ត្រីមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់។[១២៥] តំណាងរាស្ត្រមានសិទ្ធិស្នើធ្វើវិសោធនកម្មច្បាប់ ប៉ុន្តែសំណើនេះមិនអាចទទួលយកបានទេ ប្រសិនបើការធ្វើវិសោធនកម្មសំដៅបន្ថយប្រាក់ចំណូលសាធារណៈ ឬបន្ថែមបន្ទុកលើប្រជាពលរដ្ឋ។[១២៦] ក្នុងប្រព័ន្ធច្បាប់កម្ពុជា ដំណើរការធ្វើច្បាប់ចែកចេញជា ៤ ដំណាក់កាលគឺ ដំណាក់កាលទី១ នីតិវិធីនៃសេចក្តីព្រាងច្បាប់ឬសេចក្តីស្នើច្បាប់, ដំណាក់កាលទី២ នីតិវិធីពិនិត្យនិងអនុម័តច្បាប់ដោយរដ្ឋសភា, ដំណាក់កាលទី៣ នីតិវិធីនៃការពិនិត្យនិងផ្តល់យោបល់ដោយព្រឹទ្ធសភា, និងដំណាក់កាលទី៤ នីតិវិធីនៃការប្រកាសឱ្យប្រើ។

### ១.៥.៧.២ អំណាចនីតិប្រតិបត្តិ

ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា គណៈរដ្ឋមន្ត្រី គឺជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលកើតចេញពីការបោះឆ្នោតផ្តល់សេចក្តីពីទុកចិត្តពីរដ្ឋសភា និងព្រះរាជក្រឹត្យតែងតាំងគណៈរដ្ឋមន្ត្រីទាំងមូលដោយព្រះមហាក្សត្រ។[១២៧] គណៈរដ្ឋមន្ត្រី ត្រូវបានដឹកនាំដោយនាយករដ្ឋមន្ត្រីមួយរូប ដែលជាតំណាងរាស្ត្រមានសញ្ជាតិខ្មែរតែមួយគត់ និងត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ ស្របតាមការស្នើសុំរបស់គណបក្សដែលមានអាសនៈច្រើនជាងគេនៅក្នុងរដ្ឋសភា។[១២៨] គណៈរដ្ឋមន្ត្រី អមដោយឧបនាយករដ្ឋមន្ត្រី ព្រមទាំងមានទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រី ជាសមាជិក ដែលត្រូវធ្វើសច្ចាប្រណិធានមុននឹងចូលកាន់តំណែង។[១២៩] នៅពេលផុតនីតិកាលនីមួយៗ រាជរដ្ឋាភិបាលដែលត្រូវចេញពីតំណែងមានតែភារកិច្ចដឹកនាំការងារប្រចាំថ្ងៃតែប៉ុណ្ណោះ រហូតដល់ មានរាជរដ្ឋាភិបាលថ្មីចូលកាន់តំណែង។ មុខងារនៃសមាជិករាជរដ្ឋាភិបាល មានវិសមិត្តភាពនិងសកម្មភាពខាងវិជ្ជាជីវៈផ្នែកពាណិជ្ជកម្មឬឧស្សាហកម្ម ហើយនិងការកាន់តំណែងណាមួយ ក្នុងមុខងារសាធារណៈ។[១៣០] សមាជិកទាំងឡាយនៃរាជរដ្ឋាភិបាលទទួលខុសត្រូវរួមគ្នាចំពោះរដ្ឋសភា អំពីនយោបាយទូទៅរបស់រាជរដ្ឋាភិបាលដោយមិនអាចយកសំអាងនៃសេចក្តីបង្គាប់ដោយលាយលក្ខអក្សរឬដោយវាចារអំពីនរណាម្នាក់ ដើម្បីដោះសាឱ្យរួចផុតពីការទទួលខុសត្រូវ

---

[១២៥] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៩១ថ្មី។

[១២៦] Ibid.

[១២៧] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាក្រកម្ពុជា មាត្រា១១៨ ថ្មី(មួយ), មាត្រា១១៩ ថ្មី(ពីរ)។

[១២៨] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាក្រកម្ពុជា មាត្រា១១៩ ថ្មី(ពីរ)។

[១២៩] Ibid.

[១៣០] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាក្រកម្ពុជា មាត្រា១២១ ថ្មី (មាត្រា១០២ចាស់)។

នោះឡើង។[១៣១] សមាជិកគ្រប់រូបនៃរាជរដ្ឋាភិបាលត្រូវទទួលខុសត្រូវពីបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលខ្លួនបានប្រព្រឹត្តក្នុងការបំពេញការងារខ្លួន ឬប្រសិនបើធ្វើខុសធ្ងន់ ក្នុងការបំពេញការងារ រដ្ឋសភាអាចសម្រេចប្តឹងទៅតុលាការមានសមត្ថកិច្ច ដោយការបោះឆ្នោតជាសម្ងាត់តាមមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល។[១៣២]

ក្នុងករណីដែលនាយករដ្ឋមន្ត្រីអវត្តមាន នាយករដ្ឋមន្ត្រីត្រូវចាត់តាំងឧបនាយករដ្ឋមន្ត្រីមួយរូប ឱ្យធ្វើជានាយករដ្ឋមន្ត្រីស្តីទីដើម្បីទទួលភារកិច្ចដឹកនាំគណៈរដ្ឋមន្ត្រីជំនួសជាបណ្តោះអាសន្ន។ បើតំណែងនាយករដ្ឋមន្ត្រីនៅទំនេរជាស្ថាពរ ដោយហេតុជាអាទិ៍មកពីការទទួលអនិច្ចកម្ម ឬការលាលែងពីមុខតំណែង គណៈរដ្ឋមន្ត្រីថ្មីមួយត្រូវ តែងតាំងជាបន្ទាន់ ក្នុងលក្ខខណ្ឌដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនេះ។ ក្នុងនោះ ប្រធានរដ្ឋសភាត្រូវកោះប្រជុំរដ្ឋសភាជាបន្ទាន់ និងត្រូវធ្វើចំណាត់ការចាំបាច់ដទៃទៀត ដោយរួសរាន់ ក្នុងរយៈវេលា ៧ ថ្ងៃយ៉ាងយូរ បន្ទាប់ពីបានទទួលសំណើពីគណបក្ស ដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភា។ ប៉ុន្តែ ក្នុងករណីតំណែងនាយករដ្ឋមន្ត្រីនៅទំនេរជាស្ថាពរ ដោយហេតុមកពី ការទទួលអនិច្ចកម្ម គណៈរដ្ឋមន្ត្រីដែលត្រូវចេញពីតំណែង ក្រោមការដឹកនាំ របស់ឧបនាយករដ្ឋមន្ត្រីដែលទទួលបានការចាត់តាំងជានាយករដ្ឋមន្ត្រីស្តីទីមានតែភារៈកិច្ចប្រចាំថ្ងៃប៉ុណ្ណោះ រហូតដល់មានគណៈរដ្ឋមន្ត្រីថ្មីចូលកាន់តំណែង។ មានតែភារកិច្ចដឹកនាំការងារប្រចាំថ្ងៃតែប៉ុណ្ណោះ រហូតដល់មានគណៈរដ្ឋមន្ត្រីថ្មី ចូលកាន់តំណែង។[១៣៣] ការលាលែងពីមុខតំណែងរបស់នាយករដ្ឋមន្ត្រី ត្រូវធ្វើឡើងតាមលិខិត លាលែងពីមុខតំណែងដែលត្រូវធ្វើថ្វាយព្រះមហាក្សត្រ និងចម្លងជូនប្រធាន រដ្ឋសភា។ ក្នុងករណីនេះ គណៈរដ្ឋមន្ត្រីដែលត្រូវចេញពីតំណែង ត្រូវបន្តដឹកនាំ ការងាររបស់រាជរដ្ឋាភិបាល រហូតដល់គណៈរដ្ឋមន្ត្រីថ្មីចូលកាន់តំណែង។[១៣៤]

### ១.៥.៧.៣ អំណាចតុលាការ

តុលាការ គឺជាស្ថាប័នមួយដែលមានអំណាចឯករាជ្យក្នុងការធានារក្សាអនាគតិនិងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ធានាឱ្យមានកិច្ចដំណើរការល្អរបស់អង្គការតុលាការនិងអង្គការអយ្យការ លើកកម្ពស់សេវាសាធារណៈឱ្យមានប្រសិទ្ធភាពនិងឆាប់រហ័ស ធានាក្នុងការផ្តល់យុត្តិធម៌លើរឿងក្តីគ្រប់ប្រភេទ

---

[១៣១] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាក្រកម្ពុជា មាត្រា១២១ ថ្មី (មាត្រា១០២ចាស់), មាត្រា១២២ ថ្មី (មាត្រា១០៣ចាស់)។

[១៣២] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាក្រកម្ពុជា មាត្រា១២៦ ថ្មី (មាត្រា១០៧ចាស់)។

[១៣៣] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ១២៥ ថ្មី(មួយ)។

[១៣៤] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ១២៥ ថ្មី(មួយ)។

ដើម្បីបង្កើនជំនឿទុកចិត្តពីប្រជាពលរដ្ឋ និងរួមចំណែកពង្រឹងសុវត្ថិភាពសង្គម ដោយមិនស្ថិតនៅក្រោមឥទ្ធិពលឬអំណាចនៃអង្គនីតិប្រតិបត្តិ ឬអង្គនីតិបញ្ញត្តិនោះឡើយ។[១៣៥] អំណាចនេះ ត្រូវបានប្រគល់ឱ្យតុលាការតុលាការកំពូល និងសាលាជម្រះក្តីគ្រប់ផ្នែកនិងគ្រប់ជាន់ថ្នាក់[១៣៦] ដែលក្នុងនោះរួមមាន សាលាដំបូង សាលាឧទ្ធរណ៍ និងតុលាការកំពូល[១៣៧] ដែលគ្រប់ដណ្តប់លើគ្រប់រឿងក្តីទាំងអស់រួមទាំងរឿងក្តីដែលទាក់ទងនឹងរដ្ឋបាលផងដែរ។[១៣៨]

### ១.៥.៧.៤ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានតួនាទីជាអ្នកជួយព្រះមហាក្សត្រក្នុងការធានាឯករាជ្យនៃអំណាចតុលាការ ធានាវិន័យរបស់ចៅក្រម និងការប្រព្រឹត្តទៅនៃសាលាជម្រះក្តីនៃព្រះរាជាណាចក្រកម្ពុជាឱ្យដំណើរការបានល្អប្រសើរ។[១៣៩] ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវស្ថិតក្រោមព្រះរាជាធិបតីភាពនៃព្រះមហាក្សត្រ ហើយព្រះមហាក្សត្រក៏អាចចាត់តាំងព្រះរាជតំណាង ម្នាក់របស់ព្រះអង្គឱ្យធ្វើជាអធិបតីនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនេះផងដែរ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមលើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រអំពី ការតែងតាំងចៅក្រមនិងព្រះរាជអាជ្ញាអមសាលាជំរះក្តីទាំងអស់។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងមុខការដាក់វិន័យចំពោះចៅក្រម និងព្រះរាជអាជ្ញា ត្រូវប្រជុំក្រោមអធិបតីភាពនៃប្រធានតុលាការកំពូលឬ អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល អាស្រ័យដោយករណីទាក់ទងនឹងចៅក្រមឬព្រះរាជអាជ្ញា។[១៤០]

### ១.៥.៧.៥ ក្រុមប្រឹក្សាធម្មនុញ្ញ

ក្រុមប្រឹក្សាធម្មនុញ្ញ គឺជាស្ថាប័នឯករាជ្យ និងអព្យាក្រឹតក្នុងការបំពេញសមត្ថកិច្ច[១៤១] ធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញនិងច្បាប់ដែលរដ្ឋសភាបានអនុម័តនិងព្រឹទ្ធសភាបានពិនិត្យ

---

[១៣៥] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ១២៨ ថ្មី (មាត្រា១០៩ចាស់) និងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ មាត្រា១។

[១៣៦] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ១២៩ ថ្មី (មាត្រា១១០ចាស់)។

[១៣៧] ច្បាប់ស្តីពីការរៀបចំអង្គតុលាការ មាត្រា ៣។

[១៣៨] ច្បាប់ស្តីពីការរៀបចំអង្គតុលាការ មាត្រា ៤។

[១៣៩] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ១៣២ ថ្មី (មាត្រា១១៣ចាស់), មាត្រា ១៣៣ ថ្មី (មាត្រា១១៤ចាស់) និងច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មាត្រា១ ។

[១៤០] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ១៣៤ ថ្មី (មាត្រា១១៥ចាស់)។

[១៤១] ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ មាត្រា ២។

ចប់សព្វគ្រប់ហើយ និងមានសិទ្ធិពិនិត្យ និងសំរេចអំពីករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។[១៤២]

ដើម្បីជានានូវការរំលោភបំពានរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលរបស់ប្រទេសកម្ពុជា ការស្នើសុំពិនិត្យធម្មនុញ្ញភាពចែកចេញជាពីរគឺការពិនិត្យជាអាទិកាល និងការពិនិត្យជាបច្ឆាកាល។ ការពិនិត្យជាអាទិកាល គឺជាការត្រួតពិនិត្យជាមុនលើច្បាប់ដែលរដ្ឋសភាបានអនុម័ត និងពិនិត្យចប់សព្វគ្រប់លើច្បាប់រៀបចំអង្គការ ឬវិសោធនកម្មច្បាប់រៀបចំអង្គការ បទបញ្ជាផ្ទៃក្នុង ឬវិសោធនកម្មនៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងបទបញ្ជាផ្ទៃក្នុង ឬវិសោធនកម្មនៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា មុនពេលប្រកាសឱ្យប្រើ។[១៤៣] ការត្រួតពិនិត្យនេះ អាចធ្វើឡើងតាមរយៈការបញ្ជូនច្បាប់ចេញពី ព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា តំណាងរាស្ត្រចំនួនមួយភាគប្រាំ។ មួយវិញទៀតការពិនិត្យជាបច្ឆាកាល ជាការត្រួតពិនិត្យទៅលើច្បាប់ដែលអនុវត្តហើយ តាមរយៈការស្នើសុំឱ្យពិនិត្យដោយ ព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភាចំនួនមួយភាគប្រាំ តំណាងរាស្ត្រចំនួនមួយភាគដប់ឬតុលាការអាចសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យអំពីធម្មនុញ្ញភាពនៃច្បាប់នោះ។ [១៤៤] ប្រជារាស្ត្រ មានសិទ្ធិប្ដឹងអំពីធម្មនុញ្ញភាពនៃច្បាប់បាន តាមរយៈ តំណាងរាស្ត្រឬប្រធានរដ្ឋសភាឬសមាជិកព្រឹទ្ធសភាឬប្រធានព្រឹទ្ធសភា។ បទប្បញ្ញត្តិក្នុងមាត្រាណាដែលក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាមិនស្របនឹង រដ្ឋធម្មនុញ្ញ មិនអាចយកទៅប្រកាសឱ្យប្រើឬយកទៅអនុវត្តបានឡើយ។ [១៤៥] សេចក្ដីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញជាសេចក្ដីសំរេចបិទផ្លូវតវ៉ា។

### ១.៥.៧.៦ ក្រុមប្រឹក្សាអ្នកច្បាប់

ក្រុមប្រឹក្សាអ្នកច្បាប់ (ក.ប.ច.) ជាអង្គភាពមួយចំណុះទីស្ដីការគណៈរដ្ឋមន្ត្រីដែលស្ថិតក្រោមការគ្រប់គ្រងនិងដឹកនាំផ្ទាល់របស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី។ ក.ប.ច. ត្រូវបានបង្កើតឡើងតាំងពីឆ្នាំ១៩៩៤ មកម្ល៉េះដែលមានរាយឈ្មោះសមាសភាពក្រុមប្រឹក្សាអ្នកច្បាប់ និងក្រុមជំនាញនៃ ក.ប.ច.។ ក្រោយមក ដោយការផ្លាស់ប្ដូរបែបបទការងារតាមអាណត្តិក្រោយៗ ព្រះមហាក្សត្របានចេញព្រះរាជ

---

[១៤២] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ១៣៦ ថ្មី។

[១៤៣] [១៤៣] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ១៤០ថ្មី និងច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ មាត្រា១៦ថ្មី, មាត្រា១៧ថ្មី។

[១៤៤] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ១៤១ថ្មី។

[១៤៥] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ១៤២ថ្មី (មាត្រា១២៣ចាស់)។

ក្រឹត្យ ន.ស./រកត/០៦២០/៦៦១ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ ក.ប.ច. ដោយកំណត់ភារកិច្ចបន្ថែមឱ្យ ក.ប.ច. លើសពីភារកិច្ចដែលមានក្នុងអនុក្រឹត្យលេខ៣២ អនក្រ.បក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៤។ បច្ចុប្បន្ន ក.ប.ច. ដើរតួនាទីសំខាន់ក្នុងការពិនិត្យលើច្បាប់និងលិខិតបទដ្ឋានគតិយុត្តជូនគណៈរដ្ឋមន្ត្រី និងភារកិច្ចសំខាន់ៗរបស់ ក.ប.ច. មានដូចជា សិក្សាស្រាវជ្រាវ ពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ លិខិតបទដ្ឋាន សន្ធិសញ្ញា អនុសញ្ញា និងកិច្ចព្រមព្រៀងជាមួយអន្តរជាតិដែលក្រសួង-ស្ថាប័នស្នើសុំការសម្រេចពីរាជរដ្ឋាភិបាល, សិក្សានិងពិនិត្យលើច្បាប់និងលិខិតបទដ្ឋានគតោយុត្តដែលមិនសមស្របនឹងវឌ្ឍនភាពសង្គម និងលើកយោបល់ជូនរាជរដ្ឋាភិបាលដើម្បីធ្វើវិសោធនកម្ម, សម្របសម្រួលជាមួយក្រសួង-ស្ថាប័នរៀបចំសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តដែលចាំបាច់សម្រាប់អនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល, តំណាងរាជរដ្ឋាភិបាលទៅការពារសេចក្តីព្រាងច្បាប់ឬទៅបំភ្លឺនៅស្ថាប័ននីតិប្បញ្ញត្តិ, ស្រាវជ្រាវនិងផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានគតិយុត្ត, និងភារកិច្ចមួយចំនួនទៀតតាមការចាត់តាំងរបស់ប្រធាន និងប្រមុខរាជរដ្ឋាភិបាល។ បើពិនិត្យមើលលើការអនុវត្តភារកិច្ចសព្វថ្ងៃរបស់ក.ប.ច.ពាក់ព័ន្ធនឹងការកសាងច្បាប់ ក.ប.ច. បានធ្វើការយ៉ាងសកម្មលើការពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ លិខិតបទដ្ឋាន សន្ធិសញ្ញា អនុសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិរបស់ក្រសួង-ស្ថាប័ន ឱ្យមានឯកសណ្ឋានភាពជាមួយទម្រង់ដែលរាជរដ្ឋាភិបាលបានប្រកាសឱ្យប្រើតាមរយៈអនុក្រឹត្យលេខ១៧០ អនក្រ.បក ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីនីតិវិធីនិងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗរបស់រាជរដ្ឋាភិបាល ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៤ ហើយជារឿយៗ ក.ប.ច. បានចូលរួមតំណាងរាជរដ្ឋាភិបាលជាប្រចាំក្នុងការការពារសេចក្តីព្រាងច្បាប់នៅមុខនីតិបញ្ញត្តិនិងធ្វើការបំភ្លឺនានា។ ដោយឡែក ភារកិច្ចមួយចំនួនដែលអនុវត្តមិនទាន់ពេញលេញ រួមមាន ការលើកសំណើជូនរាជរដ្ឋាភិបាលក្នុងការធ្វើវិសោធនកម្មច្បាប់និងលិខិតបទដ្ឋានគតិយុត្តដែលមិនសមស្របនឹងវឌ្ឍនភាពសង្គម និងសំណើជូនរាជរដ្ឋាភិបាលដើម្បីរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តដើម្បីគាំទ្រការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល។

### ១.៥.៧.៧ គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់

ក្នុងអាណត្តិទី៧ នៃរដ្ឋសភា **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានធ្វើវិចារណកម្មលើគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ជាពីរស្ថាប័នដោយគណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌ទទួលបន្ទុកកែទម្រង់ប្រព័ន្ធយុត្តិធម៌ និងគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ (គ.ក.ច.) ទទួលបន្ទុកកែទម្រង់ច្បាប់ទាំងមូលរបស់ប្រទេស។ គ.ក.ច. ស្ថិតក្រោមការដឹកនាំរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ដែលមានរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគ

ណៈរដ្ឋមន្ត្រីជាប្រធាន និងឥស្សរជនជាន់ខ្ពស់និងថ្នាក់ដឹកនាំពីគ្រប់ក្រសួង-ស្ថាប័នជាអនុប្រធាននិងសមាជិក។ ការបង្កើតនេះធ្វើឡើងតាមរយៈព្រះរាជក្រឹត្យ នស/រកត/០២២៤/១៥០ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៤។ គ.ក.ច. មានបេសកកម្មកែទម្រង់ប្រព័ន្ធច្បាប់កម្ពុជាឱ្យទៅជាប្រព័ន្ធច្បាប់មួយដែលមានឯកភាព ប្រសិទ្ធភាព សមានគតិភាព ឧត្តមានុភាពគតិយុត្ត និងសន្តិសុខគតិយុត្ត ស្របតាមឧត្តមានុវត្តន៍អន្តរជាតិនិងបរិការណ៍កម្ពុជា។ ក្នុងន័យនេះ គ.ក.ច. មានភារកិច្ចសំខាន់ៗដូចជា៖ លើកសំណើជូនរាជរដ្ឋាភិបាលដើម្បីពិនិត្យនិងសម្រេចលើផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពកែទម្រង់ច្បាប់ ដោយផ្អែកលើគោលនយោបាយរបស់រាជរដ្ឋាភិបាល, រៀបចំគោលការណ៍ណែនាំដើម្បីពង្រឹងគុណភាពនិងប្រសិទ្ធភាពក្នុងការតាក់តែង និងផ្តល់យោបល់លើការរៀបចំច្បាប់និងលិខិតបទដ្ឋានគិតយុត្ត និងសេចក្តីណែនាំនិងវិធានការចាំបាច់នានា ធានាប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពនៃការងារកែទម្រង់ច្បាប់, ត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពពាក់ព័ន្ធនឹងការងារកែទម្រង់ច្បាប់, ត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តនៅតាមក្រសួង-ស្ថាប័ន, សម្របសម្រួលនិងសហការជាមួយក្រសួង-ស្ថាប័ន និងដៃគូអភិវឌ្ឍជាតិនិងអន្តរជាតិ ដើម្បីជំរុញដល់ការអនុវត្តការងារកែទម្រង់ច្បាប់, ផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានគតិយុត្តតាមគ្រប់មធ្យោបាយ, និងភារកិច្ចផ្សេងទៀតដែលប្រគល់ពីរាជរដ្ឋាភិបាល។ គ.ក.ច. បានចាប់ផ្តើមដំណើរកែទម្រង់ប្រព័ន្ធច្បាប់កម្ពុជានេះ ដោយការដាក់ចេញក្របខ័ណ្ឌយុទ្ធនៃកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាលជាមគ្គុទេសសម្រាប់ក្រសួង-ស្ថាប័នក្នុងការកែទម្រង់ច្បាប់ក្រោមសមត្ថកិច្ចខ្លួន។ ទោះបី គ.ក.ច. មិនទាន់បានបំពេញភារកិច្ចពេញលេញនៅឡើយតាំងពីការចាប់ផ្តើមដំណើរការ។ ដោយឡែក ភារកិច្ចក្រុមប្រឹក្សាអ្នកច្បាប់ និងគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់មានលក្ខណៈស្រដៀងគ្នាត្រង់លើកយោបល់ជូនរាជរដ្ឋាភិបាលលើការធ្វើវិសោធនកម្មលើច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ដែលមិនសមស្របនឹងវឌ្ឍនភាពសង្គម, ការត្រួតពិនិត្យនិងវាយតម្លៃលើប្រសិទ្ធភាពនៃការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តតាមក្រសួង-ស្ថាប័ន, និងការផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានគតិយុត្តមានជាធរមាន។

### ១.៥.៧.៨ គណៈកម្មាការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌

គណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌ (គ.ក.ប.យ.) ស្ថិតក្រោមការដឹកនាំរបស់ក្រសួងយុត្តធម៌ដែលមានរដ្ឋមន្ត្រីក្រសួងយុត្តធម៌ និងប្រធានតុលាការកំពូលជាសហប្រធាន។ គ.ក.ប.យ. មានតួនាទីជាសេនាធិការជូនរាជរដ្ឋាភិបាលក្នុងការកែទម្រង់ប្រព័ន្ធយុត្តិធម៌ក្នុងប្រទេសកម្ពុជា។ ជាសារតារ គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ត្រូវបានបង្កើតតាំងពីឆ្នាំ២០១៣ ដែលទទួលបន្ទុកក្នុងការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌កម្ពុជា ប៉ុន្តែដើម្បីឆ្លើយតបនឹងបរិការណ៍កម្ពុជាក្នុង

ការកែទម្រង់គន្លឹះរបស់រាជរដ្ឋាភិបាល គណៈកម្មាការធិការនេះត្រូវបែងចែកជាពីរស្ថាប័ន ដែល គ.ក.ប.យ. ត្រូវបានបង្កើតដោយព្រះរាជក្រឹត្យ នស/រកត/១២២៣/២៦៨២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២៣។ គ.ក.ប.យ. មានភារកិច្ចសំខាន់ៗដែលប្រទាក់ក្រឡាគ្នាជាមួយប្រព័ន្ធច្បាប់កម្ពុជាដូចជា ដឹកនាំ គាំទ្រ សម្របសម្រួល និងជំរុញការអនុវត្តការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌, លើកសំណើជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យនិងសម្រេចលើយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធយុត្តិធម៌, ដាក់ចេញសេចក្តីណែនាំ និងវិធានការចាំបាច់ធានាប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការអនុវត្តការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌, ត្រួតពិនិត្យនិងវាយតម្លៃលើការអនុវត្តផែនការយុទ្ធសាស្ត្រពាក់ព័ន្ធនឹងការកែទម្រង់ប្រព័ន្ធយុត្តិធម៌, ពិនិត្យនិងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យយុត្តិធម៌, និងលើកសំណើជូនរាជរដ្ឋាភិបាល ដើម្បីដោះស្រាយបញ្ហាប្រឈមជូនរាជរដ្ឋាភិបាលពិនិត្យនិងសម្រេច។ ទោះបីជាភារកិច្ចរបស់គ.ក.ប.យ. ភាគច្រើនពាក់ព័ន្ធនឹងប្រព័ន្ធយុត្តិធម៌ ប្រព័ន្ធច្បាប់មួយដែលមានភាពពេញលេញត្រូវការការចូលរួមយ៉ាងសកម្មពីនីតិតុលាការ ដើម្បីធានានូវការអនុវត្តច្បាប់ឱ្យមានឯកភាព ប្រសិទ្ធភាព សមានគតិភាព ឧត្តមានុភាពគតិយុត្ត និងសន្តិសុខគតិយុត្ត។ ដូច្នេះ នៅពេល គ.ក.ប.យ. អនុវត្តភារកិច្ចរបស់ខ្លួនបានពេញលេញហើយច្បាប់ក្នុងនិងក្រៅវិស័យប្រព័ន្ធយុត្តិធម៌ នឹងត្រូវបានបកស្រាយដោយផ្តល់តម្លាភាពជូនគ្រប់តួអង្គក្នុងប្រព័ន្ធ។

### ១.៥.៧.៩ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា គឺជាស្ថាប័នមួយដែលប្រមូលផ្តុំមេធាវីទាំងអស់ដែលតាំងការិយាល័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ច្បាប់ស្តីពីលក្ខន្តិកៈមេធាវីត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលផ្នែកមួយនៃច្បាប់នេះបានកំណត់អំពីគណៈមេធាវី។ គណៈមេធាវីដឹកនាំដោយប្រធានគណៈមេធាវីមួយរូប និងគ្រប់គ្រងដោយក្រុមប្រឹក្សាគណៈមេធាវី។ ប្រធានគណៈមេធាវីមួយត្រូវបានបោះឆ្នោតជ្រើសតាំងសម្រាប់អាណត្តិ ២ឆ្នាំ និងអាចបន្តតែមួយអាណត្តិទៀតដោយការបោះឆ្នោត រីឯក្រុមប្រឹក្សាគណៈមេធាវីត្រូវបានបោះឆ្នោតជ្រើសតាំងសម្រាប់អាណត្តិ ៣ឆ្នាំ និងអាចឈរឈ្មោះជាសមាជិកក្រុមប្រឹក្សាគណៈមេធាវីបានដោយមិនកំណត់អាណត្តិក្នុងករណីការឈរឈ្មោះមិនជាប់អាណត្តិដែលខ្លួនជាសមាជិក។ ឧទាហរណ៍ ប្រសិនជាមេធាវីមួយរូបជាសមាជិកក្រុមប្រឹក្សាគណៈមេធាវីក្នុងអាណត្តិទី១ គាត់មិនអាចឈរឈ្មោះម្តងទៀតក្នុងអាណត្តិទី២ទេ តែគាត់អាចឈរឈ្មោះម្តងទៀតបាននៅអាណត្តិទី៣។ គណៈមេធាវី ដែលមានក្រុមប្រឹក្សាជាសេនាធិការមានភារកិច្ចធ្វើបទបញ្ញត្តិផ្ទៃក្នុង និងក្រមសីលធម៌វិជ្ជាជីវៈមេធាវី, សម្រេចលើសំណើ

ចុះឈ្មោះកម្មសិក្សា និងឈ្មោះក្នុងបញ្ជីគណៈមេធាវី, បញ្ចេញមតិលើបញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងវិស័យយុត្តិធម៌ និងសិទ្ធិរបស់មេធាវី ក្នុងវិស័យការពារជាអាទិ៍នៅពេលមានការអញ្ជើញពីអាជ្ញាធរសាធារណៈ, ចេញសេចក្តីសម្រេចដាក់វិន័យឬសុំឱ្យនៅក្រៅបញ្ជីរបស់មេធាវី, និងតួនាទីផ្សេងទៀតដែលមានចែង។ បច្ចុប្បន្ន ប្រធានគណៈមេធាវីដើរតួនាទីយ៉ាងសំខាន់ក្នុងប្រព័ន្ធច្បាប់ ដោយប្រធានគណៈមេធាវីជារឿយៗជាសមាជិកគណៈកម្មាការឬគណៈកម្មការពាក់ព័ន្ធនឹងវិស័យច្បាប់ ហើយមេធាវីជាច្រើនរូបតែងតែទទួលបានការអញ្ជើញចូលរួមពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តដែរ ឬត្រូវបានទទួលការងារជាអ្នកតាក់តែងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផងដែរតាមជំនាញរបស់ខ្លួនដោយផ្តល់សេវាប្តូរជាមួយប្រាក់កម្រៃ។ ដូច្នេះ គណៈមេធាវីដើរតួសំខាន់ក្នុងការបណ្តុះបណ្តាល ចេញជាក្រមសីលធម៌គ្រប់គ្រងមេធាវី ដើម្បីជាតួអង្គសំខាន់ក្នុងការប្រើប្រាស់ច្បាប់ឱ្យសមស្រប និងមានតម្លាភាពដែលជាកម្លាំងមួយក្នុងការកសាងប្រព័ន្ធច្បាប់ដ៏រឹងមាំ។ បច្ចុប្បន្ន មេធាវីដែលចុះបញ្ជីជាមួយគណៈមេធាវីសរុបមាន ២,៦១៤រូប ដែលក្នុងនោះមានចំនួន ២,១២២រូបជាមេធាវីពេញសិទ្ធិកំពុងប្រកបវិជ្ជាជីវៈ។[146]

### ១.៥.៧.១០ អគ្គស្នងការនគរបាលជាតិ

អគ្គស្នងការដ្ឋាននគរបាលជាតិ ជាស្ថាប័នចំណុះឱ្យក្រសួងមហាផ្ទៃដែលមានតួនាទីធ្វើជាសេនាធិការជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដែលមានភារកិច្ចដូចជា៖[147]

- អនុវត្តការងាររក្សាសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម
- ការពារអាយុជីវិត សិទ្ធិ សេរីភាព កិត្តិយស សេចក្តីថ្លៃថ្នូរ ទ្រព្យសម្បត្តិ និងផលប្រយោជន៍ស្របច្បាប់ របស់ប្រជាពលរដ្ឋ
- ការពារសុវត្ថិភាពថ្វាយព្រះមហាក្សត្រ ជូនថ្នាក់ដឹកនាំជាន់ខ្ពស់ជាតិ និងអន្តរជាតិ
- គ្រប់គ្រង ដឹកនាំ បញ្ជា និងចាត់វិធានការបង្ការទប់ស្កាត់ និងបង្ក្រាបឧក្រិដ្ឋកម្មឆ្លងដែន ឧក្រិដ្ឋកម្ម មានការចាត់តាំង បទឧក្រិដ្ឋ និងបទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទ ព្រមទាំងបទល្មើសផ្សេងៗទៀត ដែលប្រឆាំង នឹងសន្តិសុខជាតិ សណ្តាប់ធ្នាប់សង្គម
- ទទួលអនុវត្តភារកិច្ច និងសិទ្ធិផ្សេងៗទៀតដែលរដ្ឋមន្ត្រីក្រសួងមហាផ្ទៃប្រគល់ឱ្យ

---

[146] ស្ថិតិមេធាវី, គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ ដកចេញពី https://www.bakc.org.kh/index.php/km/២០២០-០២-០២-០៤-០៦-២៤

[147] អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ លេខ ១០៩ អនក្របក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៥, មាត្រា ២៤។

- អគ្គស្នងការដ្ឋាននគរបាលជាតិ ដឹកនាំដោយអគ្គស្នងការមួយរូប និងមានអគ្គស្នងការរងជាជំនួយការ តាមការកំណត់។

មន្ត្រីនគរបាលយុត្តិធម៌មានតួនាទីជាជំនួយរបស់អំណាចតុលាការ និងមានភារកិច្ចធ្វើការត្រួតពិនិត្យបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ កំណត់អត្តសញ្ញាណ និងចាប់ជនល្មើសព្រមទាំងប្រមូលភស្តុតាង។[148] សមាសភាពនៃមន្ត្រីនគរបាលយុត្តិធម៌ រួមមាន មន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដ៏ទៃទៀត ដែលច្បាប់ច្បាប់ប្រគល់អំណាចឱ្យធ្វើការពិនិត្យបទល្មើសខ្លះៗ ក្នុងវង្វង់សមត្ថកិច្ចរបស់ខ្លួន។[149]

បន្ថែមពីនេះទៅទៀត មន្ត្រីរាជការនៃក្រសួងស្ថាប័ន អាចក្លាយជាមន្ត្រីនគរបាលយុត្តិធម៌លុះត្រាតែទទួលបាននីតិសម្បទានតាមរយៈច្បាប់ពិសេសដូចជា ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ច្បាប់ស្តីពីព្រៃឈើ និងច្បាប់ស្តីពីការប្រឆាំងនឹងអំពើពុករលួយ ជាដើម។

### ១.៥.៧.១១ ស្ថាប័នដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

#### ក. យន្តការដោះស្រាយវិវាទនៅតាមក្រសួង-ស្ថាប័ន

បច្ចុប្បន្ន តាមក្រសួង-ស្ថាប័នក៏មានយន្តការដោះស្រាយវិវាទរវាងបុគ្គលនិងបុគ្គលផងដែរ។ វិវាទដែលក្រសួង ស្ថាប័នអាចសម្របសម្រួលបានរួមមាន វិវាទក្នុងវិស័យពាណិជ្ជកម្ម វិវាទក្នុងវិស័យគយ រដ្ឋករ និងពន្ធដា វិវាទក្នុងសង្គម។

#### ខ. វិវាទក្នុងវិស័យពាណិជ្ជកម្ម

វិវាទពាណិជ្ជកម្មគឺ វិវាទដែលអាចកើតមានឡើងក្នុងការប្រតិបត្តិការក្នុងវិស័យពាណិជ្ជកម្ម។ ក្នុងនោះផងដែរ កម្ពុជាសព្វថ្ងៃមានយន្តការមួយចំនួនតាមក្រសួង ស្ថាប័នដែលទទួលបន្ទុកដោះស្រាយវិវាទពាណិជ្ជកម្ម ដូចជា(១)អគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិមានភារកិច្ចសម្របសម្រួល និងចូលរួមដោះស្រាយវិវាទពាណិជ្ជកម្មអន្តរជាតិ ក្រោមក្របខ័ណ្ឌអាស៊ាន ដៃគូអាស៊ាន អនុតំបន់ និងទ្វេភាគីទាក់ទងនឹងរបាំងពន្ធគយ និងមិនមែនពន្ធគយ សំដៅសម្រួលការពាណិជ្ជកម្ម, (២)អគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេសដែលមានភារកិច្ចសម្របសម្រួល ដោះស្រាយវិវាទ ដែលទាក់ទងនឹងការចុះបញ្ជីពាណិជ្ជកម្ម ការកែប្រែ និងការលុបឈ្មោះក្រុមហ៊ុន សហគ្រាស, (១) អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម ទទួលបន្ទុកដោះ

---

[១៤៨] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៥៦។

[១៤៩] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៥៧។

ស្រាយវិវាទកម្មអំពីការចុះម៉ាក ម៉ាកសមូហភាព និងវិញ្ញាតកម្ម ពាណិជ្ជនាម និងម៉ាកសម្គាល់ភូមិសាស្ត្រ, សម្រុះសម្រួលវិវាទនានាទាក់ទងនឹងកម្មសិទ្ធិបញ្ញា ដែលជាសមត្ថកិច្ចរបស់ក្រសួងពាណិជ្ជកម្ម, សហការជាមួយអាជ្ញាធរមានសមត្ថកិច្ច និងស្ថាប័នតុលាការ ដើម្បីបញ្ឈប់ការរំលោភកម្មសិទ្ធិបញ្ញា, និង(៤)អគ្គនាយកដ្ឋានគោលនយោបាយ និងជំរុញពាណិជ្ជកម្ម មានភារកិច្ចរៀបចំបែបបទនិងនីតិវិធីនៃការផ្សះផ្សាវិវាទ និងផ្សះផ្សាវិវាទពាណិជ្ជកម្ម និងទទួលពាក្យបណ្ដឹង សំណើរសុំផ្សះផ្សាវិវាទ ឬការស្នើសុំនានាពាក់ព័ន្ធនឹងការបកស្រាយ និងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តនៅក្នុងសមត្ថកិច្ចរបស់ក្រសួងពាណិជ្ជកម្ម, (៥)អគ្គនាយកដ្ឋានកិច្ចការពារអ្នកប្រើប្រាស់ និងការប្រកួតប្រជែង ដែលមានភារកិច្ចទទួលពាក្យបណ្ដឹង ពិនិត្យ និងដោះស្រាយបណ្ដឹងពីក្រសួង ស្ថាប័ន និងបុគ្គលពាក់ព័ន្ធ ក្នុងក្របខ័ណ្ឌការពារអ្នកប្រើប្រាស់ និងក្របខ័ណ្ឌប្រកួតប្រជែង ដើម្បីចាត់វិធានការតាមនីតិវិធី។[១៥០]

## គ. វិវាទក្នុងវិស័យគយ រដ្ឋករ និងពន្ធដា

ដើម្បីធានាបានតម្លាភាព អព្យាក្រឹត្យភាព នីត្យានុកូលភាពហិរញ្ញវត្ថុ និងភាពជឿជាក់បាននៃការដោះស្រាយវិវាទសារពើពន្ធ រាជរដ្ឋាភិបាលបានបង្កើតគណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធ «គ.វ.ស.»។[១៥១] គ.វ.ស. ទទួលបន្ទុកពិនិត្យ ដោះស្រាយ និងសម្រេចលើបណ្ដឹងតវ៉ារបស់អ្នកជាប់ពន្ធ ដែលមិនពេញចិត្តចំពោះសេចក្ដីសម្រេច ឬវិធានចុងក្រោយ របស់អគ្គនាយកដ្ឋានពន្ធដា អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងវិវាទផ្សេងទៀតដែលពាក់ព័ន្ធនឹងសារពើពន្ធចុងក្រោយរបស់អ្នកប្ដឹងតវ៉ា។

ដោយឡែក អគ្គនាយកដ្ឋានពន្ធដាក៏មានយន្តការដោះស្រាយបណ្ដឹងពន្ធដាសម្រាប់អ្នកជាប់ពន្ធផងដែរ។[១៥២] អង្គភាពដែលទទួលបន្ទុកដោះស្រាយបណ្ដឹងនៃអគ្គនាយកដ្ឋានពន្ធដាសព្វថ្ងៃគឺនាយកដ្ឋាននីតិកម្ម គោលនយោបាយ សារពើពន្ធ និងសហប្រតិបត្តិការពន្ធដាអន្តរជាតិ ដែលយន្តការនេះមិនមានគិតកម្រៃទេ។ ម្យ៉ាងវិញទៀត រដ្ឋបាលគយក៏មានភារកិច្ចសម្របសម្រួលបទល្មើសគយដែលមានចែងក្នុងច្បាប់ចំពោះការពិន័យជាប្រាក់ប៉ុណ្ណោះ។ ការសម្រុះសម្រួលនេះអាចធ្វើទៅបាន លុះត្រាតែករណីបទល្មើសនេះមិនទាន់ទទួលបានសាលក្រមពីតុលាការ។ [១៥៣]

---

[១៥០] អនុក្រឹត្យលេខ ២៣៨ អនក្រ.បក ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៥

[១៥១] អនុក្រឹត្យលេខ ០៣ អនក្រ. បក. ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធ

[១៥២] មាត្រា ២១១ និងមាត្រា ២៣៦ នៃច្បាប់ស្តីពីសារពើពន្ធ

[១៥៣] មាត្រា ៧៧ នៃច្បាប់ស្តីពីគយ

## ឃ. វិវាទក្នុងសង្គម

ក្នុងសង្គមបច្ចុប្បន្ន វិវាទអាចកើតមានចំពោះបុគ្គលនិងបុគ្គល បុគ្គលនិងក្រុមហ៊ុន និង បុគ្គលនិងស្ថាប័នរដ្ឋ។ ក្នុងចំណុចនេះ វិវាទបុគ្គលនិងស្ថាប័នរដ្ឋនឹងមិនយកមកពណ៌នាទេ ដោយកំណត់ត្រឹមកម្រិតបុគ្គលនិងបុគ្គល និងបុគ្គលនិងក្រុមហ៊ុន។ ជាយន្តការ នៅពេលបុគ្គលមានវិវាទជាមួយនឹងបុគ្គលម្នាក់ទៀត នោះបុគ្គលនៃវិវាទអាចព្រមព្រៀងគ្នាដោះស្រាយទំនាស់ជាមួយសង្កាត់ដែលខ្លួនមានទំនាស់បាន។[១៥៤]

យោងតាមសៀវភៅណែនាំអនុវត្តការងារសម្រាប់គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ ដែលដាក់ឱ្យប្រើប្រាស់គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ មានទិសដៅកាត់បន្ថយស្ថានភាពទំនាស់ និងគ្រប់គ្រងទំនាស់ដែលកើតមាននៅតាមមូលដ្ឋាន, ធ្វើការសម្រុះសម្រួលទំនាស់ក្នុងករណីមានការព្រមព្រៀងពីភាសគីទាំងអស់, និង ផ្តល់ការពិគ្រោះយោបល់ផ្នែកច្បាប់ និងចង្អុលបង្ហាញនីតិវិធីបន្តដល់ភាគីទំនាស់ក្នុងករណីទំនាស់មិនអាចដោះស្រាយបាន។ សូមគូសបង្ហាញផងដែរ កំណត់ហេតុដែលចេះដោយគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់មិនមានវិសាលភាពដូចសាលក្រមតុលាការទេ បុគ្គលវិវាទនៅតែអាចបន្តនីតិវិធីទៅតុលាការបាន ប្រសិនដំណោះស្រាយមិនសមស្រប។

ម៉្យាងវិញទៀត ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ជាក្រុមប្រឹក្សាជាតិរៀបចំគោលនយោបាយដើម្បីការពារសិទ្ធិកុមារ ស្ត្រី និងមនុស្សចាស់ ដែលបានចេញគោលនយោបាយសំខាន់ៗដូចជា គោលនយោបាយស្តីពីប្រព័ន្ធកិច្ចការពារកុមារ ឆ្នាំ២០១៩-២០២៩ ដែលបានចង្អុលឱ្យក្រសួងពាក់ព័ន្ធរៀបចំយន្តការដើម្បីសម្របសម្រួល និងទទួលបណ្តឹងនូវអំពើហិង្សាលើកុមារ និងស្ត្រីដែលក្នុងនោះមានក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, ក្រសួងកិច្ចការនារី, ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃជាដើម។

---

[១៥៤] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

### ១.៥.៧.១២ អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ «អ.ជ.ក»

ដើម្បីដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដូចជា វិវាទរដ្ឋប្បវេណី វិវាទពាណិជ្ជកម្ម និងវិវាទដទៃទៀត ព្រះមហាក្សត្របានបង្កើតអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ «អ.ជ.ក»[១៥៥] ជាយន្តការបំពេញបន្ថែមឱ្យប្រព័ន្ធដោះស្រាយវិវាទក្នុងការលើកកម្ពស់គុណភាព ប្រសិទ្ធភាព និងភាពឆាប់រហ័សនៃការដោះស្រាយវិវាទតាមរយៈការសម្រុះសម្រួលផ្សះផ្សារក្រៅប្រព័ន្ធតុលាការ ក្នុងគោលបំណងជួយកាត់បន្ថយការកកស្ទះសំណុំរឿងនៅតាមសាលាជម្រះក្តី។ អ.ជ.ក. មានភារកិច្ចទទួលដោះស្រាយពាក្យបណ្តឹងនានា ដែលស្នើសុំឱ្យសម្រុះសម្រួលផ្សះផ្សារវិវាទក្រៅប្រព័ន្ធតុលាការ។ អ.ជ.ក. អាចទទួលពិនិត្យ និថដោះស្រាយពាក្យបណ្តឹងរបស់រូបវន្តបុគ្គល ឬនីតិបុគ្គល ដោយផ្ទាល់ ឬតាមរយៈស្ថាប័នដែលមានការពាក់ព័ន្ធទាំងស្ថាប័នថ្នាក់ជាតិ និងស្ថាប័នថ្នាក់ក្រោមជាតិ។ ម៉្យាងវិញទៀត អ.ជ.ក. ក៏អាចទទួលពិនិត្យនិងដោះស្រាយវិវាទនូវសំណុំក្តីដែលបញ្ជូនពីសាលាជម្រះក្តីជាន់ទាបដែរ ប្រសិនបើភាគីនៃវិវាទបង្ហាញនូវឆន្ទៈឱ្យធ្វើការសម្រុះសម្រួលផ្សះផ្សាវិវាទរបស់ខ្លួន។ កំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទមានអនុភាពអនុវត្តដូចគ្នានឹងសាលក្រមស្ថាពររបស់តុលាការ និងត្រូវទុកជាបន្ទាល់ដែលតុលាការត្រូវជឿរហូតដល់មានភស្តុតាងផ្ទុយ ឬមានភស្តុតាងដែលបង្ហាញអំពីការក្លែងបន្លំ ឬកិរិយាបោកបញ្ឆោតក្នុងកំណត់ហេតុនោះ។

### ១.៥.៧.១៣ ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាល គឺជាស្ថាប័នឯករាជ្យមួយដែលមានអំណាចសម្រេចសេចក្តីដូចមានចែងនៅក្នុងច្បាប់ស្តីពីការងាររបស់ព្រះរាជាណាចក្រកម្ពុជា។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងដោយប្រកាសលេខ ៣៣៨ សកបយ. ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០២ ដោយមានការគាំទ្រ ពីសំណាក់ក្រសួងការងារ សមាគមន៍និយោជក និងសហជីព។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានអំណាចតាមច្បាប់ ដើម្បីជួយភាគីវិវាទដោះស្រាយវិវាទការងាររួមនៅក្នុងប្រទេសកម្ពុជា។ សមាសភាពក្រុមប្រឹក្សាអាជ្ញាកណ្តាលគឺ ១/៣ ស្នើឡើងដោយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ, ១/៣ ស្នើដោយសមាគមន៍និយោជក, និង ១/៣ ស្នើឡើងដោយសហជីពកម្មករនិយោជិត។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលដោះស្រាយវិវាទការងាររួម។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចដោះស្រាយវិវាទសិទ្ធិ និងវិវាទផលប្រយោជន៍។ វិវាទសិទ្ធិគឺជាវិវាទទាក់ទងនឹងសិទ្ធិរបស់ភាគីណាមួយដូចមានចែង ក្នុងច្បាប់ជាធរមាន។ ចំណែកឯវិវាទផលប្រយោជន៍គឺជាវិវាទទាក់ទងនឹងផលប្រយោជន៍នៅពេលអនាគត ហើយវាមិនទាក់ទង

---

[១៥៥] ព្រះរាជក្រឹត្យលេខ នស/រកត/១១២៣/២៣៨១ ស្តីពីការបង្កើត ការរៀបចំ និងកិច្ចដំណើរការរបស់អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២៣

នឹងសិទ្ធិស្របច្បាប់ក្នុងពេលបច្ចុប្បន្នឡើយ។ សេចក្ដីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលចែកចេញជា ២ ប្រភេទគឺ សេចក្ដីបង្គាប់ជាប់កាតព្វកិច្ច និងសេចក្ដីបង្គាប់មិនជាប់កាតព្វកិច្ច។ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលទទួលបានការគាំទ្រពីមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្ដាលលើផ្នែកបច្ចេកទេស និងការគ្រប់គ្រងរដ្ឋបាលទូទៅ។ បច្ចុប្បន្ននេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលត្រូវបានទទួលស្គាល់ថា ជាស្ថាប័នស្នូលដ៏សំខាន់ក្នុងការដោះស្រាយវិវាទការងារនៅព្រះរាជាណាចក្រកម្ពុជា ដែលមានតួនាទីចាំបាច់ក្នុងការលើកកម្ពស់ស្ថេរភាពទីផ្សារការងារ និងរួមចំណែកដល់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចជាតិ។

### ១.៥.៧.១៤ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តកការពាណិជ្ជកម្ម

មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តកការពាណិជ្ជកម្ម (ម.ជ.ម.) គឺជាមជ្ឈមណ្ឌលជាតិដែលផ្សះផ្សាវិវាទដោយប្រើប្រាស់វេទិកាមជ្ឈត្តកម្មដែលស្ថិតនៅក្នុងឬ ក្រៅក្របខ័ណ្ឌនៃការគ្រប់គ្រងរបស់ស្ថាប័នផ្សះផ្សាអចិន្ត្រៃយ៍។ ម.ជ.ម. ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៦/០១០ ស្ដីពីការប្រកាសឱ្យប្រើច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។ ដោយឡែក ម.ជ.ម. ទើបដំណើរការនៅក្នុងឆ្នាំ ២០១៣[156] តែប៉ុណ្ណោះតាមការលើកឡើងរបស់គេហទំព័រផ្លូវការរបស់ ម.ជ.ម.។ ម.ជ.ម. មានភារកិច្ចដូចជាជំរុញដោះស្រាយវិវាទពាណិជ្ជកម្មតាមរយៈការផ្សះផ្សា និងភារកិច្ចគាំទ្រឱ្យដំណើរការនៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការពាណិជ្ជកម្មផ្សេងទៀត។ អ្នកជំនួញ និងរដ្ឋាភិបាលក្នុងតំបន់ បានជ្រើសយកមជ្ឈត្តការដោយសារតែវាមានភាពបត់បែន ការបញ្ចប់ជាស្ថាពរ ការចំណាយតិច ភាពអាចអនុវត្តបាន អព្យាក្រឹតភាព ភាពជាអន្តរជាតិ និងភាពសម្ងាត់។ មជ្ឈត្តវិនិច្ឆ័យរបស់ ម.ជ.ម. ត្រូវការទទួលស្គាល់ ប្ដឹងជំទាស និងដាក់ឱ្យអនុវត្តតាមរយៈសាលាឧទ្ធរណ៍នៃព្រះរាជាណាចក្រកម្ពុជា ហើយតុលាការកំពូលមានសមត្ថកិច្ចជំនុំជំរះចុងក្រោយក្នុងសេចក្ដីសម្រេចរបស់សាលាឧទ្ធរណ៍។

### ១.៥.៧.១៥ ស្ថាប័នបណ្ដុះបណ្ដាលច្បាប់

ស្ថាប័នបណ្ដុះបណ្ដាលច្បាប់នៅកម្ពុជាដើរតួនាទីយ៉ាងសំខាន់លើការអប់រំច្បាប់ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈច្បាប់ដល់ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី មេធាវី មន្ត្រីរាជការ និងអ្នកជំនាញផ្នែកច្បាប់សម្រាប់វិស័យសាធារណៈនិងឯកជន។ ការបណ្ដុះបណ្ដាលច្បាប់នៅកម្ពុជាបានវិវត្តយ៉ាងខ្លាំងចាប់តាំងពីសម័យកាលនៃការកសាងប្រទេសជាតិឡើងវិញក្រោយជម្លោះ ប៉ុន្តែនៅតែប្រឈមមុខនឹងបញ្ហាប្រឈមទាក់ទងនឹងគុណភាព ភាពស៊ីសង្វាក់គ្នា និងអង្គិតភាពជាមួយនឹងការអនុវត្ត។ យ៉ាងណាមិញ ស្ថាប័នដែលដើរតួ

[156] មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការពាណិជ្ជកម្ម, ដកចេញពី https://ncac.org.kh/km/services/arbitration/why-ncac/

នាទីក្នុងការជម្រុញវិស័យអប់រំច្បាប់នៅកម្ពុជារួមមាន គ្រឹះស្ថានអប់រំសាធារណៈនិងឯកជន និងសាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដូចជា បណ្ឌិតសភាភូមិន្ទយុត្តិធម៌កម្ពុជា មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី រាជបណ្ឌិត្យសភានគរបាលកម្ពុជា សាលាភូមិន្ទរដ្ឋបាល សាលាជាតិពន្ធដារ និងសាលាជាតិគយជាដើម។

### ១.៥.៨ ទំនាក់ទំនងរបស់ស្ថាប័ននិងតួអង្គក្នុងវិស័យច្បាប់

#### ១.៥.៨.១ ស្ថាប័ននីតិប្រតិបត្តិនិងនីតិបញ្ញត្តិ

ដំណើរការនៃការរៀបចំបង្កើតច្បាប់នៅកម្ពុជា គឺជាកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធរវាងស្ថាប័ននីតិប្រតិបត្តិ និងនីតិបញ្ញត្តិ ក្នុងដំណាក់កាលដូចខាងក្រោម៖

នៅក្នុងដំណាក់កាលទី១ នីតិវិធីនៃសេចក្តីព្រាង ឬសេចក្តីស្នើច្បាប់ មានយន្តការដាច់ដោយឡែកពីគ្នា។ សេចក្តីព្រាងច្បាប់គឺត្រូវរៀបរៀងដោយស្ថាប័នសាមី អន្តរក្រសួង ឬជាមួយនឹងស្ថាប័នផ្សេងទៀតដោយត្រូវរៀបរៀងដោយក្រុមអ្នកច្បាប់ (ក្រុមប្រឹក្សានីតិកម្ម, ក្រុមនីតិកម្ម, មន្ត្រីនីតិកម្ម) ក្នុងការពិនិត្យមើលជាបឋមលើធម្មនុញ្ញភាព និងច្បាប់ដែលពាក់ព័ន្ធដែលនៅជាធរមាន មុននឹងបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រីដើម្បីពិនិត្យ។[១៥៧] ការប្រជុំនេះ អាចធ្វើឡើងពីមួយឬច្រើនលើកតាមការចាំបាច់ មុននឹងដាក់ជូនអង្គប្រជុំគណៈរដ្ឋមន្ត្រីដើម្បីពិនិត្យ និងសម្រេច។ ក្នុងដំណាក់កាលនេះ ក្រុមប្រឹក្សាអ្នកច្បាប់ មានតួនាទីជាសេនាធិការបច្ចេកទេសក្នុងការពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់។ បន្ទាប់មក សេចក្តីព្រាងទាំងនោះត្រូវបានបញ្ជូនទៅសុំការសម្រេចពីគណៈរដ្ឋមន្ត្រី ដើម្បីក្លាយជាសេចក្តីព្រាងច្បាប់ផ្លូវការរបស់រដ្ឋាភិបាល។ នាយករដ្ឋមន្ត្រីត្រូវបំពេញបែបបទ ដើម្បីផ្ញើសេចក្តីព្រាងច្បាប់ជូនប្រធានរដ្ឋសភា មានដូចជាអត្ថបទសេចក្តីព្រាងច្បាប់និងលិខិតស្នើសុំឱ្យរដ្ឋសភាពិនិត្យនិងអនុម័ត សេចក្តីថ្លែងហេតុដែលចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រី។ ចំពោះសេចក្តីស្នើច្បាប់ គឺជាការផ្តួចផ្តើមគំនិតដោយតំណាងរាស្ត្រ ឬសមាជិកព្រឹទ្ធសភា ដែលសេចក្តីផ្តើមនេះត្រូវដាក់ឱ្យក្រុមអ្នកជំនាញច្បាប់ដែលពាក់ព័ន្ធប្រជុំពិនិត្យ ពិភាក្សាអំពីធម្មនុញ្ញភាព និងបញ្ហាទាក់ទងទៅនឹងច្បាប់នានាជាធរមាន រហូតដល់សម្រេចបានជាសេចក្តីស្នើច្បាប់ចុងក្រោយ។ អ្នករៀបចំសេចក្តីស្នើច្បាប់ ឬតំណាងក្រុមតំណាងរាស្ត្រ ឬក្រុមសមាជិកព្រឹទ្ធសភាហត្ថលេខី ត្រូវ

[១៥៧] VITHYA, "នីតិវិធីនៃការកសាងច្បាប់," Nac.org.kh, ២០២៤, https://nac.org.kh/group-article/៣៨.

ធ្វើទម្រង់បែបបទផ្ញើជូនប្រធានរដ្ឋសភាមានជាអាទិ៍ អត្ថបទសេចក្តីស្នើច្បាប់ លិខិតស្នើសុំឱ្យរដ្ឋសភា ពិនិត្យ និងអនុម័ត និងសេចក្តីថ្លែងហេតុ។

បន្ទាប់ពីទទួលបានសេចក្តីព្រាង ឬសេចក្តីស្នើច្បាប់ ប្រធានរដ្ឋសភានឹងកោះប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ដើម្បីពិនិត្យ សម្រេច បញ្ជូនសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ឱ្យគណៈកម្មការជំនាញពិនិត្យ។ គណៈកម្មការជំនាញ ត្រូវធ្វើការប្រជុំផ្ទៃក្នុង អាចរៀបចំវេទិកាសាធារណៈដើម្បីស្តាប់និងប្រមូលអនុសាសន៍ពីសាធារណៈមតិ រៀបចំកិច្ចប្រជុំជាមួយតំណាងរាជរដ្ឋាភិបាល ឬតំណាងក្រុមតំណាងរាស្ត្រ ឬក្រុមសមាជិកព្រឹទ្ធសភាហត្ថលេខីនៃសេចក្តីស្នើច្បាប់ដើម្បីប្រជុំមួយលើកឬច្រើនលើក ដើម្បីកែប្រែឬរក្សាទុកទាំងស្រុងមុននឹងអនុម័តព្រមឬមិនព្រមដាក់ចូលសម័យប្រជុំរដ្ឋសភា។ កូរ៉ុមសម្រាប់ការប្រជុំគណៈកម្មការនានាត្រូវឱ្យមានលើសពីពាក់កណ្តាលនៃចំនួនសមាជិកទាំងមូល ហើយការអនុម័តត្រូវយកតាមសម្លេងភាគច្រើនដាច់ខាតនៃចំនួនសមាជិកគណៈកម្មការទាំងមូល។ គណៈកម្មការជំនាញធ្វើលិខិតជូនប្រធាន គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ធ្វើរបាយការណ៍អំពីលទ្ធផលនៃការពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ និងងរៀបចំកិច្ចប្រជុំពិនិត្យនិងអនុម័តបញ្ចូលក្នុងរបៀបវារៈសម័យប្រជុំរដ្ឋសភា។ នាសម័យប្រជុំរដ្ឋសភា ត្រូវអនុម័តយល់ព្រមបញ្ចូលការស្នើសុំនៅក្នុងរបៀបវារៈមុននឹងប្រធានគណៈកម្មការជំនាញអាចរាយការណ៍អំពីលទ្ធផលការងារជូនរដ្ឋសភា។ ក្នុងនោះ សេចក្តីព្រាងច្បាប់ សេចក្តីស្នើច្បាប់ ឬញត្តិណាមួយដែលត្រូវបានប្រកាសថាប្រញាប់ ត្រូវចុះក្នុងរបៀបវារៈមុន។ ការពិភាក្សានិងអនុម័តត្រូវធ្វើឡើងដោយ ពិភាក្សានិងអនុម័តលើខ្លឹមសារទាំងមូលលើមូលហេតុណាមួយដែលច្បាប់គួរ ឬមិនគួរយកមកពិចារណា ពិភាក្សានិងអនុម័តលើមាត្រា ឬលើជំពូកម្តងមួយដោយអានអត្ថបទសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ទាំងស្រុងឬដោយធ្វើរបាយការណ៍សង្ខេបខ្លឹមសារជំពូកដោយមិនអានអត្ថបទ ឬអង្គសភាអាចប្រើនីតិវិធីសង្ខេបដោយពិភាក្សាតែមាត្រា ឬជំពូកណាដែលមានសំណើធ្វើវិសោធនកម្មជាលាយលក្ខណ៍អក្សរ។ តំណាងរាជរដ្ឋាភិបាល ឬតំណាងក្រុមតំណាងរាស្ត្រ ឬក្រុមសមាជិកព្រឹទ្ធសភាហត្ថលេខី និងប្រធានគណៈកម្មការជំនាញ ត្រូវសហការគ្នាការពារសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះ។

អត្ថបទនៃសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ដែលរដ្ឋសភាបានអនុម័តលើកដំបូងរួចហើយ ត្រូវបញ្ជូនទៅព្រឹទ្ធសភាដើម្បីពិនិត្យនិងផ្តល់យោបល់យ៉ាងយូរត្រឹមរយៈពេលមួយខែ ឬ៥ថ្ងៃក្នុងករណីប្រញាប់។ [១៥៨] ក្នុងករណីដែលព្រឹទ្ធសភាមិនបានឆ្លើយតបឬឆ្លើយតបស្របរយៈពេលដែលបានកំណត់

[១៥៨] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា១១៣ថ្មី។ "នីតិវិធីនៃការពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង," គេហទំព័រ ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា, ២០២៥។

នោះច្បាប់ដែលរដ្ឋបានអនុម័តយល់ព្រមនឹងយកទៅប្រកាសឱ្យប្រើ។[១៥៩] ប្រសិនបើព្រឹទ្ធសភា ស្នើសុំឱ្យកែសម្រួលសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះ រដ្ឋសភាត្រូវយកមកពិចារណាភ្លាមជាលើកទី២ ដោយពិនិត្យនិងសម្រេចតែត្រង់បទប្បញ្ញត្តិ ឬចំណុចណាដែលព្រឹទ្ធសភាសុំឱ្យកែសម្រួល និងបដិសេធចោលទាំងមូល ឬទុកជាបានការខ្លះ។[១៦០] ទំនាក់ទំនងរវាងរដ្ឋសភា និងព្រឹទ្ធសភាលើការផ្តល់យោបល់និងការកែប្រែលើសេចក្តីព្រាងច្បាប់ឬសេចក្តីស្នើច្បាប់ ត្រូវកំណត់ត្រឹមរយៈពេលមួយខែ ឬ១០ថ្ងៃប្រសិនបើទាក់ទងនឹងការសម្រេចថវិកាជាតិនិងហិរញ្ញវត្ថុ ឬ២ថ្ងៃក្នុងករណីប្រញាប់។[១៦១] បន្ថែមពីនេះ ប្រសិនបើរដ្ឋសភាទុកឱ្យហួសរយៈពេលកំណត់ឬពន្យាពេលដែលកំណត់ទុកសម្រាប់ពិនិត្យនោះ រយៈពេលជាគោលការណ៍សម្រាប់រដ្ឋសភានឹងត្រូវផ្តល់ឱ្យដូចគ្នាចំពោះព្រឹទ្ធសភាដែរ។ ក្នុងករណីដែលព្រឹទ្ធសភាបដិសេធសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះជាអសារបង់ រដ្ឋសភាមិនអាច នឹងយកមក ពិចារណាជាលើកទី២បាន មុនរយៈពេលមួយខែទេ ឬត្រូវបន្ថយមកត្រឹម១៥ថ្ងៃ បើពិនិត្យពីថវិកា ជាតិ និងហិរញ្ញវត្ថុ និងត្រឹមតែ៤ថ្ងៃ បើជាការប្រញាប់។ ក្នុងការពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ជាលើកទី២នេះ រដ្ឋសភាត្រូវអនុម័តដោយ វិធីបោះឆ្នោតចំហ និងយកតាមមតិភាគច្រើនដាច់ខាត។ សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ណា ដែលបានសម្រេចដោយរដ្ឋសភា និងព្រឹទ្ធសភាស្របតាមនីតិវិធីដូចខាងលើ នឹងត្រូវបានយកទៅប្រកាសឱ្យប្រើ។

នីតិវិធីនៃការប្រកាសឱ្យប្រើច្បាប់ ត្រូវផ្តើមដោយប្រធានរដ្ឋសភាក្នុងការផ្ញើលិខិត និងឯកសារភ្ជាប់ជូននាយករដ្ឋមន្ត្រី ដើម្បីអនុវត្តតាមនីតិវិធី ស្នើសុំព្រះមហាក្សត្រ ទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រម ប្រកាសឱ្យប្រើ។ ច្បាប់ត្រូវចូលជាធរមាននៅរាជធានីភ្នំពេញក្នុងរយៈពេល១០ថ្ងៃគត់ និងក្នុងរយៈពេល២០ថ្ងៃគត់ ក្រោយពីប្រកាសឱ្យប្រើ។[១៦២] ក្នុងករណីដែលច្បាប់ចែងថាប្រញាប់ ច្បាប់ត្រូវចូលជាធរមានភ្លាមៗនៅទូទាំងប្រទេសក្រោយប្រកាសឱ្យប្រើ។[១៦៣] ដោយឡែកចំពោះច្បាប់រៀបចំអង្គការ បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ត្រូវផ្ញើជូន ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីពិនិត្យអំពីធម្មនុញ្ញភាព ជាមុនសិន មុននឹងប្រកាសឱ្យប្រើ។[១៦៤] ក្នុងនោះផងដែរ រាល់ការអនុម័តរបស់រដ្ឋសភាដែល

---

[១៥៩] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា១១៣ថ្មី។

[១៦០] Ibid.

[១៦១] Ibid.

[១៦២] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៩៣ថ្មី។

[១៦៣] Ibid.

[១៦៤] Ibid.

ផ្ទុយនឹងគោលការណ៍រក្សាការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា និងប៉ះពាល់ដល់ឯកភាពនយោបាយ ឬការគ្រប់គ្រងរដ្ឋបាលរបស់ប្រទេសជាតិ នឹងត្រូវមោឃភាពដោយក្រុមប្រឹក្សាធម្មនុញ្ញ។[១៦៥]

### ១.៥.៨.២ ស្ថាប័ននីតិប្រតិបត្តិនិងតុលាការ

ទំនាក់ទំនងរវាងក្រសួងយុត្តិធម៌និងសាលាជម្រះក្ដី គឺជាទំនាក់ទំនងខ្សែដេកដ៏សំខាន់បំផុតមួយ។ ទោះបីជាអំណាចតុលាការជាអំណាចឯករាជ្យក៏ដោយ ប៉ុន្តែក្នុងទិដ្ឋភាពរដ្ឋបាលនិងហិរញ្ញវត្ថុ តុលាការត្រូវការការគាំទ្រពីក្រសួងយុត្តិធម៌។ ក្រសួងមានតួនាទីរៀបចំកញ្ចប់ថវិកា ផ្ដល់បុគ្គលិករដ្ឋបាល និងរៀបចំហេដ្ឋារចនាសម្ព័ន្ធចាំបាច់នានា ដើម្បីឱ្យស្ថាប័នតុលាការអាចដំណើរការទៅបាន។ ការផ្សារភ្ជាប់នេះធានាថាអំណាចតុលាការមានធនធានគ្រប់គ្រាន់ក្នុងការបំពេញភារកិច្ចផ្ដល់យុត្តិធម៌ជូនប្រជាពលរដ្ឋ។

### ១.៥.៨.៣ ស្ថាប័នបណ្ដុះបណ្ដាលច្បាប់និងប្រព័ន្ធយុត្តិធម៌

ដើម្បីអាចប្រកបវិជ្ជាជីវៈច្បាប់បាន ប្រព័ន្ធច្បាប់កម្ពុជាបានកំណត់ផ្លូវយ៉ាងច្បាស់លាស់ដែលចាំបាច់ត្រូវចាប់ផ្ដើមពីគ្រឹះស្ថានឧត្ដមសិក្សា ឬមហាវិទ្យាល័យច្បាប់ ដែលផ្ដល់ចំណេះដឹងច្បាប់មូលដ្ឋានកម្រិតបរិញ្ញាបត្រច្បាប់។ បន្ទាប់ពីបញ្ចប់ការសិក្សា និស្សិតត្រូវឆ្លងកាត់ការបណ្ដុះបណ្ដាលវិជ្ជាជីវៈនៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា តាមរយៈមជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជិវៈមេធាវី សម្រាប់អ្នកចង់ក្លាយជាមេធាវី ឬនៅបណ្ឌិតសភាភូមិន្ទយុត្តិធម៌កម្ពុជា សម្រាប់អ្នកចង់ក្លាយជាចៅក្រម ឬព្រះរាជអាជ្ញា។ ជំហានចុងក្រោយនៃទំនាក់ទំនងនេះគឺការចូលទៅបម្រើការក្នុងប្រព័ន្ធយុត្តិធម៌ជាផ្លូវការ ពោលគឺនៅតាមសាលាជម្រះក្ដី។ ទំនាក់ទំនងនេះធានាបាននូវគុណភាព និងរក្សាបាននូវក្រមសីលធម៌និងក្រមវិជ្ជាជីវៈរបស់អ្នកច្បាប់នៅក្នុងសង្គម។

### ១.៥.៨.៤ យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនិងតុលាការ

ក្រៅពីការជម្រះក្ដីតាមរយៈប្រព័ន្ធតុលាការ កម្ពុជាក៏មានយន្តដោះវិវាទក្រៅប្រព័ន្ធតុលាការតាមរយៈស្ថាប័នដូចបានរៀបរាប់ខាងលើ។ ស្ថាប័នទាំងនេះមានតួនាទីដោះស្រាយវិវាទ ដោយមិនចាំបាច់ឆ្លងកាត់នីតិវិធីតុលាការដែលស្មុគស្មាញ។ ទោះជាយ៉ាងណាក៏ដោយ ទំនាក់ទំនងរវាងយន្តដោះវិវាទក្រៅប្រព័ន្ធតុលាការនិងតុលាការនៅតែមានភាពចាំបាច់ ព្រោះក្នុងករណីមួយចំនួនភាគីនៃវិវាទមុនសុខចិត្ត ឬ

[១៦៥] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៩២។

មិនអនុវត្តតាមសេចក្តីសម្រេចរបស់អាជ្ញាកណ្តាល ភាគីម្ខាងទៀតអាចបញ្ជូនវិវាទ ឬស្នើសុំទៅតុលាការដើម្បីបង្គាប់ឱ្យមានការអនុវត្តដោយបង្ខំតាមច្បាប់។

### ១.៥.៩ ឧត្តមានុវត្តន៍អន្តរជាតិ

តាមរយៈការស្រាវជ្រាវ យន្តការសម្របសម្រួលដែលប្រទេសមួយចំនួនលើពិភពលោកប្រើប្រាស់សម្រាប់សេចក្តីព្រាងច្បាប់ ការពិនិត្យពិគ្រោះយោបល់ ការប្រើប្រាស់ច្បាប់និងលិខិតបទដ្ឋានគតិយុត្តឱ្យសមស្របគឺ ទីកន្លែងកណ្តាលមួយដែលដើរតួនាទីជាអ្នកសម្របសម្រួលការងារទាំងនោះ។ ក្នុងន័យនេះ យន្តការនៅប្រទេសបារាំងនិងប្រទេសសង្ហបុរីអាចជាបទពិសោធសម្រាប់កម្ពុជាក្នុងការសិក្សាជាគម្រូ។

#### ១.៥.៩.១ អគ្គលេខាធិការដ្ឋាននៃរដ្ឋាភិបាល (Secrétariat général du Gouvernement) ប្រទេសបារាំង

ប្រទេសបារាំងមានអគ្គលេខាធិការដ្ឋានដែលមានឈ្មោះថា Secrétariat général du Gouvernement (SGG) ដែលមានមានបេសកកម្មសំខាន់ៗបួនគឺ ទី១. អង្គភាពសម្របសម្រួលរដ្ឋាភិបាលក្នុងការសម្រេចចិត្តលើអ្វីមួយ, ទី២. ទីប្រឹក្សារដ្ឋាភិបាល, ទី៣. ការរៀបចំរដ្ឋាភិបាលថ្មី, និងទី៤. អ្នកត្រួតពិនិត្យលើអភិបាលកិច្ចរបស់នាយករដ្ឋមន្ត្រី។ SGG មានតួនាទីសំខាន់គ្រប់ដំណាក់កាលទាំងអស់នៃពេល រដ្ឋាភិបាលបារាំងមានការសម្រេចចិត្តលើអ្វីមួយ និងជាអង្គភាពកណ្តាលក្នុងដំណើរការតាក់តែងច្បាប់របស់រដ្ឋាភិបាលបារាំង។ SGG ដើរតួសម្របសម្រួលកិច្ចប្រជុំអន្តរក្រសួង និងមានតួនាទីកត់ត្រានូវជំហររបស់រដ្ឋាភិបាលក្នុងការស្នើធ្វើច្បាប់និងលិខិតបទដ្ឋានគតិយុត្ត។ បន្ទាប់មក SGG ត្រូវរាយការណ៍ជំហររបស់រដ្ឋាភិបាលទៅក្រុមប្រឹក្សាជាតិ (Council of State/Conseil d'État)[១៦៦] និងត្រូវមានទីប្រឹក្សាម្នាក់ចូលរួមកិច្ចប្រជុំរបស់ក្រុមប្រឹក្សាជាតិ ដើម្បីធានាគោលជំហររបស់រដ្ឋាភិបាលត្រឹមត្រូវដូចសំណើ។ ទីប្រឹក្សានោះមានតួនាទីកត់ត្រាចំណុចឯកភាព និងចំណុចមិនឯកភាពរបស់ក្រុមប្រឹក្សាជាតិ។ ក្រោយមក SGG ត្រូវរៀបចំរបៀបវារៈសម្រាប់គណៈរដ្ឋមន្ត្រី និងអនុក្រឹត្យសម្រាប់ធ្វើបទបង្ហាញចំពោះមុខសភា ផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត និងតាមដាននីតិវិធីអនុម័តច្បាប់[១៦៧]។ ក្រោយច្បាប់ត្រូវបានអនុម័ត SGG ត្រូវប្រមូលរាល់ហត្ថលេខាតម្រូវដោយរដ្ឋធម្មនុញ្ញ និងធានាការផ្សព្វផ្សាយក្នុង Legifrance និង Official

---

[១៦៦] Conseil d'État ជាអង្គភាពប្រឹក្សាច្បាប់កំពូលរបស់ប្រទេសបារាំង

[១៦៧] General Secretariat of the Government (SGG). Info.gouv.fr. Retrieved from https://www.info.gouv.fr/organisation/secretariat-general-du-gouvernement-sgg/fonctions-du-sgg?utm_source=chatgpt.com

Journal។ ក្នុងការអនុវត្តជាក់ស្តែង SGG មិនត្រឹមតែជាអគ្គលេខាធិការដ្ឋានសម្រាប់គោលជំហរបស់រដ្ឋាភិបាលបារាំងប៉ុណ្ណោះទេ ប៉ុន្តែក៏ជាអង្គភាពត្រួតពិនិត្យគុណភាពច្បាប់ផងដែរ ដោយផ្តោតលើបច្ចេកទេសក្នុងការតាក់តែង ជានាសង្គតិភាពគ្នារវាងសេចក្តីព្រាងទៅនឹងឋានានុក្រមនៃច្បាប់ សម្របសម្រួលការវិភាគផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត និងការងាររដ្ឋបាលអង្គភាពសម្របសម្រួលច្បាប់ របស់រដ្ឋាភិបាលបារាំង។

ម្យ៉ាងវិញទៀត SGG ដើរតួនាទីជាទីប្រឹក្សាផ្នែកច្បាប់របស់នាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីនៅបារាំង និងពិនិត្យលើខ្លឹមសារនិងទម្រង់នៃច្បាប់និងលិខិតបទដ្ឋានគតិយុត្ត។ ជាចុងក្រោយ SGG ចាត់ចែងការផ្សព្វផ្សាយលើគេហទំព័រ Legifrance និងមគ្គទេសសិល្បសាស្ត្រនីតិកម្ម។ SGG ជាអង្គភាពអចិយត្រៃយ៍ដែលសមាជិកមិនផ្លាស់ប្តូរទេ ទោះបីមានរដ្ឋាភិបាលថ្មីក៏ដោយ ដោយ SGG មានតួនាទីសម្របសម្រួលរដ្ឋាភិបាលថ្មីក្នុងការចូលកាន់មុខតំណែង។ SGG ត្រួតពិនិត្យអភិបាលកិច្ចរបស់នាយករដ្ឋមន្ត្រីបារាំង និងមានបេសកកម្មក្នុងការធ្វើទំនើបកម្មអភិបាលកិច្ចឱ្យកាន់តែរៀកចម្រើន។

#### ១.៥.៩.២ ក្រសួងច្បាប់ (Ministry of Law) និងការិយាល័យអគ្គរដ្ឋអាជ្ញា (Attorney General Chamber) ប្រទេសសង្ហបុរី

ក្រសួងច្បាប់ (MinLaw) គឺជាក្រសួងមួយក្នុងចំណោមក្រសួងទាំង ១៦ របស់រដ្ឋាភិបាលសិង្ហបុរី។ ក្រសួងច្បាប់ ជាក្រសួងដែលរៀបចំគោលនយោបាយច្បាប់។ ផ្នែកគោលនយោបាយច្បាប់ ជាផ្នែកមួយទទួលខុសត្រូវលើមុខងារៈ ទី១. ការកែទម្រង់ច្បាប់ក្រោមសម្ថកិច្ចរបស់ខ្លួន, ទី២. ពិនិត្យលើសេចក្តីព្រាងច្បាប់ និងវាយតម្លៃគោលនយោបាយច្បាប់, ទី៣. ផ្សព្វផ្សាយវប្បធម៌នីតិរដ្ឋ, ទី៤.កិច្ចការទំនាក់ទំនងនឹងសភា, និងទី៥.ឧក្រិដ្ឋវិទ្យា (Criminology)។ ជានីតិវិធី MinLaw ត្រូវពិនិត្យមើលគោលនយោបាយរបស់ក្រសួងនីមួយៗដើម្បីធានាថា គោលនយោបាយនិងសំណើនីមួយៗស្របតាមគោលការណ៍ទាំង ៧ របស់រដ្ឋាភិបាល ដែលបានកំណត់ជាធរមានគឺ ១). អាចទុកចិត្តបាន (Reliance) ២). ធានាភាពស្មើគ្នា (Equality) ៣). ធានាឱ្យមានសង្គតិភាព (Consistency) ៤). ភាពសមមាត្រ (Proportionality) ៥). ធានាការប្រើប្រាស់អំណាចដោយការទំនួលខុសត្រូវ (Responsible Exercise of Power) ៦). ធានាឱ្យមានការបែងចែកអំណាចទាំងបី (Separation of Powers) និង៧). ធានាឱ្យមានយុត្តិធម៌ (Natural Justice)។ បន្ទាប់មក ក្រសួងសាមីត្រូវរៀបចំការពិគ្រោះយោបល់សាធារណៈ (អាចសហការជាមួយក្រសួងច្បាប់បាន) ដើម្បីទទួលមតិលើគោលនយោបាយឬសំណើនោះ ជានានូវគោលការណ៍ប្រជាធិបតេយ្យ។ MinLaw មានតួនាទីរៀបចំជាសង្ខេបនូវលទ្ធផលនៃការពិគ្រោះយោបល់ជាសាធារណៈនោះ។

ការិយាល័យអគ្គរដ្ឋអាជ្ញា (AGC) ដែលដឹកនាំដោយអគ្គរដ្ឋអាជ្ញា មានលក្ខណៈឯករាជ្យមិនស្ថិតក្រោមចំណុះរដ្ឋាភិបាលឬស្ថាប័ននយោបាយណាមួយឡើយ។ ការិយាល័យអគ្គរដ្ឋអាជ្ញាគឺជាស្ថាប័នមួយដ៏សំខាន់ មានតួនាទីជាអ្នកគាំពារផលប្រយោជន៍សាធារណៈ ជាស្ថាប័នជានានីតិរដ្ឋនៅសិង្ហបុរី តាក់តែងនូវសេចក្តីព្រាងច្បាប់ និងលិខិតគតិយុត្តក្រោមច្បាប់។ លើសពីនេះ AGC ក៏មានតួនាទី ផ្តល់ការប្រឹក្សាផ្នែកច្បាប់ពាក់ព័ន្ធរដ្ឋធម្មនុញ្ញ និងច្បាប់រដ្ឋបាល ហិរញ្ញវត្ថុសាធារណៈ ការទិញដីធ្លី អនីត្យានុកូល ការបោះឆ្នោត ច្បាប់ស្តីពីការប្រកួតប្រជែង ភាពជាដៃគូ រវាងរដ្ឋនិងឯកជន និងច្បាប់ស្តីពីកម្មសិទ្ធិបញ្ញា ជាដើម។ ដើម្បីជានាការតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ឱ្យមានគុណភាព ឆ្លុះបញ្ចាំងនឹងគោលនយោបាយដែលបានដាក់ចេញ AGC បានកំណត់នូវគោលការណ៍ច្បាស់លាស់ក្នុងការតាក់តែង គឺគោរពរដ្ឋធម្មនុញ្ញជាច្បាប់កំពូល និងគោរពនីតិរដ្ឋ ការតាក់តែងច្បាប់ត្រូវប្រាកដថាអាចអនុវត្តបានជាប់លាប់ និងសមស្រប ការអនុវត្តគោលនយោបាយឱ្យមានប្រសិទ្ធភាព មានភាពច្បាស់លាស់ និងប្រាកដប្រជា (កាត់បន្ថយការទៅតុលាការ និងកាត់បន្ថយការចំណាយក្នុងការអនុវត្ត) កំណត់វិសាលភាពឱ្យបានច្បាស់លាស់ និងការបញ្ចៀសនូវផលវិបាកដែលកើតឡើងដោយអចេតនា។ ក្នុងនាម ជាអ្នកសរសេរច្បាប់ជូនបណ្តាក្រសួង ស្ថាប័ន របស់រដ្ឋាភិបាល ឱ្យស្របតាមបរិបទ និងតម្រូវការ AGC មានកិច្ចសហការយ៉ាងស្អិតរមួតជាមួយក្រសួង ស្ថាប័នជាអ្នកស្នើ និងក្រសួងច្បាប់ ដើម្បីត្រួតពិនិត្យលើសំណើទាំងនោះ។ បន្ថែមពីនេះ ក្នុងនីតិវិធីនៃការតាក់តែងសេចក្តីព្រាងច្បាប់ AGC បានកំណត់នូវឧបករណ៍ជាក់លាក់របស់ខ្លួន សម្រាប់ក្រសួង ស្ថាប័នជាម្ចាស់សំណើដោយឆ្លើយតបនឹងសំណួរគោលមួយចំនួន ដូចជា Why? What? Who? Where? How? If? But? និងកម្រងសំណួរពាក់ព័ន្ធនឹងវិស័យ អន្តរវិស័យផ្សេងៗទៀត ជាមួយនឹងការរក្សាទុកនូវកំណត់ហេតុរាល់កិច្ចប្រជុំ រាល់ការរៀបចំសេចក្តីព្រាងច្បាប់ទាំងអស់ ដើម្បីទុកជាមូលដ្ឋាន។

**អនុសាសន៍**

ដើម្បីពង្រឹងអភិបាលកិច្ច និងទំនាក់ទំនងរវាងស្ថាប័នទាំងនេះឱ្យកាន់តែប្រសើរឡើង ប្រព័ន្ធច្បាប់កម្ពុជាគួរផ្តោតលើចំណុចសំខាន់ៗ ដូចខាងក្រោម៖

១. **ការធ្វើបរិវត្តកម្មឌីជីថល៖** បង្កើតប្រព័ន្ធទិន្នន័យរួម (Shared Digital Database) ដែលតភ្ជាប់ពីក្រសួងយុត្តិធម៌ តុលាការ និងគណៈមេធាវី ដើម្បីបង្កើនតម្លាភាព និងភាពហ័សរហួននៃនីតិវិធី។

២. **ការពង្រឹងឯករាជ្យភាពនិងស្វ័យភាព៖** គួរពិចារណាបង្កើនស្វ័យភាពហិរញ្ញវត្ថុដល់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីកាត់បន្ថយការពឹងផ្អែកខ្លាំងពេកលើផ្នែករដ្ឋបាលពីស្ថាប័ននីតិប្រតិបត្តិ។

៣. **ការបណ្តុះបណ្តាលបន្ត៖** ជំរុញកិច្ចសហការរវាងសាលាច្បាប់ និងស្ថាប័នអនុវត្តច្បាប់ (ដូចជាតុលាការ និងក្រុមប្រឹក្សាអាជ្ញាកណ្តាល) តាមរយៈកម្មវិធីកម្មសិក្សា ដើម្បីឱ្យអ្នកច្បាប់ជំនាន់ក្រោយមានទាំងចំណេះដឹងទ្រឹស្តី និងបទពិសោធន៍អនុវត្តផ្ទាល់។

៤. **ផែនទីបង្ហាញផ្លូវ៖** ការពង្រឹងអភិបាលកិច្ច និងទំនាក់ទំនងអន្តរស្ថាប័ន

- **ដំណាក់កាលទី១៖** ការធ្វើសមាហរណកម្មឌីជីថល (Digital Integration) បង្កើតឱ្យមាន «ប្រព័ន្ធគ្រប់គ្រងសំណុំរឿងរួម» ដែលតភ្ជាប់ស្ថាប័នទាំងអស់ក្នុងខ្សែច្រវាក់យុត្តិធម៌។
  - ការតភ្ជាប់រវាងក្រសួងយុត្តិធម៌, តុលាការ និងគណៈមេធាវី៖ បង្កើតបណ្តាញទិន្នន័យអេឡិចត្រូនិកតែមួយ ដែលអនុញ្ញាតឱ្យមេធាវីអាចតាមដានស្ថានភាពសំណុំរឿង និងដាក់ឯកសារតាមអនឡាញ។
  - តម្លាភាព និងគណនេយ្យភាព៖ ការប្រើប្រាស់ប្រព័ន្ធឌីជីថលនឹងកាត់បន្ថយការជួបផ្ទាល់រវាងមន្ត្រី និងពលរដ្ឋ ដែលជួយកាត់បន្ថយអំពើពុករលួយ និងបង្កើនល្បឿននៃការដោះស្រាយក្តី។
- **ដំណាក់កាលទី២៖** ការបង្កើនស្វ័យភាពរចនាសម្ព័ន្ធ (Structural Autonomy) ធានាថា អំណាចតុលាការមានឯករាជ្យភាពពិតប្រាកដពីអំណាចនីតិប្រតិបត្តិ។
  - ការពង្រឹងអំណាចដល់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម៖ ផ្ទេរសិទ្ធិគ្រប់គ្រងថវិកា និងរដ្ឋបាលតុលាការពីក្រសួងយុត្តិធម៌ ទៅឱ្យលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ជាអ្នកចាត់ចែងដោយផ្ទាល់។
  - ការបែងចែកអំណាច៖ នៅពេលដែលតុលាការមានកញ្ចប់ថវិកាផ្ទាល់ខ្លួន វានឹងកាត់បន្ថយឥទ្ធិពលពីស្ថាប័ននីតិប្រតិបត្តិមកលើការសម្រេចសេចក្តីរបស់ចៅក្រម។
- **ដំណាក់កាលទី៣៖** ការធ្វើទំនើបកម្មនៃការតាក់តែងច្បាប់ (Legislative Modernization) ធានាថាច្បាប់ដែលចេញមកមានគុណភាពនិងសង្គតិភាព។
  - តួនាទីគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់និងក្រុមប្រឹក្សាអ្នកច្បាប់៖ ពង្រឹងសមត្ថភាពវិជ្ជាជីវៈរបស់ស្ថាប័នទាំងពីរនេះ ឱ្យក្លាយជាមជ្ឈមណ្ឌលឧត្តមភាព និងជាស្ថាប័នត្រួតពិនិត្យប្រសិទ្ធភាពនិងគុណភាពច្បាប់ចុងក្រោយ មុននឹងបញ្ជូនទៅគណៈរដ្ឋមន្ត្រីពិនិត្យ និងរដ្ឋសភាអនុម័ត។

- ការពិគ្រោះយោបល់សាធារណៈ៖ បង្កើតយន្តការឱ្យគណៈមេធាវី សាលាច្បាប់និងសង្គមស៊ីវិលទាំងអស់មានសិទ្ធិចូលរួមផ្តល់យោបល់ ក្នុងដំណាក់កាលតាក់តែងសេចក្តីព្រាងច្បាប់ ដើម្បីឱ្យច្បាប់ឆ្លុះបញ្ចាំងពីតម្រូវការជាក់ស្តែងក្នុងសង្គម។

**៥. សសរស្តម្ភទាំងបួននៃទំនាក់ទំនងស្ថាប័ន**

- **សសរស្តម្ភទី១៖** ប្រសិទ្ធភាពនិងគុណភាពច្បាប់ (Impact Assessment and Legislative Quality): ការធានាថាច្បាប់ដែលបានព្រាងត្រូវបានវាយតម្លៃប្រសិទ្ធភាពដែលឆ្លើយតបទៅនឹងតម្រូវការសង្គម ដោយគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ ហើយឆ្លងកាត់ការត្រួតពិនិត្យគុណភាពដោយក្រុមប្រឹក្សាអ្នកច្បាប់ ដើម្បីធានាភាពស៊ីសង្វាក់គ្នានិងបម្រើផលប្រយោជន៍សាធារណៈ។
- **សសរស្តម្ភទី២៖** ឯករាជ្យភាពរដ្ឋបាល (Administrative Independence): ការកាត់ផ្តាច់ឥទ្ធិពលរដ្ឋបាលពីក្រសួងយុត្តិធម៌មកលើតុលាការ ដើម្បីពង្រឹងភាពជឿជាក់ពីសំណាក់សាធារណជន។
- **សសរស្តម្ភទី៣៖** ឧត្តមភាពវិជ្ជាជីវៈ (Professional Excellence): ការធានាថា មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី បណ្ឌិតសភាភូមិន្ទយុត្តិធម៌កម្ពុជាសាលាច្បាប់ និងសាលាច្បាប់ទាំងអស់ បណ្តុះបណ្តាលធនធានដែលមានសមត្ថភាពខ្ពស់។
- **សសរស្តម្ភទី៤៖** យុត្តិធម៌ជម្រើស (Alternative Justice): ការពង្រីកតួនាទីនៃយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដើម្បីកាត់បន្ថយការកកស្ទះសំណុំរឿងនៅតុលាការ។

**៦. ការយកគម្រូឧត្តមានុវត្តន៍អន្តរជាតិពីប្រទេសបារាំង និងប្រទេសសង្ហបុរី ដែលអាចជាមេរៀននិងយកមកអនុវត្តសម្រាប់ប្រព័ន្ធច្បាប់កម្ពុជា៖**

- បច្ចុប្បន្ន រដ្ឋាភិបាលកម្ពុជាមានស្ថាប័នក្នុងប្រព័ន្ធច្បាប់ច្រើន ប៉ុន្តែស្ថាប័ននៅកម្ពុជាមិនដូចប្រទេសបារាំងឬប្រទេសសង្ហបុរីទាំងស្រុងទេ ហេតុនេះការរៀបចំស្ថាប័នសម្របសម្រួលក្នុងប្រព័ន្ធច្បាប់តម្រូវឱ្យមានការផ្សំផ្គុំរវាងករណីសិក្សាពីប្រទេសបារាំងនិងប្រទេសសង្ហបុរី។ ជាដំបូង យើងអាចបែងចែកតួនាទីក្នុងយន្តការសម្របសម្រួលជាមុនសិន ដែលតួនាទីអាចមានគឺ អង្គភាពពិនិត្យគោលនយោបាយ អង្គភាពរៀបចំការពិគ្រោះយោបល់សាធារណៈ អង្គភាពផ្តល់ការប្រឹក្សាយោបល់ទៅរដ្ឋាភិបាល អង្គភាពតាក់តែងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត អង្គភាពរៀបចំនីតិវិធីរដ្ឋបាល និងអង្គភាពផ្សព្វផ្សាយច្បាប់ចូលជាធរមាន។ ដើម្បីឱ្យប្រព័ន្ធនេះដំណើរការបានល្អ គួរត្រូវមានឯកសារស្តង់ដារសម្រាប់សេចក្តីព្រាងច្បាប់

នីមួយៗ រួមមាន សេចក្តីបញ្ជាក់គោលនយោបាយពីក្រសួងជំនាញ សេចក្តីសង្ខេបលទ្ធផលនៃការពិគ្រោះយោបល់ សេចក្តីព្រាងច្បាប់និងសេចក្តីពន្យល់បច្ចេកទេស ការវិភាគផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីនិងការសម្របសម្រួលអន្តរក្រសួង។ ការបោះពុម្ពផ្សាយឯកសារពិគ្រោះ និងសេចក្តីឆ្លើយតបចំពោះមតិយោបល់សាធារណៈគួរត្រូវកំណត់ជាដំណាក់កាលស្តង់ដារ ដើម្បីបង្កើនភាពថ្លៃថ្នូរ និងការជឿជាក់លើដំណើរការតែងច្បាប់។ ដោយមិនចាំបាច់បង្កើតស្ថាប័នថ្មី កម្ពុជាអាចពង្រឹង និងបញ្ជាក់តួនាទីរបស់ស្ថាប័នទាំងនេះឱ្យច្បាស់ ដើម្បីឆ្លើយតបទៅនឹងតួនាទីដែលប្រទេសបារាំងនិងប្រទេសសិង្ហបុរីបានបែងចែករវាង SGG, MinLaw និង AGC។

- អនុលោមតាមអនុក្រឹត្យ ១៧០ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៤ ដែលបានកំណត់ពីគោលការណ៍ណែនាំស្តីពីនីតិវិធីនិងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ដែលបានចេញនីតិវិធីសម្រាប់ក្រសួង-ស្ថាប័នអនុវត្តនៅពេលមានសំណើធ្វើច្បាប់និងលិខិតបទដ្ឋានគតិយុត្ត។ ដោយដំណាក់កាលទី១ ក្រសួង-ស្ថាប័នត្រូវរៀបចំផែនការកសាងច្បាប់របស់ក្រសួងសាមី និងបញ្ជូនមកគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ ដើម្បីស្នើសេចក្តីសម្រេចអនុញ្ញាតក្នុងការធ្វើសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត។ ក្នុងករណីក្រសួង-ស្ថាប័នស្នើធ្វើច្បាប់និងអនុក្រឹត្យដែលមានលក្ខណៈជាបទបញ្ញាទូទៅ [១៦៨] ក្រសួង-ស្ថាប័នត្រូវភ្ជាប់ជាមួយទស្សនាទានរួមមួយដែលបញ្ជាក់ពីតម្រូវការចាំបាច់ គោលបំណង អត្ថប្រយោជន៍ ផលប៉ះពាល់ផ្នែកសង្គម សេដ្ឋកិច្ច និងនយោបាយជាតិនិងអន្តរជាតិ។ ដំណាក់កាលទី២ ក្រោយទទួលបានការឯកភាពពីគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ នោះក្រសួងសាមីត្រូវរៀបចំការតាក់តែងសេចក្តីព្រាងបឋម រួចដាក់ពិគ្រោះយោបល់ជាមួយក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងអាចពិគ្រោះយោបលជាមួយសង្គមស៊ីវិល និងផ្នែកឯកជនតាមវិសាលភាពដែលទាក់ទងនឹងបញ្ហាសង្គម បញ្ហាសេដ្ឋកិច្ច និងបញ្ហាថវិការ។ ក្រសួង-ស្ថាប័នត្រូវកែសម្រួលសេចក្តីព្រាងបឋមតាមលទ្ធភាពដែលអាចធ្វើបាន។ ដំណាក់កាលទី៣ ក្រោយកែសម្រួលសេចក្តីព្រាងបឋមរួច ក្រសួងសាមីត្រូវសុំយោបល់ឡើងវិញពីក្រសួង-ស្ថាប័ន រដ្ឋបាលរាជធានី ខេត្តដែលពាក់ព័ន្ធដោយផ្ទាល់ឬប្រយោលលើសេចក្តីព្រាងដែលបានកែសម្រួលហើយ និងអាចធ្វើការពិគ្រោះយោបល់

[១៦៨] ច្បាប់និងព្រះរាជក្រឹត្យមាន ២ប្រភេទគឺ បទបញ្ញាទូទៅ និងការកំណត់មុខដំណែង។

ក្នុងករណីចាំបាច់ជាមួយគណបក្សនយោបាយនានាដែលបានចុះបញ្ជីស្របច្បាប់ សង្គមស៊ីវិល និងផ្នែកសង្គមតាមរយៈលិខិត អង្គប្រជុំ សិក្ខាសាលាឬវេទិកាពិគ្រោះយោបល់ជាសាធារណៈ។ ក្រោយការពិគ្រោះយោបល់នេះ ក្រសួង-ស្ថាប័នត្រូវកែសម្រួលតាមលទ្ធភាពដែលអាចធ្វើបាន និងត្រូវមានកំណត់ហេតុពីគោលជំហរបស់ភាគីដែលចូលរួមផងដែរ។ ដំណាក់កាលទី៤ ក្រសួង-ស្ថាប័នត្រូវបញ្ជូនឯកសារមកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីដំណើរការយន្តការនីតិកម្មរបស់ទីស្តីការគណៈរដ្ឋមន្ត្រី។ ក្រោយសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តត្រូវបានអនុម័ត នោះក្រសួងសាមីត្រូវផ្សព្វផ្សាយពីច្បាប់និងលិខិតបទដ្ឋានគតិយុត្តនោះ និងភ្ជាប់ជូនរាជកិច្ចដើម្បីចុះក្នុងកម្រងឯកសាររាជកិច្ចផងដែរ។

- យើងអាចសង្កេតបានថា អង្គភាពពិនិត្យគោលនយោបាយ អង្គភាពរៀបចំការពិគ្រោះយោបល់សាធារណៈ អង្គភាពផ្តល់ការប្រឹក្សាយោបល់ទៅរដ្ឋាភិបាល អង្គភាពតាក់តែងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត អង្គភាពរៀបចំនីតិវិធីរដ្ឋបាល និងអង្គភាពផ្សព្វផ្សាយច្បាប់ចូលជាធរមានសុទ្ធតែមានក្នុងនីតិវិធីដែលបានកំណត់ក្នុងអនុក្រឹត្យ ១៧០ ខាងលើ។ ក្នុងន័យនេះ គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ជាអង្គភាពពិនិត្យលើគោលនយោបាយនិងសំណើរបស់ក្រសួង-ស្ថាប័ន, ក្រសួង-ស្ថាប័នជាអង្គភាពតាក់តែងច្បាប់និងលិខិតបទដ្ឋានគតិយុត្តនិងរៀបចំការពិគ្រោះយោបល់សាធារណៈ, ក្រុមប្រឹក្សាអ្នកច្បាប់និងក្រុមប្រឹក្សាសង្គម សេដ្ឋកិច្ច វប្បធម៌ និងបរិស្ថានជាអង្គភាពពិនិត្យលើសេចក្តីព្រាងច្បាប់និងអង្គភាពរៀបចំនីតិវិធីរដ្ឋបាល និងអគ្គនាយកដ្ឋានរាជកិច្ចនិងបណ្ណាសារជាអង្គភាពផ្សព្វផ្សាយច្បាប់ចូលជាធរ។ ដោយឡែក យន្តការនេះអាចកែសម្រួលឱ្យមានប្រសិទ្ធភាពជាងមុនផងដែរ ដោយបន្ថែមមុខងារដល់គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ក្នុងការសហការធ្វើសិក្ខាសាលា ឬវេទិការពិគ្រោះយោបល់ជាសាធារណៈជាមួយក្រសួង-ស្ថាប័ន ដើម្បីធានានូវគោលការណ៍ប្រជាធិបតេយ្យ និងសង្គតិភាពនៃគោលបំណងនៃគោលនយោបាយ ឬសំណើរបស់ក្រសួង-ស្ថាប័ន។

## ១.៦. ទម្រង់ និងការវិវត្តនៃប្រភពនៃនីតិនៅកម្ពុជា

ជាសារវតា ប្រព័ន្ធច្បាប់នៅកម្ពុជាបានវិវត្តមកពីច្បាប់ប្រពៃណីដែលឥតសរសេរ មកជាប្រភពច្បាប់ដែលមានការសរសេរវិញ។[១៦៩] យោងតាមលទ្ធផលស្រាវជ្រាវនៃសិក្ខាសាលា ច្បាប់ខ្មែរមានការវិវត្តតាមដំណាក់កាលៗដូចតទៅ៖

- មុនអង្គរ៖
- សម័យអង្គរ៖
- ក្រោយអង្គរ៖
- សម័យទំនើប(ក្រោយបារាំង ដល់មុន១៩៩៣)៖

នាពេលបច្ចុប្បន្ន ចរិតលក្ខណៈសារជាតុនៃសញ្ញាណនីតិរដ្ឋត្រូវបានបញ្ញត្តិនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ជាអាទិ៍ ប្រព័ន្ធរាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញ លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស[១៧០] សិទ្ធិនិងករណីយកិច្ចរបស់ប្រជាពលរដ្ឋ[១៧១] និងបានអនុវត្តយករបបសេដ្ឋកិច្ចទីផ្សារ។[១៧២]

## ១.៧. ទម្រង់ និងប្រភពនៃនីតិនៃព្រះរាជាណាចក្រកម្ពុជា

ការពិភាក្សាអំពីឋានានុក្រមច្បាប់ និងស្ថានភាពប្រព័ន្ធច្បាប់នៃប្រទេសមួយមានភាពស៊ីជម្រៅទាមទារឱ្យមានការសិក្សាទៅលើប្រភពនៃវិធានច្បាប់ទាំងអស់នោះមានភាពច្បាស់លាស់និងប្រាកដប្រជា។[១៧៣] ប្រភពនៃនីតិត្រូវបានចែកជា២ គឺប្រភពនៃដើមកំណើតនីតិ និងប្រភពនៃអនុភាពគតិយុត្ត។[១៧៤] ប្រភពនៃដើមកំណើតច្បាប់គឺផ្តោតទៅលើប្រភពនៃការកកើតច្បាប់តែម្តង រួមមានច្បាប់ទំនៀមទម្លាប់ ច្បាប់ធម្មជាតិ និងច្បាប់ដែលឆ្លងកាត់តាមរយៈបែបបទនីតិកម្មដែលមានការអនុម័តដោយសភា។[១៧៥] រីឯ

---

[១៦៩] Phallack Kong, 'Overview of the Cambodian Legal and Judicial System' in Peng Hor, Phallack Kong and Jörg Menzel (eds), *Introduction to Cambodian Law* (Konrad-Adenauer-Stiftung ២០១២) ៧.

[១៧០] មាត្រា ១ នៃរដ្ឋធម្មនុញ្ញ ១៩៩៣។

[១៧១] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ ១៩៩៣។

[១៧២] មាត្រា ៥៦ នៃរដ្ឋធម្មនុញ្ញ ១៩៩៣។

[១៧៣] Harold G Maier, 'The Authoritative Sources of Customary International Law in the United States' (១៩៨៩) ១០(២) Michigan Journal of International Law ៤៥០.

[១៧៤] Jaap Hage, 'Sources of Law' in Jaap Hage and Bram Akkermans (eds), *Introduction to Law* (២nd edn., Springer ២០១៧) ២៣-២៥.

[១៧៥] Ibid.

ប្រភពនៃអនុភាពគតិយុត្តគឺសំដៅលើវិធានច្បាប់ដែលបង្កើតឡើងដោយបុគ្គល ឬស្ថាប័នដែលមានអំណាចក្នុងការធ្វើនីតិកម្ម ដែលវិធានទាំងនោះមានអនុភាពព្រោះអង្គដែលមានសមត្ថកិច្ចទទួលស្គាល់ថាជាវិធានដែលមានអនុភាព។[១៧៦] ជារួមយោងលើមូលដ្ឋានទាំងនេះ ប្រភពនៃនីតិត្រូវបានរាប់បញ្ចូលទាំងប្រភពដែលមានអនុភាពគតិយុត្ត ដែលជាប្រភពដែលមានលក្ខណៈចាប់បង្ខំក្នុងការអនុវត្ត និងប្រភពដែលពុំមានលក្ខណៈចាប់បង្ខំក្នុងការអនុវត្ត។[១៧៧]

ប៉ុន្តែមានសំណួរចោទឡើងថាការទទួលស្គាល់ប្រភពមួយជាប្រភពនៃនីតិត្រូវមានល័ក្ខខ័ណ្ឌអ្វីខ្លះ?[១៧៨] ក្នុងបរិបទកម្ពុជា ក្រោមការអនុវត្តប្រព័ន្ធច្បាប់ស៊ីវិលតាមបែបបារាំង[១៧៩] ពាក្យថា *ប្រភព* មានន័យថាជាដើមកំណើតនៃវិធានច្បាប់ និងប្រភពច្បាប់ផ្សេងៗទៀតដែលត្រូវបានទទួលស្គាល់ដោយច្បាប់ជាធរមាន និងស្ថាប័នពាក់ព័ន្ធផ្សេងៗ។[១៨០] យោងតាមមូលដ្ឋានទាំងនេះ ច្បាប់និងលិខិតបទដ្ឋានគតិយុត្តទាំងឡាយណាដែលជាលិខិតូបករណ៍គតិយុត្តដែលបានតាក់តែងឡើង(សរសេរ) និងទទួលស្គាល់(អនុម័ត)ដោយស្ថាប័នមានសមត្ថកិច្ច ត្រូវចាត់ទុកជាប្រភពដែលមានអនុភាពគតិយុត្ត រីឯប្រភពឥតសរសេរដែលពុំមានការ




[១៧៦] Ibid.

[១៧៧] See: Grant Lamond, 'Philosophy of Law: Persuasive Authority in the Law' (២០១០) ១៧ The Harvard Review of Philosophy ១៦.

[១៧៨] Giorgio Pino, '៣. Sources of Law' in John Gardner, Leslie Green and Brian Leiter (eds), *Oxford Studies in Philosophy of Law* (Oxford University Press ២០២១).

[១៧៩] Dolores A Donovan, 'Cambodia: Building a Legal System from Scratch' (១៩៩៣) ២៧ The International Lawyer ៤៤៥, ៤៤៦ <https://www.jstor.org/stable/៤០៧០៧០៦២> accessed ២៥ December ២០២៥, Jörg Menzel, 'Cambodia from Civil War to a Constitution to Constitutionalism' in Peng Hor, Phallack Kong and Jörg Menzel (eds), *Cambodian Constitutional Law* (Konrad-Adenauer-Stiftung ២០១៦) ៣១.

[១៨០] Kong (n ១) ៨.

ទទួលស្គាល់ដូចជាបវេណី លទ្ធិ និងយុត្តិសាស្ត្រជាដើម ដែលត្រូវបានចាត់ទុកថាជាប្រភពដែលមិនមានអនុភាពគតិយុត្ត។

### ១.៧.១ ប្រភពសរសេរនៃនីតិ

ប្រភពសរសេរនៃនីតិនៅព្រះរាជាណាចក្រកម្ពុជាត្រូវបានបែងចែកតាមឋានានុក្រមនៃប្រភពចម្បង និងប្រភពបន្ទាប់បន្សំដូចខាងក្រោម៖




#### ១.៧.១.១ រដ្ឋធម្មនុញ្ញ

ធម្មនុញ្ញនិយម មានដំណើរដើមទងពាក់ព័ន្ធនឹងយន្តការនៃការបង្ហាញអំពីឆន្ទៈរួមរបស់ពលរដ្ឋនៅក្នុងរដ្ឋ ឬសង្គមមួយ ដោយបានកំណត់អំពីឧត្តមគតិរបស់ពួកគេ ក្នុងការគ្រប់គ្រងប្រទេសជាតិតាមរយៈការប្រមូលផ្តុំនូវទស្សនវិជ្ជានយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌ ដើម្បីជាប្រយោជន៍ជាតិ និងពលរដ្ឋដើម្បីការពារដល់សិទ្ធិនិងសេរីភាពរបស់ប្រជាពលរដ្ឋផងដែរ។ ទ្រឹស្តីនៃធម្មនុញ្ញនិយមរួមចំណែកយ៉ាងសំខាន់ក្នុងការផ្តល់នូវគោលគំនិត និងគុណតម្លៃជាមូលដ្ឋានក្នុងការតាក់តែងរដ្ឋធម្មនុញ្ញរបស់រដ្ឋនីមួយៗ។ ជាទូទៅធម្មនុញ្ញនិយមទំនើប រមែងរាប់បញ្ចូលនូវគុណតម្លៃ ប្រជាធិបតេយ្យ សិទ្ធិជាមូលដ្ឋាន និងនីតិរដ្ឋដែលគុណតម្លៃទាំងបីនេះសុទ្ធសឹងតែជាគោលគំនិតក្នុងការតាក់តែងច្បាប់កំពូលរបស់ប្រទេសមួយឡើង។

ដោយឡែកបើក្រឡេកមកមើល រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលបានប្រកាសដាក់ឱ្យអនុវត្តកាលពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ គឺជាមូលដ្ឋានគ្រឹះយ៉ាងសំខាន់ ដោយហេតុថារដ្ឋធម្មនុញ្ញនេះគឺជារដ្ឋធម្មនុញ្ញដែលមានការវិវត្តស្របតាមស្ថានភាពបរិបទរបស់សង្គមជាក់ស្តែងដោយគិតចាប់តាំងពីពេល

អនុវត្តមករដ្ឋធម្មនុញ្ញនេះបានធ្វើវិសោធនកម្មចំនួន១១លើក ដើម្បីធ្វើយ៉ាងណាឱ្យខ្លឹមសារនៃច្បាប់កំពូលមួយនេះដើរទាន់តាមការវិវត្តិរបស់សង្គមកម្ពុជានាពេលបច្ចុប្បន្ន។ បានជារដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ចាត់ទុកជាប្រភពចម្បងមួយយ៉ាងសំខាន់នៃនីតិពីព្រោះថាច្បាប់នេះគឺជាច្បាប់កំពូល នៅពេលដែលមានការគិតគូររៀបចំធ្វើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ណាមួយនោះគឺស្ថាប័នពាក់ព័ន្ធតែងតែពិនិត្យមើលទៅលើធម្មនុញ្ញភាព មានន័យថាការរៀបចំសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ណាមួយឡើងនោះមិនប្រាសចាកទៅនឹងគោលការណ៍ដែលមានកំណត់ទុកនៅក្នុងរដ្ឋធម្មនុញ្ញដែរឬអត់ ឬអាចនិយាយបានម្យ៉ាងទៀតថាត្រូវធានាឱ្យបាននូវធម្មនុញ្ញភាពនៃច្បាប់ដែលបានប្រកាសដាក់ឱ្យអនុវត្ត។

បើនិយាយអំពីឋានានុក្រមនៃលិខិតបទដ្ឋានគតិយុត្តវិញរដ្ឋធម្មនុញ្ញគឺជាច្បាប់កំពូលដែលខ្ពស់ជាងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត។ មានន័យថារាល់ច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់នៅពេលដែលដាក់ចេញឱ្យអនុវត្តត្រូវធ្វើយ៉ាងណាឱ្យស្របទៅនឹងរដ្ឋធម្មនុញ្ញ បើមិនដូច្នេះទេច្បាប់នោះនឹងមានអធម្មនុញ្ញភាពជាក់ជាមិនខាន។ តែទោះជាយ៉ាងណាក៏ដោយក៏ច្បាប់ដែលពិនិត្យធម្មនុញ្ញភាពមុនពេលប្រកាសឱ្យអនុវត្តនោះភាគច្រើនជាច្បាប់រៀបចំអង្គការឬអាចហៅបានម្យ៉ាងទៀតថាជាច្បាប់អង្គិនចំណែកឯច្បាប់សាមញ្ញវិញគេមិនសូវឃើញមានការពិនិត្យធម្មនុញ្ញភាពមុនពេលដាក់ចេញឱ្យអនុវត្តនោះឡើយ។ ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចធានាការគោរពរដ្ឋធម្មនុញ្ញបកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ដែលរដ្ឋសភាបានអនុម័តនិងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ។[១៨១] ដែលនៅក្នុងនោះក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចត្រូវពិនិត្យជាអាទិកាល មានន័យថាជាការពិនិត្យមើលលើធម្មនុញ្ញភាពមុនពេលដែលច្បាប់ត្រូវបានប្រកាសដាក់ឱ្យអនុវត្ត ការពិនិត្យមួយប្រភេទទៀតគឺជាការពិនិត្យដែលមានលក្ខណៈបច្ឆាកាល មានន័យថាជាការត្រួតពិនិត្យមើលក្រោយពេលដែលច្បាប់ត្រូវបានប្រកាសដាក់ឱ្យអនុវត្ត។

### ១.៧.១.២ ព្រះរាជក្រម

យោងតាមសេចក្តីសម្រេចឆ្នាំ២០០៧ របស់ក្រុមប្រឹក្សាធម្មនុញ្ញ ពាក្យថា ច្បាប់ សំដៅលើ ច្បាប់ជាតិទាំងឡាយណាដែលនៅជាធរមាន និងច្បាប់អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាបានទទួលស្គាល់រួចមកហើយ។[១៨២] ជាក់ស្តែង បន្ទាប់ពីទទួលបានការអនុម័តយល់ព្រមពីរដ្ឋសភានិងព្រឹទ្ធសភា ព្រះមហាក្សត្រទ្រង់ឡាយប្រហស្តលេខាលើលិខិតតូបករណ៍អន្តរជាតិ និងប្រទានសច្ចាប័នលើលិខិតតូបករណ៍អន្តរជាតិនោះ។[១៨៣] ប៉ុន្តែក្នុងការអនុវត្ត ដើម្បីឱ្យលិខិតតូបករណ៍អន្តរជាតិណាមួយមានអនុភាពគតិយុត្តយកមកអនុវត្តបាន តម្រូវឱ្យមានការធ្វើច្បាប់ស្តីពីការអនុវត្តលិខិតតូបករណ៍អន្តរជាតិទាំងនោះ រួចទទួលការឡាយប្រហ

[១៨១] មាត្រា១៣៦-ថ្មី នៃរដ្ឋធម្មនុញ្ញ១៩៩៣

[១៨២] Kong (n ១) ៨, See: សេចក្តីសម្រេចក្រុមប្រឹក្សាធម្មនុញ្ញ សំណុំរឿងលេខ ១៣១/០០៣/២០០៧ ចុះថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ២០០៧ សេចក្តីសម្រេច លេខ ០៩២/០០៣/២០០៧ ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០០៧។

[១៨៣] មាត្រា ២៦(ថ្មី) នៃរដ្ឋធម្មនុញ្ញ ១៩៩៣។

ស្តលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើច្បាប់នោះ។[១៨៤] ជារួមលិខិតតូបករណ៍អន្តរជាតិដែលត្រូវបានទទួលស្គាល់មានឋានានុក្រមស្មើនឹងច្បាប់ផ្ទៃក្នុងរបស់ប្រទេសដែរ។

## ក. ច្បាប់ជាតិ

ទោះជាយ៉ាងណាក៏ដោយ ច្បាប់ជាតិនៅតែជាប្រភពចម្បងមួយយ៉ាងសំខាន់នៃនីតិដោយសារតែច្បាប់ទាំងអស់នេះត្រូវបានរៀបចំឡើងដោយមានបែបបទនីតិវិធីច្បាស់លាស់ មានការដាក់ឆ្លងតាមនីតិវិធីអនុម័តដោយរដ្ឋសភា ត្រួតពិនិត្យដោយព្រឹទ្ធសភា និងត្រូវមានការពិនិត្យលើធម្មនុញ្ញភាពដោយក្រុមប្រឹក្សាធម្មនុញ្ញដើម្បីធ្វើយ៉ាងណាឱ្យច្បាប់ដែលបានដាក់ចេញនោះស្របទៅនឹងរដ្ឋធម្មនុញ្ញ។ ដោយឡែកនៅក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បានចែងថា រដ្ឋធម្មនុញ្ញជាច្បាប់កំពូល នៃព្រះរាជាណាចក្រកម្ពុជា ច្បាប់និងលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ផ្សេងៗទៀតនៃស្ថាប័ននានារបស់រដ្ឋ ត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត។[១៨៥] ច្បាប់គឺជាលិខិតបទដ្ឋានគតិយុត្តមួយប្រភេទដែលមានឋានានុក្រមបន្ទាប់ពីរដ្ឋធម្មនុញ្ញដោយហេតុថាច្បាប់មុនពេល និងក្រោយពេលដាក់ចេញឱ្យអនុវត្តធ្វើយ៉ាងណាត្រូវតែស្របទៅនឹងរដ្ឋធម្មនុញ្ញ។

## ខ. លិខិតតូបករណ៍អន្តរជាតិ

លិខិតតូបករណ៍អន្តរជាតិ គឺជាសំណុំនៃវិធានឬជាឯកសារដែលមានលក្ខណៈជាលាយលក្ខណ៍អក្សរដើម្បីធ្វើជាមូលដ្ឋានច្បាប់អនុវត្តទៅលើកិច្ចការអ្វីមួយ ទាំងកិច្ចការជាតិ និងកិច្ចការដែលមានលក្ខណៈជាអន្តរជាតិ។ ដែលក្នុងនោះលិខិតតូបករណ៍អន្តរជាតិរួមមាន សន្ធិសញ្ញា កិច្ចព្រមព្រៀង អនុសញ្ញា ធម្មនុញ្ញ ពិធីសារ សេចក្តីប្រកាស អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រាងបណ្តោះអាសន្ន និងលិខិតប្តូរសារនិងកំណត់ហេតុ ដែលនេះសុទ្ធសឹងតែលិខិតតូបករណ៍អន្តរជាតិយ៉ាងសំខាន់សម្រាប់ធ្វើជាមូលដ្ឋានប្រភពនៃនីតិដែលមានលក្ខណៈចម្បង។

- សន្ធិសញ្ញា (Treaty) ជាយន្តការដ៏សំខាន់សម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិនៅក្នុងទំនាក់ទំនងអន្តរជាតិ ហើយវាក៏ជាប្រភពដ៏សំខាន់មួយនៃច្បាប់អន្តរជាតិនាពេលបច្ចុប្បន្ននេះផងដែរ។ បើយោងទៅតាម អនុសញ្ញាទីក្រុងវីយែនឆ្នាំ១៩៦៩ សន្ធិសញ្ញាជាកិច្ចព្រមព្រៀងអន្តរជាតិរវាងរដ្ឋក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ និងគ្រប់គ្រងដោយច្បាប់អន្តរជាតិមិនថាបញ្ចូលលិខិតូបករណ៍អន្តរជាតិមួយឬច្រើន។ វាក៏ត្រូវបានប្រើប្រាស់សម្រាប់ពិពណ៌នាអំពីលិខិតូបករណ៍អន្តរជាតិជាច្រើនរួមទាំង អនុសញ្ញា កិច្ចព្រមព្រៀង ពិធីសារ ធម្មនុញ្ញ និងផ្សេងៗទៀត។
- កិច្ចព្រមព្រៀង (Agreement) សំដៅទៅលើលិខិតូបករណ៍អន្តរជាតិមួយដែលរដ្ឋរួមជាមួយនឹងអង្គការអន្តរជាតិប្រើដើម្បីគ្រប់គ្រងបញ្ហាដែលមានការពាក់ព័ន្ធណាមួយ។ កិច្ចព្រមព្រៀងអាចមានទម្រង់

---

[១៨៤] មាត្រា ២៨(ថ្មី) នៃរដ្ឋធម្មនុញ្ញ ១៩៩៣។

[១៨៥] មាត្រា១៥២(ថ្មី) (ពីរ មាត្រា១៥០ថ្មី) រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣។

និងរចនាបទខុសៗគ្នា ប៉ុន្តែវាទាំងអស់គឺស្ថិតនៅក្រោមការគ្រប់គ្រងដោយច្បាប់នៃសន្ធិសញ្ញា (Law of Treaties) ដែលជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ (Customary International Law)។

- អនុសញ្ញា (Convention) សំដៅទៅលើសន្ធិសញ្ញាឬកិច្ចព្រមព្រៀងប្រភេទជាក់លាក់មួយរវាងប្រទេសជាច្រើនដែលមានគោលបំណងដោះស្រាយបញ្ហាសាកលជារួមមិនមែនបញ្ហារវាងភាគីនោះឡើយ។ ជាក់ស្តែងគឺអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ (United Nations Conventions on the Law of the Sea - UNCLOS)។
- ធម្មនុញ្ញ (Charter) គឺសំដៅទៅលើឯកសារដែលផ្តល់សិទ្ធិ អំណាច ឯកសិទ្ធិ ឬមុខងារជាក់លាក់ពីអំណាចអធិបតេយ្យភាពរបស់រដ្ឋដល់បុគ្គល សាជីវកម្ម ទីក្រុង ឬអង្គភាពផ្សេងទៀតនៃអង្គការក្នុងស្រុក។ ជាក់ស្តែងដូចជា ធម្មនុញ្ញអង្គការសហប្រជាជាតិឆ្នាំ១៩៤៥។
- ពិធីសារ (Protocol) គឺប្រើប្រាស់សម្រាប់កិច្ចព្រមព្រៀងដែលមានលក្ខណៈផ្លូវការតិចជាងសន្ធិសញ្ញា ឬអនុសញ្ញា ដោយសារតែវាតំណាងឱ្យលិខិតូបករណ៍ដែលបង្កើតការប្រតិបត្តិទៅតាមច្បាប់អន្តរជាតិ។ ក្នុងករណីភាគច្រើន ពាក្យនេះរួមបញ្ចូលលិខិតូបករណ៍ដែលជាសាខានៃសន្ធិសញ្ញា។
- សេចក្តីប្រកាស (Declaration) ជាលិខិតូបករណ៍បែបសរសេរដែលមិនមានកាតព្វកិច្ចកំណត់គោលការណ៍អន្តរជាតិ ហើយវាអាចកម្លាំងរុញនយោបាយ ឬសីលធម៌។ ជាទូទៅវាត្រូវបានព្រាង និងអនុម័តដោយអង្គការអន្តរជាតិ ឬសន្និសីទ ប៉ុន្តែមិនត្រូវបានចុះហត្ថលេខា និងផ្តល់សច្ចាប័នដោយរដ្ឋនោះទេ។ ឧទាហរណ៍ដូចជា សេចក្តីប្រកាសទីក្រុងរីយ៉ូឆ្នាំ១៩៩២ (The 1992 Rio Declaration) ជាដើម។
- អនុស្សរណៈនៃការយោគយល់គ្នា (Memorandum of Understanding) ជាកិច្ចព្រមព្រៀងរវាងភាគីពីរ ឬច្រើនដែលមានការចែងនៅក្នុងឯកសារផ្លូវការមួយ ហើយការចែងនោះអាស្រ័យលើចេតនារបស់រដ្ឋហត្ថលេខី និងភាសានៅក្នុងកិច្ចព្រមព្រៀងមួយនោះ ប៉ុន្តែការចែងនោះត្រូវតែបង្ហាញពីឆន្ទៈរបស់ភាគីក្នុងការឆ្ពោះទៅមុខជាមួយនឹងកិច្ចសន្យា។
- កិច្ចព្រមព្រៀងបណ្តោះអាសន្ន (Modus Vivendi) ជាកិច្ចព្រមព្រៀងអន្តរជាតិដែលមានលក្ខណៈបណ្តោះអាសន្នដែលគេប្រើដើម្បីជំនួសដោយការរៀបចំតួអក្សរអចិន្ត្រៃយ៍ ឬលម្អិតជាងនេះ។ ជាធម្មតាវាត្រូវបានធ្វើឡើងតាមរបៀបក្រៅផ្លូវការ ហើយមិនតម្រូវឱ្យមានការផ្តល់សច្ចាប័នឡើយ។

លិខិតតូបករណ៍អន្តរជាតិខាងលើទាំងអស់នេះដើរតួជាមូលដ្ឋានគ្រឹះដ៏សំខាន់មួយសម្រាប់សង្គមជាតិក្នុងការរៀបចំតាក់តែងច្បាប់។ ការតាក់តែងច្បាប់តម្រូវឱ្យមានការពិនិត្យទាំងទៅលើបរិបទផ្ទៃក្នុង និងការវិវត្តនៃឧត្តមានុវត្តន៍ជាអន្តរជាតិ ធ្វើយ៉ាងណាឱ្យសមស្របទៅនឹងទំនោររបស់សហគមអន្តរជាតិ។ តែទោះជាយ៉ាងណាក៏ដោយ លិខិតតូបករណ៍អន្តរជាតិទាំងអស់នេះអាចយកមកអនុវត្តបានលុះត្រាតែមានការផ្តល់សច្ចាប័នទទួលស្គាល់យ៉ាងត្រឹមពីព្រះប្រមុខរដ្ឋដែលជាព្រះមហាក្សត្រ។ លិខិតតូបករណ៍អន្តរជាតិនេះបើនិយាយឱ្យងាយយល់ក៏មានឋានានុក្រមប្រហាក់ប្រហែលនឹងច្បាប់ជាតិដែរដោយហេតុថារាល់លិខិតតូបករណ៍អន្តរជាតិទាំងអស់ដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ត្រូវមានការផ្តល់សច្ចាប័នដោយព្រះមហាក្សត្រលើសពីនេះទៅទៀតនោះត្រូវមានច្បាប់អនុវត្តទៅលើលិខិតតូបករណ៍អន្តរជាតិទាំង

នោះទៀតដែលត្រូវអនុម័តដោយសភា និងឡាយព្រះហស្តលេខាប្រកាសឱ្យប្រើដោយព្រះមហាក្សត្រតាមរយៈព្រះរាជក្រម។ ដែលនេះអាចសបញ្ជាក់ឱ្យឃើញថាការការប្រកាសឱ្យច្បាប់អនុវត្តលើលិខិតតូបករណ៍អន្តរជាតិក៏ប្រកាសឱ្យប្រើដោយព្រះរាជក្រម ចំណែកឯច្បាប់ជាតិវិញក៏ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមដែលនេះបានបញ្ជាក់យ៉ាងច្បាស់ថាលិខិតតូបករណ៍អន្តរជាតិដែលកម្ពុជាទទួលស្គាល់គឺមានឋានានុក្រមស្មើគ្នាទៅនឹងច្បាប់ផ្ទៃក្នុងរបស់ប្រទេសដែរ។

### ១.៧.១.៣ ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យ គឺជាសេចក្តីសម្រេចរបស់ប្រមុខរដ្ឋដែលជាព្រះមហាក្សត្រតាមការស្នើសុំពីគណៈរដ្ឋមន្ត្រី។ ដោយផ្អែកលើរដ្ឋធម្មនុញ្ញបានបញ្ញត្តិថា ព្រះមហាក្សត្រទ្រង់ជាព្រះប្រមុខរដ្ឋអស់មួយជីវិត។[១៨៦] ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យតាមសេចក្តីស្នើសុំពីគណៈរដ្ឋមន្ត្រី។[១៨៧] ព្រះរាជក្រឹត្យដែលចេញដោយព្រះមហាក្សត្រត្រូវបានបែងចែកជាពីរប្រភេទដោយក្នុងនោះរួមមាន ព្រះរាជក្រឹត្យដែលមានលក្ខណៈជាបទបញ្ញាទូទៅ និងព្រះរាជក្រឹត្យដែលមានលក្ខណៈឯកត្តបុគ្គល។

- ព្រះរាជក្រឹត្យដែលមានលក្ខណៈបទបញ្ញាទូទៅ គឺព្រះរាជក្រឹត្យដែលបានដាក់បញ្ញត្តិទូទៅពោលគឺមិនសំដៅលើបុគ្គលណាមួយជាក់លាក់។ ឧទាហរណ៍ ព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ ព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិបេតិកភណ្ឌពិភពលោក និងព្រះរាជក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យ កសិកម្មជនបទ។ល។
- ព្រះរាជក្រឹត្យដែលមានលក្ខណៈឯកត្តបុគ្គល គឺជាព្រះរាជក្រឹត្យដែលបានដាក់បញ្ញត្តិជាក់លាក់ទៅលើបុគ្គលណាមួយ ព្រះរាជក្រឹត្យស្តីពីការតែងតាំង ឬតម្លើងឋាន្តរស័ក្តិ ឬបញ្ចប់តំណែង។ល។ ព្រះរាជក្រឹត្យមានលក្ខណៈឯកត្តបុគ្គលនេះ ក្នុងករណីបានធ្វើឱ្យប៉ះពាល់ដល់ប្រយោជន៍បុគ្គលណាមួយដោយគ្មានមូលហេតុច្បាស់លាស់ទេបុគ្គលនោះមានសិទ្ធិស្របច្បាប់ក្នុងការប្តឹងជំទាស់ទៅនឹងព្រះរាជក្រឹត្យនោះវិញបានដើម្បីការពារផលប្រយោជន៍ខ្លួន។ ប្រជាពលរដ្ឋខ្មែរមានសិទ្ធិប្តឹងបរិហារប្តឹងតវ៉ា ឬប្តឹងទារសំណងជួសជុលការខូចខាតដែលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋ របស់អង្គការ សង្គម និងរបស់បុគ្គលិកនៃអង្គការទាំងនោះ។ ការដោះស្រាយបណ្តឹងតវ៉ា និងសំណងជួសជុលការខូចខាតជាសមត្ថកិច្ចរបស់តុលាការ។[១៨៨]

ព្រះរាជក្រឹត្យអាចត្រូវបានបង្កើតតាមការចង្អុលរបស់ច្បាប់។ ក្នុងករណីនេះព្រះរាជក្រឹត្យនោះគឺមានតម្លៃស្មើច្បាប់ពីព្រោះអង្គនីតិបញ្ញត្តិបានអនុញ្ញាតឱ្យអង្គការនីតិប្រតិបត្តិបង្កើត។ ដាក់ស្តែងមាត្រា៨

---

[១៨៦] មាត្រា៧ នៃរដ្ឋធម្មនុញ្ញ១៩៩៣

[១៨៧] មាត្រា២៨ នៃរដ្ឋធម្មនុញ្ញ១៩៩៣

[១៨៨] មាត្រា៣៩ នៃរដ្ឋធម្មនុញ្ញ១៩៩៣

នៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិបានបញ្ញត្តិថា តំបន់ការពារធនធានធម្មជាតិ.....ត្រូវការពារដោយព្រះរាជក្រឹត្យ។ ប៉ុន្តែមានព្រះរាជក្រឹត្យមួយចំនួនទៀតត្រូវបានបង្កើតឡើងតាមការចាំបាច់របស់អង្គនីតិប្រតិបត្តិ ហើយពុំមានច្បាប់គ្រប់គ្រងនោះឡើយ។ ឧទាហរណ៍ ព្រះរាជក្រឹត្យស្តីពីការបង្កើតសហគមន៍នេសាទ ព្រះរាជក្រឹត្យស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ។ល។

### ១.៧.១.៤ អនុក្រឹត្យ

អនុក្រឹត្យ គឺជាលិខិតបទដ្ឋានក្រោមច្បាប់នឹងមានអនុភាពគតិយុត្តក្នុងការអនុវត្ត អនុក្រឹត្យគឺចេញដោយប្រមុខរាជរដ្ឋាភិបាលជានាយករដ្ឋមន្ត្រីដែលមានលក្ខណៈជាបទបញ្ញាទូទៅ និងមានគោលបំណងក្នុងការបង្កើត ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង/ស្ថាប័ន និងមានលក្ខណៈជាឯកត្តបុគ្គលដែលសំដៅលើការតែងតាំង ឬដកហូតឬដំឡើងឋានន្តរស័ក្តិ។ ជារួមអនុក្រឹត្យគឺមានពីរប្រភេទ៖ អនុក្រឹត្យមានលក្ខណៈជាបទបញ្ញាទូទៅ និងអនុក្រឹត្យមានលក្ខណៈឯកត្តបុគ្គល។ អនុក្រឹត្យជាលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់មួយប្រភេទដែលមានគោលបំណងចង្អុលបង្ហាញទៅលើបែបបទ និងនីតិវិធីបន្ថែមដែលច្បាប់ ឬព្រះរាជក្រឹត្យមិនបានចែងលម្អិត។

- អនុក្រឹត្យមានលក្ខណៈជាបទបញ្ញាទូទៅ គឺជាលិខិតបទដ្ឋានដែលបង្កើតស្ថាប័នណាមួយ ហើយបង្ហាញអំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ស្ថាប័ននោះ។ ឧទាហរណ៍ អនុក្រឹត្យលេខ៧៧ អន.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងអនុក្រឹត្តលេខ៤៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី។
- អនុក្រឹត្យមានលក្ខណៈឯកត្តបុគ្គល យោងលើ មាត្រា ១៥ នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី បានចែងថា នាយករដ្ឋមន្ត្រីតែងតាំង ផ្លាស់ប្តូរ បញ្ចប់ភារកិច្ចដោយអនុក្រឹត្យ នូវមន្ត្រីជាន់ខ្ពស់ស៊ីវិល យោធា មន្ត្រីការទូត និងអភិបាលរងខេត្ត ក្រុង អភិបាលស្រុក ខណ្ឌ ។ បុគ្គលដែលត្រូវតែតាំងដោយអនុក្រឹត្យ មានដូចជា៖ អភិបាលរងរាជធានី ខេត្ត និង អភិបាលក្រុង ស្រុក ខណ្ឌ អគ្គលេខាធិការរង អគ្គនាយករង ប្រធាននាយកដ្ឋាន និងមន្ត្រីនគរបាល យោធា ដែលមានឋានន្តរសក្តិចាប់ពីថ្នាក់វរសេនីយ៍ឯក ។

### ១.៧.១.៥ ប្រកាស

ប្រកាស គឺជាសេចក្តីសម្រេចដែលមានលក្ខណៈជាបទបញ្ញាទូទៅ និងមានជាលក្ខណៈឯកត្តបុគ្គលចេញដោយក្រសួងមួយ ឬក្រសួងច្រើនរួមគ្នា ដែលប្រកាសបែបនេះជាទូទៅហៅថាប្រកាសអន្តរក្រសួងដែលមានប្រធានក្រសួងស្ថាប័នចុះហត្ថលេខារួមគ្នាដើម្បីអនុវត្តទៅលើកិច្ចការអ្វីមួយដែលមានចែងនៅក្នុងប្រកាសនោះ។ រដ្ឋមន្ត្រីមានសិទ្ធិចេញប្រកាសនៅក្នុងក្របខ័ណ្ឌនៃសមត្ថកិច្ចរបស់ខ្លួន ដែលមានចែងនៅក្នុងច្បាប់ ព្រះរាជក្រឹត្យ និងអនុក្រឹត្យ។ រដ្ឋមន្ត្រីចេញប្រកាសដើម្បីណែនាំ អនុវត្តអនុក្រឹត្យ ដើម្បីបញ្ចូល

ក្របខណ្ឌតែងតាំង ដាក់ឱ្យចូលនិវត្តន៍ បង្កើតគ្រឹះស្ថានសិក្សា។ ឧទាហរណ៍៖ ប្រកាសអន្តរក្រសួងលេខ ១៤៤១៤ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវារដ្ឋបាល របស់ក្រសួងមហាផ្ទៃ ប្រកាសប្រភេទនេះជាប្រកាសអន្តរក្រសួងដោយសារតែមានប្រធានក្រសួងស្ថាប័នចំនួនពីរចុះហត្ថលេខារួមគ្នានៅលើប្រកាសនេះ ដែលនេះបង្ហាញឱ្យឃើញថាក្រសួងចំនួនពីរត្រូវតែមានកាតព្វកិច្ចអនុវត្តទៅតាមខ្លឹមសារដែលមានចែងនៅក្នុងប្រកាសនេះ។ ប្រកាស ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃការិយាល័យចំណុះនាយកដ្ឋានរបស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ប្រកាសប្រភេទនេះគឺចេញដោយរដ្ឋមន្ត្រីរបស់ក្រសួងនេះដែលអនុវត្តពាក់ព័ន្ធតែទៅនឹងវិស័យរបស់ខ្លួនតែប៉ុណ្ណោះដោយមិនមានវិសាលភាពទៅលើវិស័យផ្សេងទៀតឡើយ។

ប្រកាសចេញដោយនាយករដ្ឋមន្ត្រីជាប្រកាសដែលបង្គាប់បញ្ជាឱ្យក្រសួងស្ថាប័នអនុវត្តតាម។ ប៉ុន្តែក៏មានប្រកាសមួយចំនួនទៀតមានប្រភពចេញពីសមាជិករាជរដ្ឋាភិបាលដែលដឹកនាំក្រសួង ឬរដ្ឋលេខាធិការដ្ឋាន។ ប្រកាសមានប្រកាសរួម ឬប្រកាសអន្តរក្រសួងករណីមានការទាក់ទងក្រសួងច្រើន។ ប្រធានស្ថាប័ន ឬរដ្ឋមន្ត្រីមានសិទ្ធិចេញប្រកាសដែលទាក់ទងទៅនឹងកិច្ចការក្នុងរង្វង់ក្របខ័ណ្ឌសមត្ថកិច្ចរបស់ខ្លួន ប៉ុន្តែដាច់ខាតត្រូវស្របតាមអនុក្រឹត្យ ឬសារាចររបស់រាជរដ្ឋាភិបាល។[១៩៩] ប្រកាសត្រូវបង្កើតឡើងតាមការចាំបាច់ ឬតាមការចង្អុលរបស់លិខិតបទដ្ឋានគតិយុត្តដែលមានឋានានុក្រមខ្ពស់ជាងក៏មានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងអនុក្រឹត្យដែរ។

### ១.៧.១.៦ សារាចរ

សារាចរ គឺជាបទបញ្ជាមួយដែលអង្គភាពថ្នាក់លើបានលើកគោលការណ៍ ឬវិធានការ ឬបកស្រាយច្បាប់ ឬវិធានណាមួយ ដើម្បីជាប្រយោជន៍ឱ្យអង្គភាពថ្នាក់ក្រោមអនុវត្ត។

សារាចរណែនាំ គឺជាអត្ថបទមួយប្រភេទដែលចេញដោយអង្គភាពថ្នាក់លើ ដើម្បីឱ្យអង្គភាពថ្នាក់ក្រោមអនុវត្តបានត្រឹមត្រូវតាមច្បាប់ ឬវិធានណាមួយ ឬតាមគោលនយោបាយរបស់ខ្លួនដែលបានដាក់ចេញកន្លងមកឱ្យអនុវត្តតាម ប៉ុន្តែការអនុវត្តនៅពុំទាន់បានត្រឹមត្រូវ និងគ្រប់ជ្រុងជ្រោយ ឬអនុវត្តមិនចំទិសដៅ និងខ្លឹមសារពិតប្រាកដ។

ជារួមសារាចរ ឬសារាចរណែនាំ គេជាអត្ថបទបទបញ្ជា និងគោលការណ៍ ឬជាវិធានរបស់ថ្នាក់លើផ្តល់មកថ្នាក់ក្រោម ដើម្បីអនុវត្តឱ្យចំទិសដៅ ឬខ្លឹមសារគោលការណ៍ ឬវិធាន។ សារាចរ មានគោលបំណងគឺដើម្បីធ្វើការបកស្រាយបំភ្លឺអត្ថបទច្បាប់ណាមួយដើម្បីអនុវត្តឱ្យបានត្រឹមត្រូវច្បាស់លាស់ និងឯកភាពគ្នា។ ប៉ុន្តែសារាចរមានអានុភាពអនុវត្តបានតែចំពោះភ្នាក់ងារសាធារណៈ ដែលស្ថិតនៅក្រោមបង្គាប់របស់ខ្លួន។ ផ្ទុយទៅវិញសារាចរមិនអាចបង្កើតឡើងសម្រាប់បង្គាប់ប្រជាពលរដ្ឋឱ្យអនុវត្តតាមខ្លួនឡើយ។ ចំណែកអាជ្ញា

[១៩៩] មាត្រា២៩ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ឆ្នាំ១៩៩៤

ធរមានសមត្ថកិច្ចចេញសារាចរមានជាអាទិ៍ នាយករដ្ឋមន្ត្រី សមាជិករាជរដ្ឋាភិបាល ឬប្រធានស្ថាប័ន។ ឧទាហរណ៍៖ សារាចរលេខ០៥សរ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការប្រើកាលបរិច្ឆេទទាំងចន្ទគតិ ទាំងសុរិយគតិ ក្នុងលិខិតបទដ្ឋានគតិយុត្ត និងលិខិតរដ្ឋបាល សារាចរស្តីពីការកំណត់ និងការអនុវត្តមុខងារនៅតាមក្រសួងស្ថាប័ន ចំណុះអង្គនីតិប្រតិបត្តិ និងសារាចរស្តីពីការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥ ជាដើម។

#### ១.៧.១.៧ ដីកា (រដ្ឋបាលថ្នាក់ក្រោមជាតិ)

ដីកា ជាលិខិតចែងពីបទប្បញ្ញត្តិ ឬជាលិខិតឯកត្តកូត ចេញដោយអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។ អភិបាលរាជធានី ខេត្ត អាចចេញដីកាក្នុងបញ្ហាអ្វីមួយលុះត្រាតែមានសមត្ថកិច្ចពាក់ព័ន្ធក្នុងបញ្ហានោះ ដែលចែងដោយ ព្រះរាជក្រឹត្យ ប្រកាស។ ប៉ុន្តែបើពុំមានលិខិតបទដ្ឋានណាមួយជាមូលដ្ឋានក្នុងការចង្អុលបង្ហាញទេនោះ អភិបាលរាជធានី ខេត្ត អាចចេញដីកាសម្រេចលើកិច្ចការអ្វីមួយ ដែលស្ថិតក្នុងមុខការជាធម្មតារបស់ខ្លួន។ ដីកា ជាច្បាប់នៅមូលដ្ឋានដែលដាក់ចេញដោយក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ហេតុនេះដីកាជាឧបករណ៍ចាំបាច់ ក្នុងការធានាឱ្យការគ្រប់គ្រង ចាត់ចែងកិច្ចការនានានៅមូលដ្ឋានដោយរដ្ឋបាលថ្នាក់ក្រោមជាតិមានលក្ខណៈឆ្លើយតប ប្រសិទ្ធភាព តម្លាភាព សមធម៌ និងបរិយាបន្ន។ ដោយផ្អែកលើខ្លឹមសារនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានចែងថា ក្រុមប្រឹក្សាប្រើសិទ្ធិអំណាចបញ្ញត្តិរបស់ខ្លួនដោយការធ្វើដីកា។[១៩០] អំណាចបញ្ញត្តិរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់ ត្រូវធ្វើឡើងតាមរយៈដីកាឃុំ/សង្កាត់សម្រាប់គ្រប់គ្រងកិច្ចការនានាក្នុងក្របខ័ណ្ឌ តួនាទី មុខងារនិងអំណាចរបស់ខ្លួន។[១៩១]

### ១.៧.២ ប្រភពឥតសរសេរនៃនីតិ

#### ១.៧.២.១ បវេណី

បវេណី អាចមានន័យច្រើន ប៉ុន្តែជារួមគឺបវេណីជាវិធានដែលមានទម្លាប់ចេញពីការអនុវត្តទូទៅជាយូរអង្វែង។[១៩២] នៅក្នុងប្រពៃណីប្រព័ន្ធច្បាប់ស៊ីវិល បវេណីមានឋានានុក្រមខុសៗគ្នាដូចជា៖[១៩៣]

---

[១៩០] មាត្រា៣២ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

[១៩១] មាត្រា៤៨ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

[១៩២] Beatrice Balivet and Sinath Chaing, 'Heirarchy of Laws', *Introduction to Cambodian Law* (Royal University of Law & Economics ២០០៥) ៨៣.

[១៩៣] Mary Ann Glendon, Paolo G Carozza and Colin Picker, *Comparative Legal Traditions in a Nutshell* (West Academic Publishing ២០១៦) ១៥១-១៥២.

- អេស្ប៉ាញ៖ ក្រមរដ្ឋប្បវេណីមិនមានអានុភាពលើសំណុំរឿងដែលប្រើប្រាស់ច្បាប់ប្រពៃណីនោះទេ ( *fueros*)
- អាល្លឺម៉ង់៖ មានករណីមួយចំនួនបវេណីមានឋានានុក្រមលើច្បាប់សរសេរ
- បារាំង៖ បវេណីមានតួនាទីបំពេញឱ្យចន្លោះច្បាប់ ប៉ុន្តែមិនមានអនុភាពនិរាករណ៍ច្បាប់នោះទេ។

នៅព្រះរាជាណាចក្រកម្ពុជា ទំនៀមទម្លាប់ ឬបវេណីមានឋានានុក្រមស្រដៀងនឹងប្រទេសទាំង៣ខាងលើតែម្តង។ ឧទាហរណ៍លម្អិតមានដូចខាងក្រោម៖

- នៅក្នុងករណីទាក់ទងនឹងសិទ្ធិប្រត្យក្ស ក្រមរដ្ឋប្បវេណីបានចែងថាសិទ្ធិប្រត្យក្សដែលបង្កើតដោយ «**វិធានទំនៀមទម្លាប់**» ត្រូវបានទទួលស្គាល់ឱ្យមានអានុភាពក្នុងក្រមនេះ លុះត្រាតែផ្ទុយនឹងក្រមនេះ ឬច្បាប់ពិសេស។[១៩៤] ដូចនេះ បវេណីនៅករណីនេះមានតួនាទីបំពេញចំណុចដែលច្បាប់ពុំបានចែង ដូចនឹងប្រទេសបារាំង។[១៩៥]
- សម្រាប់កម្មសិទ្ធិ និងសិទ្ធិប្រត្យក្សរបស់រដ្ឋ វត្តអារាម សហគមន៍ជនជាតិដើមភាគតិចនិងសហគមន៍ផ្សេងទៀត ក្រមរដ្ឋប្បវេណីបានចែងថាបញ្ញត្តិនៃក្រមនេះនឹងត្រូវយកមកអនុវត្តចំពោះកម្មសិទ្ធិ និងសិទ្ធិប្រត្យក្សផ្សេងៗនៃកម្មវត្ថុខាងលើ «**លើកលែងតែមានបញ្ញត្តិផ្សេងនៅក្នុងច្បាប់ពិសេស ឬទំនៀមទម្លាប់**»។ ដូចនេះ ករណីដែលមានទំនៀមទម្លាប់នៅក្នុងដែលគ្រប់គ្រងលើកម្មវត្ថុទាំងនេះ ក្រមរដ្ឋប្បវេណីពុំអាចយកមកអនុវត្តបានទេ ពោលគឺក្រមរដ្ឋប្បវេណីមិនមានអានុភាពលើសំណុំរឿងដែលប្រើប្រាស់ច្បាប់ប្រពៃណីនោះទេ ដូចនឹងប្រទេសអេស្ប៉ាញ។

### ១.៧.២.២ លទ្ធិ

និយមន័យ តាមបែបប្រពៃណី ទ្រឹស្តីលទ្ធិ សំដៅលើមតិទាំងឡាយដែលត្រូវបានបញ្ចេញអំពីច្បាប់ ដោយបុគ្គលដែលមានមុខងារសិក្សាស្រាវជ្រាវអំពីច្បាប់ (ដូចជា សាស្ត្រាចារ្យ ចៅក្រម មេធាវី...)។ សទ្ទានុក្រមគតិយុត្តរបស់សមាគម Henri Capitant ដែលរៀបចំឡើងក្រោមការដឹកនាំរបស់ព្រឹទ្ធបុរស Cornu បានផ្តល់និយមន័យដែលមានលក្ខណៈច្បាស់លាស់ថា៖ "មតិដែលត្រូវបានប្រកាន់យកជាទូទៅដោយអ្នកបង្រៀនច្បាប់ (communis opinio doctorum) ឬសូម្បីតែអ្នកដែលសរសេរអំពីច្បាប់ ទោះបីជាមិនបានបង្រៀនក៏ដោយ"។ ក្នុងន័យនេះ "លទ្ធិ" គឺផ្ទុយនឹង "បទដ្ឋានច្បាប់ ឬសេចក្តីសម្រេចរបស់តុលាការ" (Jurisprudence) ។ ទោះជាយ៉ាងណាក៏ដោយ ពាក្យថាលទ្ធិក៏អាចប្រើដើម្បីសម្គាល់មតិដែលបានបញ្ចេញលើបញ្ហាជាក់លាក់ណាមួយផងដែរ ។ ឧទាហរណ៍ក្នុងច្បាប់អន្តរជាតិសាធារណៈ គេតែងលើកឡើងអំពី "ទ្រឹស្តីម៉ុនរ៉ូ" (Doctrine de Monroë) ។ បច្ចុប្បន្ន និយមន័យនៃលទ្ធិបង្កឱ្យមានភាពស្រពេចស្រពិលជាងមុន ជាពិសេសទាក់ទងនឹងការកំណត់បុគ្គលដែលមានមុខងារសិក្សាផ្នែកច្បាប់។ ក្នុងន័យនេះ ការរីកចម្រើននៃសហជីពនិយមបានជំរុញឱ្យមានការលេចឡើងនូវទ្រឹស្តីបែបសហជីព អមជាមួយទ្រឹស្តីបែបសាកល កត្តាទាំងនេះត្រូវបានគេសង្កេត

[១៩៤] ក្រមរដ្ឋប្បវេណី មាត្រា ១៣១។

[១៩៥] ករណីផ្សេងទៀតរួមមាន៖ មូលដ្ឋានសម្រាប់តុលាការក្នុងការបែងចែកមត៌កដោយការប្រើប្រាស់បទបញ្ញត្តិរបស់ក្រមរដ្ឋប្បវេណី និងទំនៀមទម្លាប់ក្នុងតំបន់ (មាត្រា១២៧០(២) នៃក្រមរដ្ឋប្បវេណី)។

ឃើញនៅក្នុងច្បាប់សង្គម។ សរុបមកដើម្បីក្លាយជាសមាជិកនៃក្រុមអ្នកបង្កើលទ្ធិ វាមិនចាំបាច់ទាល់តែមានសញ្ញាបត្របណ្ឌិតច្បាប់នោះទេ។ លទ្ធិបង្ហាញរូបរាងតាមរយៈវិធីជាច្រើនដូចជាៈ សន្ធិសញ្ញា (Traités), សៀវភៅសិក្សា (Manuels), សៀវភៅសង្ខេប (Précis), អត្ថបទរិភាគ (Chroniques), និងអត្ថាធិប្បាយលើសេចក្ដីសម្រេចរបស់តុលាការ។ អត្ថបទទាំងនេះអនុញ្ញាតឱ្យអ្នកនិពន្ធបង្ហាញនូវប្រព័ន្ធ ទ្រឹស្ដី ការយល់ស្រប ការរិះគន់ សំណើ និងមតិរបស់ពួកគេ ។

លទ្ធិតាមបែបបុរាណ (Doctrine classique) រួមមានស្នាដៃដែលបានបោះពុម្ពផ្សាយរហូតដល់ចុងសតវត្សទី១៩ ដោយពួកគេដើរតាមនិន្នាការសេរីនិយម និងបុគ្គលនិយមនៅឆ្នាំ១៨០៤។ វិធីសាស្ត្ររបស់ពួកគេគឺការបកស្រាយអត្ថបទច្បាប់ (Exégèse) តាមបែបតក្កវិជ្ជា ដើម្បីទាញយកគោលការណ៍ទូទៅ។ ពួកគេកម្រនឹងរិះគន់ក្រមរដ្ឋប្បវេណីណាស់ ។

លទ្ធិតាមបែបសម័យទំនើប (Doctrine moderne) ស្នាដៃដែលបោះពុម្ពក្នុងសតវត្សទី២០ មិនសូវមានការគោរពយ៉ាងតឹងរ៉ឹងចំពោះមាត្រាច្បាប់ដូចមុនទៀតទេ។ ពួកគេយកចិត្តទុកដាក់លើភាពជាក់ស្ដែង តម្រូវការនៃការអនុវត្ត និងការរិះគន់ស្ថាប័នច្បាប់ដោយផ្អែកលើប្រវត្តិសាស្ត្រ សង្គមវិទ្យា សេដ្ឋកិច្ច និងច្បាប់តាមរយៈការប្រៀបធៀប។ អ្វីដែលសំខាន់បំផុតនោះ គឺពួកគេមិនត្រឹមតែសិក្សាលើច្បាប់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសិក្សាលើការបកស្រាយរបស់ចៅក្រម (បទដ្ឋានច្បាប់) ផងដែរ ។

តាមរយៈនេះលទ្ធិមានតួនាទីដូចជាៈ

- លទ្ធិមិនមែនជាប្រភពនៃច្បាប់ទេនាពេល នេះមានន័យថាមតិរបស់អ្នកនិពន្ធទោះបីជាមានឥទ្ធិពលយ៉ាងណាក៏ដោយ ក៏មិនអាចបង្ខំឱ្យចៅក្រមអនុវត្តតាមបានដែរ។ ប្រសិនបើចៅក្រមយល់ស្របតាមមតិណាមួយ គាត់ត្រូវតែយកហេតុផលទាំងនោះមកធ្វើជាហេតុផលផ្ទាល់ខ្លួនរបស់គាត់ក្នុងសេចក្ដីសម្រេច ។
- លទ្ធិគឺជាអាជ្ញាធរ (Une autorité) ទោះបីជាមិនមែនជាប្រភពច្បាប់ ប៉ុន្តែវាដើរតួនាទីយ៉ាងសំខាន់ក្នុងការបញ្ជាក់ឱ្យច្បាស់ និងការរៀបចំសណ្ដាប់ធ្នាប់នៃវិធានច្បាប់។ បើគ្មានវាទេ ច្បាប់នឹងក្លាយជាគំនរនៃវិធាន និងសេចក្ដីសម្រេចដែលរញ៉េរញ៉ៃ។

### ១.៧.២.៣ យុត្តិសាស្ត្រ

ជានវានុវត្តន៍ វិទ្យាសាស្ត្រនីតិសាស្ត្ររបស់អាល្លឺម៉ង់(German legal science)បានបង្កើតឡើងនូវប្រព័ន្ធនៃការប្រើប្រាស់យុត្តិសាស្ត្រតុលាការ ដោយចៅក្រមបានបញ្ជូននូវសាលក្រមពិបាកៗទៅសាកលវិទ្យាល័យនីតិសាស្ត្រ និងទទួលត្រលប់មកវិញនូវយោបល់របស់សាកលវិទ្យាល័យទៅលើចំណុចណាមួយនៃច្បាប់។[១៩៦] ការអនុវត្តបែបនេះ បានចាប់ផ្ដើមពីស.វ.ទី១៧ រហូតមកដល់ស.វ.ទី២០ ដែលបានបង្កើតនូវ បណ្ដុំសំណេរមួយដែលផ្ទុកយុត្តិសាស្ត្រតុលាការ និងលទ្ធិដែលទទួលស្គាល់ជារួម។ [១៩៧] ងាកមកមើលទិដ្ឋភាពប្រទេសកម្ពុជាវិញ ការប្រើប្រាស់និងចុះផ្សាយយុត្តិសាស្ត្រតុលាការនៅមានកម្រិតក្រោមមូលហេតុថាកម្ពុជាមិនគោរពលទ្ធិនៃការប្រើប្រាស់យុត្តិសាស្ត្រ (doctrine of precedent)។[១៩៨] ប៉ុន្តែជាការអនុវត្ត

---

[១៩៦] Glendon, Carozza, and Picker (n ២០) ៣៤.

[១៩៧] Ibid.

[១៩៨] Nobumichi Teramura, *Cambodian Private International Law* (Hart Publishing ២០២៥) ៣៧.

បច្ចុប្បន្ន ក្រុមប្រឹក្សាអាជ្ញាកណ្តាលដើរតួយ៉ាងសំខាន់ក្នុងការបកស្រាយច្បាប់ និងលិខិតបទដ្ឋានក្នុងវិស័យការងារដោយការចុះផ្សាយនូវមជ្ឈតវិនិច្ឆ័យ។

### ១.៧.៣ ការបែងចែកនីតិ

ចរិតលក្ខណៈសារជាតុនៃនីតិត្រូវបានបែងដោយផ្អែកតាមធម្មជាតិនៃវិធានគតិយុត្តនោះជាអាទិ៍៖ ចរិត**លក្ខណៈ វត្ថុវិស័យ (នីតិវត្ថុវិស័យ)** និង**ចរិតលក្ខណៈអត្តវិស័យ (នីតិអត្តវិស័យ)**[199] ហេតុនេះ នីតិត្រូវបានបែងចែកជាពីរ (២) ក្រុម ដូចតទៅ៖

#### ១.៧.៣.១ នីតិសាធារណៈ

សំដៅសំណុំវិធានគតិយុត្តពាក់ព័ន្ធនឹងការរៀបចំរដ្ឋ រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ទំនាក់ទំនងសិទ្ធិ និងកាតព្វកិច្ចរវាងនីតិបុគ្គលនៃនីតិសាធារណៈ និងនីតិបុគ្គលនៃនីតិឯកជន ក្នុងគោលដៅដើម្បីធានានូវសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងផលប្រយោជន៍សាធារណៈ[២០០]។ ការរៀបចំរដ្ឋធ្វើឡើងដោយផ្សារភ្ជាប់រវាងបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិសាធារណៈ។ ពាក្យថាបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិសាធារណៈ (Prérogative de la Puissance Publique) គឺជាសញ្ញាណមានលក្ខណៈទូលាយដែលត្រូវបានប្រើតែចំពោះរដ្ឋ និងអាជ្ញាធរមានសមត្ថកិច្ច នៅក្នុងន័យសត្យាម័តបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិសាធារណៈមានលក្ខណៈផ្ទុយ និងនៅក្រៅនីតិរួម ពោលគឺជា អំណាចអាជ្ញាបញ្ជា។ នៅក្នុងអត្ថន័យអក្សរសាស្ត្រ *«បុព្វសិទ្ធ (ន) ផលប្រយោជន៍ឬអំណាចពិសេសដែលវរជនខ្លះត្រូវបានត្រូវមានតាមមុខតំណែង...។ អភ័យឯកសិទ្ធិ (ន) អំណាចដោយឡែកការពារមិនឱ្យភ័យ ច្បាប់ពិសេសសម្រាប់ជនមួយរូប ឬមួយក្រុមដែលមិនទូទៅដល់ជនឯទៀត។ សាធារណៈ (គុ.) ដែលទូទៅ ដែលទុកជាកណ្តាលដែលប្រើបានទាំងអស់គ្នា ដែលមិនចំពោះមួយៗ...។»* បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ សាធារណៈ គឺជាវិធានដែលមានចរិតលក្ខណៈវត្ថុវិស័យ ការណ៍នេះត្រូវបានបញ្ញត្តិនៅក្នុងរដ្ឋធម្មនុញ្ញ អំណាចនេះត្រូវបានអនុវត្តក្រោមទម្រង់ជា ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ជាធរមាន។ ការអនុវត្តសិទ្ធិអំណាចរបស់អាជ្ញាធរមានសមត្ថកិច្ចនេះ ត្រូវកម្រិតនៅក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន តុល្យភាពនៃអំណាច សិទ្ធិ សេរីភាពរបស់ប្រជាពលរដ្ឋ ត្រូវបានធានានៅក្នុងរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន នេះជាចរិតលក្ខណៈសារជាតុ នៃនីតិសាធារណៈ។

---

[១៩៩] Jean Dabin, Théorie générale du droit, ២é éd., ១៩៥៣, P. ៨៦.

[២០០] La définition du Droit Public, Fiche Introduction au Droit Public en ២០១៩, Par Yve Boussolle, P.៧ a ៩.

នៅក្នុងការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងផលប្រយោជន៍សាធារណៈ អាជ្ញាធរមានសមត្ថកិច្ចទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មានសិទ្ធិធ្វើសកម្មភាព ឬធ្វើសេចក្តីសម្រេចជាឯកតោភាគី។ ប៉ុន្តែត្រូវធ្វើឡើងដោយការរំលោភអំណាច។ ផលប្រយោជន៍សាធារណៈទាំងនោះត្រូវបានបង្កើតឡើងដោយទំនាក់ទំនង គតិយុត្តនីតិបុគ្គលសាធារណៈ (រដ្ឋ សមូហភាពដែនដីមូលដ្ឋាន) និងនីតិបុគ្គលឯកជន ឬរូបវន្តបុគ្គល ក្នុងគោលដៅ ដើម្បីផលប្រយោជន៍សាធារណៈ។ នៅក្នុងន័យនេះ សមូហភាពដែនដីមូលដ្ឋាន សំដៅដល់ រដ្ឋបាលរាជធានី/ខេត្ត ក្រុង/ស្រុក/ខណ្ឌ ឃុំ/សង្កាត់ គ្រឹះស្ថានសាធារណៈរដ្ឋបាល ឬគ្រឹះស្ថានសាធារណៈឧស្សាហកម្មនិងពាណិជ្ជកម្ម[២០១]។

ជាក់ស្តែង ប្រព័ន្ធរដ្ឋបាលរបស់កម្ពុជាគឺជាប្រព័ន្ធរដ្ឋបាលដែលមានឯកសណ្ឋានូបនីយកម្ម ដែលអំណាចនេះត្រូវបានផ្ទេរពីថ្នាក់ជាតិ មកថ្នាក់ក្រោមជាតិក្រោមទម្រង់ជា មជ្ឈការ វិសហមជ្ឈការ និង វិមជ្ឈការនៃអំណាចដោយនៅក្នុងនោះសិទ្ធិអំណាច និងរចនាសម្ព័ន្ធរដ្ឋបាលនៃសមូហភាពដែនដីមូលដ្ឋានត្រូវបានរៀបចំដូចខាងក្រោម៖

**១) ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ ២០០៨ បានធ្វើការកំណត់អំពីសមត្ថកិច្ចរបស់ក្រុមប្រឹក្សាដូចតទៅ៖**

- ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលបានបង្កើតឡើងដោយការបោះឆ្នោត ស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាស្រុក ក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ គឺជាតំណាងសាធារណៈ ជាអ្នកការពារ និងជាអ្នកបម្រើឱ្យផលប្រយោជន៍របស់ប្រជាពលរដ្ឋទាំងអស់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
- ក្រុមប្រឹក្សាមានអាណត្តិ៥ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលក្រុមប្រឹក្សាថ្មីចូលកាន់តំណែង។
- ក្រុមប្រឹក្សាមានសិទ្ធិអំណាចខាងបញ្ញត្តិៈ ប្រើប្រាស់សិទ្ធិអំណាចរបស់ខ្លួនដោយធ្វើដីកា។ ដីការបស់ក្រុមប្រឹក្សាមានវិសាលភាពដើម្បីកំណត់ ហាមឃាត់ ឬត្រួតពិនិត្យលើសកម្មភាពលើនីតិវិធី ឬលើកិច្ចការណាមួយដែលស្ថិតក្នុងវិសាលភាពនៃមុខងារ។
- ក្រុមប្រឹក្សាមានសិទ្ធិអំណាចខាងប្រតិបត្តិៈ គឺត្រូវបំពេញមុខងារនិងភារកិច្ចដោយធ្វើសេចក្តីសម្រេចក្នុងអង្គប្រជុំក្រុមប្រឹក្សារបស់ខ្លួន និងត្រូវធានាថាសេចក្តីសម្រេចនោះត្រូវបានអនុវត្តន៍យ៉ាងត្រឹមត្រូវ។
- ចំនួនសមាជិកក្រុមប្រឹក្សានីមួយៗ ត្រូវកំណត់ផ្អែកតាមកត្តាប្រជាសាស្ត្រនិងភូមិសាស្ត្រ ដូចខាងក្រោម៖

---

[២០១] ការពន្យល់នៅក្នុងគេហទំព័រ Vie Public.Fr។

- ក្រុមប្រឹក្សារាជធានីភ្នំពេញ មានចំនួនសមាជិកមិនលើសពី២១ រូប
- ក្រុមប្រឹក្សាខេត្ត មានចំនួនសមាជិកពី៩រូប ដល់២១រូប
- ក្រុមប្រឹក្សាក្រុង មានចំនួនសមាជិកពី៧រូប ដល់១៥រូប
- ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ មានចំនួនសមាជិកពី៧រូប ដល់១៩រូប។

**២) ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ បានធ្វើការកំណត់អំពីសមត្ថកិច្ចរបស់ក្រុមប្រឹក្សាដូចតទៅ៖**

- ឃុំ សង្កាត់នីមួយៗត្រូវមានក្រុមប្រឹក្សាហៅថាក្រុមប្រឹក្សាឃុំ សង្កាត់។
- ក្រុមប្រឹក្សាឃុំ សង្កាត់ ជាអង្គការតំណាងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួននិងមានបេសកកម្មបំរើផលប្រយោជន៍ទូទៅក្នុងឃុំ សង្កាត់របស់ខ្លួន។
- ក្រុមប្រឹក្សាឃុំសង្កាត់ត្រូវជ្រើសរើសឡើងតាមការបោះឆ្នោតដោយប្រជាពលរដ្ឋនៃឃុំ សង្កាត់របស់ខ្លួនស្របតាមនីតិវិធីដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។
- ក្រុមប្រឹក្សាឃុំ សង្កាត់ មានអាណត្តិ៥ឆ្នាំ ហើយត្រូវផុតអាណត្តិនៅពេលដែលមានក្រុមប្រឹក្សាឃុំ សង្កាត់ថ្មីចូលកាន់តំណែង។
- ក្រុមប្រឹក្សាឃុំ សង្កាត់មានសមាជិកចំនួនពី៥ទៅ១១រូបផ្អែកតាមប្រជាសាស្ត្រនិងភូមិសាស្ត្ររបស់ខ្លួន។ ចំនួនជាក់ស្តែងនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។
- រដ្ឋបាលឃុំ សង្កាត់មានតួនាទីជំរុញនិងគាំពារអភិបាលកិច្ចល្អ ដោយចាត់ចែងប្រើប្រាស់ធនធាននានាដែលមានប្រកបដោយចីរភាព សម្រាប់បំពេញសេចក្តីត្រូវការជាមូលដ្ឋានក្នុងឃុំ សង្កាត់របស់ខ្លួន បំរើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋនិងគោរពផលប្រយោជន៍របស់ជាតិស្របតាមនយោបាយទូទៅរបស់រដ្ឋ។ ឃុំ សង្កាត់មានតួនាទីបំរើកិច្ចការជាមូលដ្ឋានសម្រាប់បំរើដល់ផលប្រយោជន៍ឃុំ សង្កាត់និងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន និងមានតួនាទីជាភ្នាក់ងារតំណាងរដ្ឋក្រោមការចាត់តាំង ឬការប្រគល់អំណាចរបស់អាជ្ញាធររដ្ឋ។
- ឃុំ សង្កាត់មានអំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិ។

នៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលនេះចាំបាច់ត្រូវរៀបចំនូវការកំណត់មុខងារ និងសមត្ថកិច្ចឱ្យបានច្បាស់លាស់ទាំងខ្សែរយៈទទឹង និងខ្សែរយៈបណ្តោយដែលចំណុះឱ្យរដ្ឋបាលដែនដីមូលដ្ឋាននោះពុំនោះទេនឹងនាំឱ្យមានការរំលោភអំណាច ការអនុវត្តសិទ្ធិអំណាចលើសទំហំដែនសមត្ថកិច្ចដែលច្បាប់បានកំណត់ ជាពិសេសច្បាប់រៀបចំអង្គការដែលមានលក្ខណៈទូលាយផ្តល់ផលប្រយោជន៍ និងបម្រើឱ្យ

ប្រយោជន៍រដ្ឋបាលជាងការបម្រើផលប្រយោជន៍ទូទៅ ផលប្រយោជន៍របស់ប្រជាពលរដ្ឋ។ ហេតុនេះ ចាំបាច់ឱ្យមាននូវយន្តការបណ្តឹង មានបណ្តឹងរវាងរដ្ឋបាល និងរដ្ឋបាល រដ្ឋបាល និងប្រជាពលរដ្ឋ យន្តការនៃការដោះស្រាយវិវាទរដ្ឋបាលជាដើម។ ការគ្រប់គ្រងមន្ត្រីរាជការ បុគ្គលិកក្រោមឱវាទដែលត្រូវបំពេញការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ អង្គភាពសាមី ត្រូវកំណត់ឱ្យបានច្បាស់លាស់នូវផែនការបុគ្គលិក ការតែងតាំង និងការបញ្ចប់មុខតំណែងនាយករងរដ្ឋបាលនិងនាយកទីចាត់ការ ឬប្រធានអង្គភាពដែលមានថ្នាក់ប្រហាក់ប្រហែលនៃរដ្ឋបាលរាជធានី ខេត្ត នាយករងរដ្ឋបាលនិងប្រធានការិយាល័យ ឬប្រធានអង្គភាពដែលមានថ្នាក់ប្រហាក់ប្រហែលនៃរដ្ឋបាលក្រុង ស្រុក ការកំណត់ប្រាក់ឧបត្ថមរបស់បុគ្គលិក ទាំងនេះបង្ហាញអំពីសិទ្ធិអំណាចរបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ តាមរយៈខ្សែរយៈទទឹងនៅក្នុងមណ្ឌលសមូហភាពដែនដីមូលដ្ឋានរបស់ខ្លួន។ ឧទាហរណ៍៖ ការធ្វើប្រតិភូកម្មអំណាចដល់គណៈអភិបាលរាជធានី ខេត្ត ក្នុងការតែងតាំងនិងការបញ្ចប់មុខតំណែងរបស់មន្ត្រីរាជការស៊ីវិលនៃមន្ទីរ អង្គភាព និងការិយាល័យជំនាញនានារបស់ក្រសួងដែលបំពេញការងារនៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចាប់ពីអនុប្រធានមន្ទីរឬអនុប្រធានអង្គភាពថ្នាក់ប្រហាក់ប្រហែលចុះក្រោមតាមសំណើរបស់ប្រធានមន្ទីរឬអង្គភាព សាមី[202] សម្រាប់ការលើកសំណើតែងតាំងនិងបញ្ចប់មុខតំណែងប្រធានមន្ទី ឬប្រធានអង្គភាពជំនាញថ្នាក់ប្រហាក់ប្រហែលរបស់ក្រសួងដែលបំពេញការងារនៅរាជធានី ខេត្ត ត្រូវធ្វើឡើងដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត មករដ្ឋមន្ត្រីក្រសួងសាមីពិនិត្យសម្រេច[203]។ នៅក្នុងករណីនេះ គម្បីត្រូវធ្វើការកំណត់ឱ្យបានច្បាស់លាស់ នូវ យន្តការ នៃការត្រួតពិនិត្យការការពារចេញដីការបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្រៅពីការទទួលខុសត្រូវនៅចំពោះមុខក្រុមប្រឹក្សាភិបាល និងក្រសួងមហាផ្ទៃ គប្បីមានយន្តការដោះស្រាយវិវាទរដ្ឋបាល ជាពិសេសពាក់ព័ន្ធទៅនឹងការសិទ្ធិ និងផលប្រយោជន៍របស់បុគ្គលឯកជន។

ការកំណត់មុខងារចំនួនមន្ត្រីរាជការនៃរចនាសម្ព័ន្ធដឹកនាំរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ គឺជាការចាំបាច់ដើម្បីធានានូវតម្លាភាព គណនេយ្យភាព ជាពិសេសហិរញ្ញវត្ថុសាធារណៈ ដើម្បីសម្រាលបន្ទុកប្រជាពលរដ្ឋ និងធាននូវកំណើនសេដ្ឋកិច្ច កម្រិតជីវភាពរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន[204]។

---

២០២ អនុក្រឹត្យលេខ២៤០ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៧ របស់រាជរដ្ឋាភិបាល មាត្រា៨។

២០៣ ឯកសារដដែល មាត្រា៩។

២០៤ រចនាសម្ព័ន្ធនេះត្រូវបានកំណត់នៅក្នុងអនុក្រឹត្យលេខ ១១៤ អន.ក្រប ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ របស់រាជរដ្ឋាភិបាល។

នៅក្នុងគោលនយោបាយអភិបាលកិច្ចល្អដែលបានដាក់ចុះដោយក្រសួងមហាផ្ទៃ អភិបាលកិច្ចល្អកើតមានឡើងគឺពាក់ព័ន្ធទៅនឹងអំណាចសាធារណៈរបស់អាជ្ញាធររដ្ឋ ការអនុវត្តអំណាចនោះត្រូវធ្វើឡើងដោយឈរទៅលើល័ក្ខខ័ណ្ឌដូចតទៅ[205]៖ ១) ឯកសារក្របខ័ណ្ឌច្បាប់ ២) ការការពារសិទ្ធិមនុស្ស ៣) ប្រព័ន្ធទទួលខុសត្រូវ ៤) ប្រព័ន្ធយុត្តិធម៌ ៥) សមត្ថកិច្ចពង្រឹងការអនុវត្តច្បាប់ដោយមិនលម្អៀង និងមិនពុករលួយ។

ដើម្បីកម្រិតនូវការអនុវត្តបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិសាធារណៈរបស់អាជ្ញាធររដ្ឋ ការធានានូវសិទ្ធិស្របច្បាប់របស់បុគ្គលឯកជន និយាយដោយឡែកប្រជាពលរដ្ឋ ដែលត្រូវបានធានានៅក្នុងរដ្ឋធម្មនុញ្ញ ច្បាប់រៀបចំអង្គការត្រូវបានដាក់ចុះ ជាអាទិ៍៖ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួង ស្ថាប័ន អង្គភាព ជាសេនាធិការរបស់រាជរដ្ឋាភិបាល ដែលច្បាប់ទាំងនោះបានធ្វើការកំណត់អំពីចរិតលក្ខណៈស្ថាប័ន ការកំណត់អំពីសិទ្ធិ និងកាតព្វកិច្ច និងរបៀបរបបដំណើការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួង ស្ថាប័នទាំងនោះ។

នៅក្នុងវិស័យសាធារណៈ ចរឹតលក្ខណៈវត្ថុវិស័យនេះនឹងធ្វើឱ្យមានការបំពានទៅលើសិទ្ធិរបស់បុគ្គលម្នាក់ (ការប៉ះពាល់ចរឹតលក្ខណៈអត្តវិស័យ) និយាយដោយឡែកគឺការប៉ះពាល់ទៅដល់ប្រជាធិបតេយ្យ (ប្រជាធិបតេយ្យ ថ្នាក់ក្រោមជាតិ) នៅក្នុងករណីមិនបានធ្វើការសិក្សាឱ្យបានច្បាស់លាស់អំពីផលប៉ះពាល់នៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត (Regulatory Impact Assessment) អសង្គតិភាព អសន្តិសុខគតិយុត្ត ការកំណត់អំពីសមត្ថកិច្ចរបស់អាជ្ញាធរមានសមត្ថកិច្ចមិនបានច្បាស់លាស់ ជាពិសេសការផ្ទេរ និងការអនុវត្តមុខងារនៃរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ នីតិសាធារណៈត្រូវបានបែងចែកជាពីរមែកធាងសំខាន់ៗ គឺ៖

### ១.៧.៣.២ នីតិសាធារណៈជាតិ

នីតិសាធារណៈជាតិ គឺជាវិធានដែលមានចរិតលក្ខណៈវត្ថុវិស័យ ត្រូវបានដាក់ចុះដើម្បីដឹកនាំរដ្ឋ ថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងធានានៅផលប្រយោជន៍រួមនៅក្នុងសង្គម មានដូចតទៅ៖

**រដ្ឋធម្មនុញ្ញ** នៅក្នុងឯកសារសិក្សាស្រាវជ្រាវត្រៀមសិក្ខាសាលាផ្តល់ដោយឯកឧត្តមបណ្ឌិត **តាំង វេតនា** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ការលើកឡើងរបស់ឯកឧត្តមកិតិនីតិ

---

២០៥ គោលនយោបាយអភិបាលកិច្ចល្អ ក្រសួងមហាផ្ទៃ បោះពុម្ពលើកទី២ ខែតុលា ឆ្នាំ២០១០ ទំព័រទី១០។

កោសល្យបណ្ឌិត **អ៊ឹម ឈុនលឹម** នៅក្នុងសិក្ខាសាលាស្តីពី «**គុណតម្លៃទំនើប និងគុណតម្លៃខ្មែរ ដែលមានក្នុងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា**» ដូចតទៅ៖ «ធម្មនុញ្ញឆ្នាំ១៩៩៣ ជារដ្ឋធម្មនុញ្ញមានលក្ខណៈប្រជាធិបតេយ្យជឿនលឿន ដែលបានកើតចេញពីឆន្ទៈរួមរបស់ប្រជារាស្ត្រខ្មែរគ្រប់និន្នាការនយោបាយ។ សភាធម្មនុញ្ញបានតាក់តែងរក្សាឱ្យមានមកវិញនូវ គុណតម្លៃប្រពៃណីខ្មែរ (គឺ ជាតិ សាសនា ព្រះមហាក្សត្រ) អមជាមួយគុណតម្លៃធម្មនុញ្ញទំនើប ជាមូលដ្ឋានគ្រឹះ (គឺ ប្រជាធិបតេយ្យ សិទ្ធិមនុស្សនីតិរដ្ឋ) ដោយតាក់តែងបញ្ចូលទាំងស្រុង និងដោយលម្អិតនូវខ្លឹមសារនៃឧបសម្ព័ន្ធទី៥ នៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសដែលចែងអំពីគោលការណ៍នៃរដ្ឋធម្មនុញ្ញថ្មីរបស់កម្ពុជា។ ក្នុងដំណើរការអនុវត្តជាក់ស្តែង ការបន្សាំបន្សុីគ្នានៃគុណតម្លៃទាំងពីរបានបង្កនូវកម្លាំងសម្របសម្រួលនិងជំរុញរួមគ្នា ក្នុងការដោះស្រាយបញ្ហានយោបាយ និងបញ្ហាច្បាប់ដែលបានកើតមានឡើងជាបន្តបន្ទាប់ ដោយរក្សាបាននូវភាពសុខដុមរមនាក្នុងសង្គម[206]។ ក្នុងតម្លៃនៃធម្មនុញ្ញនិយម មានជាអាទិ៍ក្រមប្រតិបត្តិ ទសពិធរាជធម៌ ទសបារមី និងព្រហ្មវិហារធម៌ រួមនិងគោលការណ៍ "ធម្ម" នានាដែលមានក្នុងប្រពៃណីទំនៀមទម្លាប់ល្អរបស់សង្គមខ្មែរ។ គោលការណ៍ក្នុងក្រមប្រតិបត្តិទាំងនោះ តាមការសិក្សាវិភាគ គឺពិតជាបានផ្តល់សញ្ញាណធម្មនុញ្ញនិយម ស្របនឹងគុណតម្លៃធម្មនុញ្ញ ទំនើប តាមបែបបស្ចិមលោក (ប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងនីតិរដ្ឋ) ដែលបានផ្សាយមកកាន់ព្រះរាជាណាចក្រ កម្ពុជាគឺជាភាពចម្រុះនៅក្នុងប្រព័ន្ធច្បាប់កម្ពុជាដែលត្រូវទទួលយកដើម្បីសម្រេចបាននូវនីតិរដ្ឋ។

**នីតិមុខងារសាធារណៈ** សំដៅដល់ការកំណត់អំពីប្រព័ន្ធអាជីពរបស់មន្ត្រីរាជការសាធារណៈ ការកំណត់អំពីមុខងារ និងសមត្ថកិច្ចរបស់មន្ត្រីរាជការ ក្នុងការគិតគូរទៅលើនីតិរដ្ឋ នៅក្នុងមុខងារសាធារណៈ ក៏ចាំបាច់ត្រូវគិតគូរអំពីគុណតម្លៃនៃមុខងារសាធារណៈ (គុណតម្លៃឯកភាពរដ្ឋបាល) ដោយនៅក្នុងនោះ ប្រព័ន្ធអាជីពរបស់មន្ត្រីមានពីរគឺ៖ ប្រព័ន្ធអាជីព (ប្រព័ន្ធបិទ) និងប្រព័ន្ធនិយោជន៍ (ប្រព័ន្ធបើក) ដែល

---

២០៦ សេចក្តីសន្និដ្ឋានខាងលើ គឺជាសមិទ្ធផលខាងផ្នែកទស្សនាទានធម្មនុញ្ញនិយមមួយដ៏មានតម្លៃ និងជាមគេកគំនិតមិនចេះរីងស្ងួត សម្រាប់អ្នកសិក្សាខាងនីតិរដ្ឋធម្មនុញ្ញកម្ពុជា។ មួយវិញទៀត ទស្សនាទានដែលកំណត់អំពីចរិតលក្ខណៈ គុណភាព និងសមត្ថភាព នៃរដ្ឋធម្មនុញ្ញ នេះ ត្រូវបានទទួលស្គាល់ដោយថ្នាក់ដឹកនាំកំពូលរបស់ជាតិ និងគ្រប់មជ្ឈដ្ឋានក្នុងសង្គម បន្ទាប់ពីព្រះរាជាណាចក្រកម្ពុជាបានប្រារព្ធរៀបចំព្រះរាជពិធីអបអរសាទរទិវារំលឹកខួប៣០ឆ្នាំ នៃការប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា កាលពីឆ្នាំ២០២៣ និងការប្រារព្ធព្រះរាជពិធីសម្ពោធនីតិបូជនីយដ្ឋាន "**វិមានរដ្ឋធម្មនុញ្ញ**" កាលពីឆ្នាំ២០២៤។ ជាការកត់សម្គាល់ ប្រកបដោយមោទនភាព ទស្សនាទាននេះ ត្រូវបាននាំយកទៅឆ្លាក់លើផ្ទាំងសិលាចារឹកនៅឯ **វិមានរដ្ឋធម្មនុញ្ញ** ទុកជាមគេកខាងគំនិត សម្រាប់កូនចៅខ្មែរតទៅ ដូច្នេះទស្សនាទាន នេះ បានក្លាយជាផ្នែកមួយដ៏មានសារៈសំខាន់ក្នុងការកសាងសុខដុមនីយកម្មទស្សនាទានធម្មនុញ្ញនិយម ក្នុងបរិបទនៃសង្គមខ្មែរទាំងក្នុងពេលបច្ចុប្បន្ន និងតទៅអនាគត។

ចាំបាច់ត្រូវគិតគូទៅលើសិទ្ធិ និងអត្ថប្រយោជន៍ បន្ទុករបស់រដ្ឋ ជាពិសេសបន្ទុកនៃហិរញ្ញវត្ថុសាធារណៈ ជាក់ស្តែងក្រោយការវិភាគមុខងាររាជរដ្ឋាភិបាលពិនិត្យនូវលទ្ធភាពប្រើប្រាស់ប្រព័ន្ធ ការជ្រើសរើសមន្ត្រីតាមការព្រមព្រៀង ការធានាបាននូវអត្ថប្រយោជន៍ របស់មន្ត្រី ស្របតាមអភិក្រម «**ពង្រឹងជាជាងពង្រីក**»[207]។

**នីតិហិរញ្ញវត្ថុសាធារណៈ** សំដៅសំណុំវិធានពាក់ព័ន្ធទៅនឹងការប្រមូលចំណូល ការគ្រប់គ្រង និងការចំណាយរបស់រដ្ឋ ដើម្បីធានាដំណើរការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋ (រដ្ឋបាលថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យផ្សេងទៀតរបស់រដ្ឋ)។ ការគ្រប់គ្រងថវិការដ្ឋត្រូវបានគ្រប់គ្រងក្រោមទម្រង់ដូចតទៅ៖ ១) រដ្ឋមណ្ឌល (Budget Central) និងថវិកាចលនាខេត្ត (Budgets Locaux)[208]។ នៅកម្ពុជាការគ្រប់គ្រង់ហិរញ្ញវត្ថុសាធារណៈ ត្រូវបានកំណត់នៅក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដោយហេតុថា គណនេយ្យភាពហិរញ្ញវត្ថុ ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និងគណនេយ្យភាពសមិទ្ធកម្ម គឺមានភាពចាំបាច់ក្នុងការធានានូវសិទ្ធិរបស់ប្រជាពលរដ្ឋ ជីវភាពរបស់ប្រជាពលរដ្ឋ ការទ្រទ្រង់ដល់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច កំណើនសេដ្ឋកិច្ច និងសមធម៌សង្គម។

**នីតិព្រហ្មទណ្ឌ** នីតិព្រហ្មទណ្ឌ នីតិវិធីព្រហ្មទណ្ឌ គឺជាសំណុំនៃវិធានដែលគ្រប់គ្រងការវិនិច្ឆ័យដោយតុលាការនៃវិវាទដែលកើតឡើងរវាងបុគ្គល និងបុគ្គល ឬរវាងរដ្ឋ និងបុគ្គល។ នីតិវិធីព្រហ្មទណ្ឌ គឺជាការអនុវត្តច្បាប់ព្រហ្មទណ្ឌ។ គោលបំណងរបស់វា គឺដើម្បីពិនិត្យបទល្មើស ប្រមូលភស្តុតាង ស្វែងរក និងវិនិច្ឆ័យជនល្មើស។ នីតិវិធីព្រហ្មទណ្ឌបង្កើតទំនាក់ទំនងរវាងបទល្មើសនិងការផ្តន្ទាទោស។ លក្ខណៈដោយឡែកនៃនីតិវិធីព្រហ្មទណ្ឌ ស្ថិតនៅក្នុងការពិតដែលថាវាត្រូវបានភ្ជាប់យ៉ាងជិតស្និតទៅនឹងការអនុវត្តច្បាប់ព្រហ្មទណ្ឌ ចំណែកឯច្បាប់រដ្ឋប្បវេណីជាញឹកញាប់បំផុតត្រូវបានអនុវត្តនៅខាងក្រៅករណីវិវាទនៅតុលាការ។ ការអនុវត្តច្បាប់ព្រហ្មទណ្ឌតម្រូវឱ្យមានការកាត់ក្តី។ នីតិវិធីព្រហ្មទណ្ឌនឹងឈានទៅឱ្យមានការកាត់ទោស និងផ្តន្ទាទោសជនល្មើស ប៉ុន្តែវាអាចបង្ហាញពីភាពគ្មានកំហុសរបស់អ្នកផ្សេងទៀតផងដែរ។ វាមានគោលបំណងការពារសង្គម ប៉ុន្តែក៏ធានាផលប្រយោជន៍របស់បុគ្គលផងដែរ។ នីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បច្ចុប្បន្នត្រូវបានគ្រប់គ្រងដោយក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧[209]។

---

[២០៧] របាយការណ៍សិក្សាស្រាវជ្រាវរបស់ក្រុមពិភាក្សាត្រៀមសិក្ខាសាលាស្តីពីប្រព័ន្ធច្បាប់កម្ពុជា ដោយលោក ណុច រ៉ាមូ ប្រធានលេខាធិការដ្ឋាន សាលាភូមិន្ទរដ្ឋបាល។

[២០៨] របាយការណ៍សិក្សាស្រាវជ្រាវរបស់លោកស្រី ឡេង ចាន់ក្លូង អ្នកជំនាញការច្បាប់ នៃអគ្គលេខាធិការដ្ឋាន **គ.ក.ច.**។

[២០៩] របាយការណ៍សិក្សាស្រាវជ្រាវរបស់ឯកឧត្តម ពេជ អង្គ ប្រធានក្រុមការងារពាណិជ្ជកម្ម នៃក្រុមប្រឹក្សាអ្នកច្បាប់។

### ១.៧.៣.៣ នីតិអន្តរជាតិសាធារណៈ

នីតិអន្តរជាតិសាធារណៈ សំដៅដល់សំណុំវិធានគតិយុត្តទាំងឡាយដែលកំណត់អំពីសិទ្ធិ និងកាតព្វកិច្ចរបស់រដ្ឋនៅក្នុងទំនាក់ទំនងអន្តរជាតិ ការពារផលប្រយោជន៍ និងការដោះស្រាយជម្លោះអន្តរជាតិរវាងរដ្ឋ និងរដ្ឋ ឬ រដ្ឋ និងអង្គការអន្តរជាតិ ដោយសន្តិវិធី មានជាអាទិ៍ ការបង្កើតលិខិតតូបករណ៍អន្តរជាតិ ការបកស្រាយ និងការដោះស្រាយជម្លោះអន្តរជាតិ[210]។ នីតិអន្តរជាតិសាធារណៈ ដែលត្រូវបានលើកយកមកសិក្សានៅក្នុងក្របខ័ណ្ឌសិក្ខាសាលាស្តីពីប្រព័ន្ធច្បាប់កម្ពុជា មានដូចតទៅៈ

**នីតិបរិស្ថាន** សំដៅដល់សំណុំវិធានទាំងឡាយពាក់ព័ន្ធទៅនឹងការគាំពារបរិស្ថាន ការប្រើប្រាស់ធនធានធម្មជាតិជាដើម ដែលមានចរិកលក្ខណៈជាសាកលផង និងឆ្លើយតបទៅនឹងបរិការណ៍កម្ពុជាផង។ ជាក់ស្តែងក្រមបរិស្ថាន និងធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានប្រកាសឱ្យប្រើនៅក្នុងឆ្នាំ ២០២៤ ដែលត្រូវបានបង្កើតឡើងនៅក្នុងគោលបំណងដើម្បីធ្វើឱ្យឯកសណ្ឋានភាព អភិបាលកិច្ចវិស័យបរិស្ថានគ្រប់ជ្រុងជ្រោយក្នុងវិស័យបរិស្ថាន ការអភិរក្សធនធានធម្មជាតិ និងការអភិវឌ្ឍប្រកបដោយចីរភាព[211] ប៉ុន្តែក្រមនេះ មានចំណុចខ្វះខាតជាច្រើនមាន ការបកស្រាយបទប្បញ្ញត្តិជាធរមាន និងវិវាទគតិយុត្ត។

**នីតិសិទ្ធិមនុស្ស** បុគ្គលភាពគតិយុត្តរបស់មនុស្សត្រូវបានធានាតាមរយៈសិទ្ធិជាមូលដ្ឋានគ្រឹះរបស់មនុស្ស ដូចមានកំណត់នៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សក្របខ័ណ្ឌសហប្រជាជាតិ ឆ្នាំ ១៩៤៨ ហើយសិទ្ធិ និងកាតព្វកិច្ចរបស់មនុស្សនេះ ត្រូវបានបញ្ញត្តិនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ត្រង់មាត្រា៣១ ប៉ុន្តែការអនុវត្តសិទ្ធិទាំងនោះត្រូវចារិកជាលក្ខណៈវត្ថុវិស័យ អាស្រ័យទៅតាមបរិបទនយោបាយ កាលៈទេសៈសង្គមរបស់កម្ពុជា[212]។

ក្នុងរយៈពេល ២៥ ឆ្នាំចុងក្រោយ បន្ទាប់ពីការសម្រេចបាននូវសុខសន្តិភាពពេញលេញ ឯកភាពជាតិ និងឯកភាពទឹកដីទាំងស្រុង តាមរយៈនយោបាយឈ្នះ-ឈ្នះ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានព្រឹទ្ធសភានីតិកាលទី៥ រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តប្រកបដោយជោគជ័យនូវយុទ្ធសាស្ត្រត្រីកោណ និងយុទ្ធសាស្ត្រចតុកោណ ទាំង៤ ដំណាក់កាល ដោយសម្រេចបានសមិទ្ធផលធំៗលើគ្រប់វិស័យ, ទាំងនយោបាយ, សង្គម, និងសេដ្ឋកិច្ច ដែលនាំឱ្យកម្ពុជា សម្រេចបាននូវការផ្លាស់ប្តូរមុខមាត់ថ្មី គួរជាទីមោទនៈបំផុត។ ដោយឡែក

---

២១០ សូមមើលអនុសញ្ញាទីក្រុងវៀន ឆ្នាំ១៩៦៩ បំពេញបន្ថែមឆ្នាំ១៩៨០ ស្តីពី «ច្បាប់សន្ធិសញ្ញា»។

២១១ របាយការណ៍ស្រាយជ្រាវរបស់លោក ម៉ិញ សុមេត្តា អ្នកជំនាញការច្បាប់ នៃអគ្គលេខាធិការដ្ឋាន គ.ក.ច.។

២១២ របាយការណ៍ស្រាវជ្រាវរបស់លោក អៀប សុធានី អនុប្រធាននាយកដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ក.ច.។

សម្រាប់នីតិកាលទី៧ នៃរដ្ឋសភា, **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ដាក់ចេញនូវ **យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និង ចីរភាព** ដោយបន្តផ្តោតជាសំខាន់លើរបៀបវារៈ ធានាប្រសិទ្ធភាពសមិទ្ធកម្ម តាមរយៈការអនុវត្តអភិក្រម "**ឆ្លុះកញ្ចក់, ងូតទឹក, ដុសក្អែល, ព្យាបាល និង វះកាត់**" និង អភិក្រម "**ដំរភាពនៃប្រព័ន្ធតួអង្គតែមួយ**" (Pynamics of Stakeholder System)។[213] ផ្អែកលើស្នូលនៃយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ នេះ ដែលផ្តោតលើអភិបាលកិច្ច និងការធ្វើទំនើបកម្មស្ថាប័នរដ្ឋឱ្យក្លាយជារដ្ឋបាលសាធារណៈទំនើបប្រកបដោយសមត្ថភាពខ្ពស់ ខ្លាំង វៃឆ្លាត និងស្អាតស្អំ រាជរដ្ឋាភិបាលបានកំណត់អភិក្រម "**រៀបចំផ្ទះឱ្យរៀបរយ**" និង "**ពង្រឹងជាជាងពង្រីក**" ដើម្បីធានាការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង ស្ថាប័នឱ្យមានប្រសិទ្ធភាពខ្ពស់។

ដើម្បីឱ្យសង្គមមួយមានសុខដុមនីយកម្ម ការអប់រំចិត្ត ឥរិយាបទរបស់មនុស្សនៅក្នុងសង្គមគឺជារឿងចាំបាច់ បន្ថែមពីនេះការបកស្រាយច្បាប់គឺជាចំណុចសំខាន់មួយ ក្នុងចំណោមចំណុចដែលរួមចំណែកធ្វើឱ្យសង្គមមានសុខដុមនីយកម្ម។ ការបកស្រាយច្បាប់ចាំបាច់ត្រូវធានាបាននូវសង្គតិភាព គុណភាព ឯកសណ្ឋានូបនីយកម្ម ទើបការអនុវត្តច្បាប់ប្រកដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។ ការបកស្រាយច្បាប់ និងការបកស្រាយវិវាទគតិយុត្ត គឺជាផ្នែកមួយក្នុងការពង្រឹងនីតិរដ្ឋនៅកម្ពុជា ឱ្យកាន់តែរលូនត្រូវផ្អែកទៅលើកត្តាចាំបាច់ក្នុងការធានាបាននូវគោលការណ៍នីតិរដ្ឋ សន្តិសុខគតិយុត្ត ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃច្បាប់ និង/ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត។

សម្រាប់ក្របខ័ណ្ឌនៃការដោះស្រាយវិវាទគតិយុត្ត រាជរដ្ឋាភិបាលបានដាក់ចេញនូវសេចក្តីណែនាំលេខ០១ សណន ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៤ ស្តីពីការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន និងសារាចរលេខ០៨ សរ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៤ ស្តីពីការរៀបចំនិងការកែសម្រួលរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន ក្នុងគោលបំណងពង្រឹងប្រសិទ្ធភាពនៃការរៀបចំមុខងារនិងរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន។ យោងតាមលទ្ធផល នៃការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធក្រសួង ស្ថាប័ននេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវសារាចរស្តីពី ការកំណត់ និងការអនុវត្តមុខងារនៅតាមក្រសួង ស្ថាប័ន ចំណុះអង្គការនីតិប្រតិបត្តិ (លើកលែងក្រសួងការពារជាតិ និងអង្គភាពដែលទទួលបន្ទុកសន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈនៃក្រសួងមហាផ្ទៃ) ដោយធ្វើការកំណត់មុខងាររបស់ខ្លួនឱ្យបានច្បាស់លាស់ ដែលជាមុខងារស្នូលតាមវិស័យ និងមុខងាររងនៃមុខងារស្នូលតាមវិស័យដែល

---

[២១៣] យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១, រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា។

ក្រសួង ស្ថាប័នទទួលបន្ទុក[214]។ មុខងារស្នូល និងមុខងាររងនៃមុខងារស្នូល គឺជាមូលដ្ឋានផ្តល់សមត្ថកិច្ចដល់ក្រសួង ស្ថាប័នក្នុងការបំពេញមុខងារនិងភារកិច្ច។

ក្នុងបរិបទនៃការធ្វើទំនើបកម្មស្ថាប័នរដ្ឋ ដើម្បីបង្កើនប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពនៃការអនុវត្តបេសកកម្មរបស់ក្រសួង និងស្ថាប័នតាមគោលនយោបាយនៃយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ការពិនិត្យ និងវិភាគមុខងារនិងរចនាសម្ព័ន្ធរបស់អង្គភាពរដ្ឋ ក្លាយជាវិធានការមួយដ៏សំខាន់និងមិនអាចខ្វះបាន។ យ៉ាងណាមិញ ក្នុងអំឡុងនៃដំណើរការនេះ មានវិវាទសមត្ថកិច្ចជាច្រើនបាននិងកំពុងឡើងឡើងដែលប៉ះពាល់ដល់ការបំពេញបេសកកម្ម និងទិសដៅនយោបាយរបស់រដ្ឋបាលសាធារណៈ។

ដោយសារតែមានតម្រូវការជាចាំបាច់ក្នុងការកសាងកម្ពុជាឱ្យក្លាយទៅជាប្រទេសនីតិរដ្ឋ និងសម្រេចបាននូវចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ប្រែក្លាយកម្ពុជាទៅជាប្រទេសដែលមានចំណូលខ្ពស់នៅក្នុងឆ្នាំ២០៥០ ក្របខ័ណ្ឌ**ឯកសារទស្សនាទានស្តីពី "ការបកស្រាយច្បាប់ និងយន្តការនៃការដោះស្រាយវិវាទគតិយុត្ត"** ត្រូវបានរៀបចំឡើង ដើម្បីស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល នៅក្នុងកម្មវិធីកំណែទម្រង់ច្បាប់ក្នុងរយៈពេល ២០ឆ្នាំ ឆ្ពោះទៅរកគោលដៅក្លាយជាប្រទេសនីតិរដ្ឋនៅក្នុងឆ្នាំ២០៤៥ ព្រមទាំងឆ្លុះបញ្ចាំង និងដោះស្រាយនូវបញ្ហាប្រឈមដែលក្រសួង ស្ថាប័ន ចំណុះអង្គភាពនីតិប្រតិបត្តិបាន និងកំពុងជួបប្រទះ ជាពិសេសធ្វើឱ្យការបកស្រាយច្បាប់ មាននូវឯកសណ្ឋានូបនីយកម្ម សង្គតិភាព គុណភាពគតិយុត្ត ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ព្រមទាំងលុបបំបាត់ការស្ទួន ឬត្រួតស៊ីគ្នានៃមុខងារ ការធានានូវតម្លាភាព គណនេយ្យភាព និងភាពច្បាស់លាស់នៃសមត្ថកិច្ចរបស់អង្គភាពនីមួយៗ។ ការបកស្រាយច្បាប់ និងការដោះស្រាយវិវាទគតិយុត្ត ធ្វើឡើងក្នុងគោលបំណង់ដើម្បីធានានូវផលប្រយោជន៍សាធារណៈ រវាងបុគ្គលសាធារណៈ និងបុគ្គលឯកជន នៅក្នុងគោលដៅដើម្បីផលប្រយោជន៍សាធារណៈ។

នៅក្នុងចរឹតលក្ខណៈវត្ថុវិស័យនេះ កំណត់អំពីគោលបំណង និងគោលដៅនៃការគ្រប់គ្រងរដ្ឋ និងការថែរក្សាសណ្តាប់ធ្នាប់សាធារណៈ ការកំណត់អំពីសិទ្ធិ សេរីភាព និងកាតព្វកិច្ចរបស់បុគ្គលម្នាក់ៗ ដែលផ្សារភ្ជាប់ជាមួយនឹងវិធានគតិយុត្តនៃការដាក់ទណ្ឌកម្ម ហេតុនេះការបកស្រាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមានត្រូវធ្វើនៅក្នុងន័យតឹងរឹង ឬនៅក្នុងន័យចង្អៀត[215] ។ឧទាហរណ៍៖ មាត្រា៥នៃក្រមព្រហ្មទណ្ឌ

---

២១៤ សារាចរលេខ ០៥ សរ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៥ ស្តីពី ការកំណត់ និងការអនុវត្តមុខងារនៅតាមក្រសួង ស្ថាប័ន ចំណុះអង្គការនីតិប្រតិបត្តិ។

២១៥ Selon le dictionnaire de politique Toupictionnaire : « *Le droit objectif l'ensemble des règles et des normes juridiques à caractère obligatoire qui sont applicables dans un pays. Ces règles et normes, établies par le pouvoir en place, sont destinées à organiser la vie des hommes en société, à réguler leurs rapports et à maintenir l'ordre et la sécurité. Leur violation peut engendrer une sanction de la part de l'autorité publique* ».

*«ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់ត្រូវបកស្រាយ យ៉ាងតឹងរ៉ឹង។ ចៅក្រមមិនអាចពង្រីកវិសាលភាពអនុវត្ត ឬ ប្រព្រឹត្ត តាមសទិសភាពបានឡើយ»។*

### ១.៧.៣.៤ ៣នីតិឯកជន

សំណុំវិធានទាំងឡាយដែលមានចរិតលក្ខណៈជានីតិអត្តវិស័យដែលកំណត់ទំនាក់ទំនងគិតយុត្ត រវាងបុគ្គលឯកជន និងបុគ្គលឯកជន ឬបុគ្គលសាធារណៈ និងបុគ្គលឯកជន ដើម្បីការពារសិទ្ធិ និងផល ប្រយោជន៍ស្របច្បាប់របស់បុគ្គលម្នាក់ៗ។ នីតិអត្តវិស័យ គឺជាបុព្វសិទ្ធិរបស់បុគ្គលម្នាក់ៗ កត្តាសត្យានុម័តនៃ ការបង្ហាញឆន្ទៈ ដែលអនុញ្ញាតឱ្យបុគ្គលម្នាក់ៗមានទាំងរូបវន្តបុគ្គល និងនីតិបុគ្គល ការពារផលប្រយោជន៍ ផ្ទាល់ខ្លួន ប៉ុន្តែ សិទ្ធិនេះត្រូវបានអនុវត្តនៅក្នុងវិសាលភាពដែលច្បាប់កំណត់ (ក្នុងព្រំដែននៃនីតិវត្ថុវិស័យ) ពោលគឺបទប្បញ្ញត្តិដាច់ខាត (ចរិតលក្ខណៈបង្គាប់បញ្ជារ) ឬបទប្បញ្ញត្តិមិនដាច់ខាត (ចរិតលក្ខណៈ បំពេញបន្ថែម)។ សិទ្ធិរបស់បុគ្គលត្រូវបានសិក្សាទៅលើពីរ (២) ទិដ្ឋភាពៈ ១) សិទ្ធិក្រៅបេតិកភណ្ឌ សំដៅដល់សិទ្ធិរបស់បុគ្គលម្នាក់ៗ ដែលផ្សារភ្ជាប់ទៅនឹងបុគ្គលម្នាក់ៗ មិនអាចផ្ទេរ លក់ដោះដូរ និងគិតជា ប្រាក់ និងគ្មានអាជ្ញាយុកាលកំណត់ មានជាអាទិ៍ៈ សិទ្ធិចូលរួមនយោបាយ អង្គការ សមាគមន៍ សេរីភាព ក្នុងការបញ្ចេញមតិ អភ័យឯកសិទ្ធិគ្រួសារ បូរណភាពផ្លូវកាយ និងផ្លូវចិត្ត និង២) សិទ្ធិលើបេតិកភណ្ឌ សំដៅដល់សិទ្ធិផ្សារភ្ជាប់ទៅនឹងបុគ្គលម្នាក់ៗ មានតម្លៃ មូលនិធិ ទ្រព្យសម្បត្តិ ដែលអាចផ្ទេរ លក់ដោះដូរ គិតជាប្រាក់បាន តតាំងនឹងតតិយជនបាន និងមានអាជ្ញាយុកាលកំណត់ សិទ្ធិនេះត្រូវបានដឹងមានពីរ (២) គឺៈ សិទ្ធិលើបេតិកភណ្ឌចម្បង មានសិទ្ធិខាងបញ្ញា សិទ្ធិបាតិបុគ្គល និងសិទ្ធិប្រត្យក្ស និងសិទ្ធិលើ បេតិកភណ្ឌបន្ទាប់បន្សំសំដៅដល់សិទ្ធិប្រាតិភោគប្រត្យក្ស មានសិទ្ធិឃាត់ទុក ឯកសិទ្ធិ សិទ្ធិលើការបញ្ចាំ ហ៊ីប៉ូតែក សិទ្ធិប្រាតិភោគដោយអនុប្បទាន ហើយសិទ្ធិទាំងត្រូវបានធានាដោយរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ និងនៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ និងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ២០១១។

### ១.៧.៣.៥ នីតិឯកជនជាតិ

នីតិរដ្ឋប្បវេណី ឬជំនួសដោយហៅថា "នីតិឯកជន" [២៦] មានអត្ថន័យដូចគ្នា ដែលសំដៅដល់បណ្តុំនៃវិធាន ឬ បទប្បញ្ញត្តិ ដែលគ្រប់គ្រងរាល់ទំនាក់ទំនងគតិយុត្តរវាងបុគ្គលឯកជន និងបុគ្គលឯកជន ក្នុងជីវភាពរស់នៅប្រចាំ ថ្ងៃ។ បច្ចុប្បន្នកម្ពុជាបាន និងកំពុងអនុវត្តក្រមរដ្ឋប្បវេណី ដែលជាច្បាប់ទូទៅនៃនីតិឯកជនគ្របដណ្តប់លើទំនាក់ ទំនងគតិយុត្តផ្នែករដ្ឋប្បវេណី។ ក្រមនេះ ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៧ (តទៅហៅកាត់ថា "ក្រមរដ្ឋប្បវេណី ២០០៧) និងត្រូវបានប្រកាសឱ្យអនុវត្តនៅ

---

[២៦] សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ១, ម.១, ទំ.១

ទូទាំងព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ដោយបញ្ញត្តិនៃច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ (តទៅហៅកាត់ថា "ច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី" ) ដែលផ្សារភ្ជាប់ទៅនឹងបវេណីជារបៀបរបបគ្រប់គ្រងសណ្ដាប់ធ្នាប់ ទំនៀមទំលាប់រស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។ ក្រមនេះមានគោលបំណងផ្ដោតសំខាន់ គោរពលើការបង្ហាញឆន្ទៈដោយឯករាជ្យរបស់បុគ្គលឯកជនលើទំនាក់ទំនងប្រចាំថ្ងៃរបស់ពួកគេ ដែលក្នុងនោះក្រមរដ្ឋប្បវេណីបានបែងចែកជា ៩ គន្ថីធំ ដោយមាន៣ផ្នែកសំខាន់ៗរួមមាន ១. គោលការណ៍ទូទៅនៃក្រមរដ្ឋប្បវេណី ដែលមានបញ្ញត្តិ ជានានូវសិទ្ធិស្មើគ្នារបស់ប្រជាពលរដ្ឋ ការគោរពសេរីភាពឆន្ទៈ បុគ្គល ការអនុវត្តកាតព្វកិច្ចដោយសុចរិតស្មោះត្រង់ និងបញ្ញត្តិពាក់ព័ន្ធនឹងសមត្ថភាពគតិយុត្តរបស់បុគ្គលឯកជន ២.ទំនាក់ទំនងទ្រព្យសម្បត្តិ ដែលមានបញ្ញត្តិពាក់ព័ន្ធនឹងសិទ្ធិប្រត្យក្ស(សិទ្ធិលើវត្ថុ) កាតព្វកិច្ចនិងកិច្ចសន្យាសំខាន់ៗ (សិទ្ធិលើបុគ្គល ឬ សិទ្ធិលើបំណុល ឬ សិទ្ធិបាតិបុគ្គល) និង៣. សិទ្ធិក្រៅបេតិកភណ្ឌ រួមមានសិទ្ធិបុគ្គល និងសិទ្ធិគ្រួសារ ដែលក្នុងនោះមានបញ្ញត្តិពាក់ព័ន្ធនឹងការបង្កើតគ្រួសារ ទំនាក់ទំនងឪពុកម្ដាយកូន និងមត៌ក[217]។ ក្រៅពីនេះ មានច្បាប់ពិសេសមួយចំនួន ដែលត្រូវបានអនុម័ត និងប្រកាសឱ្យប្រើដើម្បីធានានូវសិទ្ធិ និងផលប្រយោជន៍ផ្នែកខាងសេដ្ឋកិច្ចផ្សេងៗ មានជាចង្កោមនៃនីតិពាណិជ្ជកម្ម នីតិកម្មសិទ្ធិបញ្ញា ជាដើម។ សម្រាប់វិធានដែលមានចរិតលក្ខណៈអត្តវិស័យនេះ ផ្ដល់នូវសិទ្ធិសេរីភាពរបស់បុគ្គលឯកជនម្នាក់ៗ ក្នុងការបង្ហាញឆន្ទៈរបស់ខ្លួន ប៉ុន្តែការអនុវត្តសិទ្ធិនេះ ធ្វើនៅក្នុងក្របខ័ណ្ឌនៃនីតិវត្ថុវិស័យ។ សម្រាប់ចរឹតលក្ខណៈនៃនីតិអត្តវិស័យ វិធាននៃការបកស្រាយច្បាប់អនុញ្ញាតឱ្យអ្នកបកស្រាយច្បាប់ប្រើប្រាស់វិធីសាស្ត្រនៃការបកស្រាយច្បាប់ក្នុងន័យទូលាយ ដោយការពង្រីកវិសាលភាព ឬការប្រព្រឹត្តតាមសទិសភាព។

### ១.៧.៣.៦ នីតិអន្តរជាតិឯកជន (Private International Law)

នីតិអន្តរជាតិឯកជន សំដៅលើសំណុំនៃវិធានដែលគ្រប់គ្រងទំនាក់ទំនងរវាងបុគ្គលឯកជន និងបុគ្គលឯកជន ដែលមានសញ្ជាតិខុសគ្នា ឬមានប្រទេសកំណើតផ្សេងគ្នា ឬពាក់ព័ន្ធនឹងការកំណត់អត្ថន័យ ការគ្រប់គ្រង ឬការអនុវត្តសិទ្ធិ នៅក្នុងស្ថានភាពដែលបុគ្គលជាម្ចាស់សិទ្ធិ និងបុគ្គលជាប់កាតព្វកិច្ចមានសញ្ជាតិខុសគ្នា ឬអាចនិយាយម្យ៉ាងទៀតបានថា នីតិអន្តរជាតិឯកជន គឺជាសំណុំនៃវិធានដែលគ្រប់គ្រងទំនាក់ទំនងអន្តរជាតិរវាងបុគ្គលឯកជន និងបុគ្គលឯកជន។

---

[២១៧] របាយការណ៍ស្រាវជ្រាវរបស់កញ្ញាមេធាវី ធីម សុភាព មេធាវី S.V.P.

នីតិអន្តរជាតិឯកជន មានគោលដៅខុសពីនីតិអន្តរជាតិសាធារណៈ។ នីតិអន្តរជាតិសាធារណៈគឺជាសំណុំនៃវិធានដែលគ្រប់គ្រងទំនាក់ទំនងរវាងរដ្ឋ និងរដ្ឋ ឬរវាងរដ្ឋ និងអង្គការអន្តរជាតិ។ នីតិអន្តរជាតិសាធារណៈមានគោលដៅផ្សារភ្ជាប់ និងដោះស្រាយបញ្ហាកើតឡើងរវាងរដ្ឋអធិបតេយ្យ ឬបញ្ហាវិវាទដែលផ្តើមចេញពីការប្រើប្រាស់អធិបតេយ្យភាពក្នុងប្រទេសមួយ ឬការខកខានមិនបានអនុវត្ត ឬការមិនអនុវត្តនូវគោលការណ៍ ឬខ្លឹមសារដែលចែង ឬកំណត់ ឬបានព្រមព្រៀងរវាងរដ្ឋហត្ថលេខីនៅក្នុងអនុសញ្ញា ឬសន្ធិសញ្ញាអន្តរជាតិ។ ចំណែកឯនីតិអន្តរជាតិឯកជនមានគោលដៅគ្រប់គ្រង និងដោះស្រាយបញ្ហា ឬវិវាទពាក់ព័ន្ធនឹងទំនាក់ទំនងអន្តរជាតិរវាងបុគ្គលឯកជន ដែលមិនត្រឹមតែរួមបញ្ចូលនូវទំនាក់ទំនងសេដ្ឋកិច្ច និងពាណិជ្ជកម្មតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរាប់បញ្ចូលទាំងទំនាក់ទំនងខាងផ្នែករដ្ឋប្បវេណីរវាងបុគ្គល និងបុគ្គល ជាអាទិ៍ អាពាហ៍ពិពាហ៍ ការសុំកូន សន្តតិកម្ម បណ្តឹងពាក់ព័ន្ធនឹងសិទ្ធិលើបំណុល ជាដើម។ ពាក្យ "បុគ្គលឯកជន" ក្នុងបរិបទនៃនីតិអន្តរជាតិឯកជន សំដៅទាំងរូបវន្តបុគ្គល និងនីតិបុគ្គល។

នៅក្នុងចរិតលក្ខណៈអត្តវិស័យនេះ កំណត់អំពីគោលបំណង និងគោលដៅនៃការធានាសិទ្ធិ សេរីភាពកាតព្វកិច្ចរបស់បុគ្គលម្នាក់ៗ ដែលផ្សារភ្ជាប់ជាមួយនឹងគោលការណ៍គ្រឹះនៃនីតិឯកជន[218] ហេតុនេះការបកស្រាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមានធ្វើនៅក្នុងន័យទូលាយ តាមរយៈការពង្រីកវិសាលភាព ឬការប្រព្រឹត្តតាមសទិសភាព។ នៅក្នុងការបកស្រាយច្បាប់នៅក្នុងន័យទូលាយនេះ ទាមទារឱ្យអ្នកបកស្រាយមានចំណេះដឹងច្បាស់លាស់ពាក់ព័ន្ធទៅនឹងបទប្បញ្ញត្តិដែលខ្លួនកំពុងធ្វើវិចារណកម្មនោះ ដោយឈរលើមូលដ្ឋានមានជាអាទិ៍៖ លទ្ធិ បវេណី យុត្តិសាស្ត្រ ការណ៍នេះមានភាពចាំបាច់ក្នុងការធានានូវសិទ្ធិ និងផលប្រយោជន៍របស់បុគ្គលពាក់ព័ន្ធ នៅក្នុងទំនាក់ទំនងគតិយុត្តដែលត្រូវបានបង្កើតនោះ[219]។

នៅក្នុងដំណើរការនៃការគ្រប់គ្រងរដ្ឋ ដើម្បីធានានូវនីតិរដ្ឋការគ្រប់គ្រងរដ្ឋមួយត្រូវពឹងផ្អែកទៅលើច្បាប់ដែលត្រូវ បំពេញបន្ថែមដោយប្រកពច្បាប់អត់សរសេរក្រោមទម្រង់ជា នីតិ ហេតុនេះចរិតសារជាតុក៏ចាំបាច់ត្រូវធ្វើការសិក្សាទៅលើប្រភេទច្បាប់ធរមានផងដែរ។

## ១.៨. ច្បាប់ជាធរមាន

---

[២១៨] Les Grandes notions de droit privé, Dalloz, en ២០១៤, Par Anne-Elisabeth Crédeville, Pages ២១០ à ២១៦, « *Les principes fondamentaux du Droit privé comme les suivants : liberté individuelle, égalité et non-discrimination, responsabilité ( Pacta Sunt Servanda ), sécurité juridique et bonne fois* ».

[២១៩] Les sources des obligations, Stéphane OBELLIANNE, Université PAUL Cézanne-Aix Marseille III Faculté de Droit et de Science Politique, Collection de l´institut de Droit des Affaires, no៦៨ p.១ et S.

ចរិតលក្ខណៈសារជាតុនៃច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា នឹងត្រូវធ្វើការសិក្សាទៅលើចំណុចដូចតទៅ៖ (៤.១) ច្បាប់ធម្មតា និងច្បាប់រៀបចំអង្គការ ឬ (៤.២)ច្បាប់អង្គីន និង (៤.៣) ច្បាប់ជាធរមានចាប់ពីនីតិកាលទី១ ដល់នីតិកាលទី៧ នៃរដ្ឋសភា។

### ១.៨.១ ច្បាប់ធម្មតា

ច្បាប់ធម្មតា សំដៅដល់សំណុំវិធានគតិយុត្តទាំងឡាយដែលត្រូវបានបង្កើតឡើងនៅក្នុងគោលបំណងដើម្បីថែរក្សាសណ្តាប់ធ្នាប់សាធារណៈ ទំនាក់ទំនងគតិយុត្តរវាងបុគ្គលនិងបុគ្គលនៅក្នុងសង្គមព្រមទាំងធានានូវរបៀបរបបនៃការដោះស្រាយវិវាទ[២២០]។ ច្បាប់ធម្មតា នេះត្រូវបានឃើញមានក្រោមពីរទម្រង់សំខាន់ៗ៖ ទី១) វិធាននីតិរូម ដែលមានបទប្បញ្ញត្តិច្បាប់ពីរប្រភេទ គឺច្បាប់មានចរិតលក្ខណៈសារជាតុ (règles substentiels) និងច្បាប់មានចរិតជាវិធាននីតិវិធី (règles proceduraux) និយាយដោយឡែកនៅកម្ពុជាគឺ៖ ក្រមរដ្ឋប្បវេណី ក្រមព្រហ្មទណ្ឌ ជាច្បាប់សារជាតុ ហើយក្រមនីតិវិធីរដ្ឋប្បវេណី និងក្រមនីតិវិធីព្រហ្មទណ្ឌ គឺជាវិធាននីតិវិធី។ ទី២) វិធានដោយឡែក សំដៅដល់បទប្បញ្ញត្តិច្បាប់ដោយឡែក ដែលត្រូវបានបញ្ញត្តិឡើងដើម្បីថែរក្សាសណ្តាប់ធ្នាប់សាធារណៈ ថែរក្សាទំនាក់ទំនងគតិយុត្ត និងដោះស្រាយបញ្ហាជាក់លាក់នៅក្នុងសង្គមស្របទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ឬកាលៈទេសៈភាពប្រែប្រួលនៅក្នុងសង្គម។ វិធានដោយឡែកនេះដោះស្រាយតែបញ្ហាចំពោះមុខនៅក្នុងសង្គមនោះតែប៉ុណ្ណោះ ដោយហេតុថា វិសាលភាពនៃបទប្បញ្ញត្តិច្បាប់នេះមិនធ្វើការអនុវត្តទៅលើបញ្ហាផ្សេងទៀតឡើយ។ ឧទាហរណ៍៖ ច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩ ធ្វើការគ្រប់គ្រងតែទៅលើវិស័យសំណង់ ការកំណត់អំពីបុព្វសិទ្ធិនិងអភ័យឯកសិទ្ធិសាធារណៈរបស់អាជ្ញាធរមានសមត្ថកិច្ច ការកំណត់សិទ្ធិនិងកាតព្វកិច្ចរបស់ម្ចាស់សំណង់ វិស្វករសំណង់ អ្នកម៉ៅការសំណង់ អ្នកប្រើប្រាស់សំណង់ និងបុគ្គលពាក់ព័ន្ធផ្សេងទៀត។

ដោយសារតែចរិតលក្ខណៈជាវិធានដោយឡែកនេះ ទើបធ្វើឱ្យច្បាប់ដោយឡែកចាំបាច់ត្រូវបានពិនិត្យ និងធ្វើការអនុវត្តមុនពេលអនុវត្តវិធាននៃនីតិរូម ដោយវិធាននៃនីតិរូមគឺត្រូវបានប្រើប្រាស់ជាមូលដ្ឋានគ្រឹះក្នុងការដោះស្រាយវិវាទនៅក្នុងករណីច្បាប់ដោយឡែកមិនមានចែង ដើម្បីធានានូវការការពារសិទ្ធិនិងផលប្រយោជន៍ស្របច្បាប់ដែលត្រូវបានធានានៅក្នុងរដ្ឋធម្មនុញ្ញ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។

### ១.៨.២ ច្បាប់រៀបចំអង្គការ ឬច្បាប់អង្គីន

ច្បាប់រៀបចំអង្គការ ឬច្បាប់អង្គីន (*loi organique*) សំដៅដល់សំណុំវិធានគតិយុត្តទាំងឡាយដែលកើតចេញពីនីតិវិធីកសាងច្បាប់ ត្រូវបានបង្កើតឡើងនៅក្នុងគោលបំណងដើម្បីធ្វើការកំណត់មុខងារ សមត្ថកិច្ច រចនាសម្ព័ន្ធ ដំណើរការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង ស្ថាប័ន ឬអង្គភាព ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាល ដោយផ្សារភ្ជាប់ជាមួយនឹងបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិសា

---

[២២០] Le dictionnaire de politique, Toupictionnaire , « Une ordinaire est un acte législatif voté par le parlement selon la procédure établie par la Constitution et dans l'un des domaines expressément prévus parcelle-ci.

ធារណៈ[221]។ ឧទាហរណ៍៖ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួង ស្ថាប័ន ដែលជាសេនាធិការ របស់រាជរដ្ឋាភិបាល។

ច្បាប់រៀបចំអង្គការ ឬច្បាប់អង្គិន ខុសពីច្បាប់ធម្មនុញ្ញ ដោយហេតុថាច្បាប់រៀបចំអង្គការសំដៅធ្វើការរៀបចំរចនាសម្ព័ន្ធនៃអង្គការ ក្រសួង ស្ថាប័ន ដែលត្រូវបានចារឹកនៅក្នុងរដ្ឋធម្មនុញ្ញ ដោយឡែកច្បាប់ធម្មនុញ្ញគឺជាច្បាប់ដែលត្រូវបានអនុម័តដើម្បីទៅធ្វើវិសោធនកម្មមាត្រាណាមួយនៅក្នុងរដ្ឋធម្មនុញ្ញ យោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ត្រង់មាត្រា ១៥៣-ថ្មី ច្បាប់ធម្មនុញ្ញនេះត្រូវបានអនុម័តដោយសម្លេងគាំទ្រ ២/៣ នៃអ្នកតំណាងរាស្ត្រ នៅពេលដែលព្រះមហាក្សត្រ ទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើច្បាប់វិសោធនកម្មរដ្ឋធម្មនុញ្ញសំដៅដល់ដំណើការប្រក្រតីនៃស្ថាប័នជាតិ បទប្បញ្ញត្តិនៅក្នុងច្បាប់នេះនឹងក្លាយជាមាត្រានៅក្នុងរដ្ឋធម្មនុញ្ញ បង្កើតអានុភាពគតិយុត្តទៅវិសោធនកម្ម ត្រង់មាត្រាដែលត្រូវធ្វើវិសោធនកម្ម។ ប៉ុន្តែ ការធ្វើវិសោធនកម្មនេះ មិនត្រូវឱ្យមានការប៉ះពាល់ដល់ខ្លឹមសារនៃមាត្រា១៥៤-ថ្មី និងមាត្រា១៥៥-ថ្មី នៃរដ្ឋធម្មនុញ្ញឡើយ។

ច្បាប់រៀបចំអង្គការ ឬច្បាប់អង្គិននេះ ចាំបាច់ត្រូវធ្វើការត្រួតពិនិត្យធម្មនុញ្ញភាពជាអាទិកាល (ការត្រួតពិនិត្យធម្មនុញ្ញភាពជាមុន) មុនដាក់ថ្វាយព្រះមហាក្សត្រឡាយព្រះហស្តលេខាប្រកាសឱ្យប្រើច្បាប់នោះ ដោយហេតុថា ច្បាប់នេះពាក់ព័ន្ធទៅនឹងការរៀបចំរចនាសម្ព័ន្ធអង្គភាព ការចាត់ចែងធនធានមនុស្សនៅក្នុងអង្គការ ការចាយវាយកញ្ចប់ថវិការសាធារណៈ ការកំណត់អំពីសមត្ថកិច្ចរបស់ក្រសួងស្ថាប័ន ឬអង្គភាពពាក់ព័ន្ធទាំងនោះ បើមិនធ្វើការត្រួតពិនិត្យធម្មនុញ្ញភាពជាអាទិកាល នឹងប៉ះពាល់ដល់សិទ្ធិរបស់ប្រជាពលរដ្ឋ ព្រមទាំងគោលការណ៍សំខាន់ៗដែលបានបញ្ញត្តិនៅក្នុងរដ្ឋធម្មនុញ្ញ។

### ១.៨.៣ ច្បាប់ជាធរមាននៅក្នុងវិស័យសាធារណៈ (នីតិកាលទី១ ដល់ទី៧)

បើពិនិត្យមើលទៅលើគម្រោងផែនការនៃការកសាងច្បាប់ និងច្បាប់ជាធរមានតាមនីតិកាលនីមួយៗ ដោយក្រសួង ស្ថាប័ននីមួយៗ ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាល ឃើញថាច្បាប់ទាំងនោះបម្រើឱ្យប្រយោជន៍រដ្ឋបាល និងមានចរិតជាវត្ថុវិស័យច្រើន ជាងចរិតអត្តវិស័យ។

តារាងសរុបទិន្នន័យច្បាប់ទាំង៧នីតិកាល

| ល.រ | ក្រសួង និងរដ្ឋលេខាធិការដ្ឋាន | ចំនួននីតិកាល | | | | | | | សរុប |
|---|---|---|---|---|---|---|---|---|---|
| | | ទី១ | ទី២ | ទី៣ | ទី៤ | ទី៥ | ទី៦ | ទី៧ | |
| ១ | ក្រសួងមហាផ្ទៃ | ១០ | ៣ | ២០ | ១២ | ២ | ៤ | ១ | ៥២ |
| ២ | ក្រសួងការពារជាតិ | ៣ | ១ | ៧ | ៣ | ០ | ២ | ០ | ១៦ |

[២២១] Le dictionnaire de politique, Toupictionnaire, «Une loi organique est une loi relative à l'organisation et au fonctionnement des pouvoirs publics. Votée par le parlement, elle précise ou complète les dispositions de la Constitution qui a fixé les principes généraux. »

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ៣ | ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | ៤ | ៨ | ៤ | ២ | ២ | ០ | ០ | ២០ |
| ៤ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ២៦ | ៣៤ | ២៧ | ៣៥ | ៣០ | ៤៩ | ២៨ | ២២៩ |
| ៥ | ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ | ១ | ៣ | ២ | ៥ | ៣ | ៥ | ២ | ២១ |
| ៦ | ក្រសួងអភិវឌ្ឍន៍ជនបទ | ១ | ០ | ០ | ០ | ០ | ០ | ០ | ១ |
| ៧ | ក្រសួងរ៉ែនិងថាមពល | ១ | ២ | ៦ | ១ | ៣ | ២ | ០ | ១៥ |
| ៨ | ក្រសួងផែនការ | ២ | ១ | ២ | ១ | ២ | ១ | ១ | ១០ |
| ៩ | ក្រសួងអប់រំយុវជននិងកីឡា | ១ | ០ | ២ | ០ | ០ | ០ | ០ | ៣ |
| ១០ | ក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា | ១ | ៤ | ២ | ៣ | ១ | ០ | ០ | ១១ |
| ១១ | ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ | ១ | ១ | ០ | ១ | ០ | ១ | ០ | ៤ |
| ១២ | ក្រសួងធនធានទឹកនិងឧតុនិយម | | ១ | ១ | ០ | ០ | ០ | ០ | ២ |
| ១៣ | ក្រសួងយុត្តិធម៌ | ៣ | ៥ | ៨ | ៨ | ៧ | ៧ | ២ | ៤០ |
| ១៤ | ក្រសួងអធិការកិច្ច | ០ | ០ | ០ | ០ | ០ | ០ | ១ | ១ |
| ១៥ | ក្រសួងប្រៃសណីយ៍និងទូគមនាគមន៍ | ១ | ១ | ១ | ០ | ១ | ០ | ០ | ៤ |
| ១៦ | ក្រសួងសាធារណការនិងដឹកជញ្ជូន | ១ | ១ | ៩ | ២ | ៣ | ០ | ៣ | ១៩ |
| ១៧ | ក្រសួងបរិស្ថាន | ៤ | ០ | ១១ | ២ | ៣ | ៤ | ០ | ២៤ |
| ១៨ | ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | ២ | ១ | ៣ | ១ | ១ | ១ | ០ | ៩ |
| ១៩ | ក្រសួងព្រះបរមរាជវាំង | | | ២ | ០ | ០ | ០ | ០ | ២ |
| ២០ | ក្រសួងទេសចរណ៍ | ១ | ០ | ០ | ១ | ០ | ០ | ០ | ២ |
| ២១ | ក្រសួងសុខាភិបាល | ៣ | ២ | ២ | ០ | ៤ | ១ | ០ | ១២ |
| ២២ | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១ | ០ | ៣ | ២ | ៤ | ៤ | ០ | ១៤ |
| ២៣ | ក្រសួងធម្មការនិងសាសនា | ១ | ០ | ០ | ០ | ០ | ០ | ០ | ១ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ២៤ | ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | | | | | ៥ | | | ៥ |
| ២៥ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | | | | | | ២ | ០ | ២ |
| ២៦ | ក្រសួងពាណិជ្ជកម្ម | ៣ | ៥ | ៦ | ២ | ៩ | ១៥ | ២ | ៤២ |
| ២៧ | ក្រសួងកិច្ចការនារី | ១ | ១ | ៣ | ១ | ០ | ០ | ០ | ៦ |
| ២៨ | ក្រសួងព័ត៌មាន | ២ | ០ | ០ | ០ | ០ | ០ | ០ | ២ |
| ២៩ | ក្រសួងមុខងារសាធារណៈ | ២ | ០ | ០ | ០ | ១ | ០ | ០ | ៣ |
| ៣០ | រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | ១ | ០ | ១ | ២ | ២ | ៣ | ២ | ១១ |
| ៣១ | រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន | ០ | ០ | ០ | ០ | ០ | ០ | ១ | ១ |
| ៣២ | រាជរដ្ឋាភិបាល | ១២ | ៨ | ១៥ | ៥ | ២៥ | ១៣ | ០ | ៧៨ |
| | ច្បាប់វិសោធកម្មរដ្ឋធម្មនុញ្ញ | ១ | ២ | ៣ | ០ | ២ | ២ | ១ | ១១ |
| ចំនួនសរុបតាមនីតិកាល | | ៩០ | ៨៤ | ១៤០ | ៨៩ | ១១០ | ១១៦ | ៤៤ | ៦៧៣ |

ដើម្បីឱ្យចរិតសារជាតុនៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមានជានាបាននូវសិទ្ធិ ផលប្រយោជន៍របស់បុគ្គលពាក់ព័ន្ធ និងសម្រេចបាននូវមាគ៌ានីតិរដ្ឋ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ការកសាងបទដ្ឋានគតិយុត្ត គប្បីគិតទៅលើលក្ខខណ្ឌនៃការកសាងបទដ្ឋានគតិយុត្ត។

### ១.៨.៤ វដ្តនៃច្បាប់

ច្បាប់ជាផ្នែកមួយអត្ថបទគតិយុត្ត ដែលផ្ដល់នីត្យានុកូលភាពទៅលើលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ ហេតុនេះ ការសិក្សាទៅលើជាតុចូល ចរិតលក្ខណៈសារជាតុ និងដំណាក់កាលនៃការវិវត្តរបស់ច្បាប់ គឺជាចាំបាច់ដើម្បីស្វែងយល់អំពីភាពប្រែប្រួលនៃចរិតលក្ខណៈសារជាតុរបស់ច្បាប់។ ការសិក្សាទៅលើវដ្តច្បាប់នេះ ក៏ជាផ្នែកមួយនៃការពង្រឹងនីតិរដ្ឋផង។

យោងតាមការសង្កេតនៅក្នុងមគ្គុទេសក៍សិល្ប៍សាស្ត្រនីតិកម្មរបស់បារាំង ឧត្តមានុវត្តនៃការកសាងអត្ថបទគតិយុត្តរបស់អាស៊ាន និងប្រទេសជាសមាជិកអាស៊ានមានសិង្ហបុរី ម៉ាឡេស៊ី ជាដើម វដ្តនៃច្បាប់ត្រូវបានគិតគូរជា ៤ដំណាក់កាល[222] ដូចតទៅ៖

១. ការកំណត់បញ្ហា សំដៅដល់ការស្វែងនូវបញ្ហាដោយឈរលើគោលនយោបាយរបស់រាជរដ្ឋាភិបាល បញ្ហាសង្គម សេដ្ឋកិច្ច និងការវិវត្តរបស់សង្គមក្នុងប្រទេស និងសង្គមអន្តរជាតិ ដោយហេតុថានៅក្នុងប្រព័ន្ធច្បាប់សរសេរច្បាប់កើតចេញពីការស្វែងរកនូវបញ្ហា ប្រមើលមើលទៅលើបញ្ហាបន្ទាប់មកនីតិករចាប់ផ្តើមធ្វើការគិតគូរ ដាក់ចុះនូវវិធានគតិយុត្តនៅក្នុងគោលដៅបង្ការ ទប់ស្កាត់ និងបង្ក្រាបបញ្ហាទាំងនោះនៅក្នុងសង្គម។

២. ការរៀបចំសេចក្តីព្រាងអត្ថបទគតិយុត្ត សំដៅដល់ការរៀបចំសិក្សាតាក់តែងបទប្បញ្ញត្តិច្បាប់របស់អង្គភាពនីតិកម្មនៃរាជរដ្ឋាភិបាល ដោយឈរលើវិធាន និងនីតិវិធីនៃការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ការពិគ្រោះយោបល់ជាមួយនឹងអង្គភាព ដៃគូអភិវឌ្ឍន៍ និងបុគ្គលពាក់ព័ន្ធ ការវាយតម្លៃទៅលើផលប៉ះពាល់ក្នុងការដាក់ចុះនូវច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

៣. ការអនុម័ត សំដៅដល់ការយល់ព្រមរបស់នីតិវិធីសភាដើម្បីផ្តល់សុពលភាពលើសេចក្តីព្រាងច្បាប់នោះដើម្បីឱ្យក្លាយទៅជាច្បាប់ និងមានអានុភាពគតិយុត្ត។

៤. ការប្រកាសឱ្យប្រើ និងការអនុវត្ត សំដៅដល់នីតិវិធីការផ្តល់សច្ចាប័នទៅលើច្បាប់តាមរយៈព្រះរាជក្រមប្រកាសឱ្យប្រើច្បាប់ និងការចូលជាធរមានសម្រាប់ការអនុវត្តច្បាប់។ ការចូលជាធរមានត្រូវបានឃើញនៅក្នុងល័ក្ខខ័ណ្ឌ ៣យ៉ាង (១). ករណីច្បាប់ប្រញ៉ាប់ (២). ករណីច្បាប់មិនប្រញ៉ាប់ និង(៣). ល័ក្ខខ័ណ្ឌបង្កង់នៅក្នុងបទប្បញ្ញត្តិច្បាប់ជាធរមាននោះ ឧទាហរណ៍៖ ករណីក្រមព្រហ្មទណ្ឌ។ នៅក្នុងដំណាក់កាលនេះ ក៏ចាំបាច់ឱ្យមាននូវយន្តការគ្រប់គ្រង និងវាយតម្លៃ (Monitoring and Evaluation)។

នៅក្នុងចរិតលក្ខណៈសារជាតុ ការកសាងបទដ្ឋានគតិយុត្តមួយ ដើម្បីឆ្ពោះទៅរកប្រព័ន្ធ និងវប្បធម៌នីតិរដ្ឋត្រូវគិតគូរទៅលើលក្ខខណ្ឌដូចតទៅ៖

---

២២២ សូមមើលត្រង់កថាខណ្ឌទី២ មាត្រា១៩ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី មាត្រា២៨ ថ្មី មាត្រា ៩៣ ថ្មី នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។

១. មូលដ្ឋាននៃការកសាងបទដ្ឋានគតិយុត្ត ដោយត្រូវធ្វើការពិនិត្យឡើងវិញនូវច្បាប់ជាធរមានដែលមានស្រាប់ អំពីគុណភាព ប្រសិទ្ធភាព អនុលោមភាពរបស់ច្បាប់ ត្រូវធ្វើសោធនកម្ម បន្តអនុវត្ត ឬដាក់ឱ្យនិរាករណ៍ ធ្វើការកាត់បន្ថយចំនួនច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

២. ការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ត្រូវគិតគូរអំពីគុណភាព ប្រសិទ្ធភាព ផលប៉ះពាល់ នៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលនឹងត្រូវដាក់ចុះ ស្របទៅតាមទិសដៅកែទម្រង់ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល ជាពិសេសការអភិវឌ្ឍសង្គម សេដ្ឋកិច្ច ដែលជាទិសដៅនៅក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ នៃរាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ការបង្ករ បរិយាកាសវិនិយោគងាយស្រួល និងប្រកបដោយបរិយាបន្ន សម្រាប់វិនិយោគក្នុងស្រុក និងបរទេស។

៣. ការកំណត់នូវសម្រង់សម្រាប់ការតាក់តែងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត សម្រាប់ពេលបច្ចុប្បន្ន រាជរដ្ឋាភិបាលកំពុងអនុវត្តអនុក្រឹត្យ លេខ ១៧០ អនក្រ.បក ស្តីពី" ការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីនិងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត" ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៤ របស់រាជរដ្ឋាភិបាល នៅក្នុងកិច្ចការនីតិកម្ម។

៤. ការកំណត់នូវលក្ខខណ្ឌសារជាតុ នៃការតាក់តែងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត តាមរយៈការរៀបចំឱ្យមាននូវ «**មគ្គុទេសក៍សិល្បសាស្ត្រនីតិកម្ម**» ដែលត្រូវគិតគូរទៅលើគុណតម្លៃខ្មែរនៅក្នុងអត្ថបទគតិយុត្ត ការធានានូវនីត្យានុកូលភាព និងអនុលោមភាព ការពិនិត្យានុភាវូបនីយកម្មនៃអត្ថបទគតិយុត្ត ជាដើម។

៥. ការរៀបចំឱ្យមានឧបករណ៍គតិយុត្ត មានព័ត៌មានវិទ្យានីតិកម្ម ការពិនិត្យគុណភាព ប្រសិទ្ធភាព នៃការតាក់តែង គុណភាព ប្រសិទ្ធភាព នៃការអនុវត្ត និងការវាយតម្លៃទៅលើការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។




### ១.៨.៥ លក្ខខណ្ឌនៃការកសាងបទដ្ឋានគតិយុត្ត

នៅក្នុងចរិតលក្ខណៈសារជាតុ ការកសាងបទដ្ឋានគតិយុត្តមួយ ដើម្បីឆ្ពោះទៅរកប្រព័ន្ធ និងវប្បធម៌នីតិរដ្ឋត្រូវគិតគូរទៅលើលក្ខខណ្ឌដូចតទៅ៖

១) មូលដ្ឋាននៃការកសាងបទដ្ឋានគតិយុត្ត ដោយត្រូវធ្វើការពិនិត្យឡើងវិញនូវច្បាប់ជាធរមានដែលមានស្រាប់ អំពីគុណភាព ប្រសិទ្ធភាព អនុលោមភាពរបស់ច្បាប់ ត្រូវធ្វើវិសោធនកម្ម បន្តអនុវត្ត ឬដាក់ឱ្យនិរាករណ៍ ធ្វើការកាត់បន្ថយចំនួនច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

២) ការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ត្រូវគិតគូរអំពីគុណភាព ប្រសិទ្ធភាព ផលប៉ះពាល់ នៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលនឹងត្រូវដាក់ចុះ ស្របទៅតាមទិសដៅកែទម្រង់ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល ជាពិសេសការអភិវឌ្ឍសង្គម សេដ្ឋកិច្ច ដែលជាទិសដៅ

នៅក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ នៃរាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ការបង្កបរិយាកាសវិនិយោគងាយស្រួល និងប្រកបដោយបរិយាបន្ន សម្រាប់វិនិយោគក្នុងស្រុក និងបរទេស។

៣) ការកំណត់នូវទម្រង់សម្រាប់ការតាក់តែងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត នាពេលបច្ចុប្បន្ន រាជរដ្ឋាភិបាលកំពុងអនុវត្តអនុក្រឹត្យ លេខ១៧០ អនក្រ.បក ស្តីពី"ការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីនិងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត" ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៤ របស់រាជរដ្ឋាភិបាល នៅក្នុងកិច្ចការនីតិកម្ម។

៤) ការកំណត់នូវល័ក្ខខ័ណ្ឌសារជាតុ នៃការតាក់តែងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត តាមរយៈការរៀបចំឱ្យមាននូវ «**មគ្គុទេសក៍សិល្បៈសាស្ត្រនីតិកម្ម**» ដែលត្រូវគិតគូរទៅលើគុណតម្លៃខ្មែរនៅក្នុងអត្ថបទគតិយុត្ត ការធានានូវនីត្យានុកូលភាព និងអនុលោមភាព ការពិនិត្យានុភាវូបនីយកម្មនៃអត្ថបទគតិយុត្ត ជាដើម។

៥) ការរៀបចំឱ្យមានឧបករណ៍គតិយុត្ត មានព័ត៌មានវិទ្យានីតិកម្ម ការពិនិត្យគុណភាព ប្រសិទ្ធភាព នៃការតាក់តែង គុណភាព ប្រសិទ្ធភាព នៃការអនុវត្ត និងការវាយតម្លៃទៅលើការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ១.៩. ការអនុវត្តច្បាប់ និងទណ្ឌកម្ម

បើសិនសមាជិកទាំងអស់នៃសង្គមស្គាល់ និងគោរពតាមច្បាប់ ពួកគេអាចការពារជីវិត និងទ្រព្យសម្បត្តិរបស់ពួកគេទៅវិញទៅមកបានដោយសុវត្ថិភាព។ ប៉ុន្តែ ទោះបីបើមានច្បាប់ក៏ដោយ តើវាមានប្រយោជន៍អ្វី បើគ្មាននរណាអនុវត្តច្បាប់ និងគោរពតាមច្បាប់? ដូច្នេះ តម្លៃនៃច្បាប់ និងអត្ថប្រយោជន៍នៃច្បាប់ គឺស្ថិតនៅលើការអនុវត្តច្បាប់ និងការគោរពច្បាប់។ «ប្រជាជនសន្តិភាពម្នាក់» គឺជាបុគ្គលមួយរូបដែលគោរពតាមច្បាប់យ៉ាងសកម្ម ដោយផ្អែកលើស្មារតីគោរពច្បាប់។ ស្មារតីនៃការគោរពច្បាប់ គឺជាកត្តាសំខាន់សម្រាប់ប្រជាជននៃពូជសាសន៍ ពណ៌សម្បុរ សាសនាផ្សេងៗគ្នា អាចរស់នៅសុខដុមរមនាជាមួយគ្នាបាន។ ដើម្បីឱ្យរដ្ឋ និងសង្គមអាចសម្រេចបាននូវការអភិវឌ្ឍប្រកបដោយចីរភាព ក្នុងបរិបទនៃសកលភាវូបនីយកម្មនៅសតវត្សទី២១ ការបណ្តុះស្មារតីឱ្យប្រជាពលរដ្ឋគោរពច្បាប់ គឺជាកិច្ចការសំខាន់ និងបន្ទាន់។[223] នៅក្នុងអត្ថបទនេះនឹងសិក្សាទៅលើគោលគំនិតនៃការអនុត្តច្បាប់ និងការដាក់ទណ្ឌកម្ម ថាតើការអនុវត្តច្បាប់ និងទណ្ឌកម្មវាមានទំនាក់ទំនងគ្នាយ៉ាងជិតស្និតដូចម្តេចខ្លះ?

### ១.៩.១ ការអនុវត្តចច្បាប់

ប្រសិទ្ធភាពនៃប្រព័ន្ធច្បាប់ណាមួយ មិនអាស្រ័យតែទៅលើការបង្កើតច្បាប់ប៉ុណ្ណោះទេ ប៉ុន្តែអាស្រ័យយ៉ាងខ្លាំងលើភាពជោគជ័យនៃការអនុវត្តច្បាប់ក្នុងសង្គមផងដែរ។ ការអនុវត្តច្បាប់ សំដៅទៅលើដំណើរការដែលធ្វើឱ្យបទប្បញ្ញត្តិច្បាប់ក្លាយទៅជាការអនុវត្តជាក់ស្តែងក្នុងអាកប្បកិរិយារបស់សង្គម ដែលតម្រូវឱ្យមានទាំងការអនុវត្តដោយស្ថាប័នរដ្ឋ និងការគោរពដោយស្ម័គ្រចិត្តពីប្រជាពលរដ្ឋ។ ដូចដែលអ្នកច្បាប់វិទូបានលើកឡើងថា នីតិរដ្ឋមិនអាចរក្សាបានឡើយ ប្រសិនបើច្បាប់មានតែស្ថិតនៅលើក្រដាស ហើយមិនត្រូវបានគោរពក្នុងជីវិតប្រចាំថ្ងៃ។ ដើម្បីឱ្យប្រព័ន្ធច្បាប់ដំណើរការបាន ប្រជាពលរដ្ឋត្រូវតែគោរពច្បាប់គ្រប់ពេលវេលា។[224] នេះបង្ហាញថា ការអនុវត្តច្បាប់មិនមែនជាបញ្ហាផ្នែកច្បាប់ ឬរដ្ឋបាលប៉ុណ្ណោះទេ ប៉ុន្តែជាបញ្ហាសង្គម និងចិត្តសាស្ត្រផងដែរ។

ជាតុសំខាន់មួយក្នុងការអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាព គឺនីត្យានុកូលភាពនៃច្បាប់ (legitimacy) នៃអាជ្ញាធរ និងការជឿទុកចិត្តរបស់សាធារណជនលើស្ថាប័នច្បាប់។ នៅពេលប្រជាពលរដ្ឋជឿថា ច្បាប់ត្រូវបានបង្កើត និងអនុវត្តដោយយុត្តិធម៌ ពួកគេនឹងទទួលយក និងគោរពបទប្បញ្ញត្តិច្បាប់ដោយស្ម័គ្រ

---

២២៣ Chapter ១១. Law-Abiding Spirit and DPCW, Section ២. Law-Abiding Spirit.

២២៤ Tom R Tyler and John M Darley, 'Building a Law-Abiding Society: Taking Public Views about Morality and the Legitimacy of Legal Authorities into Account When Formulating Substantive Law' (២០០០) ២៨ *Hofstra Law Review*

ចិត្ត។[225] គំរូនៃការគ្រប់គ្រងសង្គមដែលផ្អែកលើភាពជឿទុកចិត្ត និងភាពស្របច្បាប់ បញ្ជាក់ថា នីតិវិធីយុត្តិធម៌ (procedural justice) ឬរបៀបដែលច្បាប់ត្រូវបានអនុវត្ត មានតួនាទីសំខាន់ណាស់ក្នុងការបង្កើតអាកប្បកិរិយាក្នុងការគោរពច្បាប់។[226] នៅពេលដំណើរការច្បាប់ត្រូវបានយល់ថាមានភាពត្រឹមត្រូវ និងអព្យាក្រឹត កំណើននៃការគោរពច្បាប់នឹងកើនឡើង ទោះបីលទ្ធផលចុងក្រោយមិនផ្ដល់ប្រយោជន៍ដល់បុគ្គលក៏ដោយ។

ការអប់រំក៏មានតួនាទីសំខាន់ក្នុងការភ្ជាប់ចន្លោះរវាងច្បាប់ និងការអនុវត្តក្នុងសង្គមផងដែរ។ ជាពិសេស ស្ថាប័នអប់រំមធ្យមសិក្សា និងឧត្តមសិក្សា ជាទីកន្លែងសម្រាប់ការបង្កើតស្មារតីគោរពច្បាប់ ដែលពួកគេអាចអភិវឌ្ឍការយល់ដឹងអំពីច្បាប់ ការគិតអំពីសីលធម៌ និងការគោរពគោលការណ៍នីតិរដ្ឋ។[227] តាមរយៈការអប់រំផ្អែកច្បាប់ និងការបណ្ដុះតម្លៃសង្គម ការអប់រំជួយឱ្យបទប្បញ្ញត្តិច្បាប់ត្រូវបានទទួលយកនៅក្នុងចិត្ត និងអាកប្បកិរិយារបស់មនុស្ស លើសពីការអនុវត្តដោយការបង្ខំ។ ប្រសិនបើខ្វះការទទួលយកផ្នែកនេះ ប្រព័ន្ធច្បាប់នឹងបន្តប្រឈមមុខនឹងការមិនគោរព ទោះបីមានច្បាប់ និងបទប្បញ្ញត្តិច្រើនក៏ដោយ។

ដូចនេះ ការអនុវត្តច្បាប់គួរត្រូវបានយល់ថាជាដំណើរការចម្រុះ ដែលរួមបញ្ចូលទាំងការអនុវត្តដោយអំណាចរដ្ឋ នីត្យានុកូលភាពនៃច្បាប់ ការជឿទុកចិត្ត និងការអប់រំ និងបណ្ដុះបណ្ដាលផ្នែកច្បាប់។ វិធីសាស្ត្រដែលបញ្ចូលទាំងសមត្ថភាពស្ថាប័ន និងតម្លៃសង្គម គឺជាចំណុចសំខាន់ក្នុងការបម្លែងច្បាប់ពីអត្ថបទលើក្រដាស ទៅជាការអនុវត្តជាក់ស្ដែងក្នុងសង្គម។ ទស្សនៈនេះមានសារៈសំខាន់ជាពិសេសសម្រាប់ប្រទេសកំពុងអភិវឌ្ឍ និងប្រទេសកំពុងកំណត់ប្រព័ន្ធច្បាប់ ដែលបញ្ហាមិនមែនជាកង្វះច្បាប់ទេ ប៉ុន្តែជាការធានាឱ្យច្បាប់ត្រូវបានអនុវត្តពេញលេញ និងគោរពយ៉ាងមានប្រសិទ្ធភាព។ មួយវិញទៀត ការអនុវត្តច្បាប់ដំណើរការពីរកម្រិតដែលមានទាក់ទងគ្នា គឺ**កម្រិតស្ថាប័ន** និង**កម្រិតសង្គម**។

- នៅកម្រិតស្ថាប័ន គឺសំដៅដល់ការអនុវត្តច្បាប់មានប្រសិទ្ធភាព ត្រូវការច្បាប់ច្បាស់លាស់ ស្ថាប័នអនុវត្តមានសមត្ថភាព និងទណ្ឌកម្មដែលមានភាពសមស្រប។

[២២៥] Tom R Tyler, 'Trust and Law Abidingness: A Proactive Model of Social Regulation' (២០០១) ៨១ *Boston University Law Review*

[២២៦] Ibid.

[២២៧] Yan Dong and Sadaf Zeb, 'Role of Higher Education System in Promoting Law-Abiding Behavior among Students' (២០២២) ១៣ *Frontiers in Psychology*

- កម្រិតសង្គម គឺសំដៅដល់ការអនុវត្តច្បាប់អាស្រ័យលើការអប់រំ បទដ្ឋានសង្គម និងតម្លៃស៊ីវិល ដែលជំរុញឱ្យបុគ្គលទទួលយកកាតព្វកិច្ចតាមច្បាប់ ជាផ្នែកមួយនៃភាពជាពលរដ្ឋដែលមានការទទួលខុសត្រូវ។[228]

### ១.៩.២ ការដាក់ទណ្ឌកម្ម

ទណ្ឌកម្ម ត្រូវបានចាត់ទុកថាជាយន្តការសម្រាប់រក្សាសណ្ដាប់ធ្នាប់សង្គម ការទប់ស្កាត់អំពើល្មើស និងសម្រេចបាននូវយុត្តិធម៌។ នៅក្នុងស្នាដៃដ៏សំខាន់របស់ លោក Cesare Beccaria គឺ *On Crimes and Punishments* ទណ្ឌកម្មត្រូវបានចាត់ទុកជាឧបករណ៍សមហេតុផលដែលត្រូវបានបង្កើតឡើងដើម្បីការពារឧក្រិដ្ឋកម្មតាមរយៈភាពប្រាកដនិយម និងសមាមាត្រ។ លោក Beccaria ក៏បានអះអាងបន្តទៀតថា ទណ្ឌកម្មដែលខ្លាំងពេក ឬការដាក់ទណ្ឌកម្មតាមទំនើងចិត្ត នឹងធ្វើឱ្យបាត់បង់ប្រសិទ្ធភាពរបស់វា ដោយលោកបាននិយាយថា "ភាពពិតប្រាកដនៃទណ្ឌកម្ម ទោះបីជាកម្រិតមធ្យមក៏ដោយ នឹងបង្កើតការប៉ះពាល់ខ្លាំងជាងភាពភ័យខ្លាចនៃទោស ប៉ុន្តែរួមបញ្ចូលជាមួយនឹងក្ដីសង្ឃឹមនៃការរួចផុតពីទោស"។[229]

នៅកម្ពុជា ទណ្ឌកម្មមានតួនាទីសំខាន់ក្នុងការថែរក្សាសណ្ដាប់ធ្នាប់សាធារណៈ និងស្ថិរភាពសង្គម ជាពិសេសនៅក្នុងសង្គមក្រោយពេលមានវិវាទ។ ក្រមព្រហ្មទណ្ឌកម្ពុជាបានកំណត់ទោសជាច្រើនប្រភេទ រួមមានទោសដាក់ពន្ធនាគារ ពិន័យជាប្រាក់ និងទោសបន្ថែមផ្សេងៗទៀត ដែលមានគោលបំណងចម្បងក្នុងការបង្ការ ទប់ស្កាត់ និងការការពារសង្គម។ ទោះជាយ៉ាងណា បញ្ហាប្រឈមដូចជា ការកង្វះខាតកម្មវិធីកែប្រែ និងការទាមទាររបស់សាធារណៈជនឱ្យមានទោសធ្ងន់ធ្ងរជាងមុន តម្រូវឱ្យមានការពិនិត្យឱ្យបានស៊ីជម្រៅអំពីការដាក់ទណ្ឌកម្ម និងគោលបំណងរបស់វា។

### ១.៩.៣ និយមន័យនៃទណ្ឌកម្ម

ជាទូទៅ ទណ្ឌកម្មត្រូវបានយល់ថាជាការដាក់បន្ទុក ឬការបង្កើតទារុណកម្ម តាមអំណាចស្របច្បាប់ ដើម្បីឆ្លើយតបទៅនឹងការបំពានច្បាប់។ លោក H.L.A. Hart បានកំណត់និយមន័យថា ការដាក់ទណ្ឌកម្មដោយរួមបញ្ចូលឱ្យមានការឈឺចាប់ ឬផលវិបាកផ្សេងៗទៀត ដែលត្រូវបានអនុវត្តដោយអំណាច និងបង្កើតឡើងតាមប្រព័ន្ធច្បាប់ ទៅលើជនល្មើសដែលបានបំពានច្បាប់។[230] មួយវិញទៀត ពីទស្សនៈឧក្រិដ្ឋវិទ្យា (Criminology) ការដាក់ទណ្ឌកម្មក៏បម្រើដល់គោលបំណងសង្គមផងដែរ ដូចជាការបង្ការរារាំង

---

[២២៨] OECD, *Building a Law-Abiding Society: Role of Institutions and Education* (OECD Publishing ២០១៩).

[២២៩] Cesare Beccaria, *On Crimes and Punishments* (១៧៦៤), pp. ៤៥.

[២៣០] H.L.A Hart, *Punishment and Responsibility* (2nd edn, OUP ២០០៨).

(deterrence) ការកម្រិតសមត្ថភាព (incapacitation) ការស្តារនីតិសម្បទា (rehabilitation) និងការបង្ហាញពីការថ្កោលទោសរបស់សង្គម។[231] ដូច្នេះ ការដាក់ទណ្ឌកម្មមានមុខងារជាយន្តការបង្ខិតបង្ខំនៅក្នុងប្រព័ន្ធច្បាប់។

### ១.៩.៤ ប្រភេទនៃទណ្ឌកម្ម

#### ១.៩.៤.១ ទណ្ឌកម្មរដ្ឋបាល

ទណ្ឌកម្មរដ្ឋបាល គឺជាវិធានការដែលត្រូវបានដាក់ចេញដោយអាជ្ញាធររដ្ឋបាល ដើម្បីឆ្លើយតបទៅនឹងការបំពានលើបទបញ្ជា ឬនីតិរដ្ឋបាល។ គោលបំណងចម្បងរបស់វា មិនមែនជាការដាក់ទណ្ឌកម្មក្នុងន័យសីលធម៌ឡើយ ប៉ុន្តែគឺដើម្បីការពារសណ្តាប់ធ្នាប់សាធារណៈ និងការប្រព្រឹត្តទៅបានល្អនៃរដ្ឋបាលសាធារណៈ។

លោក François Terré បានសង្កត់ធ្ងន់ថា ទណ្ឌកម្មរដ្ឋបាលមានលក្ខណៈសម្គាល់ដូចជា៖

- មានលក្ខណៈបង្ការ និងជាបទប្បញ្ញត្តិ
- មិនមែនជាផ្នែកនៃនីតិវិធីក្នុងតុលាការព្រហ្មទណ្ឌ
- ត្រូវបានដាក់ចេញដោយអង្គភាពរដ្ឋបាល ជាជាងតុលាការ

- ទណ្ឌកម្មរដ្ឋបាលទូទៅ រួមមាន៖

- ការផាកពិន័យដែលដាក់ដោយអាជ្ញាធរមានសមត្ថកិច្ច
- ការដកហូត ឬការព្យួរអាជ្ញាប័ណ្ណ
- ការបិទគ្រឹះស្ថាន
- វិធានការវិន័យលើមន្ត្រីរាជការ[232]

លោក Terré បានកត់សម្គាល់ថា ទោះបីជាទណ្ឌកម្មរដ្ឋបាលអាចមានសភាពធ្ងន់ធ្ងរក៏ដោយ ក៏វាមានលក្ខណៈខុសប្លែកពីទណ្ឌកម្មព្រហ្មទណ្ឌដែរ ព្រោះវាមិនមែនជាការសម្រេចសេចក្តីលើពិរុទ្ធឡើយ។ ទោះជាយ៉ាងណាក៏ដោយ ការវិវត្តនៃច្បាប់ទំនើបបានធ្វើឱ្យភាពខុសគ្នានេះកាន់តែរួមតូច ជាពិសេសនៅ

---

២៣១ David Garland, *Punishment and Modern Society* ( OUP ១៩៩០ )/.

២៣២ François Terré, Les Sanctions Administratives, Introduction générale au droit. ( ១៩៩៤ )

ពេលដែលទណ្ឌកម្មរដ្ឋបាលមានលក្ខណៈស្រដៀងនឹងទណ្ឌកម្មផ្នែកព្រហ្មទណ្ឌ។ កត្តានេះបាននាំឱ្យមានការបង្កើននូវតម្រូវការផ្នែកនីត្យានុកូលភាព សមាមាត្រ និងការធានានីតិវិធី ដែលរងឥទ្ធិពលពីគោលការណ៍រដ្ឋធម្មនុញ្ញ និងសិទ្ធិមនុស្ស។[233]

### ១.៩.៤.២ ទណ្ឌកម្មព្រហ្មទណ្ឌ

ទណ្ឌកម្មព្រហ្មទណ្ឌ ត្រូវបានដាក់ចេញដោយតុលាការព្រហ្មទណ្ឌ បន្ទាប់ពីការប្រព្រឹត្តបទល្មើសដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ។ លោក Terré បានបញ្ជាក់ថាទណ្ឌកម្មប្រភេទនេះ មានទម្រង់ធ្ងន់ធ្ងរជាងគេនៃទណ្ឌកម្មផ្សេងទៀត ព្រោះវាបង្ហាញដោយផ្ទាល់នូវការថ្កោលទោសផ្នែកសីលធម៌របស់សង្គមចំពោះអំពើខុសច្បាប់។

- លក្ខណៈសំខាន់ៗនៃទណ្ឌកម្មព្រហ្មទណ្ឌ រួមមាន៖
  - គោលការណ៍តឹងរឹងនៃនីត្យានុកូលភាព (*nullum crimen, nulla poena sine lege* - គ្មានបទល្មើស គ្មានទណ្ឌកម្ម បើគ្មានច្បាប់ចែង)
  - តម្រូវឱ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌ និងកំហុស
  - នីតិវិធីតុលាការដែលមានការធានាផ្នែកនីតិវិធី
- ទណ្ឌកម្មព្រហ្មទណ្ឌជាទូទៅ រួមមាន៖
  - ការដាក់ពន្ធនាគារ
  - ការផាកពិន័យ
  - ទណ្ឌកម្មបន្ថែម (ការដកសិទ្ធិ ការរឹបអូសទ្រព្យសម្បត្តិ ការកម្រិតសិទ្ធិផ្សេងៗ)[234]

  លោក Terré បានគូសបញ្ជាក់បន្ថែមថា ទណ្ឌកម្មព្រហ្មទណ្ឌមានគោលបំណងច្រើនយ៉ាង៖
  - ការរារាំង៖ ទាំងក្នុងន័យទូទៅ និងចំពោះបុគ្គល

---

២៣៣ Ibid.

២៣៤ François Terré, Les Sanctions Pénales, Introduction générale au droit. (១៩៩៤)

- ការដាក់ទណ្ឌកម្ម៖ ជាការឆ្លើយតបទៅនឹងកំហុសក្នុងសង្គម
- ការការពារសង្គម៖ តាមរយៈការដាក់ឱ្យនៅដាច់ដោយឡែកពីសង្គមចំពោះជនល្មើសដែលមានគ្រោះថ្នាក់

ដោយសារតែលក្ខណៈបង្ខិតបង្ខំ ទណ្ឌកម្មព្រហ្មទណ្ឌត្រូវបានស្ថិតក្រោមការការពារផ្នែកច្បាប់ និងការត្រួតពិនិត្យតាមរដ្ឋធម្មនុញ្ញក្នុងកម្រិតខ្ពស់បំផុត។[235]

### ១.៩.៤.៣ ទណ្ឌកម្មស៊ីវិល

ទណ្ឌកម្មស៊ីវិល កើតចេញពីការបំពានលើកាតព្វកិច្ចច្បាប់ឯកជន ជាពិសេសក្នុងនីតិកិច្ចសន្យា និងនីតិរដ្ឋប្បវេណី (Torts)។ យោងតាមលោក Terré មុខងារចម្បងរបស់វាគឺការជួសជុល (Reparation) ជាជាងការដាក់ទណ្ឌកម្ម។

- ទណ្ឌកម្មស៊ីវិលមានគោលបំណង៖
  - ស្តារច្បាប់ដែលត្រូវបានរំលោភបំពាន
  - សងជម្ងឺចិត្តដល់ជនរងគ្រោះ
  - ធានានូវការគោរពសិទ្ធិឯកជន
- ទម្រង់ទូទៅនៃទណ្ឌកម្មស៊ីវិល រួមមាន៖
  - សំណងនៃការខូចខាត (ការសងជម្ងឺចិត្តចំពោះការបាត់បង់ ឬការប៉ះពាល់)
  - មោឃភាព ឬការរំលាយកិច្ចសន្យា
  - ការបង្ខំឱ្យអនុវត្តកាតព្វកិច្ច
  - ដីកាហាមឃាត់ -ល-។[236]

## ១.៩.៥ ភាពខុសគ្នាផ្នែកគោលគំនិត និងការបំពេញឱ្យគ្នា

លោក François Terré បានបង្ហាញថា ទណ្ឌកម្មទាំងបីប្រភេទនេះ ខុសគ្នាត្រង់៖

---

២៣៥ Ibid.

២៣៦ François Terré, Les Sanctions Civiles, Introduction générale au droit. (១៩៩៤)

- សមត្ថកិច្ចៈ អង្គភាពរដ្ឋបាល, តុលាការ (ព្រហ្មទណ្ឌ និងរដ្ឋប្បវេណី)
- គោលបំណងៈ បទប្បញ្ញត្តិ, ការដាក់ទណ្ឌកម្ម, ការជួសជុល
- តក្កវិជ្ជាៈ សណ្តាប់ធ្នាប់សាធារណៈ, ការថ្កោលទោសសង្គម, យុត្តិធម៌[237]

ទោះជាយ៉ាងណាក៏ដោយ លោក Terré ក៏បានកត់សម្គាល់ផងដែរថា ក្នុងប្រព័ន្ធច្បាប់ទំនើប ទណ្ឌកម្មកាន់តែមានទំនាក់ទំនងគ្នាទៅវិញទៅមក។ អំពើតែមួយអាចនាំឱ្យមានទណ្ឌកម្មរដ្ឋបាល ព្រហ្មទណ្ឌ និងស៊ីវិលក្នុងពេលតែមួយបាន ប្រសិនបើគោលការណ៍គ្រឹះដូចជា សមាមាត្រភាព និងគោលការណ៍ non bis in idem (មិនត្រូវកាត់ទោសពីរដងលើកំហុសតែមួយ) ត្រូវបានគោរព។

### ១.៩.៦ មូលដ្ឋានទ្រឹស្តីនៃទណ្ឌកម្ម

#### ១.៩.៦.១ ទ្រឹស្តីនៃឆ្លើយតប/ការសងសឹក

ទ្រឹស្តីនៃឆ្លើយតប/សងសឹកយល់ថា ទណ្ឌកម្មគឺ ត្រូវដាក់ឱ្យសមស្រប ព្រោះអ្នកល្មើសគួរត្រូវបានផ្តន្ទាទោសសម្រាប់អំពើខុសរបស់ខ្លួន។ លោក Immanuel Kant បានអះអាងថា ការផ្តន្ទាទោសត្រូវតែដាក់អនុវត្តដោយសារតែមានអំពើឧក្រិដ្ឋកម្មកើតឡើង មិនមែនជាមធ្យោបាយដើម្បីសម្រេចផលប្រយោជន៍សង្គមឡើយ។[238] ក្នុងទស្សនៈនេះ ទណ្ឌកម្មជាបញ្ហានៃការទទួលខុសត្រូវសីលធម៌ និងការគោរពសេរីភាពនៃបុគ្គលជាមនុស្សដោយមានហេតុផល។

#### ១.៩.៦.២ ទ្រឹស្តីនៃការបង្ការ

ទ្រឹស្តីនៃការបង្ការ របស់លោក Jeremy Bentham បានផ្តល់យុត្តិធម៌ដល់ការផ្តន្ទាទោសដោយផ្អែកលើអត្ថប្រយោជន៍នាពេលអនាគត។ ការដាក់ទណ្ឌកម្មត្រូវបានចាត់ទុកថាស្របច្បាប់ តែបើវាអាចទប់ស្កាត់អន្តរាយធំជាងនេះ ដោយរារាំងអំពើដែលចាត់ថាជាឧក្រិដ្ឋកម្ម។ Bentham បានលើកឡើងថា ទោសមិនគួរធ្ងន់ធ្ងរពេកឡើយ ដើម្បីសម្រេចគោលបំណងបង្ការរបស់វា។

នៅកម្ពុជា ការបង្ការនៅតែជាមូលហេតុសំខាន់នៃការផ្តន្ទាទោស ជាពិសេសចំពោះអំពើឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ដូចជា ការជួញដូរគ្រឿងញៀន និងអំពើហិង្សាជាដើម។ ទោសធ្ងន់ធ្ងរតែងតែត្រូវបានការពារថាចាំបាច់ត្រូវមាន ដើម្បីជាផ្ញើសារទៅសង្គម និងដើម្បីបង្ការពីការកើតមាននូវអំពើល្មើស។ ទោះជាយ៉ាងណា

---

[២៣៧] Ibid.

[២៣៨] Immanuel Kant, *The Metaphysics of Morals* (Mary Gregor tr, CUP ១៩៩៦).

ភស្តុតាងជាក់ស្តែងបង្ហាញថា ការបង្ការតែមួយគត់អាចមិនគ្រប់គ្រាន់ ប្រសិនបើការអនុវត្តច្បាប់មិនស្មើភាពគ្នា ឬបញ្ហាសង្គមដែលបទឧក្រិដ្ឋកម្មមិនត្រូវបានដោះស្រាយ។

### ១.៩.៦.៣ ទ្រឹស្តីការពារ និងការកាត់បន្ថយសមត្ថភាព

ទ្រឹស្តីការពារផ្តោតលើការការពារសង្គម ដោយកម្រិតសមត្ថភាពជនល្មើស មិនឱ្យប្រព្រឹត្តអំពើល្មើសបន្ថែមទៀត ពោលគឺធ្វើឱ្យជនល្មើសមានការរាំងចាល។ ការដាក់ពន្ធនាគារជាយន្តការល្អបំផុតនៃការកាត់បន្ថយសមត្ថភាព។ ទោះបីវិធីសាស្ត្រនេះចាំបាច់សម្រាប់ជនល្មើសក៏ដោយ ការប្រើប្រាស់លើសកម្រិតអាចនាំឱ្យមានការកកស្ទះពន្ធនាគារ និងប៉ះពាល់ធនធានរដ្ឋ។ កម្ពុជាកំពុងប្រឈមនឹងបញ្ហាទាំងនេះ ដែលបង្ហាញពីតម្រូវការនៃទោសជំនួស។

### ១.៩.៦.៤ ទ្រឹស្តីកែប្រែ និងស្តារនីតិសម្បទា

ទ្រឹស្តីកែប្រែយល់ថា ការដាក់ទណ្ឌកម្មគួរតែជាមធ្យោបាយដើម្បីកែប្រែជនល្មើស និងបញ្ចូលពួកគេឡើងវិញទៅក្នុងសង្គម។ H.L.A. Hart បានទទួលស្គាល់ថា ការដាក់ទណ្ឌកម្មអាចបម្រើគោលបំណងច្រើន រួមទាំងការកែប្រែ ប្រសិនបើវាគោរពដល់កម្រិតច្បាប់ និងសីលធម៌។[239] ចំណែកឯ ការស្តារនីតិសម្បទាត្រូវតែស្របគ្នាជាមួយគោលការណ៍សិទ្ធិមនុស្ស និងគោលការណ៍សេចក្តីថ្លៃថ្នូររបស់មនុស្ស។

នៅកម្ពុជា ការស្តារនីតិសម្បទា នៅតែមិនទាន់អភិវឌ្ឍគ្រប់ជ្រុងជ្រោយ ដោយសារការកំណត់សមត្ថភាពស្ថាប័នមានកម្រិត។ ការពង្រីកកម្មវិធីអប់រំ វិជ្ជាជីវៈ និងចិត្តសាស្ត្រ ក្នុងប្រព័ន្ធទណ្ឌកម្ម នឹងជួយបង្កើនប្រសិទ្ធភាពនៃការផ្តន្ទាទោស និងកាត់បន្ថយអត្រាបទល្មើសឡើងវិញ។

### ១.៩.៦.៥ ការស្តារយុត្តិធម៌ឡើងវិញ

ការស្តារយុត្តិធម៌ឡើងវិញតំណាងឱ្យការផ្លាស់ប្តូរបែបទំនើបមួយ ដោយវិធីសាស្ត្រដែលផ្តោតលើការដាក់ទណ្ឌកម្ម ឬការដាក់ទណ្ឌកម្មតែប៉ុណ្ណោះ។ លោក Howard Zehr បានកំណត់និយមន័យថា ការស្តារយុត្តិធម៌ឡើងវិញ គឺជាដំណើរការមួយ ដែលមានគោលបំណងជួសជុលការខូចខាត របស់ជនរងគ្រោះ និងសហគមន៍។[240] គំរូនេះផ្តោតលើការទទួលខុសត្រូវ ការផ្សះផ្សា និងសុខដុមរមនានៃសង្គម។

---

[២៣៩] H.L.A Hart, *Punishment and Responsibility* (២nd edn, OUP ២០០៨).

[២៤០] Howard Zehr, *The Little Book of Restorative Justice* (Good Books ២០១៥).

ការអនុវត្ត នៃគោលការណ៍ស្តារយុត្តិធម៌ឡើងវិញ ស្របជាមួយតម្លៃប្រពៃណីកម្ពុជា ដែលផ្តោតលើការផ្សះផ្សា និងភាពរួបរួមរបស់សហគមន៍។ ការបញ្ចូលយន្តការការស្តារយុត្តិធម៌ឡើងវិញ ជាពិសេសសម្រាប់អំពើល្មើសតូចៗ អាចបំពេញបន្ថែមដល់ការផ្តន្ទាទោស និងពង្រឹងការជឿទុកចិត្តរបស់សាធារណៈលើប្រព័ន្ធយុត្តិធម៌។

### ១.៩.៦.៦ ទណ្ឌកម្ម និងសិទ្ធិមនុស្សនៅកម្ពុជា

ការដាក់ទណ្ឌកម្មត្រូវដំណើរការនៅក្នុងរង្វង់នៃសិទ្ធិមនុស្ស និងគោលការណ៍រដ្ឋធម្មនុញ្ញ។ ច្បាប់ស្តីពីសិទ្ធិមនុស្សអន្តរជាតិបានហាមឃាត់ការដាក់ទណ្ឌកម្មឃោរឃៅ អមនុស្សធម៌ ឬប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរ និងទាមទារឱ្យគោរពតាមនីតិវិធីឱ្យបានត្រឹមត្រូវ។ កម្ពុជាជារដ្ឋភាគីនៃសន្ធិសញ្ញាស្តីពីសិទ្ធិមនុស្សសំខាន់ៗ នាំឱ្យកម្ពុជាមានកាតព្វកិច្ចធានាថា ការដាក់ទណ្ឌកម្ម ឬការទណ្ឌកម្មមានភាពស្របច្បាប់ សមាមាត្រ និងមនុស្សធម៌។

នៅក្នុងការអនុវត្ត នៅតែមានបញ្ហាប្រឈម រួមមានលក្ខខណ្ឌពន្ធនាគារ និងការចូលដំណើរការទៅកាន់សិទ្ធិទទួលបានការជំនុំជម្រះយុត្តិធម៌។ ការដោះស្រាយបញ្ហាទាំងនេះមានសារៈសំខាន់ ដើម្បីរក្សាបាននូវភាពស្របច្បាប់នៃការដាក់ទណ្ឌកម្ម និងភាពជឿជាក់លើប្រព័ន្ធច្បាប់។

ការទណ្ឌកម្មនៅតែជាផ្នែកមិនអាចខ្វះបាននៅក្នុងការអនុវត្តច្បាប់ ដែលបង្ហាញពីអំណាចរដ្ឋ និងការឆ្លើយតបសីលធម៌របស់សង្គមចំពោះអំពើខុសច្បាប់។ នៅកម្ពុជា ទណ្ឌកម្មបានបម្រើមុខងារបង្ការ និងការសងសឹកជាចម្បង ប៉ុន្តែការផ្លាស់ប្តូរផ្នែកច្បាប់ និងសង្គមកំពុងទាមទារឱ្យមានវិធីសាស្ត្រដែលទូលំទូលាយជាងនេះ។ ដោយដាក់គោលការណ៍សមាមាត្រ ការកែប្រែ និងការស្តារយុត្តិធម៌ឡើងវិញ ដែលជាមូលដ្ឋាននាំឱ្យកម្ពុជាអាចបង្កើនប្រសិទ្ធភាពនៃការអនុវត្តច្បាប់ យុត្តិធម៌ និងភាពស្របច្បាប់នៃប្រព័ន្ធច្បាប់របស់ខ្លួន។

### ១.៩.៧ ទំនាក់ទំនងផ្នែកគោលគំនិតរវាងការអនុវត្តច្បាប់ និងទណ្ឌកម្ម

ការអនុវត្តច្បាប់ និងការដាក់ទណ្ឌកម្ម មិនមែនជាមុខងារដាច់ដោយឡែកពីគ្នានៅក្នុងប្រព័ន្ធច្បាប់នោះទេ ប៉ុន្តែវាគឺជាយន្តការដែលពឹងផ្អែកគ្នាទៅវិញទៅមក។ ការអនុវត្តច្បាប់ផ្តល់នូវប្រសិទ្ធភាពដល់បទដ្ឋានគតិយុត្ត រីឯទណ្ឌកម្មដើរតួជាឧបករណ៍បង្ខំ ដើម្បីធានានូវការអនុវត្តច្បាប់ នៅពេលដែលគ្មានការគោរពច្បាប់ដោយស្ម័គ្រចិត្ត។ បើគ្មានការអនុវត្តប្រកបដោយប្រសិទ្ធភាព ទណ្ឌកម្មនឹងភាពនៃការជឿទុកចិត្តបាន ហើយបើគ្មានទណ្ឌកម្ម ការអនុវត្តច្បាប់ក៏នឹងមានកង្វះខាតអំណាចបង្ខិតបង្ខំដែរ។

តាមទស្សនៈឧក្រិដ្ឋវិទ្យា ទណ្ឌកម្មតំណាងឱ្យ Coercive Dimension នៃការអនុវត្តច្បាប់។ ដូចដែលលោក Hart បានពន្យល់ថា ប្រព័ន្ធច្បាប់មួយទាមទារឱ្យមានវិធានបន្ទាប់បន្សំ និងទណ្ឌកម្ម ដើម្បីបែងចែកកាតព្វកិច្ចតាមផ្លូវច្បាប់ ចេញពីការរំពឹងទុកផ្នែកសីលធម៌សុទ្ធ។[241] ក្នុងន័យនេះ ទណ្ឌកម្មមានមុខងារជាដំណាក់កាលចុងក្រោយនៃការអនុវត្ត ដែលបំប្លែងបទដ្ឋានអរូបីឱ្យទៅជាតថភាពសង្គមដែលអាចបង្ខំឱ្យអនុវត្តបាន។

ក្នុងបរិបទនៃប្រទេសកម្ពុជា ទំនាក់ទំនងនេះមានសារៈសំខាន់ជាពិសេស ដោយសារបញ្ហាប្រឈមចម្បង មិនមែនមកពីការខ្វះខាតវិធានច្បាប់នោះទេ ប៉ុន្តែគឺគម្លាតរវាងច្បាប់ដែលបានចែង និងការអនុវត្តជាក់ស្តែង។ នៅពេលដែលការអនុវត្តច្បាប់មានភាពមិនស៊ីសង្វាក់គ្នា ឬមានលក្ខណៈរើសអើង ការដាក់ទណ្ឌកម្មនឹងប្រឈមនឹងការមើលឃើញថាជាអំពើអត្តនោម័ត ដែលនាំឱ្យចុះខ្សោយនូវទំនុកចិត្តពីសាធារណៈ និងការគោរពច្បាប់ដោយស្ម័គ្រចិត្ត។

---

២៤១ HLA Hart, *The Concept of Law* (៣rd edn, OUP ២០១២).

## ១.១០. ការអប់រំ និងបណ្តុះបណ្តាល

ការអប់រំ និងបណ្តុះបណ្តាលច្បាប់ គឺជាមូលដ្ឋានសំខាន់មួយក្នុងការកសាងវប្បធម៌គោរពច្បាប់នៅក្នុងសង្គម។ ដូចគ្នានេះដែរ នៅក្នុងទស្សនវិជ្ជារបស់លោក H.L.A Hart បានបញ្ជាក់ថា ច្បាប់មិនអាចមានប្រសិទ្ធភាពដោយសារតែអំណាចរដ្ឋតែប៉ុណ្ណោះទេ ប៉ុន្តែអាស្រ័យលើកម្រិតនៃការយល់ដឹង ការទទួលស្គាល់ និងការចូលរួមរបស់ប្រជាពលរដ្ឋផងដែរ។ [242] នៅក្នុងបរិបទប្រទេសកម្ពុជា ដែលកំពុងឆ្លងកាត់ដំណាក់កាលអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម និងស្ថាប័ន ការផ្សព្វផ្សាយចំណេះដឹងផ្នែកច្បាប់តាមរយៈការអប់រំ និងបណ្តុះបណ្តាលទៅកាន់ប្រជាពលរដ្ឋគ្រប់កម្រិត មានសារៈសំខាន់យ៉ាងខ្លាំងក្នុងការធានាប្រសិទ្ធភាពនៃការអនុវត្តច្បាប់ ការការពារសិទ្ធិមនុស្ស និងការកាត់បន្ថយវិវាទក្នុងសង្គម។

### ១.១០.១ គោលគំនិតនៃការអប់រំ និងបណ្តុះបណ្តាល

តាមទស្សនវិជ្ជានីតិរដ្ឋរបស់លោក Tom Bingham បានលើកឡើងថា មូលដ្ឋានសំខាន់នៃនីតិរដ្ឋ គឺការដែលប្រជាពលរដ្ឋអាចយល់ដឹង និងព្យាករបានអំពីច្បាប់ដែលគ្រប់គ្រងជីវិតរបស់ខ្លួន។ ច្បាប់ដែលមិនត្រូវបានយល់ដឹងដោយសាធារណៈ គឺជាច្បាប់ដែលខ្វះភាពស្របច្បាប់ (legitimacy) ក្នុងសង្គម។ [243] ដូច្នេះ ការអប់រំច្បាប់គឺជាលក្ខខណ្ឌចាំបាច់មួយនៃនីតិរដ្ឋ និងវប្បធម៌គោរពច្បាប់ មិនមែនត្រឹមតែជាកត្តាជំនួយបន្ថែមទេ។

ក្នុងទ្រឹស្តីយុត្តិធម៌ John Rawls បានបញ្ជាក់ថា ប្រព័ន្ធច្បាប់ និងស្ថាប័នសង្គម ត្រូវផ្អែកលើការយល់ព្រមដោយមានហេតុផល (reasoned acceptance) របស់សមាជិកសង្គម។[244] ការយល់ព្រមបែបនេះ មិនអាចកើតមានបាន ប្រសិនបើប្រជាពលរដ្ឋខ្វះចំណេះដឹងមូលដ្ឋានអំពីសិទ្ធិ កាតព្វកិច្ច និងច្បាប់។ ទស្សនវិជ្ជានេះបង្ហាញថា ការអប់រំ និងបណ្តុះបណ្តាលច្បាប់ គឺជាឧបករណ៍នៃយុត្តិធម៌សង្គម។ ដូចនេះ ការអប់រំ និងបណ្តុះបណ្តាលច្បាប់ជាផ្នែកមួយដ៏សំខាន់ក្នុងការបណ្តុះវប្បធម៌គោរពច្បាប់ និងបង្កើនប្រសិទ្ធភាពនៃការអនុវត្តច្បាប់។ ការអប់រំក្នុងន័យនេះសំដៅលើ ការអប់រំផ្នែកនីតិសាស្ត្រនៅក្នុងកម្រិតមធ្យមសិក្សាទុតិយភូមិ រហូតដល់ឧត្តមសិក្សា។ ចំណែកឯការបណ្តុះបណ្តាលសំដៅលើ ការបញ្ជ្រាបទៅកាន់ប្រជាជនតាមមូលដ្ឋាននូវចំណេះដឹងផ្នែកច្បាប់ដែលពាក់ព័ន្ធទៅនឹងជីវភាពប្រចាំថ្ងៃ និងច្បាប់ពិសេសទាក់ទងនឹងវិស័យនានាដែលជាសក្តានុពលនៃតំបន់ទាំងនោះ។ ក្នុងន័យនេះវប្បធម៌នៃការគោរពច្បាប់ គឺជាផ្នែកមួយយ៉ាង

---

២៤២ HLA Hart, *The Concept of Law* ( ៣rd edn, OUP ២០១២ ), pp. ២០–២៥.

២៤៣ Tom Bingham, *The Rule of Law* ( Penguin ២០១១ ), pp. ៣៥–៤១.

២៤៤ John Rawls, *A Theory of Justice* ( rev edn, Harvard University Press ១៩៩៩, pp. ១៣៦–១៤២.

សំខាន់ក្នុងការចូលរួមជួយកាត់បន្ថយភាពអសន្តិសុខនៅក្នុងសង្គម ក៏ដូចជាពង្រឹងនូវសមត្ថភាពចំណេះដឹងរបស់ប្រជាពលរដ្ឋ ជាពិសេសគឺ សិស្សានុសិស្សផងដែរ។

### ១.១០.២ ការអប់រំ

#### ១.១០.២.១ ការអប់រំនៅក្នុងកម្រិតសិក្សាមធ្យមសិក្សាទុតិយភូមិ

យោងទៅតាមកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា សញ្ញាណនៃមុខវិជ្ជានីតិសាស្ត្រត្រូវបានបញ្ចូលនៅក្នុងផ្នែកនៃមុខវិជ្ជា"សីលធម៌ ពលរដ្ឋ"ចាប់ពីថ្នាក់ទី១១ និងទី១២ យ៉ាងសន្ធឹក។ ប្រធានបទដែលបានដាក់បញ្ចូលរួមមាន៖

- សិទ្ធិនិងការទទួលខុសត្រូវ
- ច្បាប់ការងារ
- ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ
- ក្រមនីតិវិធីរដ្ឋប្បវេណី
- ក្រមនីតិវិធីព្រហ្មទណ្ឌ
- ច្បាប់ភូមិបាល
- រដ្ឋបាលសាធារណៈ
- យុត្តិធម៌ សិទ្ធិ និងច្បាប់
- ច្បាប់អន្តរជាតិ ស្តីពីសិទ្ធិមនុស្ស
- ការដោះស្រាយវិវាទ
- ច្បាប់អន្តោប្រវេស
- ច្បាប់សញ្ជាតិ
- នីតិរដ្ឋ។[245]

ការបញ្ចូលមុខវិជ្ជាច្បាប់នៅកម្រិតនេះ មានតួនាទីជាការបង្កើត legal literacy ដល់យុវជន ដើម្បីឱ្យពួកគេក្លាយជាពលរដ្ឋល្អ និងយល់ដឹងអំពីការប្រើប្រាស់ច្បាប់ ដែលជាឧបករណ៍ការពារសិទ្ធិរបស់ខ្លួន។[246] ដោយសារតែច្បាប់មានការវិវឌ្ឍជារឿយៗ ហេតុនេះហើយគ្រូបង្រៀនត្រូវតែមានការធ្វើបច្ចុប្បន្នកម្មទៅតាមកំណែទម្រង់នៃច្បាប់ទាំងនោះ ដើម្បីមានមូលដ្ឋានច្បាស់លាស់ក្នុងការបង្រៀន។ ដូចនេះ ការបណ្តុះបណ្តា

[២៤៥] សៀវភៅសីលធម៌ពលរដ្ឋថ្នាក់ទី១១ និងទី១២

[២៤៦] William Twining, *Law in Context: Enlarging a Discipline* (Oxford University Press ២០០៩), pp.៥៥–៥៨.

លគ្រូបង្រៀនក្នុងទម្រង់ជា Continuing Education ជារៀងរាល់ឆ្នាំម្តង។ កម្មវិធីនេះនឹងប្រព្រឹត្តដូចគ្នាទៅនឹង Trainer to trainer ដែលមានដូចទៅដូចតទៅ៖

- រយៈពេល៖ ១០ ទៅ២០ម៉ោងក្នុងឆ្នាំ
- មាតិកា៖
  - ច្បាប់ថ្មី និងច្បាប់ដែលទើបធ្វើវិសោធនកម្ម
  - សេចក្តីសម្រេចសំខាន់ៗរបស់ក្រុមប្រឹក្សាធម្មនុញ្ញ
  - បញ្ហាប្រឈមថ្មីៗក្នុងសង្គម
- វិធីសាស្ត្រនៃការប្រព្រឹត្តទៅ៖
  - វគ្គបណ្តុះបណ្តាល
  - បង្រៀនតាមអនឡាញ
  - ការបង្រៀនតាមវីដេអូថតទុក។

### ១.១០.២.២ ការអប់រំកម្រិតឧត្តមសិក្សា

នៅកម្រិតឧត្តមសិក្សាទ្រឹស្តីនីតិប្រៀបធៀប (Comparative Law) បានបង្ហាញពីសារៈសំខាន់នៃការប្រៀបធៀបប្រព័ន្ធច្បាប់ ដើម្បីពង្រឹងការយល់ដឹង និងការរិះគន់ប្រព័ន្ធច្បាប់ជាតិ។ លោក Michael Bogdan បានលើកឡើងថា ការអប់រំនីតិសាស្ត្រដែលខ្វះទស្សនៈប្រៀបធៀប នឹងធ្វើឱ្យនិស្សិតមានទស្សនៈចង្អៀត និងពិបាកឆ្លើយតបនឹងបញ្ហាសកល។[247] ជាក់ស្តែង នៅកម្រិតឧត្តមសិក្សា កម្ពុជាមានសាកលវិទ្យាល័យជាច្រើនដែលបង្រៀនជំនាញនីតិសាស្ត្រ។ ទោះជាយ៉ាងណា កម្មវិធីសិក្សានៅតាមស្ថាប័នទាំងនេះ នៅតែមិនទាន់មានស្តង់ដារតែមួយ និងមិនទាន់ស៊ីសង្វាក់ជាមួយស្តង់ដាសាកល។ ហេតុនេះហើយកម្មវិធីសិក្សាទាំងនោះត្រូវ៖

- ធ្វើការកែទម្រង់កម្មវិធីសិក្សាទាំងនោះឱ្យឆ្លើយតបនឹងច្បាប់ជាតិ និងអន្តរជាតិ
- បញ្ចូលមុខវិជ្ជានីតិប្រៀបធៀប (Comparative Law) និងច្បាប់អន្តរជាតិឱ្យបានច្រើន និងល្អជាងមុន
- រៀបចំកម្មវិធីសិក្សាទាំងនោះឱ្យមានភាពស៊ីសង្វាក់គ្នាទៅតាមប្រព័ន្ធអប់រំរបស់ស្តង់ដាសាកល
- កំណត់យន្តការធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សាជាប្រចាំ

### ១.១០.២.៣ ការបណ្តុះបណ្តាលក្រៅប្រព័ន្ធអប់រំ

#### ក. បណ្តុះបណ្តាលតាមមូលដ្ឋាន (ភូមិ ឃុំ សង្កាត់)

---

[២៤៧] Michael Bogdan, *Comparative Law* ( Kluwer Law International ២០១៩ ), pp.១២–១៨.

នៅទ្រឹស្តី access to justice បានបញ្ជាក់ថា ការយល់ដឹងច្បាប់ជាមូលដ្ឋាន គឺជាជំហានដំបូងនៃការចូលដំណើរការយុត្តិធម៌។[248] ម្យ៉ាងវិញទៀត ការបណ្តុះបណ្តាលច្បាប់តាមមូលដ្ឋាននៃជាយខេត្តដូចជាតាម ភូមិ ឃុំ សង្កាត់ ជាពិសេសតាមតំបន់ជនបទ ក៏ជាកត្តាមួយក្នុងការលើកកម្ពស់ច្បាប់ឱ្យមានប្រសិទ្ធខ្ពស់ ដោយសារតែដើម្បីឱ្យច្បាប់មួយមានការអនុវត្តទៅបាន តម្រូវឱ្យមានការយល់អំពីច្បាប់គ្រប់ៗគ្នា ដូចនេះហើយគប្បីត្រូវមានកម្មវិធីបណ្តុះបណ្តាលច្បាប់ ហើយកម្មវិធីទាំងនោះមានដូចជា៖

- កម្មវិធីសិក្សាចំណេះទូទៅអំពីពាក្យច្បាប់ ឬពាក្យបច្ចេកទេស
- កម្មវិធីសិក្សាដើម្បីយល់ដឹងអំពីចំណេះដឹងទូទៅផ្នែកច្បាប់
- កម្មវិធីសិក្សាអំពី សិទ្ធិ និងកាតព្វកិច្ចទូទៅរបស់ប្រជាពលរដ្ឋ
- កម្មវិធីសិក្សាការអនុវត្តច្បាប់ដែលទាក់ទងនឹងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ (ច្បាប់ដីធ្លី ច្បាប់ការងារ ច្បាប់គ្រួសារជាដើម)

សម្រាប់អ្នកដែលបង្រៀនកម្មវិធីទាំងនោះអាចជា មេធាវី អ្នកស្រាវជ្រាវច្បាប់ មេភូមិ មេឃុំ ឬចៅសង្កាត់ មន្ត្រីច្បាប់ ឬមន្ត្រីទូទៅ ជាដើម។ ចំណែកឯ ទីតាំងសិក្សាអាចជាតាមផ្ទះមេភូមិ ឬមេឃុំ ឬអាចជាសាលាឃុំ ឬសាលាសង្កាត់ សាលារៀនជាដើម។

### ខ. ការបណ្តុះបណ្តាលច្បាប់តាមរយៈប្រព័ន្ធផ្សព្វផ្សាយ

ការបង្កើតកម្មវិធីបណ្តុះបណ្តាលច្បាប់តាមរយៈប្រព័ន្ធផ្សព្វផ្សាយ គឺជាឧបករណ៍មានប្រសិទ្ធភាពមួយក្នុងការផ្សព្វផ្សាយច្បាប់ និងអប់រំច្បាប់ទៅកាន់សាធារណៈជនឱ្យកាន់តែទូលំទូលាយ។ មួយវិញទៀត ការបណ្តុះបណ្តាលច្បាប់តាមរយៈប្រព័ន្ធផ្សព្វផ្សាយ ក៏ជាកត្តាមួយដែលជម្រុញប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងអាចជួយប្រជាពលរដ្ឋមានការយល់ដឹងអំពីច្បាប់កាន់តែងាយ និងកាត់បន្ថយភាពស្មុគស្មាញនៃការយល់ដឹងច្បាប់ផងដែរ។ ដោយឡែក ក្នុងករណីនេះត្រូវបង្កើតយន្តការមួយចំនួនដូចជា៖

- ការបណ្តុះបណ្តាលតាមរយៈកម្មវិធីក្នុងប៉ុស្តិ៍ទូរទស្សន៍ (ផ្សាយផ្ទាល់ ឬផ្សាយឡើងវិញ)
- ការបណ្តុះបណ្តាលតាមរយៈកម្មវិធី វីដេអូខ្លីៗ ក្នុងបណ្តាញសង្គម និងPodcast,Facebook, Tiktok, Youtube…)
- កម្មវិធីផ្សព្វផ្សាយច្បាប់តាមរយៈវិទ្យុផ្សព្វផ្សាយ

---

[២៤៨] Mauro Cappelletti and Bryant Garth, *Access to Justice* (Vol ១, Sijthoff and Noordhoff ១៩៧៨). pp.៦–១០.

### ១.១០.២.៤ តួអង្គបណ្តុះបណ្តាល និងការពិនិត្យ និងវាយតម្លៃ

ដើម្បីឱ្យការអប់រំ និងបណ្តុះបណ្តាលច្បាប់មានប្រសិទ្ធភាពពិតប្រាកដ ការរៀបចំតែគោលនយោបាយគឺមិនទាន់គ្រប់គ្រាន់ទេ ប៉ុន្តែត្រូវមាន ការកំណត់ស្ថាប័នអនុវត្តដែលជាតួអង្គច្បាស់លាស់ និងយន្តការតាមដាន និងវាយតម្លៃ (M&E) ដែលអាចធានាបាននូវប្រសិទ្ធភាព សមត្ថភាព និងការទទួលខុសត្រូវ។ តាមទស្សនវិជ្ជាអភិបាលកិច្ចសាធារណៈ (public governance theory) ស្ថាប័នអនុវត្ត គឺជាឧបករណ៍ដែលបម្លែងទ្រឹស្តី និងគោលនយោបាយឱ្យទៅជាការអនុវត្តជាក់ស្តែង។[249] ក្នុងបរិបទកម្ពុជា ស្ថាប័នអនុវត្តការអប់រំ និងបណ្តុះបណ្តាលច្បាប់ អាចរួមមាន ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ ក្រសួងអប់រំ យុវជន និងកីឡា ដែលពាក់ព័ន្ធនឹងនីតិសាធារណៈ នីតិសិទ្ធិមនុស្ស និង access to justice។

ជាមួយគ្នានេះ យន្តការតាមដាន និងវាយតម្លៃ (M&E) មានតួនាទីសំខាន់ក្នុងការវាស់វែងថា កម្មវិធីអប់រំ និងបណ្តុះបណ្តាលច្បាប់ បានសម្រេចគោលបំណងរបស់ខ្លួន ឬអត់។ ទ្រឹស្តីមួយរបស់ ការអនុវត្តគោលនយោបាយ បានបញ្ជាក់ថា កង្វះខាតនៃយន្តការតាមដាន និងវាយតម្លៃ នឹងធ្វើឱ្យគោលនយោបាយក្លាយជាឯកសារដែលគ្មានជីវិត (paper policy)។[250]

ក្នុងករណីនេះយន្តការតាមដាន និងវាយតម្លៃគួរតែផ្តោតលើ៖

- កម្រិតនៃការយល់ដឹងច្បាប់របស់សិស្ស និងប្រជាពលរដ្ឋ
- ការប្រែប្រួលចំពោះការគោរពច្បាប់
- ការកាត់បន្ថយវិវាទ និងការប្រើប្រាស់យន្តការដោះស្រាយវិវាទដោយសន្តិវិធី
- កម្រិតនៃការចូលដំណើរការយុត្តិធម៌ (access to justice)

តាមទស្សនវិជ្ជាវប្បធម៌នីតិរដ្ឋ (rule of law) និង access to justice អាចសន្និដ្ឋានបានថាយន្តការតាមដាន និងវាយតម្លៃ មិនមែនជាការវាស់វែងបច្ចេកទេសតែប៉ុណ្ណោះទេ ប៉ុន្តែជាឧបករណ៍ធានាថា ច្បាប់ និងការអប់រំច្បាប់ កំពុងបម្រើប្រជាពលរដ្ឋយ៉ាងពិតប្រាកដ។[251] ដូច្នេះ ការបង្កើតយន្តការតាមដាន និង

---

[២៤៩] Mark Bevir, *Governance: A Very Short Introduction* (OUP ២០១២), pp. ២៨–៣៣.

[២៥០] Michael Hill and Peter Hupe, *Implementing Public Policy* (៣rd edn, SAGE ២០១៤), pp. ៤៨–៥៥.

[២៥១] Tom Bingham, *The Rule of Law* (Penguin ២០១១), pp. ៦៦–៦៩, Mauro Cappelletti and Bryant Garth, *Access to Justice* (Vol ១, Sijthoff and Noordhoff ១៩៧៨), pp. ៦–១១.

វាយតម្លៃ ដោយឯករាជ្យ និងមានការចូលរួមពីស្ថាប័នពាក់ព័ន្ធ គួរត្រូវបានចាត់ទុកជាផ្នែកមួយនៃយុទ្ធសាស្ត្រអប់រំ និងបណ្តុះបណ្តាលច្បាប់ជាតិនៅកម្ពុជា។

ការអប់រំ និងបណ្តុះបណ្តាលច្បាប់នៅកម្ពុជា ត្រូវបានអនុវត្តទាំងក្នុង និងក្រៅប្រព័ន្ធអប់រំផ្លូវការ ប៉ុន្តែនៅតែប្រឈមនឹងបញ្ហាស្តង់ដា គុណភាព និងធនធានមនុស្ស។ ដើម្បីពង្រឹងប្រសិទ្ធភាពនៃវប្បធម៌គោរពច្បាប់ គួរតែមានការវិនិយោគយ៉ាងយូរអង្វែងលើការអប់រំច្បាប់ បង្កើតយន្តការបណ្តុះបណ្តាលបន្ត និងប្រើប្រាស់បច្ចេកវិទ្យាផ្សព្វផ្សាយជាយុទ្ធសាស្ត្រសំខាន់។

**ឧបសម្ព័ន្ធ ៧.** **សេចក្តីព្រាងសេចក្តីសម្រេចបង្កើតក្រុមការងាររៀបចំក្រមខណ្ឌប្រព័ន្ធច្បាប់កម្ពុជា**

## សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងាររៀបចំក្រមខណ្ឌទស្សនាទានស្តីពីប្រព័ន្ធច្បាប់កម្ពុជា

## ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/១៥០ ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់
- បានឃើញអនុក្រឹត្យលេខ១៨៣ អនក្រ.បក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ១០៤ អនក្រ.បក ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់
- យោងតាមសំណូមពរចាំបាច់នៃការងារ

## **សម្រេច**

**ប្រការ១.-**

ត្រូវបានបង្កើត ក្រុមការងារស្នូលរៀបចំសេចក្តីព្រាងក្របខ័ណ្ឌប្រព័ន្ធច្បាប់កម្ពុជា មួយ ដើម្បីដឹកនាំ សម្របសម្រួល តម្រង់ទិស និងពិនិត្យការរៀបចំសេចក្តីព្រាងក្របខ័ណ្ឌប្រព័ន្ធច្បាប់កម្ពុជា ស្របតាមក្របខ័ណ្ឌទស្សនាទានដែលត្រូវបានអនុម័តដោយគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងស្របតាមយន្តការ និងនីតិវិធីពាក់ព័ន្ធរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីធានាថាការរៀបចំឯកសារនេះមានភាពច្បាស់លាស់ សង្គតិភាព គុណភាពបច្ចេកទេស ប្រសិទ្ធភាព និងអនុលោមភាពជាមួយគោលដៅនៃការកែទម្រង់ច្បាប់ និងការអភិវឌ្ឍជាតិ ដោយមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម **វង្សី វិស្សុត** | ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២. | ឯកឧត្តម/លោកជំទាវ | [...] | អនុប្រធាន |
| ៣. | ឯកឧត្តម/លោកជំទាវ | [...] | អនុប្រធាន |
| ៤. | ឯកឧត្តម **លី ច័ន្ទតុលា** | អនុប្រធាន និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន គ.ក.ច. | អនុប្រធានប្រចាំការ |
| ៥. | ឯកឧត្តម/លោកជំទាវ | [...] | អនុប្រធាន |
| ៦. | ឯកឧត្តម/លោកជំទាវ | [...] | សមាជិក |
| ៧. | ឯកឧត្តម/លោកជំទាវ | [...] | សមាជិក |
| ៨. | ឯកឧត្តម/លោកជំទាវ | [...] | សមាជិក |
| ៩. | ឯកឧត្តម/លោកជំទាវ | [...] | សមាជិក |
| ១០. | ឯកឧត្តម/លោកជំទាវ | [...] | សមាជិក |
| ១១. | ឯកឧត្តម/លោកជំទាវ | [...] | សមាជិក |
| ១២. | ឯកឧត្តម/លោកជំទាវ | [...] | សមាជិក |

**ប្រការ២.-**

ក្រុមការងារស្នូលរៀបចំសេចក្តីព្រាងក្របខ័ណ្ឌប្រព័ន្ធច្បាប់កម្ពុជាមានភារៈកិច្ចដូចខាងក្រោម៖

- ដឹកនាំ សម្របសម្រួល និងតម្រង់ទិសជារួមលើការរៀបចំសេចក្តីព្រាងក្របខ័ណ្ឌប្រព័ន្ធច្បាប់កម្ពុជា ស្របតាមក្របខ័ណ្ឌទស្សនាទានដែលត្រូវបានអនុម័តដោយគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់។
- ផ្តល់ទិសដៅគោលនយោបាយ និងយុទ្ធសាស្ត្រ ពាក់ព័ន្ធនឹងការរៀបចំក្របខ័ណ្ឌប្រព័ន្ធច្បាប់កម្ពុជា។
- ពិនិត្យ និងណែនាំលើរចនាសម្ព័ន្ធ វិសាលភាព ខ្លឹមសារ និងវិធីសាស្ត្រនៃការរៀបចំសេចក្តីព្រាងក្របខ័ណ្ឌប្រព័ន្ធច្បាប់កម្ពុជា។
- ពិនិត្យ ផ្តល់យោបល់ និងសម្រេចលើសេចក្តីព្រាង និងសមិទ្ធផលការងារតាក់តែងតាមដំណាក់កាលនីមួយៗ។
- ដោះស្រាយបញ្ហាគោលនយោបាយ ទស្សនាទាន និងបញ្ហាគន្លឹះផ្សេងៗ ដែលកើតឡើងក្នុងដំណើរការតាក់តែង។
- ដឹកនាំការពិគ្រោះយោបល់ជាមួយវិស័យពាក់ព័ន្ធ និងការពិគ្រោះយោបល់អន្តរក្រសួង-ស្ថាប័ន តាមការចាំបាច់។
- ពិនិត្យ និងអនុម័តលើសេចក្តីព្រាង មុនដាក់ឆ្លងតាមយន្តការរបស់ទីស្តីការគណៈរដ្ឋមន្ត្រី និងមុនដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យ និងសម្រេច។
- តាមដាន និងជំរុញការអនុវត្តផែនការការងារនៃការរៀបចំក្របខ័ណ្ឌប្រព័ន្ធច្បាប់កម្ពុជា ឱ្យសម្រេចតាមក្របខ័ណ្ឌពេលវេលាដែលបានកំណត់។

**ប្រការ៣.-**

អនុប្រធានប្រចាំការ អនុប្រធាន និងសមាជិកក្រុមការងារ ត្រូវចូលរួមកិច្ចប្រជុំ តាមការអញ្ជើញរបស់ប្រធានក្រុមការងារ។ ក្នុងករណីប្រធានក្រុមការងារអវត្តមាន ឬមានធុរៈ អនុប្រធានប្រចាំការ ឬអនុប្រធាន អាចដឹកនាំកិច្ចប្រជុំជំនួសតាមការប្រគល់ភារកិច្ចរបស់ប្រធានក្រុមការងារ។

**ប្រការ៤.-**

ត្រូវបានបង្កើត ក្រុមការងារបច្ចេកទេសរៀបចំសេចក្តីព្រាងក្របខ័ណ្ឌប្រព័ន្ធច្បាប់កម្ពុជាដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម **លី ច័ន្ទតុលា** | អនុប្រធាន និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ | ប្រធាន |
| ២. | ឯកឧត្តម/លោកជំទាវ | [...] | អនុប្រធាន |

| | | |
|---|---|---|
| ៣. ឯកឧត្តម/លោកជំទាវ | [...] | អនុប្រធាន |
| ៤. ឯកឧត្តម/លោកជំទាវ | [...] | សមាជិក |
| ៥. ឯកឧត្តម/លោកជំទាវ | [...] | សមាជិក |
| ៦. ឯកឧត្តម/លោកជំទាវ | [...] | សមាជិក |
| ៧. ឯកឧត្តម/លោកជំទាវ | [...] | សមាជិក |
| ៨. ឯកឧត្តម/លោកជំទាវ | [...] | សមាជិក |
| ៩. ឯកឧត្តម/លោកជំទាវ | [...] | សមាជិក |
| ១០. ឯកឧត្តម/លោកជំទាវ | [...] | សមាជិក |

**ប្រការ៥._**

ក្រុមការងារបច្ចេកទេសរៀបចំសេចក្តីព្រាងក្របខ័ណ្ឌប្រព័ន្ធច្បាប់កម្ពុជាមានភារៈកិច្ចដូចខាងក្រោម៖

- ស្រាវជ្រាវ និងវិភាគច្បាប់ គោលនយោបាយ និងឯកសារពាក់ព័ន្ធ ទាំងក្នុង និងក្រៅប្រទេស ដើម្បីគាំទ្រការរៀបចំសេចក្តីព្រាងក្របខ័ណ្ឌប្រព័ន្ធច្បាប់កម្ពុជា។
- តាក់តែង កែសម្រួល និងចងក្រងអត្ថបទសេចក្តីព្រាងក្របខ័ណ្ឌប្រព័ន្ធច្បាប់កម្ពុជា ព្រមទាំងឯកសារគាំទ្រផ្សេងៗ តាមដំណាក់កាលនីមួយៗ។
- ប្រមូល ចងក្រង និងវិភាគឯកសារ ទិន្នន័យ និងធាតុចូលពីក្រសួង ស្ថាប័ន វិស័យពាក់ព័ន្ធ អ្នកជំនាញ និងភាគីពាក់ព័ន្ធនានា។
- រៀបចំកិច្ចប្រជុំ ការពិគ្រោះយោបល់បច្ចេកទេស និងការពិគ្រោះយោបល់អន្តរក្រសួង-ស្ថាប័ន ពាក់ព័ន្ធនឹងការរៀបចំសេចក្តីព្រាងក្របខ័ណ្ឌប្រព័ន្ធច្បាប់កម្ពុជា។
- រៀបចំឯកសារ និងសម្របសម្រួលការដាក់ឆ្លងសេចក្តីព្រាងតាមយន្តការរបស់ទីស្តីការគណៈរដ្ឋមន្ត្រី រួមទាំងការត្រួតពិនិត្យបច្ចេកទេស និងការពិគ្រោះយោបល់ពាក់ព័ន្ធ។
- រៀបចំរបាយការណ៍ សេចក្តីសង្ខេប និងឯកសារគាំទ្រដែលចាំបាច់ សម្រាប់ដាក់ជូនក្រុមការងារស្នូល ដើម្បីពិនិត្យ ផ្តល់យោបល់ និងកំណត់ទិសដៅក្នុងដំណាក់កាលនៃការតាក់តែងនីមួយៗ។
- បំពេញការងារផ្នែករដ្ឋបាល និងលេខាធិការ ពាក់ព័ន្ធនឹងការរៀបចំកិច្ចប្រជុំ ការសម្របសម្រួល និងការគ្រប់គ្រងឯកសារ។
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់ក្រុមការងារស្នូល។

**ប្រការ៦._**

អនុប្រធាន និងសមាជិក សមាជិកានៃក្រុមការងារបច្ចេកទេសនេះ ត្រូវចូលរួមកិច្ចប្រជុំ តាមការអញ្ជើញ របស់ប្រធានក្រុមការងារបច្ចេកទេស។ ក្នុងករណីប្រធានក្រុមការងារបច្ចេកទេសអវត្តមាន ឬមានធុរៈ អនុប្រធាន អាចដឹកនាំកិច្ចប្រជុំជំនួសតាមការផ្ទេរសិទ្ធិរបស់ប្រធានក្រុមការងារបច្ចេកទេស។

**ប្រការ៥._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥._**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន និងប្រធានគ្រប់អង្គភាពក្រោមចំណុះទីស្តីការគណៈរដ្ឋមន្ត្រី និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ខែ ឆ្នាំម្សាញ់ ព.ស. ២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ខែ ឆ្នាំ២០២៦

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**និងជាប្រធានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់**

**កន្លែងទទួល៖**

- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋាន គ.ក.ច.
- ដូចប្រការ៨
- ឯកសារ កាលប្បវត្តិ

**វង្សី វិស្សុត**